ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# អក្សរសាស្ត្រខ្មែរ

១១



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# អក្សរសាស្ត្រខ្មែរ

## ថ្នាក់ទី ១១

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

**គណៈកម្មការនិពន្ធ** លោក យិន ធី លោកស្រី ប៊ី គីមសែន
លោក យ៉ង់ កំស៊ាន លោក ព្រៃ សំបូរ
លោក គួយ សូគាន លោកស្រី ម៉ៅ តាន់ណារី

**អ្នកវាយអត្ថបទ** លោក សេង តុងបុត្តា

**វិចិត្រករ** លោក ឃុន សុវណ្ណរិទ្ធី

**អ្នករៀបរៀង** លោកជំទាវ ទន់ សាអ៊ីម

**អ្នករចនាទំព័រ** លោក គង់ ចិត្រា

**គណៈកម្មការពិនិត្យ** លោកស្រី អៀ ចាន់នារី
លោកបណ្ឌិត នៅ ស៊ុន

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ១៣៨៩ អយក.ប្រក. ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១០ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ២០១៦

ISBN 9-789-995-000-998

# អារម្ភកថា

សៀវភៅអក្សរសាស្ត្រខ្មែរថ្នាក់ទី ១១ នេះ បាននិពន្ធឡើងស្របតាមកម្មវិធីសិក្សាថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា។ សៀវភៅនេះពង្រឹងនិងពង្រីកបន្ថែមទៀតទៅលើសមត្ថភាពទាំងបួនគឺ សមត្ថភាពស្តាប់ និយាយ អាន និងសរសេរឱ្យកាន់តែស៊ីជម្រៅនិងមានលក្ខណៈឯកទេស ដើម្បីផ្សារភ្ជាប់ទៅនឹងការសិក្សានៅឧត្តមសិក្សាផងនិងត្រៀមអាជីពផង ។

សៀវភៅនេះបង្ហាញអំពីប្រធានបទសំខាន់ៗស្តីពី វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងការសិក្សាអក្សរសាស្ត្រ- អក្សរសិល្ប៍ជាគោលក្នុងការសិក្សាបំណិនច្រើនបែបដូចជាការសង្ខេប សំយោគ តែងសេចក្តី វិភាគអត្ថបទជាដើម ដែលមានកម្រិតខ្ពស់ហើយកាន់តែស៊ីជម្រៅថែមទៀត ។ សៀវភៅនេះនឹងជួយបង្កើនចំណេះដឹងអ្នកសិក្សាឱ្យបានទូលំទូលាយ តាមរយៈការសិក្សាអត្ថបទអក្សរសិល្ប៍ប្រជាប្រិយ បុរាណ ទំនើប អត្ថបទអត្ថាធិប្បាយ ពាក្យរាយ ពាក្យកាព្យ ល្ខោន ចម្រៀងរបាំ វេយ្យាករណ៍ និងសិល្ប៍វិធីតែងនិពន្ធសម្បូរបែបរបស់អ្នកនិពន្ធ កវីជាតិល្បីៗ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅអក្សរសាស្ត្រខ្មែរថ្នាក់ទី ១១នេះនឹងក្លាយជាវត្ថុដ៏មានតម្លៃសម្រាប់ប្អូនៗនិងជួយបង្កើនថាមពលសិក្សា ហើយនាំប្អូនៗឱ្យស្គាល់ច្បាស់នូវមរតកជាតិខ្មែរដ៏រុងរឿង ថ្លៃថ្នូរ តាំងពីបុរាណរហូតមកដល់បច្ចុប្បន្ន ។

សូមឱ្យប្អូនៗទទួលបានជោគជ័យជានិច្ចក្នុងការសិក្សា ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ

ទំព័រ


១. ផ្នត់គំនិត ............................................................ ១

២. ទំនៀមទម្លាប់ ............................................................ ២៥

៣. សេចក្តីក្លាហាន ............................................................ ៤៧

៤. ការលះបង់ ............................................................ ៦៩

៥. អតីតកាល ............................................................ ៩៧

៦. ការគោរពបូជា ............................................................ ១២៩

៧. អក្សរសាស្ត្រនិងអក្សរសិល្ប៍ខ្មែរ ............................................................ ១៥៣

៨. តថភាព ............................................................ ១៧៥

៩. អក្សរសិល្ប៍បរទេស ............................................................ ១៩៧

១០. សុទិដ្ឋិនិយម ............................................................ ២២៥

មេរៀនទី ១

# ផ្នត់គំនិត



ជាតិសាសន៍នីមួយៗតែងតែមានអត្តសញ្ញាណជាតិរបស់ខ្លួន ។ រីឯជនជាតិខ្មែរក៏ជាជនជាតិមួយដែលមានផ្នត់គំនិត ជំនឿ ទំនៀមទម្លាប់ ប្រពៃណី ហើយបានចារនិងចងក្រងទុកជាសម្បត្តិអរិយធម៌ដ៏ចំណាស់របស់ជាតិខ្លួនដែរ ។ ផ្នត់គំនិត គឺជាគំនិតដែលគេតែងជឿជាក់ហើយប្រកាន់និងអនុវត្តក្នុងទំនៀមទម្លាប់ ប្រពៃណី ជំនឿ ក្នុងជីវភាពរស់នៅ ឬតាមទម្លាប់ពូជពង្សជារៀងរហូតមក ។

ក្នុងមេរៀននេះ អ្នកនឹងបានស្គាល់ពីផ្នត់គំនិតខ្មែរមួយចំនួននិងបានសិក្សាបន្ថែមទៀតពីបំណែងចែកអក្សរសិល្ប៍និងលក្ខណតថៈរបស់រឿង ចលនាអក្សរសិល្ប៍ ប្រធានរឿង កាលអាកាស មូលបញ្ហារឿង ចំណោទបញ្ហា គំនិតសំខាន់បង្កប់ ការបញ្ចេញមតិ និងសំណេរសំយោគ ព្រមទាំងវិធីបង្កើតពាក្យដោយកម្លាយផ្នត់ដើម ។



# ការវិវត្តនៃអក្សរសិល្ប៍ខ្មែរ



## ក. សិក្សាពាក្យគន្លឹះ

- មហិទ្ធិឫទ្ធិ (ន) : ឫទ្ធិធំ ឫទ្ធិខ្លាំងក្រៃលែង ឬអំណាចសម្បើម ។
- អាណាព្យាបាល (ន) : អ្នកគ្រប់គ្រង (អាណាខេត្ត ឬការគ្រប់គ្រងអាណាខេត្ត) ។
- សំស្ក្រឹត (ន) : ឈ្មោះភាសាដើមឥណ្ឌាសម័យបុរាណដែលជាភាសាវេទមានន័យថា ជាភាសា ដែលសម្រិតសម្រាំងបានល្អ ជាភាសារបស់ទេវៈ ។
- សិលាចារឹក (ន) : អក្សរដែលចារលើផ្ទាំងថ្ម ។
- ប្រតិបត្តិ (កិ) : ប្រព្រឹត្ត កាន់ តាម ។
- ឧទ្ទិស (កិ) : សំដៅទៅរក សំដៅចំពោះ ។
- បូជនីយដ្ឋាន (ន) : ទីដែលគួរគោរព បូជា ។
- រាមាយណៈ (ន) : ឈ្មោះមហាកាព្យដែលថ្លែងពីរឿងរ៉ាវរបស់ព្រះរាម ដែលតែងដោយកវីឥណ្ឌាឈ្មោះ វាល្មិកិ ។
- ក្រដាសស្នាច់ (ន) : ក្រដាសបិទភ្ជាប់គ្នាច្រើនស្រទាប់ដោយវត្ថុស្អិត ។
- ហីនយាន (ន) : យានតូច ជាឈ្មោះនិកាយមួយនៃពុទ្ធសាសនា ។

## ខ. អភិវឌ្ឍន៍បំណិន

ដើម្បីទទួលលទ្ធផលល្អក្នុងការអាន អ្នកគប្បីអានដោយយកចិត្តទុកដាក់ ហើយត្រៀមឆ្លើយសំណួរដែលទាក់ទងនឹងបំណែងចែកអក្សរសិល្ប៍ទៅតាមសម័យកាលនិងខ្លឹមសារអត្ថបទ ។

## គ. អត្ថបទ

[...]ចំពោះអក្សរសិល្ប៍ខ្មែរ គេបានសង្កេតឃើញថា មានការវិវត្តយ៉ាងខ្លាំងទៅតាមសម័យកាលធំៗនៃប្រវត្តិសាស្ត្រប្រទេសខ្មែរ ។ នៅសម័យអង្គរគេបានដឹងច្បាស់ថា មហិទ្ធិឫទ្ធិខ្មែរបានឡើងដល់កម្រិតកំពូល រីឯអក្សរសិល្ប៍ក៏រីកចម្រើនខ្លាំងក្លាណាស់ដែរ ។ ប៉ុន្តែអក្សរសិល្ប៍ខ្មែរចុះថយវិញនៅពេល ដែលស្រុកខ្មែរត្រូវឈ្លានពានពីសំណាក់បរទេសនិងសង្គ្រាមក្នុងស្រុក ។ លុះមកដល់សតវត្សទី ១៨ និង ១៩ ស្នាដៃអក្សរសិល្ប៍ក៏ស្ទុះងើបចម្រើនឡើងបន្តិចវិញ ប៉ុន្តែត្រូវថយឥទ្ធិពលម្តងទៀតនៅពេលដែលប្រទេសខ្មែរធ្លាក់ខ្លួននៅក្រោមអាណាព្យាបាលបារាំង ។ នាសម័យខ្មែរបានឯករាជ្យទើបអក្សរសិល្ប៍ខ្មែរមានការរីកចម្រើនជាថ្មី ។

### អក្សរសិល្ប៍សម័យបុរាណ

**មុនសម័យអង្គរ (ស.វ.ទី ១ដល់ទី៨)** ដោយមានការផ្លាស់ប្តូររាជធានីញឹកញាប់ដូចជា ប្តូរពីវ្យាធបុរៈទៅឦសានបុរៈ រួចទៅយធបុរៈជាដើម ទើបគេប្រទះឃើញមានសិលាចារឹកនៅពាសពេញអាណាចក្រ ។ នៅសម័យមុនអង្គរ គេនិយមប្រើភាសាសំស្ក្រឹតដែលគេចាត់ទុកជាភាសាជាន់ខ្ពស់ (ភាសារបស់អ្នកប្រាជ្ញ) ។ ដូចនេះហើយបានជាមានសិលាចារឹកខ្លះសរសេរជាភាសាសំស្ក្រឹត ហើយតែងជាពាក្យកាព្យ ។ សិលាចារឹកជាភាសាសំស្ក្រឹតដែលមានចំណាស់ជាងគេ គឺសិលាចារឹកវ៉ូកាញ់ (ប្រមាណគ្រិស្តសតវត្សទី ២-៣) ។ អត្ថបទនៃសិលាចារឹកនេះ និយាយអំពីចិត្តសន្តោសរបស់ព្រះរាជាមួយអង្គ ដែលគិតដល់សុភមង្គលរបស់ប្រជារាស្ត្រ ដោយព្រះអង្គធ្វើជាបទបញ្ញាទុកឱ្យមហាក្សត្រតៗមកប្រតិបត្តិតាម ។ សិលាចារឹកខ្លះទៀតដែលសរសេរជាភាសាខ្មែរបុរាណ ហើយជាពាក្យរាយ ចាប់មានតាំងពីស.វទី៧ ។ ឯសិលាចារឹកដែលចាស់ជាងគេ គឺសិលាចារឹកអង្គរបុរី (គ.ស.៦១១) ។ សិលាចារឹកនៅសម័យមុនអង្គរ ច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រហើយនិងសាសនា ។

**សម័យអង្គរ (៨០២-១៤៣១)** អក្សរសិល្ប៍សម័យអង្គរ ពិតមែនតែបានទទួលបន្តបន្ទាប់គ្នានូវឥទ្ធិពលនៃលទ្ធិព្រាហ្មណ៍សាសនានិងពុទ្ធសាសនា ប៉ុន្តែបានរក្សាជាលក្ខណៈខ្មែរ ។ ដោយយកតួអក្សរខ្មែរពិតប្រាកដជាឧបករណ៍ អក្សរសិល្ប៍ខ្មែរសម័យនោះបានផ្តិតជាប់ទៅនឹងសម្ភារៈពីរបែប ទីមួយគឺអក្សរសិល្ប៍ដែលសរសេរដោយដីសបំពង់នៅលើស្បែកសត្វស្ងួត លាបពណ៌ខ្មៅ ។ អក្សរសិល្ប៍ដែល

សរសេរនៅលើសម្ភារៈបែបនេះមិនស្ថិតស្ថេរទេ ព្រោះពុំអាចធន់នឹងកម្លាំងធម្មជាតិ មានភ្លៀង ខ្យល់ និងការបំផ្លិចបំផ្លាញរបស់សត្វល្អិតបានឡើយ ។ មួយទៀត គឺអក្សរសិល្ប៍ដែលចារ នៅលើផ្ទាំងថ្ម ជាបន្ទះ ឬជាបង្គោល ឬជាសសរ ។

ក្នុងការសរសេរអត្ថបទអក្សរសិល្ប៍ អ្នកនិពន្ធប្រើភាសាពីរ គឺភាសាសំស្ក្រឹតនិងភាសាខ្មែរបុរាណ ។ អត្ថបទជាភាសាសំស្ក្រឹត ច្រើនជាពាក្យកាព្យ ដែលនិយាយអំពីកំណត់ហេតុក្នុងដំណើរប្រព្រឹត្តទៅនៃប្រវត្តិរបស់ព្រះរាជាឬមន្ត្រី ឬជាការអួតសរសើរចំពោះតួអង្គណាមួយក្នុងប្រវត្តិសាស្ត្រ ។ ចំណែកអត្ថបទជាភាសាខ្មែរវិញច្រើនជាពាក្យឧទ្ទិស ឬជាបញ្ជីរាប់របស់របរ រាប់វត្ថុដែលគេបូជាសម្រាប់បូជនីយដ្ឋានទាំងឡាយ ។

សេចក្ដីរុងរឿងនៃជនជាតិខ្មែរនាសម័យអង្គរ លទ្ធិព្រាហ្មណ៍និងព្រះពុទ្ធសាសនាមហាយាន បានផ្សាយឥទ្ធិពលទៅលើជីវភាពនិងចិត្តគំនិតខ្មែរទូទៅ ។ ជីវភាពសប្បាយរីករាយដោយសារបុណ្យានុភាពនេះឯង ជាប្រភពគំនិតថ្មីៗល្អៗសម្រាប់អ្នកនិពន្ធក្នុងសម័យនោះយកទៅប្រើតុបតែងស្នាដៃរបស់ខ្លួន ។

នៅសម័យអង្គរតាមរយៈអត្ថបទសិលាចារឹកគេប្រទះឃើញឈ្មោះអ្នកនិពន្ធ ៖

- បណ្ឌិតសោម : សិលាចារឹកប្រាសាទកណ្ដាលដើមរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័ន ។
- បណ្ឌិតយតិអមរភាវៈ : សិលាចារឹកប្រាសាទភ្នំប៉ាយង់រជ្ជកាលព្រះបាទសោយវរ្ម័ន ។ នៅមានបណ្ឌិតជាច្រើនទៀតដូចជា បណ្ឌិតទិវាករ បណ្ឌិតកវិន្ទ្រៈ បណ្ឌិតភូបន្ទ្រៈ និងព្រះនាងឥន្ទ្រទេវី ។

## អក្សរសិល្ប៍សម័យកណ្ដាល

**សម័យក្រោយអង្គរ(១៤៣១-១៨៦២)** កាលពីសម័យមុនៗ អក្សរសិល្ប៍ខ្មែរមានការរីកចម្រើនស្រាប់តែមកដល់ពេលនេះអក្សរសិល្ប៍ខ្មែរប្រែជាមានសភាពអាប់អួរ ដោយសារមានបច្ចាមិត្តមករាតត្បាត បណ្ដាលឱ្យមានចម្បាំង ធ្វើឱ្យមានភាពដុនដាបខាងសេដ្ឋកិច្ច មានការអត់ឃ្លាន មានជំងឺឆ្លង ហើយមានការទាស់ទែងគ្នាក្នុងស្រុកយ៉ាងច្របូកច្របល់ ។ ស្ថានភាពបែបនេះនាំឱ្យប្រទេសនិងប្រជារាស្ត្រខ្មែរទន់ខ្សោយ ។

លុះមកដល់ស.វទី ១៧ ស្នាដៃអក្សរសិល្ប៍ក៏ចាប់ងើបឡើងវិញ ។ សម្ភារៈដែលគេប្រើសម្រាប់កត់ត្រាអក្សរសិល្ប៍នៅសម័យនោះ គឺក្រាំង(សន្លឹកក្រដាសស្មាច់ក្រាស់បត់ជាផ្នត់ៗ) និងស្លឹករឹត (ហៅថាសាស្ត្រា) ។ ស្នាដៃអក្សរសិល្ប៍ពេលនោះ បានជ្រួតជ្រាបដល់មហាជនទូទៅហើយ ប៉ុន្តែជាអកុសលគេរងំណែលក្រាំងនិងសាស្ត្រាស្លឹករឹតចេះតែវិនាសទៅ ដោយសារតែសង្គ្រាម និងការឈ្លានពានរបស់ខ្មាំងបរទេសដែលបានប្រមូលយកទៅ ឬដុតបំផ្លាញចោល ។

ចំណែកខាងជំនឿសាសនាវិញ ពុទ្ធសាសនាហីនយាន(ដែលនាំមកពីលង្កា) មានការរីកចម្រើនលូតលាស់យ៉ាងខ្លាំង ហើយមានជោគជ័យលើសាសនាព្រាហ្មណ៍និងពុទ្ធសាសនាមហាយាន ។ ឯភាសាបាលីដែលប្រើក្នុងពុទ្ធសាសនាហីនយាននេះ ក៏បានចូលមកជំនួសភាសាសំស្ក្រឹត ទុកជាភាសាអ្នកប្រាជ្ញវិញម្តង ។ រីឯទស្សនៈព្រះពុទ្ធសាសនា ក៏កាន់តែជ្រួតជ្រាបឡើងយ៉ាងឆាប់រហ័សដែរ នៅក្នុងសន្តានចិត្តរបស់ប្រជារាស្ត្រនិងអក្សរសិល្ប៍ខ្មែរ ។ នៅក្នុងពេលនេះដែរ គេសង្កេតឃើញមានស្នាដៃអក្សរសិល្ប៍សាមញ្ញជាច្រើនបានកើតឡើងដូចជា រឿងព្រេង រឿងនិទានខ្លីៗ ដែលនាំឱ្យអ្នកស្រុកស្តាប់ និងយល់បានយ៉ាងស្រួល ។

អ្នកនិពន្ធដ៏ល្បីឈ្មោះក្នុងគ្រានេះមានជាអាទិ៍ អ្នកប៉ាង តែងកំណាព្យ "**ល្បើកអង្គរ**" នៅគ.ស. ១៦០៩ ដែលនិយាយអំពីភាពអស្ចារ្យក្នុងការកសាងប្រាសាទអង្គរវត្ត ។ ព្រះរាជសម្ភារ តែងកំណាព្យ "**ច្បាប់ព្រះរាជសម្ភារ**" នៅគ.ស. ១៦២២ ជាច្បាប់ទូន្មាន "**ហោមន្តមាស**" នៅគ.ស. ១៦២៩ "**ហិនលក្ខណ៍សល**" នៅគ.ស. ១៦៣០ និង "**កាព្យនិរាស**" នៅគ.ស. ១៦៦០ ជាកំណាព្យដែលព្រះអង្គបាននិពន្ធដោយព្រះទ័យសោកសៅរលឹកដល់ព្រះនាងបុប្ផាវត្តី ។ ចំណែកជ័យនន្ទ តែងកំណាព្យជាភាសាខ្មែរមុនគេបង្អស់លើសិលាចារឹកនៅគ.ស. ១៧០១ ដែលនិយាយអំពីប្រវត្តិ ទឹកចិត្តនិងសេចក្តីប្រាថ្នាទៅអនាគតរបស់ខ្លួន ។

[...] បន្ទាប់មកស្នាដៃអក្សរសិល្ប៍មួយចំនួន ពិសេសស្នាដៃជាប្រលោមលោកពាក្យកាព្យក៏ចាប់មានកំណើតឡើង ។ គេចាររឿងរ៉ាវទាំងនោះលើស្លឹករឹត ហើយដែលគេចម្លងតៗគ្នាចែកគ្នាអានបានសុសសាយពេញទាំងស្រុកភូមិ ។

ឯអ្នកនិពន្ធដែលគេបានស្គាល់ច្បាស់លាស់នោះ មានឧកញ៉ាកោសាធិបតីកៅ សរសេររឿងក្រុងសុភមិត្រ គ.ស. ១៧៩៨ ។ ឧកញ៉ាព្រះឃ្លាំងនង សរសេរច្បាប់សុភាសិត គ.ស. ១៧៩០ លោកនេយ្យជាតក គ.ស. ១៧៩៤ បុញ្ញសារសិរិសា គ.ស. ១៧៩៧ ភោគកុលកុមារ គ.ស. ១៨០៤ ។ ឧកញ៉ាសន្ធរវោហារម៉ុក សរសេររឿងទេវន្ទ ល្បើកចចក រឿងទុំទាវ (មុនទុំទាវរបស់ភិក្ខុសោម) ។ វិសេសដួងសរសេរល្បើកអក ល្បើកជុចនិងត្រី ល្បើកជូជក ។ ចំណែកព្រះអង្គឌួងបានរៀនសូត្រចេះដឹងច្រើននិងទ្រង់បានស្គាល់តម្លៃពិតប្រាកដនៃអក្សរសាស្ត្រជាតិ ព្រមទាំងបានជួយបណ្តុះបណ្តាលនិងឧបត្ថម្ភផ្នែកអក្សរសាស្ត្រឱ្យបានរីកចម្រើនឡើង ដូចជាព្រះអង្គទ្រង់បង្កើតឱ្យមានទីប្រជុំអ្នកប្រាជ្ញហៅថា "**រាជបណ្ឌិត្យ**" ដោយមានការរៀបចំឱ្យមានការប្រឡងប្រជែងស្នាដៃដែលតែងថ្មីៗជាដើម ។ ស្នាព្រះហស្តជាពាក្យឃ្លោងរបស់ព្រះអង្គមាន ចម្បាថោង គ.ស. ១៨១០ រឿងកាកី គ.ស. ១៨១៥ ច្បាប់ស្រី គ.ស. ១៨៣៧ និងរឿងព្រះមហាវេស្សន្តរ (ជាពាក្យរាយ) ។

# អក្សរសិល្ប៍សម័យទំនើប

**- សម័យអាណាព្យាបាល (១៨៦៣-១៩៥៣)** នៅក្រោមអាណាព្យាបាលបារាំង អក្សរសិល្ប៍ខ្មែរចុះអន់ថយអាប់រស្មីនិងពុំសូវមានការនិយមប្រើអក្សរខ្មែរទេ ។ រីឯក្បួនខ្នាតអក្សរខ្មែរឃើញមានតែនៅក្នុងវត្តអារាម មានព្រះសង្ឃជួយថែរក្សាឱ្យគង់វង្ស ។ ម្យ៉ាងទៀតវិជ្ជាជីវៈជាអ្នកនិពន្ធ ក៏ពុំដែលបានទទួលការលើកទឹកចិត្ត ឬការទំនុកបម្រុងពីសំណាក់អាជ្ញាធរបារាំងដែរ ។ គេបានស្គាល់អ្នកនិពន្ធនិងស្នាដៃនៅសម័យនោះដូចជា ឧកញ៉ាសុត្តន្តប្រីជាឥន្ទ សរសេរពាក្យកាព្យនិរាសអង្គរគ.ស. ១៩២៦ រឿងគតិលោកគ.ស. ១៩២០ រឿងអំបែងបែកជាដើម ។ ឧកញ៉ានូកនសរសេររឿងពិម្ពានិព្វាន គ.ស. ១៩២០ រឿងទាវឯក គ.ស. ១៩៤២ រឿងអ៊ីណាវ ។ល ។ ចំណែកអ្នកស្រីសិទ្ធិ សរសេររឿងពិម្ពាពិលាប គ.ស. ១៩២០ ហើយលោកញ៉ុកថែមសរសេររឿងកុលាបប៉ៃលិន គ.ស. ១៩៣៦ រឿងបិសាចស្នេហា គ.ស. ១៩៤០ ។ មិនតែប៉ុណ្ណោះ នៅមានលោកគិមហាក់សរសេរកំណាព្យសេកសោមបណ្ឌិត គ.ស. ១៩៣៣ រឿងទឹកទន្លេសាប គ.ស. ១៩៤១ ព្រមទាំងលោករីមគិន សរសេររឿងសូផាត គ.ស. ១៩៣៨ ។ល ។ ក្នុងចំណោមស្នាដៃទាំងនេះ មានស្នាដៃខ្លះគាត់តែងឡើងទៅតាមទម្រង់បែបប្រលោមលោកពួកបស្ចិមប្រទេស ដោយអ្នកនិពន្ធបានទទួលឥទ្ធិពលវប្បធម៌បារាំងដូចជា រឿងទឹកទន្លេសាប កុលាបប៉ៃលិន សូផាត គតិលោក ជាដើម ។

**- សម័យបច្ចុប្បន្ន (ចាប់ពី គ.ស. ១៩៥៣ រហូតមក)** ពេលបានឯករាជ្យភ្លាម អ្នកនិពន្ធបានធូរស្រាលក្នុងចិត្តគំនិតដោយបានទទួលនូវសេរីភាពក្នុងការកសាងអក្សរសិល្ប៍ថ្មីៗរបស់ខ្លួន ។ អក្សរសិល្ប៍ខ្មែរក៏បានឈានជើងទៅកាន់ការលូតលាស់ថ្មីមួយដែលមានលក្ខណៈនិងនិន្នាការជាតិនិយម សង្គមនិយម ប្រជាធិបតេយ្យ និងប្រជាប្រិយ ។ គ្រប់ប្រភេទនៃអក្សរសិល្ប៍ក៏បានកើតឡើង គឺប្រលោមលោកកំណាព្យ រឿងល្ខោន សៀវភៅបច្ចេកទេស សៀវភៅសិក្សាអប់រំ សៀវភៅទាក់ទងនឹងគំនិតទស្សនៈវិជ្ជា ។ល ។

*(ដកស្រង់និងកែសម្រួលចេញពីអរិយធម៌ខ្មែរ អ្នកស្រី ត្រឹង ងា គ.ស.១៩៧៥ ព.ស. ២៥១៨)*

## សំណួរ

១. តើអត្ថបទនេះបានបង្ហាញពីអ្វី ?

២. តាមរយៈអត្ថបទនេះ គេអាចចែកអក្សរសិល្ប៍ខ្មែរជាប៉ុន្មានសម័យកាលធំៗ ?

៣. តើអក្សរសិល្ប៍សម័យកណ្ដាលមានលក្ខណៈដូចម្ដេចខ្លះ ? តើមានអ្នកនិពន្ធនិងស្នាដៃអ្វីខ្លះ ?

៤. បើផ្អែកតាមចំណងជើងនៃស្នាដៃក្នុងអត្ថបទខាងលើនេះ តើខ្លឹមសារណាមួយដែលអ្នកគិតថាបានផ្សារភ្ជាប់ទៅនឹងផ្នត់គំនិតខ្មែរក្នុងការគោរពពុទ្ធសាសនា ? ហេតុអ្វី ?

៥. ចូរអ្នកបង្ហាញឡើងវិញពីមូលហេតុដែលនាំឱ្យអ្នកនិពន្ធយើងមានគំនិតក្នុងការព្យាយាមនិពន្ធស្នាដៃគ្រប់ប្រភេទសម្រាប់កូនចៅជំនាន់ក្រោយ ។

# កម្លាយដោយផ្នត់ដើម

នៅក្នុងភាសាខ្មែរ មានវិធីបង្កើតពាក្យច្រើនបែបច្រើនយ៉ាង ។ រីឯវិធីបង្កើតពាក្យតាមកម្លាយដោយផ្នត់ដើមក៏ជាវិធីមួយដែលធ្វើឱ្យភាសាខ្មែរកាន់តែមានភាពសម្បូរបែបថែមទៀត ។ ចំពោះផ្នត់ដើមមានទម្រង់ច្រើនប្រភេទដូចជា ៖

**ផ្នត់ដើមទម្រង់ ព- កើតមកពីព្យញ្ជនៈទោលតែមួយប៉ុណ្ណោះ ។**

- ផ្នត់ដើម [ក-] [k-]
  - [ក-] + ម៉ៅ > ខ្មៅ [k-] + [mau] > [kmau]
  - [ក-] + ជាប់ > ខ្ជាប់ [k-] + [coa:p] > [kcoa:p]
- ផ្នត់ដើម [ច-] [c-]
  - [ច-] + បង > ចម្បង [c-] + [bɒ:ŋ] > [cbɒ:ŋ]
  - [ច-] + រាល > ច្រាល [c-] + [rea:l] > [crea:l]
- ផ្នត់ដើម [ជ-] [c-]
  - [ជ-] + រុះ > ជ្រុះ [c-] + [ruh] > [cruh]
  - [ជ-] + រុល > ជ្រុល [c-] + [rul] > [crul]
- ផ្នត់ដើម [ត-] [t-]
  - [ត-] + រិះ > ត្រិះ [t-] + [rih] > [trẹh]
  - [ត-] + មោង > ត្មោង [t-] + [mo:ŋ] > [tmao:ŋ]
- ផ្នត់ដើម [ទ-] [t-]
  - [ទ-] + រេល > ទ្រេល [t-] + [re:l] > [tre:l]
  - [ទ-] + រឹង > ទ្រឹង [t-] + [rɯŋ] > [trɯŋ]
- ផ្នត់ដើម [ប៉-] [p-]
  - [ប៉-] + ដឹង > ប្ដឹង [p-] + [dœŋ] > [pdœŋ]
  - [ប៉-] + ដាច់ > ផ្ដាច់ [p-] + [dac] > [pdac]
- ផ្នត់ដើម [ម-] [m-]
  - [ម-] + ងក់ > ម្ងក់ [m-] + [ŋɔk] > [mŋɒk]

- ផ្នត់ដើម [ស-] [ s- ]

- [ស-] + កក > ស្កក [ s- ] + [ kɒ:k ] > [ skɒ:k ]

- [ស-] + គាល់ > ស្គាល់ [ s- ] + [ koa:l ] > [ skoa:l ]

ផ្នត់ដើមទម្រង់ ពស- ប្រើសម្រាប់បង្កើតពាក្យពីរព្យាង្គ ។

- ផ្នត់ដើម [ក-] [ kɒ:- ]

- [ក-] + កាយ > កកាយ [ kɒ:- ] + [ ka:j ] > [ kɒka:j ]

- [ក-] + ក្អាក > កក្អាក [ kɒ:- ] + [ kʔa:k ] > [ kɒkʔa:k ]

- ផ្នត់ដើម [ច-] [ cɒ:- ]

- [ច-] + ចឹក > ចចឹក [ cɒ:- ] + [ coek ] > [ cɒcœk ]

- [ច-] + ចាក់ > ចចាក់ [ cɒ:- ] + [ cak ] > [ cɒchak ]

- ផ្នត់ដើម [ត-] [ tɒ:- ]

- [ត-] + តះ > តតះ [ tɒ:- ] + [ tah ] > [ tɒtah ]

- [ត-] + តោង > តតោង [ tɒ:- ] + [ tao:ŋ ] > [ tɒtao:ŋ ]

- ផ្នត់ដើម [ស-] [ sɒ:- ]

- [ស-] + សិត > សសិត [ sɒ:- ] + [ sœt ] > [ sɒsœt ]

- [ស-] + សៀរ > សសៀរ [ sɒ:- ] + [ si:e] > [ sɒsi:e ]

- ផ្នត់ដើម [ប-] [ b- ]

- [ប-] + បិច > បបិច [ bɒ:- ] + [ bẹc ] > [ bɒbẹc ]

- [ប-] + បោស > បបោស [ bɒ:- ] + [ bao:h ] > [ bɒbao:h ]

ផ្នត់ដើមទម្រង់ ពពស- ប្រើសម្រាប់បង្កើតពាក្យក្លាយពីរព្យាង្គ ។

- ផ្នត់ដើម [ក្រ-] [ krɒ:- ] និង [គ្រ-] [ krɔ:- ]

- [ក្រ-] + ចាប់ > ក្រចាប់ [ krɒ:- ] + [ cap ] > [ krɒcap ]

- [គ្រ-] + វាស > គ្រវាស [ krɔ:- ] + [ viɔ:h ] > [ krɔviɔ:h ]

- ផ្នត់ដើម [ត្រ-] [ trɒ:- ] និង [ទ្រ-] [ trɔ:- ]

- [ត្រ-] + កង > ត្រកង [ trɒ:- ] + [ kɒ:ŋ ] > [ trɒkɒ:ŋ ]

- [ទ្រ-] + ហ៊ឹង > ទ្រហឹង [ trɔ:- ] + [ hɯŋ ] > [ trɔ:hɯŋ ]

- ផ្នត់ដើម [ប្រ-] [ prɒ:- ]
  - [ប្រ-] + កាប់ > ប្រកាប់ [ prɒ:- ] + [ kap ] > [ prɒkap ]
  - [ប្រ-] + ខាំ > ប្រខាំ [ prɒ:- ] + [ kham ] > [ prɒkham ]
- ផ្នត់ដើម [ព្រ-] [ prɔ:- ]
  - [ព្រ-] + ងើយ > ព្រងើយ [ prɔ:- ] + [ ŋɤ:j ] > [ prɔŋɤ:j ]
  - [ព្រ-] + លប់ > ព្រលប់ [ prɔ:- ] + [ lɔp ] > [ prɔlɔp ]
- ផ្នត់ដើម [ស្រ-] [ srɒ:- ]
  - [ស្រ-] + លះ > ស្រឡះ [ srɒ:- ] + [ lah ] > [ srɒlah ]
  - [ស្រ-] + អាប់ > ស្រអាប់ [ srɒ:- ] + [ ʔap ] > [ srɒʔap ]

ផ្នត់ដើមទម្រង់ ពសព- ប្រើសម្រាប់បង្កើតពាក្យក្លាយពីរព្យាង្គ ។

- ផ្នត់ដើម :
  - បង់- + ក > បង្ក [ bɒŋ- ] + [ kɒ: ] > [ bɒŋkɒ: ]
  - រង់- + វង់ > រង្វង់ [ rɔŋ- ] + [ vɔŋ ] > [ rɔŋvɔŋ ]
  - រំ- + កិល > រំកិល [ rum- ] + [ kẹl ] > [ rumkẹl ]
  - លន់- + លង់ > លន្លង់ [ lɔn- ] + [ lɔŋ ] > [ lɔnlɔŋ ]
  - លំ- + នៅ > លំនៅ [ lɔm- ] + [ nəu ] > [ lɔmnəu ]
  - សង់- + កត់ > សង្កត់ [ sɒŋ- ] + [ kɒt ] > [ sɒŋkɒt ]
  - សន់- + ដក > សណ្ដក [ sɒn- ] + [ dɒ:k ] > [ sɒndɒ:k ]
  - ពន់- + យល់ > ពន្យល់ [ pɔn- ] + [ jɔl ] > [ pɔnjɔl ]
  - អំ- + ពោស > អំពោស [ ʔɒm- ] + [ bao:h ] > [ ʔɒmbao:h ]
  - បាញ់- + ចប់ > បញ្ចប់ [ baɲ- ] + [ cɒp ] > [ bɒɲcɒp ]
  - បន់- + ដេញ > បណ្ដេញ [ bɒn- ] + [ deɲ ] > [ bɒndeɲ ]
  - បំ- + បាត់ > បំបាត់ [ bɒm- ] + [ bat ] > [ bɒmbat ]
  - ពង់- + រត់ > ពង្រត់ [ pɔŋ- ] + [ rɔt ] > [ pɔŋrɔt ]
  - អញ់- + ចង > អញ្ចង [ ʔɒɲ ] + [ cɒ:ŋ ] > [ ʔɒɲcɒ:ŋ ]

*គេអាចបង្កើតពាក្យ តាមវិធីកម្លាយដោយផ្នត់ដើមដែលស្ថិតនៅខាងដើមពាក្យឫស។ ផ្នត់ដើមមានទម្រង់បួនយ៉ាងគឺ "ព-" "ពស-" "ពពស-" "ពសព-"។*

## លំហាត់

១. ចូរប្រើវិធីកម្លាយពាក្យដោយប្រើផ្នត់ដើមឱ្យបានត្រឹមត្រូវ ដើម្បីបង្កើតពាក្យ :

ក. តាមទម្រង់ "ព-"

ពាក្យឫស : ងក់ ដួល ញ៉ក់ ទាស់ មាន វាង លា បង។

ខ. តាមទម្រង់ "ពស-"

ពាក្យឫស : កិត ខ្វេស ខឹក ឃួស ជីក ទាក់ ពុះ ពួក ប៉ាច់។

គ. តាមទម្រង់ "ពពស-"

ពាក្យឫស : ចាប់ ពាត់ ហាល់ វី វៀច ឈឹង សាយ ចាក់ ខាំ ដែង។

ឃ. តាមទម្រង់ "ពសព-"

ពាក្យឫស : កុញ ចាស់ ដាច ធាត់ លង លាក់ ហុយ ដើរ ទាស់។

២. ចូរអ្នករកពាក្យឫសខាងក្រោមនេះដោយប្រាប់ពីទម្រង់ :

ក. ច្រាស ផ្នួល ជ្រុល ឈ្មោក ធ្លុង ជ្រមុជ ស្អក ប្រវែង។

ខ. ចូរស្រង់ពាក្យក្លាយក្នុងសម្រង់អត្ថបទខាងក្រោមនេះ ដោយបញ្ជាក់ពីទម្រង់ផង។

[...] សម័យបច្ចុប្បន្ន (ចាប់ពី គ.ស. ១៩៥៣ រហូតមក) ពេលបានឯករាជ្យភ្លាម អ្នកនិពន្ធបានធូរស្រាលក្នុងចិត្តគំនិតដោយបានទទួលនូវសេរីភាពក្នុងការកសាងអក្សរសិល្ប៍ថ្មីៗរបស់ខ្លួន។

អក្សរសិល្ប៍ខ្មែរក៏បានឈានជើងទៅកាន់ការលូតលាស់ថ្មីមួយដែលមានលក្ខណៈនិងនិន្នាការជាតិនិយម សង្គមនិយម ប្រជាធិបតេយ្យ និងប្រជាប្រិយ។ គ្រប់ប្រភេទនៃអក្សរសិល្ប៍ក៏បានកើតឡើងគឺប្រលោមលោកកំណាព្យ រឿងល្ខោន សៀវភៅបច្ចេកទេស សៀវភៅសិក្សាអប់រំ សៀវភៅទាក់ទងនិងគំនិតទស្សនៈវិជ្ជា។ [...]

# ការវិភាគតួអង្គ

តួអង្គ គឺជាតួដែលមានវត្តមាននិងសកម្មភាពនៅក្នុងរឿង ។ តួអង្គមានសកម្មភាពតិចឬច្រើននិងបុគ្គលិកលក្ខណៈខុសៗគ្នាទៅតាមគំនិតរបស់អ្នកនិពន្ធ ។ កាលណាសិក្សាអត្ថបទរឿងយើងត្រូវវិភាគតួអង្គដើម្បីឈានទៅវិភាគផ្នែកផ្សេងៗនៃរឿង ។ ចូរអានឧទាហរណ៍ខាងក្រោម :

## រឿងព្រេងទាក់ទងនឹងពិធីសែនព្រះភូមិនៅរដូវធ្វើស្រែ

មានតំណាលក្នុងគម្ពីរធម្មបទថា ក្នុងសម័យពុទ្ធកាលមានកុដុម្ពិកម្នាក់ ជាអ្នកមានស្តុកស្តម្ភដោយទ្រព្យសម្បត្តិ ប៉ុន្តែប្រពន្ធជាស្រីអា គ្មានកូនសោះ ។ មាតារបស់កុដុម្ពិកក៏ត្រិះរិះ ៖ "បើកូនអញគ្មានកូននឹងតវង្សត្រកូលដូច្នេះ តើបានអ្នកណានឹងរក្សាទ្រព្យសម្បត្តិតទៅទៀត" ។ គំនិតនោះមិនបាត់ស្ងាត់ក៏ដឹងទៅដល់នាងភរិយាដើម ។ នាងភរិយាដើមគិតថា បើប្តីអញមានប្រពន្ធចុង ហើយនាងនោះមានកូនគេមុខជានឹងបានគ្រប់គ្រងទ្រព្យសម្បត្តិ ធ្វើជាធំក្នុងផ្ទះសម្បែងនេះពុំខាន ឯខ្លួនអញក៏មុខជានឹងថយមុខមាត់ ពុំមានអ្នកណារាប់អានឡើយ បើដូច្នោះគួរអញចេញមុខទៅដណ្តឹងប្រពន្ធជូនម្តាយក្មេក ដើម្បីឱ្យនាងប្រពន្ធចុងគោរពកោតខ្លាចអញ ។

បន្ទាប់មក នាងនោះក៏ចូលទៅនិយាយនឹងម្តាយក្មេក ដើម្បីធានាទៅដណ្តឹងប្រពន្ធថ្មីឱ្យប្តី ។ ម្តាយក្មេកក៏ព្រម ។ លុះបានប្រពន្ធថ្មីមកមិនយូរប៉ុន្មាន នាងនោះក៏មានគភ៌មែន ។ នាងប្រពន្ធដើមដឹងដូច្នោះក៏ព្យាបាទនាងប្រពន្ធចុងនោះរហូតបណ្តាលឱ្យនាងប្រពន្ធចុងមានគ្រោះថ្នាក់ដល់ជីវិតទាំងម្តាយនិងទារកក្នុងផ្ទៃផង ។ មុននឹងស្លាប់ នាងនោះដឹងថា ខ្លួនដែលដល់នូវសេចក្តីអន្តរាយនេះ មិនគឺអ្នកឯណាក្រៅអំពីប្រពន្ធដើមជាអ្នកធ្វើឡើយ ។ នាងនោះក៏ធ្វើមរណកាលទៅ ហើយអន្ទោលយកកំណើតជាសត្វឆ្មា ។ ឯប្រពន្ធដើម លុះស្លាប់ក៏ទៅយកកំណើតជាសត្វមាន់ ។ មេមាន់នោះ កាលបើបានពងពេញសម្បុកកាលណា សត្វឆ្មាទៅខាំស៊ីអស់រលីង លុះដល់ជាគម្រប់បីលើក មេមាន់ក៏ចងពៀរនឹងឆ្មាថា " កើតជាតិក្រោយសូមឱ្យបានស៊ីកូនឆ្មាវិញ " រួចក៏ដាច់ខ្យល់ស្លាប់ទៅ ។ លុះជាតិក្រោយមកទៀតឆ្មានោះក៏អន្ទោលជាតិជាមេម្រឹគ ឯមេមាន់ ក៏ចាប់កំណើតជាសត្វខ្លា ។ កាលណាមេម្រឹគសម្រាលកូនខ្លានោះតែងទៅខាំស៊ីកូនអស់ គម្រប់បីលើក ដូចន័យមុនទៀត ។ ជាតិជាបន្តទៀត ខ្លានោះទៅកើតជានាងកុលធីតា ឯមេម្រឹគទៅជានាងយក្ខិនី ។ ក្នុងពេលដែលនាងកុលធីតានោះមានកូន តែនាងយក្ខិនីនោះក៏ក្លែងធ្វើម្រាក់មកសួរសុខទុក្ខ ហើយបន្លំចាប់កូននោះស៊ីទៅ ។ លុះវារៈជាគម្រប់បី នាងកុលធីតា

នាំប្តីប្រពន្ធទាំងកូនទៅងូតទឹកស្រះ ។ នៅពេលដែលងូតរួចហើយបីកូនអង្គុយចាំប្តី នាងចោលភ្នែកទៅឃើញយក្ខិនីដើរសំដៅពីចម្ងាយមក នាងយល់ច្បាស់នូវសេចក្តីអន្តរាយ ក៏បីកូនស្ទុះរត់គេច ។ លុះរត់ទៅៗក៏ទៅដល់វត្តមួយ គាប់ជួនពេលនោះព្រះពុទ្ធអង្គកំពុងប្រទានធម៌ទេសនា នៅកណ្តាលប្រជុំជនពុទ្ធបរិស័ទ ។ នាងកុលធីតាភ័យណាស់ យកកូនទៅដាក់ទៀបព្រះបាទអង្គព្រះពុទ្ធ ហើយស្រែកយំអង្វរព្រះអង្គថា សូមព្រះអង្គជួយកុំឱ្យនាងយក្ខិនីស៊ីបាន ។ នាងយក្ខិនីតាមមកដល់កំពែងវត្ត ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ប្រើអានន្ទទៅហៅនាងយក្ខិនីនោះឱ្យចូលមក ។ កាលបើនាងយក្ខិនីនោះចូលមកក្រាបថ្វាយបង្គំព្រះអង្គ ទើបព្រះអង្គទ្រង់នាំអតីតនិទាន ៖ " អំពីការចងពៀរដែលមិនអាចរំងាប់ដោយពៀរ" មកសម្តែងប្រាប់ រួចទ្រង់ត្រាស់ផ្សះផ្សានាងទាំងពីរនាក់ ឱ្យលែងកាន់ចិត្តគំនិតគុំកួននឹងគ្នា ហើយទុកដាក់គ្នាជាបងជាប្អូនតទៅ ។ នាងយក្ខិនីទូលសួរព្រះអង្គថា តើឱ្យនាងរស់របៀបណា ? បើនាងធ្លាប់តែរស់ដោយចាប់មនុស្សសត្វជាអាហារយ៉ាងហ្នឹងទៅហើយ បើព្រះអង្គឱ្យនាងកាន់សីល តើនាងអាចចិញ្ចឹមជីវិតបានបែបណា ។ កាលនោះព្រះពុទ្ធអង្គ ទើបត្រាស់បង្គាប់ឱ្យនាងកុលធីតាយកនាងយក្ខិនីទៅចិញ្ចឹម ។ នាងយក្ខិនីនោះ ចេះមើលដំណើរទឹកភ្លៀង ។ ហេតុនេះហើយនៅរៀងរាល់ឆ្នាំបើនាងដឹងថា ឆ្នាំណាភ្លៀងតិច នាងបង្គាប់នាងកុលធីតាឱ្យធ្វើស្រែជ្រៅ បើឆ្នាំនេះមានភ្លៀងច្រើន ត្រូវធ្វើស្រែទួល ។ មិនយូរប៉ុន្មាន នាងកុលធីតាក៏ទៅជាអ្នកមានទ្រព្យសម្បត្តិ ដោយសារបានផលស្រូវច្រើន ។ អ្នកជិតខាងឃើញនាងធ្វើស្រែមិនដែលខុសឆ្នាំណាសោះ នឹកឆ្ងល់ក៏នាំគ្នាទៅសួរ នាងក៏ប្រាប់តាមដំណើរ ។ បន្ទាប់មក ឱ្យតែជិតដល់រដូវធ្វើស្រែ អ្នកជិតខាងតែងនាំគ្នាយកចំណីទៅជូននាងយក្ខិនីដើម្បីសួរដំណឹងទឹកភ្លៀង ។ ក្រោយមក នាងយក្ខិនីដែលធ្លាប់តែនៅក្នុងព្រៃ កើតក្តីអផ្សុកមិនចេះនៅក្នុងស្រុក ព្រោះនាងឮតែសូរសំឡេងត្បាល់អង្រែមិនឈប់ឈរ ក៏សុំនាងកុលធីតាទៅនៅឯស្រែឆ្ងាយអំពីស្រុកភូមិ ។ នាងកុលធីតាក៏ទៅសង់រោងមួយឱ្យនាងយក្ខិនីនៅក្រៅស្រុក រីឯអ្នកស្រុកភូមិដែលធ្លាប់តែយកអីវ៉ាន់ទៅបូជានាងយក្ខិនី ដើម្បីសួរដំណឹងទឹកភ្លៀង ក៏យកអីវ៉ាន់តាមទៅបូជានាងយក្ខិនី ឯស្រែឆ្ងាយនោះទៀត ។

រឿងបូជានេះបានធ្វើអស់កាលដ៏យូរ លុះអស់អំពីនាងយក្ខិនីទៅក៏ក្លាយទៅជាទំនៀមបូជាព្រះភូមិ ដើម្បីឱ្យធ្វើស្រូវបានផលច្រើនទៅវិញ ។

*(ដកស្រង់និងកែសម្រួលពីប្រជុំរឿងព្រេងភាគ ៩ ឆ្នាំ ១៩៧៤)*

តួអង្គក្នុងរឿងនេះមាន ប្រពន្ធដើម (នាងកុលធីតា) ប្រពន្ធចុង (យក្ខិនី) និងព្រះពុទ្ធអង្គ ។

ការវិភាគតួអង្គ នាងប្រពន្ធដើម និងប្រពន្ធចុង

## ១ . នាងប្រពន្ធដើម (ជាតិចុងក្រោយ គឺនាងកុលធីតា)

### ក. គុណសម្បត្តិ

- ខំរកស៊ីជាមួយប្ដីរហូតក្លាយជាអ្នកមានស្ដុកស្ដម្ភ ។
- ចង់រាប់អានអ្នកដទៃឱ្យបានច្រើនមិនចង់នៅឯកោ ។
- ស្ដាប់ឱវាទទូន្មានរបស់ព្រះពុទ្ធ ឈប់ចងពៀរនឹងប្រពន្ធចុងតទៅទៀត ។
- សុខចិត្តទទួលនាងប្រពន្ធចុង (នាងយក្ខិនី) ធ្វើជាញាតិតរៀងទៅ ។

### ខ. គុណវិបត្តិ

- តាំងខ្លួនជាចិត្តល្អ ប៉ុន្តែមានគំនិតអាក្រក់ ចង់ឱ្យប្រពន្ធចុងគោរពកោតខ្លាចខ្លួន ។
- មានគំនិតច្រណែនខ្លាចគេមានកូនដណ្ដើមទ្រព្យសម្បត្តិរបស់ខ្លួន ។
- ចង់បានមុខមាត់ឱ្យគេគោរពកោតសរសើរខ្លួន ។
- ជាមនុស្សចិត្តសាហាវឃោរឃៅគ្មានមនុស្សធម៌ ។
- ចងពៀរជាច្រើនជាតិជាមួយប្រពន្ធចុង ។

## ២ . នាងប្រពន្ធចុង (ជាតិចុងក្រោយ គឺយក្ខិនី)

### ក. គុណសម្បត្តិ

- អត់ធ្មត់មិនតបតជាមួយអំពើអមនុស្សធម៌របស់ប្រពន្ធដើមឡើយរហូតដល់ស្លាប់ខ្លួន ។
- ស្ដាប់ឱវាទព្រះពុទ្ធឈប់ចងពៀរជាមួយកុលធីតា (ប្រពន្ធដើម) ។
- សុខចិត្តស្រុះស្រួលរស់នៅជាមួយនាងកុលធីតាក្នុងនាមជាបងប្អូន ។
- ជាតិចុងក្រោយ គឺជួយជ្រោមជ្រែងនាងកុលធីតាឱ្យក្លាយជាអ្នកមានទ្រព្យស្ដុកស្ដម្ភ ។

### ខ. គុណវិបត្តិ

- មិនប្រាប់ការពិតដល់ប្ដីនិងក្រុមគ្រួសារអំពីអំពើអមនុស្សធម៌របស់នាងប្រពន្ធដើម ។
- លាក់គំនុំក្នុងចិត្តដើម្បីចងពៀរ ។
- មិនរកវិធីដោះស្រាយក្រៅពីការចងពៀរ ។

តាមឧទាហរណ៍ខាងលើបង្ហាញថា តួអង្គទាំងពីរសុទ្ធតែមានគុណសម្បត្តិនិងគុណវិបត្តិ ទៅតាមសកម្មភាពនៅក្នុងដំណើររឿង ។

*ការវិភាគតួអង្គ គឺជាការសិក្សាវិភាគឱ្យឃើញពីអាកប្បកិរិយា ចរិតលក្ខណៈ សកម្មភាពរបស់តួអង្គនៅក្នុងរឿងតាមរយៈលក្ខណសម្បត្តិពីរយ៉ាង គឺគុណសម្បត្តិនិងគុណវិបត្តិ ។*

## លំហាត់

ចូរអ្នកវិភាគតួអង្គសុវណ្ណ និងនាងតន់ក្នុងអត្ថបទដកស្រង់នេះ

[....] លាក់បាំងអ្វី លុយនេះបានជាអូនមិនដាច់ចិត្តជូនបងពីថ្ងៃមុននោះ ព្រោះជាលុយខ្មោចឪពុកខ្ញុំ ហើយខ្ញុំគិតថាខ្ញុំមិនចាយវាយលុយនេះផ្ដេសផ្ដាសទេ ខ្ញុំប្រាថ្នាដល់ពេលណាខ្ញុំមានប្ដីទៅ ខ្ញុំនឹងមានលុយនេះ ទៅចាត់ចែងធ្វើបុណ្យនិមន្តលោកឆាន់ឧទ្ទិសផលជូនខ្មោចឪពុកខ្ញុំ ។ ប៉ុន្តែឥឡូវនេះអូនយល់ថា បងប្រាកដជាកុនលុយខ្លាំងហើយ ទើបដាច់ចិត្តយកប្រាក់នេះ មកបង្គ្រប់ឱ្យបង ។ សុវណ្ណនឹកខ្លោចចិត្តរួចយកដៃអង្អែលស្មានាងតន់ "តន់ដឹងគុណមាតាបិតាណាស់ តែបងត្រូវតែដឹងគុណតន់នៅថ្ងៃក្រោយវិញ ។ មិនអីទេអូន ! កាលណាយើងបានគ្នាជាប្ដីប្រពន្ធ ទៅបងនឹងខំរកស៊ីសន្សំប្រាក់រួចធ្វើបុណ្យ ជូនអ្នកមានគុណអូនឱ្យបានសមនឹងចិត្តអូនវិញមិនខាន" ។ "ខ្ញុំគិតលាបងទៅផ្ទះវិញ ហើយព្រោះដូចជាញាក់ភ្នែកឆ្វេងខ្វាកៗមិនដាច់សោះថប់តែមានរឿងទេបង" ។ និយាយរួចនាងតន់ឆ្លៀតទៅបបោសអង្អែលកូនប្រុសតូចរបស់សុវណ្ណ ដែលដេកលក់មិនដឹងខ្លួន ទើបចុះដើរមកដីសំដៅទៅផ្ទះខ្លួនទាំងយប់ស្ងាត់ ។ សុវណ្ណមិនដាច់ចិត្តឱ្យនាងទៅម្នាក់ឯង ក៏ចុះចោលកូនជូនដំណើរគ្រាន់បានកក់ក្ដៅតែដើរបានចំងាយមួយប្រហែលមួយស្រែ នាងដេញសុវណ្ណឱ្យត្រឡប់មកផ្ទះវិញ ព្រោះកូនតូចនៅម្នាក់ឯងក្នុងផ្ទះ... ។ លុះព្រឹកឡើងស្រាប់តែឃើញនាងតន់ដើរសំដៅមកផ្ទះសុវណ្ណទៀត ។ ប៉ុន្តែម្ដងនេះ មានឃើញបង្វិចសម្លៀកកបំពាក់ជាប់ជាមួយខ្លួនផង ព្រមទាំងមានទឹកមុខក្រៀមស្ងួត ។ សុវណ្ណដែលប្រុងប្រៀបយកកូនទៅផ្ញើនឹងម្ដាយធំវាឱ្យជួយមើល ដើម្បីចេញទៅប្រកបការងារដូចរាល់ថ្ងៃ លុះឃើញនាងតន់ដើរចូលមកដល់មុខផ្ទះខ្លួន ប្រកបដោយអាការៈខុសប្លែកពីធម្មតាដូចនោះក៏នឹកពិភាល់ក្នុងចិត្តជាខ្លាំង ទើបស្រែកសួរពីលើផ្ទះ "តន់មកទៀតហើយឬ ? បានអ្វីនៅជាប់នឹងដៃនោះ ? ឡើងមកតន់" ។ នាងតន់មិនទាន់តបទៅវិញ ភ្លាមទេនាងឡើងទៅលើផ្ទះទាំងទឹកភ្នែក លុះអង្គុយស្រួលបួលហើយទើបនិយាយរឿងនាងប្រាប់សុវណ្ណ "បងយប់មិញ ពេលត្រឡប់ទៅដល់ផ្ទះវិញខ្ញុំមានរឿងសន្ធឹក" ។ រឿងអីទៅតន់ ? សុវណ្ណសួរដោយងឿងឆ្ងល់ ។"ណ្ហើយ ! ចាំថ្ងៃក្រោយសឹមនិយាយគ្នាទៀត ។ [...]

*(ដកស្រង់ចេញពីរឿងភូមិតិរច្ឆាន របស់ក្រសួងអប់រំបោះពុម្ពឆ្នាំ១៩៨៧)*



# ភ្នំនាងកង្រី



## ក. សិក្សាពាក្យគន្លឹះ

- ពុត (ន) : ដំណើរបាំងទោសខ្លួន ដំណើរបិញ្ជរបុញ្ជ កិច្ចកលមាយា ការក្លែងបង្វែងដំណើរ ឱ្យឃ្លាតចាកសេចក្ដីពិត ។
- ញុះញង់ (កិ) : ញុះញយៗ គឺនិយាយចាក់រុកនាំអុជអាលឱ្យអ្នកដទៃ ធ្វើកិច្ចការអ្វីៗ ដែលមិនគប្បីឱ្យឈ្លោះទាស់ទែងគ្នា ។
- គភ៌ (ន) : ផ្ទៃពោះ (មានផ្ទៃពោះ) ។
- ក្សេមក្សាន្ត (គុ) : ដែលមានសេចក្ដីសុខសាន្ត ។
- ព្រះទិវង្គត (កិ. ឬ គុ) : ស្លាប់ ។

## ខ. អភិវឌ្ឍន៍បំណិន

ដើម្បីទទួលលទ្ធផលល្អក្នុងការអាន អ្នកគប្បីយកចិត្តទុកដាក់ត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងប្រភេទអក្សរសិល្ប៍ លក្ខណតថ:របស់រឿង គំនិតសំខាន់បង្កប់ និងកាលអាកាស ។

គ. អត្ថបទ

កាលពីព្រេងនាយ មានសេដ្ឋីនៅនគរមួយជាមនុស្សឥតកូន បាននាំប្រពន្ធទៅបន់ស្រន់សុំកូននៅដើមជ្រៃមួយ ។ ក្រោយពីបន់ស្រន់រួចប្រពន្ធមានកូនរហូតដល់១២នាក់សុទ្ធតែស្រី ។ លុះបានកូនហើយសេដ្ឋីធ្លាក់ខ្លួនជាអ្នកទ័លក្រ រកអាហារចិញ្ចឹមកូនគ្មានក៏បររទេះដឹកកូនទាំង១២នាក់ទៅប្រោសចោលក្នុងព្រៃជ្រៅមួយ ។

ក្រោយពីឪពុកប្រោសចោល កូនទាំង១២នាក់ក៏នាំគ្នាដើរក្នុងព្រៃទៅដល់នគរមួយជានគរយក្សស្រីឈ្មោះនាងសន្ធមារ ។ យក្សនោះមានកូនស្រីមួយឈ្មោះនាងកង្រី ។ នាងសន្ធមារបានឃើញនាងទាំង១២នាក់ ក៏ដំណែងខ្លួនជាស្រី នាំយកនាងទាំងនោះទៅទុកក្នុងប្រាសាទរបស់ខ្លួន ឱ្យបម្រើនាងកង្រីជាកូន ។

កាលនោះនាងទាំង១២នាក់ដឹងថា នគរនោះជានគរយក្ស នាងសន្ធមារជាយក្ខិនី ហើយក៏នាំគ្នារត់ចេញ ។ នាងសន្ធមារបានតាមរកឃើញ នាងទាំង១២ បានក្លាយជាមហេសីព្រះបាទរថសិទ្ធិ នៅនគរមនុស្សទៅហើយ ។ ពេលនោះនាងសន្ធមារក៏ដំណែងខ្លួនជាស្រីក្រមុំ ហើយក៏បានធ្វើជាមហេសីព្រះបាទរថសិទ្ធិដែរ ។ នាងសន្ធមារពុតធ្វើជាឈឺធ្ងន់ញុះញង់ពេទ្យឱ្យទូលព្រះបាទរថសិទ្ធិឱ្យឆ្កៀលភ្នែកទាំង ១២ យកមកធ្វើជាថ្នាំព្យាបាលរោគខ្លួននិងឱ្យយកនាងទាំង ១២នាក់ដែលមានគភ៌គ្រប់គ្នាទៅទុកក្នុងរណ្ដៅមួយជាមួយគ្នា បង្អត់អាហារ ឱ្យយកគ្រាប់ភ្នែករបស់នាងទាំង ១២នាក់នោះទៅទុកក្នុងឃ្លាំងឯនគររបស់ខ្លួន ដោយទុកឱ្យនាងកង្រីជាកូនថែរក្សា ។

ក្នុងចំណោមនាងទាំង ១២នាក់នោះ នាងបងៗ ១១នាក់ត្រូវគេឆ្កៀលភ្នែកទាំងសងខាង ឯនាងពៅត្រូវគេឆ្កៀលភ្នែកតែម្ខាង ដោយពីជាតិមុននាងពៅឆ្កៀលភ្នែកត្រីតែម្ខាងដែរ ។ ពេលនាងទាំង១២មានគភ៌នោះ នាងពៅបានត្រូវព្រះពោធិសត្វមកចាប់ផ្ទៃ ។ វេលានាងបងៗកើតកូនភ្លាម គេហែកកូនចែកសាច់គ្នាស៊ីអស់ ចំណែកនាងពៅកើតកូនមកឱ្យឈ្មោះថា "ពុទ្ធិសែន" ហើយលាក់ទុកមិនឱ្យនាងបងៗដឹងទេ ។

ចំណេរកាលខាងក្រោយមក វេលាពុទ្ធិសែនធំពេញជំទង់ឡើង នាងសន្ធមារដឹងថាជាកូននាងទី ១២ ក៏ប្រើឱ្យជិះសេះនាំសំបុត្រទៅឱ្យកង្រីដោយដាក់សេចក្ដី ៖ "បើពុទ្ធិសែនមកដល់ពេលយប់ ឱ្យស៊ីទាំងយប់មកដល់ថ្ងៃឱ្យស៊ីទាំងថ្ងៃ" ។ តែជាភ័ព្វរបស់ពុទ្ធិសែន នៅពេលជិះសេះទៅដល់ពាក់កណ្ដាលព្រៃ មហាឫសីបានឃើញពុទ្ធិសែនកំពុងផ្ទំលក់និងឃើញសំបុត្រ ដែលចងនៅនឹងសេះ ក៏ហែកសំបុត្រ

នោះចោល ហើយសរសេរសំបុត្រជាថ្មី ៖ "បើពុទ្ធិសែនមកដល់យប់ឱ្យរៀបការទាំងយប់ ដល់ថ្ងៃរៀបការទាំងថ្ងៃជាមួយនាងកង្រីជាកូន"។ ពេលដែលពុទ្ធិសែនបានសោយរាជ្យ នៅនគរយក្សមិនយូរប៉ុន្មានពុទ្ធិសែនក៏ជ្រាបដំណឹងអំពីប្រវត្តិប្រស្រីភ្នែកមាតាខ្លួននិងអំពីថ្នាំសម្រាប់ដាក់ភ្នែកឱ្យជាសះស្បើយ និងថ្នាំសម្រាប់បោះទៅកើតជាទឹកសមុទ្រ ជាភ្នំបាន ទ្រង់ក៏លួចរត់ចោលនាងកង្រីទាំងអធ្រាត្រ។ នាងកង្រីរត់តាមមិនទាន់ក៏យំសោកស្លាប់នៅកណ្ដាលព្រៃ ហើយព្រះពុទ្ធិសែនមកដល់នគរវិញដោយសុវត្ថិភាព ទ្រង់ដាក់ថ្នាំកែវភ្នែកមាតានិងមាតាធំទាំងអស់ឱ្យជាឡើងវិញ។ ព្រះអង្គក៏សម្លាប់នាងសន្ធមារទៅ ទ្រង់បានសោយរាជ្យជំនួសបិតា ជាសុខក្សេមក្សាន្តរហូតដល់ទ្រង់ចូលទិវង្គត។ [...]

*(ដកស្រង់និងកែសម្រួលពីប្រជុំរឿងព្រេងខ្មែរភាគ៥ពុទ្ធសាសនបណ្ឌិត្យព.ស.២៥៤៧ គ.ស.២០០៣ ទំព័រទី ៩៨-១០០)*

## សំណួរ

១. តើរឿងនេះគេចាត់ទុកជាអក្សរសិល្ប៍ប្រភេទណា ? ចូររកអំណះអំណាងបញ្ជាក់។

២. ហេតុដូចម្ដេចបានជានាងទាំង១១ ត្រូវគេឆ្កៀលភ្នែកទាំងសងខាង ? ឯនាងទី១២ ត្រូវគេឆ្កៀលភ្នែកតែម្ខាង ? តាមគំនិតអ្នក តើឥទ្ធិពលនៃទស្សនៈនេះកើតមកពីណា ?

៣. តើផ្នត់គំនិតណាមួយក្នុងអត្ថបទដែលនៅតែជាឧត្ដមគតិដ៏ល្អសម្រាប់កូនខ្មែរជំនាន់ក្រោយ ? ហេតុអ្វី ?

៤. តើរឿងនេះ បានបង្ហាញពីផ្នត់គំនិតខ្មែរយ៉ាងណាខ្លះ ?

៥. ហេតុដូចម្ដេចបានជាពុទ្ធិសែន បានរៀបការជាមួយនាងកង្រី ? តើអ្នកនិពន្ធមានទស្សនៈដូចម្ដេច ទើបមិនឱ្យពុទ្ធិសែនបានរួមរស់ជាមួយនាងកង្រីជាគូរៀងទៅអនាគត ?

៦. បើតាមទស្សនៈរបស់អ្នក តើការបញ្ចប់រឿងដោយឱ្យពុទ្ធិសែន និងនាងកង្រីមិនបានរួមរស់ជាស្វាមីភរិយាលុះអនាគតបែបនេះសមស្របឬទេ ? ហេតុអ្វី ?

៧. ចូរសិក្សាពីកាលអាកាសនៃរឿង។

៨. ចូរអ្នកស្រង់ពាក្យក្លាយឱ្យបានបួនពាក្យពីក្នុងអត្ថបទអំណានរឿង "ភ្នំនាងកង្រី" ដោយបង្ហាញពាក្យឫសនិងប្រាប់ពីទម្រង់ផង។

# រឿងព្រះពាន់

ដើម្បីទទួលលទ្ធផលល្អក្នុងការស្តាប់ អ្នកគប្បីយកចិត្តទុកដាក់ត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងប្រភេទអក្សរសិល្ប៍ លក្ខណតថៈរបស់រឿង គំនិតសំខាន់បង្កប់ និងកាលអាកាស ។

ក្នុងវប្បធម៌នៃជាតិសាសន៍នីមួយៗ តែងតែមានវប្បធម៌និងផ្នត់គំនិតផ្សេងៗគ្នាដែលបង្កប់នូវអត្តសញ្ញាណរបស់ជាតិនោះ ។ ឥឡូវនេះ អ្នកនឹងបានស្តាប់រឿងព្រះពាន់ ដើម្បីស្វែងយល់ពីផ្នត់គំនិតសំខាន់ៗដែលមាននៅក្នុងអត្ថបទនេះនិងត្រៀមឆ្លើយនឹងសំណួរដូចខាងក្រោមនេះ ៖



## សំណួរ

១. តើរឿងនេះ ចាត់ទុកជាអក្សរសិល្ប៍ប្រភេទអ្វី ? ចូររកអំណះអំណាងបញ្ជាក់ ។

២. តើអំពើរបស់កូនប្រុសដែលបានប្រព្រឹត្តចំពោះម្តាយនោះ ជាអំពើយ៉ាងដូចម្តេច ? ហេតុអ្វី ?

៣. តើម្តាយរបស់កូនប្រុសនោះមានឥរិយាបថយ៉ាងដូចម្តេច ចំពោះអំពើរបស់កូនប្រុសគាត់ ?

៤. ហេតុដូចម្តេច បានជាកូនប្រុសនោះសុំខមាទោសចំពោះម្តាយវិញ ? តើការសុំខមាទោសនេះគេធ្វើនៅពេលណាខ្លះ ? ចំពោះមុខអ្វីដែរ ?

៥. តើចំណុចណាខ្លះដែលបញ្ជាក់ពីផ្នត់គំនិត ?

៦. តើរឿងនេះ បានបង្ហាញពីលក្ខណតថៈរបស់រឿងយ៉ាងណាខ្លះ ?

៧. ចូរសិក្សាពីកាលអាកាសនៃរឿង ។



# បញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿង

ការនិយាយបញ្ចេញមតិវាយតម្លៃទៅលើអ្វីមួយ គឺជាការបង្ហាញឱ្យឃើញពីគំនិត យោបល់ ការយល់ឃើញរបស់បុគ្គលម្នាក់ៗ ដើម្បីវិនិច្ឆ័យរកចំណុចសកម្ម ឬអសកម្មនៃបញ្ហា អំពើ សកម្មភាព មតិ យោបល់ គំនិតផ្សេងៗ ។ មួយវិញទៀត ការបញ្ចេញមតិវាយតម្លៃទៅលើតួអង្គ ក្នុងរឿងណាមួយ មានសារៈសំខាន់ណាស់ចំពោះអ្នកសិក្សា ព្រោះវាបានផ្តល់ចំណុចសកម្មដែលជាបទពិសោធសម្រាប់ជីវិតទាំងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។

ខាងក្រោមនេះ ជាមតិវាយតម្លៃតួអង្គពុទ្ធិសែន ក្នុងរឿងភ្នំនាងកង្រី ពីមូលហេតុនៃការស្លាប់របស់នាងកង្រី :

**មតិទី១** : មូលហេតុនៃការបាត់បង់ជីវិតរបស់តួអង្គនាងកង្រី ដោយសារតែពុទ្ធិសែនដែលបានចាកចេញទៅ ធ្វើឱ្យនាងយល់ច្រឡំថា នាងត្រូវពុទ្ធិសែនបោះបង់ចោល ។ បើតាមផ្នត់គំនិតខ្មែរតម្រូវឱ្យស្វាមីភរិយាមានចិត្តស្មោះត្រង់នឹងគ្នាទៅវិញទៅមក គឺត្រូវមានភក្តីភាព ។ ដូចករណីពុទ្ធិសែន បានរៀបការជាមួយនាងកង្រីក្លាយជាប្តីប្រពន្ធទៅហើយ គួរណាស់តែពុទ្ធិសែនត្រូវបញ្ជាក់ពីមូលហេតុនៃការចាកចេញរបស់ខ្លួនឱ្យបានច្បាស់លាស់ប្រាប់នាងកង្រីជាប្រពន្ធ ។

**មតិទី២** : មូលហេតុនៃការស្លាប់របស់នាងកង្រី គឺបណ្តាលមកពីនាងសន្ធមារជាម្តាយដែលមានចេតនាសម្លាប់មាតាធំទាំងដប់មួយនិងមាតាបង្កើតរបស់ពុទ្ធិសែន ទើបធ្វើឱ្យពុទ្ធិសែនត្រូវជ្រើសរើសយកអ្នកមានគុណជាការចាំបាច់ គឺត្រូវស្រោចស្រង់ជីវិតលោកឡើងវិញ ។ នេះបញ្ជាក់ថា ពុទ្ធិសែន មានទឹកចិត្តកតញ្ញូចំពោះអ្នកមានគុណដែលលោកកំពុងរងការឈឺចាប់ ដោយទទួលទារុណកម្មធ្ងន់ធ្ងរជាទីបំផុត ។ មាតាធំទាំង ១១និងមាតាបង្កើតរបស់ពុទ្ធិសែន សុទ្ធតែត្រូវគេខ្វេះភ្នែក ហើយរស់នៅក្នុងរណ្តៅអត់អាហារទៀតផង ។ ដូចនេះចំពោះមុខ ពុទ្ធិសែនត្រូវតែទៅជួយសង្គ្រោះអ្នកមានគុណទាំងនោះជាកាតព្វកិច្ចរបស់កូនចំពោះមាតាបិតា ។ រីឯនាងកង្រីវិញ ដោយម្តាយរបស់នាងជាសត្រូវរបស់គ្រួសារពុទ្ធិសែនបែបនេះ ទោះបីមានចិត្តរស់នៅជាមួយគ្នា ក៏មិនប្រាកដថាមានសុភមង្គលដែរ ព្រោះពុទ្ធិសែនក៏បានសម្លាប់មាតានាងកង្រីដោយផ្ទាល់ដៃទៀតផង ។

**សន្និដ្ឋាន** : មតិទាំងពីរសុទ្ធតែបានផ្អែកទៅលើបុគ្គលិកលក្ខណៈ និងសកម្មភាពរបស់តួអង្គពុទ្ធិសែនដែលតួអង្គត្រូវប្រឈមមុខនឹងការសម្រេចចិត្តដ៏លំបាកបំផុត ។ បញ្ហាពីរដែលពុទ្ធិសែនត្រូវគិត គឺម្ខាងជាម្តាយ ហើយម្ខាងទៀតគឺប្រពន្ធ បញ្ហាទាំងនេះបានតម្រូវឱ្យពុទ្ធិសែនជ្រើសរើសយកតែមួយ ។ ទីបំផុតពុទ្ធិសែនត្រូវសម្រេចចិត្តសង្គ្រោះម្តាយទាំង១២របស់ខ្លួនជាមុន ។ ការសម្រេចចិត្តនេះពិតជាត្រឹមត្រូវ ព្រោះស្ថានភាពនាងកង្រីមិនលំបាកដូចនាងមាតាពុទ្ធិសែនទេ ។ ដូចនេះក្នុងនាមជាកូនកតញ្ញូ ពុទ្ធិសែនត្រូវតែហ៊ានពុះពារ ដើម្បីអ្នកមានគុណ ។

## សំណួរ

១. តើមតិទីមួយវាយតម្លៃដូចម្ដេច ចំពោះមូលហេតុនៃការស្លាប់របស់នាងកង្រី ?

២. តើមតិទី ២ វាយតម្លៃដូចម្ដេចដែរ ?

៣. តើគំនិតណាខ្លះ ជាគំនិតដែលឯកភាពគ្នាភាគច្រើន ? ហើយគំនិតនោះ ពួកគេបានឱ្យតម្លៃទៅលើអ្វីជាធំ ? ហេតុអ្វី ?

៤. តើការវិភាគទាំងនោះ គេបានឈរលើកត្តាអ្វីខ្លះ ? តើកត្តាទាំងនោះ សមស្របដែរឬទេ ? ព្រោះអ្វី ?

## លំហាត់

ចូរអ្នកធ្វើការបញ្ចេញមតិវាយតម្លៃតួអង្គ "ព្រះបាទរថសិទ្ធិ មហាឫសី" ក្នុងរឿងភ្នំនាងកង្រី ដែលអ្នកបានអានរួចមកហើយ ។

ដើម្បីឱ្យការវិភាគរបស់អ្នក កាន់តែប្រសើរថែមទៀត អ្នកគប្បី

- ស្វែងយល់សាច់រឿង ឱ្យបានច្បាស់លាស់ ។
- ផ្អែកទៅលើសកម្មភាពតួអង្គជាមធ្យោបាយសំខាន់ ។
- ឈរលើឥរិយាបថជាអ្នកវិភាគត្រឹមត្រូវ មិនលំអៀង ។
- ប្រើសំនួនបញ្ចេញមតិ ឬទស្សនៈឱ្យបានត្រឹមត្រូវដូចជា
  - ខ្ញុំសូមបញ្ជាក់ ............... ។
  - តាមយោបល់ខ្ញុំ ខ្ញុំគិតថា ............ ។
  - និយាយអីចឹងក៏ត្រូវម្យ៉ាងដែរ ! ................. ។
  - តែខ្ញុំគិតថា ! .................... ។
  - ត្រឹមត្រូវហើយ ! ខ្ញុំគាំទ្រគំនិត ... ព្រោះថា .....
  - បើតាមគំនិតខ្ញុំ ខ្ញុំយល់ថា .......... ។

# សំយោគមតិ

ដូចម្ដេចហៅថាការសំយោគ ? ការសំយោគ គឺជាការប្រមូលផ្ដុំគំនិត ព័ត៌មាន ឬព្រឹត្តិការណ៍សំខាន់ដែលមាននៅក្នុងរបាយការណ៍ ឬអត្ថបទនានា ។ ការសំយោគនេះ ប្រព្រឹត្តទៅសម្រាប់តែអត្ថបទ ឬគំនិតទាំងឡាយណាដែលស្ថិតក្នុងប្រធានបទដូចគ្នាតែប៉ុណ្ណោះ ។

ខាងក្រោមនេះ ជាអត្ថបទសំណេរសំយោគគំនិតវាយតម្លៃមតិទាំងពីរស្ដីពី "ពុទ្ធិសែន ជាមូលហេតុនៃការស្លាប់របស់នាងកង្រី" ។

រឿងភ្នំនាងកង្រី ជាអក្សរសិល្ប៍ប្រជាប្រិយខ្មែរដែលបានចងក្រងទុកក្នុងសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៥ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ។ រឿងនេះបាននិយាយទាក់ទងទៅនឹងប្រវត្តិភូមិសាស្ត្រទឹកដី និងផ្នត់គំនិតរបស់ខ្មែរមួយចំនួនទៀតផង ។ តាមដំណើររឿងនេះមានមតិពីរវាយតម្លៃសកម្មភាព និងទង្វើរបស់តួអង្គពុទ្ធិសែនថាជាមូលហេតុនៃការស្លាប់របស់នាងកង្រី ។

បើតាមការបញ្ចេញមតិវាយតម្លៃតួអង្គពុទ្ធិសែននេះមានមតិពីរខុសៗគ្នា គឺមតិទីមួយយល់ថាការបាត់បង់ជីវិតរបស់តួអង្គនាងកង្រី ដោយសារតែពុទ្ធិសែនដែលបានចាកចេញទៅ នាំឱ្យនាងយល់ច្រឡំថា ពុទ្ធិសែនបោះបង់នាងចោល ។ បើតាមផ្នត់គំនិតខ្មែរ តម្រូវឱ្យស្វាមីភរិយាមានចិត្តស្មោះត្រង់នឹងគ្នាទៅវិញទៅមក គឺត្រូវចេះរក្សាភក្ដីភាពទៅវិញទៅមក ហើយពុទ្ធិសែនបានរៀបការជាមួយនាងកង្រីតាមប្រពៃណី ។ គួរណាស់តែពុទ្ធិសែនត្រូវបញ្ជាក់ពីមូលហេតុមុននៃការចាកចេញរបស់ខ្លួនឱ្យបានច្បាស់លាស់ ។ រីឯមតិទីពីរយល់ថា មូលហេតុនេះមកពីនាងសន្ធមារដែលមានចេតនាសម្លាប់មាតាធំទាំងដប់មួយនាក់និងមាតាបង្កើតរបស់ពុទ្ធិសែន ទើបធ្វើឱ្យពុទ្ធិសែនត្រូវជ្រើសរើសយកអ្នកមានគុណជាការចាំបាច់ ។ ការណ៍នេះបញ្ជាក់ថា ព្រះអង្គមានទឹកចិត្តកតញ្ញូចំពោះអ្នកមានគុណដែលលោកកំពុងរងការឈឺចាប់ដោយទទួលទារុណកម្មពីនាងសន្ធមារជាយក្ខិនីចិត្តឫស្យានោះ ។ ម្យ៉ាងទៀតទារុណកម្មនោះមានភាពសាហាវអមនុស្សធម៌បំផុត ព្រោះថាមាតាធំទាំងដប់មួយនាក់និងមាតាបង្កើតរបស់ពុទ្ធិសែន សុទ្ធតែត្រូវគេខ្វេះភ្នែក រស់នៅក្នុងរណ្ដៅអត់អាហារថែមទៀត ។ ដូចនេះ ចំពោះមុខពុទ្ធិសែនត្រូវតែទៅជួយសង្គ្រោះអ្នកមានគុណទាំងនោះជាចាំបាច់ ។ រីឯនាងកង្រី ដោយម្ដាយរបស់នាងជាសត្រូវរបស់គ្រួសារពុទ្ធិសែនបែបនេះ ទោះបីមានចិត្តរស់នៅជាមួយគ្នា ក៏មិនប្រាកដថាមានសុភមង្គលដែរ ព្រោះពុទ្ធិសែនក៏បានសម្លាប់មាតានាងកង្រីដោយផ្ទាល់ដៃទៀតផង ។

ដូចនេះ បើតាមគំនិតវិភាគខាងលើ បានបង្ហាញពីគំនិតពីរផ្សេងគ្នា គំនិតទីមួយមិនគាំទ្រអំពើរបស់ពុទ្ធិសែន ។ មូលហេតុនៃការបាត់បង់ជីវិតរបស់តួអង្គនាងកង្រីដោយសារតែពុទ្ធិសែន ដែលបានចាកចេញទៅ ធ្វើឱ្យនាងយល់ច្រឡំថា នាងត្រូវពុទ្ធិសែនបោះបង់ចោល ដែលជាភាពអាម៉ាស់មួយក្នុងជីវិតរបស់ស្ត្រី ។ ផ្ទត់គំនិតខ្មែរតម្រូវឱ្យស្វាមីនិងភរិយាមានចិត្តស្មោះត្រង់នឹងគ្នាទៅវិញទៅមក គឺត្រូវចេះរក្សាភក្ដីភាព ។ នាងកង្រីមានភក្ដីភាពចំពោះពុទ្ធិសែនជាប្ដី ។ បើមិនដូច្នេះទេ ម្ល៉េះសមនាងមិនយំសោកបោកខ្លួនរហូតស្លាប់នៅកណ្ដាលព្រៃនោះឡើយ ។ ចំណែកក្រុមគំនិតទីពីរវិញ គាំទ្រអំពើពុទ្ធិសែន ព្រោះថាបើឱ្យនាងកង្រីដឹងផែនការរបស់ពុទ្ធិសែន នោះនឹងត្រូវបែកការណ៍ ហើយត្រូវបរាជ័យជាមិនខាន ព្រោះនាងកង្រីជាកូនយក្ខិនីសន្ធមារ ។ នេះបានបញ្ជាក់ថា ព្រះអង្គមានទឹកចិត្តកតញ្ញូចំពោះអ្នកមានគុណដែលលោកកំពុងរងការឈឺចាប់ ដោយទទួលទារុណកម្មពីនាងសន្ធមារជាយក្ខិនីចិត្តឫស្យានោះ ។ ដោយស្ថិតក្នុងស្ថានភាពបែបនេះ តួអង្គត្រូវប្រឈមមុខនឹងការសម្រេចចិត្តដ៏លំបាកបំផុត ។ បានន័យថា គេត្រូវគិតពីម្ដាយផងនិងប្រពន្ធផង ។ ទីបំផុតគេក៏សម្រេចចិត្តជួយសង្គ្រោះម្ដាយជាមុនព្រោះស្ថានភាពនាងកង្រី មិនលំបាកដូចមាតាពុទ្ធិសែនទេ ។ ដូចនេះក្នុងនាមជាកូនកតញ្ញូពុទ្ធិសែនត្រូវតែហ៊ានពុះពារដើម្បីអ្នកមានគុណ ។

ឆ្លងតាមការបកស្រាយខាងលើនេះ បានបង្ហាញឱ្យឃើញថា មូលហេតុនៃការស្លាប់របស់នាងកង្រី គឺបណ្ដាលមកពីពុទ្ធិសែនប្រាកដមែន ។ តែទង្វើនេះពោរពេញទៅដោយអត្ថន័យសំខាន់ ក្នុងការបញ្ជាក់ពីគំនិតរបស់ជនជាតិខ្មែរ តែងតែបណ្ដុះនូវទឹកចិត្តកតញ្ញូរបស់កូនចំពោះអ្នកមានគុណ ។ ផ្នត់គំនិតនេះតែងតែដក់ជាប់ក្នុងក្រអៅបេះដូងកូនខ្មែរគ្រប់ៗរូប ។ ដូចនេះ ក្នុងនាមជាកូនល្អម្នាក់ៗ គប្បីចេះប្រកាន់នូវគុណធម៌ល្អខាងលើនេះ ។ ក្នុងជីវភាពរស់នៅជាក់ស្ដែងការសង្គ្រោះជីវិតមនុស្សទាមទារនូវការលះបង់ច្រើន ប៉ុន្តែបើគេប្ដូរមកវិញនូវជីវិតរបស់នរណាម្នាក់ ដើម្បីជីវិតផ្សេងទៀតក៏គួរតែខិតខំរកវិធីល្អជាងនេះ ដោយធ្វើយ៉ាងណាឱ្យទាំងអស់គ្នាមានការរស់នៅប្រកបដោយសេចក្ដីសុខទាំងផ្លូវកាយនិងផ្លូវចិត្ត ។ ទង្វើបែបនេះទើបសក្ដិសមជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អពិតប្រាកដ ។

## សំណួរ

១. តើសំណេរនេះមានប៉ុន្មានកថាខណ្ឌ ? ហើយមានអ្វីខ្លះ ?

២. តើកថាខណ្ឌនីមួយៗនិយាយពីអ្វីខ្លះ ?

៣. តើសំណេរនេះមានប្រធានបទអ្វី ?

៤. ចូរពិនិត្យមើលសំណេរនេះ តើមានមតិប៉ុន្មាន ? មតិទាំងនោះ ស្របគ្នាឬទេ ? ហើយគេត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីឱ្យសំណេរប្រភេទនេះក្លាយទៅជាសំណេរមួយត្រឹមត្រូវ ?

## លំហាត់

ដោយផ្អែកលើអត្ថបទអំណានទី ១ "ការវិវត្តនៃអក្សរសិល្ប៍ខ្មែរ" និងអត្ថបទរឿង "ភ្នំនាងកង្រី" ចូរអ្នកធ្វើសំណេរសំយោគដោយច្បិចយកតែគំនិតសំខាន់ៗមកនិយាយឱ្យទាក់ទងនឹងផ្នត់គំនិតខ្មែរតែប៉ុណ្ណោះ ដោយលើកអំណះអំណាងបញ្ជាក់ផង ។

ដើម្បីជំរុញឱ្យសំណេររបស់អ្នកមានរចនាបថល្អ អ្នកគប្បីធ្វើតាមលំនាំដូចខាងក្រោម :

### ១ . ការព្រាង

- ជាការព្រាងគំនិតទាក់ទងនឹងប្រធានបទ ។
- ព្រាងគំនិតទៅតាមទម្រង់ ។
- គម្រោងតែង ។

### ក. ផ្ដើមសេចក្ដី

- បង្ហាញគំនិតអត្ថបទ ។
- បញ្ជាក់ប្រធានបទរួមនៃអត្ថបទទាំងនោះ ដែលត្រូវសំយោគ ។

### ខ. តួសេចក្ដី

- ធ្វើបញ្ជីគំនិតសំខាន់នៃអត្ថបទនីមួយៗ ។
- រៀបគំនិតសំខាន់នៃអត្ថបទទាំងពីរបញ្ចូលគ្នាជាទម្រង់មួយ (គំនិតសំខាន់ដូចគ្នាយកតែមួយ) ។
- គំនិតដែលមិនរួមគ្នាត្រូវទុកទាំងអស់ ។
- គំនិតសំខាន់ដែលត្រូវយកមក ត្រូវបកស្រាយពន្យល់ឱ្យបានល្អិតល្អន់ ។
- រៀបគំនិតទាំងអស់នៃសំយោគ ទៅតាមលំដាប់លំដោយឱ្យបានត្រឹមត្រូវ ។

### គ. បញ្ចប់សេចក្តី

- បញ្ជាក់មូលហេតុនៃការជ្រើសរើសប្រធានបទនេះមកសិក្សា ។
- យោបល់របស់អ្នកសំយោគ ។

## ២ . សំណេរ

ចងក្រងគំនិតទៅតាមគម្រោង (សេចក្តីផ្តើម តួសេចក្តី បញ្ចប់សេចក្តី) ។

## ៣ . ការកែលម្អ

- គំនិត
  - ត្រូវអានសំណេរចុងក្រោយយ៉ាងយកចិត្តទុកដាក់ ដើម្បីផ្ទៀងផ្ទាត់គំនិតនីមួយៗទៅនឹងភាពជាប់ទាក់ទងគ្នា គោលគំនិតរបស់ប្រធានបទដែលបានលើកឡើង ។
  - ត្រូវមើលលំដាប់លំដោយនិងលំហូរនៃគំនិតនីមួយៗ រួមទាំងឃ្លាភ្ជាប់សេចក្តីទៀតផង ។
- ពាក្យពេចន៍ ឃ្លា ល្បះ
  - ត្រូវថ្លឹងថ្លែងខ្លឹមសារនៃពាក្យពេចន៍ ដែលប្រើប្រាស់ដើម្បីរំលេចគំនិតនីមួយៗ ។
  - មើលភាពសមស្របនៃន័យរបស់ពាក្យនៃសេចក្តីអធិប្បាយក្នុងល្បះនីមួយៗ ។
- អក្ខរាវិរុទ្ធ
  - កែតម្រូវពាក្យខុសឆ្គង
  - ការសរសេរពាក្យឱ្យត្រូវតាមក្បួនវេយ្យាករណ៍
  - គោរពតាមគោលការណ៍នៃសំណេរ ។

មេរៀនទី ២

# ទំនៀមទម្លាប់




ជនជាតិខ្មែរ ជាជនជាតិមួយដែលមានវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណីតាំងពីសម័យបុរេប្រវត្តិមកម្ល៉េះ ហើយបន្តរក្សានូវតម្លៃអត្តសញ្ញាណជាតិដ៏ល្អផូរផង់នោះ បានរហូតដល់សព្វថ្ងៃ។

អ្វីៗដែលយើងបានដឹងនិងកំពុងប្រតិបត្តិតាំងពីដើមរៀងមកសុទ្ធតែជាផ្លែផ្កានៃប្រពៃណី ទំនៀមទម្លាប់របស់ដូនតាខ្មែរយើង។ ក្នុងមេរៀននេះអ្នកនឹងបានសិក្សាពីអរិយធម៌ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់មួយចំនួនរបស់ខ្មែរយើង។ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីកំណាព្យទ្វេមាត្រ កាព្យរូបារម្មណ៍ កម្លាយដោយផ្នត់ដែក ការបញ្ចេញមតិផ្ទាល់ខ្លួនចំពោះជំនឿ និងការតែងកំណាព្យ។

## រំលឹកបញ្ញត្តិ

### ១ . សញ្ញាសម្គាល់ដែលប្រើប្រាស់ក្នុងកំណាព្យ

#### ក. សញ្ញាគូសលើព្យាង្គ

សញ្ញាចួន      សញ្ញាផ្ទួន      សញ្ញារណ្ដំ ។

#### ខ. សញ្ញាសម្រាប់បកស្រាយ

សញ្ញាចួន      សញ្ញាផ្ទួន      សញ្ញារណ្ដំ ។

#### គ. អក្សរកាត់

ព្យ : ព្យាង្គ      ឃ : ឃ្លា      វ : វគ្គ ។

*ឧទាហរណ៍ :* ព្យាង្គទី ៨ នៃឃ្លាទី ១ វគ្គ ១ ផ្ទួននឹងព្យាង្គទី ១ នៃឃ្លាទី ២ វគ្គទី ១ ។

ព្យ៨ ឃ១ វ១      ព្យ១ ឃ២ វ១

### ២ . កាព្យរូបារម្មណ៍

**តើរូបារម្មណ៍ជាអ្វី ?** រូបារម្មណ៍ គឺជារូបវត្ថុឬការណ៍ណាមួយដែលស្ថិតនៅក្នុងញាណ ។ រូបារម្មណ៍ជាលទ្ធផលនៃការប៉ះទង្គិចរវាងសរីរាង្គឥន្ទ្រិយទៅនឹងវត្ថុ ឬការណ៍ បង្កើតបានចរន្តបញ្ជូនទៅខួរក្បាលតាមរយៈសរសៃប្រសាទ ។ ខួរក្បាលបានផ្ដិតយករូបវត្ថុ ឬការណ៍ទាំងនោះតាមអារម្មណ៍របស់យើង ។

**តើកាព្យរូបារម្មណ៍ជាអ្វី ?** ជារូបារម្មណ៍ដែលមានក្នុងអត្ថបទកាព្យ ។ កាព្យនឹងមានរូបារម្មណ៍ទៅបានអាស្រ័យដោយកវីចេះជ្រើសរើសពាក្យពេចន៍ សំនួនសេចក្ដី សំនួនគំនិត ... មកតុបតែងពាក្យចួនទាំងនោះឱ្យមានសម្ផស្ស មានភាពរស់រវើក ពីរោះរណ្ដំ ទាក់ទាញអ្នកអាន អ្នកស្ដាប់ឱ្យជក់ចិត្តជិតអារម្មណ៍ ។ កាព្យរូបារម្មណ៍មាន ៖

#### ក. បំរៀបន័យរូបារម្មណ៍ (មេតាផរ)

បំរៀបន័យរូបារម្មណ៍ ឬមេតាផរ គឺជារូបារម្មណ៍នៃទំហៀបដែលកើតឡើងពីការប្រៀបធៀបដោយមិនប្រើចំណងធៀប ។ *ឧទាហរណ៍:* ភ្នំឆ្អឹងស្ទឹងឈាម សមុទ្រទឹកភ្នែក នាវាជីវិត ក្បួនជីវិត... ។

ទំហៀបនេះជួនកាលកវីប្រៀបធៀបរវាងរូបីនិងអរូបី ហើយកវីធ្វើបដិសំយោគរវាងអង្គទាំងពីរនេះ បំណងប្រែក្លាយអង្គរូបីឱ្យមានជីវិត មានចេតនា មានចលនា និងមានវិញ្ញាណឡើង ។ ទង្វើនេះបង្កើតបានជាបុគ្គលិកកម្ម ។

*ឧទាហរណ៍ :* ខ្យល់ត្អូញឆ្លើយឆ្លង កម្ដៅដុតរោលខ្លោចអស់ធម្មជាតិ ... ។

## ខ. ឧបមានរូបារម្មណ៍

ឧបមានរូបារម្មណ៍ ជារូបារម្មណ៍ដែលកើតឡើងពីការប្រៀបធៀបអង្គបង្គោលនិងទំហៀបពីរ ឬច្រើនដោយប្រើចំណងធៀប ។ ចំណងធៀបមានដូចជា ប្រៀបដូច ហាក់ដូចជា ដូចជា ប្រៀបបាន ច្រឡំនឹង ប្រហែលជា យ៉ាងណា យ៉ាងនោះ មិនបាន មិនខុសពី មិនជាជាង ... ។

*ឧទាហរណ៍ :* ទុំថាខ្លួនបងដូចរាជសីហ៍ ខ្លួននាងទាវស្រីដូចគុហា
រាជសីហ៍បើបានលំនៅជា មិនឱ្យឃ្លាតឃ្លាគុហាឡើយ ។

*(ទុំទាវ ភិក្ខុសោម)*

## គ. រូបារូប្បារម្មណ៍

រូបារូប្បារម្មណ៍ ជារូបារម្មណ៍ដែលកើតឡើងពីកវីប្រើប្រាស់ពាក្យពេចន៍ ឃ្លា ល្បះ សំនួន ទាក់ទងទៅនឹង ៖

- រូបារម្មណ៍បង្ហាញពីឥន្ទ្រិយទាំង៥ (ឥន្ទ្រិយរូបារម្មណ៍)
- រូបារម្មណ៍បង្ហាញពីស្នេហា ផ្លូវភេទ (កាមរូបារម្មណ៍)
- រូបារម្មណ៍បង្ហាញពីចិត្តរំភើបញាប់ញ័រ ខ្វាយខ្វល់ ... (វេទនារូបារម្មណ៍)
- រូបារម្មណ៍បង្ហាញពីសញ្ញាភាព សម្រាប់សម្គាល់មតិ គំនិត ទស្សនៈណាមួយ (និមិត្តរូបារម្មណ៍)

*ឧទាហរណ៍ :* សំឡេងផ្អែមល្ហែមស្រួយពីរោះ ស្តាប់ទាំងកំលោះចាស់មេម៉ាយ
ក្រមុំត្បូងឃ្មុំរត់ប្រញាយ ប្រញាប់ចង់ស្តាប់សព្ទភាសា ។
ទាវអើយទាវស្រីសេចក្តីនេះ មាននេននោះចេះមើលសាស្ត្រា
សំឡេងស្រួយស្រាប់ស្តាប់ភាសា ដូចសត្វសារិកាពិសាចេក ។(សោតរូបារម្មណ៍)

*(ទុំទាវភិក្ខុសោម)*

រួចនេនស្តាប់ជាក់ភ្ញាក់ព្រើតប្រឹង ភ្នែកគន់សម្លឹងទៅមាត់ទ្វារ
យល់ទាវឈរស្ងបដើររេរា ស្ទុះស្ទាចូលក្នុងស្លុងចេញក្រៅ ។
អើតមើលដកកច្រហមាត់ ចង់ចេញប្រាកដគ្មានគេហៅ
ស្លុតស្លឹងម្នាក់ឯងដោយក្មេងសាវ ស្ទុះចូលយកអាវពាក់ពានា ។
នេនយល់ដូច្នោះក្នុងពោះព្រួច កាន់ក្ដួចកើតទុកចុកឱរា
ឱរូបហ្នឹងហើយទាវពុំងា មិនងាកបំពាបំពេរន ។ (វេទនារូបារម្មណ៍)

*(ទុំទាវ ភិក្ខុសោម)*

 ទំមិនធំជាងនាឡិ



## ក. សិក្សាពាក្យគន្លឹះ

- ចែចូវ (កិ) : នាំសំដីទៅនិយាយបញ្ចុះបញ្ចូល មុននឹងដណ្តឹងកូនក្រមុំគេត្រូវឱ្យមនុស្សទៅចែចូវសិន ។
- ភោជផល (ន) : វត្ថុ ឬគ្រឿងបរិភោគ ។
- បណ្ណាការ (ន) : គ្រឿងសម្រាប់ធ្វើជាជំនូនសម្រាប់ជូនភាគីខាងស្រីពេលស្តីដណ្តឹងឬរៀបការ ។
- នាឡិ (ន) : រង្វាល់មួយប្រភេទសម្រាប់វាល់អង្ករ ឬគ្រាប់អ្វីមួយៗ ម្យ៉ាងទៀតជាខ្នាតទម្ងន់ស្មើនឹង ១៦តម្លឹងឬ៦ខាំ ។
- កបលក្ខណ៍ (ន) : មនុស្សគ្រប់លក្ខណ៍ ។
- នរៈ (ន) : មនុស្ស ។
- និយម (គុ) : ដែលមន្ទិល ឥតសៅហ្មង ។
- កិច្ចកល (ន) : ឧបាយយ៉ាងល្អិត ល្បិច ។
- ស្ពក (ន) : ថាសឈើ ឬតុឈើសម្រាប់ថ្កល់ បានដាក់ភោជនាហារ ។
- រន្ថាន់ (កិ វិ) : ដែលមានអាការញាប់ខ្ជាន់ៗ ។

- មោះហ្មង (ន) : សេចក្ដីសៅហ្មង ដំណើរឆ្គាំឆ្គង ។
- ទំនើង (ន) : សេចក្ដីទើង ដំណើរដែលធ្វើឥតទើសទាស់តាមតែអំណាចចិត្ត អំពើចិត្ត ចំណង់ ។
- អម្ចាស់ (ន) : អ្នកមានអំណាចកាន់កាប់អ្វីៗដែលជារបស់ខ្លួន ឥស្សរជន ។
- ប្រសាសន៍ (ន) : ពាក្យបង្គាប់ ពាក្យផ្ដាំផ្ញើ បណ្ដាំ ។
- ជញ្ជឹង (កិ) : រិះគិត ត្រិះរិះ ។
- ប្រណិបតន៍ (ន) : ការសម្ដែងសេចក្ដីគោរព ការគំនាប់ ការឱនសំពះ ។
- ចរលីលា (ន) : ដើរលេងកម្សាន្ត ដើរយាងយាសតាមការស្រួល ។
- ឆ្មើង (គុ) : ដែលកាន់ខ្លួន រពើតរពើង ។
- អំពល់ (ន) : កង្វល់ ឬសេចក្ដីខ្វល់ចិត្ត ដំណើរដែលនាំឱ្យមានរវល់ខ្វល់ចិត្ត ។
- សង្កុញខឹង (កិ) : ជំរុញ រុញដោយប្រញាប់ឱ្យជ្រុល ឬឱ្យលឿនទៅមុខ បង្ខំខ្លាំងឱ្យទាន់ចិត្ត ។
- របាញ្ញសាញ្ញ (គុ) : ដែលប្រទាក់ចាក់ស្រែះ ដែលស៊កសៀតរវឹមរវាម ។
- ចណ្ឌាល (ន) : មនុស្សពូជសូទ្រៈពួកមួយ គឺពួកមនុស្សត្រកូលទាបដែលមានពូជដើមកើតអំពីបីតាពូជសូទ្រ (មនុស្សដែលដុនដាបថោកទាប ហើយកាចប្រហើនមិនក្រែងច្បាប់ជាមនុស្សឥតអៀនខ្មាស ដើររសាត់អណ្ដែតទៅជ្រកអាស្រ័យដោយសារអ្នកដទៃ ចេញពីផ្ទះនេះទៅផ្ទះនោះ) ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីប្រុងប្រយ័ត្ននិងយកចិត្តទុកដាក់លើខ្លឹមសារដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងរង្វាស់កាព្យ ចំណាប់ចួន ផ្ទួន រណ្ដំ ខ្លឹមសារ និងរូបារម្មណ៍មួយចំនួន ។

## គ. អត្ថបទ

### (បទពាក្យ ៧)

[...] យើងនឹងឈប់ស្លេះបង្អង់នៅ រឿងពេជ្រទុំទៅដល់ត្បូងឃ្មុំ
នឹងថ្លែងដំណើរអរជូនជំ- នុំនឹងភរិយាជាប្រពន្ធ ។
ថានៃប្អូនស្ងួនន្ទួនខ្លឹមចិត្ត យើងគួរគិតត្បិតបងមានបុណ្យ
មានបុត្រស្រីប្រុសរបស់ធន បណ្ដាមហាជនជុំក្រាស់ក្រួន ។
បងឮអស់រាស្ត្រប្រជាជាក់ និយាយមិនលាក់ដូចមាំមួន
ប្រាយប្រាប់ដោយស័ព្ទសក្តិសមសួន កូនគេផងខ្លួនដូចដួនយើង ។

នាងនោះមានម្ដាយមេម៉ាយសោះ
ប៉ុន្តែរបស់តាមទំនើង
ម៉ែនបានបាវព្រាវប្រើលាងជើង
ថ្មុំថ្កើងគ្រប់សព្វចប់ដល់ចាស់ ។
ប្រពន្ធបានស្ដាប់ចាប់ចិត្តធំ
ជឿជាស្លូនសមមិនទាន់ច្បាស់
ជម្រាបទៅប្ដីថាអម្ចាស់
ខ្ញុំស្ដាប់ប្រសាសន៍លះគុំគួន ។
ថាគិតផ្គងផ្គុំផ្សំកូនគេ
ស្រែឬទន្លេដែលមានខ្លួន
ចិន្ដាលោកគិតឱ្យម៉ឺនងួន
ចំណាយចំនួនឆ្នាំ ខែ ថ្ងៃ ។
អរជូនជញ្ជីងរង់ចាំស្ដាប់
ប្រពន្ធសាស័ព្ទនៅសង្ស័យ
ទើបគាត់ប្រាប់ថាប្អូនមាសថ្លៃ
បងព្វសម័យដោយប្រជា- ។
នុរាស្ត្រនរៈអ្នកប៉ុន្មាន
ដែលបានមកដល់ជំនុំគ្នា
សរសើរពីរូបទាវសោភា
នៅនាខាងក្បែរស្រែទេស្រី ។
នេះបើប្អូនស្ងួននួនខ្លឹមចិត្ត
យើងគួរអាណិតបុត្រភ្វាប្រិយ
គួរយើងរិះរកនំចំណី
ភោជផលអ្វីៗត្រីសាច់សត្វ ។
រួចរើសរកអ្នកជាក់ចេះដឹង
មែនមានដំណឹងរឿងបរមត្ថ
ដែលតែងប្រសប់ធ្លាប់តែកាត់
ស៊ុំស្ទាត់បែបបទចេះវោហារ ។
អធិប្បាយនិយាយខាងចែចូវ
ជាអ្នកនាំផ្លូវតាមដូនតា
ឱ្យទៅស្រដីខាងមេបា
នាងទាវតើថាប្រការម្ដេច ។
ប្រពន្ធអរជូនជំនួនស្រាប់
ភ្ជុំគ្នាប្រញាប់រាន់រំពេច
យកសព្វភោជផលថ្កល់និងវេច
រៀបរួចស្រាប់ស្រេចត្រាច់ចរចេញ ។
លីលាលយលង់ដានដងផ្លូវ
ត្រូវត្រង់មាគ៌ាឃ្មាតខ្ជលខ្ជាញ់
ខំស្រូតរូតរះកាត់គ្រោកគ្រាញ់
អរញ្ញវាលព្រៃរំពៃយល់ ។
ក្រឡេកក្រលៀងឆ្មៀងពីអាយ
ច្បាស់ជានាងម្ដាយទាវនិមល
នេះគឺមិនអ្នកដទៃទាល់
ទៅជិតទៀបស្គាល់ដល់ជាម្ដង ។
នាងនោះស្ទុះឡើងលើគ្រឹះស្ថាន
ប្រមាណត្រូវមាត់ជាដន្លង
ថាអ្នកអញ្ជើញមកប៉ុនប៉ង
បំណងបំណាច់ត្រាច់ទៅឆ្ងាយ ។
ឬមួយជាមករកយើងខ្ញុំ
សូមសុំប្រសាសន៍សងរ៉ាប់រ៉ាយ
ឱ្យដឹងកិច្ចកលអធិប្បាយ
ចែកចាយកុំលាក់ឱ្យឡើងមក ។
អ្នកទាំងប៉ុន្មានបានដល់ផ្ទះ
ម្ដាយទាវអរណាស់ទើបរៀបស្លក
នំដាក់តុស្ដាន់វន្ដាន់យក
ឡើងមកលើផ្ទះសំពះសួរ ។

ថាយើងខ្ញុំមកដោយចិត្តស្ម័គ្រ ទទួលធុរៈគួរមិនគួរ
ទោះបីមោះហ្មងសូមលន់តួ ឆ្មើងជួដូចម្ដេចសូមមេត្តា ។
ត្បិតលោកចៅហ្វាយនូវអ្នកស្រី ទាំងពីរទាំងបីមានវាចា
ចាត់ប្រើយើងខ្ញុំនាំបណ្ណា ការមកប្រាថ្នាចងមេត្រី ។
ប្រៀបដូចថ្នល់ស្ពានឈានរត់ដើរ សុំស្ទើសុំស្ទាក់អ្នកថាអ្វី
ដណ្ដឹងកូនអ្នកត្បិតឮល្បី កូនស្រីស្ដីផ្ញើចំម៉ឺនងួន ។
នាងជាមេម៉ាយម្ដាយទាវស្ដាប់ ចំណាប់ចំណងត្រូវចិត្តជួន
ទទួលថាអើសរសើរខ្លួន អ្នកអើយច្បាប់ក្បួនកូនកបលក្ខណ៍ ។
វិស័យសព្វថ្ងៃលំបាកដែរ គេមកហួរហែដូចអត់អាក់
ប៉ុន្តែខ្ញុំថាកូនធុរៈ ញាតិផងប៉ងស្ម័គ្រមកច្រើនគ្នា ។
មិនដឹងទាន់ព្រមល្មមមេត្រី ឱ្យទៅមន្ត្រីរាស្ត្រប្រជា
ព្រោះតែយើងរាស្ត្រគួររាំងរា ឥឡូវទើបពារលើលោកធំ ។
ឧកញ៉ាអរជូនម្ជូនមាំពេក ធម្មតាក្រោមមេឃទាបជាងភ្នំ
មានឫទ្ធិអំណាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី ។
គួរហើយខ្ញុំសុំជម្រាបញាតិ ទៅសំពះបាទលោកប្រុសស្រី
ថាបើលោកចង់ចងមេត្រី គប្បីចាំខ្ញុំលបសួរកូន ។
នាងអ្នកស្ដាប់ជាក់ចាំរាល់ថ្ងៃ រួចលើកភស្តុភារជាជំនួន
ប្រគល់ម្ដាយទាវស្រេចអង្គុឱន លំទោនលើកប្រណិបតន៍លា ។
ចរចុះវិលទៅលំនៅស្ថាន ទាំងអស់ប៉ុន្មានចរលីលា
ឡើងប្ដឹងអរជូនជុំភរិយា ចាំជាបែបបទប្រាកដណាស់ ។
វេលាក្រោយនោះចំពោះជា ម្ដាយទាវម្ទីម្នាដូចអរណាស់
ឃើញនិភ័ស្តុផលថ្កល់តុថាស រហ័សរៀបចំសន្សំទុក ។
ហើយសួរទៅកូនថាមាសម្ដាយ សមយើងសប្បាយថ្លារីកមុខ
ម្ដាយឱ្យទៅកូនចៅហ្វាយស្រុក បានសុខដោយបុណ្យដោយបានថ្កើង ។
អំណាចខ្លួបខ្លាចមានស័ក្តិយស ចំពោះជាត្រូវបុណ្យកូនឡើង
ម្ដាយប្រាប់ប្រដៅកូនកុំឆ្មើង ចចេសចចើងណាថ្លៃម្ដាយ ។
ទាវឮម្ដាយប្រាប់ចាប់ចាំទុក ស្ទើរធ្លាក់ថ្លើមក្ដុកពុំរសាយ

ទើបមានវាចាថាម៉ែអាយ ខ្ញុំកូនដូចស្ដាយបាយចំណី ។
ថាបើម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី
លើកឱ្យគេទៅទោះពីរបី តាមម៉ែមេត្រីឱ្យថ្វីខ្ញុំ ។
ទទួលទទូចខូចការហើយ ខុសសោះហ៊ានឆ្លើយថាម៉ែកុំ
ម៉ែមានកូនគួររៀបផ្សំផ្គុំ ឃើញលោកបុណ្យធំលើកខ្ញុំឱ្យ ។
នាងម្ដាយចាំស្ដាប់ស័ព្ទទាវឆ្លើយ ប្រាប់ថាទាវអើយគួរបណ្ដោយ
បន្ទន់អន់អត់មើលមុខក្រោយ ធ្វើខ្សោយសិនចុះកុំផ្ទុញផ្ទាល់ ។
គិតក្រែងបែកបាក់ធ្លាក់ថ្លោះធ្លោយ ពងមាន់មកឱ្យមានអំពល់
ប្រមៀលត្រូវថ្មល្អិតគ្មានសល់ ហ៊ានទល់ផ្ទាល់ផ្ទុញសង្កុញខឹង ។
នែទាវទំនៀមព្រេងប្រៀបស្រាប់ ថាកូនមិនស្ដាប់ចចេសរឹង
លោកយកទាញមករកសន្លឹង របឹងរបាញសាញចណ្ដាល ។
មិនដែលសោះឡើយទាវអើយនំ ប្រឡើសបើសធំម្ដេចជាងនាឡិ
កូនគោកាចកៀចដោយព្រៃវាល រោលរាលឈឺខ្លួនជួនដល់ស្លាប់ ។

*(ដកស្រង់ចេញរឿង ទុំ ទាវ របស់ព្រះភិក្ខុសោម ១៩១៥ ទំព័រទី ៤៥)*

## សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងណា ? អ្នកនិពន្ធឈ្មោះអ្វី ? និពន្ធនៅឆ្នាំណា ?
២. តើក្នុងអត្ថបទគេចែកជាប៉ុន្មានគំនិតសំខាន់ ?
៣. ចូរអ្នកពន្យល់ឃ្លា "កូនគោកាចកៀច និងនំមិនធំជាងនាឡិ" ?
៤. តើអត្ថបទនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីទស្សនៈរៀបចំទុកដាក់កូនចៅ របស់ខ្មែរយើងសម័យមុន យ៉ាងដូចម្ដេចខ្លះ ?
៥. ចូរបង្ហាញរូបារម្មណ៍ ដែលប្រើក្នុងកំណាព្យនេះ ?
៦. ចូរអ្នកបកស្រាយគំនិតសំខាន់បង្កប់ ក្នុងវគ្គខាងក្រោម :
ថាបើម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី
លើកឱ្យគេទៅទោះពីរបី តាមម៉ែមេត្រីឱ្យថ្វីខ្ញុំ ។

# កំណាព្យបទទ្វេមាត្រ

កំណាព្យ គឺជាប្រភេទអក្សរសិល្ប៍ដែលមានជាយូរលង់ណាស់មកហើយក្នុងប្រវត្តិអក្សរសិល្ប៍មនុស្សជាតិ ។ កំណាព្យមានចំណាប់ចុងចួនត្រឹមត្រូវទៅតាមក្បួនខ្នាតនិងតាមចង្វាក់បទរបស់កំណាព្យ ។ អ្នកធ្លាប់សិក្សារួចមកហើយអំពីប្រភេទផ្សេងៗនៃបទកាព្យមូលដ្ឋានដូចជា បទកាកគតិ ព្រហ្មគីតិ ពំនោល បទពាក្យ ៧ ជាដើម ។ល ។ ឥឡូវនេះអ្នកនឹងសិក្សាបន្ថែមទៀតអំពីកំណាព្យបទទ្វេមាត្រ ។ ចូរពិនិត្យបទទ្វេមាត្រមួយចំនួនដូចខាងក្រោម :

ដូចម្ដេចដែលហៅថា បទទ្វេមាត្រ ? តើបទនេះមានលក្ខណៈខុសគ្នាពីបទមូលដ្ឋានដូចម្ដេចខ្លះ ?

## ១ . បទគោព័ន្ធស្លឹងពាក្យ៧

បទនេះមានរង្វាស់កាព្យ ចំណាប់ចួន ចង្វាក់ដូចបទពាក្យ៧ដែរ តែខុសពីបទពាក្យ៧ ត្រង់ប្រើពាក្យផ្ទួន : ***ឧទាហរណ៍ :***

ប្រាសាទអង្គរគ្រឹះជាតិខ្មែរ ខ្មែរយើងត្រូវតែថែឱ្យគង់
គង់កេរដំណែលតដៅពង្ស ពង្សយើងជាវង្សសាងប្រាង្គប្រា ។
ប្រាសាទរាប់ពាន់លោកសាងទុក ទុកតទៅមុខតាងសារតារ
ជាដាក់ដាប់ឆ្លាក់ល្អថ្លៃថ្លា ថ្លាថ្កើងអស្ចារ្យជូនតាយើង ។

*(ដកស្រង់ចេញពីសិល្បៈតែងកំណាព្យរបស់ លោក ពេជ្រទុំ ក្រវិលឆ្នាំ ១៩៨៨ ទំព័រទី ៦១)*




ព្យ ៧.ឃ.១.វ.១ |——| ព្យ ១.ឃ.២.វ.១
ព្យ ៧.ឃ.២.វ.១ |——| ព្យ ១.ឃ.៣.វ.១
ព្យ ៧.ឃ.៣.វ.១ |——| ព្យ ១.ឃ.៤.វ.១
ព្យ ៧.ឃ.៤.វ.១ |——| ព្យ ១.ឃ.១.វ.២

## ២ . បទអក្សរល្បួនពាក្យ៧

បទនេះមានរង្វាស់កាព្យ ចំណាប់ចួនដូចបទពាក្យ៧ដែរ តែប្លែកត្រង់នៅក្នុងឃ្លានីមួយៗគឺ បើកវីប្រើព្យញ្ជនៈណាមួយហើយ នោះត្រូវប្រើព្យញ្ជនៈនោះរហូតដល់ចប់ឃ្លា ដោយគ្រាន់តែផ្លាស់ប្តូរស្រៈនិងព្យញ្ជនៈប្រកបប៉ុណ្ណោះ ។ *ឧទាហរណ៍ :*

ចាស់ៗចូលចិត្តចេះចាត់ចែង ប្រឹងប្រែងប្រាយប្រាប់ប្រើប្រុសៗ
ដាស់ដីដឹកដៀវដាក់ដាំដុះ បកបុសបបេះបោកបែនបា ។
ស្រីៗស្រុកស្រែស្រុះស្រស់ស្រាយ កកេះកកាយកាន់កិច្ចការ
តូចៗតាក់តែងតាមតាតា បួតបេះបោចបាបានបែនបុក ។

*(ដកស្រង់ចេញពីសៀវភៅសិល្បៈតែងកំណាព្យ លោក ពេជ្រទុំ ក្រវិល ១៩៨៨)*

ច



ប



ដ



ប



## ៣ . បទសត្វកាងស្លាប

បទនេះមានរង្វាស់កាព្យចំណាប់ចួន និងចង្វាក់គោរពតាមបទពាក្យ៧ធម្មតា ប៉ុន្តែនៅក្នុងគ្រប់ឃ្លាទាំងអស់មានពាក្យដដែលពីដង ។ *ឧទាហរណ៍ :*

គិតជាតិ ជាតិគិតមិត្តមិនខាន ជាតិថ្កាន ថ្កានជាតិញាតិបានសុខ
ជាតិទុក្ខ ទុក្ខជាតិញាតិក្តួលក្តុក ចុកទ្រូង ទ្រូងចុកក្តុកក្តៅផ្សា ។
ជាតិបាត់ បាត់ជាតិញាតិអើយចាំ សុំផ្តាំ ផ្តាំសុំ កុំសង្កា
គ្មានសុខ សុខគ្មានហ៊ានសន្យា ខ្លោចផ្សា ផ្សាខ្លោចហោចរហួត ។

*(ដកស្រង់ចេញពីសៀវភៅសិល្បៈតែងកំណាព្យ លោក ពេជ្រទុំ ក្រវិល ១៩៨៨)*









ព្យ១ ≡ ព្យ៤
ព្យ២ ≡ ព្យ៣
ព្យ៤ ≡ ព្យ៥

ព្យ១ ≡ ព្យ៤
ព្យ២ ≡ ព្យ៣
ព្យ៤ ≡ ព្យ៥

## ៤ . បទឆត្របីជាន់ ពាក្យ៨

បទនេះមានរង្វាស់កាព្យ ចំណាប់ចួន ចង្វាក់ដូចបទពាក្យ៨ដែរ តែប្លែកត្រង់ប្រើការផ្ទួនពាក្យក្នុងឃ្លានីមួយៗដូចខាងក្រោម :

ខ្មែរអើយគួរធ្វើការគួរអើយខ្មែរ　　ក្រោកឆាប់ដេកដែរស្បើយដេកឆាប់ក្រោក

ដោកពេញស្រូវកុំអួតស្រូវពេញដោក　　ព្រួយក្រែងក្រោយស្រូវថោកក្រោយក្រែងព្រួយ ។

| | | |
|---|---|---|
| ព្យ ១.ឃ.១.វ.១ | ═══ | ព្យ ៨.ឃ.២.វ.១ |
| ព្យ ២.ឃ.១.វ.១ | ═══ | ព្យ ៧.ឃ.២.វ.១ |
| ព្យ ៣.ឃ.១.វ.១ | ═══ | ព្យ ៦.ឃ.២.វ.១ |

*កំណាព្យបទទ្វេមាត្រ គឺជាបទដែលកវីប្រើកាព្យមាត្រ២ ។ មួយជាកាព្យមាត្របទមូលដ្ឋាន ហើយបន្ថែម កាព្យមាត្រថ្មីមួយទៀតលើបទមូលដ្ឋានទាំងអស់នោះ ។*

### លំហាត់

១. ចូរអ្នកតែងកំណាព្យបទទ្វេមាត្រដូចខាងក្រោមនេះ ដោយបទនីមួយៗឱ្យបានពីរៗវគ្គ

- បទអក្សរលូនពាក្យ ៧
- បទសត្វកាងស្លាប
- បទឆត្របីជាន់ ។

២. ចូរអ្នកស្រាវជ្រាវរកកំណាព្យបទទ្វេមាត្រផ្សេងៗ ឱ្យបាន៦បទ ដោយបង្ហាញពីកាព្យមាត្រនៃបទទាំងនោះនូវ :

- ចំណាប់ចួន
- ផ្ទួន
- រណ្តំ

# កម្លាយដោយផ្នត់ដែក

ខ្មែរមានវិធីជាច្រើនក្នុងការបង្កើតពាក្យដូចជា វិធីកម្លាយ វិធីបន្សំ វិធីកម្ចី និងវិធីរណ្ដំ បរិវារស័ព្ទ ។ វិធីកម្លាយ គឺជាវិធីបង្កើតពាក្យដែលក្លាយមកពីពាក្យឫស ហើយបន្ថែមលើពាក្យឫសទាំងនោះនូវផ្នត់កម្លាយ ។ វិធីកម្លាយមានកម្លាយដោយផ្នត់ដើមនិងកម្លាយដោយផ្នត់ដែក ។

ផ្នត់ដែកមានបួនទម្រង់ :

- ផ្នត់ដែកទម្រង់ (-ព-)

  - កើយ > ខ្នើយ [ kaə:j ] > [ knaə:j ]
  - សែង > ស្នែង [ saɛ:ŋ ] > [ snaɛ:ŋ ]
  - លាយ > ល្បាយ [ li:əj ] > [ lba:j ]
  - លូន > ល្មូន [ lu:n ] > [ lmu:n ]

- ផ្នត់ដែកក្នុងទម្រង់ (-សព-)

  [-អំង-] [-អុំង-] [-អំញ-] [-អុំញ-] [-អំន-] [-អុំន-] [-អំម-] [-អុំម-]

  - ខ្វះ > កង្វះ [ kvah ] > [ kɒŋvah ]
  - ព្រាង > ពង្រាង [ pri:əŋ ] > [ pəŋri:əŋ ]
  - ផ្ញើ > បញ្ញើ [ pɲaə: ] > [ pɒɲɲaə: ]
  - ក្ដាប់ > កណ្ដាប់ [ kdap ] > [ kɒndap ]
  - ភ្លឺ > ពន្លឺ [ plɯ: ] > [ pənlɯ: ]
  - ក្ដៅ > កម្ដៅ [ kdau ] > [ kɒmdau ]
  - ជ្រាប > ជម្រាប [ cri:ep ] > [ cumri:ep ]

- ផ្នត់ដែកក្នុងទម្រង់ (-ស/ព-)

  [-អ៊ុ/ន-] [-អ៊ុ/ប-]

  - រុក > រនុក [ ruk ] > [ rənuk ]
  - រៀន > របៀន [ ri:en ] > [ rəbi:en ]
  - លេង > ល្បែង [ le:ŋ ] > [ lbaɛ:ŋ ]
  - លើក > ល្បើក [ lə̆:k ] > [ lbaə:k ]

- ផ្នត់ជែកក្នុងទម្រង់ (-សព/ព-)

[-អំម/ន-] និង [-អ៊ំម/ន-]

- កើត > កំណើត [ kaə:t ] > [ kɒmnaə:t ]
- ចោទ > ចំណោទ [ cao:t ] > [ cɒmnao:t ]
- គិត > គំនិត [ kit ] > [ kumnit ]
- ទួញ > ទំនួញ [ tu:əɲ ] > [ tumnu:əɲ ]

ដូចនេះយើងឃើញថា ពាក្យក្លាយខាងលើ កើតឡើងពីពាក្យឫសដែលមានផ្នត់កម្លាយនៅកណ្ដាល ។ ពាក្យក្លាយទាំងនោះ កើតឡើងតាមទម្រង់ផ្សេងៗគ្នា ។

*ផ្នត់ជែក គឺជាផ្នត់កម្លាយដែលជ្រែកនៅកណ្ដាលពាក្យឫស ដើម្បីបង្កើតពាក្យក្លាយ ។*

## លំហាត់

១. ចូរអ្នករកពាក្យក្លាយដែលកើតឡើងពីពាក្យឫស ខាងក្រោមនេះដោយបង្ហាញទម្រង់ផង : លង រាប រាំង លាយ ត្រាយ គិត សោក ។

២. ចូរអ្នកស្វែងរកពាក្យឫសនៃពាក្យក្លាយខាងក្រោម ដោយប្រាប់ពីទម្រង់ផង :

ក. ចំណែក ល្បែង រនាស់ ស្នូម ជម្រាប សម្ល ខ្នើត កំទេច របើស ។

ខ. [...]ឧកញ៉ាអរជូនមួនមាំពេក ធម្មតាក្រោមមេឃទាបជាងភ្នំ
មានឫទ្ធិអំណាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី ។
គួរហើយខ្ញុំសុំជម្រាបញាតិ ទៅសំពះបាទលោកប្រុសស្រី
ថាបើលោកចង់ចងមេត្រី គប្បីចាំខ្ញុំលបសួរកូន ។
នាងអ្នកស្ដាប់ជាក់ចាំរាល់ថ្ងៃ រួចលើកភស្ដុភារជាជំនូន
ប្រគល់ម្ដាយទាវស្រេចអង្គឱន លំទោនលើកប្រណិបតន៍លា ។ [...]



# ប្រពៃណីនៅពេលកើត



## ក. សិក្សាពាក្យគន្លឹះ

- សូរ្យគ្រាស (ន) : ដំណើរបាំងពន្លឺព្រះអាទិត្យ ស្រមោលផែនដីបាំងពន្លឺព្រះអាទិត្យ ។
- ចន្ទគ្រាស (ន) : ដំណើរបាំងពន្លឺព្រះចន្ទ ស្រមោលផែនដីបាំងព្រះចន្ទ ។
- មហិទ្ធិរិទ្ធិ (ន) : រិទ្ធិអំណាច កម្លាំង ។
- រាហូឬរាហ៊ុ (ន) : ឈ្មោះទេវតាព្រះគ្រោះទី៨ ក្នុងចំណោមពួកទេវតានព្វគ្រោះ មានអម្ពរ(សម្លៀកបំពាក់) និងពាហនៈសុទ្ធតែខ្មៅដែលជាសត្រូវតែងគ្របបាំងចាប់ឬលេបព្រះអាទិត្យនិងព្រះចន្ទ រាហ៊ុចាប់ចន្ទ ។
- ត្រណម (ន) : ដំណើរដែលតម ដំណើរមិនប្រព្រឹត្ត ។ ឧទាហរណ៍ តមស្រា តមខ្លាញ់ជ្រូក តមនិយាយស្ដី ... ។
- រណ្ដាប់ (ន) : វត្ថុសម្រាប់ធ្វើទាន វត្ថុជាគ្រឿងបូជាឬទេយ្យទាន ទ្រនឹបគ្រូ ... ។
- ពិធីទម្លាក់ចង្ក្រាន (ន) : ពិធីមួយដែលគេធ្វើឡើងនៅពេលដែលស្ត្រីមានកូនខ្ចីត្រូវបានបញ្ចប់ការអាំងភ្លើង ។

ខ្មែរយើងកាលពីដើមសម័យបុរាណ ហើយបន្តមកសម័យបច្ចុប្បន្នអ្នកខ្លះនៅពេលសម្រាលកូនខ្ចី គឺម្ដាយនិងកូនខ្ចីត្រូវអាំងភ្លើងដើម្បីឱ្យឆ្អិនសរសៃមានសុខភាពមាំមួនវិញ (តាមវេជ្ជសាស្ត្របច្ចុប្បន្នគេចាក់ថ្នាំ) ។

- ពិធីសុំខមាទោស (ន) : ពីធីសុំអធ្យាស្រ័យ សុំអរគុណចំពោះឆ្មប (អ្នកបង្កើតកូន)ដែលខិតខំជួយបង្កើតកូនឱ្យ ។
- ជញ្ជាត់ព្រលឹង (កិ) : ហៅ អន្ទងព្រលឹង ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគួរយកចិត្តទុកដាក់លើខ្លឹមសារនៃអត្ថបទដើម្បីឆ្លើយនឹងសំណួរដែលទាក់ទងនឹងខ្លឹមសារអត្ថបទ និងតម្លៃអប់រំរបស់អត្ថបទ ។

## គ. អត្ថបទ

ជនជាតិខ្មែរយើងមានជំនឿ ប្រពៃណីសម្បូរបែបណាស់តាំងពីបុរាណកាលមកម្ល៉េះ ។ ជំនឿទំនៀមទម្លាប់មួយចំនួនធំត្រូវបានជនជាតិខ្មែរយើងគោរពនិងប្រតិបត្តិរហូតមកដល់បច្ចុប្បន្ននេះ ។ ព្រឹត្តិការណ៍សំខាន់ៗចំនួនបីរបស់ជីវិតមនុស្សម្នាក់ៗ គឺពេលកើត ពេលរៀបអាពាហ៍ពិពាហ៍ និងពេលស្លាប់ដែលក្នុងនោះមានបង្កប់ជំនឿ ប្រពៃណី ទំនៀមទម្លាប់របស់ខ្មែរយើងយ៉ាងច្រើន ។

*មុនពេលកើត :* ដើម្បីរក្សាគភ៌ឱ្យបានគង់វង្សល្អ និងឆ្លងទន្លេបានរហ័ស ស្ត្រីម្ដាយតែងដើរតាមគន្លងប្រពៃណីបុរាណដោយត្រណមជាច្រើនដូចជា

- មិនត្រូវបរិភោគអាហារមានរសជាតិហឹរនាំឱ្យក្រហល់ក្រហាយដល់កូនក្នុងផ្ទៃ
- មិនត្រូវស្លៀកពាក់តឹងពេកនាំឱ្យចង្អៀតចង្អល់ដល់កូនក្នុងផ្ទៃ
- មិនត្រូវឈោងយករបស់ដែលនៅខ្ពស់ផុតពីដៃនាំឱ្យរបូតទងសុកពីមាត់កូន
- មិនត្រូវបរិភោគបបរនាំឱ្យកូនកើតមកមិនស្អាត (មិនជ្រះ)
- បើមានសូរ្យគ្រាស ឬចន្ទគ្រាសត្រូវយកកំបោរមកលាបលើផ្ទៃពោះដើម្បីជួយសង្កត់ទារកនៅក្នុងផ្ទៃកុំឱ្យមានការភ្ញាក់ផ្អើលនឹងមហិទ្ធិរិទ្ធិរាហូ បើមិនបានធ្វើបែបនេះទេ កូនកើតមកទៅជាល្ងីល្ងើមិនគ្រប់ដប់ (អ្នកខ្លះហៅថាកូនគ្រាសកន្លង) ។

ក្រៅពីត្រណមដែលទាក់ទងនឹងសុខភាពម្ដាយនិងកូននៅមានត្រណមច្រើនបែបយ៉ាងទៀតដែលទាក់ទងដល់ការកើតកូនបានយ៉ាងរហ័សស្រួលធម្មតារបស់ស្ត្រីជាម្ដាយដូចជា

- មិនត្រូវដេកថ្ងៃ ងូតទឹកយប់នាំឱ្យកូនថ្លោសពិបាកកើត
- មិនត្រូវអង្គុយនៅមាត់ទ្វារ ឬមាត់ជណ្ដើរខ្លាចកូនកើតមិនរួច
- មិនត្រូវដេកដំអក់ ត្រូវរហ័សរហួនក្រោកមុនប្ដី ទើបឱ្យកូនកើតបានស្រួល
- លើសពីនេះគេត្រូវរកថ្នាំជាជំនួយឱ្យសម្រាលកូនបានរហ័សទុកស្ងោរផឹកនៅពេលជិតគ្រប់ខែ ។

ក្នុងពេលឆ្លងទន្លេនិងក្រោយពេលឆ្លងទន្លេត្រូវមានអុសឬធ្យូងថ្នាំសង្កូវស្ងោរឬត្រាំស្រា រណ្ដាប់សម្រាប់រៀបចំពិធីផ្សេងៗដូចជា ស្រូវពន្លៃ (ស្រូវមួយល្អីដែលគេដាក់ជូនឆ្មបនៅពេលបង្កក់កូនខ្ចី) ទៀន ធូប ក្រមួនសុទ្ធជាដើម ។

*ពេលកើត* : នៅពេលឈឺពោះដំបូងបុរសជាប្តី ឬជាឪពុក ឬជាបងប្អូនត្រូវរត់ទៅតាមយាយហ្មបដែលនៅក្នុងភូមិឬជិតឆ្ងាយឱ្យមកជួយសម្រាលកូន ។ សូមបញ្ជាក់ថា ឆ្មបនៅសម័យមុនពុំបានរៀនសូត្រខាងវិជ្ជាឆ្មបដូចសម័យនេះទេ គឺគ្រាន់តែចេះដឹងតៗគ្នាតាមរបៀបអ្នកស្រុក ។

នៅតំបន់ខ្លះ ក្នុងពេលឈឺពោះ គេរៀបពិធីបន់ស្រន់មួយដល់វត្ថុសក្តិសិទ្ធិ ឬអ្នកដូនអ្នកតាសុំឱ្យការឆ្លងទន្លេប្រព្រឹត្តទៅដោយសុខសប្បាយកុំបីជួបប្រទះនឹងគ្រោះថ្នាក់ ឬឧបសគ្គណាមួយឡើយ ។

*ក្រោយពេលកើត* : លុះឆ្លងទន្លេរួចហើយ ស្ត្រីជាម្តាយនិយមអាំងភ្លើងចំនួន៣ថ្ងៃ ឬមួយអាទិត្យ (បើកូនដំបូង) ។ ដោយមានជំនឿថា ខ្លាចក្រែងមានខ្មោចព្រាយមកបៀតបៀនដល់ម្តាយ និងកូនខ្ចី អាចារ្យបានសូត្រមន្តអាគមព័ទ្ធអំបោះនៅជុំវិញ(ព័ទ្ធសីមា) ។ គេអាចអួសខ្វែងនៅលើសសរដោយកំបោរ ឬបិទខ្វែងដោយក្រមួនសុទ្ធក៏បាន ។ ជួនកាលគេយកកាំបិត ឬកន្ត្រៃទៅដាក់លើក្បាលដំណេកកូនខ្ចីនោះថែមទៀត ។ ក្រៅពីនេះមានត្រណមចំពោះអ្នកអាំងភ្លើងមិនឱ្យក្រោកពីដំណេកនិយាយឆ្លើយឆ្លងជាមួយភ្ញៀវ ឬញាតិមិត្តដែលមកសាកសួរនោះទេ ប៉ុន្តែគេអាចនិយាយទាក់ទងជាមួយអ្នកថែរក្សាភ្លើងបានគ្រប់យ៉ាង ។ លុះថ្ងៃទម្លាក់ចង្ក្រានទើបផុតថ្ងៃត្រណម ។

មានពិធីមួយទៀតប្រព្រឹត្តឡើងពេលទម្លាក់ចង្ក្រាន ។ ឆ្មបបានប្រារព្ធពិធីនេះដោយពូតបាយជាបួនពំនូតដាក់លើស្លឹកចេក ហើយសូត្របន់ស្រន់ដល់ព្រះធរណីនិងមេបាសុំឱ្យជួយការពារម្តាយនិងកូនខ្ចីនោះ រួចហើយក៏បានបោះពំនូតបាយទៅដី ព្រមទាំងសូត្រអង្វរខ្មោចព្រាយបិសាចកុំឱ្យមកយាយី ។ លុះចប់ពិធីនេះហើយភ្លើងចង្ក្រានក៏ត្រូវពន្លត់ទៅវិញដោយអ្នកដែលបានបង្កាត់ភ្លើងពីដំបូង ។ ជាទូទៅស្ត្រីម្តាយអាចឱ្យកូនបន្តអាំងភ្លើងទៅទៀតក៏បានដែរ ។

នៅពេលបន្ទាប់ ស្ត្រីម្តាយក៏បានប្រារព្ធពិធីជូនរង្វាន់ និងពិធីសុំខមាទោសចំពោះឆ្មប ដែលបាននឿយហត់ និងលំបាកផ្សេងៗនៅពេលឆ្លងទន្លេ ។ នៅតំបន់ខ្លះបុរសជាប្តីក៏បានចូលរួមជាមួយភរិយាដែរ ។ ប្រសិនបើគេមិនបានបំពេញការសុំខមាទោស គេមានជំនឿថា ស្ត្រីជាម្តាយនឹងត្រូវទទួលទណ្ឌកម្មនៅជាតិខាងមុខៗទៀត ដោយត្រូវទូលកន្ទេលរត់តាមសុំទោសឆ្មប ហើយឆ្មបនោះមិនទាំងងាកមើលនិងឆ្លើយតបមកវិញផង ។ បន្ទាប់មកទៀត តាមទំនៀមទម្លាប់គ្រួសារ ឪពុកទារកត្រូវយកសុកទៅកប់ ឬទៅដុតឬដាក់លើប្រគាបឈើដោយជ្រើសរើសនូវទិសណាមួយល្អ ។ នៅថ្ងៃដដែលនោះមានពិធីផ្សេងៗជាច្រើនទៀតត្រូវបានប្រារព្ធឡើងដើម្បីប្រកក់ប្រសិទ្ធិ៍ដល់ទារក ។ គេដាក់ទារកនៅចំកណ្តាលបន្ទប់ក្បែរម្តាយបែរទៅរកទិសខាងកើត ។ នៅចុងជើងទារក មានស្រូវពន្លៃនិងថាសតង្វាយដូចជាថាសម្ហូប ថាសស្លៀកបំពាក់ និងគ្រឿងអលង្ការជាដើម ។

ឆ្មបចាប់ផ្ដើមដោយអុជទៀនធូបអញ្ជើញព្រះធរណី ដើម្បីឱ្យព្រះអង្គជួយទារកឱ្យបានជោគជ័យគ្រប់ប្រការទៅអនាគត រួចហើយឆ្មបនោះយកទឹកខ្មៅចិនដែលលាយនឹងទឹកដោះម្ដាយ ឬស្រាទៅលាបចិញ្ចើមនិងសុកទារក ។ ពិធីនេះហៅថា ពិធីបើកភ្នែក ។ បន្ទាប់មក គេធ្វើពិធីកាត់សក់ព្រៃ គឺកាត់បន្តិចនៅលើបង្ហើយដាក់នៅក្នុងកូនកន្ទោងមួយដែលគេបន្ថែមម្ជូបចំណី និងច្រូចស្រាបន្តិចរួចគេយកកន្ទោងនោះចេញទៅក្រៅសម្រាប់ថ្វាយដល់ព្រះធរណី ។ តមកទៀត ទើបដល់ពិធីហៅព្រលឹង ឬជញ្ជាត់ព្រលឹង ចំពោះទារកដែលទើបនឹងកើតថ្មីៗ ក៏គេប្រារព្ធពិធីនេះដែរ ។ ដំបូងគេយកចិញ្ចៀនមាសមួយវង់ចងអំបោះនៅហើយសំបូងសង្រូងហៅព្រលឹង ១៩ ឱ្យលែងនៅក្នុងព្រៃទៅ ហើយមកថែរក្សាខ្លួនទារកនោះវិញ រួចហើយគេក៏ចងចិញ្ចៀនដែលតំណាងនេះទៅនឹងកដៃទារកម្ខាង កដៃម្ខាងទៀតគេចងអំបោះនៅ ។ បន្ទាប់មកទៀត ទើបគេធ្វើពិធីបង្វិលពពិល (ពិធីនេះគេមិនសូវនិយមធ្វើទេ) ។

ក្រៅពីបានធ្វើពិធីហៅព្រលឹងរួចហើយ គេយកពន្លៃបិទត្រង់បង្ហើយរបស់ទារកហើយគេផ្លាស់ប្ដូររាល់ថ្ងៃ ។ គេបិទពន្លៃនេះមានរយៈពេលរហូតដល់ទារកមានអាយុ ៧ឬ៨ខែ ។

នៅទីបញ្ចប់ឆ្មបដែលជាអ្នកដឹកនាំពិធីក៏បានអុជទៀនធូបដោតទៅលើតង្វាយផ្សេងៗ ហើយអញ្ជើញអស់ដូនតាឱ្យមកទទួលតង្វាយនេះ ហើយប្រសិទ្ធពរដល់កូនចៅ ។ ឪពុកម្ដាយ បងប្អូន មិត្តភក្ដិចូលម្នាក់ម្ដងៗទៅប្រោះព្រំឱ្យពរជ័យដល់ទារកនិងចងដៃទារកតាមធនធានដែលខ្លួនមាន ។

*(ដកស្រង់និងកែសម្រួលពីឯកសារអរិយធម៌ខ្មែរ របស់លោកស្រី ត្រឹង ងា ឆ្នាំ១៩៧៤ ទំព័រ ១៦៩-១៧៤)*

## សំណួរ

១. តើប្រពៃណីនៅពេលកើតចែកជាប៉ុន្មានដំណាក់ ?

២. តើស្ត្រីដែលមានផ្ទៃពោះត្រូវប្រកាន់ត្រណមដូចម្ដេចខ្លះមុនពេលកើត ?

៣. តើគេធ្វើអ្វីខ្លះនៅពេលកើត ?

៤. តាមរយៈអត្ថបទអំណាននេះ ចូរប្រាប់ពិធីមួយចំនួនដែលខ្មែរយើងតែងតែប្រារព្ធឡើងនៅដំណាក់ក្រោយពេលកើត ។

៥. តាមការសង្កេតរបស់អ្នក តើពិធីទាំងប៉ុន្មានក្រោយពេលកើត តើមានពិធីណាខ្លះ ដែលបាត់បង់ ហើយពិធីណាខ្លះដែលខ្មែរយើងបន្តប្រតិបត្តិរហូតដល់បច្ចុប្បន្ន ?

៦. ការសម្រាលកូន (កើត) តាមបែបបុរាណនិងសម័យបច្ចុប្បន្ន តើមួយណាមានសុវត្ថិភាពជាង ? ហេតុអ្វី ?



# ជំនឿ



អ្នកបានសិក្សារួចហើយពីប្រពៃណី ទំនៀមទម្លាប់មួយចំនួនរបស់ខ្មែរយើង ។ ឥឡូវនេះអ្នកត្រូវយកចិត្តទុកដាក់ស្ដាប់អត្ថបទស្ដីពីជំនឿមួយចំនួនរបស់ខ្មែរយើង ដើម្បីត្រៀមឆ្លើយនឹងសំណួរខាងក្រោម ៖

## សំណួរ

១. ក្នុងអត្ថបទនេះបង្ហាញពីប្រភពជំនឿដូចម្ដេច ?

២. ចូរបង្ហាញពីការប្រតិបត្តិជំនឿរបស់ខ្មែរយើងទៅលើព្រលឹងម្ដាយឪពុក ។

៣. ចូរអ្នករៀបរាប់ពីជំនឿផ្សេងៗទៀតរបស់ខ្មែរយើង ។

៤. ក្នុងចំណោមជំនឿទាំងឡាយរបស់ខ្មែរ តើអ្នកគោរពនិងប្រតិបត្តិជំនឿណាខ្លះ ? ព្រោះអ្វី ?

៥. ចូរអ្នកបញ្ចេញមតិផ្ទាល់ខ្លួន តើការងប់ងុលនឹងជំនឿផ្សេងៗដោយមិនបានគិតពិចារណា នាំឱ្យមានគុណវិបត្តិឬទេ ? ហេតុអ្វី ?

# ការបញ្ចេញមតិ

អ្នកបានសិក្សារួចហើយពីការបញ្ចេញមតិ ។ ការបញ្ចេញមតិ គឺជាការបង្ហាញពីការយល់ឃើញ គំនិត យោបល់ ទស្សនៈ ដើម្បីគាំទ្រ ឬជំទាស់ទៅលើមតិ យោបល់ គំនិត ទស្សនៈ សកម្មភាព ឬទង្វើផ្សេងៗ ហើយឈានទៅដល់ការវិនិច្ឆ័យនិងវាយតម្លៃ ។ ខាងក្រោមនេះ ជាការបញ្ចេញមតិមួយទៅលើបញ្ហាជំនឿ ៖

ការជឿទៅលើជំនឿផ្សេងៗជាសិទ្ធិបុគ្គលម្នាក់ៗ ។ ជំនឿមានច្រើនយ៉ាងដូចជា ការជឿទៅលើមនោគមវិជ្ជា នយោបាយ ជំនឿអរូបីផ្សេងៗ ដែលមានជាអាទិ ជំនឿទៅលើអ្នកតា ខ្មោចព្រាយ បិសាច វត្ថុសក្ដិសិទ្ធិ មន្តអាគមគាថា ។ល ។ ជនជាតិខ្មែរយើងមានជំនឿច្រើនណាស់រាប់ទាំងជំនឿអរូបីផង ។ ប្រជាជនយើងខ្លះមានជំនឿយ៉ាងងប់ងល់ទៅលើបញ្ហាអ្វីមួយដោយមិនបានគិតពិចារណាឱ្យច្បាស់លាស់ល្អិតល្អន់ឡើយ ។ ការណ៍នេះ ជាឱកាសផ្ដល់ឱ្យជនខិលខូចមួយចំនួនតូចឆ្លៀតកេងបន្លំបោកប្រាស់អ្នកទាំងនោះដើម្បីផលប្រយោជន៍របស់ពួកគេ ។

អ្នកខ្លះមានជំនឿទៅលើការយល់សប្ដិហួសហេតុ ហើយយកការយល់សប្ដិមកធ្វើជាការពិតទៅប្រព្រឹត្តអំពើផ្សេងៗដូចជាល្បែងភ្នាល់ ចាក់ឆ្នោត ឬទៅប្រព្រឹត្តអំពើអបាយមុខផ្សេងៗខុសច្បាប់ដែលនាំឱ្យខ្លួនឯង គ្រួសារ និងសង្គមជួបនឹងមហន្តរាយ ។

អ្នកខ្លះទៀតបានយកប្រពៃណីដ៏ល្អផូរផង់របស់ខ្មែរយើង ធ្វើជាមធ្យោបាយដើម្បីរកប្រយោជន៍ ឬលាភសក្ការៈ ឬបិទបាំងអំពើអាក្រក់របស់ខ្លួន ។

ដូចនេះ ដើម្បីចៀសវាងការខាតបង់ផលប្រយោជន៍និងចៀសផុតពីមហន្តរាយផ្សេងៗដល់ខ្លួនឯង គ្រួសារ និងសង្គមជាតិ មុននឹងធ្វើអ្វីមួយ ឬជឿលើអ្វីមួយ ឬក៏ជឿនរណាម្នាក់ យើងត្រូវពិចារណា ស្វែងយល់ឱ្យបានច្បាស់លាស់ជាមុនសិន ។

## សំណួរ

១. តាមមតិខាងលើ តើជំនឿមានអ្វីខ្លះ ?

២. តាមមតិខាងលើ តើការងប់ងល់នឹងជំនឿអ្វីមួយ ដោយមិនបានពិចារណាឱ្យបានច្បាស់លាស់ ផ្ដល់ឱកាសដូចម្ដេចខ្លះដល់ជនខិលខូច ?

៣. តើអ្នកខ្លះយកជំនឿលើការយល់សប្ដិទៅប្រព្រឹត្តអំពើអ្វីខ្លះ ?

៤. តើជនខិលខូចឆ្លៀតឱកាសនោះធ្វើអ្វីខ្លះ ?

៥. តើចុងបញ្ចប់នៃមតិនេះផ្ដល់ការអប់រំដូចម្ដេចខ្លះ ?

## លំហាត់

ចូរអ្នកបញ្ចេញមតិផ្ទាល់ខ្លួនទៅលើ ៖

១. ការយល់សប្តិ

២. ការជីងជាតិរបស់មនុស្ស ។

៣. គ្រូទស្សន៍ទាយ ។

នៅពេលអ្នកបញ្ចេញមតិ អ្នកត្រូវអនុវត្តទៅតាមគម្រោងខាងក្រោម ៖

### ក. សេចក្តីផ្តើម

យោបល់ទូទៅទាក់ទងនឹងប្រធានបទ ។

### ខ. តួសេចក្តី

- បង្ហាញគំនិតផ្ទាល់ខ្លួនក្នុងការគាំទ្រ ឬជំទាស់ទៅនឹងគំនិតរបស់ប្រធានបទ
- បង្ហាញអំណះអំណាងដើម្បីគាំទ្រមតិរបស់ខ្លួន
- សរុបមតិឬគំនិតរបស់ខ្លួនឡើងវិញ ដោយប្រកាន់ជំហរច្បាស់លាស់ ។

### គ. សេចក្តីបញ្ចប់

- វាយតម្លៃគំនិតរបស់ប្រធានបទ
- ចំណាប់អារម្មណ៍ផ្ទាល់ខ្លួនចំពោះប្រធានបទ ។

នៅពេលអ្នកចង់បញ្ចេញមតិបង្ហាញពីគំនិតឬការយល់ឃើញរបស់ខ្លួនអ្នកគប្បី :

- សុំការអនុញ្ញាតបញ្ចេញមតិ
- រង់ចាំដល់វេនរបស់ខ្លួន
- យកចិត្តទុកដាក់ស្តាប់យោបល់អ្នកដទៃនៅចន្លោះពេលរង់ចាំវេនរបស់ខ្លួន
- ប្រើសំដីសមរម្យគ្រប់ស្ថានភាព (គាំទ្រ ឬ ជំទាស់ ...)
- ផ្តល់យោបល់ក្នុងន័យស្ថាបនា អភិវឌ្ឍន៍ និងសាមគ្គីភាព ។

# ការតែងកំណាព្យ

អ្នកបានសិក្សារួចហើយពីកំណាព្យបទទ្វេមាត្រ និង ប្រភេទមួយចំនួននៃកំណាព្យនេះ។ តើកំណាព្យបទទ្វេមាត្រជាកំណាព្យដូចម្ដេច ? កំណាព្យបទទ្វេមាត្រ គឺជាកំណាព្យដែលកវីប្រើកាព្យមាត្រពីរ គឺកាព្យមាត្របទមូលដ្ឋាននិងបន្ថែមកាព្យមាត្រថ្មីមួយទៀតលើកាព្យមាត្រមូលដ្ឋាន ។

កំណាព្យបទទ្វេមាត្រមានច្រើនប្រភេទ ហើយប្រែប្រួលទៅតាមបទមូលដ្ឋាន ដូចជា បទគោព័ទ្ធស្ទឹងពាក្យ ៧ បទអក្សរលួនពាក្យ ៧ បទឆត្របីជាន់ពាក្យ ៨ បទសត្វកាងស្លាប ... ។

ឥឡូវនេះចូរអ្នកតែងកំណាព្យបទគោព័ទ្ធស្ទឹងពាក្យ៧ឱ្យបាន៥វគ្គយ៉ាងតិចដោយផ្ដោតលើប្រធានបទទាក់ទងនឹង

- ពិធីបុណ្យប្រពៃណីរបស់ខ្មែរ
- ជំនឿផ្សេងៗ
- ប្រពៃណី ទំនៀមទម្លាប់ខ្មែរមួយចំនួន ។

ពេលសរសេរអ្នកគប្បីអនុវត្តតាមការណែនាំខាងក្រោម ៖

## ក. ទម្រង់ (ក្បួនតែង)

១. កំណាព្យមូលដ្ឋានបទពាក្យ៧

១វ=៤ឃ

១ឃ=៧ព្យ

- ចួនក្នុងវគ្គ :

ព្យ ៧.ឃ.១.វ.១ ═ ព្យ ២ឬ៤.ឃ.២.វ.១

ព្យ ៧.ឃ.៣.វ.១ ═ ព្យ ២ឬ៤.ឃ.៤.វ.១ ។

- ចួនឆ្លងវគ្គ:

ព្យ ៧.ឃ.៤.វ.១ ═ ព្យ ៧.ឃ.២.វ.២ ═ ព្យ ៧.ឃ.៣.វ.២ ═ ព្យ ២ឬ៤.ឃ.៤.វ.២

២. កំណាព្យបទទ្វេមាត្រគោព័ទ្ធស្ទឹងពាក្យ៧ បន្ថែមលើបទពាក្យ៧មូលដ្ឋាននូវ ៖

ព្យ ៧.ឃ.១.វ.១ ═ ព្យ ១.ឃ.២.វ.១

ព្យ ៧.ឃ.២.វ.១ ═ ព្យ ១.ឃ.៣.វ.១

ព្យ ៧.ឃ.៣.វ.១ ═ ព្យ ១.ឃ.៤.វ.១

ព្យ ៧.ឃ.៤.វ.១ ═ ព្យ ១.ឃ.១.វ.២

គំនូសតាងកំណាព្យបទទ្វេមាត្រ




## ខ. ខ្លឹមសារ

ខ្លឹមសារកំណាព្យផ្ដោតលើប្រធានបទខាងលើ ដោយសម្ដែងឱ្យឃើញស្ថានភាពទូទៅ ការប្រតិបត្តិ ចំណាប់អារម្មណ៍ផ្ទាល់ខ្លួនក្នុងន័យស្ថាបនា អភិវឌ្ឍន៍ និងមោទនភាពជាតិ ។

## គ. ការណែនាំ

- សរសេរព្រាងនិងប្រមូលគំនិតសំខាន់ៗដែលទាក់ទងនឹងប្រធានបទ ។
- តាក់តែងរៀបចំគំនិតទៅតាមលំដាប់លំដោយ (មុន ក្រោយ) ឱ្យទៅជាអត្ថបទកាព្យទ្វេមាត្រ បទគោព័ទ្ធស្នឹងពាក្យ ៧ ។
- កែលំអឡើងវិញដោយពិនិត្យទៅលើ :
  - ខ្លឹមសារ
  - ពាក្យពេចន៍
  - ឃ្លាល្បះ
  - ក្បួនតែងកាព្យ

មេរៀនទី ៣

# សេចក្ដីក្លាហាន



ការហ៊ានពុះពារ តស៊ូ ជំនះគ្រប់ឧបសគ្គ មិនខ្លាចគ្រោះថ្នាក់កើតចេញពីសេចក្ដីក្លាហាន ។ សេចក្ដីក្លាហានកើតចេញពីឧត្ដមគតិផ្ទាល់របស់បុគ្គលម្នាក់ៗ ហើយជំរុញឱ្យមានការលះបង់ដើម្បីឧត្ដមប្រយោជន៍ផ្សេងៗ ។ សេចក្ដីក្លាហាន ជាកត្តាជំរុញឱ្យមានជ័យជំនះ ។

ក្នុងមេរៀននេះ អ្នកបានសិក្សាពីអត្ថបទដែលបង្ហាញពីសេចក្ដីក្លាហានរបស់ពលរដ្ឋខ្មែរយើងដើម្បីបុព្វហេតុមាតុភូមិរបស់ខ្លួន ។ ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពី មូលបញ្ហា កាលអាកាស វិភាគតួអង្គ តម្លៃអប់រំ ការបន្លឺសំឡេង ការសង្ខេបអត្ថបទ និងសំណេរវិភាគអត្ថបទ ។

 ## យប់មួយនៅភូមិក្រាំងលាវ



### ក. សិក្សាពាក្យគន្លឹះ

- ថ្ពក (គុ.ឬគុ.កិ) : ប្រសប់ ស្ទាត់ដោយធ្លាប់ ។
- ប្រមាថ (ន.សំ) : ការមើលងាយគេ ការបៀតបៀនគេ ការញាំញីគេ ការធ្វើទុក្ខបុកម្នេញឱ្យគេលំបាក ការមើលងាយគេ ។
- ស្ពុង (គុ.កិ) : ដែលឃើញទទុងព្រិលៗមិនច្បាស់ ។
- សាក (កិ) : ល្បងមើលឱ្យដឹង ពិសោធមើល ។
- ព្យាបាទ (ន) : ដំណើរចងចិត្តនឹងធ្វើអ្នកដទៃឱ្យវិនាស សេចក្ដីគុំកួន គំនុំ ។
- កំរោល (ន) : អាការៈងងឹតមុខជ្រប់ ឬងងឹតមុខខ្លាំងដល់ដួលដេក ដោយហេតុឃើញវត្ថុគួរឱ្យខ្លាច អាការៈប្លែកៗមិនដឹងខុសត្រូវ ... ។
- ពន្ធដារ (ន) : សួយអាករគ្រប់មុខ ដែលប្រជានិករត្រូវបង់តាមកំណត់ ។
- បំពង់ប៉ុយ (ន) : វត្ថុមានរាងបំពង់មានប្រហោងខាងក្នុងគេដាក់សំឡីឬប្រឆេះសម្រាប់កេះបង្កើតជាភ្លើង ។

- ភូមិក្រាំងលាវ(ន) : ជាឈ្មោះភូមិមួយនៅស្រុករលៀប្អៀរ ខេត្តកំពង់ឆ្នាំង តែនៅក្នុងរវាងឆ្នាំ ១៩២៥ ត្រូវអាណានិគមនិយមបារាំងដាក់ទោសប្ដូរឈ្មោះទៅជាភូមិតិរច្ឆាន លុះរវាងឆ្នាំ ១៩២៦ ក៏កែប្រែជាភូមិក្រាំងលាវវិញ ។
- ប្រមាណ (ន) : ការរាប់ ការស្ទង់ គ្នេរ ស្មាន ចំនួន ពាក្យសេចក្ដីដែលគួររាប់ គួរយកជាការពិតបាន ការកំណត់ ឬស្ទង់ដំណើរ ។
- អង្គញ់ ឈូង លោតអន្ទាក់ ចាប់កូនមាន់ (ន): ល្បែងប្រជាប្រិយខ្មែរ គេតែងនិយមលេងក្នុងពិធីបុណ្យចូលឆ្នាំជាប្រពៃណីខ្មែរ ។
- គុន (ន) : ឈ្មោះសិល្បខាងគ្រឿងអាវុធ សម្រាប់ចូលប្រឡូកលោតហក់តយុទ្ធផ្ទាល់ខ្លួន ជាចំណេះវិសេសម្យ៉ាងរបស់អ្នកចម្បាំងពីក្នុងសម័យបុព្វបុរសរាល់ប្រទេស គុនដាវ គុនដំបង ។
- ចំបាប់ (ន) : អាការដែលមនុស្សពីរនាក់ឬច្រើនចាប់គ្នាបោកផ្ដួល លេងចំបាប់ ។
- បារីស្លឹកសង្កែ (ន) : បារីមូរស្លឹកសង្កែព័ទ្ធពីខាងក្រៅជំនួសក្រដាសជក់ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទអ្នកត្រូវយកចិត្តទុកដាក់ស្វែងយល់ខ្លឹមសារអត្ថបទនិងសិល្បវិធី ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងប្រភពអត្ថបទ កាលអាកាស មូលន័យ មូលបញ្ហា និងតម្លៃអប់រំ ។

## គ. អត្ថបទ

ភូមិក្រាំងលាវ ភូមិនេះគឺជាតួឃុំក្រាំងលាវហ្នឹងឯង (ស្ថិតនៅក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង) ។ បើគិតប្រវែងដី ពីក្រុងកំពង់ឆ្នាំង ទៅភូមិក្រាំងលាវមានចំងាយប្រមាណ ១៤គ.ម ពីខាងលិចឆៀងខាងត្បូងនៃក្រុងកំពង់ឆ្នាំង ។ ជំនាន់នោះ(១៩២៥) អ្នកស្រុកក្រាំងលាវ មានមុខរបរចិញ្ចឹមជីវិតតែពីរមុខប៉ុណ្ណោះ គឺធ្វើស្រែនិងឡើងត្នោត ។ ប៉ុន្តែនៅឆ្នាំ ១៩២៥ ស្ថានភាពរស់នៅរបស់អ្នកស្រុកទូទៅនៅទីនោះក៏ដូចនៅទីដទៃដែរ គឺជួបប្រទះនឹងការខ្វះខាតផុតមុខផុតក្រោយ ដោយសារតែធ្វើស្រែចំការពុំសូវបានផលចំនួនពីរបីឆ្នាំជាប់គ្នារួចមកហើយ ។

រដូវចម្រូតឆ្នាំនេះក៏បានកន្លងហួសផុតទៅដែរ ។ អ្នកស្រុកកំពុងប្រញឹកដៃធ្វើត្នោតគ្រប់កន្លែង ។ ប៉ុន្តែពេលយប់ទំនេរពីការងារ គេចូលចិត្តលេងល្បែងប្រជាប្រិយដូចជា អង្គញ់ ឈូង លោតអន្ទាក់ ចាប់កូនមាន់ ។ល ។ នៅតាមភូមិតាមក្រុមរៀងខ្លួន ។ ឯពួកសង្ហាតវិជ្ជាគុន ចំបាប់ ក៏ឆ្លៀតស្កាត់ជួបគ្នាក្នុងពេលយប់ដែរ ដើម្បីសាកល្បងចំណេះដឹងរបស់ខ្លួនជាមួយមិត្តភក្តិ ប្រយោជន៍ធ្វើឱ្យថ្មីកនូវមុខវិជ្ជាដែលខ្លួនបានរៀនរួចមកហើយ ។

នៅពេលយប់នោះ មានការជួបជុំរវាងជនមួយក្រុមនៅទីវាលមួយក្នុងភូមិផ្លូវគោ ឃុំក្រាំងលាវ ក្រោមពន្លឺព្រះចន្ទពេញវង់ ។ ក្រុមជនទាំងនោះមានឈ្មោះ

១. ឈួន អាយុ ២៧ឆ្នាំ
២. សំ ប៊ីន
៣. ប៉ាង អាយុ ២២ឆ្នាំ
៤. ពត
៥. សន ស៊ិន
៦. ម៉ិញ ខ្មៅ
៧. ឌី ម៉ោ អាយុ ២៥ឆ្នាំ
៨. អ៊ុំ ពុំ អាយុ ២៧ឆ្នាំ
៩. ប៊ុត អាយុ ២៨ឆ្នាំ
១០. អ៊ុយ អាយុ ១៧ឆ្នាំ
១១. អ៊ុំ ជួន
១២. ឈុំ
១៣. ប៊ិត ហៅ ប៉ាង
១៤. គង ជិម អាយុ ២៦ឆ្នាំ
១៥. ជា ប៊ុត
១៦. គង់ មៀច
១៧. ស៊ឹម ប៉ាល់
១៨. ហង់ ប៊ី
១៩. ញ៉ែម ប៊ិត
២០. ដា ប៊ុត

អ្នកស្រុកក្រាំងលាវច្រើនស្គាល់ក្រុមនេះថា ជាអ្នកក្លាហានគ្រាន់បើចេះវិជ្ជាគុនកាប់ចាក់រួចចេះជួយការពារសន្តិសុខ ដល់អ្នកភូមិផងរបងជាមួយ ក្នុងគ្រាដែលមានការប្រមាថពីសំណាក់សត្រូវ ។

បន្ទាប់ពីបានជួបជុំគ្នាអស់ហើយ យប់នេះមិត្តទាំងអស់គ្នាក៏អង្គុយលេងនៅកណ្តាលវាល សំណេះសំណាលអួតសរសើរពីគ្រូនេះគ្រូនោះ ថាមានចំណេះពូកែខាងគុនខាងគង់ ។ល ។ កំពុងជជែកគ្នា ស្រាប់តែមនុស្សពីរនាក់ ដើរស្ទុងៗពីចំងាយសំដៅមករកក្រុមជនទាំងនោះ ។ លុះអ្នកទាំងពីរនោះដើរមកជិត ឈ្មោះម៉ោលាន់មាត់ថា ៖

- ចុម ! ល្បួងជួននិងល្បួងនៅទេតើ ! យើ ! ឯងចង់ជួបមុខអ្នកព្រៃខ្មែរយូរមកហើយ ឥឡូវបានជួបតែម្ដង ។

ភ្ញៀវដែលទើបមកដល់ថ្មីៗដូចនោះធ្វើមុខញឹមៗ ។ ចំណែកអ្នកឯទៀតចោលភ្នែកទៅរកភ្ញៀវគ្រប់គ្នា តែគេឥតមានការចាប់អារម្មណ៍ពីដំណើររបស់អ្នកទាំងពីរនេះទេ ព្រោះតែកាលណារួចស្រូវហើយ គេតែងតែស្កាត់ទៅមករកជួបគ្នារៀងរាល់ឆ្នាំជាធម្មតាដូច្នេះឯង ។ បន្ទាប់ពីដាក់គូទអង្គុយដល់ដីទើបឈ្មោះជួនឆ្លើយទៅរកឈ្មោះម៉ោវិញ ៖

- ចង់ជួបមុខអ្នកព្រៃខ្មែរចង់ល្បងឫទ្ធិគ្នាឬ ? ហាស ! ...ហាស ! ...ហាស ។ ឯឈ្មោះនៅ ក៏ជួយបន្ថែម ៖
- អ្នកព្រៃខ្មែរ ពុំទាន់ដែលឃើញថ្វីដៃអ្នកក្រាំងលាវម្ដងសោះ ។ ឆ្នាំនេះខ្ញុំចង់ឱ្យល្បួងម៉ោរើសគូណាសាកគ្នាជាមួយអ្នកព្រៃខ្មែរម្ដងមើល៍ ។

អ្នកស្ដាប់ទាំងប៉ុន្មាន នាំគ្នាសើចគឹល ! ទើបឈ្មោះពត និយាយចំអន់ឱ្យភ្ញៀវទាំងពីរនោះថា ៖

- យើ ! ខ្ញុំទ្រាន់នឹងអ្នកព្រៃខ្មែរដល់ហើយ មកម្ដងណាថាមិនអួតពីរឿងកាប់ចាក់ ។

ឈ្មោះប៊ិនជួយបន្ថែម ៖

- នរណាមួយមិនដឹងថា ល្បួងជួននិងល្បួងនៅជាជើងឯក ! ទុកជាមិនអួតក៏គេដឹងដែរ ។

ឈ្មោះជួន ឆ្លើយតបវិញទាំងលាយឡំដោយសំណើចផង ៖

- ហាស ! ហាស ! ខ្ញុំជាជើងឯកត្រឹមតែខាងការពារទល់នឹងសត្រូវ ដែលចង់ព្យាបាទមកលើរូបខ្ញុំប៉ុណ្ណោះទេ តែមិនមែនជាជើងឯកខាងលួចប្លន់ កាប់ចាក់ដោយរំលោភលើមនុស្សណាមួយសោះឡើយ ។

ទើបឈ្មោះប៉ាងនិយាយសម្រួលឡើងថា ៖

- ណ្ហើយខ្ជិលអួត ខ្ជិលសរសើរអី ! ចំណែកពួកយើងរាល់គ្នាបានត្រឹមតែអ្នកស្រុកគេកោតញញើតនៅនឹងមុខមួយភ្លែតៗប៉ុណ្ណោះ ។ ប្រសិនបើយើងទៅអួតអាងនៅចំពោះមុខមនុស្សមិនធ្លាប់ស្គាល់គ្នាមើលមុខជាបានចំណេញតែទាស់គ្នាកើតជារឿងធំមិនខាន ពុំនោះសោតចំណេញត្រឹមតែគេស្អប់ប៉ុណ្ណោះ ។ អើ ! ឯងភ្លេចសួរ ! រួចចុះប្អូនជួននិងប្អូននៅមកលេងទេ ឬមានការអ្វីប្លែកខ្លះដែរ ?

ឈ្មោះជួនឆ្លើយកំបុតថ្គុយ ៖

- មានការណ៍សំខាន់មួយដែរ ។

- និយាយទៅមើល៍ ទាន់នៅជុំគ្នា គ្រាន់បានស្ដាប់ទាំងអស់គ្នាផង ។

ឈ្មោះជួនទាញយកប្រអប់ថ្នាំជក់ពីក្នុងហោប៉ៅមកក្រៅ មូរបារីបណ្ដើរនិយាយបណ្ដើរ ៖

- រឿងដែលខ្ញុំត្រូវនិយាយពេលនេះសំខាន់ណាស់ ហើយវារឿងស្ងាត់កំបាំងទៀតផងតែដោយខ្ញុំធ្លាប់ស្គាល់ រាប់អានទុកចិត្តបងប្អូនរាល់គ្នាយូរយារមកហើយ ខ្ញុំត្រូវតែនិយាយប្រាប់ក្នុងពេលនេះចុះ ។

ឮសម្ដីនេះ ពួកអ្នកដទៃទៀតៗដែលនៅអង្គុយជំកង់ជាមួយគ្នា ខំប្រឹងស្ដាប់ខ្លបស្លឹកត្រចៀកហាក់ដូចជាចង់ដឹងខ្លាំងណាស់ ។ ទើបឈ្មោះម៉ោ តឿនឱ្យឆាប់និយាយ ៖

រឿងអី ? និយាយឱ្យចំតែម្ដងទៅកុំបូរបាច់លែបខាយនាយអាយច្រើនពេក គេស្គាល់ចិត្តថ្លើមគ្នាអស់ហើយទេតើ !

ឈ្មោះជួន លើកបារីស្លឹកសង្កែបៀមក្នុងមាត់ ឆឹកបំពង់ប៉ុយឮសូរប៉ក់ៗព្រាយផ្កាភ្លើងព្រាត ! ហើយអុជបារីជក់ហុយផ្សែងទ្រលោម ទើបចាប់ផ្ដើមនិយាយតទៅទៀត ៖

- ខ្ញុំចូលចិត្តនិយាយខ្លីៗ ចាំៗសាច់រឿងដែលត្រូវនិយាយណាស់ដែរដើម្បីឱ្យឆាប់ចប់ ។

- អឺចឹងហើយ និយាយទៅ ! (ឈ្មោះម៉ោ)
- រ៉េស៊ីដង់បារដេសស្អីគេនោះ ដូចជាកាចសាហាវដល់ហើយ តាំងពីមកឈរកាន់កាប់នៅកំពង់ឆ្នាំងកាលណាឮសូរតែវាយដំ ច្រំធាក់គេឯងទាំងកំរោល
- មែន ! (ឈ្មោះឈួននិយាយកាត់) ដូចរឿងដើរទារពន្ធដារពីអ្នកស្រុក គឺជាភារៈរបស់ រាជការឃុំសោះ តែអាលោកម៉ាសៀបារដេស ស្រាប់តែចេញដើរទារពន្ធដារពីបណ្ដារាស្ត្រដោយខ្លួនឯងតែម្ដង ! រួចបើនរណាគ្មានលុយបង់ពន្ធជូនគាត់ទេ ច្បាស់ជារឿងធំមិនខាន ។
- លាក់បាំងអីខ្ញុំមិនទាន់បានបង់ពន្ធជូនរាជការ ពីរបីឆ្នាំមកហើយ ។ ឱ្យខ្ញុំរកប្រាក់ឯណាបង់បាន បើប្រាក់គ្រាន់តែសម្រាប់ចាយវាយខ្លួនឯងនៅក្នុងគ្រួសារមិនទាន់ទាំងគ្រប់គ្រាន់ផង (ឈ្មោះពត) ។

ទើបឈ្មោះជួន ហើបគូទផុតពីដីដោយយកក្បាលជង្គង់ទាំងពីរទល់ដី រួចនិយាយបែបម៉ឺងម៉ាត់បំផុត ៖

បងប្អូនទាំងអស់គ្នា ! ខាងខ្ញុំទាំងពីរនាក់ឯណោះ គឺជួននិងនៅបានស្រុះចិត្តគ្នាជាស្រេចថានឹងសម្លាប់បារាំងកំណាចឈ្មោះបារដេសនេះឱ្យបាន បើសម្លាប់វាមិនបានទេ យើងខ្ញុំមិនខ្វីឱ្យគេហៅឈ្មោះខ្ញុំថា ជាជួន អ្នកជើងឯកព្រៃខ្មែរជាដាច់ខាត ! ស្ដាប់បានទេបងប្អូន !

ពេលនោះអ្នកស្ដាប់ទាំងប៉ុន្មាន ហាក់ដូចជាភ្ញាក់ខ្លួនព្រើត ! ស្ងាងភ្នែកចែស ! ទើបឈ្មោះម៉ោសួរមួយរំពេច ៖

- តើល្បងឯងចង់សម្លាប់បារាំង ដើម្បីគ្រាន់តែល្បីឈ្មោះប៉ុណ្ណោះទេឬ ?
- ហាស ! ហាស ! ហាស ! ... ខ្ញុំសុំសរសើរ ម៉ោឯងចេះសួរគ្រាន់បើ ! តែម៉ោឯងនៅកប់គំនិតបន្តិច ត្រង់មិនចេះជួយឱ្យយោបល់គ្នាផង ។ ត្រូវសម្លាញ់យល់ថា បើខ្មែរគ្នាឯងគឺមកពីគំនុំផ្ទាល់ខ្លួន ។ ប៉ុន្តែគំនិតជួនដែលចង់សម្លាប់បារាំងកំណាចនេះ គឺក្នុងនាមខ្មែរម្នាក់ដែលមិនសុខចិត្តនឹងអំពើជិះជាន់យ៉ាងអមនុស្សធម៌ពីសំណាក់បារាំង ... ។
- ពេលនោះស្រាប់តែអ្នកស្ដាប់ទាំងប៉ុន្មានហាក់ដូចជាណាត់គ្នាត្រូវ ក៏តាំងបញ្ចេញវាចាដូចគ្នាថា ៖ ខ្ញុំសុំចូលដៃផងៗ ...

ទើបឈ្មោះនៅនិយាយបន្តពីមិត្តរបស់ខ្លួន ៖

- រឿងនេះពុំមែនឆាកកំប្លែងទេ គឺមានស្លាប់ មានរស់ មានស៊ី មានសង ព្រោះបារាំងមានអំណាចលើខ្មែរយើង បើយើងសម្លាប់គេបានមួយ គេក៏ហ៊ានសម្លាប់យើងបានដប់ម្ភៃដែរ ។ ហើយត្រូវបងប្អូនជ្រាបឱ្យច្បាស់ថា ពួកខ្មែរចៃបារាំង វាចាំតែជួយចាប់យើងឱ្យបារាំងផ្ញើទោស ដើម្បីបានបុណ្យ បានសក្តិ និងរង្វាន់ខាន់ខៅ ។ ដូចនេះ បើបងប្អូនហ៊ានស្ម័គ្រចិត្ត

សម្លាប់បារាំងឈ្មោះបារដេសនេះហើយ ត្រូវតែតាំងចិត្តជាមុនឱ្យស្រេចថា អញសម្លាប់បារាំង បារាំងនឹងសម្លាប់អញវិញ ។ ប្រសិនបើបងប្អូននៅអាឡោះអាល័យប្រពន្ធ សូមកុំចូលប្រឡូកក្នុងល្បែងនេះជាមួយខ្ញុំឱ្យសោះ ។ ម៉េចយល់ហើយនៅ !

ក្នុងចំណោមអ្នកក្រាំងលាវទាំងអស់ ដែលស្តាប់នៅក្នុងទីនោះមានម្នាក់ឆ្លើយតបទៅឈ្មោះនៅវិញថា ៖

- ល្បងជួន ល្បងនៅ ចេះចង់សម្លាប់បារាំង ដើម្បីបុព្វហេតុដ៏ត្រឹមត្រូវនៃប្រជាជនខ្មែរ ចុះអ្នកក្រាំងលាវមិនមែនខ្មែរទេឬ? ចំពោះរូបខ្ញុំមួយ ខ្ញុំមិនស្ដោះទឹកមាត់ហើយលេបមកវិញជាដាច់ខាត !
- ពេលនោះស្រាប់តែអ្នកប្អូននាក់ទៀត ត្រូវចិត្តនឹងសំដីមិត្តខ្លួនម្នាក់នោះ ក៏ពោលព្រមគ្នាឡើងថា ៖ ខ្ញុំក៏អ៊ីចឹងដែរៗ ...

*(រៀបសម្រួលពី រឿងភូមិតិរច្ឆាន អ្នកនិពន្ធ ឌឹក គាមនិងខៀក អំ ឆ្នាំ ១៩៦៤-៦៥)*

## សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងអ្វី ? នរណាជាអ្នកនិពន្ធ ? គាត់តែងនៅឆ្នាំណា ?

២. តើអ្នកភូមិក្រាំងលាវប្រកបមុខរបរអ្វី ? បណ្ដារាស្ត្រភូមិនេះនិយមធ្វើអ្វីខ្លះក្រោយពីរដូវច្រូតកាត់រួច ?

៣. តើជួននិងនៅ ជាអ្នកស្រុកភូមិណា ? ពួកគាត់មកលេងជាមួយនឹងអ្នកភូមិក្រាំងលាវក្នុងបំណងអ្វី?

៤. តើដំណើររឿងនៃអត្ថបទដកស្រង់នេះបានប្រព្រឹត្តទៅនៅកន្លែងណា ?

៥. ចូរសិក្សាមូលន័យនិងមូលបញ្ហានៃអត្ថបទខាងលើនេះ ។

៦. ចូរបង្ហាញតម្លៃអប់រំតាមរយៈអត្ថបទខាងលើនេះ ។

៧. តើគម្រោងសម្លាប់លោករេស៊ីដង់បារដេសរបស់អ្នកក្លាហាន ជួន នៅ និងអ្នកភូមិក្រាំងលាវអាចនឹងទទួលជោគជ័យឬទេ ? ព្រោះអ្វី ?

៨. ចូរវិភាគតួអង្គជួន នៅ និងលោករ៉េស៊ីដង់បារដេស ។

# ការបន្លឺសំឡេង

ការបន្លឺសំឡេងសម្រាប់បង្កើតសូរសំឡេង ត្រូវតែពឹងផ្អែកលើការរៀបចំប្រដាប់សំឡេង លើចលនាខ្យល់និងលើភាពឮ។ ដូចនេះ សូរសំឡេងត្រូវប្រកបដោយលក្ខណៈបីយ៉ាង គឺលក្ខណៈបន្លឺ លក្ខណៈខ្យល់ និងលក្ខណៈឮ។

## ១ . លក្ខណៈបន្លឺ

លក្ខណៈបន្លឺ សំដៅយករបៀបរៀបចំនិងចលនានៃប្រដាប់សំឡេង។ ប្រដាប់សំឡេងចែកជាប្រដាប់បន្លឺនិងទីបន្លឺ។

### ក. ប្រដាប់បន្លឺ

ប្រដាប់បន្លឺសំដៅយកប្រដាប់សំឡេង មានចលនាអាចកម្រើក និងផ្លាស់ប្ដូរកន្លែងបាន។ វានៅខាងក្រោមនៃប្រហោងមាត់។ ប្រដាប់បន្លឺមាន ៖

- បបូរមាត់ក្រោម
- ធ្មេញក្រោម
- អណ្ដាត (ចុង ខ្នង គល់អណ្ដាត)
- ខ្សែសំឡេង។

### ខ. ទីបន្លឺ

ទីបន្លឺ សំដៅយកប្រដាប់សំឡេង គ្មានចលនាពុំអាចកម្រើកនិងផ្លាស់ប្ដូរកន្លែងបាន។ វានៅផ្នែកខាងលើនៃប្រហោងមាត់។ ទីបន្លឺមាន ៖




- បបូរមាត់លើ
- ធ្មេញលើ
- គន្លាក់ក្រអូម
- ក្រអូម (មុខ កណ្ដាល ក្រោយ)
- សន្ទះដើមមាត់
- សន្ទះខ្សែសំឡេង។

តាមលក្ខណៈបន្លឺសូរសំឡេងចែកជា ៖

- សូរបបូរមាត់ កើតត្រង់បបូរមាត់

- សូរធ្មេញ កើតត្រង់ធ្មេញ
- សូរគន្លាក់ក្រអូម កើតត្រង់គន្លាក់ក្រអូម
- សូរក្រអូមមុខ កើតត្រង់ក្រអូមមុខ
- សូរក្រអូមកណ្ដាល កើតត្រង់ក្រអូមកណ្ដាល
- សូរក្រអូមក្រោយ កើតត្រង់ក្រអូមក្រោយ
- សូរដើមមាត់ កើតត្រង់សន្ទះដើមមាត់
- សូរខ្សែសំឡេង កើតត្រង់សន្ទះខ្សែសំឡេង ។

## ២ . លក្ខណៈខ្យល់

ដំណើរខ្យល់ចេញពីសួត ឬបឺតចូលតាមមាត់ ឬបឺតចូលតាមច្រមុះតែងតែឆ្លងកាត់តាមបំពង់ខ្យល់និងសន្ទះខ្សែសំឡេង ។ ក្នុងចលនាចេញចូល ខ្យល់នេះប៉ះនឹងទីបន្លឺផង និងប្រដាប់បន្លឺផង ។

តាមលក្ខណៈ សូរសំឡេងចែកជា ៖

- សូរមានខ្យល់ និងគ្មានខ្យល់
- សូរខ្យល់ស្ទះ
- សូរខ្យល់ច្រមុះ
- សូរខ្យល់បង្ហូរត្រដុស
- សូរខ្យល់វែងនិងខ្យល់ខ្លី ។

## ៣ . លក្ខណៈព្ទ

ភាពព្ទនៃសូរសំឡេងមានពីរយ៉ាង គឺព្ទតាមត្រចៀកនិងព្ទតាមភាពញាប់ញ័រនៃខ្សែសំឡេង ។ ភាពព្ទក្នុងទីនេះសំដៅយកព្ទបែបខាងក្រោយ ។

ដូចនេះ សូរសំឡេងណាដែលបន្លឺឡើងធ្វើខ្សែសំឡេងឱ្យញាប់ញ័រហៅថា "សូរព្ទ" ។ រីឯសូរសំឡេងណាដែលបន្លឺឡើង ពុំធ្វើខ្សែសំឡេងឱ្យញាប់ញ័រទេហៅថា "សូរថ្លង់" ។



## ៤ . កំណត់សម្គាល់ មូលភេទ អ-អ៊

ពិនិត្យឧទាហរណ៍ខាងក្រោមនេះ ៖

តា (□ា) សី (□ី) ចេរ (េ□)

ទា (□ា) ស៊ី (□ី) ជេរ (េ□)

យើងសង្កេតឃើញថា :

- ក្នុងពាក្យ តា សី ចេរ សញ្ញា "□ា □ី េ□" សម្គាល់សូរ "អា អី អេ"
- ក្នុងពាក្យ ទា ស៊ី ជេរ សញ្ញា "□ា □ី េ□" សម្គាល់សូរ "អ៊ា អ៊ី អ៊េ" ទៅវិញ

បានសេចក្ដីថា

- គេដឹងថាសញ្ញា"□ា ..." សម្គាល់ "អា..." ដោយសារតែសញ្ញា "ត..."។
- គេដឹងថាសញ្ញា"□ា ..." សម្គាល់ "អ៊ា..." ដោយសារតែសញ្ញា "ទ..."។

ដូចនេះ ៖

- សូរស្រៈចែកជាពីរពួក គឺពួក អ និងពួក អ៊
- សញ្ញា ព្យញ្ជនៈចែកជាពីរពួកដែរ គឺ ពួក អ និង ពួក អ៊។
- ព្យាង្គ ក៏ចែកពីរដែរ គឺ ព្យាង្គពួក អ និង ពួក អ៊។

ប្រភេទ អ-អ៊ ចែកស្រៈ ព្យញ្ជនៈ ព្យាង្គ ជាសូរក្ដី សញ្ញាក្ដី ពីរៗពួកគឺ ពួក អ និង ពួក អ៊។ ទំនាក់ទំនងរវាងស្រៈ ព្យញ្ជនៈ ព្យាង្គត្រូវគោរពពួក អ និងពួក អ៊ នេះ។ ប្រភេទ អ-អ៊ ជាមូលភេទពិសេសសម្រាប់ទ្រទ្រង់លក្ខណៈជាតិ។

## សំណួរ

១. តើភាសាបន្លឺត្រូវពឹងផ្អែកលើអ្វី ?

២. ដូចម្ដេចដែលហៅថាលក្ខណៈបន្លឺ ? តើលក្ខណៈបន្លឺមានអ្វីខ្លះ ?

៣. តាមលក្ខណៈខ្យល់ តើសូរសំឡេងចែកជាប៉ុន្មាន ?

៤. តើព្យញ្ជនៈ ក ខ ជ ឈ ញ យ រ ហ ស្ថិតក្នុងសូរពួកណាខ្លះ ?

៥. តើការសិក្សាមូលភេទ អ-អ៊ដើម្បីអ្វី ?



# ទឹកចិត្តពោធិកំបោរ



## ក. សិក្សាពាក្យគន្លឹះ

- ហាយនភាព (ន) : សេចក្ដី វិនាស ភាពសាបសូន្យ ឬដំណើរទ្រុឌទ្រោម ។
- ក្រមការ (ន) : ជាងារឬថ្នាក់មន្ត្រីដែលធ្វើការផ្នែករដ្ឋបាល ឬការិយាល័យ ។
- អង្គរក្ស (ន) : ទាហានរក្សា ទាហានការពារ ។
- អាណាព្យាបាល (ន) : អ្នកគ្រប់គ្រងរក្សាអាណាខេត្ត ឬ ការគ្រប់គ្រងរក្សាអាណាខេត្ត ។
- បញ្ចុះបញ្ចូល (កិ) : និយាយណែនាំពន្យល់ឱ្យចុះចូល ។
- សេនាជន (ន) : អ្នកដែលមានតួនាទីការពារមូលដ្ឋាន ។
- ពាម (ន) : មាត់ព្រែក ឬមាត់ស្ទឹងដែលបែកចេញពីទន្លេទៅ ។
- ឧបាយកល (ន) : ល្បិចល្បួងយ៉ាងល្អិត ឧបាយបញ្ឆោត ក្រឡិចក្រលៀត ។
- កកកុញ (ន) : តាន់តាប់ ជុំជិត ត្រៀបត្រា ។
- ក្រសែ (ន) : ជំនួរវង្សត្រកូល ទំនង លំអាន ។
- ជើងញាយ (ន) : ឆ្នូតពពកវែងលលាយឆ្លូកជាមួយនឹងពពកឯទៀត ថ្ងៃនេះពពកមានជើងញាយប្លែក ។

- ប្រផ្នូល (ន) : ការបួស បុព្វនិមិត្ត ឬបុព្វនិមិត្ត អាភេទ គឺហេតុដែលបណ្ដាលឱ្យឃើញមុន ហេតុភេទដែលដឹងដោយបួលឬផ្សង ។
- សសៀរ (កិឬកិ.វិ) : សៀរសំរៀមៗ សសៀរតាមជញ្ជាំង ។
- កន្ទុយពាក្យ (ន) : សំដី ឬពាក្យចុងក្រោយ ។
- អាចារ្យ (ន) : អ្នកប្រដៅឬហាត់មារយាទ អ្នកប្រព្រឹត្តល្អ អ្នកកាន់ត្រឹមត្រូវ អ្នកត្រឹមត្រូវ អ្នកដែលសិស្សត្រូវគោរព អ្នកធ្វើប្រយោជន៍ដល់សិស្ស អ្នកបង្រៀន ចំណោះគេ គ្រូ គ្រូបង្រៀន
- បន្សាត់ (កិ) : ធ្វើឱ្យរសាត់ គឺដាក់អ្វីៗ ដែលអណ្ដែតលើទឹកបានឬដែលអណ្ដែតទៅតាមខ្យល់បានឱ្យអណ្ដែតដោយតាមទឹកឬតាមខ្យល់ទៅ ។
- កេណ្ឌ (កិ) : បង្គាប់ ប្រមូលហៅរកដោយអាជ្ញា កែនពល កែនរទេះ ។
- មេការ (ន) : អ្នកដែលជាមេលើកិច្ចការនីមួយៗ ។
- មេក្រុម (ន) : អ្នកដែលជាប្រធានលើក្រុមឬពួកមួយ ។
- ខណ្ឌ (ន) : សង្កាត់ ប៉ែក កំណត់ ប៉ែកអាណាខេត្ត ។
- ជំនិត (គុ) : ដែលជិត ដែលជាទីស្និទ្ធស្នាល ជាទីទុកចិត្ត ។
- សង្កៀត (កិ) : ប៉ះរតដុសតៀតគ្នា លាន់ឮសូរង៉េតង៉ត ឬក្រេតក្រុតជាដើម ។
- អ្នកលេង (ន) : ក្រុមអ្នកដែដល់ដោយប្រើអាវុធ ឬដោយដៃផ្ទាល់ក្នុងការវាយតប់គ្នា ។
- សស្រាក់ (កិ.វិ) : ដែលហៀរហូរ ស្រក់ស្រាក់ៗមិនដាច់ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានត្រូវយកចិត្តទុកដាក់ ដើម្បីឆ្លើយនឹងសំណួរទាក់ទងនឹងប្រភពអត្ថបទលក្ខណៈដោះស្រាយចំណោទបញ្ហា វិធីនិពន្ធ និងវិភាគតួអង្គ ។

## គ. អត្ថបទ

ពោធិកំបោរឈរជិតបង្អួចយ៉ាងស្ងៀមស្ងាត់ ក្រសែចក្ខុសម្លឹងមើលពពកដែលបន្លាយជើងព្លាយកាត់ទទឹងមេឃសឹងជាប្រផ្នូលអាក្រក់សម្រាប់ស្រុកទេស ។ មេដឹកនាំខិនមុខជ្រប់ គាត់ដកដង្ហើមធំឮសូរឃ្យូរ ! ទន្ទឹមនឹងគំនិតគិតដល់វាសនានៃប្រទេសជាតិ ៖

"ឱ ! មាតុភូមិខ្មែរដែលឱ្យកំណើតដល់រូបអញមក មិនគួរបើនឹងសសៀរទៅរកហាយនភាពដោយសារតែជាតិសាសន៍ដទៃ ជាអាណាព្យាបាលអឺចឹងសោះ" ។

រំពេចនោះ ស្នូរគោះទ្វារបន្លឺឡើង ពោធិកំបោរងាកក្រោយព្រមជាមួយនឹងពាក្យ " អញ្ជើញចូល " ។

ដំណាលគ្នានឹងកន្ទុយពាក្យនេះ ទ្វារបើកសន្សឹមៗ លេចមុខអ្នកជើងការពិសេសម្នាក់ដើរតម្រង់មកសម្ដែងការគួរសម រួចប្រាប់ដំណឹង ៖

"លោកអាចារ្យ ! ទ័ពបារាំងមកតាំងទីនៅពាមមង្គលហើយ ម្យ៉ាងទៀតពួកវាកំពុងបញ្ចុះបញ្ចូលមហាជននៅតំបន់នោះទៀតផង"។ គ្រាន់តែសេនាជនរាយការណ៍ចប់ភ្លាម ពោធិកំបោរបន្សាត់ខ្យល់ដង្ហើមយ៉ាងវែង ហាក់កុំឱ្យតឹងទ្រូងខ្លាំងពេក។ បន្ទាប់ពីសញ្ជឹងគិតមួយសន្ទុះ លោកអាចារ្យងាកទៅសេនាជន ៖

"យើងជាខ្មែរ ចាំបាច់ត្រូវការពារទឹកដីឱ្យគង់វង្សរៀងរហូតទៅ។ ឥឡូវនេះចូរប្អូនឯងទៅប្រាប់មេកង ក្រុមពួកទាំងអស់ឱ្យចូលមកកាន់រោងជំនុំភ្លាម"។ បន្តិចក្រោយមក រោងជំនុំចំហទ្វារទទួលមនុស្សម្នាជាហូរហែស្ទើរតែរកកន្លែងអង្គុយគ្មាន។ ពោធិកំបោរចាប់ផ្ដើម បើកការប្រជុំមួយរំពេច ៖

"បងប្អូនរួមឈាម ជាទីស្នេហាទាំងឡាយ ! ជាដំបូងខ្ញុំមានកិត្តិយសសូមជម្រាបដំណឹងមួយ គឺថាឥឡូវនេះ ទ័ពបារាំងកំពុងតាំងទីនៅពាមមង្គល ហើយកំពុងកេណ្ឌកម្លាំង និងបញ្ចុះបញ្ចូលប្រជាជននៅទីនោះ។ យើងមិនខ្លាចទ័ពបារាំងទេ តែយើងស្ដាយត្រង់កម្លាំងយើងមិនដល់។ តើបងប្អូនគិតយ៉ាងណាទៅវិញ ?"

ខណៈនោះ មេក្រុមម្នាក់ឈ្មោះ "ឆន" ស្ថិតនៅក្នុងវ័យកណ្ដាលមនុស្ស ឡើងបញ្ចេញយោបល់ ៖

"សូមគោរពលោកអាចារ្យនិងបងប្អូនរួមលោហិត ខ្ញុំយល់ឃើញថាយើងត្រូវខិតខំប្រមូលកងទ័ពលុះត្រាតែបានគ្រប់គ្រាន់ ដើម្បីកម្ចាត់សត្រូវ"។

យុវជនជើងចាស់ម្នាក់ឡើងបន្ទាន់ " ជម្រាបប្រសាសន៍លោកអាចារ្យនិងបងប្អូនទាំងអស់បើនិយាយតាមក្បួនសឹក ដោយភូមិសុរិលនិងពាមមង្គលនៅជិតគ្នាពេក យើងចាំបាច់ត្រូវចាកចេញពីទីនេះសិន ទើបសម្រេចគម្រោងការផ្សេងៗបានដូចបំណង "។

មេកងម្នាក់លើកដៃនិយាយគាំទ្រ "មែនហើយ ! បើយើងនៅភូមិសុរិលតទៅទៀត បញ្ហារើសទ័ពបន្ថែមពិបាកដោះស្រាយណាស់ ព្រោះអ្នកភូមិជិតៗនេះត្រូវក្រមការសៅអូសទាញស្ទើរតែទាំងអស់ទៅហើយ"។ ពោធិកំបោរញញឹមរួចបន្លឺវាចា ៖ "មុននឹងបញ្ចប់ការប្រជុំនេះ យើងសូមថ្លែងអំណរគុណដល់បងប្អូនទាំងអស់ដែលបានសហការក្នុងការតស៊ូរំដោះជាតិ"។ យោលទៅតាមការសម្រេចរបស់អង្គប្រជុំ ពោធិកំបោរក៏នាំស្មគ្របក្សពួកចេញពីភូមិសុរិល ខេត្តត្បូងឃ្មុំឡើងដល់ខេត្តក្រចេះ រួចឆ្លងទៅកាន់ខេត្តកំពង់ស្វាយ។ ពោធិកំបោរបានពន្យល់រាស្ត្រនៅទីនោះឱ្យសាមគ្គីគ្នាបណ្ដេញពួកអាណានិគមនិយមបារាំងចេញពីទឹកដីខ្មែរ។ យុវជនម្នាក់បានពោលដោយក្លាហានថា ៖

"ខ្ញុំសូមចូលរួមកម្លាំងជាមួយក្រុមលោកអាចារ្យ ប្រឆាំងបារាំងឈ្លានពានដែលហ៊ានប្រមាថខ្មែរ" ។

និយាយពីម្ខាងព្រៃឆ្ងាយឯណោះ មានការប្រជុំសម្ងាត់មួយរបស់ក្រុមការសៅដែលជាអ្នកចូលដៃជាមួយបារាំង ហើយកេណ្ឌទ័ពប្រឆាំងនឹងពោធិកំបោរ ។ ការប្រជុំនេះ ក្រុមក្រុមការសៅបានមូលមតិគ្នាប្រើឧបាយកលទៅចុះចូលជាមួយកងទ័ពពោធិកំបោរ កាលបើជួបជុំមានឱកាសល្អហើយ ពួកគេនឹងព័ទ្ធចាប់ពោធិកំបោរ ។

ក្រោយពីឯកភាពគ្នា ជនទាំងអស់ក៏ស្រែកទាំងអំនួត ៖ "នរណាមិនស្គាល់ស្នាដៃអ្នកស្រុកកំពង់ស្វាយ ? ..." ។ រួចហើយក៏ចាប់ផ្ដើមអនុវត្តឧបាយកលរបស់ពួកគេ ។ រំលងបានមួយថ្ងៃទ័ពពោធិកំបោរ ក៏បានជួបជុំគ្នាម្ដងទៀត តែពេលនេះខុសប្លែកពីធម្មតា ដោយមានមនុស្សម្នាកកកុញ ។

ពោធិកំបោរពោលទៅកាន់មេក្រុមឆនទាំងញញឹម ៖

"ថ្ងៃនេះមានបងប្អូនចូលរួមច្រើនណាស់ មានទាំងអ្នកកំពង់ស្វាយទៀត ។ ចូរប្អូនទៅអញ្ជើញគាត់ឱ្យចូលបន្តិចមក" ។ មេក្រុមឆនក៏ធ្វើតាម ។

ពោធិកំបោរវេក្រសែភ្នែកចុះឡើង ស្រាប់តែប៉ះនឹងក្រុមការសៅ មេដឹកនាំនៅកំពង់ស្វាយ ។ រំពេចនោះក្រុមការពោល ៖ "ពួកខ្ញុំទាំងអស់គ្នាមកសុំចុះចូលនឹងលោកអាចារ្យ គ្មានចិត្តងាករេទៅណាទេ" ។ ពោធិកំបោរញញឹម ទទួលសំដីទាំងពេញចិត្ត ។ ពោធិកំបោរក៏ចាប់ផ្ដើមនិយាយផ្ដោះប្ដូររកវិធីរំដោះជាតិចេញពីបារាំងនិងផែនការសម្រាប់ពេលខាងមុខ ។ ក្រុមការសៅមិនបានយកចិត្តទុកដាក់នឹងសំដីលោកអាចារ្យទេ គាត់វេក្រសែភ្នែករកគូកន ដើម្បីសម្រេចឧបាយកលរបស់គាត់ ។ ក្រោយពីឃើញបក្សពួកគ្នាច្រើនហើយ ក្រុមការចំណាស់នេះ ក៏បន្លឺសំឡេងទៅកាន់ពោធិកំបោរ ៖

"នែ ! ពោធិកំបោរ ! យើងសូមប្រាប់ឯងឱ្យភ្លឺភ្នែកនៅខណ្ឌកំពង់ស្វាយនេះគ្មាននរណាគេចុះចូលជាមួយឯងជាមនុស្សឆ្កួតដូចនេះទេ ។ បារាំងគេមកស្រុកខ្មែរ ដើម្បីជួយខ្មែរជួយកសាងការពារទឹកដីឱ្យខ្មែរ តែឯងបែរជានាំគ្នាប្រឆាំងបះបោរទៅវិញ" ។ ឮសំដីថោកទាបរបស់ក្រុមការសៅយ៉ាងដូចនេះ សេនាជំនិតទាំងប្អូនរបស់ពោធិកំបោរស្ទុះចាកពីកន្លែងបម្រុងទៅក្របួចក្រុមការសៅតែពោធិកំបោរឃាត់ ។ អត់ទ្រាំពុំបាន មេក្រុមឆនបន្លឺវាចា ៖ "យើ ! អីក៏សម្បើងម្ល៉េះ ? ឯងចង់បំបែកបំបាក់អ្នកស្នេហាជាតិ ឱ្យចូលដៃនឹងបារាំងឬ ?" រួចស្ទុះទៅរកក្រុមការសៅ តែពោធិកំបោរឃាត់ទៀត ។ ក្រុមការសៅ ៖ "នែ ! ពោធិកំបោរ ពួកឯងរាល់គ្នាមានកម្លាំងសឹកច្រើនយ៉ាងនេះ ប្រសិនបើចុះចូលនឹងរាជការបារាំង ពួកឯងពិតជាបានទទួលបុណ្យសក្តិខ្ពង់ខ្ពស់មិនខានឡើយ" ។ ពោធិកំបោរសង្កៀត

ធ្មេញ រួចតបយ៉ាងខ្លាំងទៅវិញៈ "ហ៊ឺះ ! លោកបង ! លោកបងយល់ខុសហើយ !បារាំងមិនមែនមកជួយខ្មែរទេ លោកបងឃើញជីវិតទារពន្ធដារសង្កត់សង្កិនខ្មែរគ្រប់ពេលវេលា ខ្ញុំមិនចង់បានបុណ្យសក្តិអ្វី ក្រៅពីចង់បានឯករាជ្យជូនមាតុភូមិនិងប្រជាជនខ្មែរនោះទេ ទោះជាមួយជីហានស្លាប់ ក៏ខ្ញុំនៅតែតស៊ូប្រឆាំង ជាមួយបារាំងដាច់ខាត ។ ព្រោះតែចង់បានបុណ្យសក្តិ លោកបងសុខចិត្តធ្វើបាបជនជាតិឯងមែនទេ ?"ក្រមការសៅខឹងណាស់ ក៏បញ្ជាគូកនរបស់ខ្លួនចូលប្រឡូកបម្រុងនឹងចាប់ពោធិ-កំបោរ តែគួរឱ្យចង់សើចត្រូវអង្គរក្សទាំងបួននិងមេទ័ពឆន បំប៉ើងអ្នកលេង២នាក់ខ្ទាតយ៉ាងឆ្ងាយ ។ ពេលនោះគេឮស្នូរដាវ ដំបង លំពែង ប្រជែងគ្នាយកឈ្នះចាញ់តែរៀងខ្លួន ។ ការកាប់សម្លាប់ជនជា-តិដូចគ្នា សម្រែកឈឺចាប់របស់គូប្រយុទ្ធទាំងសងខាង បានជំរុញឱ្យពោធិកំបោរខ្លោចផ្សាក្នុងចិត្តយ៉ាងខ្លាំង ។ គាត់ក៏ស្រែកយ៉ាងខ្លាំងទៅក្រមការសៅ ៖ "លោកបង ! យើងឈប់សម្លាប់គ្នាឯងទៅ លោកបងមិនអាណិតជនជាតិខ្មែរដូចគ្នាឬទេ ?" មិនទាន់ទាំងចប់សំដីផង ស្រាប់តែស្នូរកាំភ្លើងលាន់ឮផាំង ! ផាំង ! នៅក្បែរភូមិខាងកើត ។ មួយរំពេចនោះមេក្រុមម្នាក់រត់ត្រហេបត្រហបទាំងរបួសឈាមសស្រាក់ ៖ "ជម្រាបលោកអាចារ្យទ័ពបារាំងមកច្រើនណាស់ (តាមពិតមុនពេលដែលមកចូលរួមប្រជុំក្រមការសៅបានផ្តល់ដំណឹង ប្រាប់បារាំងរួចស្រេចទៅហើយ) ។ ពេលនោះគេឃើញទ័ពខោអាវកាគីប្រដាប់ដោយកាំភ្លើងវែង ខ្លះរត់ ខ្លះត្រូវនឹងគ្រាប់ កាំបិត លំពែង ដេកដួលក្នុងថ្លុកឈាមរដូករណែល ... ។

*(ដកស្រង់និងកែសម្រួលពីសៀវភៅពោធិកំបោរ អ្នកនិពន្ធ ស៊ូ ចំរើន បោះពុម្ព ១៩៧១)*

## សំណួរ

១. តើចំណុចត្រង់ណាខ្លះដែលបញ្ជាក់ថា ពោធិកំបោរជាអ្នកក្លាហាន ហ៊ានលះបង់ដើម្បីប្រទេសជាតិ ?

២. តើចំណុចត្រង់ណាខ្លះបញ្ជាក់គំនិតស្នេហាជាតិរបស់តួអង្គពោធិកំបោរ ?

៣. តើអត្ថបទនេះមានតួអង្គនរណាខ្លះ ? នរណាជាតួអង្គឯក ? តួអង្គរង ?

៤. ចូរបង្ហាញពីកាលអាកាសរបស់អត្ថបទ ។

៥. ចូរអ្នកវិភាគតួអង្គពោធិកំបោរ ។

៦. ចូរបង្ហាញតម្លៃអប់រំតាមរយៈអត្ថបទនេះ ។



# រឿងអ្នកតាឃ្លាំងមឿង



ក្នុងការស្តាប់ គេអាចស្តាប់ ដោយកត់ត្រាយកព័ត៌មានសំខាន់ៗ ដែលទាក់ទងនឹងតថភាព គំនិតសំខាន់បង្កប់ តួអង្គ និងកាលអាកាសនៃរឿង។ ចូរអ្នកស្តាប់ “**រឿងអ្នកតាឃ្លាំងមឿង**” ដើម្បីត្រៀមឆ្លើយនឹងសំណួរខាងក្រោម ៖

១. តើមានអព្ភូតហេតុអ្វីខ្លះ កើតឡើងក្រោយមរណភាពរបស់សេនាមឿង ?

២. ចូររកកាលអាកាស ក្នុងរឿងខាងលើនេះ ។

៣. ចូរបង្ហាញលក្ខណតថ:នៃអត្ថបទសម្រង់នេះ ។

៤. តើអត្ថបទសម្រង់នេះ បាននិយាយគំនិតសំខាន់អ្វីខ្លះ ?

៥. ចូរវិភាគតួអង្គ “សេនាមឿង” ។

៦. តាមរយៈអត្ថបទស្តាប់នេះ តើអ្នកបានទទួលបទពិសោធអ្វីខ្លះអំពីតួអង្គសំខាន់ ?



# សង្ខេបអត្ថបទ

សង្ខេបអត្ថបទ គឺជាការនិយាយឬកត់ត្រាចំណុចសំខាន់ៗ ដែលមាននៅក្នុងអត្ថបទដកស្រង់ ឬអត្ថបទរឿង ឱ្យខ្លីមានន័យគ្រប់គ្រាន់ ។ តទៅនេះចូរប្អូនអានអត្ថបទដកស្រង់ខាងក្រោម រួចកត់ចំណាំចំណុចសំខាន់ៗ ។

## ព្រឹត្តិការណ៍ភូមិក្រាំងលាវ

[...]ក្រោយពីបានទទួលដំណឹងថា ប្ដីរបស់ខ្លួនជាប់ខ្នោះរបស់បារាំងទៅហើយ នាងនីក្ដី នាងប៊ីក្ដីមានការតក់ស្លុតយ៉ាងខ្លាំង ។ ពួកនាងបានទូលបាយរៀងៗខ្លួនទៅសាលាឃុំ ដើម្បីយកទៅឱ្យប្ដីបរិភោគ ។ ប៉ុន្តែពេលនាងទៅដល់មាត់ជណ្ដើរសាលាឃុំ ក៏ត្រូវកងរក្សាស្រុកដែលឈរកាន់កាំភ្លើងមួយដើមយាមនៅទីនោះ ហាមឃាត់មិនឱ្យឡើង ជាហេតុធ្វើឱ្យនាងនីក្ដៅស្លឹកត្រចៀកមួយរំពេចទើបសួរដោយសុភាពនិងទន់ភ្លន់ ៖

"ហេតុអ្វីបានជាខ្ញុំសុំឡើងមួយភ្លែតមិនបានលោកចី ?"

"ព្រោះមានបញ្ជាពីលោកធំ !" ។ ស្ត្រីម្នាក់ទៀតដែលប្រុងឡើងយកបាយទៅឱ្យប្ដីដែរ គឺនាងប៊ីក៏សួរបន្ថែម ៖

"លោកបង្គាប់ដូចនេះមែនឬ ?"

"បាទ !"

លុះជជែកចុះជជែកឡើងតឹងសរសៃករៀងៗខ្លួន ក៏ឮដល់លោករ៉េស៊ីដង់ ។ គាត់ក៏សួរចីស្មួនឱ្យបកប្រែឱ្យគាត់ស្ដាប់ ។ លុះដឹងរឿងភ្លាម ទើបលោករ៉េស៊ីដង់ស្រែកសួរឡូលៗស្ទើរលៀនភ្នែក ជាភាសាបារាំង ដែលចីស្មួនប្រែបានសេចក្ដី ៖

"នាងឯងមានជាប់ប្រាក់យកមកផងទេ ? បើមានប្រាក់យកមកបង់ពន្ធ ទើបយើងអនុញ្ញាតឱ្យជួបប្ដីនាងឯងបាន !" ។

ពេលនោះនាងនី នាងប៊ី ឆ្លើយតបទៅវិញយ៉ាងសមរម្យរាបសា ៖

"លោកចីអើយ បើយើងខ្ញុំមានប្រាក់ យើងខ្ញុំពុំមែនបណ្ដោយឱ្យប្ដីនៅជាប់ខ្នោះមួយកំណាត់ថ្ងៃដូចនេះទេ ។ ឥឡូវ យើងខ្ញុំពុំមែនសុំឱ្យលោកដោះលែងប្ដីយើងខ្ញុំទេ គឺយើងគ្រាន់តែសុំអនុញ្ញាត យកបាយឱ្យប្ដីទទួលទានទេតើ ម្ដេចក៏លោកតឹងតែងដាច់មេត្តាខ្លាំងម្ល៉េះ !

លោករ៉េស៊ីដង់ធ្វើក្បាលងីងើៗ សម្លក់សម្លឹងចុះឡើង លុះចីស្មួនប្រែជាភាសាបារាំងឱ្យស្ដាប់ ក៏ស្រាប់តែក្ដៅឆួលចុងច្រមុះ ខឹងច្រលោតតោតតួងមួយរំពេច ទើបបញ្ជាឱ្យចាប់ស្ត្រីមាត់រឹងទាំងពីរនាក់នោះ យកទៅដាក់ខ្នោះជាបន្ទាន់ ប៉ុន្តែនាងទាំងពីរពុំព្រមឱ្យចាប់ រួចពោលសងទៅបារាំងវិញ ៖

"នែលោកធំ ! លោកប្រើអំណាចមកលើខ្ញុំ និងជាតិខ្ញុំជ្រុសហួសហើយ ។ លោកដាក់ខ្នោះប្ដី មិនទាន់ស្កប់ចិត្ត ឥឡូវលោកគិតដាក់ខ្នោះប្រពន្ធទៀត ..." ។

ពេលនោះ ក្រុមអ្នកក្លាហាន កាន់តែសសៀរមកកៀកនាងនី នាងបី ។ ឯអ្នកដទៃទៀត ក៏ចេះតែចូលមកជិតយ៉ាងពពាក់ពពូន ។ ម្នាក់ៗហាក់ដូចជាកាន់ជើងនាងទាំងពីរនេះ ។

ទើបនាងនីបន្តទៀតថា ៖

"លោកធ្វើថៅហ្វាយលើខ្មែរ លោកមើលឃើញត្រឹមតែប្រាក់មួយមុខប៉ុណ្ណោះ ចង់ខ្មែរធ្វើស្រែមិនបាន ចង់ខ្មែរដាច់ពោះស្លាប់ លោកឥតឈឺក្បាលអ្វីទេ លោកគិតតែសង្វើញទារពន្ធឱ្យខាងតែបាន ។ នេះឬដែលហៅអ្នកអាណាព្យាបាល ?"

នៅពេលនោះលោក រ៉េស៊ីដង់ ក៏បញ្ជា ៖

"បើនរណាមានលុយ យកមកបង់ពន្ធនឹងលែងប្ដីភ្លាម" ។

នាងបីពេលនោះមានលុយ តែមិនទាន់បង់ភ្លាមទេ ព្រោះនាងនីមិនមានលុយ ។ បើបង់ទៅក្រែងបានតែប្ដីនាងមក មិនបានប្ដីនាងនី ម្ល៉ោះហើយបានជាខំអង្វរបារាំង ។ ដោយអង្វរមិនបានការ ហើយពួបារដេសថាដូចនេះ ក៏សម្រេចចិត្តយកលុយបង់មុននាងនី ។ នាងបីបង់លុយហើយ មិនឃើញគេដោះលែងប្ដីខ្លួន នាងក៏សួរ ៖

"ម៉េចលោកថា បើមានលុយបង់ពន្ធ លោកឱ្យរួចពីឃុំឃាំង ។ ឥឡូវខ្ញុំបង់លុយ ម៉េចបានជាមិនលែងប្ដីខ្ញុំ" ។

"លែងមិនបានទេ ទាល់តែអ្នកដទៃទៀត យកលុយមកបង់គ្រប់សិន ទើបដោះលែងជាមួយគ្នាតែម្ដង" ។

ពួកអ្នកស្ដាប់ទាំងប៉ុន្មាននៅឯដីដែលឃ្លានបាយឡើងមុខស្លូតរៀងខ្លួន លុះដល់ឮនាងនីនិយាយបែបត្រូវចិត្ត ក៏តាំងញញឹមញញែម តែមិនទាន់ហ៊ានសើចទេ ព្រោះនៅញញើតលោករ៉េស៊ីដង់នៅឡើយ ។

បន្ទាប់មកនាងបីនិយាយស៊កទៅឱ្យបារាំងម្ដងវិញ ៖

"យើសលោកបារាំង ! លោកឯងអាងសាសន៍លោកត្រួតលើក្បាលខ្មែរ លោកចង់ជាន់លើខ្មែរស្មើម៉ាន បានស្មើនោះឬ ? តើលោកទុកខ្មែរជាមនុស្សម្នាដូចលោកដែរ ឬមួយជាសំរាមសំរោចមិនស្មើនឹងបាតជើងលោកទេ ?"

ពេលនោះរ៉េស៊ីដង់បារដេស ប្រឹងជំទែងស្រែកសួរចឹបកឈ្មោះសួន ដែលនៅជិតបង្កើយនឹងលោកសោះ ឮសួរសំឡេងឡូលៗយ៉ាងគ្រលរនិងញាប់រន្ថើន ព្រោះចង់ដឹងអំពីសំដីនៃស្ត្រីទាំងពីរនាក់នោះខ្លាំងពេក ។ លុះចឹសួនប្រែឱ្យស្ដាប់យល់ន័យហើយ គាត់ក្ដៅក្រហាយចំពោះនាងមាត់រឹងទាំងពីរនាក់នោះឥតឧបមា ទើបបញ្ជាឱ្យចាប់ទៅដាក់ខ្នោះជាប្រញាប់ ។ ប៉ុន្តែនាងនីគ្គី នាងប៊ីគ្គីហាក់ដូចជាមានគំនិតត្រូវគ្នា គឺមិនបណ្ដោយឱ្យនរណាចូលមកចាប់បានដោយងាយឡើយ ។

ដោយពិនិត្យឃើញថា ស្ត្រីទាំងពីរនាក់នោះសែនមហាមានះ រឹងរូសរកអ្នកណាមកប្រដូចពុំបាន គ្មានញញើតកោតខ្លាចអំណាចលោកសោះ ទើបលោករ៉េស៊ីដង់បង្គាប់ទៅកងរក្សាស្រុក ឱ្យបាញ់នាងនីនាងប៊ីជាបន្ទាន់ ដើម្បីផ្ដាច់ជីវិតអ្នកទាំងពីរក្នុងពេលនោះតែម្ដងទៅ សោះនឹងនៅតវ៉ាច្រងេងច្រងាងនាំអំពល់គេឯង ។ ឯកងរក្សាស្រុកគ្រាន់តែឮចៅហ្វាយនាយបញ្ជាឱ្យបាញ់ ក៏ចាប់កាំភ្លើងតម្រង់ទៅរកនាងទាំងពីរយ៉ាងរហ័សដូចប្រាថ្នា ។ ទាហាននោះហៀបនឹងគាស់កៃទៅហើយ ស្រាប់តែមានដៃមនុស្សម្នាក់ទៅភើចគះចុងកាំភ្លើងនោះទៅលើ ឯគ្រាប់កាំភ្លើងក៏ផ្ទុះផ្លូងក្នុងពេលដំណាលគ្នានោះដែរ ទៅធ្លាយរបើកដំបូលសាលាឃុំ ។

ដោយឃើញលោករ៉េស៊ីដង់ ប្រើអំណាចព្រៃផ្សៃខ្លាំងពេក បណ្ដារាស្ត្រក៏ផ្ទុះកំហឹងគ្រប់គ្នា ខាំមាត់សង្កៀតធ្មេញ លែងខ្លាចបុណ្យបារមីគាត់តទៅទៀត ។ ជាបន្ទាន់នោះ ក្រុមអ្នកក្លាហានក្រោមការដឹកនាំនៃឈ្មោះ នៅ និងឈ្មោះ ជួន ក៏ស្រែកហ៊ោក្រេវជាមួយនឹងចលនាលោតបោលសំរុកទៅមុខយ៉ាងរហ័ស... ។ [...]

## សង្ខេបអត្ថបទសម្រង់ខាងលើ

ដំបូងនាងនី និង នាងប៊ីបានអង្វរទាហាន ដើម្បីយកបាយឱ្យប្ដីបរិភោគ តែត្រូវកងរក្សាស្រុកហាមឃាត់ មិនឱ្យចូលទៅជួប ។ លោករ៉េស៊ីដង់បារដេស មិនបានធ្វើតាមសន្យា ពុំព្រមដោះលែងប្ដីនាងប៊ី ក្រោយពីនាងបានបង់លុយគ្រប់ចំនួន ។ បុព្វហេតុទាំងពីរនេះបានបង្កឱ្យមានជម្លោះយ៉ាងខ្លាំងរវាង នាងនី នាងប៊ី និងកងរក្សាស្រុក ។ បន្ទាប់មក លោករ៉េស៊ីដង់បារដេស បានបញ្ជាឱ្យកងរក្សាស្រុកបាញ់សម្លាប់នាងប៊ីនិងនាងនី ។ ទាហាននោះក៏បានធ្វើតាមបញ្ជា តែពុំបានសម្រេចឡើយ ហើយក៏មានចលាចលកើតឡើង ។ ចុងក្រោយ សកម្មភាពនេះបានផ្ដល់ឱកាសឱ្យក្រុមអ្នកក្លាហានបានមកនៅក្បែរ លោករ៉េស៊ីដង់បារដេស ។

## លំហាត់

ចូរអ្នកនិយាយសង្ខេប :

- អត្ថបទដកស្រង់ " ទឹកចិត្តពោធិកំបោរ "
- អត្ថបទដកស្រង់ " ភ្នំនាងកង្រី "

[...] កាលនោះនាងទាំង១២នាក់ដឹងថា នគរនោះជានគរយក្ស នាងសន្ធមារជាយក្ខិនី ហើយក៏នាំគ្នារត់ចេញ ។ នាងសន្ធមារបានតាមរកឃើញ នាងទាំង១២ បានក្លាយជាមហេសីព្រះបាទរថសិទ្ធិនៅនគរមនុស្សទៅហើយ ។ ពេលនោះនាងសន្ធមារក៏តំណែងខ្លួនជាស្រីក្រមុំ ហើយក៏បានធ្វើជាមហេសីព្រះបាទរថសិទ្ធិដែរ ។ នាងសន្ធមារពុតធ្វើជាឈឺធ្ងន់ញុះញង់ពេទ្យឱ្យទូលព្រះបាទរថសិទ្ធិឱ្យឆ្កៀលភ្នែកទាំង ១២ យកមកធ្វើជាថ្នាំព្យាបាលរោគខ្លួននិងឱ្យយកនាងទាំង ១២នាក់ដែលមានគភ៌គ្រប់គ្នាទៅទុកក្នុងរណ្ដៅមួយជាមួយគ្នា បង្អត់អាហារ ឱ្យយកគ្រាប់ភ្នែករបស់នាងទាំង ១២នាក់នោះទៅទុកក្នុងឃ្លាំងឯនគររបស់ខ្លួន ដោយទុកឱ្យនាងកង្រីជាកូនថែរក្សា ។

ក្នុងចំណោមនាងទាំង ១២នាក់នោះ នាងបងៗ ១១នាក់ត្រូវគេឆ្កៀលភ្នែកទាំងសងខាង ឯនាងពៅត្រូវគេឆ្កៀលភ្នែកតែម្ខាង ដោយពីជាតិមុននាងពៅឆ្កៀលភ្នែកត្រីតែម្ខាងដែរ ។ ពេលនាងទាំង១២មានគភ៌នោះ នាងពៅបានត្រូវព្រះពោធិសត្វមកចាប់ផ្ទៃ ។ វេលានាងបងៗកើតកូនភ្លាម គេហែកកូនចែកសាច់គ្នាស៊ីអស់ ចំណែកនាងពៅកើតកូនមកឱ្យឈ្មោះថា "ពុទ្ធិសែន" ហើយលាក់ទុកមិនឱ្យនាងបងៗដឹងទេ ។

ចំណេរកាលខាងក្រោយមក វេលាពុទ្ធិសែនធំពេញជំទង់ឡើង នាងសន្ធមារដឹងថាជាកូននាងទី ១២ ក៏ប្រើឱ្យជិះសេះនាំសំបុត្រទៅឱ្យកង្រីដោយដាក់សេចក្ដី ៖ "បើពុទ្ធិសែនមកដល់ពេលយប់ ឱ្យស៊ីទាំងយប់មកដល់ថ្ងៃឱ្យស៊ីទាំងថ្ងៃ" ។ តែជាភ័ព្វរបស់ពុទ្ធិសែន នៅពេលជិះសេះទៅដល់ពាក់កណ្ដាលព្រៃ មហាឫសីបានឃើញពុទ្ធិសែនកំពុងផ្ទំលក់និងឃើញសំបុត្រ ដែលចងនៅនឹងសេះ ក៏ហែកសំបុត្រនោះចោល ហើយសរសេរសំបុត្រជាថ្មី ៖ "បើពុទ្ធិសែនមកដល់យប់ឱ្យរៀបការទាំងយប់ ដល់ថ្ងៃរៀបការទាំងថ្ងៃជាមួយនាងកង្រីជាកូន" ។ ពេលដែលពុទ្ធិសែនបានសោយរាជ្យ នៅនគរយក្សមិនយូរប៉ុន្មានពុទ្ធិសែនក៏ជ្រាបដំណឹងអំពីប្រវត្តិប្រស្រីភ្នែកមាតាខ្លួននិងអំពីថ្នាំសម្រាប់ដាក់ភ្នែកឱ្យជាសះស្បើយនិងថ្នាំសម្រាប់បោះទៅកើតជាទឹកសមុទ្រ ជាភ្នំបាន ទ្រង់ក៏លួចរត់ចោលនាងកង្រីទាំងអធ្រាត្រ ។ នាងកង្រីរត់តាមមិនទាន់ក៏យំសោកស្លាប់នៅកណ្ដាលព្រៃ ហើយព្រះពុទ្ធិសែនមកដល់នគរវិញដោយសុវត្ថិភាព ទ្រង់ដាក់ថ្នាំកែវភ្នែកមាតានិងមាតាធំទាំងអស់ឱ្យជាឡើងវិញ ។ ព្រះអង្គក៏សម្លាប់នាងសន្ធមារទៅ ទ្រង់បានសោយរាជ្យជំនួសបិតា ជាសុខក្សេមក្សាន្តរហូតដល់ទ្រង់ចូលទិវង្គត ។ [...]

# វិភាគអត្ថបទ

អ្នកធ្លាប់បានសិក្សាពីសំណេរពន្យល់ ពិភាក្សា និងប្រៀបធៀបកន្លងមកហើយ ។ សំណេរទាំងនោះសុទ្ធតែបានធ្វើការវិភាគនិងពិចារណាទៅលើបញ្ហាដែលកើតមានក្នុងជីវិតពិតៗ ។ ដោយឡែកនៅពេលនេះអ្នកនឹងបានសិក្សាសំណេរវិភាគអត្ថបទអត្ថបទអក្សរសិល្ប៍នានា ។

ការវិភាគអត្ថបទ គឺការសិក្សាឬវិភាគទៅលើទម្រង់នៃអត្ថបទរឿងណាមួយដូចជា ការបង្ហាញអត្ថបទ វិភាគអត្ថន័យ អត្ថរូប និងអត្ថរសជាដើម ។

ក្នុងការវិភាគអត្ថបទ អ្នកវិភាគត្រូវសង្កត់ធ្ងន់ទៅលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

## គម្រោងសិក្សាអត្ថបទ

### ក. ការបង្ហាញអត្ថបទ

**ចលនា**
- ព្រាហ្មណ៍និយម
- ពុទ្ធនិយម
- ខេមរនិយម
- បរទេសនិយម ...

**អ្នកនិពន្ធ**
- ឈ្មោះ
- ជីវប្រវត្តិ
- ស្នាដៃ ...
- កាលកំណត់តែង : និពន្ធនៅឆ្នាំណា ? ខែណា ? ថ្ងៃណា ?
- សង្គមបរិយាកាស : ព្រឹត្តិការណ៍សំខាន់ៗ សម័យកាលប្រវត្តិ

**អត្ថបទនិងប្រភព**
- ចំណងជើង
- មកពីប្រភពណា ?
- សៀវភៅដើម ? ...

**ប្រភេទ**
- ប្រជាប្រិយ
- បុរាណ
- ទំនើប ...

ខ. វិភាគអត្ថបទ

- សង្ខេបអត្ថបទ
- តួអង្គ
- កាលអាកាស
- បញ្ហាសង្គម
- ..................

គ. អត្ថន័យ

- ប្រធានរឿង
- មូលបញ្ហារឿង
- ទំនាស់
- វិភាគតួអង្គ
- តម្លៃអប់រំ ...

ឃ. អត្ថរូប

- វិធីតែងនិពន្ធ
- ផ្ដើមរឿង (វិធីផ្ដើមដោយបង្ហាញតួអង្គ...)
- ដំណើររឿង (វិធីពណ៌នា សំវាទវិធី ឯកវាទវិធី វចនវិធី ...)
- បញ្ចប់រឿង (ដោយសង្ឃឹម ...)

## លំហាត់

ចូរអ្នកវិភាគអត្ថបទដកស្រង់ ៖

១. យប់មួយនៅភូមិក្រាំងលាវ ។

២. ទឹកចិត្តពោធិកំបោរ ។

៣. នំមិនធំជាងនាឡិ ។

....................

មេរៀនទី ៤

# ការលះបង់



ការលះបង់ គឺជាការធ្វើពលិកម្មប្រកបដោយគុណធម៌ ដើម្បីសម្រេចកិច្ចការអ្វីមួយ ។ ការលះបង់មានទំហំខុសៗគ្នា ។ ការលះបង់ខ្លះមានដូចជា ការលះបង់ពេលវេលា ការលះបង់កម្លាំងកាយ កម្លាំងចិត្ត ។ល ។ ការលះបង់អាយុជីវិត ការលះបង់ប្រពន្ធកូនជាដើម គឺជាការលះបង់មានទំហំធំ ព្រោះគេច្រើនធ្វើឡើង ដើម្បីបម្រើឧត្តមគតិស្នេហាជាតិដូចជា ការការពារទឹកដី ការជួយសង្គ្រោះមនុស្សជាតិពេលជួបគ្រោះមហន្តរាយផ្សេងៗ ។ បុគ្គលដែលហ៊ានលះបង់គ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិត្រូវបានគេចាត់ទុកជាវីរជន ។ ក្នុងប្រទេសមួយ ប្រសិនបើមានពលរដ្ឋជាច្រើនហ៊ានលះបង់ដើម្បីជាតិខ្លួន នោះនឹងធ្វើឱ្យប្រទេសជាតិស្ថិតស្ថេរគង់វង្សនិងមានការរីកចម្រើនឆាប់រហ័សជាក់ជាមិនខាន ។

មេរៀននេះអ្នកនឹងបានសិក្សាអំពីការលះបង់ក្នុងនាមជាពលរដ្ឋ ដើម្បីបុព្វហេតុជាតិមាតុភូមិ ។ អ្នកនឹងបានសិក្សាផងដែរអំពី ការសម្តែងតួរឿងល្ខោន ឃុតឃាត តួអង្គ ការវិភាគតួអង្គ កាលអាកាស ខ្លឹមសារអត្ថបទ សូរស្រៈ និងតែងរឿងល្ខោនខ្នាតខ្លី ។

# ឈុតនិងឆាក

ខ្មែរយើងមានល្ខោនច្រើនប្រភេទដូចជា ល្ខោនយីកេ ល្ខោនមហោរី ល្ខោននិយាយ ល្ខោនខោល ល្ខោនអាប៉េ ល្ខោនស្រមោល (ស្បែកធំស្បែកតូច)។ល។ ល្ខោនគឺជាសិល្បៈមួយ ប្រភេទដែលគេយកទៅសម្តែងលើឆាក។ គេអាចស្គាល់អត្ថបទល្ខោនតាមរយៈការសន្ទនា បញ្ជីឈ្មោះ តួអង្គ និងការរៀបចំជាឈុត ឆាកសម្រាប់សម្តែង។

រឿងល្ខោនខ្មែរយើងមានច្រើនណាស់ ប៉ុន្តែការរៀបចំជាឈុតឆាកពុំមានឯកភាពគ្នាទេ គឺអាស្រ័យលើទេពកោសល្យរបស់អ្នកនិពន្ធម្នាក់ៗ។ រឿងវែងមានច្រើនឈុត ឯរឿងខ្លីមានឈុតតិច និងឆាកក៏តិចដែរ។ ក្នុងឈុតនីមួយៗក៏មិនបានកំណត់ថាត្រូវមានចំនួនឆាកស្មើៗគ្នានោះដែរ។

ជាពិសេសទៅទៀតនោះ គឺនៅក្នុងអត្ថបទរឿងល្ខោនជាច្រើនពុំឃើញមានបែងចែកជាឈុតនៅក្នុងអត្ថបទរឿងនោះទេ។ *ឧទាហរណ៍ :* អត្ថបទល្ខោនបាសាក់រឿង **តេជោយ៉ត** ដែលនិពន្ធនៅឆ្នាំ ១៩៨៣ ដោយលោកទីជីហួតមាន១៨ឆាកពុំឃើញមានការបែងចែកជាឈុតទេ។ អត្ថបទល្ខោននិយាយ រឿង **ថៅកែចិត្តចោរ** ដែលនិពន្ធនៅឆ្នាំ ១៩៥៦ ដោយលោក ***ពៅ យូឡេង*** និង លោក ***អ៊ុំឈឿន*** មាន៧ឆាកក៏ពុំឃើញមានការបែងចែកជាឈុតដែរ។

## ក. ឈុត

គឺជាសាច់រឿងដែលគេរៀបចំឡើងមានច្រើនឆាក។ ឈុតមានការផ្លាស់ប្តូរនៅពេលមានការផ្លាស់ប្តូរស្ថានភាពធំៗនៃរឿង។

*ឈុត គឺជាវគ្គធំៗនៃការសម្តែងល្ខោន ហើយឆាកគឺជាវគ្គតូចៗនៃការសម្តែងនៅក្នុងឈុតរបស់ល្ខោន។*

## ខ. ឆាកមានន័យពីរយ៉ាង

**ន័យទី១ :** ឆាក គឺជាកន្លែងសម្រាប់សម្តែងរឿង។ ឆាកល្ខោនត្រូវបានគេរៀបចំតុបតែងលំអ និងផ្លាស់ដោយប្រើផ្ទាំងរូបភាព ផ្ទាំងទេសភាពឬដើមឈើ ដើម្បីឱ្យស៊ីទៅនឹងស្ថានភាពសាច់រឿង។

**ន័យទី២ :** ឆាក គឺជាសាច់រឿងដែលជាផ្នែកតូចមួយនៃឈុត។ កាលណាមានការផ្លាស់ប្តូរបន្ថែម ឬបន្ថយតួអង្គក្នុងការសម្តែង នោះក៏មានការផ្លាស់ប្តូរឆាកថ្មីផងដែរ។

## លំហាត់

ចូរអ្នកអានអត្ថបទរឿងល្ខោនរបស់ខ្មែរឬបរទេស អាចជាអត្ថបទល្ខោនបាសាក់ឬ យីកេឬ ល្ខោននិយាយ ... ដោយប្រាប់ពី ៖

ចំណងជើងរឿង ទម្រង់សំណេរ ចំនួនឈុត ឆាក និងការផ្លាស់ប្តូរឆាករបស់រឿងនីមួយៗ។



# ក្ដៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ



## ក. សិក្សាពាក្យគន្លឹះ

- ជំទាវ (ន) : បណ្ដាស័ក្តិសម្រាប់ស្ត្រីជាភរិយាសេនាបតីដោយព្រះករុណា ជាម្ចាស់ជីវិត ទ្រង់ ប្រោសព្រះរាជទានតាំង លោកជំទាវ(លោកស្រី) ។ បណ្ដាស័ក្តិនេះ ទោះបីភរិយារបស់មន្ត្រីស័ក្តិ១០ ហ៊ូពាន់ឯទៀតៗ ក្រៅពីសេនាបតីក៏ដោយ ស្រេចតែនឹងព្រះករុណាជាម្ចាស់ជីវិត បើទ្រង់ព្រះមេត្តាប្រោសព្រះរាជ ទានតាំងក៏បាន ។ បច្ចុប្បន្នងារនេះត្រូវបានគេប្រើសម្រាប់ភរិយារបស់ ស្វាមីដែលមានងារជាឯកឧត្ដមនិងសម្រាប់ស្ត្រីដែលមានឋានៈចាប់ពីអគ្គ នាយិកា អនុរដ្ឋលេខាធិកាឡើងទៅ ។
- ឧកញ៉ា (ន) : ពាក្យប្រើជាឋានន្តរស័ក្តិនៃមន្ត្រីថ្នាក់ខ្ពស់ជាង ទីព្រះ សំដៅសេចក្ដីថាអ្នក ចេះត្រួតត្រាមុខការក្នុងក្រសួងឬ នាទីរបស់ខ្លួន ។ ប្រើតាមលំដាប់ធំតូច គឺលោកអ្នកឧកញ៉ា > អ្នកឧកញ៉ា > ឧកញ៉ា ។
- គាល់ (កិ) : អង្គុយក្នុងសំណាក់ស្ដេច ទៅកាន់សំណាក់ស្ដេច (រាជសព្ទ សង្ឃសព្ទ) ។

- មហាតលិក (ន) : ខ្ញុំរាជការមានងារខាងគាល់បម្រើព្រះរាជា ។ ក្សត្រីយ៍ត្រឹមថ្នាក់ព្រះអង្គម្ចាស់ចុះមកច្រើនហៅថាមហាតលិក ឬមហាត្លិក ។
- អគ្គមហេសី (ន) : មហេសី(ភរិយា)ស្តេចដែលជាធំបំផុតជាងព្រះរាជទេវីទាំងពួង ។
- កេសា (ន) : សក់ ។
- ប្រណិប័តន៍ (ន) : ការឱនសំពះ ការគំនាប់ សេចក្តីគោរព ។
- តេជោ (ន) : អំណាច អានុភាព កម្លាំង ។
- ក្រយា (ន) : អាហារ ភោជនាហារ(ពាក្យខ្ពស់) អញ្ជើញពិសាក្រយា ។
- យាង (កិ) : (រាជសព្ទ)ដើរ ដើរទៅ ធ្វើដំណើរ ស្តេចយាង
- ឱន (ន) : គ្រឿងវិចិត្រធ្វើដោយប្រាក់ មាស ស្ពាន់ឬ លាយមាស សម្រាប់ប៉ាក់គ្រឿងប្រដាប់ប្រើជាលំអផ្សេងៗ ។
- ប្រទាន (កិ) : ឱ្យ ផ្តល់ឱ្យ ។
- ទាសា (ន) : ខ្ញុំប្រុស ខ្ញុំបម្រើប្រុស ។
- ទាសី (ន) : ខ្ញុំស្រី ខ្ញុំបម្រើស្រី ។
- ឱរា(-រ៉ា) (ន) : ទ្រូង ។
- បដិសណ្ឋារកិច្ច (ន) : ការទទួលរាក់ទាក់ ។
- ហេមន្ត (ន) : ឈ្មោះរដូវមានទឹកសន្សើម រដូវរងា ។
- ឃ្នាង (ន) : គ្រឿងមានកាំម្យ៉ាងសម្រាប់ដាក់កមនុស្សមានទោស ។
- កេណ្ឌ(កែន) (កិ) : ប្រមូលហៅដោយអាជ្ញា ឬកេណ្ឌពល ។

## ១. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទល្ខោននេះ ចូរអ្នកអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរដែលទាក់ទងនឹងឆាក តួអង្គ កាលអាកាស វិភាគតួអង្គ និងខ្លឹមសារអត្ថបទ ។

ដោយអស់មធ្យោបាយក្នុងការកំចាត់ស្តេចសំរែដែលជាជនក្បត់ជាតិ តេជោមាសជាមេទ័ពប្រចាំនគរ ក៏បានពិភាក្សានឹងជំទាវស្រែនជាភរិយា ។ លោកជំទាវក៏បានធានាចេញមុខដោះស្រាយបញ្ហានេះជួសស្វាមី ។

គ. អត្ថបទ

## ស្ដេចសំរែ - ឧកញ៉ាពិភា ឆាកទី៥

ស្ដេចសំរែ : អាំ! ជំទាវស្រែន! ជំទាវស្រែនលែងប្ដី! យី! ជំទាវស្រែនស្អាតណាស់ ។ ឱ! យើងចង់បានណាស់ ។ (ច្រៀង) : ឮឈ្មោះនាងស្រែន ចាប់ចិត្តផ្ដើមស្នេហា ចង់បានកន្និដ្ឋារួមរក្សមេត្រី ។ អស់អញជាស្ដេច ត្រូវមានមហេសី (ពីរដង) រូបស្អាតប្រិមប្រិយដូចទេពកញ្ញា ។ អាំ! បើតាមស្ដាប់ការរៀបរាប់របស់ពួកអាមាត្យ ជំទាវស្រែនប្រាកដជាមានក្ដួចចិត្តមកលើយើងមិនខានហាស! ហាស!

ឧកញ៉ាពិភា : សូមក្រាបថ្វាយបង្គំព្រះកុរណា (ឧកញ៉ាពិភាចូលមកដល់) ។

ស្ដេចសំរែ : អើ!

ឧកញ៉ាពិភា : តើព្រះអង្គទ្រង់ត្រាស់ ហៅទូលបង្គំចូលគាល់នេះមានកិច្ចការអ្វីទៅក្រាបទូល ?

ស្ដេចសំរែ : អើ! មានការមួយសំខាន់ណាស់ លោកឧកញ៉ាពិភា ។

ឧកញ៉ាពិភា : ព្រះករុណាថ្លៃវិសេស ។

ស្ដេចសំរែ : មហាតលិករបស់យើងបានមកទូលថា ជំទាវស្រែនឈ្លោះទាស់ទែងនឹងតេជោមាសជាស្វាមី រហូតលែងលះគ្នា ហើយចែកទ្រព្យសម្បត្តិគ្នារៀងៗខ្លួន ។ ហាស! ហាស! ហាស! ឥឡូវនេះនារីស្រែនមកបើកផ្ទះ លក់ត្រីងៀតនិងផ្ទះលក់គ្រឿងអាវុធនៅនឹងផ្សារកំពង់មែនទេ?

ឧកញ៉ាពិភា : ករុណាថ្លៃវិសេស រឿងពិតដូចបន្ទូលព្រះអង្គមែនក្រាបទូល ។

ស្ដេចសំរែ : អូមែន!អេះ ។

ឧកញ៉ាពិភា : ឯផ្ទះលក់អាវុធនោះគឺមានសុទ្ធតែកាំបិតផ្គាក់ហើយនិងដាវល្អៗណាំព្រះអង្គ ។

ស្ដេចសំរែ : អើមិនតែប៉ុណ្ណោះ មហាតលិកបានទូលថា ពួកអ្នកបម្រើរបស់ជំទាវស្រែនដែលកាន់កាប់ផ្ទះលក់ត្រីងៀតនិងផ្ទះលក់អាវុធទាំងនោះ បើឃើញពលទាហានយើងទៅទិញ គេលក់ថោកជាទីបំផុត ។ ដូច្នេះ ជំទាវស្រែនច្បាស់ជានាងក្ដួចចិត្តស្រលាញ់យើងហើយ ។ លើសពីនេះទៀតឮថានាងស្អាតដូចទេពអប្សរអីចឹង ហ៊ឺះ... ហ៊ឺ... ។

ឧកញ៉ាពិភា : ព្រះករុណាជាអម្ចាស់ ពិតដូចពាក្យមហាតលិក ពិតប្រាកដណាស់ ។

ស្ដេចសំរែ : ប្រាកដមែន ?

ឧកញ៉ាពិភា : ជំទាវស្រែនមានអាយុទើបតែ ២៨ឆ្នាំប៉ុណ្ណោះ ។

ស្តេចសំវែ : ២៨ឆ្នាំ ? អូ!

ឧកញ៉ាពិភា : ព្រះករុណាថ្លៃវិសេស ក៏ប៉ុន្តែមិនទាន់មានកូនមួយសោះ ។ ចំណែករូបរាងសោតទៀតនែ៎សាច់ក៏ល្អស្អាត លើសស្រីក្រមុំព្រហ្មចារីយ៍ ដែលទើបចេញពីម្លប់ទៀតណា៎ព្រះអង្គ ។

ស្តេចសំវែ : យី! ម្ល៉ឹងផង!

ឧកញ៉ាពិភា : ហើយក្នុងឆ្នាំនេះ ព្រះអង្គទើបតែព្រះជន្ម ៤២ ព្រះវស្សា ។

ស្តេចសំវែ : ទើបតែព្រះជន្ម ៤២ ព្រះវស្សាទេតើ! (ស្តេចសំវែនិយាយបន្ទរ) ។

ឧកញ៉ាពិភា : ហើយបើបានជំទាវស្រែនមកធ្វើជាអគ្គមហេសី ឃើញថាសក្តិសមជាទីបំផុតណា៎ក្រាបទូល ។

ស្តេចសំវែ : ហាស! ហាស! ហាស! អើ! ប្រសើរណាស់ៗ ។ ដូច្នេះហើយបានជាយើងហៅលោកឧកញ៉ាមកពិភាក្សាពេលនេះណា៎ ។

ឧកញ៉ាពិភា : ព្រះករុណាថ្លៃវិសេស ។

ស្តេចសំវែ : ចូរលោកនាំរបស់ទ្រព្យល្អៗដែលមានតម្លៃរបស់យើងទៅជូនជំទាវស្រែនហើយនិយាយស្ទាបស្ទង់ចិត្តនាងមើល៍ណា៎ ។

ឧកញ៉ាពិភា : ករុណាថ្លៃវិសេស ទូលព្រះបង្គំធានាថានឹងខិតខំបំពេញកិច្ចការនេះ លុះត្រាព្រះអង្គបានសម្រេចព្រះរាជបំណង ក្រាបទូល ។

## ជំទាវស្រែន-អ្នកបម្រើប្រុសស្រី ភាគទី៦

ស្រីបម្រើទី១ : អ៊ា៎! លោកជំទាវ ហេតុអីអង្គុយមើលទឹកទន្លេ ស្រពាប់ស្រពោនអ៊ីចឹង ?

ស្រីបម្រើទី២ : លោកជំទាវប្រហែលជានឹកដល់លោកម្ចាស់វិញហើយមើលទៅ!

ជំទាវស្រែន : និយាយតែផ្តាស ។ យើងបានលះលែងគ្នាជាមួយគេជោមាសរាប់ខែមកហើយ ។ គ្មាននឹកគាត់អីទៀតទេព្រោះយើងទាស់អធ្យាស្រ័យគ្នា ។ ប៉ុន្តែយើងកំពុងតប់ប្រមល់រឿងផ្សេងទៀតវិញទេណា៎!

ស្រីបម្រើទី១ : ឱ! លោកជំទាវសូមជំរះអារម្មណ៍មួហ្មងចេញទៅ ។ អា៎! នែ បងស៊ីចាន់ក្រងផ្កាម្លិះនេះធ្វើជាកេសាជូនលោកជំទាវណា៎!

ក្រុមស្រីបម្រើច្រៀង : ម្ចាស់គន់មើល អឺ... អឺង... អឺ... អឺង... អើយផ្កានៅក្នុងឧទ្យានក្រេបរុះ លំអង អើយលំអង ។ ចំប៉ីចំប៉ា អឺ... អឺង... អឺ... អឺង... អើយផ្កាចាម្ប៉ីះផង អើយម្លិះផង កុលាបរីកស្រស់ អឺ... អឺង... អឺ... អឺង... អើយសព្វសាយគន្ធា អើយគន្ធា ។ ពេលថ្ងៃគងភ្នំ អឺ... អឺង... អឺ... អឺង... អើយនាំខ្ញុំអាល័យ អើយអាល័យកេសាម្ចាស់ ស្រី អឺ... អឺង... អឺ... អឺង... អើយពាក់ភួងមាលា អើយមាលា ។ ស្អាតដូចអប្សរ អឺ... អឺង... អឺ... អឺង... អើយចុះចាកសួគ៌ា អើយសួគ៌ា គួរអីប្រែជា អឺ... អឺង... អឺ... អឺង... អើយអភ័ព្វមេម៉ាយអើយ មេម៉ាយ ។

ជំទាវស្រែន : ពួកនាងទាំងអស់គ្នា កុំនាំរំលឹករឿងនេះធ្វើអ្វី ។ មេម៉ាយក៏មេម៉ាយចុះ ព្រោះខ្ញុំ... ន៎ែនឹងតែជោមាស ទាស់អាស្រ័យគ្នាធ្ងន់ណាស់ ។ ពុំអាចរួមរស់ជាប្ដីប្រពន្ធតទៅទៀតបានទេណ៎ា !

ប្រុសបម្រើ : សូមគោរពលោកជំទាវ (អ្នកបម្រើចូលមកដល់ជាបន្ទាន់) ។

ជំទាវស្រែន : មានការអីពួ ? ថ្ងៃនេះលក់ដាច់ទេ ?

ប្រុសបម្រើ : បាទរឿងលក់ដូរនោះ គឺខ្ញុំបាទប៉ាវដាច់មុខបាទ ! លក់ដាច់ណាស់លោកជំទាវ ព្រោះនែ ! នែ ! ពួកទាហានរបស់ស្ដេចសំរែណ៎ា ស្រាប់តែបាក់ឈ្មួនរចូលមកទិញ ។ នែ ! នែ ! ទាំងកាំបិត ទាំងត្រីងៀត ផ្អក ម៉ាំ អីវ៉ាន់បន្តិចក៏គ្មានសល់ ។ ទិញទាំងអស់ចង់ទិញទាំងផ្ទះទៀត ។ ប៉ុន្តែឥឡូវនេះន៎ែ ! ន៎ែ ! អញ្ចេះ មាននែ ! នែ ! មន្ត្រីមកពីបន្ទាយនគរសុំជួបលោកជំទាវបាទ !

ជំទាវស្រែន : អូ ! មានមន្ត្រីមកពីបន្ទាយចង់ជួបខ្ញុំអ្ហ៎ែ ។

ប្រុសបម្រើ : បាទ ! បាទ ! តើលោកជំទាវអនុញ្ញាតទេទាន ! ពួកយើងទៅផ្ទះវិញ (លោកជំទាវបបួលអ្នកបម្រើទាំងអស់) ។

ឧកញ៉ាពិភា : សូមក្រាបប្រណិប័តន៍លោកជំទាវ ។

ជំទាវស្រែន : ចា៎ះ ! ជម្រាបសួរលោក មកពីបន្ទាយនគរអែះ?

ឧកញ៉ាពិភា : បាទ ! លោកជំទាវ ខ្ញុំបាទជារាជបម្រើព្រះសំរែរាជាធិរាជ បាទ !

ជំទាវស្រែន : អូ ! ហា៎ ! បម្រើរបស់ព្រះសំរែឬ ? ចាស ! អញ្ជើញ អញ្ជើញអង្គុយមក លោកមានការអីដែរលោក ? (ជំទាវស្រែនសួរដោយក្ដីរំភើប) ។

ឧកញ៉ាពិភា : បាទ! ខ្ញុំបាទជម្រាបលោកជំទាវ ។

ជំទាវស្រែន : មានការអីមានប្រសាសន៍មកចុះណា៎!

ឧកញ៉ាពិភា : (ច្រៀង) ព្រះបាទសំរែជាស្តេចពូកែអស្ចារ្យ(ពីរដង) ទ្រង់ព្រះចិន្តាស្វែងរកមហេសី(ពីរដង) ។ ព្រះអង្គទ្រង់ប្រឹង ប្រើបម្រើប្រុសស្រី (ពីរដង) ទាំងរូបខ្ញុំក្តីនាំព្រះរាជទ្រព្យ (ពីរដង) ។

ជំទាវស្រែន : អូ! យី! វត្ថុអស់នេះសុទ្ធតែមានតម្លៃណាស់ណា៎លោក ។

ឧកញ៉ាពិភា : គឺព្រះរាជទ្រព្យដែលព្រះអង្គផ្ញើមកជូនលោកជំទាវ ។

ជំទាវស្រែន : យី! អា៎! ជូនខ្ញុំ ? (ជំទាវសួរបញ្ជាក់ដោយអារម្មណ៍រំភើប) ។

ឧកញ៉ាពិភា : បាទ!

ជំទាវស្រែន : អូ!ខ្ញុំមានភ័ព្វសំណាងណាស់ណា៎លោកអើយ ។ លោកឧកញ៉ាហេតុអីក៏ស្គាល់ខ្ញុំ?

ឧកញ៉ាពិភា : មិនត្រឹមតែស្គាល់ប៉ុណ្ណោះទេ រឿងរ៉ាវរបស់លោកជំទាវនិងតេជោមាស ព្រះអង្គជ្រាបទាំងអស់ ឥតមានចន្លោះឡើយណា៎ លោកជំទាវ ។

ជំទាវស្រែន : យី! ព្រះអង្គដឹងរឿងខ្ញុំ ?

ឧកញ៉ាពិភា : បាទ! លោកជំទាវ ។

ជំទាវស្រែន : ចាស! ខ្ញុំត្រេកអរណាស់ បានព្រះករុណាប្រទានកិត្តិយសសម្រាប់ខ្ញុំយ៉ាងនេះ អា៎! ថ្ងៃស្អែកខ្ញុំនឹងរៀបចំនំចំណីយ៉ាងវិសេសវិសាលឱ្យអ្នកបម្រើយកទៅថ្វាយ ដើម្បីឱ្យទ្រង់រីតតែសព្វព្រះរាជហឫទ័យណា៎!

ឧកញ៉ាពិភា : អូ! បានអីចឹងរឹតតែប្រសើរ ។ មិនអីទេ ពួកខ្ញុំក៏ឧស្សាហ៍ទៅមកញឹកញាប់ដែរណា៎លោកជំទាវ! ព្រោះតែកាលណាព្រះអង្គបានទទួលតង្វាយដ៏ត្រកុំត្រកាលមុខជាទ្រង់ត្រាស់ប្រើឱ្យមកជូនលោកជំទាវទៀតហើយ ។

ជំទាវស្រែន : នៅថ្ងៃ ៨ រោចខាងមុខនេះ ខ្ញុំត្រូវរៀបចំមង្គលការក្មួយម្នាក់ ។ ដូច្នេះខ្ញុំសូមពឹងលោកបានទេ ?

ឧកញ៉ាពិភា : មិនអីទេលោកជំទាវ ។

ជំទាវស្រែន : ចាស! ជួយយាងព្រះករុណាចែកទានឱ្យខ្ញុំផង ដើម្បីឱ្យគូស្វាមីភរិយាថ្មីបានទទួលពរជ័យពីព្រះអង្គណា៎ ។ សូមលោកកុំព្រួយបារម្ភណា៎ ខ្ញុំនឹងរៀបចំបម្រើព្រះអង្គឱ្យពេញព្រះទ័យជាមិនខានណា៎ ។

ឧកញ៉ាពិភា : ថៃជន្យល្អណាស់ មិនអីទេសូមលោកជំទាវទុកចិត្តខ្ញុំចុះ ។ ព្រះករុណាមុខជាសព្វព្រះរាជហឫទ័យយាងមកជាមិនខានទេ ណ៎ាលោកជំទាវ ។

ជំទាវស្រែន : ចា៎! ចា៎! ខ្ញុំត្រេកអរណាស់ ។

## ជំទាវស្រែន ឧកញ៉ាពិភា និងស្តេចសំរែ ឆាកទី៧

ថ្ងៃពិធីមង្គលការក៏មកដល់ ភ្ញៀវចូលរួមយ៉ាងកុះករ ពិសេសស្តេចសំរែនិងលោកសេនាក៏មកចូលរួមដែរ ៖

ឧកញ៉ាពិភា : លោកជំទាវ ព្រះករុណាស្តេចសំរែជាអម្ចាស់យាងមកដល់ហើយ លោកជំទាវ ។

ជំទាវស្រែន : ព្រះអង្គយាងមកដល់ហើយ! នែ! បងប្អូនទាំងអស់គ្នាមើលរៀបចំធ្វើបដិសណ្ឋារកិច្ច ដូចដែលខ្ញុំបានរៀបចំចាត់រួចមកអីចឹងណ៎ា អស់លោក ។

អ្នកបម្រើ : បាទ! លោកជំទាវ ។

ជំទាវស្រែន : អា៎! សូមក្រាបថ្វាយបង្គំ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ... ។

ស្តេចសំរែ : អា៎! អា៎! នែ! នែ! ល្អហើយៗ ។ យី! ជំទាវស្រែន ស្អាតលើសពាក្យដែលគេនិយាយទៅទៀត ។ យី! ... អើ ... អ៊ី ...! លោកជំទាវ (ស្តេចសំរែនិយាយដោយរំភើបក្រៃលែងចំពោះសម្ផស្សរបស់ជំទាវស្រែន) ។

ជំទាវស្រែន : ព្រះករុណាជាអង្គម្ចាស់សូមស្តេចយាងចូលក្រាបទូល ។

ស្តេចសំរែ : អ៊ូ៎! យាងចូល ? យីជំទាវស្រែនស្អាតណាស់! អូយាងចូល! អ៊ូ៎! ស្អាតណាស់ស្អាតលើសស្រីលើផែនដីនេះទៅទៀត (ស្តេចសំរែរំភើបខ្លាំង) ។

ជំទាវស្រែន : សូមព្រះអង្គយាងចូលមកកុំខ្លាចអី ។

ស្តេចសំរែ (ច្រៀង) : ឱកែវជីវាមេត្តាបង បានយល់ភក្ត្រនួនល្អង ព្រឺព្រួចកន្លងក្នុងចិន្តា លន់តួក្តីស្នេហាឱណា កែវមាសអូនអើយ ។ (ពីរដង)

ជំទាវស្រែន (ច្រៀង) : ខ្ញុំម្ចាស់ស្មោះស្ម័គ្រ(ពីរដង)តែខ្ញុំម្ចាស់លាក់មិនវាចា ។ (ពីរដង) សូមព្រះអង្គយាង (ពីរដង) ចូលឆាប់វាំមានព្រះក្រយារៀបចំថ្វាយស្រេច ។ (ពីរដង)

ជំទាវស្រែន : ឱះ! សូម ... សូមព្រះអង្គយាងគង់លើព្រះទែននេះក្រាបទូល ។ ខ្ញុំម្ចាស់នៅគាល់បម្រើព្រះក្រយាដោយផ្ទាល់ដៃណ៎ាក្រាបទូល ។

ស្តេចសំរែ : អស្ចារ្យ! អស្ចារ្យ! យី! ជំទាវស្រែន (ស្តេចសំរែរំភើប)

ជំទាវស្រែន : ពួកនាងទាំងអស់គ្នា! លើកក្រយាមក (ជំទាវស្រែនបញ្ជាទៅអ្នកបម្រើ)

ស្តេចសំរែ : អូ! អូ! ក្រយា! យី! ជំទាវប៉ិនប្រសប់តុបតែងទីលំនៅស្អាតរុងរឿង ប្រៀបបាននឹងវាំងស្តេច ។ យី! មើល៍ ... នែ៎ ... អើ! តាំងពីខ្ញុំកើតមកទើបនឹងឃើញនៅស្រាក្រអូបឈ្ងុយ ឈ្ងប់ ។ អូនែ៎! ក្រយាឆ្ងាញ់ ។ យីគ្រប់សព្វទាំងអស់ជំទាវ ហ៊ឺះ!ហ៊ឺះ! (ស្តេចសំរែរីករាយនឹងការទទួលរបស់ជំទាវស្រែនដោយគ្មានសង្ស័យ) ។

ជំទាវស្រែន : ពរព្រះអង្គ ។ សូមព្រះករុណាប្រទានកិត្តិយស ដល់ខ្ញុំម្ចាស់មួយពែងទៀត ក្រាបទូល ។

ស្តេចសំរែ : មិនអីទេ! មិនអីទេ! អើៗ អឺៗ នែ៎! បានស្រែនចាក់ស្រាឱ្យសោយយ៉ាងនេះ ទោះត្រូវស្រវឹងដល់ស្លាប់ក៏ដោយក៏មិនខ្លាចដែរស្រែន (ស្តេចសំរែពោល ដោយស្រវឹង) ។

ជំទាវស្រែន : ឯណាបងប្អូនអ្នកភ្លេង ឆាប់ប្រគំកំដរព្រះរាជាភ្លាមទៅ ។

ស្តេចសំរែ : អូ! មានភ្លេងទៀតអ្ហែ ?

ជំទាវស្រែន : ព្រះពរព្រះអង្គ មានភ្លេងកំដរទៀតព្រះអង្គ ។ ព្រះអង្គសោយទៅកុំខ្មាស អៀន ខ្ញុំនៅគាល់បម្រើផ្ទាល់ព្រះករុណា ។

ក្រុមចម្រៀងច្រៀងបំពេ : ឱព្រះអង្គអើយ ស្តេចសោយកើត ក្រយាគ្រប់បែប ថ្វាយព្រះចក្រី អើយ (ពីរដង) ស្រាក្រហមខៀវលាយបទតន្ត្រី ទាសាទាសី គាល់ចាំឱត្រៀប ត្រាអើយ ... អឺ ... អឺ ... អឺ ... អឺ ... អឺងអើយ គាល់ចាំឱត្រៀបត្រា ។ ឱរាត្រីអើយ រាត្រីរនោច លន្លង់លន្លោច ខ្វាយខ្វល់ឱរាអើយ (ពីរដង) មេឃ បាត់ដួងចន្ទ សុទ្ធតែតារាប្រៀបដូចបុប្ផា ត្រូវការហោមន្ត អើយ ហា ... អឺ ... អឺ ... អឺ ... អឺ ... អឺងអើយត្រូវការហោមន្ត ។ ក្រោយពីត្រូវថ្នាំសណ្តំក្នុងស្រា ហើយស្តេចសំរែនិងបរិវារក៏លង់លក់ទៅ មួយរំពេចនោះកងទ័ពតេជោមាស និងយ៉តក៏សំរុកចូលមក ព័ទ្ធចាប់ស្តេចសំរែនិងបក្សពួកបានទាំងអស់ ។

*(ដកស្រង់ដោយកត់ត្រាចេញពីល្ខោនបាសាក់សម្តែងតាមវិទ្យុ តេជោយ៉ត របស់លោកទីជីហ្វួត)*

# សំណួរ

១. តាមរយៈតួអង្គស្ដេចសំវ៉ែ ចូរអ្នក ៖

- បង្ហាញពីតួនាទី
- សកម្មភាព
- ចរិតលក្ខណៈ

២. តើការធ្វើសង្គ្រាមរវាងតេជោមាស ជាមួយស្ដេចសំវ៉ែអ្នកណាឈ្នះ ? ឈ្នះដោយសារអ្វី ?

៣. តើរឿងនេះមានតួអង្គប៉ុន្មាននាក់ ? អ្នកណាខ្លះ ? ហើយតួអង្គណាជាតួអង្គឯក តួអង្គរង ? តើតួនីមួយៗមានតួនាទីជាអ្វី ?

៤. តើជំទាវស្រែនជាមនុស្សយ៉ាងដូចម្ដេច ? លោកជំទាវជួយស្វាមីដូចម្ដេចខ្លះ ? ហើយអ្នកយល់យ៉ាងណាចំពោះបេសកកម្មជំទាវស្រែន ?

៥. តើអត្ថបទនេះជាប្រភេទអ្វី ? ហើយប្រភេទនៃអត្ថបទនេះមានរចនាបថខុសពីប្រភេទអត្ថបទរឿងប្រលោមលោក ឬរឿងនិទានយ៉ាងដូចម្ដេច ?

៦. តើអត្ថបទល្ខោនដកស្រង់នេះមានប៉ុន្មានឆាក ? តើការប្ដូរឆាកកើតឡើងនៅពេលណា ?

៧. តាមរយៈសកម្មភាពជំទាវស្រែន តើបានបង្ហាញពីតួនាទីរបស់ស្ត្រីខ្មែរក្នុងការអភិវឌ្ឍសង្គមយ៉ាងណាខ្លះ ?

៨. ចូរសិក្សាអំពី ៖

- កាលអាកាសនៃរឿង
- និមិត្តរូបវិធី
- ឧបមានវិធី

៩. តើ "ក្ដៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ" ដែលជាចំណងជើងអត្ថបទអំណាននេះមានន័យដូចម្ដេច ? ចូររកអំណះអំណាងមកបញ្ជាក់ ។



# ការសម្តែងតួរឿងល្ខោន

ល្ខោន គឺជាសិល្បៈមួយប្រភេទដែលគេយកទៅសម្តែងលើឆាក តាមរយៈកាយវិការរបស់តួអង្គនីមួយៗនៅពីមុខទស្សនិកជន ។ ដើម្បីសម្តែងល្ខោនបានល្អគេត្រូវរៀបចំជាឈុត ឆាកឱ្យបានត្រឹមត្រូវ ។

ចូរអានអត្ថបទរឿងល្ខោនខាងក្រោម ៖

## រឿង តេជោយ៉ត ភាគទី១

តេជោមាស : ខ្ញុំឈ្មោះ " មាស " មានគោរម្យងារជាឧកញ៉ាតេជោបវររាជ ... (ច្រៀង) តាំងចិត្តប្តេជ្ញាការពារទឹកដី ដូចជាប្រស្រីក្នុងកែវនេត្រា (២ដង) ទោះត្រូវលះបង់ អាយុសង្ខារ ក៏ចិត្តស្នេហាជាតិមិនរសាយ ។ (និយាយ) ជិតដល់ពេលចេញដំណើរហើយតើ! ឯណាយ៉ត ?

យ៉ត : បាទលោកគ្រូ!

តេជោមាស : កងទ័ពរបស់យើងបានរៀបចំរួចរាល់ហើយ ឬនៅ ?

យ៉ត : បាទ! ខ្ញុំត្រៀមរួចអស់ហើយ គឺយើងយកតែទ័ពសេះប៉ុណ្ណោះ តាមការគ្រោងទុកណាលោកគ្រូ!

តេជោមាស : អឺ! ល្អហើយ (សូរសំឡេងសេះកញ្ជៀវខ្ទៀវខ្ទារ ...) ។

ជំទាវស្រែន : បងគិតចេញដំណើរឥឡូវនេះឬ ?

តេជោមាស : ហ្នឹងហើយអូន! ដល់ពេលវេលាបងហើយណា៎!

ជំទាវស្រែន : នេះថ្នាំព្យាបាលរបួសដែលបងតែងដាក់តាមខ្លួន អូនបានរៀបចំជូនបងសព្វគ្រប់ហើយ ។

តេជោមាស : អឺ! ល្អហើយ!

ជំទាវស្រែន : ហ៊ឺ! រាល់ពេលមានកលយុគក្នុងនគរបងតែងមានភារកិច្ច ចេញធ្វើសឹកសង្គ្រាមជានិច្ច ។

តេជោមាស : ស្រែនអូន!

ជំទាវស្រែន : ចាសបង!

តេជោមាស : បានធ្វើពលិកម្មបម្រើជាតិយ៉ាងនេះ គឺជាកិត្តិយសមួយធំធេងណាស់អូន ។

ជំទាវស្រែន : ចាស! សូមបងប្រយ័ត្នណា៎ ព្រោះអូនឮគេថាស្តេចសំរែនោះពូកែណាស់បង!

តេជោមាស : មិនអីទេអូន! មិនអីទេ!

ជំទាវស្រែន : (ច្រៀង) អូនសូមជូនពរជោគជ័យ អឺ អឹង អឺយ (២ដង) ដល់រូបអ្នកប្ដី អឺ អឹង អឺយ (២ដង) គួគាប់វាសនា សូមបងបានឈ្នះលើពួកបច្ចា អឺ អឹង អឺយ ... ។

តេជោមាស : ស្រែនអូន! នៅផ្ទះចូរថែរក្សាខ្លួនប្រាណឱ្យបានសុខចុះណា៎កុំព្រួយបារម្ភដល់បងអី ណា៎អូន!

ជំទាវស្រែន : ចាស! បងជាមេទ័ពខ្លាំងពូកែធ្លាប់មានស្នាដៃក្នុងសឹក អូនតែងគិតដល់សុខទុក្ខរបស់បងជានិច្ចណា៎!

តេជោមាស : អឺ! មែនហើយអូនកុំគិតច្រើនពេកណា៎អូនស្រែន ស្លាប់ក្នុងបុព្វហេតុការពារប្រទេសជាតិមាតុភូមិ ជាមហាកិត្តិយសដ៏ធំ មែនទេអូន!

ជំទាវស្រែន : ចា៎ះ ឯណាយ៉ត ?

យ៉ត : បាទ!

ជំទាវស្រែន : បម្រើគ្រូឯងឱ្យដិតដល់មែនទែនណា៎!

យ៉ត : បាទ! សូមលោកជំទាវកុំបារម្ភឱ្យសោះ ។

តេជោមាស : ប្រពន្ធសម្លាញ់ បងលាហើយណា៎!

ជំទាវស្រែន : សូមបង! ប្រកបតែជោគជ័យនិងសេចក្ដីសុខណា៎បង!

តេជោមាស : សូមនៅឱ្យបានសេចក្ដីសុខណាអូន បងលាសិនហើយ!

ជំទាវស្រែន : ចាស! ចា៎ះ! (ស្ទួរជើងសេះចេញដំណើរ) ។

*(ដកស្រង់ដោយកត់ត្រាចេញពីល្ខោនបាសាក់សម្ដែងតាមវិទ្យុ តេជោយ៉ត របស់លោកទីជីហ្វួត)*

## លំហាត់

ចូររៀបគ្នាជាក្រុមដើម្បីសម្ដែងល្ខោនបាសាក់តាមអត្ថបទរឿង **តេជោយ៉ត** ត្រង់ឆាកទី១ តាមអត្ថបទគំរូខាងលើ ។ ក្នុងការសម្ដែងល្ខោន គេត្រូវត្រៀមនិងរៀបចំដូចខាងក្រោម ៖

### ១ . ការជ្រើសរើសអ្នកដឹកនាំសម្ដែងនិងតួអង្គសម្ដែង

- ការជ្រើសរើស អ្នកដឹកនាំសម្ដែងជាការចាំបាច់ ព្រោះអ្នកនោះអាចជួយកែលំអចំណុចខ្វះខាតរបស់តួសម្ដែងផងនិងចាត់ចែងការបញ្ចេញតួសម្ដែងផង ។
- ការជ្រើសរើសចំនួនតួអង្គតាមចំនួនតួអង្គក្នុងរឿងដូចជា ក្នុងអត្ថបទឆាកល្ខោនដកស្រង់ខាងលើមានតួអង្គបីនាក់គឺ តេជោមាស យ៉ត និងជំទាវស្រែន ។
- ការចាត់តាំងតួអង្គសម្ដែង

**តួអង្គឯក** : ត្រូវជ្រើសរើសអ្នកមានរូបរាងស្អាត សំឡេងពីរោះ

**តួអង្គកាច** : ត្រូវជ្រើសរើសអ្នកមានទឹកមុខកាច

**តួអង្គកំប្លែង** : ត្រូវជ្រើសរើសមនុស្សក្រមាច់ ប្រសប់និយាយកំប្លែង

**តួអង្គផ្សេងៗទៀត** : ត្រូវជ្រើសរើសមនុស្សដែលមានទេពកោសល្យតាមលក្ខណៈតួអង្គនៅក្នុងសាច់រឿង ។

### ២ . ការត្រៀមរៀបចំនិងការហ្វឹកហាត់

- រៀបចំសាច់រឿងជាឈុត ឆាកឱ្យបានត្រឹមត្រូវ ។
- ត្រៀមសម្ភារៈសម្រាប់ប្រើប្រាស់ពេលសម្ដែងដូចជា ដាវ កាំបិត លំពែង(ឈើ) ដំបង សម្លៀកបំពាក់ ជាដើម ឱ្យសមស្របតាមកាលអាកាសរឿង ។
- ហាត់ច្រៀងនិងទន្ទេញពាក្យសម្ដីដែលខ្លួនត្រូវនិយាយនិងច្រៀងចម្រៀងឱ្យបានចាំស្ទាត់មុនពេលសម្ដែង ។
- រៀនតុបតែងខ្លួន មុខមាត់ រាងកាយ ប្រើប្រាស់សំលៀកបំពាក់ អាវុធ ឱ្យស្របតាមលក្ខណៈតួនីមួយៗនិងកាលអាកាសរឿង ។
- ចងចាំពេលវេលាដែលខ្លួនត្រូវចេញមកសម្ដែងក្នុងឆាក រយៈពេលសម្ដែង និងពេលវេលាត្រឡប់ចូលក្នុងឆាកវិញ ។

*ឧទាហរណ៍* ៖ តួអង្គតេជោយ៉តត្រូវចេញមកសម្ដែងពេលណា ជាមួយអ្នកណា អ្នកណាចេញមុន អ្នកណាចេញក្រោយ ... ។

- ឱ្យតួអង្គហ្វឹកហាត់ធ្វើកាយវិការឱ្យបានសមស្របតាមលក្ខណៈល្ខោន និងតាមស្ថានភាពសាច់រឿង ។

## ៣ . ការរៀបចំឆាកសម្ដែង

ការរៀបចំឆាកសម្រាប់សម្ដែង ត្រូវជ្រើសទីកន្លែងធំទូលាយ និងរៀបចំតុបតែងឆាកឱ្យបានស្អាតសមស្របតាមដំណើររឿង ។ គប្បីប្រើប្រាស់ផ្ទាំងរូបភាពនិងវត្ថុខ្លះៗសមស្របតាមសម័យកាល ដើម្បីឱ្យការសម្ដែងមើលទៅហាក់ដូចជាស្ថិតក្នុងទីកន្លែងនិងសម័យកាលមួយជាក់លាក់ ។ ការរៀបចំតុបតែងឆាកសម្ដែងគប្បីប្រែប្រួលទៅតាមស្ថានភាពនៃទីកន្លែងក្នុងសាច់រឿង ។

## ៤ . ការសម្ដែង

- តុបតែងនិងប្រើប្រាស់សម្ភារៈ ព្រមទាំងចេញសម្ដែងលើឆាកតាមពេលវេលាដែលបានកំណត់នៅក្នុងឆាកនីមួយៗ ។
- និយាយសន្ទនា ច្រៀងដោយធ្វើកាយវិការឱ្យបានសមស្រប ។

# សូរស្រះ

ស្រះ  គឺជាសូរសំឡេងដែលកើតមកពីដំណើរខ្យល់តាមបំពង់សំឡេងបន្លឺឡើងដោយគ្មានទំនប់ប្រកបដោយភាពច្បាស់លាស់ ។

ស្រះអាចចែកតាម បញ្ចែក អ - អ៊  បញ្ចែក វែង - ខ្លី  និងបញ្ចែក ទោល - ផ្សំ ។

## ១ . បញ្ចែក អ - អ៊

តាមមូលភេទ ស្រះចែកជាបីពួក គឺស្រះពួក **អ** ស្រះពួក **អ៊** និងស្រះពួក **អ - អ៊** ។

### ក. ស្រះពួក អ

***ឧទាហរណ៍ :*** ការ ឡើង ចេញ ។ ក្នុងពាក្យទាំងនេះសញ្ញាស្រះ " □ា  េ□ី  េ□ " ប្រើជាមួយតួព្យញ្ជនៈពួក  " **អ** " កត់សូរស្រះពួក **អ**  " [អា]  [អើ] [អេ] ...  " ។

ស្រះពួក **អ** មាន ៖ [អ] [អ់] [អា] [អ់ា] [អិ] [អី] [អឹ] [អឺ] [អុ] [អូ] [អើ] [អេ] [អែ] [អៃ] [អោ] [អៅ] [អំ] ។

### ខ. ស្រះពួក អ៊

***ឧទាហរណ៍ :*** ទា ឃើញ គេ ។ ក្នុងពាក្យទាំងនេះសញ្ញាស្រះ " □ា  េ□ី  េ□" ប្រើជាមួយតួព្យញ្ជនៈពួក  " **អ៊** " កត់សូស្រះពួក **អ៊**  " [អ៊ា]  [អ៊ើ] [អ៊េ] ...  " ។

ស្រះពួក **អ៊** មាន : [អ៊] [អ៊់] [អ៊ា] [អ៊់ា] [អ៊ិ] [អ៊ី] [អ៊ឹ] [អ៊ឺ] [អ៊ុ] [អ៊ូ] [អ៊ើ] [អ៊េ] [អ៊ែ] [អ៊ៃ] [អ៊ោ] [អ៊ៅ] [អ៊ំ] ។

### គ. ស្រះពួក អ-អ៊

***ឧទាហរណ៍ :*** គួរ តួ ខឿន កៀក ទៀត ជឿ សៀរ ។ ក្នុងពាក្យទាំងនេះសញ្ញាស្រះ  " □ួ  េ□ឿ  េ□ៀ " ប្រើជាមួយតួព្យញ្ជនៈពួក  " **អ** "  ឬពួក  " **អ៊** "  កត់សូរស្រះពួក **អ-អ៊** " [អួ] [អឿ] [អៀ] ...  " ។

ស្រះពួក **អ-អ៊** មាន : [អួ] [អឿ] [អៀ] ។

## ២ . បំណែងចែក វែង - ខ្លី

តាមលក្ខណៈខ្យល់ ស្រៈអាចចែកជាពីរពួក គឺស្រៈវែងនិងស្រៈខ្លី ។

### ក. ស្រៈវែង

*ឧទាហរណ៍ :* យើង រៀន មួយ សប្បាយ បាន ។

ស្រៈវែងមាន ៖ [អ] [អា] [អី] [អូ] [អើ] [អេ] [អែ] [អោ] [អ៊] [អ៊ា] [អ៊ិ] [អ៊ី] [អ៊ូ] [អ៊ឺ] [អ៊េ] [អ៊ែ] [អ៊ោ] [អ៊៎] [អួ] [អឿ] [អៀ] ។

### ខ. ស្រៈខ្លី

*ឧទាហរណ៍ :* ក្បត់ រនាំង ពង្រឹង មាត់ កប់ ។

ស្រៈខ្លីមាន ៖ [អ់] [អាំ] [អិ] [អឹ] [អឹ] [អុ] [អៃ] [អៅ] [អ៊់] [អ៊ាំ] [អ៊ិ] [អ៊ឹ] [អ៊ុ] [អ៊ែ់] [អ៊ៃ] [អ៊ៅ] ។

នៅក្នុងសំណេរ ស្រៈខ្លីខ្មែរយើងសម្គាល់ដោយ ៖

- សញ្ញាបន្តក់ " ◌់ " : កាត់ គក់ ជាក់ ។
- សញ្ញាដំលើ " ◌ំ " : បាំង ខំ ទំ ។
- វិសជ្ជនី ឬសញ្ញារះមុខ " ◌ះ " : ជះ កោះ ពោះ ចេះ បេះ ។
- យុគលពិន្ទុ ឬសញ្ញាចុចពីរ " ◌ៈ " : រយៈ សុខៈ ធុរៈ ។
- លេខអស្តា ឬសញ្ញាលេខប្រាំបី " ◌៏ " : ក៏ ដ៏ ។
- សំយោគសញ្ញា ឬសញ្ញាផាត់លើ " ◌័ " : ជ័យ សម័យ ស័ព្ទ ។
- ព្យាង្គដើមក្នុងពាក្យច្រើនព្យាង្គ កកេះ ញញួរ ។

*ស្រៈវែងបន្លឺឡើងដោយដំណើរខ្យល់បង្ហូរវែង ។ រីឯស្រៈខ្លីបន្លឺឡើងដោយដំណើរខ្យល់បង្ហូរខ្លី កាត់យ៉ាងរហ័សដោយបំណិទនៃខ្សែសំឡេង ។*

## ៣ . បំណែងចែក ទោល - ផ្សំ

ស្រៈអាចចែកជា ទោលនិងផ្សំ ៖

ស្រៈទោលមាន : [អ] [អ់] [អា] [អាំ] [អិ] [អឹ] [អឺ] [អុ] [អូ] [អេ] [អ៊] [អ៊់] [អ៊ិ] [អ៊ី] [អ៊ឹ] [អ៊ឺ] [អ៊ុ] [អ៊ូ] [អ៊ើ] [អ៊េ] [អ៊ែ] [អ៊ែ់] [អ៊ោ] ។

ស្រះផ្សំមាន : [អី] [អើ] [អែ] [អៃ] [អោ] [អៅ ] [អ៊ា] [អ៊ាំ] [អ៊ែ] [អ៊ៅ] [អ៊ិ] [អ៊ូ] [អឿ] [អៀ] ។

*ស្រះទោលកើតឡើងតែម្នាក់ឯង ។ រីឯស្រះផ្សំកើតឡើងដោយស្រះទោលពីរយ៉ាងតិចផ្សំចូលគ្នា ។*

## លំហាត់

១. ចូរស្រង់ពាក្យពីក្នុងប្រអប់ខាងក្រោម ដាក់ទៅក្នុងតារាងក្រុមពាក្យសូរស្រះពួក អ ក្រុមពាក្យសូរស្រះពួក អ៊ និងក្រុមពាក្យសូរស្រះពួក អ-អ៊ ឱ្យបានត្រឹមត្រូវ ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| របៀន | សប្បាយ | ជឿនលឿន | រលួស | ទាហាន | តារា | ស្ពាន | កៀន |
| ស៊ី | ដំណេក | ក្បឿង | តឿ | រណារ | ឆ្នាំង | ពាង | បង្គួរ | មៀន | ជញ្ជីង |
| ចាប៊ី | ហ៊ីង | សួរ | គ្រូ | ញញួរ | ជឿ | សសរ | ទុក្ខ | វិជ្ជា | សរសើរ |

| សូរស្រះពួក អ | សូរស្រះពួក អ៊ | សូរស្រះពួក អ-អ៊ |
|---|---|---|
| ❑ សរសើរ | ❑ គ្រូ | ❑ ជឿ |

២. ចូររកពាក្យដែលមានសូរស្រះពួក អ សូរស្រះពួក អ៊ និងសូរស្រះពួក អ-អ៊ ក្នុងមួយក្រុមឱ្យបាន ១០ពាក្យ ។

៣. ចូរអ្នករៀបពាក្យក្នុងប្រអប់ខាងក្រោមនេះ ដាក់ទៅតាមក្រុមសូរស្រះវែង ឬសូរស្រះខ្លី ។

| |
|---|
| អន្ទិត ទាត់ របង ញញឹម ប្រគល់ ក្រមា របាំង រីង សរសេរ លំបាក ហាត់ ដាក់ ឡើង រលួយ មោះមុត ដេក រនាំង ត្រកួន សំណាញ់ កសាង បណ្ដោយ ស្ររីង លិច ឪទីន ខ្ទីង សំបក បាល់ កង់ សារាយ ទុន |

៤. ចូរស្រង់ពាក្យសូរស្រះវែងនិងសូរស្រះខ្លី ឱ្យបាន ១០ពាក្យក្នុងមួយក្រុមពីក្នុងអត្ថបទ អំណានទី១ ។

៥. ចូររកពាក្យដែលមានស្រះទោលនិងស្រះផ្សំ ក្នុងមួយក្រុមឱ្យបាន ១០ពាក្យ ។



# រឿង ចៅកែចិត្តចោរ



## ក. សិក្សាពាក្យគន្លឹះ

- ប្រសាសន៍ (ន) : ពាក្យ សំដី ។
- ព្រះតេជគុណ (ន) : លោកអ្នកមានអំណាចនិងគុណដ៏ប្រសើរ លោកជាធំ លោកជាម្ចាស់ ។
- វង្សត្រកូល (ន) : ក្រសែស្រឡាយសាច់លោហិត តំណត្រកូល ។
- សាក្សី (ន) : អ្នកបានឃើញ ដឹង ឮ ហេតុការណ៍ពិតប្រាកដ ។
- មនុស្សធម៌ (ន) : ច្បាប់សម្រាប់ប្រដៅពួកមនុស្សឱ្យប្រព្រឹត្តសុចរិត ។
- លុយស៊ុប (ន) : ប្រាក់បន្ថែម ប្រាក់លើកទឹកចិត្ត ។
- រាជការ (ន) : ការរបស់ព្រះរាជា ការផែនដី ការរក្សាប្រទេស ។
- សមាគម (ន) : ការរួមគំនិតគ្នា ដំណើររួមកិច្ចការជាមួយគ្នា ។
- អាការ (ន) : គ្រឿងសម្គាល់ លក្ខណៈជាគ្រឿងសម្គាល់ រូបរាង ទ្រង់ទ្រាយ សភាព ភិនភាគ ឫកពា ។
- សម្បជញ្ញៈ (ន) : សេចក្ដីដឹងខ្លួន ការមិនភ្លេចខ្លួន ការប្រុងប្រយ័ត្នជានិច្ច ការត្រិះរិះរំពឹងជាដរាប ។
- នាយទុន (ន) : ពួកអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ អ្នកធ្វើជំនួញ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទល្ខោននេះ ចូរអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងឆាក តួអង្គ កាលអាកាស វិភាគតួអង្គ និងខ្លឹមសារអត្ថបទ ។

## គ. អត្ថបទ

### ផានីត-ហំ-ថៅកែ ឆាកទី២

ថៅកែ : (ដើរចូលមកមើលឃើញតែផានីត ព្រោះពូហំពួនទៅហើយ) ផានីតមានមនុស្សចម្លែកមកសួរអ្វី ... អ្វីដែរ ?

ផានីត : បាទដូចជាមិនឃើញទេ ។

ថៅកែ : អញទៅស្នាក់ខ្ចប់ឯក្រសួងគិញហើយ តែមិនដឹងជាបានផលយ៉ាងណា ? តែនៅផ្ទះប្រយ័ត្នមើលបើមានមនុស្សចម្លែកមកសួរ ឆ្លើយថាមិនដឹងៗទៅ ។

ផានីត : បាទ !

ហំ : (ស្ទុះចេញពីកន្លែងពួនមក) ក្រាបប្រណិប័តន៍ ថៅកែ

ថៅកែ : យី ! អាំហំ អាឯងឆ្កួតទេឬ ! មកធ្វើអ្វីហ្នឹង ?

ហំ : ព្រះបាទ ... មក ... សុំ ... នែ ...

ថៅកែ : អាឯងមិនដឹងថាគេប្រកាសតាមវិទ្យុរកចាប់ក្បាលទេ ? រួចអាឯងមកនេះគិតសម្លាប់ទាំងអស់គ្នាហ្ន៎ ?

ហំ : ខ្ញុំដឹងថាគេរកចាប់ខ្លួនខ្ញុំហើយ បានជាខ្ញុំឆ្លៀតមកបើកលុយរង្វាន់រួចនឹងអាលគេច ។

ថៅកែ : យី ! អានេះវង្វេងខួរហើយ គិតតែរង្វាន់ ជាប់គុកឯណោះមិនគិតទេ ។ ទៅ ! រត់ឱ្យបាត់ពីទីនេះទៅ !

ហំ : ថៅកែមេត្តាឱ្យលុយមកសិន !

ថៅកែ : (ហូតកាបូបយកលុយ) ហ៎ ! យក ២០០រៀល រួចទៅឯណាឱ្យបាត់ទៅអាចង្រៃវាយក៏ !

ហំ : កាលថៅកែមានប្រសាសន៍ថានឹងឱ្យខ្ញុំ ១ម៉ឺនរៀល ! ទាល់តែប៉ុណ្ណឹងដែរបានខ្ញុំប្រថុយលក់ស្បែក ។

ថៅកែ : យី អានេះ ! អញមិនដឹង ! បើ ២០០មិនយកអញមិនដឹងអីទេ ទៅ ! ចេញទៅ ! ធ្វើឱ្យអញមានរឿងដោយសារផង ឥឡូវមកលំអុករក ១ម៉ឺនទៀត អាណាតាមអាឯងទាន់ ។

ហាំ : ព្រះតេជគុណ ខ្ញុំទុកជាម៉ែឪហើយ មេត្តាខ្ញុំចុះ ។ ជីវិតខ្ញុំថ្លៃតែ ១ម៉ឺនរៀលទេ ។ ម្ដេចព្រះបាទម្ចាស់មានប្រសាសន៍ឯណាទៅវិញ ? ឱ្យខ្ញុំភ្លាមមក ១ម៉ឺនដូចជាបោះចោលឱ្យសត្វលង់ទឹកទៅចុះ ។ ព្រះតេជគុណស្គាល់ចិត្តខ្ញុំស្រាប់ហើយ ស៊ូស្លាប់រស់នឹងព្រះតេជគុណយ៉ាងណាៗ ... ។

ថៅកែ : យីអានេះ និយាយច្រើនណាស់ អញថាមិនដឹងៗហើយ ។ យកឡានអញទៅបុកគេខូចឡានអញ ងាប់មនុស្ស ៣នាក់ រឿងរ៉ាវនឹងអាឯងសំបើមណាស់ ប៉ោកេប្ដឹងផងឥឡូវមករឹតឯងមួយទៀត ។ ផានីត ជួយគិតមើល អានេះវាគិតជញ្ជក់ឈាមឯង ឱ្យនៅតែស្បែកនិងឆ្អឹងតែម្ដង ។

ហាំ : ព្រះតេជគុណជ្រាបស្រាប់ហើយ ! ខ្ញុំបរឡានបុកគេ គឺធ្វើតម្រូវចិត្តព្រះតេជគុណ ។

ថៅកែ : អញឱ្យបុកមែន តែមិនមែនឱ្យបុកទាល់តែមានស្លាប់មនុស្សឯណា !

ហាំ : ខ្ញុំក៏មិនមែនចង់ឱ្យមានមនុស្សស្លាប់ដែរ តែនរណាប៉ាន់គ្រោះថ្នាក់បាន !

ថៅកែ : អើ ! រួចអាឯងមកទារលុយអញទៀត !

ហាំ : ចុះថៅកែសន្យាថា បើខ្ញុំបុកឡានអាហុងលីបាន ឱ្យខ្ញុំ ១ម៉ឺន ។ ខ្ញុំទារតាមថៅកែសន្យា ។ (កម្មករចូល) ។

ថៅកែ : យី អាំ ! សំដីរឹងណាស់ហ្ន៎ !

ហាំ : ថៅកែ ខ្ញុំបាទត្រូវការ ១ម៉ឺនណាស់ ប្រពន្ធខ្ញុំឈឺ កូនត្រូវចូលអនុវិទ្យាល័យ ម្ដាយខ្ញុំចង់ធ្វើបុណ្យបន្តិចបន្តួចនឹងគេ ។ ឱ្យតែបាន ១ម៉ឺនមកខ្ញុំយកទៅឱ្យប្រពន្ធកូន ម្ដាយសប្បាយ ខ្ញុំយ៉ាងណាយ៉ាងនោះចុះ ខ្ញុំឥតគិតទេ ខ្ញុំសូមលើកដៃសំពះថៅកែម្ដង បើមិនអាណិតខ្ញុំទេ អាណិតតែប្រពន្ធកូនម្ដាយខ្ញុំចុះ កុំតែមានវង្សត្រកូល ខ្ញុំមិនត្រូវការ ១ម៉ឺនធ្វើអ្វីទេ ។

ថៅកែ : ឃើញទេអានេះ មានត្រង់នឹងឯងឯណា វាធ្វើការឱ្យឯងមិនមែនស្រឡាញ់ឯងទេ តែវាធ្វើការឱ្យឯងដើម្បីសម្រេចប្រយោជន៍វាឯនោះ ឯងមិនទាំងអាណិតអញផង ចុះឱ្យអញអាណិតឯងម្ដេចបាន ។

ហាំ : ឥឡូវឈប់និយាយ ពីអាណិតខ្ញុំចុះ និយាយពីពាក្យដែលថៅកែបានសន្យានឹងខ្ញុំ ។ ថៅកែបានថា "អាហាំឯងមើលស្រឿឡានអាហុងលីឱ្យចំឆ្អឹងជំនីរ អញឱ្យឯង ១ម៉ឺនរៀល" ។ ខ្ញុំបានបញ្ជាក់ ថៅកែថាឱ្យ ១ម៉ឺនមែន ឱ្យតែខ្ញុំធ្វើបាន ។

ថៅកែ : អញមិនដឹង អញមិនដែលនិយាយដូច្នេះទេ អាឯងចង់ទៅប្ដឹងៗទៅអាឯងនិយាយឱ្យបែកមេឃ ក៏គ្មានលោកណាជឿឯងដែរ ។ នាម៉ឺនគេជឿអញ អាសំអុយ ។

ហាំ : ថៅកែមិនខ្លាចឆ្កែទាល់ច្រកទេឬ ? លេងបញ្ឆោះឱ្យប្តឹងតិចខ្ញុំប្តឹងមែន ខ្ញុំមានសាក្សីខ្ញុំណាំ ព្រោះកាលថៅកែនិយាយ គឺថៅកែនិយាយនៅចំពោះមុខអាដែងអស់នោះ អាសុខ អាមាន អាទ្រី អាគង់ សុទ្ធតែបានឮ។ ពួកទាំងនោះវាទាំងបានឃាត់ខ្ញុំ កុំឱ្យធ្វើផង ។

ថៅកែ : (សើច) ពួកអាអស់នោះ វាមិនមែនឆ្កួតទៅសម្លាប់អញឱ្យអាឯងរស់នោះទេ ។ ទុកជាវាឮមែន ឱ្យលុយវាខ្លះទៅ វាទៅជាមិនឮវិញហើយ ។

ហាំ : កុំអាងទឹកប្រាក់ ហើយមើលងាយមនុស្សពេក ថៅកែ !

ថៅកែ : កុំអាងទឹកចិត្តមនុស្សធម៌ ហើយមើលងាយកម្លាំងប្រាក់អាហាំ !

ហាំ : អ្នកមានស្គាល់តែពីលុយតែម្តង គ្មានចិត្តមេត្តា គ្មានសម្បជញ្ញៈទេ ។

ថៅកែ : បើអ្នកក្រមិនស្គាល់លុយ អ្នកក្រមកទារ ១ម៉ឺនធ្វើអ្វី !

ហាំ : ព្រោះអ្នកក្រត្រូវការលុយយកមកចិញ្ចឹមជីវិត ខុសពីអ្នកមានដែលត្រូវការលុយសម្រាប់យកទៅអួតប្រាប់គេថា ខ្លួនមានលុយច្រើន ឬសម្រាប់ជាគ្រឿងបញ្ឆោតចិត្តឱ្យសប្បាយរីកថ្លើមធំជាន់គេ ជាន់ឯង ។

ថៅកែ : យីអានេះ កាន់តែព្រហើនឡើង ចេញពីផ្ទះអញឱ្យឆាប់ ។

ហាំ : ផានីតជាសាក្សីខ្ញុំមួយទៀត ថាថៅកែបានប្រើខ្ញុំបុកឡានអាហុងលីមែន ថាឱ្យខ្ញុំ ១ម៉ឺន ឥឡូវមិនឱ្យ ។ យើងនិយាយគ្នាទាំងប៉ុន្មាន ផានីតបានស្តាប់ឮទាំងអស់ ។

ថៅកែ : ចេញពីផ្ទះអញទៅ !

ហាំ : ឱ្យ ១ម៉ឺនមក !

ថៅកែ : ទៅ !

ហាំ : ទេ ។

ថៅកែ : អាហាំទៅ អាណិតអញហ៎ ! អញឱ្យ ៥០០រៀល ។

ហាំ : ថៅកែអាណិតខ្ញុំ ឱ្យខ្ញុំ ១ម៉ឺនមក ។

ថៅកែ : ១ម៉ឺន ! ១ម៉ឺន ! អញបានពីណាមក ?

ហាំ : បានពីខ្ញុំ ពីផានីត ពីអាសុខ ពីអាទ្រី ពីអាមាន អាគង់ ពីខ្មែរអ្នកធ្វើការទាំងអស់គ្នា ។

ថៅកែ : អាហាំចេញពីផ្ទះអញឱ្យឆាប់ក្រែងលោ ...

ហាំ : ក្រែងលោស្អី ខ្លាំងណាស់ចូលគុកទាំងអស់គ្នា ។ រឿងបុកឡាន ខ្ញុំគ្រាន់តែជាដៃជើង ខួរក្បាលគឺថៅកែឯង ។

ចៅកែ : អាហាំ ... អាហាំ ... អាហាំ ... អញអង្វរអាឯង ។

ហាំ : អង្វរខ្ញុំធ្វើអ្វី ឋានៈចៅកែ មិនត្រូវអង្វរខ្ញុំទេ ខូចកិត្តិយសអ្នកមានអស់ហើយ ។ ម្យ៉ាងទៀត ខ្ញុំលែងឆោតហើយ សំឡេងទន់របស់ចៅកែ គ្មានឥទ្ធិពលមកលើខ្ញុំទៀតទេ ។ លុយ ១ម៉ឺនរៀលដែលសន្យា ទើបលួងចិត្តខ្ញុំបាន ។

ចៅកែ : អាហាំចង់សម្លាប់អញឬ ? បានជាអញនិយាយអ្វី ឯងធ្វើដូចជាថ្លង់ ដូចជាស្ដាប់គ្នាពុំបាន ! ខំជួយឯងពីនោះមកឥតប្រយោជន៍សោះ ផ្គត់ផ្គង់តាំងពីខោអាវ លុយស៊ីបខ្លះទៀត កូនប្រពន្ធឯង ក៏អញមិនធ្មេចភ្នែកដែរ ។ តាំងពីនោះមក យើងមានរឿងសុខទុក្ខជាមួយគ្នាច្រើន ៖ អញពឹងអាឯងក៏មាន ម្ដេចឥឡូវនេះនិយាយស្ដាប់គ្នាពុំបាន ។ អញអស់ប៉ុណ្ណឹងហើយ ! មើលនាយជានីត ឯងនេះគ្មានការធ្វើ អញយកមកឱ្យធ្វើការជាមួយ អញជួយយុវជន ។ រឿងអ្វីដែលរាជការហៅឱ្យជួយជាតិ អញមិន ដែលខានទេ តាំងពីសង់សាលា ទិញឆ្នោតវត្ថុជួយសមាគម សង់សាលាបាលី សង់វត្តធ្វើបុណ្យទានសព្វគ្រប់ នៅតែមិនដឹងអញទៀត ។ អញសព្វថ្ងៃខ្សោះអស់ហើយ គេជញ្ជក់គ្រប់ទិសនៅតែស្បែកនិងឆ្អឹងទេ ។

ហាំ : អឺ ! រឿងចៅកែកម្សត់មែន គួរសរសេរជាសៀវភៅទុក ដើម្បីបញ្ជាក់ថាចៅកែជួយជាតិសាសនាយ៉ាងណាខ្លះ ។ ចៅកែនេះជួយខ្ញុំ ជួយក្នុយឯណោះដើម្បីប្រើយកកំរៃពីខ្ញុំនិងពីក្នុយ ឯណោះ ។ ជួយជាតិយកចំណេញពីជាតិ ។ ជួយសាសនាយកចំណេញពីសាសនា ។ គោរពសរសើរ ពីស្ដេចដើម្បីចំណេញពីស្ដេច កុំត្រដាងអំពើល្អប្រាប់យើងខ្ញុំនោះ ទៅមិនរួចទេ ចៅកែនិងខ្ញុំមានរឿងជាមួយគ្នា ឱ្យខ្ញុំ ១ម៉ឺនដូចសន្យាឬមិនឱ្យ ? បើឱ្យខ្ញុំ ខ្ញុំមិនឆ្លើយដាក់ចៅកែ ខ្ញុំសុខចិត្តធ្មេចភ្នែកជួយចៅកែទៀតចុះ ។ បើមិនឱ្យទេ ... ខ្ញុំសូមទោស ឆ្លើយដាក់ហើយ ។

ចៅកែ : ជានីត បើមានរណាមករកអញ ថាអញទៅជួបនឹងគេ ថាមិនដឹងជាថ្មើរម៉ានបានមកវិញទេ ។

ហាំ : ចៅកែគិតទៅណាហ្នឹង ? ទៅណាមិនបានទេ ។

ចៅកែ : អាឯងស្អី ក៏ផ្ដាច់សិទ្ធិអញមិនឱ្យទៅណាបាន ?

ហាំ : មានរឿងមួយវាភ្ជាប់ចៅកែនិងខ្ញុំ ។

ចៅកែ : អញទៅ !

ហាំ : ខ្ញុំមិនឱ្យទៅ !

ថៅកែ : អញនៅតែទៅ ។

ហំ : ទៅ ខ្ញុំទៅតាម ។

ថៅកែ : អញឡើងឡាន ។

ហំ : ខ្ញុំឡើងដែរ ។

ថៅកែ : អញទៅប្ដឹង ។

ហំ : ឱ្យតែប្ដឹងល្អហើយ ។

ថៅកែ : អញទៅហើយ ។

ហំ : ខ្ញុំទៅតាមដែរ ។

## ភាគទី៣ ផានីត-កម្មករ-សុខ-មាន-ទ្រី-គង់

(ដោយថៅកែនិងតៃកុងហំចេញពីទីនោះទៅ ពួកកម្មករធ្វើឡានដោយបានឮគេជជែកគ្នាយ៉ាងខ្លាំងក៏នាំគ្នាមកសួរមើលតើនរណាមានរឿងអ្វី)

ទ្រី : លោកប្អូនមានរឿងអ្វី ឮមាត់នរណាជជែកគ្នាខ្លាំងម្ល៉េះ ?

ផានីត : (ងើបមុខឡើងរួចឱនទៅវិញ)

សុខ : បើសួរគេមិនឆ្លើយដដែល មកទៅធ្វើការយើងវិញ ។

គង់ : ទេចង់ដឹង ។ នែ លោកប្អូននរណាមានរឿងអ្វី ?

ផានីត : រឿងធំណាស់ ខ្ញុំមិនហ៊ាននិយាយជម្រាបទេ ។

មាន : នែ ! ...នែ ... ពូហំគាត់មកហើយ គាត់ជាប់ឈ្លោះនឹងថៅកែ ពីរឿង ... ណ្ហើយកុំសួរខ្ញុំ ខ្ញុំនិយាយមិនរួចទេលោកអើយ ! ក្នុងលោកនេះ បើខ្ញុំកើតមកហើយកុំឱ្យមានភ្នែកមានត្រចៀកប្រហែលជាខ្ញុំបានសប្បាយជាង ។ ខ្វាក់ ថ្លង់ គ កុំឱ្យឃើញ ឮ និយាយចេញ ឮរឿងតែម្ដងទៅ វាធូរដើមទ្រូងជាង ! ខ្វាក់ត្រង់អាការៈ អាចនាំឱ្យមនុស្សពិបាកខ្លះមែន តែពិបាកនោះ តូចជាងអាការៈ ឃើញ ឮ នេះនិយាយហើយធ្វើអ្វីមិនកើត ។ មនុស្សយើងរស់សព្វថ្ងៃប្រយុទ្ធគ្នាក្នុងអយុត្តិធម៌ លួចល្បិចគ្នាទៅវិញទៅមកដើម្បីម្នាក់ៗបានស្រួល ល្អពីរោះតែសំដីក្រៅ តែមេទន្ទេញចាំមាត់សម្រាប់បង្រៀនសិស្សានុសិស្សឱ្យគ្នាសូត្រមួយថ្ងៃៗអំពីសេចក្ដីល្អទៀងត្រង់សម្បជញ្ញៈ ករណីយកិច្ចចិត្តមេត្តា ចិត្តបរិសុទ្ធ តែក្នុងជីវិតក្នុងសង្គម រឿងល្អទាំងអស់អំបាញ់មិញដែលបានរៀនចេះពីសាលាមក ហើយយកមកប្រើស្ទើរតែមិនកើត ក្នុងជីវិតនេះ ។

គង់ : លោកប្អូនកុំអាលផ្ទុះភ្លាម អញ្ជើញនិយាយប្រាប់យើងឱ្យស្រួលមក រឿងយ៉ាងម៉េច ?

ផានីត : រឿងឡានបុកពីម្សិល !

សុខ : ណ្ហើយគិតឱ្យសព្វៗទៅ មិនត្រូវយើងចង់ដឹងរឿងគេទេ ។ មកទៅធ្វើការវិញពួកយើង ។

គង់ : រឿងនេះវាទាក់ទងដល់យើងទាំងអស់គ្នា សុខត្រូវតែយើងចង់ដឹងបានត្រូវ ។

ផានីត : បងទាំងអស់សួរខ្ញុំថា រឿងបុកឡានរួចវាម្ដេចទៅ ចុះក្រែងដឹងស្រាប់ហើយរឿងលុយ ១ម៉ឺន ។

មាន : អើ ... អើ ... អើ ...

ផានីត : ឥឡូវស្ងាត់ទៅហើយ ថៅកែថាគាត់មិនដឹងទេ ។

ទ្រី : ពួកអានាយទុនទុកចិត្តមិនបានទេ ដូចត្រីឆ្តោអីចឹង ដើម្បីធំធាត់ វាគ្មានញញើតនឹងស៊ីកូនឯងឡើយ ។

សុខ : លោកបងហំ គាត់មិនជឿខ្ញុំៗនិយាយប្រាប់ថាឱ្យប្រយ័ត្ន តិចលោថៅកែមិនទទួលដឹងយើងងាប់តែម្តង ។

ផានីត : ឥឡូវពូហំឡាំប៉ា ឱ្យខាងតែបាន ។

សុខ : អា ! លេងមិនកើតទេដូចនេះ រឿងនេះធំណាស់ !

មាន : មកទៅធ្វើការវិញ តិចលោរាលដាលដល់យើង រឿងនេះអញច្បាស់ជាមិនយកជ័រញ្ចៅមកត្បៀតត្បៀកទេ ។ អញស្រេចតែមិនដឹង រួចគ្នាតែប៉ុណ្ណឹងហើយ ។ នុះឮសូរដូចជាថៅកែមកវិញហើយ មកទៅធ្វើការវិញពួកយើង ។

ទ្រី : លោកប្អូនមើលផងណា៎ លោកបងហំតែហួសចិត្តគាត់ៗព្រលែងឥតស្គាល់ថៅកែអ្វីទេ ។

គង់ : បើមានរឿងមិនស្រួល មើលទៅហៅពួកយើងផង ។ ទាំងអស់គ្នាត្រឡប់ទៅធ្វើការវិញទៅ ។

*(ដកស្រង់ពីរឿងថៅកែចិត្តចោរ ឆ្នាំ១៩៨៩ត្រង់ភាគទី ២និងទី ៣ ទំព័រទី៨ដល់ទី១៧)*

## សំណួរ

១. តើពូហាំមានតួនាទីជាអ្វី ? ហើយបានធ្វើសកម្មភាពអ្វីខ្លះ ?

២. ហេតុអ្វីបានជាពូហាំ បើកឡានបុកឡានអ៊ុងប៉ាងហុង លី ?

៣. ហេតុអ្វីបានជាពូហាំ មានទំនាស់ជាមួយថៅកែ ?

៤. តើរឿងនេះ មានតួអង្គណាខ្លះ ? ចូរប្រាប់តួអង្គឯកនិងតួអង្គរង ។

៥. ចូរវិភាគតួអង្គ ពូហាំ និង ថៅកែ ។

៦. តើអត្ថបទនេះជាប្រភេទអត្ថបទអ្វី ? ហើយប្រភេទនៃអត្ថបទនេះមានរចនាបថខុសគ្នាពីប្រភេទអត្ថបទរឿងប្រលោមលោក ឬរឿងនិទានយ៉ាងដូចម្តេច ?

៧. តើអត្ថបទដកស្រង់នេះមានប៉ុន្មានឆាក ? តើការប្តូរឆាក កើតឡើងនៅពេលណា ?

៨. តើអត្ថបទដកស្រង់នេះមានរចនាបថយ៉ាងដូចម្តេចខ្លះ ?

៩. ចូរសិក្សាអំពីកាលអាកាសនៃរឿង ។

១០. ចូរបង្ហាញឱ្យឃើញថា អំពើរបស់តួអង្គថៅកែ តួអង្គហាំ ជាអំពើខុសឆ្គងនិងផ្លូវ :

- ពុទ្ធចក្រ រកអំណះអំណាង ។
- អាណាចក្រ រកអំណះអំណាង ។
- សីលធម៌ រកអំណះអំណាង ។

១១. ចូរពន្យល់សំដីរបស់តួអង្គ :

- ហាំ "កុំអាងទឹកប្រាក់ ហើយមើលងាយមនុស្ស" ។
- ថៅកែ "កុំអាងទឹកចិត្តមនុស្សធម៌ ហើយមើលងាយកម្លាំងប្រាក់" ។

# រឿងតេជោយ៉ត



ចូរស្ដាប់អត្ថបទរឿងល្ខោន "តេជោយ៉ត" ត្រង់ឆាកទី ១១ ។ នៅពេលអ្នកស្ដាប់អត្ថបទល្ខោននេះចូរអ្នកស្ដាប់ដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងឆាក តួអង្គ កាលអាកាស វិភាគតួអង្គ និងខ្លឹមសារអត្ថបទ ។

## សំណួរ

១. តើតេជោយ៉តមានតួនាទីជាអ្វី ? ហើយបានធ្វើសកម្មភាពអ្វីខ្លះ ?

២. តើម៉ឺនថៃចុងរ៉ាក់មានតួនាទីជាអ្វី ? ហើយបានធ្វើសកម្មភាពអ្វីខ្លះ ?

៣. ហេតុអ្វីបានជាតេជោយ៉តសម្លាប់ម៉ឺនថៃចុងរ៉ាក់ ?

៤. តើរឿងនេះមានតួអង្គប៉ុន្មាននាក់ ? អ្នកណាខ្លះ ? តើអ្នកណាជាតួអង្គឯកនិងអ្នកណាជាតួអង្គរង ? តើតួអង្គនីមួយៗមានតួនាទីជាអ្វី ?

៥. តើតេជោយ៉តជាមនុស្សដូចម្ដេច ? ហើយអ្នកយល់យ៉ាងណាចំពោះ ទង្វើរបស់តេជោយ៉ត ?

៦. តើអ្នកសង្កេតឃើញថា អត្ថបទដកស្រង់នេះមានប៉ុន្មានឆាក ?

៧. ចូរបង្ហាញអំពីកាលអាកាសនៃរឿង ។

# ការតែងរឿងល្ខោនខ្លី

ខ្មែរយើងមានល្ខោនច្រើនប្រភេទដូចជា ល្ខោនបាសាក់ ល្ខោនយីកេ ល្ខោនមហោរី ល្ខោននិយាយ ល្ខោនខោល ល្ខោនអាប៉េ ល្ខោនស្រមោល (ស្បែកធំ ស្បែកតូច) ។ល។ អត្ថបទល្ខោន គឺជាអត្ថបទអក្សរសិល្ប៍មួយប្រភេទ ដែលអ្នកនិពន្ធចងក្រងឡើងសម្រាប់យកទៅសម្ដែងជាសិល្បៈល្ខោន។ អត្ថបទល្ខោនស្រដៀងគ្នានឹងអត្ថបទរឿង ត្រង់ធាតុសំខាន់ដូចជា ចំណោទបញ្ហា តួអង្គ កាលអាកាស និងមូលន័យ។ ទម្រង់សំណេររបស់អត្ថបទល្ខោនខុសពីទម្រង់សំណេររបស់អត្ថបទរឿង។ អត្ថបទល្ខោនចែកជា ឈុត និងឆាក។ នៅខាងដើមអត្ថបទនីមួយៗមានបញ្ជីរាយនាមតួអង្គ និងឋានៈ ឬបទសន្ទនា រវាងតួអង្គ និងតួអង្គ។ ក្នុងអត្ថបទល្ខោននិយាយ អ្នកនិពន្ធសរសេរសេចក្ដីបញ្ជាក់ពីរូប ទឹកមុខ កាយវិការ ឬសំឡេងរបស់តួអង្គក្នុងវង់ក្រចក។

## លំហាត់

ចូររៀបគ្នាជាក្រុម រួចពិភាក្សាតែងរឿងល្ខោននិយាយ ឬល្ខោនបាសាក់ ឬយីកេខ្លីមួយរឿង ទាក់ទងនឹងប្រធានបទ :

- សេចក្ដីក្លាហាន
- ការហ៊ានលះបង់របស់តួអង្គក្នុងបុព្វហេតុណាមួយ (គ្រួសារ សហគមន៍ ...)ក្នុងការតាក់តែង អ្នកត្រូវគិតទៅលើ ៖
- ការរាយឈ្មោះតួអង្គនិងតួនាទី មុខងារនៅខាងដើមរឿង
- ការរៀបចំសាច់រឿងជាឈុត ឆាក
- រៀបចំសំណេរជាអត្ថបទសន្ទនារវាងតួអង្គនិងតួអង្គ
- បញ្ជាក់ពី :
    - សកម្មភាព
    - កាយវិការ
    - ទឹកមុខ
    - សំឡេងតួអង្គ (ដោយសរសេរក្នុងវង់ក្រចក)

មេរៀនទី ៥

# អតីតកាល



អតីតកាលជាពេលវេលាដែលកន្លងផុតទៅ ។ ការសិក្សាពីអតីតកាលជាមធ្យោបាយដ៏ល្អសម្រាប់ជាមេរៀន ឬជាបទពិសោធក្នុងការដោះស្រាយបញ្ហាផ្សេងៗនាពេលបច្ចុប្បន្ននិងអនាគត ។ ជោគជ័យធំៗមួយចំនួនអាចកើតឡើងអាស្រ័យដោយបទពិសោធពីអតីតកាល ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាពីស្ថានភាពរស់នៅរបស់ប្រជាជនខ្មែរយើងនាសម័យពីអតីតកាល ។ ទន្ទឹមនឹងនេះអ្នកនឹងបានសិក្សាបន្ថែមទៀតអំពីកាព្យរូបារម្មណ៍ វិធីមួយចំនួន គឺវិធីផ្ទួន រណ្តំ និងបដិវិធី ខ្លឹមសារអត្ថបទ សង្ខេបអត្ថបទពាក្យកាព្យទៅជាពាក្យរាយ សញ្ញាស្រៈ និងសំណេរតែងសេចក្តីអធិប្បាយពន្យល់ ។

# វិធីផ្ទួនពាក្យនិងវិធីរណ្តំ

តាមរយៈស្នាដៃអក្សរសិល្ប៍ដែលបុព្វបុរសយើងបានបន្សល់ទុកមកដល់សព្វថ្ងៃ យើងឃើញមានអត្ថបទមួយចំនួនដូចជា សាស្ត្រាល្បែង ច្បាប់ទូន្មាន ... បានតាក់តែងជាពាក្យកាព្យ ប្រកបដោយឃ្លោងឃ្លាណែងណងយ៉ាងពីរោះរណ្តំ ។ នេះជាសក្ខីភាពមួយបញ្ជាក់អំពីវិធីសាស្ត្របង្កើតរូបារម្មណ៍របស់កវីយើង ដោយយករូបភាពកំណាព្យ "ពីរោះត្រចៀក" ជាមធ្យោបាយដើម្បីងាយស្រួលបញ្ចូលខ្លឹមសារនៃការអប់រំទូន្មានទាំងឡាយដែលលោកចង់បានឱ្យដក់ដិតជាប់ក្នុងអារម្មណ៍របស់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយៗ ។

វិធីសាស្ត្រតាក់តែងដែលបង្កើតឱ្យមានរូបារម្មណ៍មាន វិធីផ្ទួនពាក្យ វិធីរណ្តំ បដិវិធីជាដើម ។

## ១ . វិធីផ្ទួនពាក្យ

ចូរពិនិត្យអត្ថបទកាព្យខាងក្រោម ៖

*ឧទាហរណ៍ ១ :*

ខ្លួនខ្ញុំខំហាត់ ខំលះខំកាត់ ខំពត់លត់ដំ
ខំជំនះចិត្ត ខំឥតបន្ធូរ ខំអើយសែនខំ
សាងខ្លួនជានិច្ច ។

*(កំណាព្យខ្មែរភាគ ២ ក្រសួងអប់រំ ១៩៨៤)*

*ឧទាហរណ៍ ២ :*

ពុកខ្ញុំពូកែខាងទាក់ទាញ ទាក់គ្រប់ជំនាញអន្តរជាតិ
ទាក់វិនិយោគិនមកព្រោងព្រាត បោះទុនថែមទៀតទាំងក្រៅក្នុង ។
ពុកខ្ញុំពូកែខាងស្ថាបនា ផ្តល់ស្ពានសាលាគ្រប់ខេត្តក្រុង
ប្រព័ន្ធប្រឡាយទឹកបម្រុង ឥឡូវស្រែក្រុងសែនជិតគ្នា ។

*ឧទាហរណ៍ទី ១ :* កវីបានប្រើពាក្យ "ខំ" ដើម្បីពន្លេចឱ្យឃើញកាន់តែច្បាស់នូវសកម្មភាពទាំងប៉ុន្មាន គឺមនុស្សម្នាក់គត់ដែលជាអ្នកធ្វើ ។

*ឧទាហរណ៍ទី ២ :* កវីបានប្រើពាក្យ "ទាក់ ពូកែ" ដើម្បីបង្ហាញឱ្យឃើញច្បាស់ពីគុណសម្បត្តិរបស់ "ពុកខ្ញុំ" ។ ក្រៅពីនេះវិធីផ្ទួនពាក្យក៏មានប្រើក្នុងការតាក់តែងដើម្បីរៀបរាប់តាមធម្មជាតិផងដែរ ។

*ឧទាហរណ៍ ៣ :* ភ្លៀងស្រក់ស្រិបៗមិនឈប់ឈរ ភ្លៀងហូរតាមទសូរតក់ៗ
កង្កែបកូបៗតាមដើមកក់ ខ្យល់បក់ហ៊ូៗតាមបង្អួច ។

*(ចិត្តក្រមុំ ទំព័រទី៦)*

តាមរយៈឧទាហរណ៍នេះ កវីបានយកពាក្យ "ស្រឹបៗ តក់ៗ កួបៗ ហ៊ូៗ" មកប្រើផ្ទួនគ្នា ដើម្បីត្រាប់សំឡេងធម្មជាតិ ហើយបង្កើតសួរស័ព្ទពីរោះផងដែរ ។

តាមរយៈឧទាហរណ៍ខាងលើ យើងអាចសង្កេតឃើញថា វិធីផ្ទួនពាក្យ វិធីតាក់តែងដែលធ្វើឱ្យកំណាព្យពីរោះផង និងសង្កត់ន័យលើគំនិតណាមួយ ឬបង្កើតសញ្ចេតនាអ្វីមួយផង ។

*វិធីផ្ទួនពាក្យ គឺជាវិធីដែលកវីតាក់តែងដោយប្រើពាក្យ (ព្យាង្គ) តែមួយច្រើនដងក្នុងឃ្លា ឬវគ្គ ដើម្បីបង្ហាញនិងសង្កត់ន័យព្រមទាំងបង្កើតសញ្ចេតនានិងរូបារម្មណ៍នៅក្នុងអត្ថបទកាព្យរបស់ខ្លួន ។*

## លំហាត់

ចូរបង្ហាញវិធីផ្ទួនពាក្យនៅក្នុងវគ្គកាព្យខាងក្រោម ៖

ត្រីត្រីត្រីត្រី ពេញទឹកភក់ដី ត្រីហូបមិនអស់
ត្រីច្រើនមុខណាស់ ឥតខ្វះខាតសោះ ហូបងៀតឬស្រស់
តាមចិត្តហូបចុក ។

ត្រីឆ្អើរត្រីងៀត ត្រីប្រឡាក់ទៀត ត្រីផ្អកប្រហុក
ត្រីម៉ាំទឹកត្រី ប្រុសស្រីសម្រុក បានច្រើនស្រណុក
ប្រមូលធនធាន ។

*(ស កាពុន កំណាព្យខ្មែរភាគ ២ ក្រសួងអប់រំ ១៩៨៤)*

## ២ . វិធីរណ្ដំ

វិធីរណ្ដំមានពីរយ៉ាង គឺរណ្ដំស្រៈនិងរណ្ដំព្យញ្ជនៈ

### ក. វិធីរណ្ដំព្យញ្ជនៈ

ចូរពិនិត្យវគ្គកាព្យខាងក្រោម ៖

ស្រីស្រីស្រុកស្រែស្រុះស្រស់ស្រាយ កកេះកកាយកាន់កិច្ចការ
តូចៗតាក់តែងតាមតាតា បួតបេះបោចបារបានបែនបុក ។

*(សិល្បៈតែងកំណាព្យ ពេជ្រទុំ ក្រវិល ១៩៨៨)*

ក្នុងឧទាហរណ៍ខាងលើផ្ទួនព្យញ្ជនៈ "ស ក ត ប" ធ្វើឱ្យមានសំឡេងពីរោះ ដើម្បីបង្កើតរូបារម្មណ៍មួយ គឺ "សោតរូបារម្មណ៍" ។

## ១. វិធីរណ្តំស្រៈ

ចូរពិនិត្យវគ្គកាព្យខាងក្រោម ៖

ស្តាយសាច់ស្រអែមកែមសំដី ទ្រលន់ទន់ខ្ចីទាំងមំសា

ទ្រលុកម្លេះសមទុក្ខខ្លោចផ្សា អនិច្ចាមិនគួរឃ្លាតគ្នាបាន ។

ស្តាយសាច់ទ្រលន់ទន់ត្រជាក់ ស្តាយភក្ត្រផូរផង់បុប្ផាផាន

ស្តាយសៀងសំនៀងយ៉ុតយោវមាន្យ ប្រៀបបាននឹងសៀងសត្វករវីក ។

*(សិល្បៈតែងកំណាព្យ ពេជ្រ ទុំក្រវិល)*

ក្នុងឧទាហរណ៍ខាងលើនេះ កវីបានយកស្រៈមកប្រើឱ្យជួនសូរសំឡេងទាក់ទងរណ្តំគ្នា បង្កើតជាតន្ត្រីភាពដែលធ្វើឱ្យពីរោះដល់សោតិន្ទ្រីយារម្មណ៍ ។

> ***វិធីរណ្តំ គឺជាវិធីដែលកវីប្រើព្យញ្ជនៈដដែលៗ ឬស្រៈដដែលៗក្នុងឃ្លា ឬវគ្គ ដើម្បីបង្កើតឱ្យសំឡេងពីរោះនិងបង្កើតរូបារម្មណ៍មួយគឺសោតរូបារម្មណ៍ ។***

## លំហាត់

ចូរបង្ហាញវិធីរណ្តំក្នុងវគ្គកាព្យខាងក្រោម ៖

[...] លីលាលយលង់ដានដងផ្លូវ ត្រូវត្រង់មាគ៌ា ឃ្លាតខ្នុលខ្មាញ់

ខំស្រូតរូតរះកាត់គ្រោកគ្រាញ់ អរញ្ញវាលព្រៃរំពៃយល់ ។

ក្រឡេកក្រលៀងឆ្មៀងពីអាយ ច្បាស់ជានាងម្តាយទាវនិមល

នេះគឺមិនអ្នកដទៃទាល់ ទៅជិតទៀបស្គាល់ដល់ជាម្តង ។

នាងនោះស្ទុះឡើងលើគ្រឹះស្ពាន ប្រមាណត្រូវមាត់ជាដន្លង

ថាអ្នកអញ្ជើញមកប៉ុនប៉ង បំណងបំណាច់គ្រាច់ទៅឆ្ងាយ ។

ឬមួយជាមករកយើងខ្ញុំ សូមសុំប្រសាសន៍សង់រ៉ាប់រ៉ាយ

ឱ្យដឹងកិច្ចកលអធិប្បាយ ចែកចាយកុំលាក់ឱ្យឡើងមក ។

អ្នកទាំងប៉ុន្មានបានដល់ផ្ទះ ម្តាយទាវអរណាស់ទើបរៀបស្លក

នំដាក់តុស្ពាន់រន្ទាន់យក ឡើងមកលើផ្ទះសំពះសួរ ។

ថាយើងខ្ញុំមកដោយចិត្តស្ម័គ្រ ទទួលធុរៈគួរមិនគួរ

ទោះបីមោះហ្មងសូមលន់តួ ឆ្អើងជួដូចម្តេចសូមមេត្តា ។ [...]

# អត្ថបទដកស្រង់រឿង ទុំទាវ



## ក. សិក្សាពាក្យគន្លឹះ

- អាគម (ន) : មន្តគាថាដែលរៀនចេះតៗគ្នាជារៀងមក របៀន ។
- សាមណេរ (ន) : បព្វជិតកាន់សីលដប់ ... (លោកនេន) ។
- តោក (ន) : ភាជនៈឈើ ឬស្មាច់មានជើងស្រដៀងនឹងតុស្ពាន់ រាងកាច់ជ្រុងក្រឡូង ជ្រៅជាងតុច្រើនដាំខ្យង ឬដាំកញ្ចក់ បិទមាសសម្រាប់ដាក់ទ្រព្យអ្វីៗដែលជាវត្ថុចេញមុខ ។
- និន្ទា (ន) : ដំណើរតិះដៀល ការរិះគន់ ដំណៀល ។
- ព្រះសព្វញ្ញូ (ន) : លោកអ្នកត្រាស់ដឹងសព្វ (ព្រះសម្មាសម្ពុទ្ធ) ។
- វោហារ (ន) : សំនួនសំដី ។
- ពុទ្ធដីកា (ន) : ព្រះបន្ទូលព្រះពុទ្ធ ។ បព្វជិតនិយាយស្ដីតែពាក្យពិតតាមលំអានពុទ្ធវចនៈ ប្រយ័ត្នមិនហ៊ានឱ្យល្អៀង ។ ឧទាហរណ៍ៈ លោកគ្រូពុំយូរមានពុទ្ធដីកា ថា អើតាមអាប្រាថ្នាត្រាច់ ។
- លែបខាយ (គុឬកិ) : និយាយលលេង ចែចង់... ។
- អាចក្តី (បុ.ស) : ពាក្យសម្រាប់បព្វជិត ប្រើជាជំនួសឈ្មោះខ្លួនក្នុងការនិយាយទៅកាន់គ្រហស្ថដូចពាក្យ "អាត្មា"ដែរ ។ មានន័យថា "ជាអ្នកដឹងសេចក្តីខុសត្រូវរាក់ជ្រៅបាន ឬថា "ជាអ្នកអាចដឹងកិច្ចការក្នុងក្តី គឺក្នុងវត្តអារាមបាន" ។

- ផ្នួស (ន) : អំពើដែលបួស ភេទដែលបួស (បព្វជ្ជា) ។
- ក្រសែ (ន) : ជំនួរវង្សត្រកូល ទំនង លំអាន ។
- ពិភាល់ (កិ) : ចាប់មន្ទិល ភ្នកគិតព្រួយដោយចាប់មន្ទិល ។
- អប្រិយ (គុ) : ដែលមិនជាទីស្រឡាញ់ ដែលពុំគួរស្រឡាញ់ ។
- ឡូក (កិ) : បើសំដីលូកលឱ្យដឹងខ្លួន ឬឱ្យអន់ចិត្ត និយាយចំអកឱ្យ ។
- ឧបាសក (ន) : អ្នកដល់ព្រះរតនត្រ័យជាទីពឹង ឬជាទីរឭក គឺគ្រហស្ថដែលចូលកាន់ពុទ្ធសាសនាស៊ប់ ហើយកាន់សីលធម៌ខ្ជាប់ខ្ជួនតាមច្បាប់សម្រាប់ពុទ្ធសាសនិកជនជាគ្រហស្ថ ។
- ស្រើបស្រាល (កិ) : កើតតម្រេកទៅរកតាម ត្រេកត្រអាល ឬត្រអេកត្រអាលភ្លេចខ្លួន ។
- ភីលៀង (ន) : បងចិញ្ចឹម អ្នកគយគន់ឃ្លាំចាំរក្សា អ្នកបីបាច់រក្សាមើលការខុសត្រូវ ។ ពាក្យនេះខ្មែរច្រើនហៅចំពោះអ្នកមើលថែទាំបីបាច់រក្សាព្រះរាជបុត្រ ឬអ្នកថែររក្សាកូនមន្ត្រីធំ និងអ្នកមានធនធានស្តុកស្តម្ភ ។
- សង្ឃាដី (ន) : សំពត់ឃ្នាប ឬសំពត់សម្រាប់ពាក់ពាត គឺសំពត់ដែលដេរក្ដបគ្នាជាពីរជាន់ ឬបួនជាន់មានផ្ទាំងខ្ពង់ សង្កាត់ដូចគ្នានិងឧត្តរាសង្គៈដែរ ជាបរិក្ខាររបស់បព្វជិតពុទ្ធសាសនិក សម្រាប់ប្រើឃ្លុំការពាររងារ សម្រាប់បត់ជាផ្នត់ពាក់ពាតលើឧត្តរាសង្គៈក្នុងកាលធ្វើសង្ឃកម្ម ឬបត់ប្រើជាកម្រាលសិងមួយដងមួយកាលក៏បាន ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរដែលទាក់ទងទៅនឹងប្រភពនិងប្រភេទអត្ថបទ វិធីបង្កើតកាព្យរូបារម្មណ៍ និងខ្លឹមសារអត្ថបទ ។

## គ. អត្ថបទ

១. ផ្កាថ្លែងសម្តែងដើមឈ្មោះទុំ នៅខេត្តបាភ្នំដែនដីស្រែ
កើតកបទំនៀមមានឪម៉ែ ប៉ុន្តែហេតុត្បិតឥតសម្តែង ។
២. កើតឡើងលុះធំល្មមប្រមាណ ឆ្នាំច្រើនសោតបានម្តាយតុបតែង
យកទៅឱ្យរៀនចោលគ្រឿងល្បែង ស្វះស្វែងរកវត្តវិហារធំ ។

៣. លោកគ្រូទទួលស្រួលព្រះទ័យ ប្រិតប្រៀនទុំវៃខាងអាគម
អាចគាប់ដោយប្រាជ្ញប្រឹងជញ្ជុំ ខិតខំចង់បួសផ្នួសសាមណេរ ។
៤. សំណាក់ចិតបេរចំណោរលង់ មាននេនមួយអង្គគ្រាន់បើដែរ
នាមឈ្មោះនេនពេជ្រលេចក្រសែ នេនទាំងពីរកែតែតោកលក់ ។
៥. ទុំមានវោហារប្រាជ្ញាផ្សេង មានទាំងសំឡេងរូបខ្ចីល្អក់
ល្អទ្រង់អង្គកាយសាយទឹកមុខ រួចទុកនេនពេជ្រស្រេចជាប្អូន ។
៦. នេនពេជ្រចេះស្រេចខាងផ្លុំប៉ី ឈ្លាសវៃប្រសប់ភ្លេងមាំមួន
អ្នកនេនពីរពិតគិតគុំកួន ចំណេះក្នុងខ្លួនប្រហែលគ្នា ។
៧. ធ្វើតោកធ្វើទុកលក់ជាច់ខ្លះ នៅផ្ទះទៀបវត្តជាមឹងមា
លុះដល់រដូវត្រូវរងា ព្រឺប្រុងអង្គាជាទុក្ខព្រួយ ។
៨. អកុសលដល់គ្របសង្កត់កាយ ជួបនេនពេជ្ររាយដូចខ្លួនមួយ
ថានេនពេជ្រអើយចូរគាត់ជួយ យើងលក់តោកមួយៗយូរហើយ ។
៩. វាគ្មានចំណេញជំនួញទាល់ កុំឆ្ងល់ដូចពាក្យបុរាណឆ្លើយ
ថានៅវៀងអាយជិតបង្កើយ លំហែលំហើយតែប្អូនស្រី ។
១០. បុរាណលោកថាមិនខុសសោះ ខ្លួនយើងកំលោះក្នុងលោកិយ
បួសស៊ីបាយបាត្រមិនចេះអ្វី នៅថ្ងៃចោលម្សៀតឆ្លៀតដើរឆ្ងាយ ។
១១. គិតស្រេចព្រមព្រៀងម៉ៀងមើលគ្រប់ ខំទប់មិនឈ្នះរៀបខ្វល់ខ្វាយ
ទៀនធូបបានស្រាប់ប្រញាប់កាយ ឡើងដាក់អង្គថ្វាយបង្គំគាល់ ។
១២. លោកគ្រូពុំយូរមានពុទ្ធដីកា ថានេនទៅណាដូចពិភាល់
នេនទូលពុទ្ធដីកាថាទាំងទាល់ ក្រាបទូលកុំឆ្ងល់សូមមេត្តា ។
១៣. ព្រោះយើងទាំងសងប៉ងបង្គំ លាព្រះគុណធំខ្ញុំព្រះករុណា
ទាំងពីរអ្នកនឹងចរយាត្រា ប្រោសប្រាណមានការទៅស្រុកឆ្ងាយ ។
១៤. នៅវត្តប្រាកដជាអផ្សុក ជាទុក្ខគ្មានល្ហែក្នុងអង្គកាយ
ខ្ញុំលណាស់ព្រះគុណមិនសប្បាយ ក្រហល់ក្រហាយខ្វល់ចង់ដើរ ។
១៥. ដោយសារត្រូវខ្យល់ដល់រដូវ លាព្រះគុណទៅក្រែងប្រសើរ
ប្រសិនដឹកតោកយកទៅផ្ញើ គ្រាន់បើនៅអាយចាយមិនដាច់ ។
១៦. លោកគ្រូពុំយូរមានពុទ្ធដីកា ថាអើតាមអាប្រាថ្នាត្រាច់
ថាលាអញទៅលក់ដូរស្រេច ចាំបាច់សារសព្វប្រាប់អញថ្វី ។

១៧. ទៅចុះគាប់ខុសប្រយ័ត្នណា កុំឲ្យអីអាឃើញរូបស្រី
បត់បួចឡកលេងមិនគប្បី ដំនៀលអប្រិយមកដល់គ្រូ ។
១៨. កេរ្តិ៍ខ្មាសនិន្ទានាលោកិយ ខុសពីវិន័យព្រះសព្វញ្ញូ
បើទៅលក់អស់កុំនៅយូរ គិតគួរថ្លៃថោកមកវិញឆាប់ ។ ...
១៩. ដល់ស្រុកភូមិស្ថានបានលក់តោក បាសកទិញយកខ្លះសល់នៅ
សល់ខានប៉ុន្មានលក់តាមផ្លូវ ខំបរដល់ទៅខេត្តត្បូងឃ្មុំ ។
២០. ប្រទល់ដែនដល់ខេត្តទទឹង ថ្ងៃតែងឈប់នឹងត្បិតជនជុំ
ចង់ទិញតោកនេនខ្លះគន់គុំ សម្លឹងនេនទុំសមរូបឆោម ។
២១. ខ្លះថាអើម្ល៉េះប្រសិនណា បានអញប្រវាឱបប្រលោម
ប្រឡែងតាមចិត្តគិតចង់ចោម មៀងមើលព្រឺព្រមប្រឈមឈប់ ។
២២. បៀតបែរស្នេហ៍ស្និទ្ធជិតអណ្តូង ជ្រួលច្រូងស្រើបស្រួលទីទួលម្លប់
ឈ្មោះពោធិ៍ជើងខាលត្រកាលគ្រប់ មើលសព្វស្រីប្រុសស្រុះស្រើបស្រាល ។
២៣. នេនដាក់ស្នាក់ស្និទ្ធជិតភូមិស្ថាន ប្រមាណបាសកជួយឃឹស្នាល
លក់ដាច់ដោយយល់ឃើញត្រកាល បណ្តាលបណ្តោយឱ្យយូរនៅ ។
២៤. ឈប់រង់អង់ខានបានច្រើនថ្ងៃ អាល័យអ្នកនេនមិនឱ្យទៅ
ចាកទីដែននោះព្រោះយល់ត្រូវ រដូវដល់ដែលប្រហែលថា ។
២៥. ប្រមាណដោយគិតគំនិតអ្នក ដែលឱ្យនេនស្នាក់ប៉ងប្រាថ្នា
ប្រយោជន៍ឱ្យនេនមើលសាស្ត្រា នេនមានប្រាជ្ញាចេះលែបខាយ ។
២៦. សំឡេងផ្អែមល្ហែមស្រួយពីរោះ ស្តាប់ទាំងកំលោះចាស់មេម៉ាយ
ក្រមុំត្បូងឃ្មុំរត់ប្រញាយ ប្រញាប់ចង់ស្តាប់សព្ទភាសា ។
២៧. កាលណោះនាងនោជាភីលៀង នាងទាវបានឆៀងចរយាត្រា
កាន់ក្អមថ្មិតថ្មមនឹកប្រាថ្នា ចូលទៅស្តាប់ការណ៍ដឹងសេចក្តី ។
២៨. ឈរទ្រឹងរឹងខ្លួនពួនចាំស្តាប់ ពីរោះហាក់ផ្កាប់មុខដល់ដី
ស្រងាកស្រងោចស្រងល់ស្រី នោនឹកបេតីមិនស្តីសោះ ។
២៩. ចាំទៅដល់ផ្ទះប្រាប់ទាវគ្រប់ ទាវនៅក្នុងម្លប់សមស្រណោះ
នាងជាម្តាយទាវមានរបស់ កូនស្រស់រូបស្រេចដាច់ស្រីផង ។

៣០. នោនឹកក្នុងចិត្តគិតស្រេចស្រាប់ ដងទឹកទូលឆាប់ដើរផ្តៀងផ្គង
ដល់ផ្ទះនោឡើងទៅជាម្តង សាសងរ៉ាយរ៉ាប់ប្រាប់ទៅថា ។
៣១. ទាវអើយទាវស្រីសេចក្តីនេះ លោកនេននោះចេះមើលសាស្ត្រា
សំឡេងស្រួយស្រាប់ស្តាប់ភាសា ដូចសត្វសារិកាពិសាចេក ។
៣២. ទាវទៅនៅយូរគួរពិភាល់ មិនសល់គេប្រាប់ជាក់ហើយត្រេក
ត្រង់ណោះកុំឆ្ងល់បានដឹងពេក តម្រេកចង់ស្តាប់ហ៊ានប្រាប់ម្តាយ ។
៣៣. ចេញមកក្រៅក្រាបទៀបមាតា ទាវថាម៉ែអើយអើម៉ែអាយ
អាណិតកូនម្តងទើបកូនរាយ បាសកយើងអាយឆ្ងាយវត្តឋាន ។
៣៤. មិនដែលស្តាប់សោះកំលោះលោក មិនដឹងថាមកពីណាថ្កាន
ឮនោគេថាពីរអង្គប្រាណ សម្រាន្តកាយយកលក់តោកលេង ។
៣៥. ថាមកពីឆ្ងាយដល់អាយស្នាក់ ផ្ទះគេមួយជាក់ជានេនក្មេង
ពីរោះមែនដឹងផ្សឹងតាមឈ្វេង នោថាសំឡេងមានគ្រាន់បើ ។
៣៦. នាងជាម្តាយទាវផ្ទៀងស្តែងស្តាប់ ឮទាវកូនប្រាប់ឆ្លើយថាអើ
លូកដៃយកស្បៃដណ្តប់ដើរ ញាំងញើផ្ទៀងឈ្មងទំនងចាស់ ។
៣៧. បានដល់យល់មនុស្សស្រុះជៀវនោ ម្តាយទាវថាឱមែនជាក់ច្បាស់
ឡើងទៅឃើញនេនតូចល្អណាស់ ផ្គុំហត្ថសំពះក្រាបបង្គំ ។
៣៨. ហើយទូលសួរថាករុណាម្ចាស់ និមន្តទៅផ្ទះសត្វជាខ្ញុំ
ឆាន់ស្លាបានម្តងហើយយើងសុំ និមន្តលោកកុំខានណា៎ម្ចាស់ ។
៣៩. នេនទុំបានស្តាប់សព្ទញោមមន្ត ភ្នែកតែងគយគន់មើលឱ្យច្បាស់
ឆ្លើយថាបើមន្តញោមរហ័ស ទៅផ្ទះរៀបរួចអាចក្តីទៅ ។ ...
៤០. នេនពេជ្រនេនទុំជំនុំព្រម នេនពេជ្រថាល្មមឆាន់ទៅដែរ
ទុំថាចុះគោនៅក្នុងស្រែ ដាច់ខ្សែស៊ីស្រូវត្រូវសងគេ ។
៤១. នេនពេជ្រគេចថាអើទៅចុះ បើខុសឆាន់រួចខ្លួនទទេ
ក្រែងវិលទៅវត្តលោកគ្រូជេរ ថាឯងវេះវេរដើរចង់ស្រី ។
៤២. កាត់ដើរគ្រប់ខេត្តហេតុទាំងម្លេះ អាងមានតម្រិះក្នុងលោកិយ
ហៅឆាន់រំពួកមិនគប្បី ទំនៀមចាស់ស្តីមិនចេះខុស ។

៤៣. ថាដើរមានប្អូនខ្លួនជាសង្ឃ ទើបបានត្រូវត្រង់ឥតមានមោះ
បើដើរទៅក្តីបាសកសោះ កេរកោះថ្លោះធ្លោយឱ្យមានប្រាំ ។
៤៤. នេះទៅម្នាក់ឯងក្រែងគេថា បាសកសិកាគេមកផ្តាំ
ឱ្យមន្តទៅលេងឆាន់ស្លាថ្នាំ មន្តចុះឆាន់ចាំគោម្នាក់ឯង ។
៤៥. នេនទុំងឿងងំជញ្ជ្រំគិត ព្រួយចិត្តត្បិតពេជ្រលេចសម្តែង
យកសព្ទទំនៀមមកថ្លាថ្លែង រួចទុំតុបតែងស្បង់សង្ឃដី ។ ...

*(ដកស្រង់ពីរឿងទុំទាវ ភិក្ខុ សោម ទំព័រទី ៥-៩)*

## សំណួរ

១. ចូរបង្ហាញប្រភពនិងប្រភេទអត្ថបទដកស្រង់ខាងលើ ។

២. តើអត្ថបទនេះបានបង្ហាញពីទំនៀមទម្លាប់ខ្មែរយ៉ាងណាខ្លះ ?

៣. តើកវីបានប្រើវិធីនិពន្ធបែបណាខ្លះ ?

៤. ចូរអ្នកបង្ហាញពីវិធីបង្កើតកាព្យរូបារម្មណ៍ដោយវិធីផ្ទួននិងរណ្តំក្នុងអត្ថបទដកស្រង់នេះ ។

៥. ចូរលើកយកលក្ខណសម្បត្តិ (រូប សំឡេង)របស់តួអង្គនេនទុំនិងនេនពេជ្រមកបង្ហាញដោយភ្ជាប់អំណះអំណាងផង ។

៦. តើអ្នកយល់យ៉ាងណាចំពោះសកម្មភាពនេនទុំនិងពេជ្រចាកចេញពីវត្តវិហារធំទៅជួញដូរ "តោក"ផង ស្មូត្រ (ទេសនា) ផងនៅតាមភូមិស្រុក ?

៧. ចូរអ្នកធ្វើការសិក្សា "ថាដើរមានប្អូនខ្លួនជាសង្ឃ ទើបបានត្រូវត្រង់ឥតមានមោះ បើដើរទៅក្តីបាសកសោះ កេរកោះថ្លោះធ្លោយឱ្យមានប្រាំ" :

- បង្ហាញពីខ្លឹមសារ ។
- តើវិធីតែងកាព្យ (ចួន ផ្ទួន រណ្តំ) មានភាពសមស្របឬទេ ? ចូរបញ្ជាក់ពីមូលហេតុនៃចម្លើយនោះ ។

៨. តាមរយៈអត្ថបទនេះ តើស្ថានភាពជីវភាពប្រជាជនខ្មែរយើងសម័យនោះមានលក្ខណៈដូចម្តេចដែរ ?

# សញ្ញាស្រៈ

អ្នកបានសិក្សាស្រៈរួចហើយ ។ ស្រៈគឺជាសូរសំឡេងដែលកើតមកពីដំណើរខ្យល់តាមបំពង់សំឡេងបន្លឺឡើងដោយគ្មានទំនប់ប្រកបដោយភាពច្បាស់លាស់ ។ ឥឡូវអ្នកត្រូវសិក្សាបន្តអំពីសញ្ញាស្រៈ ។ សញ្ញាស្រៈមានពីរពួក គឺសញ្ញាស្រៈនិស្ស័យនិងសញ្ញាស្រៈពេញតួ ។

## ១ . សញ្ញាស្រៈនិស្ស័យ

សញ្ញាស្រៈនិស្ស័យមានពីរបែប ៖

### ក. សញ្ញាស្រៈកប់តួ

*ឧទាហរណ៍ :* កសាង ប្រទេស ទ្រទ្រង់ ។

- ក្នុងសូរ " [ក] (កសាង) និង [ប្រ់] (ប្រទេស)" មានសូរស្រៈ [អ] និង [អ់] ។ ប៉ុន្តែយើងមើលពុំឃើញសញ្ញាស្រៈទាំងពីរនេះទេ ។
- ក្នុងសូរ " [ទ្រ] និង [ទ្រ់] (ទ្រទ្រង់)" មានសូរស្រៈ [អ៊] និង [អ៊់] ។ ប៉ុន្តែយើងមើលពុំឃើញសញ្ញាស្រៈទាំងពីរនេះដែរ ។

មានន័យថា សញ្ញាស្រៈ [អ] [អ់] [អ៊] [អ៊់] កប់តួរបស់ខ្លួននៅក្នុងព្យញ្ជនៈ ។

*សញ្ញាស្រៈកប់តួ គឺជាសញ្ញាស្រៈ [អ] [អ់] [អ៊] [អ៊់] ដែលគេសន្មតថាមានកប់ក្នុងព្យញ្ជនៈទាំង ៣៣តួ ។ សញ្ញាស្រៈកប់តួកំណត់ដោយសញ្ញា [់] (តាមទម្លាប់រួចមកហើយ) ។*

### ខ. សញ្ញាស្រៈភ្ជាប់តួ

*ឧទាហរណ៍ :* ធ្វើដើម្បីហូប ឬក៏ហូបដើម្បីមូលហេតុការងារ ?

ក្នុងឧទាហរណ៍នេះយើងសង្កេតឃើញថា ៖

- សញ្ញា " ◌ើ " នៅជាមួយនឹង " ធ្វ និង ដ "
- សញ្ញា " ◌ូ " នៅជាមួយនឹង " ហ និង ម "
- សញ្ញា " ◌ា " នៅជាមួយនឹង " ក និង ង "
- សញ្ញា " ◌ើ " នៅជាមួយ " ធ្វ " កត់សូរ [អឺ] តែ

- សញ្ញា “ ◌ើ ” នៅជាមួយ “ ដ ” កត់សូរ [អើ] វិញ។
- សញ្ញា “ ◌ូ ” នៅជាមួយ “ ហ ” កត់សូរ [អូ] តែ
- សញ្ញា “ ◌ូ ” នៅជាមួយ “ ម ” កត់សូរ [អ៊ូ] វិញ។
- សញ្ញា “ ◌ា ” នៅជាមួយ “ ក ” កត់សូរ [អា] តែ
- សញ្ញា “ ◌ា ” នៅជាមួយ “ ង ” កត់សូរ [អ៊ា] វិញ។

មានន័យថា “ ◌ើ ◌ូ ◌ា ” ភ្ជាប់តួរបស់ខ្លួនទៅនឹងតួព្យញ្ជនៈ “ ធ្វ ដ ហ ម ក ង ” ដែលសញ្ញាស្រៈនីមួយៗអាចកត់សូរពួក [អ]ផង ពួក [អ៊] ផង។

ដូច្នេះសញ្ញាស្រៈភ្ជាប់តួ គឺជាសញ្ញាស្រៈដែលអាចប្រើបានជាមួយនឹងសញ្ញាព្យញ្ជនៈពួក [អ]ផង ពួក [អ៊] ផង។

- សញ្ញាស្រៈភ្ជាប់តួមាន ៖ ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ។
- សញ្ញាស្រៈភ្ជាប់តួកត់សូរពួក អ ៖ [អា] [អិ] [អី] [អឹ] [អឺ] [អុ] [អូ] [អួ] [អើ] [អឿ] [អៀ] [អេ] [អែ] [អៃ] [អោ] [អៅ]។
- សញ្ញាស្រៈភ្ជាប់តួកត់សូរពួក អ៊ ៖ [អ៊ា] [អ៊ិ] [អ៊ី] [អ៊ឹ] [អ៊ឺ] [អ៊ុ] [អ៊ូ] [អ៊ួ] [អ៊ើ] [អឿ] [អៀ] [អ៊េ] [អ៊ែ] [អ៊ៃ] [អ៊ោ] [អ៊ៅ]។

*សង្កេត :*

- សញ្ញាស្រៈ ◌ួ ◌ឿ ◌ៀ កត់សូរ [អួ] [អឿ] [អៀ] តែមួយពួកប៉ុណ្ណោះ។
- សញ្ញាស្រៈខ្លះមានឈ្មោះផ្សេងទៀតដូចជា

  “◌ា” ហៅថាទាញយារ។

  “◌ុ” រុកជើង ឬ បុកជើង។

  “◌េ” ហៅថាបាំងឈើ ...។
- សញ្ញាស្រៈភ្ជាប់តួប្រើនៅកណ្ដាលព្យាង្គ ឬ ចុងព្យាង្គ

  *ឧទាហរណ៍ :* កើត < ក + ◌ើ + ត

  ឈី < ឈ + ◌ី

*ដូចនេះសញ្ញាស្រៈប្រើសម្រាប់កត់សូរស្រៈ។*

## ២ . សញ្ញាស្រៈពេញតួ

*ឧទាហរណ៍ :* ឥសូរ ឱកាស ឯក ។

ឧទាហរណ៍នេះបញ្ជាក់ថា " ឥ ឱ ឯ " អាចប្រើតែឯកឯងបាន ។ សញ្ញាស្រៈពេញតួមាន អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ឱ ។

*សញ្ញាស្រៈពេញតួ គឺជាសញ្ញាស្រៈពិសេសក្នុងពាក្យខ្ចីពីបាលីសំស្ក្រឹតដែលអាចសរសេរនិងប្រើប្រាស់តែឯកឯងបាន ដោយពុំចាំបាច់ភ្ជាប់នឹងសញ្ញាព្យញ្ជនៈ ។*

*សម្គាល់:* សញ្ញាស្រៈពេញតួប្រើនៅដើមព្យាង្គ ឧទាហរណ៍ ឧបករណ៍ ឪពុក អវយវៈ ... ។

### លំហាត់

១. ចូរពិនិត្យពាក្យខាងក្រោម រួចបង្ហាញថា ព្យាង្គណាខ្លះមានស្រៈកប់តួនៅជាមួយ ។

ក ភូមិ ឧត្រី ដើមគ ទូកង ដើមញ ឆ្នាំច ។

២. ចូរប្រាប់ទីតាំងសញ្ញាស្រៈភ្ជាប់តួទាំងអស់ដែលភ្ជាប់ជាមួយនឹងព្យញ្ជនៈដោយបង្ហាញឧទាហរណ៍ផង ។

៣. ចូររកនាមអ្នកកវីដែលមាននៅក្នុងកំណាព្យដកស្រង់នេះ ៖

យើងនឹងថ្លែងនាមតាមបញ្ញា ដើមថាតាមឈ្មោះចំពោះងាយ
តួ "ស" រាប់រៀបធៀបនិយាយ ទើបទាយប្រកបរាប់រៀបទៅ ។
ទាញយារ "ស" សព្ទប្រកប "ម" បាំងឈើលើ "ស" ទើបបានត្រូវ
ឈ្មោះដើមដូចនឹងពីម៉ែឪ ឥឡូវនាមបែកចែកដោយគុណ ។

៤. ចូរសរសេរសូរនៃសញ្ញាស្រៈពេញតួ ចំពោះពាក្យ

ឦសាន ឥន្ទ ឧក្រិដ្ឋ រឭក ឯរំ ឥឡូវ ឪម៉ាល់ ឮរាវីណ ។

# បដិវិធី

ដូចម្ដេចហៅថាបដិវិធី ? តើបដិវិធីមានអ្វីខ្លះ ?

បដិវិធីចែកជាពីរបែប ៖

ក. កវីលើកអង្គពីរ ដែលមានគុណភាព អំពើ មតិទស្សនៈផ្ទុយគ្នាមកបង្ហាញ ។

*ឧទាហរណ៍ :*

ក្នុងសង្គមចាស់

នគរថ្កើងណាស់ ថ្កើងថ្កានហួសហេតុ

ផ្ទះថ្មក៏ច្រើន លូតកើនហួសមេឃ

មានសប្បាយពេក ក្រវែកទុក្ខក្តុក ។

*(ដកស្រង់ពីកំណាព្យភាគ ២ ក្រសួងអប់រំ ឆ្នាំ ១៩៨៥)*

បដិវិធីក្នុងឧទាហរណ៍ខាងលើ កើតឡើងពីអង្គពីរ គឺអ្នកមាននិងអ្នកក្រ ដែលលើកយកគុណភាពប្រឈមមកប្រៀបគ្នាដើម្បីពន្លេចឱ្យឃើញរឹតតែច្បាស់ឡើងនូវតម្លៃបដិភាពនៃអង្គទាំងពីរ ។ (បដិវិធីបែបនេះ ច្រើនស្ថិតនៅក្នុងឃ្លា ឬល្បះផ្សេងគ្នា)

មាន ↔ ក្រ

↓ ↓

សប្បាយ ↔ ទុក្ខ

ខ. ប្រឈមស្ថិតនៅត្រង់កវីយកអង្គតែមួយដែលមានគុណភាពអំពើ មតិ ទស្សនៈប្រឈមគ្នាមកបង្ហាញ (បដិវិធីបែបនេះច្រើនស្ថិតនៅក្នុងឃ្លាតែមួយ) ។

*ឧទាហរណ៍ :*

មនុស្សធម៌បង់បាត់

ខ្លួនមនុស្សចិត្តសត្វ លែងស្គាល់ប្អូនបង

ជាតិជាមួយគ្នា ប្រហារចាប់ចង

ចិត្តពាលយង់ឃ្នង មោហ៍បាំងជុំជិត ។

*(ដកស្រង់ពីកំណាព្យមើលផែនដីខ្មែរ ជួន ម៉េន ទំព័រ ១៧)*

បដិវិធីខាងលើនេះ កើតពីការប្រឈមលក្ខណៈក្នុងអង្គតែមួយ ។ អង្គជា "មនុស្ស" មនុស្សគួរតែមានចិត្តជាមនុស្ស មិនគួរមានចិត្ត "ជាសត្វឡើយ" ។ ទីនេះមានការប្រឈមរវាង "ខ្លួនមនុស្ស" និង "ចិត្តសត្វ" ។

ចូរអ្នកសាកល្បងរកវិធីប្រឈមដែលកវីប្រើក្នុងវគ្គនីមួយៗ ខាងក្រោមនេះ ៖

១. បងមិនអាណិតចិត្តប្អូនផង | ទុក្ខធ្ងន់កន្លងពុំមានស្បើយ
សមប្អូនក្សិណក្ស័យទេដឹងអើយ | ទុក្ខអើយទោម្ទេញពេញជាថ្មី ។ [...]
ម្តាយទាវជិះទូកទៅជាមួយ | ប្រុសស្រីរងួយមិនដឹងការណ៍
គិតស្មានទាវស្ម័គ្រនឹងក្សត្រា | អរឥតឧបមានាំទាវទៅ ។

*(ដកស្រង់ពីរឿងទុំទាវ ភិក្ខុសោម)*

វគ្គនេះកវីបានយកអារម្មណ៍មនុស្សពីរនាក់ ដែលប្រឈមគ្នា គឺចិត្តនាងទាវ "ទុក្ខធ្ងន់" ផ្ទុយនឹងចិត្តម្តាយ "ត្រេកអរសប្បាយ" ។

ទាវ ↔ ម្តាយ
↓ ↓
ទុក្ខធ្ងន់ ↔ ត្រេកអរសប្បាយ

ដូចនេះ កវីប្រើវិធីប្រឈមគុណភាព (អារម្មណ៍មនុស្សផ្សេងគ្នា) ។

២. សម្តីថាស្មើ

តែឃើញអំពើ | គឺជាចោរប្លន់
អ្នកម្ចាស់មិនឱ្យ | នឹងត្រូវអាសន្ន
ជាប់ទោសយ៉ាងអន់ | ជាន់កវាយចោល ។

*(ដកស្រង់ពីកំណាព្យមើលផែនដីខ្មែរ ជួន ម៉េន)*

វគ្គនេះគេយកការប្រឈមសំដីនិងអំពើរបស់មនុស្សម្នាក់មកបង្ហាញ ។

សម្តី ↔ អំពើ
↓ ↓
ស្មើ ↔ ប្លន់

៣. មាត់ស្រែកសប្បាយ

តែចិត្តនិងកាយ រីងស្រពោនស្វិត

សុភមង្គល ដូចយប់ងងឹត

ចង់ឆ្លាក់រូបរីត ដូចពស់លេបប្រាណ ។

*(ដកស្រង់ពីកំណាព្យមើលផែនដីខ្មែរ ជួន ម៉េន)*

កវីបានពន្លេចឱ្យឃើញការប្រឈមរវាងអត្ថៈខាងក្រៅ "វាចា" របស់មនុស្ស "មាត់ស្រែកសប្បាយ"និង អត្ថៈខាងក្នុង (អារម្មណ៍) "តែចិត្តនិងកាយ រីងស្រពោនស្វិត" ។

៤. ធ្វើណាស់ក្រណាស់

ប្រឹងរីតតែខ្វះ ខ្វះគ្មានឈប់ខាន

អ្នកមានដេកសុខ ស្រណុកក្សេមក្សាន្ត

ម្ដេចក៏ទ្រព្យបាន ហូរចូលគ្មានឈប់ ។

*(ដកស្រង់ពីកំណាព្យភាគ ២ ក្រសួងអប់រំ ឆ្នាំ ១៩៨៥)*

វគ្គនេះកវីបានបង្ហាញហេតុនិងផលប្រឈមគ្នា ។

| | | |
|---|---|---|
| ហេតុ | ↔ | ផល |
| ↓ | | ↓ |
| ធ្វើណាស់ | ↔ | ក្រណាស់ |
| ប្រឹង | ↔ | ដេក |
| ↓ | | ↓ |
| ខ្វះ | ↔ | ទ្រព្យបាន |

*បដិវិធី ជាល្បិចវិធីមួយបែបដែលកវីលើកយកគុណភាពពីរ អំពើ ចលនា ឬសកម្មភាពពីរ សំនួនសេចក្ដីពីរ មតិទស្សនៈពីរដែលមានភាពផ្ទុយ មកដាក់ប្រឈមគ្នា ដើម្បីជាមធ្យោបាយពន្លេចឱ្យឃើញតម្លៃអ្វីមួយដែលកវីចង់បង្ហាញ ។*

## លំហាត់

ចូរអ្នកបង្ហាញពីវិធីប្រយោមក្នុងវគ្គនីមួយៗ របស់កំណាព្យខាងក្រោម ៖

១. ខ្លួនស៊ីតាមឃ្លាន

ប្រើគេបំពាន គ្មានក្ដីអាណិត

ខ្លួនធាត់ថ្លាថ្លោស គ្មាចុះស្គមស្វិត

សម្រុកឥតគិត ខ្លួនស្រែកតែមាត់ ។

*(ដកស្រង់ពីកំណាព្យមើលផែនដីខ្មែរ ជួន ម៉េន)*

២. វាយតែជាតិខ្លួន

ហើយស្រែកផ្ទួនៗ ថាខ្លួនវាយខ្លាំង

ឃើញសុទ្ធខ្មោចខ្មែរ នៅតែស្រវាំង

ងងើលភាន់ភាំង ថាខ្មែរអប្រិយ ។

*(ដកស្រង់ពីកំណាព្យមើលផែនដីខ្មែរ ជួន ម៉េន)*

៣. អ្នកស្រែធ្វើស្រូវ

ក្រោមភ្លៀងផ្គរត្រូវ សូរ្យសែងចំហាយ

ផលហូបបបរ ត្រដរខ្វះបាយ

អ្នកនៅសុខកាយ បាយដូចសំឡី ។

*(ដកស្រង់ពីកំណាព្យភាគ ២ ក្រសួងអប់រំ ឆ្នាំ ១៩៨៥)*

៤. សក់ចេះតែស

ចិត្តចង់តែល្អ មិនព្រមបណ្ដោយ

ឱ្យសាច់ឈាមផ្លាស់ ឱ្យចាស់ទន់ខ្សោយ

រត់តែតាមក្រោយ ចាស់រត់លឿនជាង ។

*(ដកស្រង់ពីកំណាព្យ កេង វ៉ាន់សាក់ គុកកាមកិលេស ទំព័រ ៧៦)*



# ការពិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ



## ក. សិក្សាពាក្យគន្លឹះ

- អាទិទេព (ន) : ទេព្តាខាងដើម ទេព្តាមុនបង្អស់ ។
- អង្គការ (ន) : ទីកន្លែងចាត់ការធំៗ ។
- អវិចី (ន) : ឈ្មោះរណ្តៅនរកធំមួយ ក្នុងពួកនរកធំទាំង៨រណ្តៅ ។ "នរកមានអណ្តាតភ្លើងឥតស្រាក" ។
- ព្រហ្មវិហារ "ធម៌" (ន) : ធម៌ជាលំនៅនៃចិត្តដ៏ប្រសើរមានបួនយ៉ាង គឺ មេត្តា ករុណា មុទិតា និងឧបេក្ខា ។
- តិរច្ឆាន (ន) : ពពួកសត្វដែលមានរូបរាងកាយ ដូចជា គោ ក្របី ដំរី សេះ ។ល ។
- សមូហភាព (ន) : ភាពនៃការរួបរួម ការប្រមូល ។
- អន្ធការ (ន) : ងងឹត ។
- សិទ្ធិ (ន) : សេចក្តីសម្រេច សេចក្តីសម្រេចផល ឬផលសម្រេច ការសម្រេចប្រយោជន៍ ការដាច់ស្រេច ការសមប្រកប ការសមតាមបំណង សេចក្តីសុខ សេចក្តីចម្រើន សេចក្តីសក្តិសិទ្ធិ សេចក្តីខ្លាំងពូកែ

សេចក្ដីសម្បូណ៌ សេចក្ដីសម្រេចតាមអំណាចច្បាប់ អំណាច សេចក្ដីអង់អាច មុខការដែលត្រូវសម្រេចលើខ្លួន ។

- សីលធម៌ (ន) : សីលដែលជាធម៌ ឬសីលនិងធម៌ កិរិយាមារយាទ សណ្ដាប់ធ្នាប់ ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អ ។
- ខ្នោះ (ន) : ឈ្មោះគ្រឿងដាក់ក្ដីមួយយ៉ាង ធ្វើដោយឈើ ឬដែកសម្រាប់ដាប់ភ្ជាប់ជើងដៃ ។
- ស្ទើ (កិ) : សួរឱ្យដឹងសិន ពិគ្រោះ ឬប្រឹក្សាមុនសិន ។
- អាសន្ន (គុ) : ភ័យ គឺហេតុឬអ្វីៗដែលគួរខ្លាចនៅជិតបង្កើយ ឬតាមប្រកិតជិតមកៗ ។
- ប្រវ័ញ្ច (កិ) : បញ្ឆោត បោកប្រាស ឬឆបោក ។
- ពុល (គុ) : ដែលមានពិសអាចបណ្ដាលឱ្យរង៉ាប់រងើ ឱ្យក្អួតចង្អោរ ឬធ្វើទុក្ខខ្លាំងដល់ឈឺស្លាប់ក៏មាន ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរទាក់ទងនឹងប្រវត្តិតែងនិពន្ធសង្គមបរិយាកាស វិធីបង្កើតកាព្យរូបារម្មណ៍ ... ។

## គ. អត្ថបទ

**(បទកាកគតិ)**

១. មេសាចិតប្រាំ នគររងកម្ម សិទ្ធិសេរីចុះ
សីលធម៌ជាតិ ឃ្លាតធ្លាក់ផ្លូវខុស ជនទាំងស្រីប្រុស
ជាប់ទោសពេញដី ។

២. គុកខ្នោះថាគ្មាន ភរទាំងបំពាន លាក់មិនឱ្យស្ទើ
អំពើបាញ់កាប់ ចងចាប់ប្រក្រតី ច្បាប់នៅសម្ដី
អ្វីៗស្រេចថា ។

៣. មាត់ជាអាទិទេព ឱ្យយំឱ្យពេប ឱ្យអត់អាហារ
នីឡុងចំណាង ចងវាយឥតការណ៍ នេះជាវាចា
គេថាទន់ភ្លន់ ។

៤. សំដីថាស្មើ តែឃើញអំពើ គឺជាចោរប្លន់
អ្នកម្ចាស់មិនឱ្យ នឹងត្រូវអាសន្ន ជាប់ទោសយ៉ាងអន់
ជាន់កវាយចោល ។

៥. ដកដាក់អង្គការ គាត់មានខ្លឹមសារ តែដូចស្រមោល
ភូតភរប្រវ័ញ្ច មិនអាចដេញដោល ប្រើឱ្យរត់បោល
បម្រើអាត្មា ។

៦. នាឡិកាខោអាវ ឃើញច្បាស់ក្រឡៅ គេពាក់ហ៊ឺហា
យកបុគ្គលម្នាក់ ដាក់ជាអង្គការ បំភ័ន្តនេត្រា
ថាតំណាងជន ។

៧. អង្គការខ្លួនឯង ខំស្រែកក្ដែងៗ ថាមានគុណធ្ងន់
ព្រះនិងម៉ែពុក ទុកជាគុណធ្ងន់ មិនស្មើនឹងជន
ដែលហៅអង្គការ ។

៨. ក្ដៅដូចអុសគល់ អរិចិពុំដល់ គ្មានព្រហ្មវិហារ
ចិត្តជាត្រីឆ្ដោ ជាចោរហិង្សា អួតអាងអាត្មា
ជាគ្រូមនុស្សជាតិ ។

៩. បង្ខំឱ្យជឿ ស្មោះត្រង់ជំនឿ ហាមកុំរវាត
កុំប្រើបញ្ញា អង្គការជាជាតិ គ្មានអ្វីខុសឃ្លាត
ចាកមាគ៌ាត្រូវ ។

១០. ហាក់សជានិច្ច ទោះបីគគ្រិច ខ្មៅខ្នរអាស្រូវ
ដូចអាទិទេព មានបែបត្រឹមត្រូវ បរិសុទ្ធគ្រប់ផ្លូវ
ត្រូវជាសាកល ។

១១. ន័យមហាលោតផ្លោះ អង្គការធ្វើទាស់ ប្រាសចាកហេតុផល
គ្រែងមានមហាជន វិះគន់ខ្វក់ខ្វល់ ងាយភរពន្យល់
ជាមហាលោតផ្លោះ ។

១២. ធ្វើហើយរើរុះ រើឡើងរើចុះ រើទាល់តែអស់
ដូចត្រីពុលភក់ រុលរុកផ្លេកផ្លោះ រើទាល់តែអស់
ខ្សោះក្រៀមស្រកា ។

១៣. រើទាល់លែងយល់ លែងដឹងលែងស្គាល់ វប្បធម៌ខេមរា
ខំលៃឱ្យឃ្លាត ពីជាតិដូនតា ឡេះឡុញដូចស្វា
ស្រវាដូងទុំ ។

១៤. សុទ្ធអ្នកវិភាគ ហាឡើងលើកពាក្យ ជាអ្នកប្រាជ្ញធំ
ឃើញអាក្រក់ណាស់ បែបខ្មែរនិយម ល្អតែសង្គម
តាមបែបបទថ្មី ។

១៥. រុះរើសាលា ស្អប់អ្នកសិក្សា ទាំងប្រុសទាំងស្រី
ដុតផ្សារភូមិវត្ត ជនបទបុរី ទ្រព្យជាតិអ្វីៗ
បំផ្លាញចោលអស់ ។

១៦. រួចស្រែកប្រហារ ថាខ្មាំងឬស្សា មុខខ្លួនរំដោះ
វាដុតបំផ្លាញ រុះរើចោលអស់ នេះល្បែងយកឈ្មោះ
រឿងស្វាពពៃ ។

១៧. អ្វីៗខ្លួនចាត់ ក្នុងភាពសម្ងាត់ រួចមកបកប្រែ
ថានេះគឺជា សម្ងហភាពខ្មែរ ហេតុនេះត្រូវតែ
គោរពគ្រប់គ្នា ។

១៨. រឿងប្តីប្រពន្ធ ធ្ងន់អើយសែនធ្ងន់ ក្រៀមក្រំឱរា
គេរៀបបង្ខំ ឱ្យផ្គុំគ្រួសារ គ្មានសួរចិន្តា
ស្ម័គ្រឬមិនស្ម័គ្រ ។

១៩. ស្រេចតែចិត្តគេ បើប្រកែកទេ នឹងមានគ្រោះថ្នាក់
ចោទថាជាខ្មាំង ប្រឆាំងនឹងបក្ស ត្រូវមានឧបសគ្គ
គ្រោះថ្នាក់ខ្លោចផ្សា ។

២០. ឱ្យតាមសំដី ថាជនប្រុសស្រី ម្ចាស់ស្រែចំការ
ម្ចាស់ដីម្ចាស់ទឹក ម្ចាស់ព្រៃព្រឹក្សា ម្ចាស់កម្ពុជា
ម្ចាស់រដ្ឋអំណាច ។

២១. ឮពាក្យថាម្ចាស់ ពីរោះស្តាប់ណាស់ គួរបាត់ភ័យខ្លាច
តែគេក្លែងទេ ដូចខ្មោចបិសាច គេឱ្យអំណាច
ដូចសត្វកង្កែប ។

២២. បានឡើងជាម្ចាស់ មានសិទ្ធិអ្វីខ្លះ អ្នកសម្បូណ៌បែប
សម្បូណ៌តែយំ សម្បូណ៌តែពេប អត់ឃ្លានគ្រប់បែប
ព្រាត់ប្រាសមរណា ។ ...

២៣. យកប្រជាជន ធ្វើជារូងរន្ធ ជាលេណដ្ឋាន
ប្រើអំណាចបក្ស លាក់បំបាត់ដាន វាយចោលប៉ុន្មាន
ច្រានថាប្រជាជន ។

២៤. ល្បិចសុទ្ធប្រហារ លាក់ខ្លួនដូចខ្លា សំងំលួចប្លន់
ដេកនៅមិនសុខ ជាទុក្ខស្ពោស្លន់ ទីសទាសដូចមាន់
រាន់រកវាកពង ។

២៥. ខ្លាចភាពសេរី គិតធ្វើស៊ីស្ពី សុទ្ធត្រាយទំនង
អ្នកក្រោមអំណាច ធ្វើដូចអារង ទើបមិនខុសឆ្គង
ចាកពីមាគ៌ា ។

២៦. ត្រូវតែត្រាច់ទៅ សំដៅទីនៅ ជាទិសអង្គការ
ទោះពារព្រៃស្បាត ជ្រោះឬបន្លា ក្រពើឬខ្លា
ត្រូវសម្រុកទៅ ។

២៧. កុំមានវាចា កុំដឹងហេតុការណ៍ កុំគិតរាក់ជ្រៅ
ថាឈប់ត្រូវឈប់ ថាទៅត្រូវទៅ កុំយល់សខ្មៅ
មនុស្សដូចតិរច្ឆាន ។

២៨. ដំណឹងឆ្ងាយជិត គេលាក់បាំងបិទ មិនឱ្យដឹងដាន
ប្រពន្ធកូនចៅ ម៉ែឪសន្ដាន ស៊ើបសួរមិនបាន
សុទ្ធខ្ទាំងស្ទះការ ។

២៩. នេះហើយអំណាច ដែលគេបានសាច ជូនជនប្រជា
អ្នកស្រែកម្មករ ត្រេកអរជ្រះថ្លា លង់ទឹកនេត្រា
ដូចអណ្ដើកចូលភ្លើង ។

៣០. ពាក្យស្លោកគេថា សុទ្ធមហាអស្ចារ្យ មហាថ្កុំថ្កើង
ភ្លឺស្វាងត្រឹមត្រូវ ជាផ្លូវខ្ពស់ឡើង សម្បូណ៌ថ្កានថ្កើង
ឡើងស្មើចន្ទ្រា ។

៣១. តែប្រជាជន ទុក្ខគ្នាសែនធ្ងន់ ដូចទូលបព្វតា
ខ្វះទីលំនៅ ខោអាវអាហារ ជួបតែពាលា
បាបធម៌ពោរពេញ ។

៣២. ស្លោកគេប្រមាថ ដកចេញមិនខាត ទុកមិនចំណេញ
គេពោលញ៉ូវមាត់ សង្កត់ខាំធ្មេញ ចិត្តអររលេញ
តែខាងសម្លាប់ ។

៣៣. សុទ្ធខ្មាំងខ្មៅអែ ខ្មែរសម្លាប់ខ្មែរ ជ័យឃោសអឹងអាប់
ភរនឹងជាតិឯង វង្វេងជឿផ្កាប់ លែងគិតរស់ស្លាប់
ដូចមមាចនិងភ្លើង ។

៣៤. ស្មាដៃពត-សារី ជាតិខូចខ្ទេចខ្ទី ដូចផេះចំបើង
បំផ្លាញហិនហោច ខ្មោចកៀរនឹងជើង នេះហៅផ្លូវថ្កើង
បំផ្លាញជាតិសាសន៍ ។...

*(ដកស្រង់ពីសៀវភៅមើលផែនដីខ្មែររបស់កវី ជួន ម៉េន ១៩៨០)*

## សំណួរ

១. តើវគ្គណាមួយដែលទ្រទ្រង់ចំណងជើងកំណាព្យនេះ ?

២. តាមរយៈកំណាព្យនេះ តើបរិយាកាសសង្គមខ្មែរនាសម័យនោះមានលក្ខណៈដូចម្តេចខ្លះ ?

៣. ចូរបង្ហាញពីឧបមានវិធី និង បំរៀបន័យវិធីក្នុងអត្ថបទកាព្យខាងលើ ។

៤. ដើម្បីបង្កើតកាព្យរូបារម្មណ៍ក្នុងអត្ថបទកាព្យនេះ តើកវីបានប្រើវិធីផ្ទួន វិធីរណ្តំ និងវិធីបញ្ច្រាសដូចម្តេចខ្លះ ?

៥. តើអ្នកយល់ដូចម្តេចខ្លះ ចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ?

៦. តើលោកជួនម៉េនរស់នៅខេត្តណា ? ស្រុកណា ?

៧. ប្រសិនបើអ្នកមានឱកាសអាចជួបនឹងលោកជួនម៉េន ចូរអ្នកសាកសួរបន្ថែមទៀតពីព័ត៌មានដែលអ្នកចង់ដឹង ហើយទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ ១៩៧៥-១៩៧៩ ។

# ទំនុកច្រៀងនិងរបាំស្នែងទន្សោង



នៅពេលអ្នកស្តាប់ "ទំនុកច្រៀងរបាំស្នែងទន្សោង" ចូរអ្នកកត់សម្គាល់ចំណុចសំខាន់ៗ ដើម្បីឆ្លើយសំណួរខាងក្រោម ៖

១. ចូរនិយាយពីប្រវត្តិរបាំស្នែងទន្សោង ។

២. ហេតុអ្វីបានជាគេដាក់ឈ្មោះថា "របាំស្នែងទន្សោង" ?

៣. តើរបាំស្នែងទន្សោងនេះឋិតក្នុងទម្រង់សិល្បៈទីប៉ុន្មាន ?

៤. តើទំនុកច្រៀងនៃរបាំស្នែងទន្សោងមានប៉ុន្មានផ្នែក ? ចូរសង្ខេបផ្នែកនីមួយៗ ។

៥. ចូររកអត្ថន័យនៃចម្រៀងរបាំស្នែងទន្សោង ។

៦. តើអ្នកយល់ដូចម្តេចចំពោះទំនុកច្រៀងនិងរបាំស្នែងទន្សោងនេះ ?

៧. ក្នុងនាមអ្នកជាកូនកុលបុត្រកុលធីតាខ្មែរដ៏ឆ្នើម តើអ្នកមានគំនិតយ៉ាងដូចម្តេច ក្នុងការអភិរក្សសិល្បៈខ្មែរ ?

# សង្ខេបអត្ថបទកាព្យជាពាក្យរាយ

អ្នកធ្លាប់បានសិក្សារួចហើយ អំពីការនិយាយសង្ខេបអត្ថបទពាក្យរាយនៅមេរៀនមុន ។ ឥឡូវនេះអ្នកនឹងសិក្សាអំពីការនិយាយសង្ខេបអត្ថបទដែលជាពាក្យកាព្យឱ្យទៅជាពាក្យរាយបន្តទៀត ។

ចូរអ្នកអានឬសូត្រអត្ថបទកាព្យខាងក្រោម ៖

១. ស្នាដៃពត-សារី ជាតិខ្ទួចខ្ទេចខ្ទី ដូចផេះចំបើង
បំផ្លាញហិនហោច ខ្មោចកៀរនឹងជើង នេះហៅផ្លូវថ្មើង
បំផ្លាញជាតិសាសន៍ ។

២. ពិតត្រូវបំណង ដែលបរទេសប៉ង មកជាយូរណាស់
សតវត្សដ៏វែង គេស្វែងយុទ្ធសាស្ត្រ តែមិនប្រទះ
ដូចគ្រាពត-សារី ។

៣. សម័យលង្វែក សៀមគេជ្រៀតជ្រែក បំបែកសាមគ្គី
ឱ្យខ្មែរនិងខ្មែរ វាយគ្នារក់រី រដ្ឋខ្មែរខ្ទេចខ្ទី
ធ្លាក់ហាយនភាព ។

៤. គេកៀរយកខ្មែរ ត្រចៀកដោតខ្សែ យកធ្វើទាសភាព
រាប់ច្រើនម៉ឺនសែន គេកេណ្ឌធ្វើបាប ខ្មែរចុះទន់ទាប
ដូចសត្វតិរច្ឆាន ។

១. គម្ពីរក្រមក្រិត្យ គេរប្រាជ្ញបណ្ឌិត សិល្បៈខ្មែរមាន
សព្វស្រូវអង្ករ មាសពេជ្រធនធាន សៀមប្រមូលបាន
ដាក់ចូលជាតិគេ ។ ...

២. សម័យបារាំង ខ្មែរណាខ្លាំងៗ គេមិនទុកទេ
អ្នកចេះដឹងជាតិ គេវាតបំបែរ បំបាត់ជាតិខ្មែរ
ឱ្យនៅល្ងិតល្ងង់ ។

៣. ខ្មែរទាំងប្រុសស្រី អស់សិទ្ធិសេរី ដូចសត្វជាប់ជង់
ភពលោកលែងស្គាល់ លែងយល់ទំនង គេស្គាល់ទាក់ទង
ត្រឹមឥណ្ឌូចិន ។ ...

៤. សម័យជប៉ុន ខ្មែរដូចញាក់គ្រុន ភ័យញ័របុកពោះ
នាំសង្គ្រាមចូល ខ្មែរស្ទើរពុំរស់ រលាយកិត្តិយស
ពីភពមណ្ឌល ។

៥. គ្រាប់បែកធ្លាក់ចំ ចេតិយមួយធំ រលំគ្មានសល់
មនុស្សផ្សារកណ្តាល ឈាមច្រាលស្លាប់ខ្វល់ ខ្មែរទាំងសកល
រចល់ពេញដី ។

៦. សម័យអាមេរិក ខ្មែរបែកខ្ចាំខ្ចេច ជាពីរជាបី
បក្សពួកនិយម សង្គមចាស់ថ្មី រឹតគ្នាពេញដី
ប្រល័យតែខ្មែរ ។

៧. រឿងជាតិបរទេស គេមកជាន់ជិះ ជាតិយើងជាតិគេ
ជារឿងស្មោកគ្រោក ក្នុងលោកណាស់ដែរ តែប្រវត្តិគេ
ជាតិគេថ្លៃថ្លា ។

៨. រឿងគេជិះជាន់ គេលួចគេប្លន់ ទ្រព្យជាតិខេមរា
ខ្មែរត្រូវទាមទារ កុំរាជីវ៉ា តែហួសពាក្យថា
"ខ្មែរសម្លាប់ខ្មែរ" ។ ...

*(ដកស្រង់ពីសៀវភៅមើលផែនដីខ្មែររបស់កវី ជួន ម៉េន ១៩៨០)*

អ្នកបានអានឬសូត្រអត្ថបទកាព្យនេះរួចហើយ ចូរអ្នកពិនិត្យមើលវគ្គនីមួយៗជាបន្តបន្ទាប់ ដោយកំណត់យកចំណុចសំខាន់មួយ បន្ទាប់មករកសេចក្តីលំអិតដែលទាក់ទងនឹងចំណុចសំខាន់នៃវគ្គនោះ ។

វគ្គទី ១ គឺនិយាយពីពួកសៀមឈ្លានពានប្រទេសខ្មែរនៅសម័យលង្វែក ។ សៀមបានបំបែកបំបាក់ខ្មែរឱ្យសម្លាប់គ្នាឯង រួចគេប្រមូលគម្ពីរក្បួនខ្នាត អ្នកប្រាជ្ញបណ្ឌិត សិល្បៈ ស្រូវអង្ករ មាសពេជ្រ ធនធានយកទៅដាក់ចូលក្នុងជាតិរបស់គេ ។

វគ្គទី២ និងទី៣ គឺនិយាយពីពួកបារាំងបានដាក់នឹមអាណានិគមលើប្រទេសខ្មែរ ។ បារាំងបានសម្លាប់ខ្មែរដែលមានចំណេះដឹង បំបិទសិទ្ធិសេរីភាពខ្មែរមិនឱ្យមានការទាក់ទងនឹងពិភពលោកខាងក្រៅ ពិភពលោកមិនស្គាល់ខ្មែរទេ គេស្គាល់តែប្រទេសឥណ្ឌូចិន (កម្ពុជា វៀតណាម លាវ) ។

វគ្គទី៤និងវគ្គទី៥ និយាយពីពួកជប៉ុនមកត្រួតត្រាប្រទេសខ្មែរ ។ ជប៉ុនបាននាំសង្គ្រាមចូលស្រុកខ្មែរ ដូចជាការទម្លាក់គ្រាប់បែបនៅចេតិយធំនិងផ្សារកណ្ដាល ធ្វើឱ្យប្រជារាស្ត្រខ្មែរស្លាប់យ៉ាងវេទនា ហើយស្ថិតក្នុងសភាពភ័យខ្លាចជាទីបំផុត ។

វគ្គទី៦ និយាយពីពួកអាមេរិក លូកដៃកកូរកកាយបំបែកឱ្យខ្មែរមានបក្សពួកជាពីរ ជាបីក្រុម ឈ្លោះទាស់ទែងគ្នា ព្រោះតែមានសង្គមចាស់ និង សង្គមថ្មី ហើយសម្លាប់តែខ្មែរគ្នាឯង ។

វគ្គទី៧និងទី៨ និយាយពីការត្រួតត្រាឈ្លានពានញុះញង់របស់ពួកបរទេសខាងលើ គឺជាអំពើស្មោកគ្រោកអាក្រក់ក្រៃលែងចំពោះប្រជារាស្ត្រខ្មែរ ។ ចំពោះទង្វើរបស់ពួកបរទេសដែលធ្វើមកលើខ្មែរ ខ្មែរត្រូវតែតស៊ូប្រឆាំង រើបម្រះដោយពុំរាថយឡើយ ប៉ុន្តែអ្វីដែលហួសនិស្ស័យនោះ គឺអ្នកដឹកនាំខ្មែរក្រហម ដែលបញ្ជាខ្មែរឱ្យសម្លាប់ខ្មែររាប់លាននាក់ គឺជាទង្វើថោកទាបបំផុត ។

តាមរយៈឧទាហរណ៍ខាងលើអ្នកអាចនិយាយសង្ខេបអត្ថបទពាក្យកាព្យនេះឱ្យមានលក្ខណៈរៀបរយល្អតាមគំរូខាងក្រោម ៖

នៅសម័យលង្វែក សៀមបានឈ្លានពានប្រទេសខ្មែរ ។ គេបានចាប់ចោះត្រចៀកខ្មែរដោតខ្សែដឹកទៅធ្វើទាសករបួន់ស្រូវអង្ករ មាសពេជ្រ អ្នកប្រាជ្ញបណ្ឌិតគម្ពីរក្បួនខ្នាតសម្បត្តិទ្រព្យផ្សេងៗ របស់ខ្មែរដាក់បញ្ចូលទៅក្នុងជាតិគេ ។ បន្ទាប់មកប្រទេសខ្មែរ ក៏ត្រូវបានពួកអាណានិគមនិយមបារាំងត្រួតត្រា ។ ពួកនេះបានសម្លាប់អ្នកប្រាជ្ញចេះដឹងខ្មែរក្នុងបំណងបំបាត់ជាតិសាសន៍ដោយបំបិទសិទ្ធិសេរីភាពមិនឱ្យខ្មែរស្គាល់ពិភពលោកខាងក្រៅហើយគ្រានោះពិភពលោកគេស្គាល់តែប្រទេសឥណ្ឌូចិនប៉ុណ្ណោះ ។ បន្តមកទៀត ជប៉ុនបានមកត្រួតត្រាខ្មែរ ដោយនាំយកទាំងភ្លើងសង្គ្រាមមកជាមួយផង ។ សង្គ្រាមនេះបានបំផ្លាញខ្មែរក្នុងភាពភ័យខ្លាច ដែលគ្រានោះមានទម្លាក់គ្រាប់បែកលើវត្ត ផ្សារ និងផ្ទះសម្បែងស្លាប់មនុស្សជាច្រើន ។ ចុងក្រោយនៃប្រវត្តិបរទេសឈ្លានពានខ្មែរ អាមេរិចក៏បានលូកដៃកកូរកកាយផ្ទៃក្នុងខ្មែរឱ្យបំបែកជាបក្សពីរបី បែងចែកពួកសង្គមចាស់ សង្គមថ្មីឱ្យខ្មែរឈ្លោះគ្នាសម្លាប់គ្នាទៅវិញទៅមក ។

រាល់សកម្មភាពបរទេសឈ្លានពានខ្មែរ ជាអំពើស្មោកគ្រោកអាក្រក់បំផុតសម្រាប់ជាតិខ្មែរ តែសម្រាប់ប្រទេសគេ គឺរុងរឿង ហើយខ្មែរក៏ត្រូវតែទាមទារ តស៊ូរើបំរះយកសម្បត្តិទាំងនោះមកវិញឱ្យបាន ។ ប៉ុន្តែគេហួសចិត្តរកពាក្យណាមកនិយាយឱ្យចំឱ្យសមបានទេ ចំពោះពួកខ្មែរក្រហម បញ្ជាខ្មែរឱ្យសម្លាប់ខ្មែរគ្នាឯងអស់រាប់លាននាក់នោះ ។

ការនិយាយសង្ខេបអត្ថបទកាព្យឱ្យទៅជាពាក្យរាយមានលក្ខណៈរៀបរយល្អអ្នកត្រូវ ៖

- រកព្រឹត្តិការណ៍សំខាន់ៗតាមវគ្គនីមួយៗ
- និយាយពីសេចក្ដីលំអិតដែលទាក់ទងនឹងព្រឹត្តិការណ៍សំខាន់នោះ
- ប្រើពាក្យពេចន៍ជាពាក្យរាយដោយមាន ឃ្លា ល្បះឱ្យបានត្រឹមត្រូវ
- ប្រើសំនួនប្រាប់លំដាប់ឱ្យបានត្រឹមត្រូវ ។

## លំហាត់

ចូរប្អូនសង្ខេបអត្ថបទពាក្យកាព្យដូចខាងក្រោម ឱ្យទៅជាពាក្យរាយ មានលក្ខណៈរៀបរយល្អ :

- អំណានទី១ "រឿងទុំទាវ" ។
- វគ្គដកស្រង់ខាងក្រោម ។

មេសាចិតប្រាំ នគររងកម្ម សិទ្ធិសេរីចុះ
សីលធម៌ជាតិ ឃ្លាតធ្លាក់ផ្លូវខុស ជនទាំងស្រីប្រុស
ជាប់ទោសពេញដី ។

គុកខ្មោះថាគ្មាន ភរទាំងបំពាន លាក់មិនឱ្យស្ដី
អំពើបាញ់កាប់ ចងចាប់ប្រក្រតី ច្បាប់នៅសម្ដី
អ្វីៗស្រេចថា ។

មាត់ជាអាទិទេព ឱ្យយំឱ្យពេប ឱ្យអត់អាហារ
នីឡុងចំណង ចងវាយឥតការណ៍ នេះជាវាចា
គេថាទន់ភ្លន់ ។

សំដីថាស្មើ តែឃើញអំពើ គឺជាចោរប្លន់
អ្នកម្ចាស់មិនឱ្យ នឹងត្រូវអាសន្ន ជាប់ទោសយ៉ាងអន់
ជាន់កវាយចោល ។

ដកដាក់អង្គការ គាត់មានខ្លឹមសារ តែដូចស្រមោល
ភូតភរប្រវ័ញ្ច មិនអាចដេញដោល ប្រើឱ្យរត់បោល
បម្រើអាត្មា ។

នាឡិកាខោអាវ ឃើញច្បាស់ក្រឡៅ គេពាក់ហ៊ឺហា
យកបុគ្គលម្នាក់ ដាក់ជាអង្គការ បំភ័ន្តនេត្រា
ថាតំណាងជន ។ [...]

# ប្រធានអត្ថាធិប្បាយបែបពន្យល់

អត្ថាធិប្បាយពន្យល់ គឺការបកស្រាយបំភ្លឺមតិ គំនិតរបស់នរណាម្នាក់ ទស្សនៈរបស់អ្នកប្រាជ្ញណាម្នាក់ ឬបង្ហាញការយល់ឃើញរបស់ខ្លួនផ្ទាល់។ ក្នុងការពន្យល់ត្រូវតែវិភាគរកហេតុផលមកធ្វើជាអំណះអំណាង ហើយប្រើសិល្បវិធីធ្វើឱ្យគេយល់ច្បាស់ពីខ្លឹមសារ អត្ថន័យនៃមតិទស្សនៈ ឬបញ្ហានោះ។ ទស្សនៈ បញ្ហា អត្ថន័យ ... ដែលបានចោទនៅក្នុងប្រធានតែងសេចក្ដី ច្រើនមានលក្ខណៈជឿនលឿន សកម្មរួចស្រេចទៅហើយ ដោយពុំមានមតិឬយោបល់ណាមួយមកខ្ទាស់នឹងអត្ថន័យ ឬទស្សនៈនោះបានឡើយ។ អត្ថន័យជឿនលឿន ឬសកម្មមានន័យថា ប្រធាននោះមានអត្ថន័យជាវិជ្ជមានគ្រប់គ្រាន់ក្នុងការអប់រំ ដែលបម្រើជីវភាពរស់នៅរបស់មនុស្ស។

ប្រធានគំរូ ៖ គេថា "វត្តអារាមពុទ្ធសាសនា មានតួនាទីសំខាន់ណាស់ចំពោះសង្គមខ្មែរ"។ តើមតិនេះមានខ្លឹមសារដូចម្ដេចខ្លះ ? ចូរបង្ហាញដោយលើកឧទាហរណ៍ក្នុងរឿងទុំទាវមកបញ្ជាក់ផង។

## គម្រោងតែងគំរូ

## ១ . ផ្ដើមសេចក្ដី

- លំនាំបញ្ហា ៖ ពុទ្ធសាសនា ជាសាសនារបស់រដ្ឋនៃព្រះរាជាណាចក្រកម្ពុជា
- ចំណូលបញ្ហា ៖ "វត្តអារាមពុទ្ធសាសនា មានតួនាទីសំខាន់ណាស់ចំពោះសង្គមខ្មែរ"។
- ចំណោទបញ្ហា ៖ តើមតិនេះមានខ្លឹមសារដូចម្ដេចខ្លះ ?

## ២ . តួសេចក្ដី

### ក. ឃ្លាភ្ជាប់សេចក្ដី

- ពន្យល់ពាក្យ ៖ វត្តអារាម ពុទ្ធសាសនា តួនាទី សង្គមខ្មែរ
- ពន្យល់ន័យប្រធាន ៖ "វត្តអារាមពុទ្ធសាសនា មានតួនាទីសំខាន់ណាស់ចំពោះសង្គមខ្មែរ"។

### ខ. បកស្រាយប្រធាន

តួនាទីពុទ្ធសាសនាចំពោះសង្គមខ្មែរ

- ប្រកាន់យកសន្តិភាព គ្មានហិង្សា គ្មានសង្គ្រាម
- អប់រំមនុស្សឱ្យពឹងលើខ្លួនឯង ជឿជាក់លើសមត្ថភាពខ្លួនឯង...
- ការចូលរួម ៖ សង្គមជាតិជាកម្មសិទ្ធិពលរដ្ឋ ហើយពលរដ្ឋមានតួនាទីថែរក្សា និងអភិវឌ្ឍប្រទេសនោះដោយខ្លួនគេផ្ទាល់។

- និរន្តរភាព : ត្រៃសរណគមន៍ពុទ្ធសាសនា គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឯសង្គមមានបច្ច័យបី គឺបុគ្គល សង្គម និងធម្មជាតិ ដែលមានទំនាក់ទំនងជួយគ្នាទៅវិញទៅមក ដើម្បីថែរក្សាពុទ្ធសាសនា ក៏ដូចជាថែរក្សាសង្គមខ្មែរ ។ ករណីដូចនេះហើយ ទើបពុទ្ធសាសនាបានក្លាយជាសាសនារបស់រដ្ឋ ។
- ពុទ្ធសាសនាបានចូលរួមក្នុងសង្គមខ្មែរៈ ក្នុងភាពជាអ្នកដឹកនាំប្រកបដោយទសពិធរាជធម៌និងអប់រំបុគ្គល គ្រួសារលើផ្នែកចរិយាសាស្ត្រ សីលធម៌... ។ល ។

**តួនាទីវត្តអារាមពុទ្ធសាសនាចំពោះសង្គមខ្មែរ**

- ជាទីតាំងនៃព្រះពុទ្ធសាសនា
- ជាមន្ទីរពេទ្យខាងផ្លូវចិត្ត
- មជ្ឈមណ្ឌលវប្បធម៌របស់ប្រជាជន
  - សារមន្ទីរនៃស្ថាបត្យកម្មខ្មែរ
  - កន្លែងប្រមូលផ្តុំជំនឿរបស់ប្រជាជន
  - កន្លែងសម្រាប់ផ្តល់បុណ្យកុសល
  - ផ្សាយវប្បធម៌និងផ្តល់ព័ត៌មាន
  - កន្លែងបង្កើតស្នាដៃនិពន្ធ
  - បណ្ណាល័យរបស់ប្រជាជន
  - កន្លែងអប់រំវិជ្ជាជីវៈ
  - កន្លែងអប់រំសីលធម៌របស់ខ្មែរ
  - សាលារៀនខាងលេខនព្វន្ត និងអក្សរសាស្ត្រសម័យបុរាណ
- កន្លែងជ្រកកោនរបស់អ្នកកម្សត់ទុរគត
- ជំរកនិរភ័យនៃពពួកសត្វ
- រណ្តៅកប់ទំនាស់ កន្លែងមានភាពស្មើគ្នា ។

  ***ឧទាហរណ៍ :*** រឿង ទុំទាវ
- ការអប់រំវិជ្ជាជីវៈ
  - នេនទុំមានថ្វីមាត់ពូកែ មានសំឡេងពីរោះ
  - នេនពេជ្រមានចំណេះខាងផ្លុំប៉ីយ៉ាងពីរោះ

*ឧទាហរណ៍ :*

ទុំមានវោហារប្រាជ្ញាផ្សេង　　មានទាំងសំឡេងរូបឱ្យល្អក់
ល្អទ្រង់អង្គកាយសាយទឹកមុខ　　រួចទុកនេនពេជ្រស្រេចជាប្អូន ។
នេនពេជ្រចេះស្រេចខាងផ្លុំប៉ី　　ឈ្លាសវៃប្រសប់ភ្លេងមាំមួន
អ្នកនេនពីរពិតគិតគុំកួន　　ចំណេះក្នុងខ្លួនប្រហែលគ្នា ។ ...

- នេនទុំ ពេជ្រ ចេះធ្វើតោកនិងចេះលក់តោក

*ឧទាហរណ៍ :*

ធ្វើតោកធ្វើទុកលក់ដាច់ខ្លះ　　នៅផ្ទះទៀបវត្តជាមីងមា ...
....　　លាព្រះគុណទៅក្រែងប្រសើរ
ប្រសិនជីកតោកយកទៅផ្ញើ　　គ្រាន់បើនៅអាយចាយមិនដាច់ ។ ...

- កន្លែងអប់រំសីលធម៌

- នេនទុំ ពេជ្រ បានសុំការអនុញ្ញាតពីគ្រូចៅអធិការទៅលក់តោក

*ឧទាហរណ៍ :*

ព្រោះយើងទាំងសងប៉ងបង្គំ　　លាព្រះគុណធំខ្ញុំករុណា
ទាំងពីរនាក់នឹងចរយាត្រា　　ប្រោសប្រាណមានការទៅស្រុកឆ្ងាយ ។

- ព្រះចៅអធិការបានទូន្មាននេនទាំងពីរ

*ឧទាហរណ៍ :*

ទៅចុះគាប់ខុសប្រយ័ត្នណា　　កុំរវើយអីអាឃើញរូបស្រី
បត់បួចឡកលេងមិនគប្បី　　ដំនៀលអប្រិយមកដល់គ្រូ ។
កេរ្តិ៍ខ្មាសនិន្ទានាលោកិយ　　ខុសពីវិន័យព្រះសព្វញ្ញូ
បើទៅលក់អស់កុំនៅយូរ　　គិតគួរថ្លៃថោកមកវិញឆាប់ ។

- នេនពេជ្ររំលឹកនេនទុំមុននិមន្តទៅទេសនៅផ្ទះម្ដាយទាវ

*ឧទាហរណ៍ :*

ថាដើរមានប្អូនខ្លួនជាសង្ឃ　　ទើបបានត្រូវត្រង់ឥតមានមោះ
បើដើរទៅក្ដីបាសកនោះ　　កេរកោះថ្លោះធ្លោយឱ្យមានប្រាំ ។ ...

- ផ្សាយវប្បធម៌ (ទៅតាមភូមិស្រុក)

- នេនទុំបានមន្តទៅទេសនានៅស្រុកត្បូងឃ្មុំ (លក់តោកផង ទេសនាផង) តាមការនិមន្តរបស់ម្ដាយទាវ ... ។

- សាលារៀនខាងលេខ នព្វន្ត និង អក្សរសាស្ត្រ
  - ទុំ ពេជ្រ បានចូលមករៀននៅវត្តវិហារធំ ហើយបួសជាសាមណេរ

*ឧទាហរណ៍ :*

| | |
|---|---|
| កើតឡើងលុះធំល្មមប្រមាណ | ឆ្នាំច្រើនសោតបានម្ដាយតុបតែង |
| យកទៅឱ្យរៀនចោលគ្រឿងល្បែង | ស្វះស្វែងនៅវត្តវិហារធំ ។ |
| លោកគ្រូទទួលស្រួលព្រះទ័យ | ប្រិតប្រៀនទុំវៃខាងអាគម |
| អាចគាប់ដោយប្រាជ្ញាប្រឹងជញ្ជំ | ខិតខំចង់បួសផ្នួសសាមណេរ ។ ... |

**សរុបមតិ :** វត្តអារាមពុទ្ធសាសនា ជាទីកន្លែងដែលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ជាសាលារៀន ... ដើម្បីទ្រទ្រង់សង្គមខ្មែរប្រកបដោយសុខសន្តិភាព សុវត្ថិភាព និងអភិវឌ្ឍន៍ ។

## ៣ . បញ្ចប់សេចក្ដី

- វាយតម្លៃប្រធាន : ទស្សនៈប្រធានមានអត្ថន័យជ្រាលជ្រៅ ...
- យោបល់ផ្ទាល់ខ្លួន : ចូលរួមថែរក្សានិងអភិវឌ្ឍពុទ្ធសាសនា ...

ដើម្បីសរសេរតែងសេចក្ដីអធិប្បាយពន្យល់បានល្អ អ្នកត្រូវធ្វើតាមការណែនាំដូចខាងក្រោម ៖

ក. ត្រូវស្គាល់ប្រធាននោះថាជាប្រធានអត្ថាធិប្បាយពន្យល់តាមរយៈ

- ពាក្យបញ្ជា : ចូរពន្យល់ ចូរបំភ្លឺ ចូរបង្ហាញ ...
- ពាក្យចោទសួរ : បែបណាខ្លះ ? ... ដូចម្ដេច ? ...

ខ. តើសំណេររបស់អ្នកមានសេចក្ដីផ្ដើម តួសេចក្ដី សេចក្ដីបញ្ចប់សមស្របឬទេ ?

គ. តើមតិសំខាន់ៗសមហេតុផលឬទេ ?

ឃ. តើមតិអះអាងឬសេចក្ដីលំអិតនីមួយៗពិតជាច្បាស់លាស់និងស្របតាមមតិសំខាន់នីមួយៗឬទេ ?

ង. តើអ្នករៀបរាប់មតិទាំងនោះសមហេតុផលនិងស៊ីចង្វាក់គ្នាតាមលំដាប់លំដោយឬទេ ?

ច. អ្នកបានគិតដល់អ្នកអានសំណេររបស់អ្នកឬទេ ថាតើកថាខណ្ឌនីមួយៗដែលអ្នកបានរៀបរាប់នោះគួរឱ្យគេជឿឬទេ ?

## លំហាត់

**ប្រធាន :** មុនពេលនេនទុំនិមន្តទៅទេសនានៅផ្ទះម្ដាយទាវ នេនពេជ្រទូន្មានថា ៖

| | |
|---|---|
| "ថាដើរមានបួនខ្លួនជាសង្ឃ | ទើបបានត្រូវត្រង់ឥតមានមោះ |
| បើដើរទៅក្ដីបាសកនោះ | គេរកោះថ្លោះធ្លោយឱ្យមានប្រាំ" ។ ... |

តើការទូន្មាននេះមានន័យដូចម្ដេច ? ចូរពន្យល់ ។

មេរៀនទី ៦

# ការគោរពបូជា



ប្រទេសកម្ពុជាជាប្រទេសមួយដែលបានទទួលឥទ្ធិពលពីសាសនាធំៗពីរ គឺព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ។ ឥទ្ធិពលនៃសាសនាទាំងពីរនេះបានជ្រៀតចូលទៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជាស្ទើរគ្រប់ស្រទាប់វណ្ណៈតាំងពីយូរយារណាស់មកហើយ ។ ជំនឿទាំងនេះបានក្លាយទៅជាប្រពៃណី ទំនៀមទម្លាប់ និងការគោរពបូជា ការប្រតិបត្តិរបស់ប្រជាជនខ្មែរទៅហើយដូចជា ការគោរពមាតាបិតា គ្រូអាចារ្យ គោរពព្រះពុទ្ធ ព្រះឥន្ទ្រ ព្រះព្រហ្មជាដើម ។ល ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាពីការគោរពបូជាមួយចំនួនតាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរ និងគោលគំនិតសំខាន់ៗមួយចំនួនរបស់ព្រះពុទ្ធសាសនានិងព្រាហ្មណ៍សាសនា ។ ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីលក្ខណៈអក្សរសិល្ប៍ ចលនាអក្សរសិល្ប៍ ការនិយាយប្រៀបធៀប សំណេរតែងសេចក្ដីប្រៀបធៀប និងអំពីសូរព្យញ្ជនៈទោល ។

# លក្ខណៈអក្សរសិល្ប៍

អក្សរសិល្ប៍របស់ជាតិសាសន៍នីមួយៗតែងតែមានលក្ខណៈដោយឡែករបស់ជាតិសាសន៍នោះជានិច្ច ហើយអក្សរសិល្ប៍នោះទៀតសោតក៏បានបង្ហាញផងដែរនូវលក្ខណៈមនុស្ស លក្ខណៈសង្គម លក្ខណៈជាតិ លក្ខណៈអន្តរជាតិ លក្ខណៈវណ្ណៈជាដើម ... ។ល។ ពេលនេះ យើងលើកយកលក្ខណៈមនុស្សនិងលក្ខណៈសង្គមនៅក្នុងអក្សរសិល្ប៍មកបង្ហាញដូចខាងក្រោម ៖

## ១ . លក្ខណៈមនុស្ស

លក្ខណៈមនុស្សក្នុងអក្សរសិល្ប៍ គឺការសិក្សាអំពីមនុស្សក្នុងសម័យកាលដ៏ជាក់លាក់ណាមួយ ។ លក្ខណៈមនុស្សក្នុងអក្សរសិល្ប៍ សំដៅលើលក្ខណៈរួមទូទៅរបស់មនុស្សដូចជា ការសើចសប្បាយ ការរីករាយ ប្រចណ្ឌ ព្រួយយំ ការច្រណែន ខឹង ...។ល។ លក្ខណៈមនុស្សបង្ហាញឱ្យឃើញតាមរយៈសកម្មភាព ទង្វើ អាកប្បកិរិយា ពាក្យសំដី ចិត្តគំនិត... របស់តួអង្គនៅក្នុងរឿង ។

*ឧទាហរណ៍ :* លក្ខណៈមនុស្សរបស់តួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ខ្មែរគឺ

- ព្រះរាមយំសោកនឹករឭកនាងសីតា
- ព្រះរាមខឹងប្រចណ្ឌនាងសីតាជាមួយក្រុងរាពណ៍
- ព្រះរាមឱ្យនាងសីតាដើរលុយភ្លើងដើម្បីបញ្ជាក់ភាពបរិសុទ្ធ
- ព្រះរាមឈ្លោះជាមួយកូនក្មេង គឺកូនរបស់ខ្លួន រាមលក្ស្មណ៍និងជបលក្ស្មណ៍ ។ល។

## ២ . លក្ខណៈសង្គម

លក្ខណៈសង្គមក្នុងអក្សរសិល្ប៍ ត្រូវបានបង្ហាញតាមរយៈខ្លឹមសារនៃអត្ថបទអក្សរសិល្ប៍ទាំងឡាយណា ដែលបានលើកយកបញ្ហាមនុស្សនៅក្នុងសង្គមណាមួយមកចោទនិងដោះស្រាយសមស្របតាមសភាពលក្ខណៈនៃសង្គមរបស់ខ្លួន ។ បញ្ហាសង្គម គឺជាមតិយោបល់ឬគំនិតទាំងឡាយដែលតំណាងឱ្យព្រឹត្តិការណ៍សង្គមទាំងមូល ។

*ឧទាហរណ៍ :* រឿងទុំទាវបង្ហាញឱ្យឃើញពីរបៀបរបបគ្រប់គ្រងនិងច្បាប់ទម្លាប់មួយចំនួនរបស់សង្គមខ្មែរសម័យលង្វែកគឺ

- អំណាចរបស់ព្រះរាជា : ព្រះរាជាជាអ្នកគ្រប់គ្រង កាត់ក្តី ដឹកនាំប្រទេស... ។
- អំណាចស្តេចត្រាញ់ : ស្តេចត្រាញ់មានអំណាចគ្រប់គ្រងជំនុំជម្រះកាត់សេចក្តីក្នុងដែនដីរបស់ខ្លួន ។

"ឧកញ៉ាអរជូនមាំមួនពេក ធម្មតាក្រោមមេឃទាបជាងភ្នំ
មានឫទ្ធិអំណាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី" ។

- អំណាចមេគ្រួសារ : អំណាចគ្រួសារស្ថិតនៅលើមេគ្រួសារ "នំមិនធំជាងនាឡិ" ។

## លំហាត់

១. ចូរបង្ហាញលក្ខណៈមនុស្សនិងលក្ខណៈសង្គមតាមរយៈស្នាដៃអក្សរសិល្ប៍ :

ក. រឿងរាមកេរ្តិ៍

ខ. រឿងព្រះវេស្សន្តរ ។

២. ចូរបង្ហាញលក្ខណៈសង្គមតាមរយៈស្នាដៃរឿងខាងក្រោមនេះ :

[...]ហាំ : ព្រះតេជគុណ ខ្ញុំទុកជាម៉ែឪហើយ មេត្តាខ្ញុំចុះ ។ ជីវិតខ្ញុំថ្លៃតែ ១ម៉ឺនរៀលទេ ។ ម្ដេចព្រះបាទម្ចាស់មានប្រសាសន៍ឯណាទៅវិញ ? ឱ្យខ្ញុំភ្លាមមក ១ម៉ឺនដូចជាបោះចោលឱ្យសត្វលង់ទឹកទៅចុះ ។ ព្រះតេជគុណស្គាល់ចិត្តខ្ញុំស្រាប់ហើយ ស៊ូស្លាប់រស់នឹងព្រះតេជគុណយ៉ាងណាៗ ... ។

ថៅកែ : យីអានេះ និយាយច្រើនណាស់ អញថាមិនដឹងៗហើយ ។ យកឡានអញទៅបុកគេខូចឡានអញ ងាប់មនុស្ស ៣នាក់ រឿងរ៉ាវនឹងអាឯងសម្បើមណាស់ ប៉ោកេប៉ឹងផងឥឡូវមករឹតឯងមួយទៀត ។ ផានិត ជួយគិតមើល អានេះវាគិតជញ្ជក់ឈាមឯង ឱ្យនៅតែស្បែកនិងឆ្អឹងតែម្ដង ។

ហាំ : ព្រះតេជគុណជ្រាបស្រាប់ហើយ ! ខ្ញុំបរឡានបុកគេ គឺធ្វើតម្រូវចិត្តព្រះតេជគុណ ។

ថៅកែ : អញឱ្យបុកមែន តែមិនមែនឱ្យបុកទាល់តែមានស្លាប់មនុស្សឯណា !

ហាំ : ខ្ញុំក៏មិនមែនចង់ឱ្យមានមនុស្សស្លាប់ដែរ តែនរណាប៉ាន់គ្រោះថ្នាក់បាន !

ថៅកែ : អើ ! រួចអាឯងមកទារលុយអញទៀត !

ហាំ : ចុះថៅកែសន្យាថា បើខ្ញុំបុកឡានអាហុងលីបាន ឱ្យខ្ញុំ ១ម៉ឺន ។ ខ្ញុំទារតាមថៅកែសន្យា ។ (កម្មករចូល) ។

ថៅកែ : យី អា៎ ! សំដីរឹងណាស់ហ្ន៎ !

ហាំ : ថៅកែ ខ្ញុំបាទត្រូវការ ១ម៉ឺនណាស់ ប្រពន្ធខ្ញុំឈឺ កូនត្រូវចូលអនុវិទ្យាល័យ ម្ដាយខ្ញុំចង់ធ្វើបុណ្យបន្តិចបន្តួចនឹងគេ ។ ឱ្យតែបាន ១ម៉ឺនមកខ្ញុំយកទៅឱ្យប្រពន្ធកូន ម្ដាយសប្បាយ ខ្ញុំយ៉ាងណាយ៉ាងនោះចុះ ខ្ញុំឥតគិតទេ ខ្ញុំសូមលើកដៃសំពះថៅកែម្ដង បើមិនអាណិតខ្ញុំទេ អាណិតតែប្រពន្ធកូនម្ដាយខ្ញុំចុះ កុំតែមានវង្សត្រកូល ខ្ញុំមិនត្រូវការ ១ម៉ឺនធ្វើអ្វីទេ ។ [...]

## រំលឹកបញ្ញត្តិ

### ១ . លក្ខណៈសម្គាល់របស់រឿងបែបព្រាហ្មណ៍និយម

អក្សរសិល្ប៍ព្រាហ្មណ៍និយមសម្គាល់អត្ថបទអក្សរសិល្ប៍ណាដែលមានទំនាក់ទំនងទៅនឹងលទ្ធិសាសនាព្រាហ្មណ៍។ អក្សរសិល្ប៍នេះតែងលើកយកអច្ឆរិយបុគ្គល ទេវតា អាទិទេព ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ យក្ស ដោយរួមផ្សំនឹងមន្តអាគមគាថា បែងភាគ កាឡាខ្លួន ចេះជប ចេះហោះហើរ ដើរលើអាកាសជាដើម ។

លក្ខណៈសម្គាល់អក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយមមាន ៖

### ក. ផ្ដើមរឿង

ការផ្ដើមរឿងនៃស្នាដៃអក្សរសិល្ប៍ប្រភេទនេះ គឺចាប់ផ្ដើមឡើងដោយការបង្ហាញពីឈ្មោះរបស់អាទិទេពធំៗ ទាំងបីដូចជាព្រះព្រហ្ម ព្រះវិស្ណុ ព្រះឥសូរ ពិធីបូជាយញ្ញ ឬពិធីផ្សេងៗទៀត ។

*ឧទាហរណ៍ :* ផ្ដើមរឿងរាមកេរ្តិ៍ អ្នកនិពន្ធសរសេរថា "ដងនោះមានអសូរសា មានរូបមួយនាមាហៅកាកនាសូរស្តែង ។ ពួស័ព្ទសង្ខធុជថ្មើងថ្កានព្រតព្រះគម្ហែង ឥសូរដ៏រាមឫទ្ធា ។ អសុរនោះនិរ-មិត្ររូបាជាកាកមួយសា ហោះហើរនូវតេជបីពន្លឹក ។ មកចឹកហោមសាស្រ្តាធម្មិក ពួស័ព្ទគគឹក ស្លឹកស្មឹភ្ញឹញ័ររុះរោយ ។ ស្រែកស័ព្ទកាកនោះពួឆ្ងាយធុជធោងព្រាត់ព្រាយក៏ភិតពួនពឹងនៅនិត្យ ..." ។

### ខ. តួរឿង

- តួអង្គ : ជាអាទិទេព ឬអវតារនៃព្រះវិស្ណុមកយោនយកកំណើតជាមនុស្សជាបុរសអស្ចារ្យ និងជានារីអស្ចារ្យ ឯតួអង្គផ្សេងទៀតមានឥសី ទេវតា យក្ស គ្រុឌ ... ។ល ។
- ដំណើររឿង : ដំណើររឿងមានភាពអច្ឆរិយៈដូចជា ជប ប្រោះ ហោះហើរ ផ្លែងសរ ... ។
- ទីកន្លែង : ព្រៃហេមពាន្ត ក្រុងព្ជយុធ្យា ស្ថានសួគ៌ ស្ថានបាតាល ស្ថានសិម្ពលី(គ្រុឌ) ពោល គឺឋានទាំងបី ។
- ដំណោះស្រាយបញ្ហា : ដោះស្រាយបញ្ហាដោយយុទ្ធវិធីឬសង្គ្រាម ។
- បញ្ហាទំនាស់ : ទំនាស់កើតឡើងរវាងសភាវៈល្អនិងសភាវៈអាក្រក់ ។
- ឧត្ដមគតិរឿង ៖
  - អប់រំមនុស្សឱ្យជឿលើអាទិទេព
  - អប់រំឱ្យមនុស្សមានជំនឿថា ទុក្ខសោក សំណាងល្អអាក្រក់របស់ខ្លួនបានមកពីអាទិទេព ជាអ្នក កំណត់ ។

### គ. បញ្ចប់រឿង

ការបញ្ចប់រឿងបែបព្រាហ្មណ៍និយម គឺតួអង្គតំណាងអាទិទេព (សភាវៈល្អ) មានជ័យជំនះលើសភាវៈអាក្រក់ យក្ស អសុរៈ ។ល ។

## ២ . លក្ខណៈសម្គាល់របស់រឿងបែបពុទ្ធនិយម

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមសម្គាល់អត្ថបទអក្សរសិល្ប៍ណាដែលមានទំនាក់ទំនងទៅនឹងលទ្ធិពុទ្ធសាសនា គឺលើកយកសកម្មភាពពោធិសត្វក្នុងការកសាងបារមី ឬដែលបានលើកយកទស្សនៈសំខាន់ៗក្នុងពុទ្ធសាសនាមានបញ្ហាកម្មផល បុណ្យ បាប ជាដើមមកបង្ហាញ ៖

### ក. ផ្ដើមរឿង

រឿងផ្ដើមឡើងដោយធ្វើបទនមស្ការ មានតំណាលថា ព្រះពុទ្ធគង់នៅក្នុងអារាមណាមួយទ្រង់សម្ដែងឡើងនូវរឿងអតីតជាតិរបស់ព្រះអង្គទៅកាន់ពុទ្ធបរិស័ទ ។ល ។

### ខ. តួរឿង ឬដំណើររឿង

- តួអង្គ : តួអង្គប្រុសជាពោធិសត្វ ឯតួអង្គស្រីជាកន្សៃសារពេជ្ជ ។ តួអង្គរងមានមនុស្ស ទេវៈ អសុរៈ ... ។
- ទីកន្លែង : ដំណើររឿងប្រព្រឹត្តទៅនៅនគរពារាណសី កត្តសិលា ព្រៃហេមពាន្ត ឋានទាំងបី ... ។
- បញ្ហាទំនាស់ : ជាទំនាស់រវាងព្រះពោធិសត្វនិងសង្គមមនុស្ស ទំនៀមទម្លាប់ កម្មពៀរ អំពើបាប ... ។
- ដំណោះស្រាយបញ្ហា : ព្យាយាមតស៊ូប្រឹងប្រែងដោយយកសីលធម៌សន្តិវិធី ខន្តីសន្ដោសប្រណីមិនប្រើហិង្សា ដើម្បីដោះស្រាយបញ្ហាជានិច្ច ។
- ឧត្ដមគតិរឿង : អប់រំមនុស្សឱ្យស្គាល់និងជឿបុណ្យបាប ឱ្យធ្វើអំពើល្អ ខំប្រឹងតស៊ូព្យាយាមដោយជឿជាក់លើខ្លួនឯង ។

### គ. បញ្ចប់រឿង

ការបញ្ចប់រឿងដោយមានការសរជាតិរបស់តួអង្គព្រះពោធិសត្វនិងកន្សៃសារពេជ្ជ ។

# លទ្ធិផ្សេងៗក្នុងសាសនាព្រាហ្មណ៍



## ក. សិក្សាពាក្យគន្លឹះ

- សាហ័ស (ន) : សេចក្ដីក្លាហាន ការបៀតបៀន ភាវៈកាច ។
- សាស្ត្រធម្មិក (ន) : ដែលទ្រទ្រង់ ឬអ្នកមានចំណេះខាងគម្ពីរសាស្ត្រ ។
- សិទ្ធិការ (ន) : ការធ្វើឱ្យសម្រេចប្រយោជន៍ ។
- កោទ័ណ្ឌ (ន) : ធ្នូ ។
- សុភតិត្ថិ (ន) : ពេលាដែលជាសុភឫក្ស ថ្ងៃដែលល្អ ។
- សច្ចាអធិស្ឋាន (ន) : ការតាំងចិត្តទៀងទាត់ ការតាំងប្រកាសពាក្យសច្ចៈ ។
- រូពិន (គុ) : ប្រសើរឧត្ដុង្គឧត្ដម ។
- សុរិយាធុជ (ន) : ពន្លឺព្រះអាទិត្យដ៏ចិញ្ចាចចិញ្ចែង ។
- តេជតបៈជយោ (ន) : អំណាចដ៏ពូកែ ។
- ហសមាន (កិ) : ភ្ជួរនង្គ័ល ។
- សុពណ្ណៈ (គុ) : ដែលមានពណ៌មាស ។
- កោមល (ន) : ផ្កាឈូក ។
- សហស្ស (ន) : មួយពាន់ ។
- ឧណ្ហា (គុ) : ក្ដៅឧណ្ហៗ ក្ដៅតិចៗ ។
- អមរនាគេន្ទ្រា (ន) : ដំរីដ៏ល្អប្រសើរជាជំនិះរបស់ព្រះឥន្ទ្រ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងប្រភពអត្ថបទ តួអង្គ ។

## គ. អត្ថបទ

ដងនោះ ព្រះមកុដដ៏ភិរម្យ ប្រសើរដ៏ឧត្ដម ប្រពៃរូពិនមហាក្សត្រ ។ បិទបាំងនូវជញ្ជាំងជុំជិតស្ដម្ភទ្វារដ៏ពិចិត្រ ក្រលាតបះដុងដោម ។

ក្រលាចំរើនយេជ-សុរិយាធុជដ៏ធោងហោម សមិទ្ធិដ៏ស្លឹកស្លោម អម្លប់ត្រសាយសាខា ។ ទឹកធារហូរហួស បន្សាបពិសនូវសេលា ព្រិមព្រាលលាយដ៏សោភា ទឹកគង្គាដ៏សាចឡើង ។ ដូងស្លាដុះល្បុំបន្សំព្រះកុដិថ្កើង រៀងរាយបីយល់ឡើង គួរដៃក្តិចបីឆ្លូតឆ្លាស់ ។ ក្រូចក្រាយបង្គោភ្ញៀវ ស្រគំគុយក្រសាំងលាស់ ស្លឹកស្លោមដ៏ក្រៃក្រាស់ ប្រកបនូវអម្រឹតដ៏ផលា ។ កំប្រុកកំប្រោនក្រួញក្រាប នូវទោចសំពោចស្វា លលោតលេងលើសាខា ។

**សំរេប** ដងនោះមានអសូរសា-មាន្យមួយនាមា ហៅកាកនាសូរ[១] ស្តែង ។ ឮស័ព្ទសង្ខធុជថ្កើងថ្កែង ព្រតព្រះគម្ដែង ឥសូរដ៏រាមឫទ្ធា ។ អសុរនោះនិរមិត្ររូបា ជាកាកមួយសា ហោះហើរនូវតេជបីពន្លឹក ។មកចឹកហោមសាស្ត្រធម្មិក ឮស័ព្ទគឹក ស្លឹកស្មឹក្ញីញ័ររុះរោយ ។ ស្រែកស័ព្ទកាកនោះឮឆ្ងាយធុជធោងព្រាត់ព្រាយ ក៏ភិតពួនពឹងនៅនិត្យ ។ ដងនោះព្រះពិស្វាមិត្រ មហាឫសីសក្តិសិទ្ធ៏ ប្រព្រឹត្តដ៏ទ្រង់ឫទ្ធា ។ ស្ដេចសាងសីលធម៌សាស្ត្រា យេជយកចរិយា ដ៏ផ្ដុងនូវព្រតសិទ្ធិការ ។ ស្ដេចយល់កាកនាសុរមារ អសុរសាហ័សពាល បណ្ដាលអស់ព្រតសិទ្ធិការ ។ អញនូវសុំរាជបុត្រធម៌ ពីរពង្សអស្ចារ្យគឺអង្គសម្ដេចព្រះនារាយណ៍ ។ បុត្រព្រះទសរថឫទ្ធីសាយ អញនូវប្រស្រ័យស្រាយ សម័យនៃព្រះរាជា ។ អញនូវមកបំពេញព្រះសាសនា សម្ដេចឫទ្ធីចេស្ដា ជបសិល្ប៍នៃសាស្ត្រាគម ។ ឱ្យព្រះរាមលក្ស្មណ៍[២] ដ៏ឧត្ដមរឹងឫទ្ធីសិទ្ធិសម្ដែងតេជតបះជយា ។ ថាហៃរាមលក្ស្មណ៍ចូរបា អញ្ជើញក្សត្រលេលាដោយ ឫក្សពេលាទៀងទាត់ ។

**សំណា** ស្ដេចលេលាដងនោះ ព្រះរាជឫសីសិទ្ធីមារាជដ៏បពិត្រ នូវព្រះអនុជលក្សា[៣] ទៅអាស្រមដ៏ក្រឡាហោមជបកើតជា សរស័ក្តិសម្រិទ្ធីក្រៃ ។ ថាហៃរាមលក្ស្មណ៍ជាញជ័យ ឫទ្ធីបាលើសក្រៃ ចូរបាកោះសរផ្ទាញ់ថ្លែង ។ ផ្ទាញកាកនាសូរឱ្យស្តែង ឫទ្ធីតេជគម្ដែង នៃរាមនូវលក្ស្មណ៍ពីរពង្ស ។

**សំណាខរ** ដងនោះ ព្រះរាមស្ដេចទ្រង់ កៅទ័ណ្ឌសរទ្រង់ កោះកាំតម្រង់យក្សា ។ ព្រះថ្លែងអសុរកាកនា សុរក្ស័យជន្មា ជីវិតក៏មរណ៍ដួលនៅ ។

សរស័ក្តិហ្មលហ្មសបីសំដៅ មុជបាតាលទៅក៏សរព្រះអង្គដេញដល់ ហើរសព្វភូមិភពដ៏មណ្ឌល សរព្រះដេញដល់ ក៏លុះនូវក្ស័យជន្មា ។

**ដើតហើយច្រះ** ដងនោះ ព្រះបាទមិថិលា ស្តេចធ្វើចរិយា បីដោយនូវក្រឹត្យដ៏ពិធី ។ លុះពិសាខសុភតិត្ថិ ភ្ញុំមុខមន្ត្រី ប្រយោជន៍នូវប្រែពសុធា ។ ដើម្បីនូវធ្វើឱ្យក្សេមដល់ប្រជា រាស្ត្ររដ្ឋដោយនាក្រិតាធិការដ៏បុរាណ ។ ស្តេចទ្រង់នង្គ័លហសមាន ព្រះឧសភរាជបីរូហាន ដំណើរសីហនាថលេលា ។ ស្តេចភ្ជួរលុះដ៏ឆ្នេរ យមុនា នទីទេពកញ្ញា សុពណ្ណពោងពាយភុល ។

**សម្តេចភាណ** លើឈូករ័តន៍រាជកោមល បរិបូណ៌និមល ប្រសើរពិសេសលើសក្រៃ ។ ស្តេចមានព្រះរាជហឫទ័យ ត្រេកត្រិះអរក្រៃនឹងរាជបុត្រីកញ្ញា ។

**ច្រះជុក** ដងនោះឥសូរមិថិលា រៀបរាជយោធា នូវថ្វាត់រឹងថ្កានព្រះនគរ ។ នាំរាជកញ្ញាសុបវរស្មើបុត្រដ៏ឧទរ ក៏លុះលើរាជពិភព ។ ស្តេចរក្សារាស្ត្រផងស្គល់ស្កប់ ស្តេចទើបឱ្យអភិសេកប្រកបនាមា ។ ដោយហេតុហៅរាជសីតា បរិសុទ្ធសោភា[៤] ដូចបូណ៌ព្រះចន្ទ្រច្រាលច្រាស ។ វរភក្ត្រវរលក្ខណ៍យល់ច្បាស់ អស់ទេពទសសហ័ស្ស ពុំស្មើនូវរាជបុត្រី ។ ដងនោះព្រះបាទនរបតី យល់រាជបុត្រី ពិសេសពិសុទ្ធសុន្ទរ ។ នោះព្រះមុនីរាជដ៏បវរ ជបធនូសិល្ប៍សរ នូវស័ព្ទសច្ចាអធិស្ថាន ។ ថាទោះទេពតាឫទ្ធិមានជ័យអាចលើកបាន ធនូសិល្ប៍នូវតេជោជ័យ ។ យើងនូវយករ័តន៍សីតាថ្លៃ អភិសេកឱ្យពួនាទេពដ៏មានចេស្តា ។ អស្ចារ្យទួទសទិសា កក្រើកត្រៃត្រឹង្សាឧណ្ហា អស់ទេពដ៏និករ ។ អស់ទេពតាផងសឹងដ៏អរ បរគ្នាវីវរ រត់ចុះពីត្រៃត្រឹង្សា ។ ព្រះឥន្ទ្រស្តេចលើពួរា អមរនាគេន្ទ្រា រស្មីរុងរឿងគិតដ៏ថ្កើង ។ ព្រះអគ្គីស្តេចលើរមាសភ្លើង តេជោជ័យថ្កើង ឫទ្ធីរមាសមោះហិមា ។ ព្រះពាយផ្សាយផ្សព្វដ៏វេហាស៍ អស្សពាហន៍លេលា គឺពាយក៏បក់បីប្រហារ ។ ព្រះភិរុណព្រះអង្គបីឧទារ ស្តេចលើនាគនាថពិពិធពិពណ៌ជលធី ។ ព្រះចន្ទ្រកុមារ ស្តេចលីលាលើបក្សី សុពណ៌មយូររចនា ។ ព្រះព្រហ្មទ្រង់ព្រតសីលា ស្តេចលើហង្សា ធិរាជរឹងឫទ្ធិដ៏តបះ ។ ព្រះនេហូ[៥] ធិរាជតេជះ គង់លើយក្សតបះ កម្លាំងក៏ស្តេចយាត្រា ។ ព្រះព្រៃស្រីពណ៌រាជដ៏មហាធិបតិន្ទលេលា លើក្រោយពិមានដ៏មង្គល ។ ព្រះឥសូរសិទ្ធិស័ក្តិសួស្តីសល់ ត្រៃភពដ៏មង្គល សំណាក់នៃទេពឥន្ទ្រា ។ ស្តេចលើឧសភរាជដ៏មហា អតិរេកមោះហិមា នុភាពអំណាចព្រះធនូ ។ អស់ទេពកិន្នររាជព្រះភូធរទេតឫទ្ធិធនូ ប្រយោជន៍នូវចង់លើកលង ។

**ជើត** ព្រះឥសូរឫទ្ធីដ៏កន្លង ទូតទេពក្សត្រផង ក៏លងនូវតេជៈប្រាណ ។ ពុំអាចបីនូវលើកធនូបាននឹងនៅនាស្ថាន សំថិតនៅព្រះមុនី ។ នោះព្រះមុនីនាថនរបតី ស្តេចយល់ព្រះហរិ សម្តេចព្រះនារាយណ៍រាមា ។ ទោះនូវលើកធនូសិល្ប៍នូវឫទ្ធា បានបរិបូណ៌អានុភាពនូវតេជោពល ។ ព្រះឥសូរនរនាថស្តេចយល់ អស់ទេពតាដល់ ក៏ស្តេចនូវរឹងស្ថានស្ថិត ។

សម្តេចលេលា ដងនោះ ព្រះពិស្វាមិត្រ នាំរាជដ៏បពិត្រ នូវលក្ស្មណ៍សម្តេចយាត្រា ។ លុះដល់បុរីមិថិលា ចូលទូលរាជាធិរាជនូវសូមលើកលែង ។ ក្រុងមិថិលារីងស្នង អញ្ជើញស្តេចហោង សម្តែងនូវតេជព្រះធនូ ។

**សំណាខម** ព្រះរាមស្តេចមើលអស់ភូធរលើកឫទ្ធីធនូ ក៏ព្រើសព្រះភក្ត្រប្រិមប្រិយ ។ ស្តេចចូលលងឫទ្ធិដ៏ពិធី អស់ទេពដ៏ឥសី ក្សត្រទតអានុភាពចេស្តា ។ ព្រះរាមរឹងឫទ្ធិមោះហិមា ស្តែងស្តេចចេស្តាធិការនុភាពលើសក្រៃ ។ ស្តេចលើកកៅទ័ណ្ឌសរជ័យ អស់ទេពមនុស្សព្ទ ដ៏មានកំលុងលោកធាតុ ។ សឹងថ្វាយសព្ទសាធុការសាទរ ព្រះបរមនាថ ឫទ្ធីអំណាចយល់ថ្កើង ។ ស្តេចវាត់កៅទ័ណ្ឌបីជុំឡើងកោះសរសក្តិថ្លើង សម្តែងនូវតេជប្រត្យ័ក្ស ។ ស្តេចក្រាយកៅទ័ណ្ឌសរសក្តិ រូមណ្ឌលចក្រ រំភាយព្រះករសោភា ។

**ដើតហើយច្រះ** ដងនោះព្រះបាទមិថិលា ស្តេចយល់ដ៏ឫទ្ធា នុភាពព្រះរាមលើសក្រៃ ។ ស្តេចត្រេកអរឱ្យពរជ័យ ជយោជ័យក្រៃ សម្រិទ្ធីរាមមោះហិមា ។ ស្តេចយករ័តន៍រាជសីតា ប្រកបនូវលក្ខណា ក៏ថ្វាយព្រះរាមដ៏កន្លង ។ ស្តេចមុខមន្ត្រីផង ប្រើទូតទៅចង មេត្រីព្រះបាទទសរថ ។ ស្តេចផ្តាំទូតទៅបីកំណត់ ថ្កានព្រះទសរថ បីលុះបុរីអយុធ្យា ។

*(ដកស្រង់ចេញពីរឿងរាមកេរ្តិ៍ខ្មែរខ្សែទី១ ទំព័រទី ១-១១ ពុទ្ធសាសនបណ្ឌិត្យ)*

## សំណួរ

១. តើអត្ថបទខាងលើនេះមានប្រភពដកស្រង់ចេញពីរឿងណា ? បទអ្វីខ្លះ?

២. ចូរប្រាប់តួអង្គក្នុងអត្ថបទនេះ ។

៣. តើអត្ថបទនេះតែងក្នុងសម័យកាលណា ?

៤. ចូរប្រាប់មូលន័យនៅក្នុងអត្ថបទនេះ ។

៥. ចូរកំណត់គំនិតសំខាន់ៗនៅក្នុងអត្ថបទនេះ ។

៦. ចូរបង្ហាញលក្ខណៈមនុស្សតាមរយៈអត្ថបទនេះ ។

៧. ចូរបង្ហាញពីតម្លៃអប់រំនៅក្នុងអត្ថបទនេះ ។

---

*១. អសុរនេះឈ្មោះតារក តែដោយហេតុនិម្មិតត្រខ្លួនជាក្អែក គេទើបហៅ កាកនាសូរ ។*

*២. ច្បាប់សំស្រ្កឹតជា លក្ស្មណ៍ ។*

*៣. ពាក្យត្រូវលក្ស្មណ៍*

*៤. ច្បាប់ខ្មែរប្រើសរសេរជា សេតា*

*៥. ប្រហែលជានាមព្រះកុវរ សរសេរដូច្នេះប្រហែលជាខុសទេ ?*

# អំពីព្យញ្ជនៈទោល

ក្នុងមេរៀនមុនអ្នកធ្លាប់សិក្សារួចមកហើយអំពីសូរស្រៈតទៅនេះទៀតអ្នកនឹងបានសិក្សាបន្ថែមទៀតអំពីសូរព្យញ្ជនៈ ដែលមាននៅក្នុងភាសាខ្មែរ ។

ចូរអ្នកសង្កេតឧទាហរណ៍ខាងក្រោមនេះ ៖

"ព្រះឥសូរឫទ្ធិដ៏កន្លង ទូតទេពក្សត្រផង ក៏លងនូវតេជៈប្រាណ ។ ពុំអាចបីនូវលើកធនូបាននឹងនៅនាស្ថាន សំបិតនៅព្រះមុនី ។"

- បី ផ្សំឡើងដោយ : ប + [អី] ។
- នា ផ្សំឡើងដោយ : ន + [អា] ។
- បិត ផ្សំឡើងដោយ : ប + [អិ] + ត ។
- ទូត ផ្សំឡើងដោយ : ទ + [អូ] + ត ។

ក្នុងឧទាហរណ៍នេះ បង្ហាញឱ្យឃើញថា ព្យញ្ជនៈដើមព្យាង្គសុទ្ធតែជាព្យញ្ជនៈទោល គឺ "ប ន ប ទ" ។ ឯព្យញ្ជនៈចុងព្យាង្គ ក៏ជាព្យញ្ជនៈទោលដែរគឺ "ត" ។ តាមលក្ខណៈបន្លឺព្យញ្ជនៈទោលអាចចែកចេញជា ៖

ក. ព្យញ្ជនៈបបូរមាត់មាន ៖

- ប ប៊ [b] បរ ប៊ិក ។
- ផ ភ [ph] ផង ភួយ ។
- ប៉ ព [p] ប៉ិច ពុត ។
- ម៉ ម [m] ម៉ក់ មូល ។

ខ. ព្យញ្ជនៈធ្មេញមុខមាន ៖

- វ៉ វ [v] វ៉ៃ វែង ។

គ. ព្យញ្ជនៈក្រអូមមុខមាន ៖

- រ៉ រ [r] រ៉ រាង ។

ឃ. ព្យញ្ជនៈគន្លាក់ក្រអូម មាន ៖

- ដ ឌ [d] ដឹង ឌិន ។
- ថ ធ ឋ ឍ [th] ថៃ ធន់ ឋាន ឍាល ។
- ណ ន [n] ណាត់ នាង ។
- ស ស៊ [s] សក ស៊ក ។

- ត ទ [t] តឹង ទង។

- ឡ ល [l] ឡើង លង។

ង. ព្យញ្ជនៈក្រអូមកណ្ដាល មាន ៖

- ច ជ [c] ចឹក ជីក។

- ឆ ឈ [ch] ឆី ឈី។

- ញ៉ ញ [ɲ] ញ៉ែ ញោច។

- យ៉ យ [j] យ៉ យោក។

ច. ព្យញ្ជនៈក្រអូមក្រោយមាន ៖

- ក គ [k] កើត គិត។

- ខ ឃ [kh] ខឹង ឃើញ។

- ង [ŋ] ងើប។

ឆ. ព្យញ្ជនៈដើមមាត់ មាន ៖

- ហ ហ៊ [h] ហោះ ហ៊ាន។

ជ. ព្យញ្ជនៈចន្លោះខ្សែសំឡេង មាន ៖

- អ អ៊ [ʔ] អរ អ៊ុត។

ដូចនេះតាមលក្ខណៈបន្លឺ ព្យញ្ជនៈមាន ៖

១. ព្យញ្ជនៈបបូរមាត់ គឺជាព្យញ្ជនៈដែលកើតត្រង់បបូរមាត់ មាន បប៊ ប៉ព ផភ ម៉ម។

២. ព្យញ្ជនៈធ្មេញ គឺជាព្យញ្ជនៈដែលកើតត្រង់ធ្មេញមុខ មាន វ៉ វ។

៣. ព្យញ្ជនៈក្រអូមមុខ គឺជាព្យញ្ជនៈដែលកើតត្រង់ក្រអូមមុខ មាន រ៉ រ។

៤. ព្យញ្ជនៈគន្លាក់ក្រអូម គឺជាព្យញ្ជនៈដែលកើតត្រង់គន្លាក់ក្រអូម មាន ដឌ តទ ថធ ឋឍ ណន សស៊ លឡ។

៥. ព្យញ្ជនៈក្រអូមកណ្ដាល គឺជាព្យញ្ជនៈដែលកើតត្រង់ក្រអូមកណ្ដាល មាន ចជ ឆឈ ញ៉ញ យ៉យ។

៦. ព្យញ្ជនៈក្រអូមក្រោយ គឺជាព្យញ្ជនៈដែលកើតត្រង់ក្រអូមក្រោយ មាន កគ ខឃ ង៉ង។

៧. ព្យញ្ជនៈដើមមាត់ គឺជាព្យញ្ជនៈដែលកើតត្រង់សន្ទុះដើមមាត់ មាន ហ ហ៊។

៨. ព្យញ្ជនៈចន្លោះខ្សែសំឡេង គឺជាព្យញ្ជនៈដែលកើតត្រង់សន្ទុះខ្សែសំឡេង មាន អ អ៊។

## លំហាត់

១. ចូរអ្នកជ្រើសរើសពាក្យ តែ១ព្យាង្គទៅតាមលក្ខណៈបន្លឺ(ព្យញ្ជនៈទោល) ដែលមាននៅក្នុងអត្ថបទដកស្រង់ខាងក្រោមនេះ ដើម្បីបញ្ជាក់ថា :

ក. ព្យញ្ជនៈបបូរមាត់

ខ. ព្យញ្ជនៈធ្មេញ

គ. ព្យញ្ជនៈក្រអូមមាត់

ឃ. ព្យញ្ជនៈគន្លាក់ក្រអូម

ង. ព្យញ្ជនៈក្រអូមកណ្ដាល

ច. ព្យញ្ជនៈក្រអូមក្រោយ

ឆ. ព្យញ្ជនៈដើមមាត់

ជ. ព្យញ្ជនៈចន្លោះខ្សែសំឡេង ។

[...] សំណាខ្មែរ ព្រះបាទទសរថភូធរ ស្ដេចសោកគក់គរ ឱរាប្រមៀលអាត្មា ។ ឃើត្បិតប្រាសព្រះរាមា បុត្រច្បងស្ងួនភ្ងា និងព្រះលក្សាធិបតី ។ ដ្បិតពាក្យនាងកៃកេសី ទូលទាស់នូវក្ដី ឥតធម៌កន្ទ្រឹសឫស្យា ។

ឱត ក្សិណាឮដល់ព្រះរាមា នូវព្រះលក្សា ធិរាជដ៏ពីរចក្រី ។ ព្រះលក្ស្មណ៍ស្ដេចក្រោធឡើងខ្មីដាលដូចអគ្គី ក៏ទ្រង់ព្រះខ័នពេជ្រថ្លា ។ ប៉ងនូវពិឃាតជន្មា ព្រះវរមាតា គឺនាមនាងកៃកេសី ។ ទើបព្រះរាមទេពធិបតី ព្រះឱស្ឋប្រិមប្រិយ ឃាត់ព្រះអនុជលក្សា ។ ថាហៃវរលក្ស្មណ៍កុំបីបា គិតចងទោសានឹងអ្នកដ៏មានគុណថ្លៃ ។ អំពើនោះបាបធ្ងន់ក្រៃ កុំធ្វើថ្មោះនៃ ចូរបារំសាយក្រោធា ។

សំណាខ្មែរ ដងនោះព្រះលក្ស្មណ៍អនុជា ក្រាបវរបាទា សម្ដេចព្រះរាមនរបតី ។ ព្រះរាមព្រះអនុជចក្រី រួមរាជមេត្រី ក៏ស្ដេចនូវចរយាត្រា ។ [...]

២. ចូរអ្នកជ្រើសរើសពាក្យខាងក្រោមនេះ ដែលជាព្យញ្ជនៈទោល : ដើរ ទាន រៀន សិស្ស ថ្នាក់ លេង សើច បិដក ព្រះ សិរៈ មន្ត ។

៣. ចូរអ្នកជ្រើសរើសព្យញ្ជនៈខាងក្រោមនេះ ដែលជាព្យញ្ជនៈបបូរមាត់ : បាញ់ វែង វារ មើល ផើង មេ ម៉ែ ពាង រឹង វែង រុំ រុក្ខា ។

៤. ចូរអ្នកជ្រើសរើសព្យញ្ជនៈដើមមាត់ ដែលមានដូចខាងក្រោម : ហ៊ឺហា ហោ៊ លេង ការងារ ខកចិត្ត តោង តែងតែ ខំរៀន ។



# គោលគំនិតសំខាន់នៃសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនា



## ក. សិក្សាពាក្យគន្លឹះ

- គម្ពីរ (នឬគុ) : សាស្ត្រាច្បាប់ ធម្មវិន័យ ដែលរួបរួមដោយពួកប៉ែកដោយខ្សែ ។
- ត្រៃវេទ (ន) : ប្រជុំនៃវេទទាំងបីក្នុងសាសនាព្រាហ្មណ៍ គឺឫគវេទ សាមវេទ និងយជុរវេទ ។
- បិដក (ន) : ប្រជុំគម្ពីរបីមានន័យថា ប្រជុំនៃព្រះវិន័យ ព្រះសុត្តន្ត និងព្រះអភិធម្ម ។
- អារ្យ៉ាន (ន) : ឈ្មោះជនជាតិមួយដែលនាំសាសនាព្រាហ្មណ៍ចូលមកនិងលុកលុយក្នុងប្រទេសឥណ្ឌា ។
- ស្រុតិ (ន) : ការស្តាប់ ដំណឹង ត្រចៀក ។
- ឫសិ (ន) : ព្រះឥសី ។
- ពាហិរសាសនា (ន) : ក្រៅពីសាសនាព្រះពុទ្ធ (សាសនាដទៃ) ។
- សង្គាយនា(ន) : ការប្រជុំសូត្រឱ្យត្រូវគ្នាតាមបែបតែមួយ ការប្រជុំផ្ទៀងផ្ទាត់ធម៌ ឬច្បាប់ឱ្យត្រឹមត្រូវតាមបែបដើម ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយសំណួរទាក់ទងនឹងការវិវត្តនៃសាសនាព្រាហ្មណ៍ លក្ខណៈនៃគម្ពីរត្រៃវេទ និងលក្ខណៈនៃគម្ពីរព្រះត្រៃបិដក ។

## គ. អត្ថបទ

ដោយវប្បធម៌ខ្មែរនិងវប្បធម៌ឥណ្ឌាមានទំនាក់ទំនងគ្នាជាយូរណាស់មកហើយ ពោលគឺចាប់ពីរជ្ជកាល ហ៊ុន ទៀន និងនាង លីវ យី មកម្ល៉េះ។ វប្បធម៌ឥណ្ឌា ដែលគេសង្កេតឃើញមាននៅក្នុងវប្បធម៌ខ្មែរដូចជា អក្សរ ភាសាបាលី សំស្ក្រឹត ប្រពៃណី ទំនៀមទម្លាប់ ជំនឿ ...។ល។ ក្រៅពីនេះ គេឃើញសាសនាធំពីរនេះ កំពុងមានឥទ្ធិពលយ៉ាងខ្លាំងក្នុងសង្គមខ្មែរលើគ្រប់វិស័យ គឺសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនា។

សាសនាព្រាហ្មណ៍មានកំណើតនៅប្រទេសឥណ្ឌាប្រមាណ ១៥០០ ឆ្នាំមុនគ.ស. ដែលនាំចូលដោយពួកអារ្យ៉ន។ សាសនាព្រាហ្មណ៍នេះទៀតសោតត្រូវបានហូរចូលមកក្នុងដែនដីសុវណ្ណភូមិចំនួនពីរលើកធំៗ គឺដើមសតវត្សរ៍ទី១ តាមរយៈព្រះបាទ ហ៊ុន ទៀន និង នាង លីវ យី។ ចំណែកលើកទីពីរនៅដើមសតវត្សរ៍ទី ៥ ។

សាសនាព្រាហ្មណ៍ត្រូវបានគេចែកជាបីដំណាក់កាលធំៗគឺ សម័យវេទនិយម (១៥០០ឆ្នាំមុន គ.ស.ដល់ ៥៥០ឆ្នាំមុនគ.ស.)គឺសម័យព្រាហ្មណ៍និយម(៥៥០ឆ្នាំមុន គ.ស. ដល់សតវត្សរ៍ទី ១០នៃ គ.ស.) និងដំណាក់កាលទី ៣ សម័យហិណ្ឌូនិយម(សតវត្សរ៍ទី១០នៃគ.សដល់សម័យបច្ចុប្បន្ននេះ)។

សម័យវេទនិយម គឺជាសម័យដែលគេចាត់ទុកគម្ពីរវេទជាមូលដ្ឋានទ្រឹស្តីសម្រាប់អធិប្បាយអំពីសាសនានៃពួកអារ្យ៉នដែលជាជាតិមួយក្រុមមានកំណើតនៅតំបន់ឥណ្ឌូ-អឺរ៉ុប ហើយបានលុកលុយផ្សាយវប្បធម៌និងអរិយធម៌របស់ខ្លួន ចាប់ពីប្រទេសអ៊ីរ៉ង់រហូតដល់ប្រទេសឥណ្ឌា។ វេទ គឺជាចំណេះដឹងដ៏ពិសិដ្ឋដែលព្រះអាទិទេពបានធ្វើអំណោយមក។ ព្រះអាទិទេពបានប្រគល់គម្ពីរវេទឱ្យពួកមនុ (Manu) ដែលជាតំណាងរបស់ខ្លួន ហើយបានក្លាយជាមនុស្សចម្បងគេបំផុតក្នុងលោក។ មនុស្សបានផ្សាយគម្ពីរវេទឱ្យពួកឫសិតាមស្រុតិ។ ពួកឫសិបានចងក្រងបទបញ្ញាទាំងឡាយជាគម្ពីរហើយផ្សាយទៅឱ្យពួកព្រាហ្មណ៍រៀនសូត្រតាមយល់ តាមដោយពុំមានសិទ្ធិសួរដេញដោលរកខុសត្រូវឡើយ ព្រោះគម្ពីរនេះជាអំណោយរបស់ព្រះអាទិទេព។ បទបញ្ញាទាំងឡាយក្នុងគម្ពីរមានលក្ខណៈសច្ចៈ។ ពួកព្រាហ្មណ៍មានសិទ្ធិផ្តាច់មុខក្នុងការផ្សាយគម្ពីរវេទនេះ។ គម្ពីរវេទទាំងអស់មានបី ហៅថាត្រៃវេទ។ គម្ពីរទីមួយ គឺឫគវេទ គឺជាគម្ពីរដែលនិយាយសរសើរ បួងសួង អង្វរករទេវតាផ្សេងៗនិងអាទិទេពដែលស្ថិតនៅក្នុងធម្មជាតិយើងនេះដូចជា ព្រះអាទិត្យ ព្រះចន្ទ ព្រះពាយ ព្រះធរណី ព្រះអគ្គី ព្រះពិរុណ គម្ពីរឫគវេទចែកជា ១០២៨ សូត្រ ឬមណ្ឌល ១សូត្រមាន ៥៨គាថា។ ចំណែកឯគម្ពីរយជុរ

វេទ គឺជាគម្ពីរនិយាយពីការបន់ស្រន់អង្វរករទេវតានៅឋានលើឱ្យចុះមកជួយ ដើម្បីមានឫទ្ធិតេជៈបារមី ផ្នែកខ្លះទៀតនិយាយដូចគម្ពីរឫគវេទដែរ ។ គម្ពីរយជុរវេទចែកជាពីរផ្នែក គឺយជុរវេទខ្មៅសម្រាប់ធ្វើការបូជាក្សត្រក្នុងពិធីរាជាភិសេក បូជាក្នុងខណៈពេលដែលមានព្រះមហាក្សត្រពង្រីកទឹកដី ។ ចំណែកយជុរវេទស គឺជាគាថាសម្រាប់ធ្វើបូជាយញ្ញ ។ គម្ពីរសាមវេទ គឺជាគម្ពីរដែលមានលក្ខណៈជាពាក្យកាព្យសម្រាប់សូត្របន់ចិត្តទេវៈអាទិទេពស្ដីអំពីពិធីបូជាយញ្ញនិងមន្តអាគមផ្សេងៗ ។ មន្តអាគម មានពីរបែប គឺទីមួយមន្តអាគមសម្រាប់រៀនក្នុងស្រុកនិងមួយទៀតសម្រាប់រៀនក្នុងព្រៃព្រោះអាចមានគ្រោះថ្នាក់ចង្រៃផ្សេងៗកើតមានឡើង ។ ក្រៅពីនោះ មានអត្ថបទកំណាព្យខ្លះទៀតនិយាយសរសើរព្រះអាទិទេពដូចគម្ពីរឫគវេទ ។ គម្ពីរអថិវេទ (អថិវេទ គឺសម្គាល់លើឈ្មោះព្រាហ្មណ៍ម្នាក់) ជាគម្ពីរបន្ថែមពេលក្រោយ ។ គម្ពីរអថិវេទមាន ២០សៀវភៅចែកជា ២០កណ្ឌរួមមាន ៦០០០គាថា ។ គម្ពីរនេះបង្រៀនពីមន្តអាគម ដើម្បីសម្រេចបំណងដែលជាសេចក្ដីត្រូវការរបស់អ្នកស្រុក ។ គម្ពីរអថិវេទនេះមានដូចជា មន្តអាគមស្ដោះពិសពស់ មន្តអាគមហៅពស់ មន្តអាគមបណ្ដេញគ្រោះ មន្តអាគមលើករាសី មន្តអាគមស្នេហ៍ មន្តអាគមឱ្យពរពេលរៀបអាពាហ៍ពិពាហ៍ មន្តអាគមសម្រាប់បូជាសព ។

សម័យព្រាហ្មណ៍និយម ពួកព្រាហ្មណ៍ជាអ្នកគោរពបូជាអាទិទេព គេជឿថាបញ្ហាអាទិទេព គឺពុំមានបញ្ហាអស្ថិរូបទេ ដែលគេចាត់បញ្ចូលទៅក្នុងទស្សនវិជ្ជារូបនិយម ។ អាស្រ័យហេតុនេះ បានជាគេធ្វើឱ្យអាទិទេពរបស់ពួកគេ ជាតួអង្គមានរូបរាងមានគ្រួសារមានបញ្ហាដូចមនុស្សដែរ ។ ក្នុងសម័យព្រាហ្មណ៍និយម គេនិយមគោរពទេវសំខាន់បីអង្គ គឺព្រះព្រហ្ម ព្រះសិវៈ ព្រះវិស្ណុ ។

ចំណែកឯអាទិទេពរងមាន ដូចជាព្រះអាទិត្យ ព្រះចន្ទ ព្រះធរណី ព្រះគង្គា ព្រះពាយ ព្រះពិរុណ ។ល។ សាសនាហិណ្ឌូមានការវិវត្តច្រើនយ៉ាងទៅតាមជំនឿនៃតំបន់នីមួយៗ ។ ការគោរពព្រះអាទិទេពខុសគ្នា ការឱ្យតម្លៃព្រះអាទិទេពខ្វែងគ្នា ។ ហិណ្ឌូនិយមជាលទ្ធិសំយោគរវាងវេទនិយមនិងព្រាហ្មណ៍និយម បានសេចក្ដីថាហិណ្ឌូនិយមពុំមែនជាលទ្ធិថ្មីរបស់ពួកហិណ្ឌូនោះទេ ។ ផ្ទុយទៅវិញលទ្ធិនេះមានមូលដ្ឋានផ្អែកលើទស្សនទ្រឹស្ដីវេទនិយមនិងទ្រឹស្ដីព្រាហ្មណ៍និយមស្ទើរទាំងស្រុង ។

ក្នុងព្រះពុទ្ធសាសនា ទស្សនទ្រឹស្ដី លទ្ធិទាំងប៉ុន្មានរបស់ព្រះពុទ្ធ ត្រូវបានគេចងក្រងជាគម្ពីរដែលហៅថាព្រះត្រៃបិដក ។ គម្ពីរព្រះត្រៃបិដក គឺជាឃ្លាំងផ្ទុកពុទ្ធវចនៈរបស់ព្រះពុទ្ធ ដែលទ្រង់ទេសនាទូន្មានរវាង ៤៥ ព្រះវស្សាចាប់តាំងពីទ្រង់បានត្រាស់ដឹងព្រះសម្ពោធិញ្ញាណរហូតដល់ព្រះអង្គ

បានចូលនិព្វាន ។ វចនៈដែលទ្រង់សម្តែងនេះហៅថាធម្មវិន័យ ។ ធម្មវិន័យនេះចែកជាបី (សុត្តន្ត វិន័យនិងអភិធម្ម) ទាំងបីចំណែកនេះព្រះថេរៈទាំងឡាយបានសង្គាយនា(ផ្ទៀងផ្ទាត់) ចងក្រងទុកដាក់មួយក្រុមៗ ហៅថាបិដក ឬព្រះត្រៃបិដក (កញ្ជើបី) ។ ពាក្យថាបិដក បើប្រែជាបណ្ណាល័យក៏សឹងតែបានដែរ ។ គម្ពីរព្រះត្រៃបិដកមានចំនួនច្រើនជាងគម្ពីរវេទច្រើនណាស់ ច្រើនជាងគម្ពីរប៊ីប១១ដង ។

**គម្ពីរព្រះត្រៃបិដក** គឺគម្ពីរដែលជាឃ្លាំងផ្ទុកនូវពុទ្ធវចនៈចំនួន ៨៤០០០ធម្មក្ខន្ធ ហើយពុំមានជាវចនៈអាទិទេពនោះទេ ហើយក៏មិនមែនជាពាហិរសាសនាដែរ ។ ក្រោយព្រះពុទ្ធបរិនិព្វានភ្លាម មានការធ្វើសង្គាយនាផ្ទៀងផ្ទាត់ធ្វើឱ្យបានត្រឹមត្រូវគង់វង្សបរិសុទ្ធនៅដូចដើមពុំមានការបន្ថែមឡើយ ។

គម្ពីរព្រះត្រៃបិដកមានបី គឺវិន័យបិដក (១៣ ភាគ មាន ២១០០០ធម្មក្ខន្ធ) សុត្តន្តបិដក (១៤ ភាគ មាន ២១០០០ធម្មក្ខន្ធ) អភិធម្មបិដក ( ៣៣ ភាគ មាន ៤២០០០ធម្មក្ខន្ធ) ។

**វិន័យបិដក** ជាគម្ពីរស្តីពីច្បាប់ក្រឹត្យក្រម ដែលព្រះអង្គទ្រង់បញ្ញត្តិអនុញ្ញាតទុក សម្រាប់ជាផ្លូវប្រតិបត្តិរបស់ព្រះភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ គម្ពីរវិន័យនេះមានសេចក្តីពិស្តារណាស់ ជាកញ្ចក់ឆ្លុះមើលជីវភាពប្រវត្តិព្រះអង្គក្នុងកាលដែលទ្រង់គង់ជាធរមាននៅឡើយ ព្រមទាំងហេតុការណ៍ផ្សេងៗនៅប្រទេសឥណ្ឌានាសម័យព្រះអង្គដូចជា ប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ ការរចនា និងវិទ្យាសាស្ត្រផ្សេងៗ ។ល ។

វិន័យបិដកមាន៥គម្ពីរ គឺ អាទិកម្ម (ទោសធ្ងន់) បាចិត្តយ (ទោសស្រាល) មហាវគ្គ (វគ្គធំ) ចុលវគ្គ (វគ្គវាយរង) បរិវារ (បទវាយរង) ។

**សុត្តន្តបិដក** ជាគម្ពីរស្តីពីព្រះសូត្រ ដែលព្រះអង្គទ្រង់ត្រាស់ទេសនាក្នុងសម័យផ្សេងៗ មានព្រះសូត្រខ្លះព្រះអរិយសាវ័កសម្តែងដូចជាព្រះសារីបុត្តត្ថេរជាដើម ។ គម្ពីរសុត្តន្ត ឬគម្ពីរព្រះសូត្រមាន ៥គម្ពីរ គឺទីឃនិកាយ (សូត្រមានសេចក្តីពិស្តារ) មជ្ឈិមនិកាយ (សូត្រមានសេចក្តីមធ្យម) សំយុត្តនិកាយ (សូត្រមានសេចក្តីប្រហែលៗគ្នា) អង្គុត្តរនិកាយ (សូត្រមានសេចក្តីជាក្រុមជាពួក) ខុទ្ទកនិកាយ (សូត្រមាន សេចក្តីខ្លី) ។

**អភិធម្មបិដក** ជាគម្ពីរស្តីពីធម៌អាថ៌ជ្រាលជ្រៅជាល្អិតសុខុមបំផុតបានដល់ទស្សនវិជ្ជាព្រះសម្មទ្ធដែលមានអាថ៌កម្ពីរភាព (ជ្រាលជ្រៅ) ជាអត្ថបទផ្ទុយពីសុត្តន្តបិដក ។ សុត្តន្តបិដកជាវោហារទេសនា រីឯអភិធម្មបិដកជាបរមត្ថទេសនាស្តីពីចិត្ត ចេតសិក រូប និព្វាន ។ អភិធម្មបិដកនេះ ព្រះសម្ពុទ្ធទេសនាទុកថាសត្វទាំងអស់ជាបុគ្គល ដោយញែកយ៉ាងល្អិតសុខុមទាល់តែចែកលែងកើត ហើយចែករំលែកធម៌ដោយបរិយាយហ្មត់ចត់បំផុត ។

គម្ពីរនេះមានទាំងអស់ ៧គម្ពីរ គឺធម្មសង្គណី (ការចាត់របៀបធម៌) វិភង្គ (ការចែករំលែកធម៌) កថាវត្ថុ (ចំណុចធម៌ដែលមានសេចក្ដីផ្ទុយគ្នា) បុគ្គលបញ្ញត្តិ (បញ្ញត្តិកថាបុគ្គល) ធាតុកថា (ការវែកញែកធាតុ) យមកៈ (ធម៌គូគ្នា) បដ្ឋាន (ធម៌ជាបច្ច័យទាក់ទងគ្នា)។

បិដកទាំងបីរួមឈ្មោះថា ត្រៃបិដក។ ប្រទេសកម្ពុជាយើងបានបោះពុម្ពជាសៀវភៅ១១០សៀវភៅ ដែលជាចំនួនច្រើនលើសសាសនាដទៃ បើធ្វើការប្រៀបធៀបជាមួយពាហិរសាសនាក្នុងលោក។

*(ដកស្រង់ចេញពីឯកសារវប្បធម៌ អរិយធម៌ខ្មែរភាគទី ២ របស់លោក សរ សារុន ទំព័រទី ១៦០-២០៥)*

## សំណួរ

១. តាមរយៈអត្ថបទនេះ ៖

- តើសាសនាព្រាហ្មណ៍មានកំណើតនៅឯណា ?
- តាំងពីពេលណាមក ?
- ហើយបានហូរចូលក្នុងដែនដីសុវណ្ណភូមិដូចម្ដេចដែរ ?

២. តើគេបែងចែកសាសនាព្រាហ្មណ៍ជាប៉ុន្មានដំណាក់កាលធំៗ ? អ្វីខ្លះ ?

៣. តើគម្ពីរវេទចែកចេញជាប៉ុន្មាន ? ហើយគម្ពីរនីមួយៗខុសគ្នាដូចម្ដេចខ្លះ ?

៤. តើព្រះពុទ្ធសាសនាគេគោរពគម្ពីរអ្វី ? ហើយមានអ្វីខ្លះ ?

៥. តើភាពខុសគ្នានៃការគោរពគម្ពីរក្នុងព្រះពុទ្ធសាសនាមានលក្ខណៈដូចម្ដេច ?

៦. ចូរបង្ហាញពីតម្លៃអប់រំតាមរយៈ ៖

- ការគោរពសាសនាព្រាហ្មណ៍។
- ការគោរពសាសនាព្រះពុទ្ធ។

៧ ចូរអ្នកបង្ហាញបន្ថែមទៀតពីឥទ្ធិពលសាសនាព្រាហ្មណ៍នៅក្នុងមង្គលការ។

# ការនិយាយប្រៀបធៀប

ការនិយាយប្រៀបធៀប គឺជាការលើកយកគំនិត ទស្សនៈ មតិ ឬវត្ថុពីរមកធ្វើការប្រៀបធៀប ដើម្បីស្វែងយល់ពីចំណុចដូចគ្នានិងចំណុចខុសគ្នានៃគំនិត ទស្សនៈ មតិ ឬវត្ថុនោះ។ ដូចនេះ ក្នុងពេលបញ្ចេញមតិ សមាជិកនៃក្រុមពិភាក្សានីមួយៗ គប្បីមានគោលជំហរមួយ គឺត្រូវបង្ហាញឱ្យឃើញលក្ខណៈដូច ឬលក្ខណៈខុសគ្នា ដោយផ្អែកលើហេតុផលឱ្យបានសមស្រប ។ មិនតែប៉ុណ្ណោះ សមាជិកក្នុងក្រុមមានសិទ្ធិគាំទ្រ ឬមិនគាំទ្រចំពោះគោលគំនិតណាមួយដែលត្រឹមត្រូវ ឬមិនត្រឹមត្រូវ ។

ខាងក្រោមនេះជាការណែនាំ ក្នុងការនិយាយប្រៀបធៀប ៖

- បង្ហាញសេចក្ដីលំអិតសំខាន់ៗ របស់គំនិតពីរឱ្យសមាជិកក្នុងក្រុមឃើញពីលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នា ។
- លើកយកចំណុចដូចគ្នានិងចំណុចខុសគ្នាងាយៗរបស់គំនិត ឬស្ថានភាពទាំងពីរមកបង្ហាញ ដោយផ្ដល់ឧទាហរណ៍ ឬអំណះអំណាងច្បាស់លាស់ ។
- ធ្វើសេចក្ដីសន្និដ្ឋាននៅចុងបញ្ចប់នៃការនិយាយប្រៀបធៀបរបស់អ្នក ។
- ទុកពេលឱ្យសមាជិកនៅក្នុងក្រុមសួរ ឬបញ្ចេញយោបល់បន្ថែមទៅលើគំនិតរបស់អ្នក ។
- ប្រើសំនួនប្រៀបធៀបលក្ខណៈខុសដូចជា :
  - ផ្ទុយពី ...
  - បែរជា ...
  - ផ្ទុយទៅវិញ ...
  - មិនដូច ...
  - មិនស្មើនឹង ...
  - មិនប្រហាក់ប្រហែលនឹង ...
  - ..................................

## លំហាត់

ចូរចែកសិស្សជាក្រុម ដោយជ្រើសរើសប្រធានបទខាងក្រោមមកនិយាយប្រៀបធៀប ស្របតាមការណែនាំខាងលើនេះ ៖

១. ពិធីមង្គលការសម័យបុរាណនិងពិធីមង្គលការសម័យបច្ចុប្បន្ន ។

២. ការគោរពបូជាក្នុងពុទ្ធសាសនានិងព្រហ្មញ្ញសាសនា ។

# រឿងសុវណ្ណសាម



ដើម្បីស្វែងយល់ពីជាតិសាសន៍មួយ គេត្រូវសិក្សាពីវប្បធម៌នៃជាតិសាសន៍នោះ ដែលទាក់ទងទៅនឹងជំនឿ សាសនា ទំនៀមទម្លាប់ប្រពៃណី ឬការគោរពបូជាជាដើម។ ដើម្បីជាជំនួយក្នុងការផ្តល់ពុទ្ធិជុំវិញផ្នត់គំនិតសំខាន់នៃការគោរពបូជានេះ អ្នកនឹងបានស្តាប់រឿងសុវណ្ណសាម ហើយត្រៀមឆ្លើយសំណួរដូចខាងក្រោមនេះ ៖

១. ចូរអ្នកធ្វើការបង្ហាញពីប្រភេទរបស់រឿងនេះ ដោយបញ្ជាក់ឧទាហរណ៍។

២. តើសុវណ្ណសាមត្រូវព្រះបាទកបិលយក្ខបាញ់នៅពេលណា ? ទីកន្លែងណា ?

៣. ហេតុអ្វីបានជាព្រះបាទកបិលយក្ខបាញ់សុវណ្ណសាម ?

៤. តើរឿងនេះបានបង្ហាញពីលក្ខណតថៈយ៉ាងណាខ្លះ ?

៥. តើសុវណ្ណសាមត្រូវបំពេញកាតព្វកិច្ចយ៉ាងណាខ្លះ ក្នុងការគោរពប្រណិប័តន៍ចំពោះអ្នកមានគុណ?

៦. តើការគោរពប្រណិប័តន៍ ចំពោះអ្នកមានគុណអាចចាត់ទុកជាផ្នត់គំនិតជាតិខ្មែរបានដែរឬទេ ? ព្រោះអ្វី ?

៧. ចូរអ្នកបង្ហាញពីគុណសម្បត្តិ នៃតួអង្គសុវណ្ណសាមនិងតួអង្គព្រះបាទកបិលយក្ខ។

៨. ចំពោះអ្នកវិញ អ្នកគប្បីត្រូវត្រាប់ តាមកិច្ចគោរពប្រណិប័តន៍ចំពោះអ្នកមានគុណ ដូចជាសុវណ្ណសាមដែរឬទេ ?

# តែងសេចក្ដីប្រៀបធៀប

ប្រធានប្រៀបធៀប ជាប្រធានបែបពន្យល់ ប៉ុន្តែការពន្យល់ត្រូវពន្លេចឱ្យឃើញចំណុចដូចគ្នា ឬប្រហាក់ប្រហែលគ្នា និងចំណុចខុសគ្នា ។

ចូរអ្នកធ្វើការប្រៀបធៀបលក្ខណៈសម្បត្តិតួអង្គនាងសីតាក្នុងរឿងបែបព្រាហ្មណ៍និយមនិងតួអង្គនាងមទ្រីក្នុងរឿងបែបពុទ្ធនិយម ។ តើមានលក្ខណៈដូចគ្នានិងខុសគ្នាយ៉ាងណាខ្លះ ?

បើតាមលក្ខណៈជាតិខ្មែរ នារីគឺជាកត្តាចម្បងដែលជំរុញឱ្យសង្គមគ្រួសារមានសុភមង្គល ។ ចំពោះភាពចាំបាច់នៃលក្ខណសម្បត្តិរបស់ស្ត្រីនេះ ត្រូវបានកវីនិពន្ធយើងលើកយកមកបង្ហាញនៅក្នុងរឿងបែបព្រាហ្មណ៍និយម គឺនាងសីតានិងរឿងបែបពុទ្ធនិយម គឺនាងមទ្រីដែរ ។

តើនាងទាំងពីររូបនេះ មានលក្ខណសម្បត្តិដូចគ្នានិងខុសយ៉ាងណាខ្លះ ?

ដើម្បីធ្វើការប្រៀបធៀបរវាងចំណុចដូចគ្នានិងចំណុចខុសគ្នាលើលក្ខណសម្បត្តិរបស់នារីទាំងពីរខាងលើឱ្យបានត្រឹមត្រូវ លុះត្រាតែយើងស្វែងយល់ន័យនៃពាក្យ "លក្ខណសម្បត្តិ" ជាមុនសិន ។ "លក្ខណសម្បត្តិ" គឺសំដៅទៅលើចរិតលក្ខណៈគ្រប់យ៉ាងរបស់តួអង្គ ឬរបស់មនុស្ស ដែលស្តែងចេញតាមរយៈសកម្មភាពគ្រប់យ៉ាងទាំងកាយវាចានិងចិត្ត ។ ដូចនេះតាមគំនិតប្រធានបានតម្រូវឱ្យយើងធ្វើការប្រៀបធៀបនូវភាពដូចគ្នានិងខុសគ្នានៃចរិតលក្ខណៈរបស់នាងសីតាជាមហេសីព្រះរាម ក្នុងរឿងរាមកេរ្តិ៍និងនាងមទ្រីជាមហេសីរបស់ព្រះវេស្សន្តរក្នុងរឿងមហាវេស្សន្តរជាតក ។

ប្រសិនបើគេលើកយកលក្ខណសម្បត្តិ របស់តួអង្គទាំងពីរនេះមកសិក្សាប្រាកដជាឃើញថាទាំងនាងសីតានិងនាងមទ្រីសុទ្ធតែមានរូបសម្បត្តិស្រស់ស្អាតដូចគ្នា ។ ដោយហេតុថា នាងសីតាក្នុងឱកាស ដែលក្រុងរាពណ៍បានដល់អាស្រមនាង រួចក៏ពោលអួតសរសើរថា ទាល់តែគេមានអណ្តាតរាប់សែននិងភ្នែករាប់លាន ទើបអាចអួតសរសើរនិងគយគន់សម្ផស្សរបស់នាងអស់ ។ រីឯនាងមទ្រីក៏ជានារីឯកព្រោះនាងជាតួអង្គកន្សែសារពេជ្ញ ដែលពោរពេញទៅដោយសម្ផស្ស គឺនាងជាដៃគូជាមួយនឹងពោធិសត្វតាមបែបពុទ្ធនិយម ។ ក្រៅពីនេះទៀត នារីទាំងពីរជានារីពោរពេញទៅដោយភាពស្មោះចំពោះស្វាមីរបស់ព្រះនាងដូចៗគ្នា គឺក្នុងពេលដែលក្រុងរាពណ៍ ចាប់យកនាងទៅលង្កាក៏នាងសីតានៅតែរក្សាភាពបរិសុទ្ធចំពោះព្រះរាមដែរ ។ ទន្ទឹមនឹងនេះ នៅពេលដែលព្រះរាមយាងចេញពីនគរសាងផ្នួសក្នុងព្រៃដប់បួនឆ្នាំនាងសីតាស្ម័គ្រចិត្តយាងតាមព្រះអង្គ ដោយគ្មានក្តីបារម្ភឡើយ ។ ចំណែកនាងមទ្រីវិញក៏យ៉ាងដូច្នោះដែរ ពេលដែលព្រះវេស្សន្តរត្រូវពួកអ្នកស្រីពិរាស្ត្របំបរបង់ព្រះអង្គឱ្យចូលព្រៃគិរីវង្កត ក៏ព្រះនាងសុខចិត្តចាកចេញទៅរស់នៅក្នុងព្រៃតាមព្រះវេស្សន្តរ ទោះបីមានការហាមឃាត់ពីសំណាក់ ព្រះបាទស្រីសញ្ជ័យយ៉ាងណាក៏ដោយ ។

ម្យ៉ាងទៀតបើគេលើកយកលក្ខណសម្បត្តិរបស់តួអង្គទាំងពីរនេះ មកសិក្សាម្តងទៀតនឹងបានឃើញថា នារីទាំងពីរនៅមានចំណុចខុសគ្នាទៅលើលក្ខណសម្បត្តិនេះ។ ដោយហេតុថា នាងសីតាជានារីល្អឯក តាមបែបលទ្ធិព្រាហ្មណ៍និយម គឺត្រូវជួយបំពេញកាតព្វកិច្ចចំពោះអវតាររបស់ព្រះវិស្ណុ។ ក្រៅពីនេះទៀត ព្រះនាងត្រូវព្រះរាមសព្វព្រះទ័យធ្វើជាមហេសី ដោយសារការប្រឡងលើកធ្នូសិល្ប៍ឈ្នះអស់ទេវៈក្នុងឋានទាំងបី។ មិនតែប៉ុណ្ណោះ នាងសីតាពោរពេញទៅដោយឆន្ទៈស្មោះត្រង់ម៉ឺងម៉ាត់ក្លាហាននិងប្រកាន់ពាក្យសត្យ។ ថ្វីត្បិតតែនាងមានទឹកព្រះទ័យស្រឡាញ់ព្រះរាមពិតមែន តែនាងមិនខ្លាចញញើតនឹងការភៀសព្រះកាយចាកចេញពីព្រះរាម តាមពាក្យសន្យានោះឡើយ គឺទីបំផុតព្រះនាងនិងព្រះរាមត្រូវព្រាត់ប្រាសគ្នាជារៀងរហូត។

រីឯនាងមទ្រីវិញ នាងមានលក្ខណសម្បត្តិខុសពីនាងសីតា ស្ថិតនៅត្រង់នាងជានារីស្រស់ស្អាតតាមបែបលទ្ធិពុទ្ធនិយម គឺជាកន្សែសារពេជ្រ។ នាងក៏ជានារីស្លូតបូតនិងទន់ភ្លន់ជាទីបំផុតក្នុងការដោះស្រាយបញ្ហាចំពោះមុខ។ នាងតែងតែមានទឹកព្រះទ័យមេត្តាគោរពតាមព្រះរាជបំណងព្រះស្វាមីជានិច្ច ទោះជាធ្វើបុត្តបរិច្ចាគ ឬភរិយាបរិច្ចាគក្តី។ ទោះបីដឹងថា ព្រះស្វាមីធ្វើបុត្តបរិច្ចាគឱ្យទៅជូជកយ៉ាងណាក្តី ឬទោះបីព្រះវេស្សន្តរធ្វើភរិយាបរិច្ចាគក្តី ក៏ព្រះនាងនៅតែទទួលអនុមោទនា ដោយក្តីរីករាយពីព្រះវេស្សន្តរជានិច្ច។ បានសេចក្តីថា ព្រះនាងតែងតែពេញព្រះទ័យ ចំពោះការធ្វើទានបារមី នៃព្រះវេស្សន្តរជានិច្ច គឺជាព្រះទ័យក្នុងការជំរុញឆន្ទៈព្រះស្វាមីឱ្យព្យាយាមធ្វើឱ្យបានសម្រេចគោលដៅនៃការត្រាស់ដឹង។ ជាមួយគ្នានេះដែរ នាងមទ្រីខុសពីនាងសីតាត្រង់ថា តាំងពីដើមដល់ចប់នាងមទ្រីតស៊ូទ្រាំទ្រការលំបាក តាមបម្រើព្រះវេស្សន្តរ នៅក្នុងព្រៃជារៀងរហូត ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សាជាលីនិងក្រឹស្នាយ៉ាងល្អប្រពៃទៀតផង។ ចំណែកឯនាងសីតាបានចាកចោលព្រះរាមនិងបុត្ររបស់ខ្លួន។

សរុបសេចក្តីមក ភស្តុតាងខាងលើនេះ សុទ្ធសឹងជាចំណុចដូចគ្នានិងខុសគ្នា រវាងលក្ខណសម្បត្តិរបស់តួអង្គនាងសីតាក្នុងរឿង រាមកេរ្តិ៍និងនាងមទ្រីក្នុងរឿង មហាវេស្សន្តរជាតក។ តួអង្គទាំងពីរនេះសុទ្ធសឹងជាតួអង្គតំណាងឱ្យនារីខ្មែរគ្រប់រូប ដែលតែងមានភក្តីភាពចំពោះស្វាមីស្លូតបូតសុភាពរាបសាម៉ឺងម៉ាត់ ព្រមទាំងម៉ត់ចត់។ ដោយសារតែនារីទាំងពីរនេះ មានលក្ខណសម្បត្តិបែបនេះហើយទើបធ្វើឱ្យពួកគេឈានដល់កិត្តិយសមួយ យ៉ាងឧត្តុង្គឧត្តមបំផុត។

តាមរយៈការប្រៀបធៀបនេះ យើងបានឃើញថា ទាំងនាងសីតា ទាំងនាងមទ្រីសុទ្ធតែមានលក្ខណសម្បត្តិល្អប្រសើរដូចៗគ្នា ពីព្រោះរាល់ឥរិយាបថរបស់នារីទាំងពីរ គឺជាឥរិយាបថពោរពេញទៅដោយទឹកចិត្តស្រឡាញ់គ្រួសារធ្វើឱ្យគ្រួសារមានកិត្តិយសជានិច្ច។ ព្រមជាមួយនឹងលក្ខណសម្បត្តិខាងលើនេះ ក៏យើងបានមើលឃើញកាន់តែច្បាស់អំពីតម្លៃស្ត្រីខ្មែរ ដែលស៊ូទ្រាំការលំបាកគ្រប់យ៉ាងដើម្បីគ្រួសារក៏ដូចជាសង្គមជាតិ ដើម្បីសុភមង្គលនិងសន្តិភាព។

## សំណួរ

១. ដូចម្ដេចដែលហៅថា សំណេរប្រៀបធៀប ? តើសំណេរប្រៀបធៀបមានប៉ុន្មានផ្នែក ?

២. តើក្នុងតួសេចក្ដីត្រូវមានសេចក្ដីពន្យល់និងអំណះអំណាងដូចម្ដេចដែរ ?

៣. តាមរយៈតែងសេចក្ដីគំរូខាងលើនេះ ចូរអ្នកបង្ហាញគម្រោងតែងមួយឱ្យបានសមស្រប ។

## លំហាត់

ចូរអ្នកធ្វើសំណេរតែងសេចក្ដីប្រៀបធៀបប្រធានខាងក្រោមតាមគំរូតែងសេចក្ដីខាងលើ ហើយអនុវត្តតាមគម្រោងដែលអ្នករកឃើញ ។

១. ប្រៀបធៀបលក្ខណៈនៃការគោរពបូជារបស់តួអង្គព្រះវិស្ណុនិងតួអង្គព្រះពុទ្ធ ។

២. ប្រៀបធៀបតួអង្គនាងទាវក្នុងរឿង ទុំទាវនិងតួអង្គនាងវិធាវីក្នុងរឿងផ្កាស្រពោន ។

៣. ប្រៀបធៀបលក្ខណសម្បត្តិនៃតួអង្គព្រះរាមក្នុងរឿងបែបព្រាហ្មណ៍និយមនិងតួអង្គព្រះវេស្សន្តរក្នុងរឿងបែបពុទ្ធនិយម ។

ដើម្បីជំរុញឱ្យសំណេរតែងសេចក្ដីប្រៀបធៀបរបស់អ្នកកាន់តែល្អប្រសើរថែមទៀត អ្នកគប្បីអនុវត្តតាមគម្រោងខាងក្រោម ៖

### ១ . ផ្ដើមសេចក្ដី

- លំនាំបញ្ហា : និយាយឱ្យទាក់ទងនឹងគំនិតប្រធានបទ ។
- ចំណូលបញ្ហា : បង្ហាញបញ្ហាប្រធានបទ ។
- ចំណោទបញ្ហា : បំផុសសំណួរតាមបែបប្រធានប្រៀបធៀប (តើ ...មានលក្ខណៈដូចគ្នា ឬខុសគ្នាយ៉ាងណាខ្លះ) ?

### ២ . តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី
- ពន្យល់ពាក្យ
- ពន្យល់ន័យប្រធាន
- បកស្រាយ

ក. បង្ហាញលក្ខណៈដូចគ្នា (និយាយរួមគ្នា)

- គំនិតសំខាន់ទី ១ (មានឧទាហរណ៍) ។
- គំនិតសំខាន់ទី ២ (មានឧទាហរណ៍) ។
- គំនិតសំខាន់ទី ៣ (មានឧទាហរណ៍) ។

ខ. បង្ហាញលក្ខណៈខុសគ្នា (និយាយដោយឡែក )

- បញ្ហាទី ១
  - គំនិតសំខាន់ទី ១ (មានឧទាហរណ៍) ។
  - គំនិតសំខាន់ទី ២ (មានឧទាហរណ៍) ។
  - គំនិតសំខាន់ទី ៣ (មានឧទាហរណ៍) ។
  - ...................................... ។
- បញ្ហាទី ២
  - គំនិតសំខាន់ទី ១ (មានឧទាហរណ៍) ។
  - គំនិតសំខាន់ទី ២ (មានឧទាហរណ៍) ។
  - គំនិតសំខាន់ទី ៣ (មានឧទាហរណ៍) ។
  - ...................................... ។
- **សរុប** : និយាយសរុបខ្លីអំពីលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នាលើបញ្ហា ទស្សនៈ មតិ ... ។

## ៣ . បញ្ចប់សេចក្តី

- សន្និដ្ឋាន : ឱ្យតម្លៃទៅលើប្រធានបទ (មួយណាមានតម្លៃជាងមួយណា ឬមានតម្លៃដូចគ្នា) ដោយបញ្ជាក់ពីហេតុផលនៃការឱ្យតម្លៃនោះផង ។
- មតិផ្ទាល់ខ្លួន : ជាទស្សនៈរបស់អ្នកធ្វើតែងសេចក្តីប្រៀបធៀប ថាតើគំនិតប្រធានបានផ្តល់គុណប្រយោជន៍ ឬផ្តល់បទពិសោធក្នុងការអប់រំដល់គ្រួសារ សហគមន៍ សង្គម ។

ការប្រៀបធៀបតួអង្គត្រូវបានបង្ហាញឱ្យឃើញ ៖

## ក. លក្ខណៈដូចគ្នា

លក្ខណសម្បត្តិខាងក្រៅ ៖

- រូបសម្បត្តិខាងក្រៅ
- សកម្មភាព
- ឥរិយាបថ
- អាកប្បកិរិយា

លក្ខណសម្បត្តិខាងក្នុង ៖

- ចិត្តគំនិត
- ឧត្តមគតិ
- ឧត្តមប្រយោជន៍

## ខ. លក្ខណៈខុសគ្នា

លក្ខណសម្បត្តិខាងក្រៅ ៖

- រូបសម្បត្តិខាងក្រៅ
- សកម្មភាព
- ឥរិយាបថ
- អាកប្បកិរិយា

លក្ខណសម្បត្តិខាងក្នុង ៖

- ចិត្តគំនិត
- ឧត្តមគតិ
- ឧត្តមប្រយោជន៍ ។

មេរៀនទី ៧

# អក្សរសាស្ត្រនិងអក្សរសិល្ប៍ខ្មែរ



ប្រវត្តិសាស្ត្របានបង្ហាញថាខ្មែរយើងមានវប្បធម៌អរិយធម៌រុងរឿងល្បីល្បាញពេញពិភពលោក ។ បុព្វបុរសជាតិយើងបានបន្សល់ទុកកេរដំណែលជាច្រើនរហូតដល់សព្វថ្ងៃដូចជា អក្សរសាស្ត្រ អក្សរសិល្ប៍ សិលាចារឹក ចម្លាក់ រូបបដិមា ប្រព័ន្ធធារាសាស្ត្រ ប្រាសាទបុរាណនានា ពិសេសគឺ ប្រាសាទអង្គរវត្ត ។ អក្សរសាស្ត្រ អក្សរសិល្ប៍ជាមរតកដ៏សំខាន់មួយដែលបានបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយរហូតដល់បច្ចុប្បន្ន ។ នេះជាមោទនភាពរបស់ជាតិយើង ។ ខ្មែរគ្រប់រូបត្រូវមានស្មារតីស្នេហាជាតិ ថែរក្សាការពារលើកតម្កើងវប្បធម៌ អរិយធម៌ជាតិឱ្យបានស្ថិតស្ថេរគង់វង្សនិងធ្វើឱ្យមានការអភិវឌ្ឍ ។

ក្នុងមេរៀននេះអ្នកនឹងបានសិក្សាពីកេរដំណែលអក្សរសាស្ត្រមួយចំនួនរបស់ខ្មែរហើយទន្ទឹមនឹងនោះ អ្នកនឹងបានសិក្សាផងដែរអំពីការបញ្ចុះបញ្ចូល ការអូសទាញ និយមន័យអក្សរសាស្ត្រ សង្គម បរិយាកាស កាលកំណត់តែង អ្នកនិពន្ធ និងខ្លឹមសារអត្ថបទ ។

# អក្សរសិល្ប៍ខ្មែរ





## ក. សិក្សាពាក្យគន្លឹះ

- ជាតិ (ន) : កំណើត, មនុស្សដែលមានសញ្ជាតិផ្សេងគ្នា ។
- ទស្សនៈ (ន) : ដំណើរឃើញ ការយល់ឃើញ ។
- ព្រហ្មញ្ញ (ន) : អ្វីដែលជាប់ទាក់ទងដោយព្រហ្មឬដែលជារបស់ពួកព្រាហ្មណ៍ ។
- មហិទ្ធិឫទ្ធិ (ន) : អំណាចធំ មានអំណាចក្រៃលែង ។
- មោក្ខៈ (ន) : ការរំដោះ ការរួចផុត ព្រះនិព្វាន ។
- វដ្តសង្សារ (ន) : ដំណើរអន្ទោលវិលកើតវិលស្លាប់ ។
- វណ្ណៈ (ន) : ពូជពង្ស ពណ៌សម្បុរ ។
- វិវត្តន៍ (ន) : ការប្រែប្រួល ។
- វីរជន (ន) : ជនក្លាហាន អង់អាច មោះមុត ។
- សង្គម (ន) : ការប្រជុំគ្នា ការប្រមូលរួបរួមផ្តុំមនុស្ស ។
- សច្ចៈ (ន) : សេចក្តីពិត ដំណើរទៀងត្រង់ ។

- សន្និបាត (ន) : ការប្រជុំ ការជួបជុំគ្នា ។
- សមាធិ (ន) : ដំណើរតាំងស៊ប់មាំនៃចិត្ត ។
- សម្ពោធ (ន) : ការថ្លែងសេចក្ដីរៀបរាប់ឬរាយការណ៍ក្នុងទីប្រជុំឆ្លងមន្ទីរថ្មីជាដើម ។
- សិក្ខាសិលា (ន) : ការប្រជុំរៀនសូត្រ ។
- សុខៈ (ន) : សេចក្ដីសុខស្រួល ។
- សោភ័ណ (គុ) : ល្អ ហ្មតហ្មង ប្រសើរ ។
- អក្សរសិល្ប៍ (ន) : គឺជាស្នាមគំនូសដែលតុបតែងឡើងប្រកបដោយសិល្ប៍ ។
- អច្ឆរិយៈ (គុ) : ដែលអស្ចារ្យ ដែលគួរឱ្យស្ញើចពេកក្រៃ ។
- អត្ថាធិប្បាយ (ន) : សេចក្ដីពន្យល់ សេចក្ដីបកស្រាយ ។
- អាត្ម័ន (ន) : ព្រលឹង ។
- អាណានិគម (ន) : រដ្ឋដែលតាំងនៅក្នុងអំណាចបរទេស ។
- អាណាព្យាបាល (ន) : អ្នកគ្រប់គ្រងរក្សាឬការគ្រប់គ្រងរក្សា ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ ចូរអ្នកយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងនិយមន័យ អក្សរសិល្ប៍ ប្រភេទអក្សរសិល្ប៍ និងលក្ខណៈអក្សរសិល្ប៍ ។

## គ. អត្ថបទ

អក្សរសិល្ប៍ ជាប្រភេទរឿងដែលតុបតែងឡើងប្រកបដោយសិល្ប៍ ពោលគឺបំណិនប្រសប់ក្នុងការតែងរបស់អ្នកនិពន្ធ ដែលឱ្យអ្នកអានឬអ្នកស្ដាប់ចូលចិត្តចាប់អារម្មណ៍រំភើបញាប់ញ័រទៅតាមបញ្ហារបស់រឿង ។ អក្សរសិល្ប៍ មានវត្ថុបំណងស្វែងរកសោភ័ណ សច្ចៈ និងសុខៈ ។ ចំពោះសុខៈនេះមានទស្សនៈប្លែកៗគ្នាដូចជា ទស្សនៈទីមួយបានឱ្យឃើញថា ដើម្បីសម្រេចសុខៈបាន មនុស្សត្រូវគោរពបន់ស្រន់អាទិទេពធ្វើសមាធិបំពេញមោក្សៈ (ការរំដោះ) ដើម្បីផ្ដាច់អាត្ម័នចេញពីវដ្ដសង្សារ ឱ្យវិលទៅជួបព្រហ្ម័ន ។ ចំណែកទស្សនៈទីពីរក៏បានបញ្ជាក់ថា ដើម្បីសម្រេចសុខៈបាន មនុស្សត្រូវប្រមូលទ្រព្យសម្បត្តិឱ្យបានច្រើនដោយគ្រប់វិធី ទោះបីសង្គមជាតិត្រូវធ្លាក់ដល់ណាក៏ដោយ ។ រីឯមតិទីបីបង្ហាញដែរថា សុខៈពុំស្ថិតនៅលើការបន់ស្រន់ គោរពអាទិទេព ឬការប្រមូលទ្រព្យសម្បត្តិឱ្យបានច្រើននោះទេ គឺសុខៈសំដៅលើការអភិវឌ្ឍនៃសង្គមនោះឯង ។ ដូច្នេះអក្សរសិល្ប៍ដែលបណ្ដុះការងារនិយមអភិវឌ្ឍសង្គម ហៅថាអក្សរសិល្ប៍មានបំណងស្វែងរក "សុខៈ" សម្រាប់សង្គមមនុស្ស ។

បើតាមបញ្ញើកបុរាណ អក្សរសិល្ប៍ខ្មែរចែកជាប្រាំប្រភេទធំៗ ដែលទីមួយមានសន្ទស្សន៍អក្សរសិល្ប៍។ សន្ទស្សន៍អក្សរសិល្ប៍ គឺស្នាដៃសរសេរសម្រាប់ប្រាប់បង្ហាញរៀបរាប់ ដូចជាពណ៌នាកថា រៀបរាប់ពីមនុស្ស សត្វ វត្ថុ។ល។ វណ្ណនាកថា ជាការរៀបរាប់ពីការធ្វើបុណ្យ ការធ្វើដំណើរអំពីខ្យល់ព្យុះ ភ្លើងឆេះផ្ទះ។ល។ និទានកថា បានរៀបរាប់ពីអនុស្សាវរីយ៍ ការផ្សងព្រេង ការប្រយុទ្ធជាដើម។ ក្រៅពីនេះទៀត មានសារកថាជាអត្ថបទមានលក្ខណៈជាសំបុត្រឆ្លងឆ្លើយក្នុងគ្រួសាររវាងមិត្តភក្តិក្នុងបំណងលាតត្រដាងពីបញ្ហាអ្វីមួយ។

ចំណែកផ្នែកទីពីរ ជាប្រលោមអក្សរសិល្ប៍ គឺជាស្នាដៃដែលតែងអំពីវិបត្តិទំនាស់របស់មនុស្ស ដោយប្រើវិធីប្រលោមធ្វើឱ្យអណ្តែតអណ្តូង ភ័យតក់ស្លុត ញាប់ញ័រ រំភើបខុសធម្មតា។ ក្នុងស្នាដៃប្រភេទនេះ មានដូចជាព្រេងកថា អ្នកនិពន្ធប្រឌិតចងក្រងដោយយករឿងរ៉ាវផ្សេងៗដូចជា រឿងឈ្លោះប្រកែកគ្នា រឿងច្រណែនប្រចណ្ឌជាដើម ដើម្បីមកលើកជាសេចក្តីតំណាលទូន្មានប្រាប់អនុជន។ វីរកថាជារឿងមួយបែបដែលបង្ហាញតួឯកជាវីរជន ដែលមានចិត្តតស៊ូអង់អាចក្លាហាន ក្នុងនោះមានរឿងរាមកេរ្តិ៍ជាដើម។ នវកថាគេច្រើនតែតែងរឿងដែលមានក្នុងព្រឹត្តិការណ៍ថ្មីៗមាននៅក្នុងជីវភាពសង្គមនាពេលបច្ចុប្បន្ន ដូចជាបញ្ហាកសាងជាតិសាមគ្គីភាព។ល។

ចំណែកចំណុចទីបី គឺជានាដកអក្សរសិល្ប៍ ជាស្នាដៃដែលតែងសម្រាប់យកទៅលេងល្ខោន។ ឧទាហរណ៍នាដ្យកថា ជាអត្ថបទល្ខោនដែលលើកយករឿងវិបត្តិទំនាស់របស់មនុស្សក្នុងសង្គមនាសម័យណាមួយធ្វើជាប្រធានរឿង។ ហាសកថាក៏ជាអត្ថបទរឿងល្ខោន ដែលប្រកបដោយសកម្មភាពនិងដំណើររីករាយ សប្បាយដោយកំប្លុកបំប្លែងធ្វើឱ្យសើច។ ចំពោះទារុណកថាវិញ ជារឿងល្ខោនដែលមានសកម្មភាព ដំណើររឿងរីកវរកម្សត់ធ្វើឱ្យអ្នកអាន អ្នកទស្សនាញាប់ញ័រ រន្ធត់ចិត្តអាណិតអាសូរតួអង្គទន់ខ្សោយ ដែលត្រូវតួអង្គខ្លាំងធ្វើបាប។

ទីបួនហៅថា ឧបទេសអក្សរសិល្ប៍ជាអត្ថបទបែបច្បាប់ទូន្មានសម្រាប់អប់រំប្រដៅណែនាំជាមួយនោះមានសុភាសិតកថា ជាកម្រងពាក្យពេចន៍ ចងក្រងឡើងសម្រាប់និយាយអប់រំក្រើនរំឭកចំពោះប្រជាជនដោយប្រើវិធីធ្វើឱ្យចេះពិចារណាត្រិះរិះគិត។ ដូចជា "ចេះមកពីរៀន មានមកពីរក" ឬ "លួចគេបានវាគ្រាន់ ម្ចាស់គេទាន់វាក្រែល"។ ស្របជាមួយនឹងការទូន្មាននេះ ក៏មានច្បាប់អប់រំណែនាំប្រជាជនឱ្យដើរផ្លូវល្អ ផ្លូវត្រូវវិញ ដូចជាច្បាប់ក្រម។ ដោយឡែកក្នុងល្បើកកថា អ្នកនិពន្ធច្រើនយកតួអង្គជាសត្វ រុក្ខជាតិមកដើរតួតំណាងឱ្យមនុស្ស។ ឧទាហរណ៍ រឿងរៃនិងស្រមោច រឿងកូនចៀមនិង

ផ្ដែចចក ។ល ។ មួយវិញទៀតចំពោះសុន្ទរកថា ជាអត្ថបទសម្រាប់ថ្លែងអំពីវិធីអ្វីមួយដូចជាពិធីសម្ពោធ ពិធីបញ្ចប់ការងារ សន្និបាត សិក្ខាសិលា ។ល ។

ជាមួយនោះដែរ ចំណុចចុងក្រោយនៃអក្សរសិល្ប៍គឺទិដ្ឋិអក្សរសិល្ប៍ជាស្នាដៃបែបអត្ថាធិប្បាយឬការបញ្ចេញមតិយោបល់របស់អ្នកនិពន្ធ អ្នករិះគន់អក្សរសិល្ប៍ ដូចជាអត្ថាធិប្បាយកថា គឺអត្ថាធិប្បាយអំពីពាក្យសុភាសិតនានា អំពីគំនិតផ្សេងៗរបស់អ្នកប្រាជ្ញ អ្នកនិពន្ធ ។ល ។ ឯសិក្សាកថាវិញ គឺជាអត្ថបទដែលលើកយកជីវប្រវត្តិស្នាដៃនានានិងគំនិតរបស់អ្នកនិពន្ធ កវី ទស្សនវិទូក្នុងសម័យណាមួយយកមកសិក្សា ។ អក្សរសិល្ប៍កថា គឺអត្ថបទដកស្រង់ចេញពីរឿងដែលជាស្នាដៃរបស់អ្នកនិពន្ធនាសម័យណាមួយ ។ ជួនកាលអក្សរសិល្ប៍កថានេះ ក៏មានសភាពជាអត្ថបទតាក់តែងខ្លីល្មម អំពីបញ្ហាអ្វីមួយសម្រាប់ធ្វើជាអត្ថបទអំណានឬធ្វើជាអត្ថបទសរសេរតាមអានជាដើម ។

តាមរយៈអក្សរសិល្ប៍ គេអាចដឹងការរស់នៅរបស់មនុស្សក្នុងសម័យនីមួយៗ ព្រោះអក្សរសិល្ប៍តែងតែប្រែប្រួលទៅតាមដំណើរវិវត្តរបស់សង្គមមនុស្សជាដរាប ។ អក្សរសិល្ប៍ខ្មែរយើងមានការវិវត្តទៅតាមសម័យកាលធំៗនៃប្រវត្តិសាស្ត្ររបស់ប្រទេសខ្មែរ ។ នៅសម័យអង្គរ គេបានដឹងច្បាស់ថាមហិទ្ធិឫទ្ធិខ្មែរបានឡើងដល់កម្រិតកំពូល រីឯអក្សរសិល្ប៍ក៏រីកចម្រើនខ្លាំងក្លាណាស់ដែរ ប៉ុន្តែចុះថយទៅវិញនៅពេលដែលស្រុកខ្មែរត្រូវឈ្លានពានពីប្រទេសជិតខាង ។ លុះមកដល់សតវត្សទី ១៨និង១៩ ស្នាដៃអក្សរសិល្ប៍ក៏ស្ទុះងើបឡើងវិញ ប៉ុន្តែត្រូវថយឥទ្ធិពលម្ដងទៀតនៅពេលដែលប្រទេសខ្មែរធ្លាក់នៅក្រោមអាណាព្យាបាលបារាំង (១៨៦៣-១៩៥៣) រួចទើបលូតលាស់ឡើងជាថ្មីនាសម័យឯករាជ្យ (១៩៥៣) ។

ជាទូទៅយើងអាចសង្កេតឃើញថា អក្សរសិល្ប៍មានចរិតនិងលក្ខណៈច្រើនយ៉ាង ក្នុងនោះមានលក្ខណៈមនុស្ស ។ អក្សរសិល្ប៍ដែលគេចាត់ទុកថា មានលក្ខណៈមនុស្ស លុះណាតែអក្សរសិល្ប៍នោះបានលើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយ ដោយបង្កើតបញ្ហាមួយហៅថា បញ្ហាមនុស្ស ។ ទោះបីអ្នកនិពន្ធលើកយកតួអង្គប្រភេទណាក៏ដោយ ទោះជាតួអង្គអច្ឆរិយៈក្ដី សត្វក្ដី ធម្មជាតិក្ដី ក៏តួអង្គទាំងនោះសុទ្ធតែតំណាងមនុស្សនៅក្នុងសង្គមជាដរាប ។ ឧទាហរណ៍ ទន្សាយតំណាងមនុស្សមានប្រាជ្ញា ស្រឡាញ់យុត្តិធម៌ ខ្លា ក្រពើតំណាងមនុស្សកាចសាហាវឬព្រះរាមតំណាងមនុស្សអត្តទត្តនិយមជាដើម ។

មួយវិញទៀត អក្សរសិល្ប៍គេអាចចាត់ទុកថា មានលក្ខណៈសង្គមលុះត្រាតែបានលើកយកបញ្ហាសង្គមមនុស្សក្នុងសម័យកាលណាមួយមកបង្ហាញចោទនិងដោះស្រាយទៅតាមការវិវត្តចម្រើនក្តី ធម្មតាក្តី ឬថយក្រោយក្តី។ មតិយោបល់ សកម្មភាពដែលតួអង្គនីមួយៗបានបំពេញសុទ្ធតែតំណាងមនុស្សភាគច្រើន ពោលគឺតំណាងសង្គមមនុស្សនេះឯង។ ឧទាហរណ៍ ម្តាយទាវ តំណាងអ្នកម្តាយភាគច្រើននៅសម័យនោះ(នំមិនធំជាងនាឡិ) អរជូន តំណាងភាគច្រើននៃនាហ្មឺននាសម័យនោះ(ផ្តាច់ការ)។

លក្ខណៈប្រវត្តិនៃអក្សរសិល្ប៍ គឺតែងមានទំនាក់ទំនងទៅនឹងសម័យកាលណាមួយនៃប្រវត្តិសាស្ត្រ តែពុំមែនជាប្រវត្តិសាស្ត្រទេ។ ដូចជារឿងទុំទាវ(តាមប្រវត្តិកើតនៅសម័យលង្វែក)។ រីឯរឿងភូមិតិរច្ឆាន(តាមប្រវត្តិកើតនៅសម័យអាណានិគមបារាំង)ជាដើម។ អក្សរសិល្ប៍បានលើកយកតែដំណើររឿងទាក់ទងទៅនឹងសម័យកាលខ្លះនិងព្រឹត្តិការណ៍ផ្សេងៗខ្លះដែលមាននៅក្នុងប្រវត្តិសាស្ត្រ។

លក្ខណៈវណ្ណៈនៃអក្សរសិល្ប៍ គឺសំដៅទៅលើណាមួយដែលបង្កើតអក្សរសិល្ប៍វណ្ណៈនោះតែងតែការពារឧត្តមគតិ ចរិត គោលបំណងខ្លួនជានិច្ច។ យ៉ាងណាមិញនៅក្នុងរឿង "ជ័យមេរត" សរសេរឡើងដោយពួកស្រទាប់លើបានបង្ហាញថា ពួកស្រទាប់ក្រោមគ្មានប្រាជ្ញាអ្វីបន្តិចសោះ។ រឿង "ធនញ្ជ័យ" សរសេរឡើងដោយបញ្ញាជន តំណាងស្រទាប់ក្រោម គឺសម្រាប់ប្រយុទ្ធប្រឆាំងនឹងពួកស្រទាប់លើទៅវិញ។

អក្សរសិល្ប៍ដែលគេទទួលស្គាល់ថាមានលក្ខណៈជាតិ លុះណាតែមានតម្លៃសំខាន់ទ្រទ្រង់សីលធម៌ ជំនឿ ទំនៀមទម្លាប់ សាសនានិងអ្វីៗដែលជារបស់ជាតិ។ ដូចជារឿងទុំទាវ បានបង្ហាញឱ្យឃើញពីវប្បធម៌ ប្រពៃណីរបស់ជាតិខ្មែរដែលមានតាំងពីយូរយារណាស់មកហើយ។

អក្សរសិល្ប៍ដែលមានលក្ខណៈជាតិផ្ទាល់ខ្លួនរួចហើយ បន្ទាប់មកប្រទេសដទៃទៀតទទួលស្គាល់ថាជាអត្ថបទល្អដែរ ហើយបានយកទៅសិក្សាផ្សាយជាទូទៅ។ អក្សរសិល្ប៍នោះមានលក្ខណៈអន្តរជាតិ។

មិនតែប៉ុណ្ណោះ ចំពោះចលនាអក្សរសិល្ប៍វិញ គឺសំដៅយកដំណើរប្រែប្រួលនៃអក្សរសិល្ប៍តាមការនិយមនៃវណ្ណៈឬស្រទាប់សង្គមលើទ្រឹស្តី ទស្សនៈ គោលគំនិតណាមួយក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រ។ គេអាចចែកចលនាអក្សរសិល្ប៍ខ្មែរជាបួនប្រភេទ ទីមួយមានអក្សរសិល្ប៍ព្រាហ្មណ៍និយម (ឬហិនណ្ឌូនិយម)ទីពីរ ជាអក្សរសិល្ប៍ពុទ្ធនិយម ទីបី ជាអក្សរសិល្ប៍ខ្មែរនិយម(ឬខេមរនិយម) ហើយទីបួនជាអក្សរសិល្ប៍បរទេសនិយម។ អក្សរសិល្ប៍មិនគ្រាន់តែជាកញ្ចក់សម្រាប់ឆ្លុះមើលការរស់

នៅសង្គមមនុស្ស ក្នុងសម័យកាលនីមួយៗប៉ុណ្ណោះទេ តែវាជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់អប់រំ ផ្សព្វផ្សាយអរិយធម៌ វប្បធម៌ជាតិ ។ ដូចនេះ អ្នកនិពន្ធដែលមានតួនាទីជាអ្នកផ្សាយអរិយធម៌ វប្បធម៌ គប្បីជ្រើសរើសយកគំនិតទស្សនៈយោបល់ល្អៗ ហើយសំខាន់ៗទៅតាក់តែងអត្ថបទរបស់ខ្លួនឱ្យបានជាទីគាប់ចិត្ត ចាប់អារម្មណ៍ និងជាគុណប្រយោជន៍ដល់អ្នកអានថែមទៀត ។ ចំណែកអ្នកអានវិញមិនមែនអានដើម្បីកំសាន្តកែអផ្សុកប៉ុណ្ណោះទេ គេត្រូវចេះពិចារណា ចេះទាញយកគំនិតល្អៗទុកជាមេរៀន ទុកជាបទពិសោធ ទុកជាចំណេះដឹងរបស់ខ្លួនទៀតផង ។

*(ដកស្រង់និងកែសម្រួលពីសៀវភៅ អរិយធម៌ខ្មែរ*

*របស់លោកសូ មុយឃៀង លោកទិត សៀង លោកជា ឈិន គ.ស.២០០៥)*

## សំណួរ

១. ដូចម្ដេចហៅថា អក្សរសិល្ប៍ ?

២. តើអ្វីជាវត្ថុបំណងរបស់អក្សរសិល្ប៍ ?

៣. តើមានទស្សនៈដូចម្ដេចខ្លះចំពោះ សុខៈ ? ហើយសុខៈក្នុងអក្សរសិល្ប៍មានទំនាក់ទំនងយ៉ាងណាខ្លះចំពោះសង្គម ? ចូររកឧទាហរណ៍មកបញ្ជាក់ ។

៤. តើអក្សរសិល្ប៍មានប៉ុន្មានប្រភេទ ? អ្វីខ្លះ ? ចូរបកស្រាយទស្សនៈនីមួយៗដោយលើកឧទាហរណ៍មកបញ្ជាក់ ។

៥. តើប្រភេទអក្សរសិល្ប៍និងចលនាអក្សរសិល្ប៍មានលក្ខណៈខុសគ្នាយ៉ាងណាខ្លះ ? ចូររកអំណះអំណាងមកបញ្ជាក់ផង ។

៦. ហេតុដូចម្ដេចបានជាអ្នកនិពន្ធពោលថា "អក្សរសិល្ប៍មិនគ្រាន់តែជាកញ្ចក់សម្រាប់ឆ្លុះមើលការរស់នៅរបស់សង្គមមនុស្សក្នុងសម័យកាលនីមួយៗប៉ុណ្ណោះទេ តែវាជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់អប់រំ ផ្សព្វផ្សាយអរិយធម៌ វប្បធម៌ជាតិ" ? ចូរអ្នកពន្យល់ ។

៧. ចូរធ្វើការពណ៌នាអំពីលក្ខណៈអក្សរសិល្ប៍ដោយផ្សារភ្ជាប់ជាមួយឧទាហរណ៍ផង ។

៨. ក្រោយពីអ្នកបានសិក្សាអំណាននេះហើយ តើអ្នកមានគំនិតយ៉ាងណាខ្លះ ក្នុងការរួមចំណែកថែរក្សានិងការពារវប្បធម៌ជាតិរបស់អ្នកឱ្យសក្តិសមជាទំពាំងស្នងឫស្សី ?

៩. តាមការសិក្សា អក្សរសិល្ប៍គឺជាការសិក្សាពីមនុស្សនិងដើម្បីមនុស្ស ។ ចូរអ្នកពន្យល់ ។

## សិលាចារឹកបណ្ឌិតជ័យនន្ទ



### ក. សិក្សាពាក្យគន្លឹះ

- ភុជង្គ (ន) : ពស់ នាគ ។
- លីលា (ន) : ដំណើរ ។
- មោហោ (ន) : មិនស្គាល់ខុសត្រូវ សេចក្តីល្ងង់ សេចក្តីវង្វេង អវិជ្ជា ភ័ន្តស្មារតីមិនយល់ការពិត ។
- ព្យាធិ៍ (ន) : រោគ ជំងឺ ។
- ចតុរាបាយ (ន) : ភូមិ ភព ទីសម្រាប់សត្វដែលមានបាបបណ្តាលឱ្យឃើញស្តែងក្នុងកាលជិតស្លាប់ទៅចាប់កំណើតនៅរងទុក្ខមាន ៤យ៉ាង គឺនរក ប្រេត អសុរកាយ តិរច្ឆាន ។
- សាហាវ (ន) : កាច សាហាវ ព្រហើន រហ័សខឹង ច្រណែន ឫស្យា ។
- សរពេជ្ញ (ន) : អ្នកត្រាស់ដឹងសព្វ ។
- ភគវា (គុឬន) : ដែលមានជោគ មានបុណ្យ មានយស អ្នកប្រាជ្ញ ។
- វន្ទា (ន) : ថ្វាយបង្គំ សំពះ គំនាប់ ។
- ឧបជ្ឈាយ៍ (ន) : គ្រូបង្រៀនធម៌ គ្រូបង្រៀនច្បាប់ ។
- តិរ្ថិយ (ន) : មនុស្សជំពូកខ្លះដែលប្រព្រឹត្តកាន់សាសនាទីទៃពីព្រះពុទ្ធសាសនា ។

- អសុរ (ន) : គំនិតអាក្រក់ អមនុស្សមួយពួកទីទៃពីទេវតា ។
- កាសា (ន) : គជមនុស្ស គជដំរី ។
- ស្រីង្គារ (ន) : សេចក្ដីស្រឡាញ់ តម្រេក គ្រឿងប្រលោមចិត្ត ។ ស្រីស្រីង្គារ ស្រីដែលមានលំអគួរឱ្យកើតសេចក្ដីស្រឡាញ់ ។
- បរិពារ (ន) : អ្នកបម្រើ អ្នកហែហមជាកិត្តិយស អ្នកចោមរោមកំដរ ។
- អសង្ខេយ្យ (គុ) : ដែលច្រើនរាប់ពុំអស់ ។
- កប្ប (ន) : កាលដែលតាំងនៅយូរអង្វែង ។
- បទុមា (ន) : ផ្កាឈូក ។
- ភិប្រាយមកពី អភិប្រាយ (ន) : អធិប្បាយ សេចក្ដីរាយការណ៍ ការនិយាយរៀបរាប់ ។
- ម្នាច (ន) : អំណាច ។
- អសល (ន) : អសុរ មនុស្សមួយពួកទីទៃពីទេវតាដូចយក្ស ខ្មោច បិសាច... ។
- ល្បា (ន) : ការលា ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ ចូរអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងអ្នកនិពន្ធកាលកំណត់តែង សង្គមបរិយាកាស និងខ្លឹមសារអត្ថបទ ។

## គ. អត្ថបទ

### (បទភុជង្គលីលា)

| | | |
|---|---|---|
| នេះបទភុជង្គលីលា | លើកដោយកាព្យ | ជាល្បាទាំងឡាយ ។ |
| លាអស់លោភទោសសម្មាយ | លាភ័យអន្តរាយ | ព្រាត់ព្រាយប្រាស់គ្នា ។ |
| ខ្ញុំក្រាបទូលព្រះពុទ្ធា | ព្រះអើយខ្ញុំលា | ត្រង់ណាទុក្ខសោក ។ |
| ខ្ញុំលាត្រង់កំណើតថោក | កើតមកអស់លោក | សើចដៀលសន្តាន ។ |
| ខ្ញុំលាសព្វជាតិពៀរស្ថាន | ក្ដីអាស្រូវស្ថាន | កុំមានឡើយណា ។ |
| ខ្ញុំលាត្រង់ឥតប្រាជ្ញា | ឆ្លល់ខ្លៅមោហា | ខ្មាសគេអៀនប្រៀន ។ |
| ខ្ញុំលាត្រង់ឥតរបៀន | ចូលជំនុំស្ងៀម | ពុំចេះឆ្លើយថា ។ |
| ខ្ញុំលាពិសព្យាធិរោគា | ប្រាស់បុត្រភរិយា | ស្លាប់ឧបាសប្រាណ ។ |

ខ្ញុំលាវិបាកបូរាណ ជាទុក្ខក្នុងប្រាណ ស្រែកឃ្លាននោះផង ។
ខ្ញុំលាអស់បាបពៀរហោង ចតុរាបាយផង ប្អូនកុំទៅសោយ ។
ខ្ញុំលាត្រង់គំនិតឆ្លោយ លាខ្ជិលកុំសោយ ហើយស្មារតីតិច ។
ខ្ញុំលាពុំចេះកលកិច្ច សិល្បសាស្ត្រការស្រេច ពាក្យពេចន៍នោះណា ។
ខ្ញុំលាត្រង់ឥតប្រាជ្ញា ពុំចេះភាសា ស្រដីនឹងគេ ។
ខ្ញុំលាត្រង់ខ្សត់ខ្លួនទេ ត្រមោចឯកឯង ឥតព្រៀងនៅភ្ញា ។
ខ្ញុំលាឥតទ្រព្យភោគ្គា ទាសីទាសា ពុំមានដល់ម្នាក់ ។
ខ្ញុំលាត្រង់ចិត្តប្រត្យក្ស ស្រដីឱ្យអាក់ អន់អៀនចិត្តគេ ។
ខ្ញុំលាត្រង់ពាក្យស្រោប់ស្រែ ស្រដីដូចគេ មមើឆ្កួតណា ។ [...]
ខ្ញុំលាត្រង់ល្ងង់ភិប្រាយ ឆ្វល់ធុញរាយមាយ ជ្រងោឥតការណ៍ ។
ខ្ញុំលាស្មារតីសាធារណ៍ ស្រដីកិច្ចការ ពុំចាំនោះហោង ។
ខ្ញុំលាពំនោលសួរសង ស្រដីពាក្យឆ្គង ពុំត្រូវចិត្តគេ ។ [...]
ខ្ញុំលាត្រង់ក្ដីមោហា ប្រមាថមេបា គ្រូបាធ្យាយផង ។
ខ្ញុំលាត្រង់ក្ដីឆ្គាំឆ្គង ប្រមាថសង្ឃផង ព្រះពុទ្ធព្រះធម៌ ។
ខ្ញុំលាត្រង់ចិត្តសាហារ សាហាវអស្ចារ្យ បន្ទន់ក្របាន ។
ខ្ញុំលាមនុស្សណាបៀតប្រាណ ស្រដីបង្ខាន ញុះញង់ចែចូវ ។ [...]
ខ្ញុំលាសព្វៗជាតិផង កើតជាសែនដង លាត្រង់សត្រូវ ។
ខ្ញុំលាក្បាលទំពែកសក់ស្កូវ ជើងស្ពក់អាស្រូវ ធ្មេញបាក់ខ្វាក់ឃ្លង់ ។
ខ្ញុំលាវេរាស្រែងឃ្លង់ ដំបៅអស់អង្គ ជាទុក្ខឥតស្បើយ ។
ខ្ញុំលាកើតឡើងឥតត្រើយ រូបអាក្រក់ហើយ ក្លិនក្លាស់ឆ្អេះផង ។
ខ្ញុំលាអស់ទាំងនោះហោង សារពើឆ្គាំឆ្គង ហៅអកុសល ។ [...]
ខ្ញុំលាភរិយាអាក្រក់ នៅស្ថានឥតសុខ ជាទុក្ខឯងហោង ។
ខ្ញុំលាបើមានទ្រព្យផង អាក្រក់នោះហោង កុំត្រាយល់ឡើយ ។ [...]
ខ្ញុំលានេះជាបង្ហើយ បាបពៀរទុក្ខអើយ កុំមានឡើយណា ។
ខ្ញុំលាវេរភ័យវេរា កើតឡើងកាលណា ថ្ងៃល្អស្រេចផង ។
កើតសុខនឹងក្ដីបំណង លាត្រង់នោះហោង កុំកើតមកឡើយ ។

## (បទកាកគតិ)

បទដើមនេះក្តី ហៅកាកគតិ ដោយបាលីថា
លើកជាសំណូម ខ្ញុំសូមប្រាថ្នា សូមចិត្តសទ្ធា
កាត់អំណោយទាន ។

អញខ្ញុំនេះនៃ នាមដើមឈ្មោះជ័យ វៀរភ័យបុរាណ
សូមបានត្រាស់ស្រេច សរពេជ្ញតាញាណ សូមបាននិញ្វន
នាំអស់សត្វផង ។

ជាមុខច្រើនក្រៃ កើតជាអសង្ខៃយ្យ ឆ្នាំនៃកប្បហោង
ខ្ញុំសូមប្រាថ្នា សទ្ធាទានផង តាមដានគន្លង
ព្រះសិអារ្យមេត្រី ។

ទោះគេប្រាថ្នា សុំអស់អង្គា សាច់បញ្ចឥន្ទ្រិយ
ស្ងួតថ្លើមបេះដូង ពុងពោះឈាមថ្មី ភ្នែកឆ្អឹងខ្ញុំក្តី
ឱ្យទានគេហោង ។

ខ្ញុំសូមប្រាថ្នា ត្រេកអរសទ្ធា ចិន្តាស្មោះផង
ដូចព្រះជធរ ឱ្យទានប្រេតហោង ឆីសាច់ឈាមផង
អស់ឥតសំណល់ ។

ខ្ញុំសូមប្រាថ្នា ឱ្យទានកាលណា ទេវតាជួយយល់
សូមអស់ឥន្ទព្រហ្ម ជ្រោមជ្រែងពន្យល់ កើតកាលាហល់
ជួយបំពេញទាន ។ [...]

ខ្ញុំថ្វាយបទុមា សម្តេចភគវា ស្រោចស្រង់ប្រោសប្រាណ
ខ្ញុំកាន់បុប្ផា វន្ទាស្រេចបាន ឧបជ្ឈាយ៍បួសប្រាណ
សូត្រកម្មវាចហោង ។

ខ្ញុំបួសនេះនៃ សំណាក់ព្រះត្រ័យ សរណគមន៍ផង
ខ្ញុំសូមឱ្យដឹង កំណើតសត្វហោង តាមដោយគន្លង
នៃព្រះពុទ្ធត្រាស់ ។ [...]

ខ្ញុំសូមប្រាថ្នា ចេះឆ្លើយប្រស្នា ដោះស្រាយសាសង
ដូចព្រះនាគសេន ឆ្លើយប្រស្នាផង នៅក្រុងមលិន្ទហោង
ដោះឥតជំពាក់ ។ [...]

ខ្ញុំសូមអំណត់ ចិត្តល្អស្រគត់ ដូចព្រះតេមិយ
ព្រះវរបិតា ឱ្យល្បងឥតធ្មើ ព្រះអង្គអត់គេ
ឆទសឆ្នាំគត់ ។ [...]

ខ្ញុំសូមមានម្ចាច ឫទ្ធីអំណាច អានុភាពដោយចង
ខ្ញុំសូមសិល្ប៍ជប ឆុតដូចព្រះអង្គ ព្រះឥសូរស្តេចទ្រង់
ជបនាងភគវតី ។

សូមម្ចាចពន្លាយ ដូចកាលព្រះនារាយណ៍ ចុះចាកអំពី
សួគ៌មកកើតជា ព្រះរាមទេពីខ្មី ផ្ចាញ់អស់តិរ្ថិយ
អសុរលង្កា ។ [...]

ខ្ញុំសូមកម្លាំង អានុភាពចែងខ្លាំង សិល្បសាស្ត្រឆុតចាំ
ដូចហនុមាន បូរាណនាយនាំ កើតមកជាកម្លាំង
ព្រះរាមទេព ។ [...]

លែងជាតិនេះទៅ បើវិលមកនៅ កើតផ្ទៃស្តេចហោង
បានដូចថៅកែត មាលាហោះផ្សង ទៅសួគ៌នាយហោង
ជាកូនព្រះឥន្ទ្រ ។ [...]

ខ្ញុំសូមទ្រព្យធន មាសប្រាក់រ័ត្នតន់ កែវមណីជោតជ្រះ
ខៀនព្រៃកាសា ចៀមព្រាំពេញផ្ទះ ពូកពិតានមនះ
ដូចជោតិកសេដ្ឋី ។

ខ្ញុំសូមបរិពារ អស់ស្រីស្រិង្គារ ត្រកាលប្រិមប្រិយ
រូបល្អលើសលន់ ទន់ភ្លន់មានស្រី សម្បុរសខៀវខ្ចី
ដូចផ្កាស្លាកេត ។

*(ដកស្រង់និងកែសម្រួលពីទស្សនាវដ្ដីកម្ពុជសុរិយា ទំព័រ ៧៨៦ ដល់ ៧៩៣ ស្រាវជ្រាវដោយ ឌឹក គាម)*

## សំណួរ

១. តើអត្ថបទសិលាចារឹកនេះជាស្នាដៃរបស់អ្នកនិពន្ធណា ?

២. តើអត្ថបទនេះនិយាយអំពីអ្វី ?

៣. តើបណ្ឌិតជ័យនន្ទ :

- មានគោលបំណងអ្វីខ្លះទៅអនាគត ។
- ចូរលើកអំណះអំណាងមកបញ្ជាក់អំពីគោលបំណងនីមួយៗ ។
- ចូរអ្នកវិភាគចរិតលក្ខណៈរបស់តួអង្គក្នុងកំណាព្យខាងលើនេះ ។

៤. តើអត្ថបទនេះតាក់តែងនៅពេលណា ?

៥. ចូរធ្វើការសិក្សាពីសង្គមបរិយាកាសតាមរយៈអត្ថបទនេះ ។

៦. តើអត្ថបទនេះមានខ្លឹមសារដូចម្ដេច ?

៧. តើអត្ថបទនេះផ្ដល់បទពិសោធដូចម្ដេចខ្លះដល់អ្នក ?

៨. ចូរអ្នកបង្ហាញពីវប្បធម៌ជាតិដែលឆ្លុះបញ្ចាំងតាមរយៈសិលាចារឹកខាងលើនេះ ។

៩. ដោយអ្នកធ្លាប់បានស្គាល់សិលាចារឹកខ្មែររួចមកហើយ ចូរអ្នក :

- ប្រាប់ឈ្មោះសិលាចារឹកឱ្យបានចំនួនប្រាំ ។
- បញ្ជាក់ពីខ្លឹមសារចម្បងនៃសិលាចារឹកនីមួយៗនោះផង ។
- ប្រាប់ពីកាលបរិច្ឆេទនៃការនិពន្ធសិលាចារឹកនោះ ។

១០. ចូរអ្នកជ្រើសរើសអត្ថបទណាមួយដែលបញ្ជាក់ថាតួអង្គបានទទួលឥទ្ធិពលពីព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ។

## រំលឹកបញ្ញត្តិ

- កាលអាកាស គឺជាពេលវេលា និងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ ។ ពេលវេលានិងទីកន្លែងនៃរឿង ជួនកាលអ្នកនិពន្ធលើកឡើងតាមស្ថានភាពពិតជាក់ស្តែង ជួនប្រឌិតឡើងតាមមនោគតិរបស់ខ្លួន ។
- លក្ខណតថៈនៅក្នុងរឿង គឺជារឿងរ៉ាវ ហេតុការណ៍ ព្រឹត្តិការណ៍ ឈ្មោះ ទីកន្លែង សកម្មភាព ... ដែលមានពិតនៅក្នុងសង្គមជាក់ស្តែង ហើយត្រូវបានអ្នកនិពន្ធបញ្ចូល ឬផ្សារភ្ជាប់ទៅនឹងដំណើររឿងដោយរួមផ្សំនឹងមនោគតិរបស់ខ្លួន ។
- អ្នកនិពន្ធ គឺជាអ្នកសរសេរ ឬតាក់តែងរឿង ។
- កាលកំណត់តែង គឺជាពេលវេលា ថ្ងៃខែឆ្នាំ ដែលអ្នកនិពន្ធបានសរសេរចប់សព្វគ្រប់ ហើយបានបញ្ជាក់នៅក្នុងស្នាដៃរបស់ខ្លួនយ៉ាងពិតប្រាកដ ។
- សង្គមបរិយាកាស គឺដំណើររឿងដែលអ្នកនិពន្ធលើកមកបង្ហាញស្ថិតក្នុងសម័យកាលណាមួយ ហើយមានព្រឹត្តិការណ៍សង្គមអ្វីខ្លះនៅក្នុងរឿងដែលគួរកត់សម្គាល់ក្នុងស្នាដៃរបស់ខ្លួន ។
- អក្សរសិល្ប៍ព្រាហ្មណ៍និយម គឺអត្ថបទអក្សរសិល្ប៍ណាដែលមានទំនាក់ទំនងទៅនឹងលទ្ធិសាសនាព្រាហ្មណ៍ ដោយការផ្តើមរឿងច្រើនលើកសរសើរពីឫទ្ធិអំណាចរបស់ព្រះឥសី ព្រះឥសូរ ទេវៈ អាទិទេពជាដើម ។ ឯតួរឿង ឬដំណើររឿងមានភាពអច្ឆរិយៈហួសហេតុ ហើយតួអង្គប្រុសជាអវតារនៃព្រះនារាយណ៍ ស្ត្រីជាកំពូលនារីល្អឯក និងបញ្ចប់រឿង អ្នកនិពន្ធបញ្ចប់ដោយឱ្យសភាវៈល្អឈ្នះសភាវៈអាក្រក់ ។
- ចលនាអក្សរសិល្ប៍ គឺជាដំណើរប្រែប្រួលនៃអក្សរសិល្ប៍តាមការនិយមនៃវណ្ណៈ ឬស្រទាប់សង្គមលើទ្រឹស្តីទស្សនៈគោលគំនិតណាមួយក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រ ។ គេអាចចែកចលនាអក្សរសិល្ប៍ខ្មែរជាបួនប្រភេទ គឺចលនាអក្សរសិល្ប៍ព្រាហ្មនិយម ពុទ្ធនិយម ខេមរនិយម និងបរទេសនិយម ។
- អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមសម្គាល់អត្ថបទអក្សរសិល្ប៍ដែលមានទំនាក់ទំនងទៅនឹងលទ្ធិពុទ្ធសាសនា ដោយការផ្តើមរឿង គឺធ្វើបទនមស្ការរំលឹកគុណព្រះរតនត្រ័យមានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ឯក្នុងដំណើររឿងតួអង្គឯកបុរសជាពោធិសត្វ នារីជាកន្សែសារពេជ្ជ និងការបញ្ចប់រឿង ដោយមានការសរជាតិរបស់តួអង្គ ។ ពោធិសត្វទៅជាព្រះពុទ្ធ ឯកន្សែសារពេជ្ជទៅជានាងពិម្ពា ។ ចំពោះតួអង្គអាក្រក់វិញ បើតួអង្គនោះប្រឆាំងនឹងទៅជាទេវទត្ត ឯតួអង្គស្រីទៅជានាងចិញ្ចា ។

# ស្វរព្យញ្ជនៈ

ព្យញ្ជនៈ គឺជាសូរសំឡេងដែលកើតមកពីដំណើរខ្យល់តាមបំពង់សំឡេង បន្លឺឡើងដោយមានទំនប់ប្រកបដោយភាពពុំច្បាស់លាស់។ ព្យញ្ជនៈអាចចែកតាមលក្ខណៈបន្លឺ តាមលក្ខណៈខ្យល់ និងលក្ខណៈឮ។

ក្នុងមេរៀនមុន អ្នកបានសិក្សារួចហើយអំពីលក្ខណៈបន្លឺ។ ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីលក្ខណៈខ្យល់និងលក្ខណៈឮ។

## ១ . តាមលក្ខណៈខ្យល់

ក្នុងភាសាខ្មែរតាមលក្ខណៈខ្យល់ព្យញ្ជនៈចែកជា ៖

- ព្យញ្ជនៈខ្យល់ស្ទះ
- ព្យញ្ជនៈខ្យល់ច្រមុះ
- ព្យញ្ជនៈខ្យល់បង្ហូរត្រដុស។

### ក. ព្យញ្ជនៈខ្យល់ស្ទះ

*ឧទាហរណ៍ :* កាច់ ខិត គោ ចង ឃុំ ជីក ឆាន់ ឈប់ ទៅ ដាំ ខាន ធំ ពោះ បាយ ...។

ការបន្លឺព្យញ្ជនៈក្នុងពាក្យខាងលើប្រកបដោយលក្ខណៈបីយ៉ាង ៖

- ការរៀបចំស្ថានភាពនៃប្រដាប់សំឡេង
- ការប្រឹងនៃប្រដាប់សំឡេង
- ការផ្លាស់កន្លែងនៃប្រដាប់សំឡេងពីទីបន្លឺ ដើម្បីលែងសន្ទុះខ្យល់។

ព្យញ្ជនៈខ្យល់ស្ទះមាន ៖

- ព្យញ្ជនៈខ្យល់ស្ទះគ្មានខ្យល់

*ឧទាហរណ៍ :* កង់ គាប ចូល ជុច ដាំ តាំង ទូក បុក ប៉ាន់ ពាង អូរ។

ព្យញ្ជនៈខ្យល់ស្ទះគ្មានខ្យល់មាន : កគ [ k ] ចជ [ c ] ដឌ [ d ] តទ [ t ] បប៊ [ b ] ប៉ព [ p ] អអ៊ [ ? ] ។

- ព្យញ្ជនៈខ្យល់ស្ទះមានខ្យល់

*ឧទាហរណ៍ :* ខាន ឃាំង ឆាប់ ឈើ ឋាន ថា ធុង ផង ភ្លួយ។

ព្យញ្ជនៈខ្យល់ស្ទះមានខ្យល់មាន : ខឃ ឆឈ ឋឍ ថធ ផភ។

*ព្យញ្ជនៈខ្យល់ស្ទះ គឺជាព្យញ្ជនៈបន្លឺឡើងដោយមានការរៀបចំ បរិង និងបំលាស់កន្លែងនៃប្រដាប់សំឡេង ។*

ខ. ព្យញ្ជនៈខ្យល់ច្រមុះ

*ឧទាហរណ៍ :* ញ៉ិក នាង ណា មាន ង៉េះៗ ... ។

ការបន្លឺព្យញ្ជនៈក្នុងពាក្យខាងលើ មានភាពរំពងនៅក្នុងប្រហោងច្រមុះ ។

ព្យញ្ជនៈខ្យល់ច្រមុះមាន : ង៏ង ញ៏ញ ន៏ណន ម៏ម ។

*ព្យញ្ជនៈខ្យល់ច្រមុះ គឺជាព្យញ្ជនៈបន្លឺឡើងដោយមានភាពរំពង ក្នុងច្រមុះ ។*

គ. ព្យញ្ជនៈខ្យល់បង្ហូរត្រដុស

*ឧទាហរណ៍ :* យាយ យំ វ៉ៃ វា រាយ រ៉ាំរ៉ៃ ស្រូវ ស៊ី លក់ ឡូឡា ហាង ហ៊ាន ... ។

ការបន្លឺព្យញ្ជនៈក្នុងពាក្យខាងលើ មានដំណើរខ្យល់ផ្លុំបង្ហូរ ដែលធ្វើឱ្យឮឡើងដោយត្រដុស ។

ព្យញ្ជនៈខ្យល់ច្រមុះមាន : យ៏យ រ៏រ ឡល៏ល វ៏វ សស៏ ហហ៏ ។

*ព្យញ្ជនៈខ្យល់បង្ហូរត្រដុស គឺជាព្យញ្ជនៈបន្លឺឡើងដោយមានដំណើរខ្យល់ផ្លុំបង្ហូរត្រដុស ។*

## ២ . តាមលក្ខណៈឮ

ក្នុងភាសាខ្មែរ តាមលក្ខណៈឮព្យញ្ជនៈចែកជា ព្យញ្ជនៈឮនិងព្យញ្ជនៈថ្លង់ ។

ក. ព្យញ្ជនៈឮ

*ឧទាហរណ៍ :* ដោយ បាច ប៊ិច ងងុយ ង៉ាវៗ ញញឹម ញ៉ាំ មាន ម៉ៅ នាង ណា យាង ឡើង វា យ៉ាង រាវ រ៉ាំរ៉ៃ រលំ ... ។

ព្យញ្ជនៈឮមាន : ដឌ [d] បប៊ [b] ង៏ង [ŋ] ញ៏ញ [ɲ] ណន៏ន [n] ម៏ម [m] យ៏យ [j] រ៏រ [r] ឡល៏ល [ℓ] វ៏វ [v] ។

*ព្យញ្ជនៈឮ គឺជាព្យញ្ជនៈធ្វើឱ្យចន្លោះខ្សែសំឡេងញាប់ញ័រ ។*

## ខ. ព្យញ្ជនៈថ្លង់

*ឧទាហរណ៍ :* កេងកង គគ្រឹក ខិតខំ ឃុំឃាំង ចរចា ជជុះ ឆាឆៅ ឈើ តតាំង ទទឹក ឋាន ថា ណាលិន ធំធេង ប៉ប្រិម ពពក ផាយផាត់ ភូមិ សសៀរ ស៊ី ហាល ហ៊ាន អ៊ូអរ ... ។

ព្យញ្ជនៈថ្លង់មាន : កគ ខឃ ចជ ឆឈ តទ ឋ ថ ឍ ធ ប៉ព ផភ សស៊ ហហ៊ អអ៊ ។

> *ព្យញ្ជនៈថ្លង់ គឺជាព្យញ្ជនៈពុំធ្វើឱ្យចន្លោះខ្សែសំឡេងញាប់ញ័រឡើយ ។*

## លំហាត់

ក. ចូរស្រង់ពាក្យខាងក្រោមទៅដាក់ឱ្យត្រូវតាមខ្ទង់ព្យញ្ជនៈខ្យល់ស្ទះមានខ្យល់និងខ្យល់ស្ទះគ្មានខ្យល់ ។

| ព្យញ្ជនៈខ្យល់ស្ទះមានខ្យល់ | ព្យញ្ជនៈខ្យល់ស្ទះគ្មានខ្យល់ |
|---|---|
| ឃោរឃៅ<br>............. | ដឹង<br>............. |

អ៊ូអែ ភ្លឺភ្លើ កោងកាច ខកខាន អាំង គាត់ ឃោរឃៅ ពព្រិច ឆ្កាង ប៉ប្រេះ ចូល ឈ្មោន់ បាយ ជាង ថិត ប៊ិច ឍាមរា ទទឹក ថាំង តឹង ធ្នូ ដឹង ឧប ភ្នាល់ តុបតែង ចចេស ទំ ផង ឆាឆៅ ។

ខ. ចូររកពាក្យដែលត្រូវនឹងព្យញ្ជនៈខ្យល់ច្រមុះខាងក្រោម ក្នុងមួយតួឱ្យបានយ៉ាងតិចពីរពាក្យ ។

| ព្យញ្ជនៈខ្យល់ច្រមុះ | ពាក្យ | ពាក្យ |
|---|---|---|
| ង៉ | ............. | ............. |
| ង | ............. | ............. |
| ញ៉ | ............. | ............. |
| ញ | ............. | ............. |
| ន៉ | ............. | ............. |
| ណ | ............. | ............. |
| ណ | ............. | ............. |
| ម៉ | ............. | ............. |
| ម | ............. | ............. |

គ. ចូររកពាក្យដែលត្រូវនឹងព្យញ្ជនៈឱ្យលំបង្ហូរត្រដុសខាងក្រោម ក្នុងមួយតួឱ្យបានយ៉ាងតិចពីរពាក្យ ។

| ព្យញ្ជនៈឱ្យលំច្រមុះ | ពាក្យ | ពាក្យ |
|---|---|---|
| យ៉ | ............. | ............. |
| យ | ............. | ............. |
| រ៉ | ............. | ............. |
| រ | ............. | ............. |
| ឡ | ............. | ............. |
| ល | ............. | ............. |
| ល៉ | ............. | ............. |
| វ៉ | ............. | ............. |
| វ | ............. | ............. |
| ស | ............. | ............. |
| ស៊ | ............. | ............. |
| ហ | ............. | ............. |
| ហ៊ | ............. | ............. |

ឃ. ចូរស្រង់ពាក្យខាងក្រោមទៅដាក់ឱ្យត្រូវតាមខ្ទង់ព្យញ្ជនៈឮនិងព្យញ្ជនៈថ្លង់ ។

| ព្យញ្ជនៈឮ | ព្យញ្ជនៈថ្លង់ |
|---|---|
| ប៊ូល<br>............. | ងាប់<br>............. |

មមៃ កកាយ ប៉ើង បោយ ប៊ូល គាស់ ម៉ឺន ដុំ ឱន ខូច ឃ្នាង ង៉ាវ តតេះ ទូក ងាប់ ជួល ញ៉ាំ ឋិត ថ្នាក់ ញញួរ ណាស់ នាំ ឈាល ផាង សយនា រវល់ ឡាន សាលា ហ៊ឹង ហួល សក ស៊ុប អន់ វ៉ៗ វីកវរ យាន យ៉ាប់យ៉ឺន ផ្សារ ភ្ញី ទាល់ មីនា ធឹងធោង តែង ជញ្ជីង ពពុះ ។



# ការឃោសនាបញ្ចុះបញ្ចូល

ជារៀងរាល់ថ្ងៃ អ្នកតែងបានឮការផ្សព្វផ្សាយព័ត៌មានឃោសនាបញ្ចុះបញ្ចូលផ្សេងៗជាច្រើន តាមរយៈវិទ្យុ ទូរទស្សន៍ និងបានឃើញតាមរយៈកាសែត ទស្សនាវដ្ដី ខិតប័ណ្ណ បដាជាដើម។ ការឃោសនាបញ្ចុះបញ្ចូលទាំងនោះច្រើនទាក់ទងនឹងការផ្សព្វផ្សាយពាណិជ្ជកម្ម ការឃោសនាលក់ផលិតផល ការឃោសនាផ្សព្វផ្សាយអំពីការអប់រំជាដើម។ គោលបំណងនៃការឃោសនាបញ្ចុះបញ្ចូល គឺដើម្បីទាក់ទាញអតិថិជន ឬសមាជិកឱ្យគាំទ្រផលិតផល ឬក៏អង្គការសមាគមផ្សេងៗ។ ដូច្នេះដើម្បីឃោសនាបញ្ចុះបញ្ចូលឱ្យមានប្រសិទ្ធភាព ឃោសនិកគប្បីគិតទៅដល់ចំណុចសំខាន់ៗដូចជា ការប្រើប្រាស់មធ្យោបាយឃោសនា (តាមវិទ្យុ ទូរទស្សន៍ ផ្ទាំងរូបភាព ខិតប័ណ្ណ បដា ...)និងការប្រើប្រាស់សំនួនវោហារសព្វល្អៗដូចជា សំនួនអួតសរសើរ សំនួនបញ្ចើចបញ្ចើជាដើម ដើម្បីទាក់ទាញអារម្មណ៍និងទឹកចិត្តឱ្យអ្នកស្ដាប់ អ្នកអានចងចាំ។

ចូរអានសារឃោសនាបញ្ចុះបញ្ចូលខាងក្រោម ៖

ក. **មកដល់ទៀតហើយ** ! កំពូលវណ្ណកម្មថ្មីល្អគ្មានពីរមិនធ្លាប់មានពីមុនមក ដែលអស់លោក លោកស្រី អ្នកនាងកញ្ញាកំពុងរង់ចាំនោះ គឺកំពូលរឿង "ក ខ គ"។ រឿងនេះត្រូវបានថតជាខ្សែភាពយន្តខ្នាតធំ ពណ៌ធម្មជាតិ មើលឃើញច្បាស់ត្រជាក់ភ្នែក ...។ គ្រប់ឈុត គ្រប់ឆាកសុទ្ធតែធ្វើឱ្យទស្សនិកជនរំភើបទប់អារម្មណ៍មិនបាន កំប្លែងសើចចុកពោះ កម្សត់ស្រក់ទឹកភ្នែកនិងមានឆាកប្រយុទ្ធថែមទៀតផង។ ពេលបានទស្សនាហើយលោកអ្នកនឹងបាត់អស់នូវភាពតានតឹងក្នុងអារម្មណ៍បន្សល់ទុកនៅតែភាពរីករាយ។ ទស្សនាហើយចង់ទស្សនាទៀត។ រួមសម្ដែងដោយតារាឯកល្បីៗ កំពុងពេញនិយមដូចជា ក ខ គ ឃ ង។ សូមកុំភ្លេច សូមអញ្ជើញមកចូលរួមទស្សនាឱ្យបានរួសរាន់ ព្រោះកន្លែងមានកំណត់។ សំបុត្រទិញមួយថែមជូនមួយ។ ខ្សែភាពយន្តនេះនឹងបញ្ចាំងជូននៅរោងភាពយន្តយើងខ្ញុំ ដែលនឹងចាប់បញ្ចាំងនៅថ្ងៃទី ..... ខែ ....... ឆ្នាំ .......។ សួស្ដី! កំពូលរឿង "ក ខ គ"!

ខ. **ដំណឹងថ្មី** : ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ហាងលក់សម្លៀកបំពាក់ សែនសម យើងខ្ញុំបាននាំចូលសម្លៀកបំពាក់បុរសស្ត្រីពីបរទេសមានគុណភាពអន្តរជាតិ មិនក្លែងក្លាយដែលអាចធ្វើឱ្យឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ស្លៀកពាក់យ៉ាងស្រស់សង្ហា ទំនើបទាន់សម័យ។ ក្នុងឱកាសចូលឆ្នាំថ្មីខាងមុខនេះ ហាងសម្លៀកបំពាក់ សែនសម យើងខ្ញុំនឹងបញ្ចុះតម្លៃ ២០% និងផ្ដល់ជូនសន្លឹកឆ្នោតផ្សង

សំណាងមួយសន្លឹកសម្រាប់អស់លោក លោកស្រី អ្នកនាង កញ្ញាទិញផលិតផលអស់ ៣០ដុល្លារ។ សូមអញ្ជើញឱ្យបានរួសរាន់កុំឱ្យឱកាសនេះកន្លងផុត។

អត្ថបទឃោសនាខាងលើនេះ យើងឃើញមានប្រើសំនួនបញ្ចុះបញ្ចូលដូចជា ៖

- សំនួនពាក្យអួតសរសើរគុណភាព : កំពូលវណ្ណកម្មថ្មីល្អគ្មានពីរ មិនធ្លាប់មានពីមុនមក ពណ៌ធម្មជាតិ មើលឃើញច្បាស់ ត្រជាក់ភ្នែក តារាឯកល្បីៗ កំពុងនិយម គុណភាពអន្តរជាតិ ...។
- សំនួនសរសើរអត្ថប្រយោជន៍ : បាត់អស់នូវភាពតានតឹងក្នុងអារម្មណ៍ បន្សល់ទុកនៅតែភាពសប្បាយរីករាយ ស្លៀកពាក់យ៉ាងស្រស់សង្ហាទំនើបទាន់សម័យ ...។
- សំនួនបញ្ឆេះបញ្ឆើ : រំភើបទប់អារម្មណ៍មិនបាន កំប្លែងសើចចុកពោះ កម្សត់ស្រក់ទឹកភ្នែក សំបុត្រទិញមួយថែមជូនមួយ ស្លៀកពាក់យ៉ាងស្រស់សង្ហាទំនើបទាន់សម័យ និងផ្តល់ជូនសន្លឹកឆ្នោតផ្សងសំណាងមួយសន្លឹក ...។

ក្នុងការឃោសនាបញ្ចុះបញ្ចូល គេតែងប្រើប្រាស់បច្ចេកទេសឃោសនាមួយចំនួនដូចខាងក្រោម

- បង្ហាញឈ្មោះវត្ថុ ឬឈ្មោះអ្វីមួយដែលគួរឱ្យរីករាយ
- បង្ហាញភាពចាំបាច់នៃវត្ថុ
- ប្រើពាក្យទាក់ទាញប្រកបដោយភាពរំជើបរំជួល
- ប្រើពាក្យបំផុសអារម្មណ៍ឱ្យរំភើប
- បញ្ជាក់ពីគុណភាពដ៏ល្អនៃវត្ថុ។

## លំហាត់

ចូរអ្នករៀបគ្នាជាក្រុម រួចជ្រើសរើសប្រធានបទមួយខាងក្រោមមកពិភាក្សាដើម្បីតាក់តែងជាអត្ថបទឃោសនាផ្សព្វផ្សាយពាណិជ្ជកម្ម ដើម្បីទាក់ទាញអតិថិជនឱ្យមកគាំទ្រ។

១. ការសម្តែង យីកេ ល្ខោនបាសាក់ ភាពយន្ត ការប្រគំតន្ត្រី មហោស្រពសិល្បៈ ...។

២. ការលក់ផលិតផល រូបចម្លាក់ ផ្ទាំងគំនូរ សៀវភៅរឿង ...។

# ការឃោសនាបញ្ចុះបញ្ចូល

ការឃោសនាបញ្ចុះបញ្ចូលត្រូវបានគេធ្វើឡើងតាមរយៈ វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្ដី ខិតប័ណ្ណបដាជាដើម ។ សារឃោសនាបញ្ចុះបញ្ចូលទាំងនោះ ច្រើនទាក់ទងទៅនឹងការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផល ការឃោសនានយោបាយ ការផ្សព្វផ្សាយអប់រំសុខភាពជាដើម ។ គោលបំណងនៃការឃោសនា គឺអូសទាញ ឬបញ្ចុះបញ្ចូល ដោយធ្វើយ៉ាងណាទាក់ទាញអតិថិជន ឬអូសទាញប្រជាពលរដ្ឋឱ្យគាំទ្រផលិតផល ឬក៏គណបក្សនយោបាយរបស់ខ្លួន ។ ដូច្នេះដើម្បីឃោសនាបញ្ចុះបញ្ចូលឱ្យមានប្រសិទ្ធភាព ឃោសនិកគប្បីគិតទៅដល់ចំណុចសំខាន់ៗដូចជា ការប្រើប្រាស់មធ្យោបាយនិងការប្រើប្រាស់សំនួនវោហារសព្ទឱ្យបានល្អៗ ដើម្បីទាក់ទាញអារម្មណ៍ និងទឹកចិត្តឱ្យគេគាំទ្រខ្លួន ។

## លំហាត់

ចូររៀបគ្នាជាក្រុមពិភាក្សា ដោយជ្រើសរើសប្រធានបទ តាមរយៈរូបភាពនិងសារឃោសនាណាមួយខាងក្រោមមកពិភាក្សាសរសេរជាអត្ថបទឃោសនាបញ្ចុះបញ្ចូលដោយប្រើសំនួនឱ្យបានសមស្របដើម្បីទាក់ទាញអ្នកគាំទ្រ ។

- **រូបភាពទី ១**

  នេះជាបដាផ្សព្វផ្សាយអំពីការសម្ដែងសិល្បៈមហោស្រពអង្គរ ។

  ចូរអ្នកសរសេរអត្ថបទឃោសនាទាក់ទងនឹងមហោស្រពនេះ ។



- **រូបភាពទី ២**

  នេះគឺជាផ្ទាំងរូបភាពផ្សាយពាណិជ្ជកម្មលក់សៀវភៅនៅបណ្ណាគារ ។

  ចូរអ្នកសរសេរអត្ថបទផ្សព្វផ្សាយឃោសនាបញ្ចុះបញ្ចូលអតិថិជនឱ្យមកទិញសៀវភៅនៅបណ្ណាគារនេះ ។



- រូបភាពទី ៣

នេះជាបដាផ្សព្វផ្សាយអំពីការអប់រំសុខភាពទាក់ទងនឹងការជក់បារី ។

ចូរអ្នកសរសេរអត្ថបទឃោសនាបញ្ចុះបញ្ចូលឱ្យគេឈប់ជក់បារី ។




- រូបភាពទី ៤

នេះគឺជាផ្ទាំងរូបភាពផ្សាយអប់រំពីច្បាប់ចរាចរណ៍ ។

ចូរអ្នកសរសេរអត្ថបទផ្សព្វផ្សាយឃោសនាបញ្ចុះបញ្ចូលឱ្យគេគោរពច្បាប់ចរាចរណ៍ ។



- រូបភាពទី ៥

នេះគឺជាផ្ទាំងរូបភាពផ្សាយអំពីការហាមប្រើប្រាស់អាវុធជាតិផ្ទុះខុសច្បាប់ ។

ចូរអ្នកសរសេរអត្ថបទផ្សព្វផ្សាយឃោសនាបញ្ចុះបញ្ចូលឱ្យគេគោរពច្បាប់នៃការប្រើប្រាស់អាវុធជាតិផ្ទុះនេះ ។



មេរៀនទី ៨

# តថភាព




*ស្ពានមិត្តភាពកម្ពុជា-ចិន សេកុង*

អតីតកាលបានបន្សល់ទុកនូវមរតកជាច្រើនស្ដីពីមនុស្សនិងសង្គម សម្រាប់ស្រាវជ្រាវជំនាន់ក្រោយៗ ព្រឹត្តិការណ៍ទាំងអស់នេះត្រូវបានគេយកមករៀបចំតាក់តែងទៅតាមជំនាញឯកទេសនីមួយៗ ដើម្បីអ្នកសិក្សារៀនសូត្រជំនាន់ក្រោយគ្រប់កម្រិតសិក្សា ។ រឿងរ៉ាវនេះ ជាតថភាពសង្គមដែលអ្នកនិពន្ធបានយកមករៀបចំធ្វើខ្លឹមសារ ឬអត្ថន័យនៃស្នាដៃក្នុងរឿង ក្នុងទិសដៅឱ្យអ្នកសិក្សាចេះឆ្លុះបញ្ចាំង វិភាគ ពិចារណា រកហេតុផល ដើម្បីជាបទពិសោធសម្រាប់ជីវិត ក្នុងការរស់នៅប្រចាំថ្ងៃ ក៏ដូចជាបទពិសោធក្នុងការរៀបចំសង្គមផងដែរ ។

ក្នុងមេរៀននេះ អ្នកនឹងបានស្គាល់នូវតថភាពសង្គមខ្មែរពីអតីតកាល តាមសម័យកាលមួយចំនួន ទន្ទឹមនឹងនេះ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីលក្ខណៈតថភាពក្នុងអក្សរសិល្ប៍ លក្ខណៈអក្សរសិល្ប៍ ព្យញ្ជនៈផ្សំ បកស្រាយន័យ ពាក្យស្លោក សុភាសិត សំណេរតែងសេចក្ដី អត្ថាធិប្បាយពិភាក្សា ។

## លក្ខណៈតថៈនៅក្នុងអក្សរសិល្ប៍

អក្សរសិល្ប៍ គឺជាកញ្ចក់ឆ្លុះបញ្ចាំងនូវតថភាពសង្គមគ្រប់បែបយ៉ាងតាមរយៈប្រវត្តិសាស្ត្រនៃអក្សរសិល្ប៍ខ្មែរ ។ សង្គមមនុស្សត្រូវបានគេរាប់បញ្ចូលទាំងជីវភាពរស់នៅ ទំនៀមទម្លាប់ ប្រពៃណី សាសនា សិទ្ធិមនុស្ស បរិស្ថាន សុខភាពជាដើម ។ គេអាចស្គាល់អំពីទិដ្ឋភាពទូទៅនៃសង្គមមួយតាមការអានអត្ថបទអក្សរសិល្ប៍ដែលត្រូវបានពន្លេចឡើងតាមរូបារម្មណ៍អក្សរសិល្ប៍ ។ ទោះបីអ្នកអាននោះមិនបានរស់នៅក្នុងសម័យកាលនោះក៏ពិតមែនក៏ដោយ ។

*ឧទាហរណ៍ :*

| | | |
|---|---|---|
| ដំឡូងមួយដុំ | ដើមស្ពៃមួយគុម្ព | ប្រៀបធៀបឧបមា |
| បាយក្រៀមមួយដៃ | តម្លៃស្មើគ្នា | ជីវិតប្រជា |
| | ក្នុងសង្គមថ្មី ។ | |
| យកវត្តធ្វើគុក | អំណាចផ្តាច់មុខ | ហោះហើរសេរី |
| ជនក្រោមអំណាច | មិនអាចហាស្តី | ដូចគោក្របី |
| | ធ្វើអ្វីតាមចិត្ត ។ | |
| ពាក្យឱ្យរៀនសូត្រ | ឮដូចស្លូតបូត | គួរត្រេកត្រអាល |
| តែមិនអប់រំ | បន្លំខួរក្បាល | ភាពពិតពួកពាល |
| | បោកប្រាស់សម្លាប់ ។ | |

*(ដកស្រង់ពីសៀវភៅមើលផែនដីខ្មែរ សម័យ ប៉ុល ពត អ្នកនិពន្ធ ជួន មេន)*

*លក្ខណៈតថៈក្នុងអក្សរសិល្ប៍ គឺជាសច្ចភាពរបស់សម័យកាលណាមួយដែលអ្នកនិពន្ធបានលើកយកមកកែច្នៃជាមួយគំនិតផ្ទាល់ខ្លួន ដើម្បីបង្កើតជាស្នាដៃ និម្មិតកម្មឡើង ។*

## លំហាត់

ចូរអ្នកកំណត់នូវលក្ខណៈតថៈអក្សរសិល្ប៍ក្នុងវគ្គខាងក្រោមនេះ ៖

១. [...] សេចក្តីស្រេកឃ្លានបានបង្ខំចិត្តគំនិតរបស់**សម**ឱ្យប្រែប្រួលផ្លាស់ប្តូរពីបាតដៃទៅជាខ្នងដៃភ្លាមៗ ភ្នែកទាំងពីររបស់សម ប្រែទៅជាក្រហមហើយស្រវាំងព្រិល ។ **សម** បានដើរចេញពីកន្លែងនោះ ហើយបានទៅដល់មុខរោងភាពយន្តដោយទឹកមុខស្រពោនក្រៀមក្រំ ។ ពេលនោះគាត់ចូលជាភាពយន្តដល់ពេលចប់រឿង ។ មនុស្សម្នាទាំងឡាយប្រជ្រៀតគ្នាចេញពីរោងភាពយន្ត ។ **សម** ក្រឡេក

មើលទៅឃើញបុរសស្ត្រី ក្នុងវ័យកណ្ដាលពីរនាក់ កំពុងប្រជ្រៀតចេញមកពីក្នុងរោងភាពយន្តដែរ ។ បុរសនិងស្ត្រីទាំងពីរនាក់នេះតែងខ្លួនរៀបរយស្រគត់ស្រគំ មានលក្ខណៈបង្ហាញឱ្យដឹងថា ជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ ។ ស្ត្រីមានរូបរាងធាត់បន្តិចហើយនាងកាន់កាបូបស្បែកក្រពើនៅដៃ ។ ខណៈនោះ **សម** ដាច់ចិត្តប្រព្រឹត្តនូវការទុច្ចរិតភ្លាមដោយនឹកជឿជាក់ថា នៅក្នុងកាបូបស្បែកក្រពើនោះ បើហោចណាស់ក៏គង់មានប្រាក់ល្មមនឹងជួយជីវិតឱ្យបានរួចផុតពីការដាច់ពោះស្លាប់បានមួយពេលដែរ ។

អំណាចនៃសេចក្ដីស្រេកឃ្លាននេះសេចក្ដីអាក្រក់ថោកទាបបានកើតឡើងដល់ចិត្តគំនិតរបស់ **សម** ហើយ**សម** ដើរសសៀរចូលទៅជិត ហើយក៏កញ្ឆក់កាបូបស្បែកក្រពើយកចេញពីដៃនៃស្ត្រីនោះភ្លាម ។ [...]

*(ដកស្រង់ពីសៀវភៅរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ អ្នកនិពន្ធ សួន សុរិន្ទ)*

២. [...] **លឹមនិងថន** បានដើរកាត់ភូមិទៅត្បូងដល់ចុងភូមិ គាត់ចូលទៅហៅតាមុយរួចអ្នកទាំងបីបានបណ្ដើរគ្នា សំដៅទៅផ្ទះមេឃុំ**ផាន់** នៅភូមិគោកចំបក់ ។ **តាមុយ** បានផ្ដើមសួរលឹមថា : ឯងដឹងទេ ?

រឿងអ្វី ?

រឿងកំណែន ។ ឆ្នាំនេះរាជការបង្គាប់កេណ្ឌគូលី ១០០នាក់មួយលើកៗក្នុងមួយឃុំ ហើយបើនរណារឹងទទឹងបង្គាប់នេះ មេឃុំមានអំណាចណាស់ ចាប់ដាក់ខ្នោះបញ្ជូនទៅសាលាស្រុក ទៅសាលាខេត្ត ។ **ផាន់** បានចាត់ក្រុមប៉ូលិសឱ្យកេណ្ឌលើសម្ដែនាក់សំដៅទៅលើគ្រួសារណាដែលមានធុរៈធូន់ ហើយបើគង់យកទៅបាញ់ចោលក៏អ្នកម្ដៃនាក់នោះឃ្លាតពីផ្ទះមិនបានដែរ ។ ចំពោះអ្នកម្ដៃនាក់ **ផាន់** ប្រើឧបាយកលធ្វើជាចិត្តល្អបន្ធូរបន្ថយមិនប្រិតខ្លាំងក្លា ។ គាត់ធ្វើជាយោគយល់ដោយមានធុរៈធូន់ ។ **ផាន់** បង្ខំឱ្យអ្នកម្ដៃនាក់នោះបង់ប្រាក់វិញ ។ គាត់ធានារកជួលគូលីជួស យកតម្លៃឈ្នួលម្នាក់ៗ ៥០រៀល ។

មេឃុំ**ផាន់** ធ្វើជាបន្ធូរខ្លាំងទៅដល់អ្នកក្រវេទនា ។ គាត់មិនយកប្រាក់ឈ្នួលភ្លាមទេ គាត់ធ្វើជាចេញប្រាក់ផ្ទាល់ខ្លួនគាត់ ជួសមុនសិន ។ ដូចនេះ មេឃុំ**ផាន់** ក្នុងកំណែនមួយលើកៗបានធនធាន បានអំណាច បានក្ដីដឹងគុណខ្លះពីអ្នកក្រវេទនា ។ មេឃុំ**ផាន់** កត់អ្នកជំពាក់គាត់ ដល់ខែភ្ជួររាស់ ឬខែច្រូតគាត់ទៅកាត់សំណងពីអ្នកក្រីក្រជំពាក់គាត់ទាំងនោះឱ្យមកភ្ជួររាស់ស្រែ ដកស្ទូង ច្រូតឱ្យគាត់ ធម្មតាប្រាក់បានដោយវិធីនេះ **ផាន់**ចែកទៅអ្នកភ្នាក់ងារគាត់ខ្លះ ទុកខ្លួនគាត់ខ្លះ ទិញអីវ៉ាន់ជូនលោកប្រុសលោកស្រីខ្លះ ... ។

*(ដកស្រង់ពីសៀវភៅរឿងគូលីកំណែន អ្នកនិពន្ធ អ៊ឹម ថុក)*



# ប្រមូលកំណែន



## ក. សិក្សាពាក្យគន្លឹះ

- អន្ទិត (ន) : សម្គាល់ទៅលើមនុស្សប្រុសដែលធ្លាប់បានបួសជាព្រះសង្ឃខាងព្រះពុទ្ធសាសនា ។
- កេណ្ឌកំណែន (ន) : ប្រមូលកំណែនដើម្បីកសាងប្រលានយន្តហោះ(ក្នុងអត្ថបទ) ប្រមូលមនុស្សដើម្បីធ្វើអ្វីមួយ ។
- ខោស្នាប់ភ្លៅ (ន) : ខោខ្លីមានជើងបត់ត្រឹមជង្គង់ ។
- ថី (ន) : លេខាធិការ ឬលេខានុការ គឺជាស្មៀនអ្នកចេះភាសាបារាំងសែស (ពាក្យសម្រាប់រាស្ត្រហៅទៅមន្ត្រី) ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទនេះអ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយសំណួរទាក់ទងនឹងលក្ខណតថៈក្នុងអក្សរសិល្ប៍ អ្នកនិពន្ធ កាលអាកាស កាលកំណត់តែង លក្ខណសម្បត្តិរបស់តួអង្គ ។

## គ. អត្ថបទ

[...] មាន់រងាវលើកទីពីរ យាយម៉ុកភ្ញាក់ក្រោកឡើង គាត់បង្កាត់ភ្លើងដាំជុតប្រហុក ខ្វប់ត្រីងៀត អំបិល បុកក្រសាំង អំពិលរៀបចំអង្ករឱ្យកូនពៅគាត់ ថ្ងៃរះចោលកាំរស្មីក្រហមឆ្អៅពីទិសខាងកើត តាង៉ែតបានក្រោកដើរថ្នមៗមិនឱ្យរង្គើរនាប ។ ចុះដល់ដីគាត់និយាយតិចៗជាមួយប្រពន្ធគាត់ :

- យើងស្ដីបន្ទោសអន្ទិតខ្លាំងពេក យប់មិញបានជាវាដេកក្រលក់ ។ អញឮតែវាប្រែប្រួលចុះឡើង ហើយដកដង្ហើមធំជាញឹកញយ ។ អញមិនដាស់វាទេ អញចង់ទៅធ្វើគូលីជួសវា បើវាសុខចិត្ត ។
- កុំដាស់វាអី ឪវាអើយ ទុកឱ្យវាដេកសិនចុះតង់តែអន្ទិតថនមកហៅវាទេ ... ។ ថ្ងៃរះកំពស់ចុងឈើអ្នកភូមិបានចេញទៅធ្វើការគ្រប់គ្នា ។ ក្មេងរត់លេងមីរនៅក្រោមដើមអំពិលអាចម៍ឆ្មាមុខភូមិ ។ អន្ទិតថន បានមកហៅ**លឹម** ។ **លឹម** ដឹងខ្លួនក្រោកឡើងស្ទុះទៅដីខ្ពរមាត់លាងមុខប្រញាប់ប្រញាល់ពុនអង្ករមួយកូនការុងនិងកញ្ចប់បាយប្រហុកដាក់ក្នុងបង្គី ។ គាត់លាម៉ែឪគាត់ ។ យាយ**ម៉ុក** បានស្រែកផ្ដាំថា :
- ត្រីឆ្អើរនៅក្នុងការុងអង្ករជារបស់នាង**ហេង** ដែលយកមកឱ្យឯងពេលស្រាងៗនេះ ។ នាង**ហេង** មិនបាននៅជូនដំណើរឯងទេ ... ។ នាងហួសទៅដកថ្នាលខ្ញីមមីស្រមួនបាត់ហើយ ... ។ ឯងទៅធ្វើការជាមួយគេប្រយ័ត្នកុំមាត់ផ្ដេសផ្ដាស ។
- **លឹមនិងថន** បានដើរកាត់ភូមិទៅត្បូងដល់ចុងភូមិគាត់ចូលទៅហៅតា**មុយ**រួចអ្នកទាំងបីបានបណ្ដើរគ្នា សំដៅផ្ទះមេឃុំ**ផាន់**នៅភូមិគោកចំបក់ ។ តា**មុយ** បានផ្ដើមសួរ**លឹម**ថា ៖

  ឯងដឹងទេ ?

  រឿងអ្វី ?

រឿងកំណែន ។ ឆ្នាំនេះរាជការបង្គាប់កេណ្ឌគូលី ១០០នាក់មួយលើកៗក្នុងមួយឃុំ ហើយបើនរណារឹងទទឹងបង្គាប់នេះ មេឃុំមានអំណាចណាស់ ចាប់ដាក់ខ្នោះបញ្ជូនទៅសាលាស្រុក ទៅសាលាខេត្ត ។ **ផាន់** បានចាត់ក្រុមប៉ូលិសឱ្យកេណ្ឌលើសម្ភៃនាក់សំដៅទៅលើគ្រួសារណាដែលមានធុរៈធូន់ ហើយបើគង់យកទៅបាញ់ចោលក៏អ្នកម្ភៃនាក់នោះឃ្លាតពីផ្ទះមិនបានដែរ ។ ចំពោះអ្នកម្ភៃនាក់ **ផាន់** ប្រើឧបាយកលធ្វើជាចិត្តល្អបន្ធូរបន្ថយមិនប្រិតខ្លាំងក្លា ។ គាត់ធ្វើជាយោគយល់ដោយមានធុរៈធូន់ ។ ផាន់បង្ខំឱ្យអ្នកម្ភៃនាក់នោះបង់ប្រាក់វិញ ។ គាត់ធានារកជួលគូលីជួសយកតម្លៃឈ្នួលម្នាក់ៗ៥០រៀល ។

មេឃុំ**ផាន់** ធ្វើជាបន្ធូរខ្លាំងទៅដល់អ្នកក្រវេទនា ។ គាត់មិនយកប្រាក់ឈ្នួលភ្លាមទេ គាត់ធ្វើជាចេញប្រាក់ផ្ទាល់ខ្លួនគាត់ជួសមុនសិន ។ ដូចនេះ មេឃុំ**ផាន់** ក្នុងកំណែនមួយលើកៗបានធនធាន បានអំណាច បានក្ដីដឹងគុណខ្លះពីអ្នកក្រវេទនា ។ មេឃុំ**ផាន់** កត់អ្នកជំពាក់គាត់ ដល់ខែភ្ជួររាស់ ឬខែច្រូត

គាត់ទៅកាត់សំណាងពីអ្នកក្រីក្រជំពាក់គាត់ទាំងនោះឱ្យមកភ្ជួរស្រែរាស់ ដកស្ទូង ច្រូតឱ្យគាត់។ ធម្មតាប្រាក់បានដោយវិធីនេះ ផាន់ ចែកទៅអ្នកភ្នាក់ងារគាត់ខ្លះទុកខ្លួនគាត់ខ្លះ ទិញអីវ៉ាន់ជូនលោកប្រុសលោកស្រីខ្លះ ... ។

- គ្រប់តែមេឃុំប្រព្រឹត្តដូចផាន់ទាំងអស់ឬ ? (លឹមបានសួរបញ្ជាក់)
- មានតិចណាស់ដែលត្រឹមត្រូវ ។ មួយរយនាក់មានមិនដល់មួយផង ... ។

**លឹមនិងតាមុយ** បានជជែកគ្នាពីនេះពីនោះចប់ផ្លូវដើរកាត់ទួលគោកត្រល់ រួចក៏បានទៅភូមិគោកចំបក់។ នៅមុខផ្ទះមេឃុំ**ផាន់** កំណែនមកដល់ជាបន្តៗគ្នា។ គ្រប់ចំនួន ១០០នាក់ មេឃុំ**ផាន់**មានប៉ូលិសពីរនាក់ស្ពាយកាំភ្លើងបានបណ្តើរកំណែនទៅសាលាស្រុក។ ថ្ងៃជិតត្រង់ហ្វូងគូលីឃុំគោកចំបក់បានទៅដល់សាលាស្រុក ដែលថ្ងៃនេះធ្វើរហូតគ្មានឈប់សម្រាក។ ក្នុងវាលរបងមុខសាលាស្រុកគេឃើញមានកំណែនឃុំឯទៀតបានមកដល់មុនខ្លះៗអង្គុយជាសង្កាត់ៗតាមឃុំ ក្បាលមីរនៅផ្ទាល់ដី។ កំណែនគ្រប់គ្នាតោកយ៉ាក ស្លៀកពាក់ខោស្ទាប់ភ្លៅលើជង្គង់បំណះយុល មុខក្រៀមអង្គុយឱ្យគេរាប់ក្បាលដូចជាអ្នកមានទោសប្លន់ ឬទោសលួច។

លោកបាល័ដ្ឋសស្អាតទំនងជាកូនកាត់ចិនខ្មែរ អាយុប្រហែល ២៥ឆ្នាំ និងចីដោយប៉ូលិសមួយរូបទៀតបានកាន់ភារៈទទួលកំណែន។ ថ្ងៃទទួលកំណែននេះ លោកបាល័ដ្ឋបានរៀបតុនៅរានហាល។ គាត់អង្គុយក្រោយតុ ហើយនៅខាងស្តាំតុ ចីដោយបានឈរប្រុងជួយមើលការខុសត្រូវ។ មេឃុំម្តងៗបានដើរឡើងទៅតុលោកបាល័ដ្ឋ ហុចបញ្ជីដៃពីររួចសំពះលាចុះមកវិញ។ ពួកមេឃុំផាន់មិននៅស្ងៀមគាត់រៀបចំបញ្ជីគាត់ហើយចាំផ្ទៀងស្តាប់លោកបាល័ដ្ឋហៅ។ មិនយូរប៉ុន្មានគេឮ ៖

- អាគោកចំបក់នៅឯណា ? បានគូលីគ្រប់ចំនួនទេ ? ពូផាន់ភ័យញ័រកាន់បញ្ជីទៅជូនលោកបាល័ដ្ឋឆ្លើយសំពះលើកដៃពីរថា
- ទានប្រុសរកគ្រប់ចំនួនហើយ
- គ្រាន់បើល្អ ឃើញទេអាកញ្ចាស់ស្វាយ ហេតុអ្វីក៏តាប៉ិឯងមិនខំកេណ្ឌឱ្យដូចអាគោកចំបក់។ ប្រយ័ត្នហួតងារចោល (លោកបាល័ដ្ឋបានបន្ទោសមេឃុំស្វាយ)។ ពូ**ផាន់** បានសំពះលាលោកបាល័ដ្ឋដើរថយក្រោយមកវិញ ហើយមុខគាត់បានស្រស់។ ឃើញដូចនោះលឹមលាន់មាត់សួរតា**មុយ**ថា យីពូ**ផាន់** បានតែជាមួយអ្នកតូចតាចទេ នៅចំពោះមុខលោកបាល័ដ្ឋមុខកញ្ច្រៀនដូចឈីពោះឯចឹង ...ហើយលោកបាល័ដ្ឋបែបកាចណាស់ ហៅមេឃុំស្វាយសុទ្ធតែអាកញ្ចាស់ ... ។
- ជាធម្មតាទេចៅអើយ អ្នកធំត្រូវតែកាន់ឫកដូចនេះ ហើយអ្នកតូចត្រូវតែសំពះត្រូវតែលូន ... ។

• មិនចម្ងតាទេ (លឹមប្រកែក)។ តាមខ្ញុំដឹងថា មានតែក្នុងស្រុកខ្ញុំគេទេ ដែលនាម៉ឺនជិះជាន់រាស្ត្រ នៅប្រទេសប្រជាធិបតេយ្យប្រជារាស្ត្រមិនថោកដូចស្រុកយើងទេ។ រាស្ត្រគេមានសិទ្ធិ មានសេរីភាពជជែកតវ៉ាបាន ហើយថារបបលុតក្រាបដើរទាក៏មិនសូវមានដែរ ...។

តាមិនសូវដឹងទេរឿងនេះ។ ឯងកុំនិយាយខ្លាំងពេក តិចមេឃុំផាន់ ឮ ...។ និយាយអ្វីៗត្រូវងាកមើលឆ្វេងស្តាំ ... ប្រយ័ត្ន។ (តាមុយ បានទូន្មាន)

លុះទទួលបញ្ជីនិងប្រមូលគូលីបានគ្រប់ចំនួនដូចជប៉ុនបង្គាប់ លោកបាល័ដ្ឋ ចីដោយនិងប៉ូលីសប្រាំនាក់ទៀតស្ពាយកាំភ្លើង បានបណ្ដើរគូលីកំណែនមានប្រហែលជាងពីរពាន់នាក់ទៅពោធិចិនតុង។ ថ្ងៃជ្រេជិតលិច គូលីកំណែនបានទៅដល់កន្លែងធ្វើការ។ សក្តិពីរជប៉ុននៅកាន់កាប់ត្រួតកន្លែងនោះបានចាប់ដៃទះស្មា អង្អែលខ្នងលោកបាល័ដ្ឋយ៉ាងរាក់ទាក់ សរសើរពូកែកេណ្ឌគូលីជួយទ័ពជប៉ុន ហើយសន្យាឱ្យប្រលង់ដៃសរសេរជាអក្សរជប៉ុន បើកច្បាប់ឱ្យលោកបាល័ដ្ឋចេញចូលពោធិចិនតុងមើលយន្តហោះឡើងចុះតាមចិត្ត។ លោកបាល័ដ្ឋរីករាយហើយធានាថា ថ្ងៃក្រោយកេណ្ឌឱ្យច្រើនជាងនេះទៅទៀត បើជប៉ុនត្រូវការស្លឹកត្នោតប្រាប់សាលាស្រុករកជូនបានទាំងអស់។ ប្រគល់បញ្ជីនិងគូលីរួចកាលណា លោកបាល័ដ្ឋបានគំនាប់ចាប់ដៃសក្តិពីរជប៉ុនត្រឡប់ទៅវិញ។

ឯចំណែកគូលីកំណែន ទាហានជប៉ុនបានឃុំនៅក្នុងបន្ទាយរបងលួសបន្លាឱ្យជីកដីធ្វើផ្លូវយន្តហោះដឹកថ្ម ដើម្បីធ្វើមូលដ្ឋានសង្គ្រាមផាស៊ីសមហាអាស៊ី។

*(ដកស្រង់ចេញពីរឿង គូលីកំណែនរបស់អ្នកនិពន្ធ អ៊ឹម ថុក ទំព័រ ៩ដល់ ១២)*

## សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងណា ? វគ្គទីប៉ុន្មាន ?

២. តើអត្ថបទនេះចែកជាប៉ុន្មានវគ្គ ? ហើយវគ្គនីមួយៗបានបង្ហាញពីព្រឹត្តិការណ៍អ្វីខ្លះ ?

៣. ចូរអ្នកបង្ហាញពីទំនាស់ នៅក្នុងអត្ថបទនេះ។

៤. ចូរវិភាគតួអង្គ លឹម មេឃុំផាន់ តាមុយ និងលោកបាល័ដ្ឋ។

៥. តើអត្ថបទនេះបានឆ្លុះបញ្ចាំងពីតថភាពសង្គមខ្មែរនាសម័យកាលណា ?

៦. ហេតុអ្វីបានជាមានវត្តមានពួកជប៉ុននៅលើទឹកដីនៃប្រទេសកម្ពុជា ហើយផ្តល់បាននូវគុណសម្បត្តិនិងគុណវិបត្តិអ្វីខ្លះដល់ប្រជាជនកម្ពុជា ?

# ព្យញ្ជនៈផ្សំ

អ្នកបានសិក្សារួចហើយអំពីតួនាទីនិងលក្ខណៈរបស់ព្យញ្ជនៈទោល ។ ឥឡូវនេះអ្នកនឹងសិក្សាអំពីព្យញ្ជនៈផ្សំបន្តទៀត ។ *ឧទាហរណ៍ :* អ្នកស្រែច្រូតស្រូវ ដោយទឹកមុខស្រស់ ។

ក្នុងឧទាហរណ៍ខាងលើមានសូរ "ច្រ ស្រ"

- ជាសូររួមនៃព្យញ្ជនៈនិងព្យញ្ជនៈ
- ជាសូរគ្មានស្រៈនៅចន្លោះព្យញ្ជនៈទាំងពីរ

ព្យញ្ជនៈផ្សំមានដូចជា :

១. ស្ទះ + ស្ទះ

ប្តូរ ផ្ទី ផ្តល់ ផ្ចាញ់ ផ្កា ផ្អក ខ្ពស់ ខ្ពង់ ត្បូង ថ្គាម ឆ្ពោះ ច្បា ឆ្តោ ឆ្កែ ក្បាល ក្តាន់ ខ្ទី ។

២. ស្ទះ + ច្រមុះ

ភ្នំ ផ្ញើ ផ្ងារ ភ្ញី ភ្ញា ថ្ម ធ្នូ ថ្នូរ ឆ្មា ឆ្នាំ ឆ្ងល់ ក្មេង ក្នុង ខ្ញុំ ក្ងាន ត្នោត ខ្មោច ខ្នាយ ។

៣. ស្ទះ + បង្ហូរត្រដុស

ផ្សារ ផ្លូវ ព្រៃ ព្យួរ ធ្វើ ថ្លា ទ្រុង គ្រែ ធ្យូង ឆ្វេង ឈ្លី ជ្រេ ឃ្យាល ខ្សែ ឃ្លេ ខ្យល់ ។

៤. ច្រមុះ + ស្ទះ

ម្ភៃ ម្ទេស ម្តាយ ម្កាក់ ម្ខាង ។

៥. ច្រមុះ + ច្រមុះ

ម្នាស់ ម្ញិកម្ញ៉ុក ម៉្ញៃ

៦. ច្រមុះ + បង្ហូរត្រដុស

ម្សៅ ម្លូ ម្រេច ម្យ៉ាង ម្ហូប ។

៧. បង្ហូរត្រដុស + ស្ទះ

ស្តី ស្បៃ ស្ទៃ ស្តាយ ស្កា ល្ពៅ ល្បី ល្គង ល្ខោន ។

៨. បង្ហូរត្រដុស + ច្រមុះ

ស្មា ស្នា ស្ងោរ ស្ងាត់ ល្មម ល្ង

៩. បង្ហូរត្រដុស + បង្ហូរត្រដុស

ស្វាយ ស្លាប ស្រា ស្យាម ល្ហុង

១០. បង្ហូរត្រដុស

- ច្រមុះ + ស្ទះចន្លោះខ្សែសំឡេង
- ស្ទះ

ក្អេងក្អាង ឆ្អិនឆ្អៅ ត្អូញត្អែរ ឆ្អាល ប្អូន ផ្អោះ ម្អម ល្អិតល្អ ស្អកស្អា ។

*ព្យញ្ជនៈផ្សំ គឺជាសូររួមនៃព្យញ្ជនៈពីរឬបីដែលគ្មានស្រៈនៅចន្លោះសូរទាំងនោះទេ ។*

## លំហាត់

១. ចូរអ្នកជ្រើសរើសព្យញ្ជនៈផ្សំដែលមានលក្ខណៈ (ស្ទះ + ស្ទះ) ដូចខាងក្រោមនេះ :

ក. ខ្ពស់ ខ្ពង់ ត្បូង ថ្កាម ជ្រៃ ឃ្យាល ខ្សែ ឃ្លេ ខ្យល់ ឆ្កោះ ច្បារ ឆ្កោ ថ្ងូរ ឆ្មា ឆ្នាំ ឆ្វល់ ក្មេង ក្នុង ។

ខ. [...] រឿងកំណែន ។ ឆ្នាំនេះរាជការបង្គាប់កេណ្ឌគូលី ១០០នាក់មួយលើកៗក្នុងមួយឃុំ ហើយបើនរណារឹងទទឹងបង្គាប់នេះ មេឃុំមានអំណាចណាស់ ចាប់ដាក់ខ្នោះបញ្ជូនទៅសាលាស្រុក ទៅសាលាខេត្ត ។ **ផាន់** បានចាត់ក្រុមប៉ូលិសឱ្យកេណ្ឌលើសម្ភែនាក់សំដៅទៅលើគ្រួសារណាដែលមាន ធុរៈធូន់ ហើយបើគង់យកទៅបាញ់ចោលក៏អ្នកម្ភៃនាក់នោះឃ្លាតពីផ្ទះមិនបានដែរ ។ ចំពោះអ្នកម្ភៃ នាក់ **ផាន់**ប្រើឧបាយកលធ្វើជាចិត្តល្អបន្ធូរបន្ថយមិនប្រិតខ្លាំងក្លា ។ គាត់ធ្វើជាយោគយល់ដោយមានធុរៈ ធូន់ ។ផាន់បង្ខំឱ្យអ្នកម្ភៃនាក់នោះបង់ប្រាក់វិញ ។ គាត់ធានារកជួលគូលីជួសយកតម្លៃឈ្នួលម្នាក់ៗ ៥០រៀល ។ [...]

២. ចូរអ្នកប្រៀបធៀបនិយមន័យព្យញ្ជនៈផ្សំនិងព្យញ្ជនៈទោលដូចខាងក្រោម :

- ព្យញ្ជនៈទោល គឺជាសូរសំឡេងដែលកើតឡើងមកពីដំណើរខ្យល់តាមបំពង់សំឡេងបន្លឺឡើង ដោយមានទំនប់ប្រកបដោយភាពពុំច្បាស់លាស់ ។
- ព្យញ្ជនៈផ្សំ គឺជាសូររួមនៃព្យញ្ជនៈពីរឬបីដែលគ្មានស្រៈនៅចន្លោះសូរទាំងនោះទេ ។



# ជីវិតអន្ធការរបស់ប្រជាជនខ្មែរ



## ក. សិក្សាពាក្យគន្លឹះ

- តណ្ហា (ន) : បំណង សេចក្ដីប្រាថ្នា សម្រេក សេចក្ដីអន្ទះអន្ទែង ។
- មហិច្ឆតា (ន) : សេចក្ដីប្រាថ្នាធំ ការចង់បានច្រើន សេចក្ដីលោភលន់ ។
- អសុរី (ន) : យក្សអង់អាច អ្នកចិត្តអាក្រក់ ។
- ទេវទត្ត (ន) : ឈ្មោះភិក្ខុមួយរូបជាព្រះអនុជអយ្យិកាមួយ គឺជាជីដូនមួយរបស់ព្រះសម្មាសម្ពុទ្ធសក្យមុនីគោតម ។
- អង្គការ (ន) : បែបផែនរបៀបរៀបចំកិច្ចការដែលល្អ ឬក្រុមណាមួយរៀបចំឡើង ដើម្បីចំណាត់ការអ្វីមួយ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទល្ខោននេះ ចូរអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងប្រភពអត្ថបទ លក្ខណៈតថៈក្នុងអក្សរសិល្ប៍ ។

## គ. អត្ថបទ

[...] ផ្គរភរអ្នកស្រែ មេឃមីរខ្មៅអែ ហាក់រំលំប្រេះ
សង្ឃឹមថាភ្លៀង មិនទៀងជាផេះ ក្លាយជាភ្លើងឆេះ
ខ្លោចអស់ព្រឹក្សព្រៃ ។

ពាក្យដូចទឹកឃ្មុំ តែចិត្តក្តៅងំ ឆេះទាំងយប់ថ្ងៃ
ខ្លួនពេញកិលេស ស្មើរប្រេះបែកផ្ទៃ ហ៊ានឱ្យតម្លៃ
លោកអស់តណ្ហា ។

បំបាត់ព្រះធម៌ ថាធាតុមិនល្អ ប្រតិកិរិយា
ខ្លួនពុលអំណាច អង់អាចមហិច្ឆតា កាន់ច្បាប់យក្សមារ
លែងស្គាល់សុចរិត ។

ប្រើតែអំណាច សម្លុតកម្លាច គ្មានមេត្តាចិត្ត
បែងចែកសង្គម តូចធំគ្មានក្រិត្យ ឆ្ងាយគ្នាហួសពិត
ជាងមេឃនិងដី ។

គេពោលបន្លំ ថាយើងត្រូវកុំ ប្រកាន់គ្នាអី
កុំថានេះចាស់ កុំថានេះថ្មី បើកសិទ្ធិសេរី
ដូចៗតែគ្នា ។

ថាផ្សេងធ្វើផ្សេង ស្តាប់តែសំឡេង ហាក់ដូចទេព្តា
តែចិត្តទេវទត្ត ប្រាកដដូចខ្លា មានតែហិង្សា
ក្នុងចិត្តប្រក្រតី ។

សម្បូរអាជ្ញា អំណាចផ្តាច់ការ ជាងក្រុងអសុរី
វាយកាប់សម្លាប់ មិនថាប្រុសស្រី ចាស់ក្តីក្មេងក្តី
មានភាពដូចគ្នា ។

ជំឡូងមួយដុំ ដើមស្ពៃមួយគុម្ព ប្រៀបធៀបឧបមា
បាយក្រៀមមួយដៃ តម្លៃស្មើគ្នា ជីវិតប្រជា
ក្នុងសង្គមថ្មី ។

យកវត្តធ្វើគុក អំណាចផ្តាច់មុខ ហោះហើរសេរី
ជនក្រោមអំណាច មិនអាចហាស្តី ដូចគោក្របី
ធ្វើអីតាមចិត្ត ។

ខ្លួនស៊ីតាមឃ្លាន ប្រើគេបំពាន គ្មានក្តីអាណិត
ខ្លួនធាត់ថ្លាថ្លោស គ្នាចុះស្គមស្វិត សម្រុកឥតគិត
ខ្លួនស្រែកតែមាត់ ។

ទោះក្តៅរងា ឈឺគ្រុនគ្រាំគ្រា កុំពោលថាហត់
បើហ៊ានវាចា ចោទថាខ្មាំងក្បត់ នឹងត្រូវពង្រាត់
ទៅលោកដទៃ ។

ឱ្យស៊ីវាល់ចែក ត្រឹមបីកូនវែក ម្ហូបប្រចាំថ្ងៃ
បបររាវៗ ភ្លាវស្មើរសាបប្រៃ អ្នកឈឺរ៉ាំរ៉ៃ
ត្រូវបន្ថយចុះ ។

ឈឺខានធ្វើការ ត្រូវថយអាហារ មិនតាមចំណុះ
គេបែកញើសហូរ ឯងដេកថ្ងូរចុះ ទោះត្រូវបញ្ចុះ
ឱ្យខ្សោយអាហារ ។

ជនមានវ័យចាស់ គេចាត់ប្រើប្រាស់ ដូចគោជរា
ឱ្យទឹកឱ្យស្មៅ ទោះក្តៅរងា មិនសួរនឹកនា
ព្រោះការងារស្រាល ។

អាសូរកុមារ គេឱ្យធ្វើការ ក្នុងព្រៃក្នុងវាល
គ្មានអាវបាំងកាយ ក្របាយរងាល ពេលដេកហាលវាល
រងាឱបដៃ ។

ស៊ីដេកគ្មានស្អាត មាត់ដូចសត្វធាតុ ហួសមនុស្សវិស័យ
សង្កើចមូសខាំ ប្រចាំយប់ថ្ងៃ ក្បាលសុទ្ធហ្វូងចៃ
ធ្ងន់ក្រៃរងកម្ម ។

បើរឿងសិក្សា ក ខ អ អា រាល់ៗតែឆ្នាំ
ពាក្យថាបង្រៀន ប្រែជាលត់ដំ ចិត្តត្រូវក្តៅងំ
និយមហិង្សា ។

ក្មេងតូចស្រែកឃ្លាន បើនាងណាហ៊ាន ឃុំទារអាហារ
នឹងត្រូវទោសទណ្ឌ ទម្ងន់កិច្ចការ ត្រូវបានអាហារ
ក្រោយគេយូរកាល ។

ពាក្យឱ្យរៀនសូត្រ ឮដូចស្លូតបូត គួរត្រេកត្រអាល
តែមិនអប់រំ បន្លំខួរក្បាល ភាពពិតពួកពាល
បោកប្រាស់សម្លាប់ ។

រៀនសូត្រមានន័យ ផ្សេងៗទីទៃ ពិបាកយល់សព្ទ
មួយគឺត្រូវគេ ប្រហារចងចាប់ យកទោសសម្លាប់
ប្រាប់រៀនថ្នាក់លើ ។

ពីរគឺឱ្យស្ដាប់ ពាក្យគេរៀបរាប់ អំនួតសរសើរ
ពីប៉ុល ពតបក្ស ដូចថ្នាក់ជណ្ដើរ ថាមហាប្រសើរ
ខ្ពស់ស្មើមេឃា ។

បីគឺអំណាច សម្លុតកម្លាច ដាក់ការបញ្ជា
ទោះក្ដៅត្រជាក់ គ្រោះថ្នាក់យ៉ាងណា ត្រូវទទួលថា
ប្ដេជ្ញាធ្វើបាន ។

បួនគឺឱ្យស្រែក ជយឃោសន៍ចម្លែក ទះដៃគ្រប់ប្រាណ
ប្ដេជ្ញាជយោ ស្រែកហ៊ោស៊ានៗ អង្គការកល្យាណ
ភ្លឺស្វាងត្រឹមត្រូវ ។

នេះន័យរៀនសូត្រ តាមមើលរហូត គ្មានអ្វីជាផ្លូវ
អប់រំបញ្ញា ឃើញការខុសត្រូវ ឃើញសុទ្ធតែផ្លូវ
សម្លាប់រង្គាល ។

ការឱ្យដេកពេទ្យ បើគិតមួយភ្លែត ហាក់ដូចវិសាល
តែចិត្តពួកពេទ្យ ដូចយមបាល ជំងឺឈឺស្រាល
ដាលទៅជាធ្ងន់ ។ [...]

*(អត្ថបទនេះដកស្រង់ចេញពីស្នាដៃមើលផែនដីខ្មែរ អ្នកនិពន្ធ ជួន មេន ១៩៨០)*

## សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីណា ? ជាបទអ្វី ? ក្នុងសម័យកាលណា ? ឆ្នាំណា ?

២. តើអត្ថបទនេះចែកជាប៉ុន្មានគំនិតសំខាន់ ?

៣. ចូរអ្នក :

ក. ពន្យល់ខ្លឹមសារនៃវគ្គដកស្រង់នីមួយៗនេះ ។

ខ. រកបដិវិធីក្នុងវគ្គដកស្រង់នេះ ។

គ. បង្ហាញពីវិធីចួន ផ្ទួន រណ្តំ ។

| | | |
|---|---|---|
| ផ្គរភរអ្នកស្រែ | មេឃមីរខ្មៅអែ | ហាក់រំលំប្រេះ |
| សង្ឃឹមថាភ្លៀង | មិនទៀងជាផេះ | ក្លាយជាភ្លើងឆេះ |
| | ខ្លោចអស់ព្រឹក្សព្រៃ ។ | |
| ពាក្យដូចទឹកឃ្មុំ | តែចិត្តក្តៅងំ | ឆេះទាំងយប់ថ្ងៃ |
| ខ្លួនពេញកិលេស | ស្មើរប្រេះបែកផ្ទៃ | ហ៊ានឱ្យតម្លៃ |
| | លោកអស់តណ្ហា ។ | |
| បំបាត់ព្រះធម៌ | ថាធាតុមិនល្អ | ប្រតិកិរិយា |
| ខ្លួនពុលអំណាច | អង់អាចមហិច្ឆតា | កាន់ច្បាប់យក្សមារ |
| | លែងស្គាល់សុចរិត ។ | |
| ប្រើតែអំណាច | សម្លុតកម្លាច | គ្មានមេត្តាចិត្ត |
| បែងចែកសង្គម | តូចធំគ្មានក្រិត្យ | ឆ្ងាយគ្នាហួសពិត |
| | ជាងមេឃនិងដី ។ | |

៤. តើអត្ថបទបានឆ្លុះបញ្ចាំងពីវិស័យអ្វីខ្លះនាសម័យកាលនោះ ?

៥. តាមរយៈការសិក្សាអត្ថបទនេះ តើអ្នកឃើញពីស្ថានភាពសង្គមខ្មែរនាសម័យនោះដូចម្តេចខ្លះ ?

៦. ចំពោះអំពើនៃបុគ្គលក្នុងអត្ថបទខាងលើនេះ តើស័ក្តិសមជាបុគ្គលដែលមានមនុស្សធម៌ចំពោះប្រជារាស្ត្រដែរឬទេ ? ហេតុអ្វី ?

# រឿង ជីវិតទុគ៌តជន



ដើម្បីទទួលលទ្ធផលល្អក្នុងការអាន អ្នកគប្បីអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងប្រភេទអក្សរសិល្ប៍ លក្ខណតថៈរបស់រឿង គំនិតសំខាន់បង្កប់ តម្លៃអប់រំ ។

## សំណួរ

១. តើរឿងនេះ ចាត់ទុកជាអក្សរសិល្ប៍ប្រភេទអ្វី ? ចូរបញ្ជាក់ ។

២. ហេតុអ្វីបានជាសមសម្រេចចិត្តឆក់កាបូបពីស្ត្រីរូបនោះ ?

៣. តើអំពើរបស់សមនៅពេលនោះជាអំពើដែលកើតចេញពីឆន្ទៈផ្ទាល់ខ្លួនតែម្តង ឬយ៉ាងណា ? ហេតុអ្វី ?

៤. ដោយផ្អែកទៅលើតថភាពនៃរឿង តើសង្គមនាសម័យកាលនោះ មានលក្ខណៈដូចម្តេចខ្លះ ?

៥. ហេតុដូចម្តេចបានជាអ្នកនិពន្ធពោល "អ្នករត់ទាំងឡាយ គេរត់ប្រណាំងប្រជែងក្លាយករង្វាន់ តែសមរត់ប្រណាំងនឹងការដាច់ពោះស្លាប់" មានន័យដូចម្តេច ?

៦. ចូរបង្ហាញគំនិតអ្នកនិពន្ធតាមរយៈខ្លឹមសារនៃរឿងនេះ ។

# បកស្រាយន័យ សុភាសិត និងពាក្យស្លោក

សុភាសិត គឺជាពាក្យល្អពីរោះមានន័យសេចក្តីគ្រប់គ្រាន់សម្រាប់អប់រំទូន្មានកូនខ្មែរគ្រប់ជំនាន់ ជាពិសេសទាក់ទងជាមួយផ្នែកសីលធម៌រស់នៅប្រចាំថ្ងៃ ការដាស់តឿនក្រើនរំលឹក ការប្រុងប្រយ័ត្ន ចំពោះសត្រូវ ការទទួលយកបទពិសោធពីមនុស្សជំនាន់មុន ពោលគឺសុភាសិតសុទ្ធតែបង្កប់នូវតម្លៃអប់រំគ្រប់ផ្នែកទាំងអស់ក្នុងទិសដៅលើកកម្ពស់តម្លៃមនុស្សនិងតម្លៃជាតិទាំងមូល ។ ចំណែកឯពាក្យស្លោកវិញជាទស្សនៈ ឬគោលគំនិតដែលបានលើកឡើងសម្រាប់ឱ្យអ្នកដទៃយកទៅអនុវត្តក្នុងសង្គមឱ្យមានការរីកចម្រើន ។ ពាក្យស្លោកអាចផុតរលត់ទៅវិញក្នុងករណីសង្គមមានការប្រែប្រួលឬអាចសាបរលាបទៅតាមពេលវេលា ។

ខាងក្រោមនេះ គឺជាសេចក្តីណែនាំសម្រាប់ការពន្យល់បកស្រាយពាក្យស្លោកខ្លះ មិនមានន័យធៀបទេ ។សុភាសិតនិងពាក្យស្លោកដូចជា :

១. ត្រូវស្គាល់ពីប្រភេទសុភាសិតនិងពាក្យស្លោកឱ្យបានច្បាស់លាស់ជាមុនសិន
២. ត្រូវស្គាល់ពីភាពខុសគ្នារវាងសុភាសិតនិងពាក្យស្លោក
៣. ត្រូវស្គាល់អំពីន័យត្រង់ (អត្ថានុរូប)និងន័យធៀប (អត្ថាបដិរូប)របស់សុភាសិតនិងពាក្យស្លោក
៤. អ្នកពន្យល់ត្រូវលើកជាឧទាហរណ៍និងអំណះអំណាងខ្លះយកមកការពារក្នុងការពន្យល់នេះ
៥. ត្រូវចេះពន្លេចឱ្យឃើញពីតម្លៃអប់រំដោយផ្សារភ្ជាប់ជាមួយតម្លៃក្នុងសង្គម ។

*ឧទាហរណ៍ :*

ចូរបកស្រាយអត្ថន័យសុភាសិត "សន្សឹមៗកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា"

## ក. ន័យចំ

ការធ្វើដំណើរដោយយានជំនិះផ្សេងៗ គឺក្នុងបំណងឆ្ពោះទៅរកគោលដៅឱ្យបានឆាប់រហ័ស ។ ប្រសិនបើយើងជិះរទេះគោ យើងតោងបររទេះដេញគោ ក្របីដោយសន្សឹមៗជាធម្មតា ពេលនោះសត្វពាហណៈដែលទឹមនោះវាធូរកម្លាំង រទេះមិនបែកបាក់ ការធ្វើដំណើរពិតជាមានសុវត្ថិភាពទៅដល់គោលដៅ ។

ប្រសិនបើយើងធ្វើដំណើរដោយកង់ គឺយើងធាក់វាដោយសន្សឹមៗ មិនប្រើកម្លាំងខ្លាំងពីដំបូងនាំឱ្យបាក់កំលាំង ឆាប់ហត់ឡើយ ។ ប្រសិនបើយើងប្រឹងប្រួសកម្លាំងពីដំបូងនាំឱ្យហត់បាក់កំលាំង ណាមួយការធាក់លឿននាំឱ្យមានគ្រោះថ្នាក់ដោយប្រការផ្សេងៗ គឺនាំឱ្យយើងយឺតយូរទៅវិញទេ ។

ចំណែកអ្នកជិះយានយន្តដូចជា ម៉ូតូ រថយន្ត... ក៏ត្រូវធ្វើដំណើរដោយសន្សឹមៗដែរ ទើបធ្វើដំណើរទៅដល់គោលដៅដោយសុវត្ថិភាព ។ ប្រសិនបើយើងបើកបរលឿន ឬបង្ខំពេកនាំឱ្យមានគ្រោះថ្នាក់ចរាចរណ៍ មានបញ្ហាសម្រាប់រថយន្ត ខុសច្បាប់ចរាចរណ៍... ។ ពេលនោះ ការធ្វើដំណើររបស់យើងពិតជាមានបញ្ហាមិនអាចទៅដល់គោលដៅបានដូចបំណងឡើយ ។

## ខ. ន័យធៀប

ការសិក្សារៀនសូត្រក៏មិនខុសគ្នានឹងការធ្វើដំណើរដែរ គឺយើងត្រូវខិតខំរៀនសូត្រសន្សំចំណេះវិជ្ជាពីក្មេងម្ដងបន្តិចៗ ទើបសម្រេចគោលដៅក្នុងជីវិតរបស់យើងបាន ។ ចំណែកការសិក្សាក្នុងថ្នាក់ក៏ដូចនេះដែរ គឺយើងត្រូវខិតខំក្រេបយកចំណេះវិជ្ជាតាំងពីដើមឆ្នាំ ឬតាំងពីថ្នាក់តូច មិនមែនជិតដល់ពេលប្រឡងទើបខំប្រឹងនោះទេ ។ រីឯការរកទ្រព្យសម្បត្តិវិញក៏ដូចគ្នាដែរ គឺយើងត្រូវខិតខំសន្សំទ្រព្យបន្តិចម្ដងៗ ទើបមានទ្រព្យសម្បត្តិស្ដុកស្ដម្ភបាន ។ ការលោភលន់ កេងប្រវ័ញ្ច ចង់បាន ចង់មានហួសហេតុពេកនាំឱ្យធ្លាក់ក្នុងអំពើអបាយមុខ ខុសច្បាប់មានគ្រោះថ្នាក់ដល់ជីវិត ។

## លំហាត់

១. ចូរអ្នកជ្រើសរើសនូវឃ្លាខាងក្រោមនេះដោយបញ្ជាក់ថា មួយណាជាសុភាសិតនិងមួយណាជាពាក្យស្លោក ដោយភ្ជាប់ជាមួយនូវការពន្យល់ផង ។

- ត្រីកំភ្លាញស្លាប់ព្រោះមាត់ ខ្មែកងាប់ព្រោះអាចម៍
- ការអប់រំ គឺជាគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

២. ចូរបកស្រាយសុភាសិតខាងក្រោម

- ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក
- ត្រូវដំដែកក្នុងពេលដែកកំពុងក្ដៅ ។

# តែងសេចក្តីបែបពិភាក្សា

អ្នកធ្លាប់បានសិក្សារួចមកហើយអំពីតែងសេចក្ដីបែបពន្យល់ បែបប្រៀបធៀប ពេលនេះអ្នកនឹងបានសិក្សាតែងសេចក្ដីមួយបែបទៀត គឺតែងសេចក្ដីបែបពិភាក្សា ។ តែងសេចក្ដីបែបនេះ តម្រូវឱ្យអ្នកធ្វើតែងសេចក្ដីម្ដងនិយាយស្របតាមប្រធាន ម្ដងនិយាយផ្ទុយឬជំទាស់នឹងប្រធាន ។

ដូចនេះតែងសេចក្ដីពិភាក្សា គឺជាប្រភេទតែងសេចក្ដីមួយបែបដែលតម្រូវឱ្យយើងថ្លឹងថ្លែងពិចារណាលើមតិប្រធាន ដែលក្នុងនោះមាន ៖

- **មតិស្រប** គឺជាមតិដែលយើងពន្យល់ស្របតាមមតិប្រធាន ។
- **មតិផ្ទុយ** គឺជាមតិដែលពន្យល់ជំទាស់ ឬប្រឆាំងនឹងមតិប្រធាន ។
- **ការពិភាក្សា** គឺជាការថ្លឹងថ្លែងវិនិច្ឆ័យរវាងមតិស្របនិងមតិផ្ទុយ ដើម្បីប្រមើលមើលរកចំណុចរួមនិងចំណុចសមហេតុផលនៃមតិនីមួយៗ ។
- **ការសំយោគ** គឺជាការផ្សំមតិរួមគ្នា ឬបំពេញគ្នាទៅវិញទៅមករវាងមតិស្របនិងមតិផ្ទុយ ។

ចូរអ្នកអានខ្លឹមសារសេចក្ដីអធិប្បាយនៃប្រធានបទខាងក្រោមនេះ :

**ប្រធាន** : មានមតិមួយពោលថា "តថភាពនៃទុក្ខវេទនារបស់ក្រុមកំណែន ក្នុងរឿងគូលីកំណែន គ្រាន់តែជាតថភាពមួយនៅក្នុងរឿងតែប៉ុណ្ណោះ ពុំបានផ្ដល់តម្លៃអប់រំដល់អ្នកសិក្សានោះទេ" ។ តើជាការពិតឬទេ ?

ចូរពិភាក្សាដោយរកឧទាហរណ៍ក្នុងរឿងគូលីកំណែនមកបញ្ជាក់ ។

## សេចក្ដីអធិប្បាយ

តួនាទីសំខាន់នៃអក្សរសិល្ប៍ គឺលើកយកតថភាពមកឆ្លុះបញ្ចាំងឱ្យស្របទៅតាមសម័យកាលនីមួយៗទៅតាមសិល្បវិធីរបស់អ្នកនិពន្ធ ។ ជាអាទិនៅក្នុងរឿងគូលីកំណែន អ្នកនិពន្ធក៏បានធ្វើការឆ្លុះបញ្ចាំងពីតថភាពនៃសង្គមខ្មែរនាសម័យអាណានិគមនិយមដែរ ។ ជាមួយនឹងការឆ្លុះបញ្ចាំងនេះនាំឱ្យមានមតិមួយពោលថា "តថភាពនៃទុក្ខវេទនារបស់ក្រុមកំណែន ក្នុងរឿងគូលីកំណែន គ្រាន់តែជាតថភាពមួយនៅក្នុងរឿងតែប៉ុណ្ណោះ ពុំបានផ្ដល់តម្លៃអប់រំដល់អ្នកសិក្សាឡើយ" ។ តើមតិខាងលើនេះត្រឹមត្រូវឬទេ ?

ដើម្បីជាជំនួយក្នុងការបកស្រាយគំនិតប្រធានឱ្យមានអត្ថន័យស៊ីជម្រៅទៅបាន យើងគប្បីស្វែងយល់ន័យនៃពាក្យគន្លឹះប្រធានជាមុន ។ "តថភាព" គឺសំដៅទៅលើការពិតនៅក្នុងសម័យកាលណាមួយដែលអ្នកនិពន្ធបានលើកយកមកធ្វើការឆ្លុះបញ្ចាំង នៅក្នុងស្នាដៃរបស់ខ្លួន ។ រីឯ "ទុក្ខវេទនា" ជាការ

លំបាកគ្រប់យ៉ាងទាំងខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត ។ "ក្រុមកំណែន" ជាក្រុមដែលរាជការនាសម័យអាណានិគមនិយមជប៉ុន បានកេណ្ឌយកទៅធ្វើគូលីនៅការដ្ឋានពោធិចិនតុង ។ ផ្អែកតាមគំនិតប្រធានខាងលើនេះមានន័យថា ការពិតនៃសេចក្ដីលំបាកគ្រប់យ៉ាងរបស់ក្រុមគូលីដែលរាជការអាណានិគមនិយមជប៉ុនបានកេណ្ឌ ហើយមាននៅក្នុងរឿងគូលីកំណែននោះ គ្រាន់តែជាតថភាពមួយនៅក្នុងរឿងតែប៉ុណ្ណោះ ពុំមានផ្ដល់តម្លៃអប់រំចំពោះអ្នកសិក្សាឡើយ ។

ជាការពិតណាស់ បើនិយាយពីរឿងទាំងឡាយដែលឆ្លងកាត់តាមសិល្បរូបារម្មណ៍អ្នកនិពន្ធរួចហើយ ស្នាដៃនោះលែងជាការពិតហើយ ។ ដូចនេះហើយ ទើបក្នុងការលើកយកប្រធានបទនៃទុក្ខលំបាករបស់ក្រុមគូលីកំណែនមកឆ្លុះបញ្ចាំងលែងមានការពិត ព្រោះអ្វីៗគឺអ្នកនិពន្ធបានប្រឌិតទៅតាមអារម្មណ៍ស្រមើស្រមៃរបស់ខ្លួន ។ ជួនកាល ធាតុពិតពុំមានលក្ខណៈដូចក្នុងសាច់រឿងទេ តែដោយអ្នកនិពន្ធចង់ពន្លេចន័យអ្វីមួយដល់អ្នកអាន អ្នកទស្សនា ក៏ខិតខំបំផ្លើសឱ្យហួសពីការពិតទៅវិញ ។ តាមការបង្ហាញទាំងនោះ វាពុំបានផ្ដល់ការអប់រំចំពោះអ្នកសិក្សា អ្នកអានឱ្យមានការតស៊ូ ឬការព្យាយាមរិះរកមធ្យោបាយណាមួយ ដើម្បីរកវិធីដោះស្រាយនោះឡើយ ។ តួយ៉ាងក្នុងរឿងគូលីកំណែន អ្នកនិពន្ធបានផ្ដិតយកតថភាពនៃក្រុមគូលីដែលត្រូវរាជការអាណានិគមនិយមជប៉ុន កេណ្ឌយកទៅធ្វើជាគូលីនៅការដ្ឋានវាលយន្តហោះពោធិចិនតុង បានបង្ហាញពីទុក្ខលំបាកដ៏ធ្ងន់ធ្ងរបំផុត ។ ជាក់ស្ដែងក្នុងដំណើររឿងបានឱ្យដឹងថា ក្រុមកំណែនដែលត្រូវគេកេណ្ឌនោះ ពួកគេមានស្បៀងអាហារមិនសមស្របទៅ តាមកម្លាំងពលកម្ម គឺមានត្រឹមតែ "ដុតប្រហុកត្រីងៀត អាំបិល បុកក្រសាំង អាំពិល" ។ មិនតែប៉ុណ្ណោះ ជុំវិញនៃការគ្រប់គ្រងប្រមូលកំណែននេះ គេឃើញថារាជការបង្គាប់ឱ្យកេណ្ឌតែមួយរយនាក់ក្នុងមួយលើកៗ ប៉ុន្តែមេឃុំផាន់ជាមេឃុំគោកចំបក់បែរជាកេណ្ឌលើសដល់ទៅម្ភៃនាក់ដែលតម្រូវឱ្យទៅលើគ្រួសារណាដែលមានធុរៈធ្ងន់ ។ ប្រសិនបើនរណារឹងទទឹងនឹងបង្គាប់នេះ មេឃុំមានអំណាចណាស់ចាប់ដាក់ខ្នោះ បញ្ជូនទៅសាលាស្រុក ទៅសាលាខេត្តជាដើម ។ វិធីនេះបានធ្វើឱ្យមេឃុំផាន់បានទទួលសំណូកយ៉ាងច្រើន តាមរយៈការរកជួលគូលីជំនួស ដោយបង់ជាប្រាក់ឈ្នួលម្នាក់ៗហាសិបរៀលទៅវិញ ។ ជាមួយគ្នានេះដែរ តាមការនិទានពីតថភាពដែលអ្នកនិពន្ធក្នុងរឿងខាងលើបានបង្ហាញឱ្យឃើញពីភាពទុរគតនៃក្រុមគូលីខ្លះអង្គុយជាសង្កាត់ៗតាមឃុំ ក្បាលមីរនៅផ្ទាល់ដី ។ អ្នកកំណែនទាំងនេះមានលក្ខណៈតោកយ៉ាក ស្លៀកពាក់ខោស្នាប់ភ្លៅលើជង្គង់បំណះយុល មុខក្រៀមអង្គុយឱ្យគេរាប់ក្បាលដូចជាមានទោសប្លន់ ឬទោសលួច ។ ក្នុងតថភាពនេះពុំបានអប់រំដល់អ្នកសិក្សាអ្នកអាន ឱ្យកែប្រែបុគ្គលិកលក្ខណៈខ្លួនឱ្យឈានទៅរកភាពរុងរឿងបានឡើយ ។ នេះបានសេចក្ដីថាអ្វីៗដែលមាននៅក្នុងស្នាដៃនេះ គ្រាន់តែជាការឆ្លុះបញ្ចាំងឱ្យគេមើលឃើញពីព្រឹត្តិការណ៍មួយចំនួនព្រោះពុំមានសញ្ញាណនៃការដាស់តឿនឱ្យមានស្មារតីតស៊ូនោះឡើយ ។ ដោយតួអង្គទាំងអស់គ្រាន់តែ

ធ្វើតាមអ្វីដែលជាតម្រូវការរបស់រាជការក្នុងសង្គមនាសម័យកាលនោះ ដើម្បីបម្រើប្រយោជន៍របស់អាណានិគមនិយមជប៉ុនដែលបម្រើឱ្យយុទ្ធសាស្ត្រសង្គ្រាមប៉ុណ្ណោះ ។

សរុបសេចក្ដីមក តថភាពដែលមាននៅក្នុងរឿងគូលីកំណៃន ហើយនិយាយទាក់ទងទៅនឹងទុក្ខវេទនារបស់ក្រុមគូលីនោះ គឺគ្រាន់តែជាតថភាពមួយនៅក្នុងរឿងពិតប្រាកដមែន ព្រោះមិនអាចផ្ដល់តម្លៃអប់រំដល់អ្នកសិក្សាបានឡើយ ។

តើតថភាពនៃទុក្ខវេទនារបស់ក្រុមកំណែន ក្នុងរឿងគូលីកំណែន គ្រាន់តែជាតថភាពមួយនៅក្នុងរឿងពុំបានផ្ដល់តម្លៃអប់រំមែន ឬយ៉ាងណា ?

ផ្ទុយទៅវិញ បើគេធ្វើការពិនិត្យនិងសង្កេតស្នាដៃអក្សរសិល្ប៍ ពិតជាបានស្គាល់មុខងារសំខាន់ៗរបស់អក្សរសិល្ប៍នឹងឃើញថា អក្សរសិល្ប៍មាននាទីសំខាន់ក្នុងការឆ្លុះបញ្ចាំងពីតថភាពនិងផ្ដល់ការអប់រំ ។ ដូចនេះ ការលើកយកតថភាពនៅក្នុងរឿងគូលីកំណែនបានឱ្យឃើញថា ទំនាស់នៅក្នុងរឿងនោះគឺការគិតតែប្រយោជន៍របស់ពួកក្រុមអ្នកកាន់អំណាចប៉ុណ្ណោះ រីឯប្រយោជន៍ប្រជារាស្ត្រវិញពួកគេពុំបានគិតឡើយដូចជា ការប្រមូលប្រជារាស្ត្រខ្មែរឱ្យទៅធ្វើជាគូលីកំណែន គឺក្នុងបំណងយកទៅសាងសង់វាលយន្តហោះពោធិចិនតុង ដែលបម្រើឱ្យយុទ្ធសាស្ត្រសង្គ្រាមលោកលើកទីមួយ រវាងបារាំងនិងជប៉ុន ។ ជាមួយនោះ គេឃើញមានការកេងប្រវ័ញ្ចតាមរយៈកំណែន ដូចករណីមេឃុំផាន់ដែលបានកេណ្ឌមិនរើសមុខ ។ ទោះបីជាមនុស្សចាស់ជរាដូចជា តាមុយ ក្មេងមិនទាន់ពេញវ័យ មាននាយអ៊ួចឬក៏អ្នកមានជំងឺ គឺអន្ទិត អ៊ិន ក៏ត្រូវជាប់កំណែនរហូតមានអ្នកជំងឺត្រូវស្លាប់នៅការដ្ឋាននោះទៀតផង ។ ទាំងនេះបញ្ជាក់ថា គាត់កេណ្ឌចំពោះគ្រួសារណាដែលមានធុរៈចាំបាច់ដែលត្រូវទទួលបន្ទុកគ្រួសារ ដោយតម្រូវឱ្យបង់លុយជំនួសទៅវិញ បើពួកគេមិនអាចទៅធ្វើកំណែន ។ គំនិតនេះមិនត្រឹមតែធ្វើឱ្យរាស្ត្រខ្មែរសម័យនោះ រងទុក្ខលំបាកដោយសារតែសង្គ្រាមប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យរាស្ត្រខ្មែរត្រូវធ្លាក់ទៅក្នុងទុរគតភាពថែមទៀតផង ។ ដោយសារតែវិបត្តិនេះហើយ ទើបលឹមត្រូវព្រាត់ប្រាសម្ដាយឪពុក គួដល្អឹងដោយការបៀតបៀនពីសំណាក់មេឃុំផាន់និងសង្គ្រាមចក្រពត្តិនោះថែមទៀត ។ ទន្ទឹមនឹងនេះ ស្នាដៃខាងលើក៏បង្ហាញឱ្យឃើញអំពីការបាត់បង់សិទ្ធិសេរីភាពនៃក្រុមគូលីកំណែន ដែលមិនអាចបញ្ចេញមតិ ឬទស្សនៈរបស់ខ្លួនបានឡើយ ។ ឧទាហរណ៍តាមុយ បាននិយាយប្រាប់ដល់ក្រុមគូលីកំណែនជាមុន "តាមិនសូវដឹងទេរឿងនេះ ។ ឯងកុំនិយាយខ្លាំងពេក តិចមេឃុំផាន់ឮ ... ។ និយាយអ្វីៗត្រូវងាកមើលឆ្វេងស្ដាំ ...ប្រយ័ត្ន" ។ ម្យ៉ាងវិញទៀត ក្នុងដំណើររឿងនេះ ក៏បានអប់រំឱ្យយើងមើលឃើញពីកាយវិការរបស់មន្ត្រីក្រោមអាណានិគមនិយមដែលពុំចេះគោរពចាស់ទុំ សំអាងអំណាចបុណ្យសក្ដិរបស់ខ្លួន ដូចជាលោកបាល័ដ្ឋដែលជាអ្នកកាន់ភារៈទទួលកំណែន បានប្រើពាក្យអសុរស ចំពោះមេឃុំនានាដូចជា "អាគោកចំបក់នៅឯណា ? បានគូលីគ្រប់ចំនួនទេ ?" ឬ

"គ្រាន់បើល្អឃើញទេអាកញ្ចាស់ស្វាយ ហេតុអ្វីក៏តាប៊ិងមិនខំកេណ្ឌឱ្យបានដូចអាគោកចំបក់។ ប្រយ័ត្នហួតងារចោល ..."។ ទាំងនេះគឺជាតថភាពដែលសង្គមជាតិយើងស្ថិតនៅក្រោមការត្រួតត្រារបស់ជប៉ុន។ ឯការសាងសង់ព្រលានយន្តហោះពោធិចិនតុង គឺជាយុទ្ធសាស្ត្ររបស់អាណានិគមជប៉ុន។ ទន្ទឹមនេះ យើងមើលឃើញពីទង្វើអមនុស្សធម៌របស់អ្នកអាងបុណ្យសក្តិនិងអំណាចនាសម័យនោះ។

សរុបសេចក្តីមក រឿងគូលីកំណែន បាននិយាយអំពីទុក្ខវេទនារបស់ប្រជាជនជាក្រុមគូលី ដែលតាមពិតរឿងរ៉ាវទាំងនោះបានកើតឡើងនៅក្នុងសង្គមជាតិយើងនាសម័យអាណានិគមជប៉ុន។ នេះជាតថភាពមួយនៅក្នុងរឿង ហើយតាមរយៈតថភាពនេះ អ្នកសិក្សាធ្វើការវាយតម្លៃនិងស្រង់បទពិសោធក៏ដូចជាតម្លៃអប់រំយ៉ាងប្រសើរបំផុត។

ជារួម អ្នកដែលយល់ឃើញថា តថភាពនៃទុក្ខវេទនារបស់ក្រុមកំណែន ក្នុងរឿងគូលីកំណែនគ្រាន់តែជាតថភាពមួយនៅក្នុងរឿង ពុំបានផ្តល់តម្លៃអប់រំដល់អ្នកសិក្សានោះ មិនសមស្របទេ ដោយហេតុថា នៅក្នុងស្នាដៃនីមួយៗអ្នកនិពន្ធតែងផ្តិតយកតថភាពនាសម័យកាលណាមួយមកឆ្លុះបញ្ចាំងដើម្បីផ្តល់ពុទ្ធិនិងការអប់រំតាមរយៈសិល្បវិធីផ្សេងៗ ដែលពេលខ្លះអ្នកអានមួយចំនួនពុំបានយល់ពីបំណងអ្នកនិពន្ធ ដែលនាំឱ្យមានការវិភាគមិនស៊ីជម្រៅទៅលើស្នាដៃ ព្រមទាំងធ្វើឱ្យបាត់តម្លៃស្នាដៃនោះទៀតផង។

ការបកស្រាយខាងលើនេះ បានបង្ហាញឱ្យឃើញថា មតិប្រធានមិនត្រឹមត្រូវទេ ព្រោះជាការមើលរំលងពីមុខងារនៃអក្សរសិល្ប៍ សិល្បៈ ដែលតែងតែផ្សារភ្ជាប់ទៅនឹងតថភាព ដើម្បីអប់រំមនុស្សនិងដើម្បីមនុស្ស។ តែទោះជាយ៉ាងណាក៏ដោយ ក៏គំនិតប្រធានខាងលើនេះ បានញ៉ាំងអ្នកសិក្សាឱ្យវិភាគដោយរកហេតុផលនិងបានស្វែងយល់ពីសិល្បវិធីរបស់អ្នកនិពន្ធ ព្រមទាំងជំរុញឱ្យអ្នកសិក្សាកាន់តែមានទុនថែមទៀតក្នុងការវិភាគស្នាដៃ។

## សំណួរ

១. តើសេចក្តីអធិប្បាយខាងលើនេះ មានប៉ុន្មានផ្នែកធំៗ ?

២. តើសេចក្តីអធិប្បាយនេះ បានបកស្រាយពីប្រធានបទអ្វី ?

៣. ចូរបញ្ជាក់ពីមូលហេតុដែលនាំសំណោរនេះ ប្រើសំនួនស្របនិងប្រើសំនួនបដិសេធ។

៤. តើការប្រើសំនួន "ជារួម" ស្ថិតនៅក្នុងផ្នែកណាមួយនៃសេចក្តីអធិប្បាយ ?

៥. តើរាល់បំណកស្រាយទាំងនោះ មានអំណះអំណាងគាំទ្រដែរឬទេ ? ចូរបញ្ជាក់។

៦. តើកថាខណ្ឌចុងក្រោយ សំដៅទៅលើអ្វី ? តើរបៀបនិយាយយ៉ាងដូចម្តេច ?

៧. ចូរអ្នកធ្វើការកត់សម្គាល់ចុងក្រោយ អំពីប្រធានខាងលើនេះ។

## កំណត់សម្គាល់

- មតិស្របក្តី មតិផ្ទុយក្តី ត្រូវមានអំណះអំណាងគាំទ្រ ។
- ប្រធានតែងសេចក្តីពិភាក្សា ចាំបាច់ត្រូវមានផ្នែកមួយដែលលើកយកមតិស្រប ឬមតិផ្ទុយមកវិនិច្ឆ័យ ឬថ្លឹងថ្លែងជាដាច់ខាត ។
- តែងសេចក្តីពិភាក្សា ជួនកាលមានសំយោគ ប្រសិនបើមតិស្របនិងមតិផ្ទុយបំពេញឱ្យគ្នាទៅវិញទៅមក (សំយោគជាការផ្សំគ្នា) ។
- ចំពោះការពិភាក្សា ដែលត្រូវបដិសេធនូវមតិណាមួយ (មតិស្របឬមតិផ្ទុយ) នោះគ្មានការសំយោគទេ ។
- ដើម្បីធ្វើឱ្យសំណេរតែងសេចក្តីពិភាក្សារបស់អ្នកមានអត្ថន័យគ្រប់គ្រាន់ អ្នកគប្បី :
  - ស្វែងយល់ពីប្រធានបទឱ្យបានច្បាស់លាស់
  - ធ្វើប្លង់ ឬគម្រោង តែងសេចក្តីបែបពិភាក្សាឱ្យបានត្រឹមត្រូវ
  - បកស្រាយគំនិតប្រធានបទឱ្យបានច្បាស់លាស់ មានហេតុផល ឬអំណះអំណាងព្រមទាំងរៀបប្លង់គំនិតក្នុងមតិនីមួយៗ ទៅតាមលំដាប់លំដោយ
  - សរសេរឃ្លាល្បះឱ្យបានច្បាស់លាស់និងត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ ។

## លំហាត់

១. មតិមួយពោលថា "ហំ ប្រព្រឹត្តអំពើមនុស្សឃាតដោយសារតែស្ថានភាពគ្រួសារបង្ខំ" តើអ្នកយល់យ៉ាងណាដែរចំពោះមតិខាងលើនេះ ? ចូរពិភាក្សាដោយលើកឧទាហរណ៍ក្នុងរឿងចៅកែចិត្តចោរមកបង្ហាញ ។

២. សុភាសិតមួយចែងថា "ស្លឹកឈើជ្រុះមិនដែលឆ្ងាយពីគល់" តើអ្នកយល់ដូចម្តេចចំពោះសុភាសិតនេះ ។ ចូរពិភាក្សាដោយលើកឧទាហរណ៍ឬអំណះអំណាងជាក់ស្តែងមកបញ្ជាក់ ។

មេរៀនទី ៩

# អក្សរសិល្ប៍បរទេស



ប្រជាជាតិទាំងអស់នៅលើពិភពលោកនេះ សុទ្ធតែបានរស់នៅលើភពផែនដីក្នុងបរិយាកាសមួយឯកភាពគ្នាក្រោមមេឃតែមួយ ក្រោមពន្លឺព្រះអាទិត្យតែមួយ ។ ដូចនេះយើងទាំងអស់គ្នាតែងបានទទួលឥទ្ធិពល ក្រឹត្យក្រមរួមពីធម្មជាតិនិងសង្គមផងដែរ ។ សកម្មភាពការងារ ការប្រកបរបរចិញ្ចឹមជីវិត ជំនឿសាសនា ទំនៀមទម្លាប់ ប្រពៃណីវប្បធម៌ សឹងមានទំនាក់ទំនងគ្នាជាដរាបរវាងជាតិសាសន៍ ឬប្រទេសនានាលើពិភពលោក ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាពីស្ថានភាពរស់នៅរបស់ប្រជាជន នៃប្រទេសមួយចំនួនលើពិភពលោកពីអតីតកាល ។ ទន្ទឹមនឹងនេះអ្នកក៏បានសិក្សាបន្ថែមទៀតអំពីលក្ខណៈអន្តរជាតិនៃអក្សរសិល្ប៍ ខ្លឹមសារអត្ថបទ អំពីព្យាង្គ ការនិយាយសម្របសម្រួលនិងសំណេរបំពេញលិខិតឯកជន និងលិខិតផ្លូវការមួយចំនួន ។

## រំលឹកបញ្ញត្តិ : ចលនាអក្សរសិល្ប៍

ពុទ្ធសាសនា ជាសាសនាមួយដែលជនជាតិខ្មែរធ្លាប់បានគោរពបូជាតាំងពីបុរាណកាលមកម្ល៉េះ ។ សាសនានេះបានចាក់ឫសយ៉ាងជ្រៅទៅក្នុងផ្នត់គំនិតខ្មែរដូចជាព្រហ្មញ្ញសាសនាដែរ ។ ក្នុងពេលខ្លះព្រះពុទ្ធសាសនាបានរួមចំណែកយ៉ាងខ្លាំងដល់ការកសាងប្រទេសឱ្យរីកចម្រើននិងការពារទឹកដីឱ្យមានអត្ថិភាពថែមទៀត ។ សព្វថ្ងៃនេះ ទោះបីពុទ្ធសាសនាបានជ្រាបចូលក្នុងចិត្តគំនិត ទំនៀមទម្លាប់ប្រពៃណីនៃសង្គមខ្មែរក៏ដោយ ក៏ឥទ្ធិពលនៃសាសនាព្រាហ្មណ៍នៅតែមានលាយឡំនៅក្នុងសន្ដានចិត្តខ្មែរផងដែរ ។ ទន្ទឹមនឹងនោះ ឥទ្ធិពលបរទេសផ្សេងទៀតក៏កំពុងជ្រាបចូលក្នុងសង្គមខ្មែរ ហើយបានជះឥទ្ធិពលមកលើអក្សរសិល្ប៍ខ្មែរយើងទៀតផង ។

### ១ . ចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម

អក្សរសិល្ប៍គោលព្រាហ្មនិយម ឬអក្សរសិល្ប៍បែបព្រាហ្មនិយម គឺជាស្នាដៃអក្សរសិល្ប៍ទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងបែបបទលទ្ធិសាសនាព្រាហ្មណ៍ ។ អក្សរសិល្ប៍បែបនេះបានផ្ដោតជំនឿលើអាទិទេពមានព្រះព្រហ្ម ព្រះឥសូរ ព្រះវិស្ណុ ឬព្រះនារាយណ៍ជាដើម ។ ម្យ៉ាងទៀតគេជឿថាពុទ្ធិទាំងឡាយស្ថិតនៅក្នុងគម្ពីរវេទ ។ តួអង្គសំខាន់ៗ ជាតួអង្គអាទិទេព ឬអវតារ ។

*ឧទាហរណ៍ :* រឿង រាមាយណៈ រឿងមហាភារតយុទ្ធ ... ។

### ២ . ចលនាអក្សរសិល្ប៍ពុទ្ធនិយម

អក្សរសិល្ប៍គោលពុទ្ធនិយម ឬអក្សរសិល្ប៍បែបពុទ្ធនិយម ជាអត្ថបទរឿងរ៉ាវផ្សេងៗដែលទាក់ទងនឹងការលើកយកទ្រឹស្ដីព្រះពុទ្ធសាសនាធ្វើជាគោល ហើយទ្រឹស្ដីទាំងនោះស្ថិតនៅក្នុងគម្ពីរព្រះត្រៃបិដក ដែលអ្នកនិពន្ធលើកយកបញ្ហាបុណ្យ បាប ផលល្អ ផលអាក្រក់របស់តួអង្គមកចោទនិងដោះស្រាយ ។ អក្សរសិល្ប៍បែបពុទ្ធនិយមមានអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធនិងពុទ្ធនិយមក្លាយ ។

*ឧទាហរណ៍ :* រឿង សុវណ្ណសាម ... ។

### ៣ . ចលនាអក្សរសិល្ប៍ខេមរនិយមឬខ្មែរនិយម

គោលនិយមនេះ ប្លែកពីចលនាដទៃទៀតដោយពុំបានយកគោលពីលទ្ធិណា ឬសាសនាណាឡើយ គឺជាការប្រឌិតតាមការណ៍ដែលគេធ្លាប់ឃើញពិតជាក់ស្ដែងក្នុងសង្គមជាតិខ្មែរតែម្ដង ។ បើស្រុកទេសយើងជួបប្រទះនឹងបញ្ហាផ្សេងៗ បញ្ហានោះក៏បានជាការផ្ដួចផ្ដើមគំនិត កកើតជាបញ្ហាក្នុងវប្បធម៌និងសង្គមធម៌ជាតិឡើង ។ ដូច្នេះបញ្ហាដែលកើតឡើងក្នុងគោលនិយមនេះពុំមានភាពអច្ឆរិយៈឡើយ គឺសុទ្ធសឹងតែជាភាពពិតមែនទែនដែលស្របទៅនឹងលោកិយសច្ចៈទាំងស្រុង ។

*ឧទាហរណ៍ :* រឿង ផ្កាស្រពោន រឿង កុលាបប៉ៃលិន រឿង សូផាត ... ។

## ៤ . ចលនាអក្សរសិល្ប៍បរទេសនិយម

គោលនិយមនេះសំដៅដល់គោលគំនិតផ្សេងៗ ដែលពុំស្របតាមលទ្ធិសាសនាព្រាហ្មណ៍ សាសនាព្រះពុទ្ធ ឬជាទំនៀមសុទ្ធសាធរបស់ខ្មែរ ដែលធ្លាប់មានមកនោះទេ ។ ប្រទេសយើងទើបតែមានគោលនិយមនេះកើតឡើងក្នុងពេលដែលប្រទេសខ្មែរត្រូវធ្លាក់ខ្លួនគ្រាំគ្រា ហើយបរទេសនាំយកគោលគំនិតពីស្រុកគេមកផ្សព្វផ្សាយក្នុងប្រទេសយើង ។ គោលនិយមនេះមានឥទ្ធិពលខ្លាំងក្លាណាស់ក្នុងពេលបច្ចុប្បន្ន ព្រោះមនុស្សទូទៅក្នុងសកលលោកច្រើនចូលចិត្តគោលនិយមបែបនេះ ។ សព្វថ្ងៃគេឃើញនៅសល់គោលនិយមនេះជាច្រើនដូចជា ផ្នែកសុជីវធម៌ សំលៀកបំពាក់ សិល្បៈ ការរាំរែក... ។ល ។ ចំណែកឯស្នាដៃអក្សរសិល្ប៍មួយចំនួនក៏ទទួលឥទ្ធិពលនេះដែរ ។

ចលនាអក្សរសិល្ប៍ គឺជាដំណើរប្រែប្រួលនៃអក្សរសិល្ប៍តាមការនិយមនៃវណ្ណៈ ឬស្រទាប់សង្គមលើទ្រឹស្តីទស្សនៈគោលគំនិតណាមួយក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រ ។ គេអាចចែកចលនាអក្សរសិល្ប៍ខ្មែរជាបួនប្រភេទ គឺចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម ពុទ្ធនិយម ខេមរនិយម និងបរទេសនិយម ។

### វិធីតែងនិពន្ធ

វិធីតែងនិពន្ធ គឺការតាក់តែងរឿង ឬរបៀបតាក់តែងរឿង ដែលមានច្រើនប្រភេទដូចជា រឿងបុរាណ រឿងទំនើប ហើយប្រភេទរឿងនីមួយៗមានលក្ខណៈពិសេសដោយឡែកៗពីគ្នាតាំងពីចំណុចផ្តើមរឿង តួរឿង និងការបញ្ចប់រឿង ។

### ក. ការផ្តើមរឿង

អ្នកនិពន្ធសរសេរផ្តើមរឿងដោយបង្ហាញធម្មជាតិត្រង់ណាមួយ តួអង្គ ទំនាស់ ឬសកម្មភាពតួអង្គ ។ល ។ (ភ្ជាប់ទៅនឹងដំណើររឿង)

### ខ. ដំណើររឿង ឬតួរឿង

នៅក្នុងដំណើររឿង អ្នកនិពន្ធបានប្រើវិធីច្រើនយ៉ាង ដើម្បីធ្វើឱ្យដំណើររឿងស្របគ្នាទៅនឹងបញ្ហាចោទ ស្រាយនៅក្នុងរឿង ដោយធ្វើយ៉ាងណាឱ្យសាច់រឿងមានសកម្មភាពប្រទាក់ក្រឡាគ្នា ហើយមានសកម្មភាពរស់រវើក ធ្វើឱ្យអ្នកអាន អ្នកស្តាប់ ទស្សនាជក់ចិត្តជិតអារម្មណ៍ ... ។

### គ. បញ្ចប់រឿង

ជាវិធីដែលអ្នកនិពន្ធសរសេរបញ្ចប់រឿងរបស់ខ្លួនដោយប្រើវិធីច្រើនយ៉ាង ។ ជួនកាលអ្នកនិពន្ធសរសេរបញ្ចប់រឿងដោយឱ្យតួអង្គសំខាន់របស់រឿងរស់ ជួនកាលឱ្យតួអង្គសំខាន់ស្លាប់ ... ។

# លក្ខណៈអន្តរជាតិនៃអក្សរសិល្ប៍

អ្នកបានសិក្សាលក្ខណៈអក្សរសិល្ប៍មួយចំនួនរួចហើយដែលលក្ខណៈនីមួយៗសុទ្ធតែបានឆ្លុះពីបញ្ហាមនុស្ស សង្គមជាតិ និងប្រជាជនដែលមានតាំងពីយូរលង់ណាស់មកហើយ ។ ពេលនេះ យើងនឹងសិក្សាអំពីលក្ខណៈអន្តរជាតិនៃអក្សរសិល្ប៍។ ចូរពិនិត្យអត្ថបទដកស្រង់ "រឿងអង់ទីហ្គូនវីរនារីក្រុងថែប" ។

ស្ថានភាពរឿង : ព្រះអង្គម្ចាស់ប៉ូលីនីសនិងព្រះអង្គម្ចាស់អេតេអុងបានច្បាំងគ្នាដណ្ដើមរាជ្យបល្ល័ង្ក ហើយត្រូវសុគតទាំងពីរព្រះអង្គ។ ស្ដេចក្រេអុងជាម្ចាស់មា ក៏បានគ្រងរាជ្យបន្ត ហើយបានបញ្ជាឱ្យគេបូជាសពស្ដេចអេតេអុងជាប្អូនទៅតាមប្រពៃណីសក្តិសមកិត្តិយសជាវីរជនស្នេហាជាតិ ។ រីឯសាកសពស្ដេចប៉ូលីនីសដែលជាបងត្រូវគេទុកចោលលើវាលខ្សាច់ឱ្យឆ្មាតស៊ី ព្រោះជាជនក្បត់ ហើយបញ្ជាដាច់ខាតចំពោះនរណាម្នាក់ដែលទៅធ្វើពិធីបញ្ចុះសព ឬយំសោក ត្រូវមានទោសប្រហារជីវិត ។ ព្រះនាងអង់ទីហ្គូនជាប្អូនពៅបានធ្វើពិធីស្រោចទឹក បាចដីលើសាកសព ក្នុងបំណងការពារព្រលឹងបងប្រុស ដោយបំពានលើក្រឹត្យច្បាប់ស្ដេចក្រេអុង ដែលជាហេតុធ្វើឱ្យមានសោកនាដកម្មដ៏គួរឱ្យសង្វេគ ។

ឆ្មាំ : សុំជួយមើលចុះ ! នេះហើយអ្នកប្រព្រឹត្តបទឧក្រិដ្ឋដែលគេចាប់បានកំពុងយំលើសាកសព។ ឥឡូវនេះ! ជនឧក្រិដ្ឋបានដល់ដៃព្រះករុណាហើយ សូមព្រះករុណាសួរចម្លើយចុះ !...

ស្ដេចក្រេអុង : ចូរឯងឆ្លើយឱ្យខ្លីមើល៍ ! តើឯងបានដឹងឮពីក្រឹត្យច្បាប់របស់យើងទេ ?

ព្រះនាងអង់ទីហ្គូន : ខ្ញុំដឹង ! បើក្រឹត្យនេះជាក្រឹត្យសាធារណៈ។

ស្ដេចក្រេអុង : ហើយឯងហ៊ានកន្លងក្រឹត្យនេះ ? ឯងឥតអៀនខ្មាសទេឬអី ដែលធ្វើខុសពីគេឯង តែម្នាក់ឯងដូចនេះ ?

ព្រះនាងអង់ទីហ្គូន : បើគ្រាន់តែធ្វើបុណ្យជូនឈាមខ្លួនឯង យើងខ្មាសអ្នកណា ? មានអ្វីទៅគួរឱ្យខ្មាសនោះ ?

ស្ដេចក្រេអុង : តែសពមួយទៀត ! សពជាខ្មាំងរបស់សពដែលឯងបញ្ចុះ ពុំមែនជាបងឯងទេឬ ? ឯងត្រូវដឹង ការអាណិតអាសូរ ប៉ូលីនីសរបស់ឯង វាហាក់បំបែរអេតេអុង ទៅជាអ្នកឧក្រិដ្ឋទៅវិញ ។

ព្រះនាងអង់ទីហ្គូន : រីអ្នកដែលម្ចាស់បងអេតេអុងសម្លាប់ក៏មិនមែនជាទាសករដែរ គឺជាបងរបស់គាត់បង្កើត ។

ស្ដេចក្រេអុង : សត្រូវស្លាប់ទៅក៏នៅតែជាសត្រូវ ! ... គ្មានលេសអ្វីទៀតទេ។ ទោសនេះពេញចិត្តខ្ញុំហើយ ! ... ណ្ហើយ ៗ ! ចុះទៅនរកទៅ ! បើឯងស្រលាញ់ខ្មោចខ្លាំងណាស់នុះ ! ចំណែក

ខ្ញុំស្ដេចក្រេអុង ! ដរាបណាខ្ញុំនៅរស់ដរាបនោះគ្មានមនុស្សស្រីណា មកកែច្បាប់នេះបានជាដាច់ខាត ! ឮទេអង់ទីហ្គូន ? ... នែ ! ពួកឯងចាំពេលណាទៀតឆាប់នាំនាងស្រីទៅ ! កុំភ្លេចយាមឱ្យជាប់ឮទេ ? ហើយបិទផ្នូរឱ្យជិតផង ទុកឱ្យវាអង្គុយចាំខ្មោច បើវាមិនស្លាប់ទេ ក៏ទុកឱ្យវារស់ក្នុងគុកងងឹតបិទជិតនោះចុះ ។ ចំណែកខ្ញុំធ្វើដូច្នេះដៃខ្ញុំវាស្អាតផង ឥតប្រឡាក់ឈាមទៀត ចំពោះស្រីបែបនេះ ។ ស្លាប់ដូច្នេះមិនពិបាកអ្នកណាទៅធ្វើបុណ្យបូជាវាផង ។

ព្រះនាងអង់ទីហ្គូន : ឱ ! ផ្នូរ ! អ្នកជាចេតិយ ជាបន្ទប់ផ្សំដំណេករបស់ខ្ញុំជាមួយស្ពានហាដែស ហើយ ! នេះឬជាគុកក្នុងដីដ៏និរន្តរ៍របស់ខ្ញុំ ? ណ្ហើយ ! ស្លាប់ចុះ ! ស្លាប់ទៅជាជាងរស់នៅក្នុងជ្រោះចំបែង ! ខ្ញុំនឹងបានទៅជួបជុំសាច់ឈាមខ្ញុំហើយ ! ក្ដីសង្ឃឹមតែមួយរបស់ខ្ញុំ គឺវត្តមានខ្ញុំនៅទីនោះនឹងមានតម្លៃបំផុតដល់បិតាខ្ញុំ មាតាសម្លាញ់ខ្ញុំ និងបងប្រុសដ៏កម្សត់របស់ខ្ញុំ៕ ពេលព្រះបិតាព្រះមាតាសុគតទៅបុត្រីបានស្រោចទឹកលាងខ្លួនជូនលោកទាំងពីរ ដោយដៃរបស់បុត្រផ្ទាល់ កូនបានស្លៀកពាក់រុំខ្លួនសពជូនអ្នកទាំងពីរដោយដៃបុត្រផ្ទាល់ កូនបានប្រោះទឹកបាចដីលើផ្នូរព្រះបិតាមាតា ។ ប៉ុន្តែ ! ចុះកម្មអី ! ម្ចាស់បងប៉ូលីនីស មើលចុះ ! ព្រោះតែចង់គោរពតាមច្បាប់ការពារព្រលឹងនៃរូបកាយរបស់ម្ចាស់បង ម្ចាស់បងឃើញទេ ! គេឱ្យប្រាក់ខែខ្ញុំប៉ុន្មាន ? ការពិតខ្ញុំឥតធ្វើខុសសោះ ។ បើសិនរូបខ្ញុំជាម្ដាយមានកូនស្លាប់បែបនេះ ឬក៏ខ្ញុំជាស្ត្រីមានប្ដីស្លាប់បែបនេះ ខ្ញុំក៏ប្រហែលជាមិនហ៊ានកន្លងច្បាប់ម្ចាស់មាក្រេអុង ដើម្បីបង្គ្រប់កិច្ចនេះដែរ ! ប៉ុន្តែ ខ្ញុំគិតដូចម្ដេច ? ខ្ញុំគិតក្នុងចិត្តថា បើខ្ញុំជាស្ត្រីមេម៉ាយ ខ្ញុំគង់តែរកប្ដីបានទៀត ហើយបើកូនខ្ញុំស្លាប់ ប្ដីទីពីរនិងខ្ញុំគង់មានកូនទៀតបាន ។ ប៉ុន្តែ ! បងប្រុស ! បងប្រុសដែលបិតាមាតាខ្ញុំសុគតអស់ទៅហើយនោះ តើអ្នកណានៅលើផែនដីនេះ អាចបង្កើតបងប្រុសឱ្យខ្ញុំបានទៀត ? មើលចុះ តើខ្ញុំបានធ្វើអ្វីខុស ? ហេតុអ្វីក៏ម្ចាស់មាថាខ្ញុំប្រព្រឹត្តបទឧក្រិដ្ឋទៅវិញ ? មើលចុះ ! ព្រះអើយ ! ស្ដេចក្រេអុងចង់ខ្ញុំដាក់គុកងងឹតបិទជិត ជាផ្នូរផ្ដាច់ខ្ញុំពីគូដណ្ដឹងជាទីស្នេហា ! ផ្ដាច់ខ្ញុំពីងារជាម្ដាយរបស់កូនគេ ! ស្ដេចក្រេអុងចាប់ចងខ្ញុំឱ្យនៅឯកោពីមិត្តភក្ដិខ្ញុំ ហើយបញ្ជូនខ្ញុំទៅកប់ទាំងរស់ ។ តើច្បាប់ព្រះឯណាទៅ ដែលបានរំលោភនោះ ? បើសិនជាព្រះអមតៈណាឃើញថាខ្ញុំប្រព្រឹត្តអំពើឧក្រិដ្ឋពិតមែន ខ្ញុំក៏សុខចិត្តនឹងសារភាពដែរ ។ ប៉ុន្តែ ! ប៉ុន្តែ ! ឧក្រិដ្ឋកម្មនេះ វានៅលើដៃអ្នកម្ខាងទៀត គឺអ្នកសម្លាប់ខ្ញុំ ! ...

ទីបញ្ចប់នៃរឿងនេះ ស្ដេចក្រេអុងបានទទួលនូវផលវិនាសកម្ម ដោយបុត្រាហេម៉ុងនិងព្រះមហេសីអឺរីឌីសសម្លាប់ខ្លួនឯង ព្រោះតែច្បាប់របស់ព្រះអង្គ ។ ស្ដេចក្រេអុងមានវិប្បដិសារីនិងទាមទារឱ្យមច្ចុរាជយកជីវិតទ្រង់ទៅផង ។

*(ដកស្រង់និងសម្រួលពីរឿង អង់ទីហ្គូនវីរនារីក្រុងថែប របស់លោក សូហ្វូក្ល)*

រឿងអង់ទីហ្គូននារីក្រុងថែប ឆ្នាំ ៤៤១ មុនគ.ស. របស់លោកសូហ្វូក្លនាសម័យក្រិចបុរាណ ។ ខ្លឹមសាររឿងបានឆ្លុះបញ្ចាំងអំពីឆន្ទៈរបស់អ្នកនិពន្ធដែលយកលក្ខណៈមនុស្សក្រិចបុរាណមកបង្ហាញមនុស្សជំនាន់ក្រោយ ។ ព្រះនាងអង់ទីហ្គូនជាវីរនារីក្រុងថែប បានយកសេចក្ដីស្លាប់ ប្រានច្បាប់ស្ដេចក្រេអុង ដើម្បីការពារសាកសពបងប្រុសបង្កើត ។ ព្រះនាងធ្វើពិធីតាមប្រពៃណីនៃការទុកដាក់សពនោះ តែត្រូវក្រេអុងចោទប្រកាន់ថាក្បត់ជាតិមានទោសឧក្រិដ្ឋ រហូតដល់ធ្វើទារុណកម្មកប់ក្នុងផ្នូរទាំងរស់ ។

តាមការបង្ហាញខាងលើ យើងឃើញថា រឿងអង់ទីហ្គូនបង្ហាញវប្បធម៌ទុកដាក់សពតាមប្រពៃណីរបស់ជាតិក្រិច ។ ម្យ៉ាងទៀត រឿងនេះក៏បានឆ្លុះបញ្ចាំងពីមនោសញ្ចេតនាបងប្អូន ពីច្បាប់ផ្ដាច់ការ ជាពិសេសចរិតមានះរបស់អ្នកដឹកនាំដែលមានលក្ខណៈរើសអើងភេទ ។

សរុបមក រឿងអង់ទីហ្គូនរបស់សូហ្វូក្លជាស្នាដៃមួយ ដែលបានពាំនាំវប្បធម៌ក្រិច ចូលជ្រាបយ៉ាងជ្រៅនៅប្រទេសអឺរ៉ុប ។ ស្រមោលនៃវប្បធម៌ក្រិចបាននាំអារម្មណ៍យើងឱ្យពិចារណាលើតម្លៃជីវិតមនុស្ស លើមនោសញ្ចេតនា និងលើការគិតរបស់មនុស្ស ។ វប្បធម៌ក្រិចជាមាតាមួយនៃវប្បធម៌អឺរ៉ុប ។

ដូច្នេះ រឿងអង់ទីហ្គូន ជាអក្សរសិល្ប៍ដែលមានតម្លៃសម្រាប់ជាតិរបស់ខ្លួន ពេញលក្ខណៈ ហើយក៏ជាអក្សរសិល្ប៍ដែលមនុស្សទូទៅនៅអឺរ៉ុបទទួលស្គាល់ ព្រមទាំងមានតម្លៃរហូតដល់សម័យកាលបច្ចុប្បន្ន ។ រឿងនេះត្រូវបានផ្សព្វផ្សាយពាសពេញពិភពលោក ហើយត្រូវបានគេប្រែជាភាសាផ្សេងៗ នៅបណ្ដាប្រទេសដទៃទៀត ។

*អក្សរសិល្ប៍មានលក្ខណៈអន្តរជាតិ ជាស្នាដៃដែលមានលក្ខណៈជាតិរួចជាស្រេចទៅហើយ នៅពេលដែលសង្គមជាតិបានទទួលស្គាល់ថា ជាអត្ថបទមានតម្លៃ ទ្រទ្រង់វប្បធម៌ អរិយធម៌របស់ជាតិ ។ បន្ទាប់មកបរទេសគេយកទៅសិក្សាផ្សព្វផ្សាយនៅក្នុងសង្គមជាតិរបស់គេ គឺនៅពេលនោះហើយដែលអក្សរសិល្ប៍មានលក្ខណៈសកល គឺលក្ខណៈអន្តរជាតិ ។*

## លំហាត់

១. ចូរបង្ហាញថា រឿងទុំទាវ មានលក្ខណៈអន្តរជាតិ ។

២. តើចំណុចណាខ្លះដែលបញ្ជាក់ថា រឿងអាប៉ាកុងមានលក្ខណៈជាអក្សរសិល្ប៍សកលឬលក្ខណៈអន្តរជាតិ ?

# អាពាហ៍ពិពាហ៍ខុងជី



## ក. សិក្សាពាក្យគន្លឹះ

- ស្រូវភោជន៍សាលី (បា) (ន) : ឈ្មោះស្រូវវិសេសពួក ដែលមានគ្រាប់មូលទ្រវែងជាងគ្រាប់ស្រូវធម្មតា នៅខាងចុងគ្រាប់មានព្រុយវែង ។ ម្សៅភោជន៍សាលីនៅអឺរ៉ុបគេយកទៅធ្វើនំប៉័ង ។
- ទាសី (ន) (បា. សំ) : ខ្ញុំបម្រើស្រី ។
- អភិជន (ន) (បា) : មនុស្សខ្ពង់ខ្ពស់ ។
- មេកន្ទ្រាញ (ន) : មេកុលសម្ព័ន្ធ អ្នកត្រួតត្រាកុលសម្ព័ន្ធ ។
- ទស្សនវិទូ (ន) (បា) : អ្នកប្រាជ្ញខាងទស្សនវិជ្ជា ។
- ទេពកោសល្យ(ន) : ការប៉ិនប្រសប់ ឈ្លាសវៃដូចទេវតា ។
- ទិដ្ឋភាព (ន) (បា) : ភាពនៃអ្វីៗដែលគេបានឃើញ បានប្រទះមកហើយ បែបភាព ឬដំណើរទំនងនៃវត្ថុដែលហុចហេតុផលមកឱ្យឃើញ ។
- នាឡិ (នា. លិ) (ន) : ទម្ងន់ ១៦តម្លឹង ឬ៦ខាំ ។ រង្វាស់តូចមួយប្រភេទសម្រាប់វាល់អង្ករ ឬវាល់គ្រាប់អ្វីៗ មានគ្រាប់សណ្ដែកបាយជាដើម ។
- តម្រា (ន) : សេចក្ដីត្រាទុក រឿងដែលកត់ទុកដោយសង្ខេប ក្បួនតូច ។
- ក្រសោវ (កិ) : ឈោងចាប់ប្រមូល ដោយដៃទាំងពីរ ។
- ឆន្ទៈ (ន) : សេចក្ដីប្រាថ្នា បំណង គំនិត យល់ព្រម ... ។
- កាតព្វកិច្ច (ន) : កិច្ចដែលគួរធ្វើ ការងារដែលត្រូវតែធ្វើ ។
- ភេត្រា (ន) : សំពៅ ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរដែលទាក់ទងទៅនឹង សង្គមបរិយាកាស វិភាគតួអង្គ អត្ថន័យនៃការធ្វើគុណ និងការជួញដូរមនុស្ស ។

## គ. អត្ថបទ

នៅតាមទន្លេលឿង គេឃើញទូកនេសាទជាច្រើនដឹកនាំទាសីល្អៗនិងភោជន៍សាលី តម្រង់ទៅស្រុកហាន់កូវ ។ នាយភេត្រាជាមនុស្សឃោរឃៅ ប្រៀបបាននឹងខ្លាភ្នំ ហើយតែងដឹកជញ្ជូនកំណាត់សំពត់សូត្រ យកទៅដូរឱ្យអ្នករស់នៅតាមភូមិភាគខាងជើង ។ ពួកគេដឹកនាំយកមកវិញនូវភោគទ្រព្យដ៏មានតម្លៃដូចជា ស្បែកសត្វ រោមសត្វចចាតជាដើម ។ ជួនកាលគេទិញទាសីល្អៗមកពីភូមិភាគខាងជើង ដើម្បីយកទៅលក់ឱ្យត្រកូលលោកម្ចាស់គ្រប់ស្រុក ។

មកដល់ស្រុកលូ ឈ្មួញសំពៅទាំងនោះដឹកជញ្ជូនភោគទ្រព្យដ៏មានតម្លៃជាច្រើន ហើយបញ្ជាឱ្យគេដឹកនាំយកទៅលើគោក ។ ក្នុងចំណោមទំនិញទាំងនោះមាន អាវធ្វើពីរោមសត្វចចាត ព្រមទាំងស្បែកសត្វចតុបាទដ៏ល្អៗ ដែលគេពន្លាត់យកតែស្បែកដឹកជញ្ជូនតាមរទេះ បន្តកន្ទុយគ្នាហូរហែជាក្បួនគួរចាប់អារម្មណ៍យ៉ាងក្រៃលែង ។ ពួកស្រីៗត្រូវគេបង្គាប់ឱ្យតែងខ្លួន ព្រមទាំងលម្អដោយគ្រឿងអលង្ការដ៏មានតម្លៃ ស្លៀកពាក់ដោយកំណាត់សំពត់ភ្លឺផ្លេក ។

នៅក្នុងវិមានលោកម្ចាស់លូ ឈ្មួញគ្រប់គ្នាបានត្រូវម្ចាស់ផ្ទះបង្គាប់ឱ្យរៀបចំពិធីជប់លៀងយ៉ាងអធិកអធម ។ បន្ទាប់មក គេបានបញ្ចេញទាសីល្អៗ ពីក្នុងបន្ទប់យកមកបង្ហាញទស្សនិកជនដែលជាត្រកូលអភិជនម្នាក់ម្តងៗ ។ ពេលនោះ ខុងជឺត្រូវថៅហ្វាយរបស់គាត់បញ្ជាឱ្យទៅជញ្ជូនស្នែងសត្វប្រើសតំបន់ទឹកកកចេញពីសំពៅ ។ ទស្សនវិទូកំលោះក្នុងវ័យម្ភៃឆ្នាំ មានកម្លាំងមាំមួន ប្រកបដោយអវយវៈតាន់ដូចដែក ។ អ្នកនិពន្ធ លីវូធី បានពោល ៖ "ខុងជឺ មានមាឌខ្ពស់ស្រឡះ ជើងដៃមាំដូចឪពុករបស់ខ្លួន តែមានសភាពស្លូតបូតដូចអ្នកបួស ។ ក្នុងមួយថ្ងៃគាត់អាចដើរបានមួយរយគីឡូម៉ែត្រដោយអត់មានហត់ ឬអស់កម្លាំងអ្វីឡើយ" ។ លោក ហ៊ុង យូឡាន់ បានពោល ៖ "ខុងជឺ ជាគ្រូទស្សនវិជ្ជាផង ជាគ្រូពេទ្យព្យាបាលជំងឺផង ។ ក្បួនវេជ្ជសាស្ត្រជាទេពកោសល្យដែលម្តាយរបស់គាត់បានបង្ហាត់បង្រៀន ព្រោះជីតាខាងម្តាយរបស់គាត់ជាគ្រូពេទ្យជនបទយ៉ាងចំណានម្នាក់មានក្បួនតម្រាថ្នាំនិងក្បួនទស្សន៍ទាយ ទុកជាមរតកឱ្យកូនស្រីគាត់ ដែលជាម្តាយរបស់ខុងជឺតាំងតែពីកូនរបស់គាត់ធ្វើដំណើរតាមប្តីមកស្រុកចាន់តុង" ។

នៅពេលលោកម្ចាស់លួបញ្ជាឱ្យខុងជីទៅយាមសំពៅនោះ ខុងជីបានឮសូរសំឡេងច្រវាក់អូស ក្រោកក្រាកនៅក្នុងបាតសំពៅ លាយឡំនឹងសំណើចក្អាកក្អាយរបស់ពួកនាវិក ដែលកំពុងស៊ីផឹក សប្បាយនៅក្នុងទីនោះដែរ ។ ពេលនោះខុងជីបានចុះទៅមើលហេតុការណ៍ពិតនៅក្នុងបាតសំពៅ ។ ទស្សនវិទូនេះបានឃើញទិដ្ឋភាពមួយគួរឱ្យរំភើបញ្ជាប់ញ័រក្នុងចិត្តក្រៃលែង ។ គេឃើញមនុស្សបួនប្រាំ នាក់កំពុងស៊ីផឹកស្រវឹង ស្រែកច្រៀងឡូឡាអ៊ឹងអាប់ ខុងជីក៏បានឃើញស្រីម្នាក់មុខជាំខ្មៅ អាក្រាត នៅខ្លួនទទេ មានច្រវាក់ជាប់អវយវៈទាំងសងខាង ។ ខុងជីសួរតាចាស់ដែលជាអ្នកបោសសំអាត នៅបាតសំពៅពីបុព្វហេតុដ៏គួរឱ្យសង្វេគនេះ ឯតាក៏និយាយប្រាប់ ៖ "ស្រីនេះជាតិម៉ុងហ្គោលី ចៅហ្វាយយើងទិញមកជាតម្លៃអំបិល ១០នាឡិ ។ ដំបូងវាមានមុខមាត់ស្អាតបាតដូចស្រីក្រមុំនៅហាន់ ចូវទាំងឡាយ ។ តែក្រោយមកស្រីនេះបែរជាឆ្កួតវង្វេងអត់ដឹងអី ចេះតែយំនិងសើច និយាយផ្ដេស ផ្ដាស ។ គេយកបាវស្រូវឱ្យវាស្លៀកពាក់ ព្រោះវាតែងដេកនឿលនៅជិតចង្ក្រានបាយ ហើយគេ យកវាទៅដាក់ច្រវាក់ដៃជើង ព្រោះខ្លាចវាវើរបស់ទ្រព្យ ឬបំផ្លាញឆ្នាំងបាយនិងពាងទឹកដែលគេដាក់ ជិតវា!" ។ ពេលនោះ ខុងជីចូលទៅយកសំលៀកបំពាក់មួយសម្រាប់មកបិទបាំងរាងកាយអាក្រាត របស់នារីអភ័ព្វនោះ ។ កាយវិការនេះធ្វើឱ្យនាយភេត្រាផ្ទុះសំណើច ហើយប្រាប់អភិជនលួថា ក្មេង កំលោះនេះ សុភាពគួររាប់អាន ហើយនាយសំពៅនិយាយទៀត ៖ "បើឯងចង់បានប្រពន្ធ អញនឹងឱ្យ ស្រីម្នាក់ធ្វើជាប្រពន្ធ ។ ចូរឯងរើសតាមចំណង់ចិត្តចុះ !" ។ ខុងជី ថ្លែងអំណរគុណដល់នាយសំពៅ ហើយក៏ចុះទៅបាតនាវា ដោះលែងស្រីខ្មៅដែលជាប់ច្រវាក់នោះចេញមកក្រៅ ។ ខុងជីបាននាំនាងមក បង្ហាញនាយភេត្រា រួចពោល ៖ "បើលោកម្ចាស់ចង់ធ្វើអំណោយប្រពន្ធដល់ខ្ញុំ ខ្ញុំសូមស្រីល្អម្នាក់នេះ យកទៅរៀបការនៅពេលពីរបីថ្ងៃខាងមុខនេះ !" ។ សំដីខុងជីធ្វើឱ្យគេសើចគ្រប់ៗគ្នា ។ ខុងជី ក៏នាំស្ត្រី ជាតិម៉ុងហ្គោលនោះទៅឱ្យម្ដាយខ្លួនព្យាបាល ។

ម្ដាយខុងជីខិតខំស្រាវជ្រាវតម្រាថ្នាំយកមកពិនិត្យ ដើម្បីព្យាបាលជំងឺនាងក្រមុំម៉ុងហ្គោលនេះ ។ កន្លះខែមកហើយដែលម្ដាយខុងជី បានជ្រើសរើសថ្នាំផ្សេងៗជាច្រើនមុខ ដើម្បីព្យាបាលសុខភាពនិងមុខ មាត់របស់យុវតីនេះ ។ ប៉ុន្តែជាការឥតប្រយោជន៍ ព្រោះក្បួនថ្នាំឫសឈើ ដែលមានក្នុងមហាគម្ពីរ ចាំងគ្មានប្រសិទ្ធភាពក្នុងការធ្វើមុខមាត់យុវតីនេះឱ្យល្អដូចដើមវិញឡើយ ។ ដោយអស់ចំណេះ ខុងជី បានជួយណែនាំនាងឱ្យចេះធ្វើកិច្ចការទូទៅដូចស្រីៗឯទៀតក្នុងស្រុក មានរវៃអំបោះ ក្រសាវសូត្រ និង រៀបចំទុកដាក់ប្រដាប់ប្រដានៅក្នុងផ្ទះជាដើម ។

ពេលយប់ខុងជី តែងបង្រៀននាងឱ្យចេះនិយាយភាសាចិនក្នុងស្រុក ព្រមទាំងបង្ហាត់ឱ្យចេះអាន អក្សរថែមទៀត ។ ពេលណាខុងជីសង្កេតឃើញនាងមានទុក្ខព្រួយ នាយតែងនាំនាងដើរលេងកម្សាន្ត

តាមជើងភ្នំ បង្ហាត់នាងឱ្យច្រៀងឬសូត្រកំណាព្យដែលខុងជឺបាននិពន្ធខ្លួនឯង នៅពេលទំនេរម្តងៗ ។ ប៉ុន្តែ នៅថ្ងៃមួយ ស្រីជាតិម៉ុងហ្គោលនេះបានលួចសេះមួយរបស់ខុងជឺ ហើយបំផាយយ៉ាងលឿនតម្រង់ទៅភ្នំទឹកកកប៉ែកអាគ្នេយ៍ស្រុកចាន់តុងដោយគ្មានទុកដំណឹងអ្វីបន្តិចសោះដល់គ្រួសារខុងជឺ ។ ខុងជឺតែងគិតថាអំពើដែលខ្លួនគាត់ធ្វើទាំងអំបាលម៉ាន ជាការសង្គ្រោះមួយដែល "សីលធម៌សកលជំរុញនូវឆន្ទៈមនុស្សឱ្យដើរទៅរកមាគ៌ាល្អូតលាស់ខាងផ្លូវចិត្តសាស្ត្រ" ។ ខុងជឺបានទន្ទេញ ៖ "ធ្វើគុណទៅហើយ បើគេតបគុណមកវិញ ចាត់ទុកដូចជាពុំបានធ្វើគុណ ! ធ្វើគុណទៅហើយ ត្រលប់បានផលអាក្រក់វិញ ត្រូវទទួលយកការពិសោធដោយដៃពីរ ! ធ្វើគុណទៅហើយ បើវារលាយសាបសូន្យទៅត្រូវបន្តការធ្វើគុណទៅទៀតប្រៀបដូចត្រី បើវាចឹកនុយអស់ហើយ គេត្រូវយកសន្ទូចមកបិទនុយថែមទៀត !" ។

រាត្រីមួយ នៅពេលម្តាយនិងកូនកំពុងគិតពិចារណាពីកាតព្វកិច្ចដែលគេត្រូវអនុវត្តក្នុងថ្ងៃមុខ នៅក្រៅផ្ទះ ព្រិលក៏បានរុះរោយយ៉ាងខ្លាំង ។ ម្នាក់ៗអង្គុយកម្តាភ្លើងចង្ក្រាន ដែលគេនាំគ្នាបង្កាត់ក្នុងឡនៃគេហដ្ឋានខ្លួន ។ ខុងជឺឮសូរសំឡេងជើងសេះ ប្រហែលជប់បានមកឈប់នៅមុខផ្ទះគេ ។ បន្ទាប់មកស្នូរគោះទ្វារបន្ទាន់ និងសំឡេងដ៏ស្រួយស្រែសរបស់ស្ត្រីម្នាក់បន្លឺឡើង ។ ម្តាយខុងជឺបានស្គាល់សំឡេងនេះច្បាស់ណាស់ គឺនាងជាកូនស្រីមេកន្ទ្រាញភ្នំម្នាក់ជាតិម៉ុងហ្គោល ។ ក្នុងពេលពួកឈ្មួញលួចចាប់យកមក យុវតីនេះបានលេបថ្នាំម្យ៉ាងបំផ្លាញសម្ផស្ស ។ ដោយកញ្ញាម៉ុងហ្គោលជាប់ចិត្តនឹងគ្រួសារខុងជឺព្រមទាំងរូបខុងជឺផង នាងក៏បានលួចរត់ទៅស្រុកខ្លួនវិញ ដើម្បីព្យាបាលមុខមាត់ឱ្យជាដូចដើម ។

*(ដកស្រង់និងកែសម្រួលចេញពីទស្សនវិជ្ជា ខុងជឺ សុខសុត្ថាល ១៩៧២)*

## សំណួរ

១. តាមរយៈអត្ថបទនេះ តើសង្គមសម័យខុងជឺជាសង្គមយ៉ាងដូចម្តេច ?

២. ហេតុអ្វីបានជាខុងជឺ ជ្រើសរើសនារីអ្នកទោសធ្វើជាភរិយា ? តើខុងជឺជាមនុស្សដូចម្តេច ?

៣. ចូរបកស្រាយវាចាខុងជឺ ៖

ក. ធ្វើគុណទៅហើយ បើគេតបគុណមកវិញចាត់ទុកដូចជាពុំបានធ្វើគុណ ។

ខ. ធ្វើគុណទៅហើយ ត្រឡប់បានជាផលអាក្រក់មកវិញត្រូវទទួលយកការពិសោធដោយដៃពីរ ។

គ. ធ្វើគុណទៅហើយ បើវារលាយសូន្យទៅ ត្រូវបន្តការធ្វើគុណទៅទៀត ប្រៀបដូចត្រី បើវាចឹកនុយអស់ហើយ គេត្រូវយកសន្ទូចបិទនុយថែមទៀត ។

៤. តើសព្វថ្ងៃ ការជួញដូរមនុស្សនៅមានឬទេ ? តើអ្នកយល់ថាគួរធ្វើដូចម្តេចដើម្បីបំបាត់អំពើបែបនេះ ?

# អំពីព្យាង្គ (សទ្ទក្នុងព្យាង្គ)

អ្នកបានសិក្សាអំពីការបន្លឺសំឡេង ស្រៈ ព្យញ្ជនៈរួចហើយ ។ ស្រៈនិងព្យញ្ជនៈ ជាសទ្ទដែលតូចបំផុតផ្សំគ្នា ធ្វើឱ្យកើតទៅជាព្យាង្គ ។ ដូចម្ដេចដែលហៅថាព្យាង្គ ?

## ១ . ព្យាង្គ

ចូរពិនិត្យល្បះខាងក្រោម ៖

ឧទាហរណ៍ : តើយើងទុកសាច់ឈាមយើងឱ្យត្មាតស៊ីបានទេ ? (ស្រង់ពីរឿងអង់ទីហ្គូន)

ឧទាហរណ៍ខាងលើបញ្ជាក់ថា :

- សូរ " តើ " កើតមកពីព្យញ្ជនៈ [ត] ផ្សំនឹងស្រៈ [◌ើ] ។
- សូរ " ត្មាត " កើតមកពីព្យញ្ជនៈ [ត្ម] ផ្សំនឹងស្រៈ [◌ា] ហើយប្រកបនឹង [ត] ។

គឺថា [តើ] < [ត] + [◌ើ]

[ត្មាត] < [ត្ម] + [◌ា] + [ត]

សូរដែលបន្លឺឡើងដូចជា " តើ ត្មាត " ហៅថាព្យាង្គ ។

ព្យាង្គមានទម្រង់ដូចខាងក្រោម :

- ពស : គោ ស
- ពសព : ទឹក កក
- ពពស : ស្ពៃ ខ្មៅ
- ពពសព : ក្រឹត្យ ក្រម

*ព្យាង្គ គឺសូររួមនៃសទ្ទដែលបន្លឺឡើងតែមួយបន្សាយសំឡេង ។*

## ២ . សទ្ទនៅក្នុងព្យាង្គ

ព្យាង្គនីមួយៗមាន សទ្ទដើមព្យាង្គ សទ្ទកណ្ដាលព្យាង្គ និងសទ្ទចុងព្យាង្គ ។

### ក. សទ្ទដើមព្យាង្គ

- សទ្ទទោល ទម្រង់ "ពស ឬ ពសព"

*ឧទាហរណ៍ :* ជីក ជី ដាំ ដូង ។

ជីក < [ជ] + [◌ី] + [ក]

ដី < [ដ] + [□ី]

ដូចនេះ [ជ] [ដ] ជាសទ្ទដើមព្យាង្គ។

- សទ្ទផ្សំ ទម្រង់ "ពពស ឬ ពពសព"

*ឧទាហរណ៍ :* ប្រឹង ប្រែង ព្រម គ្នា។

ប្រឹង < [ប្រ] + [□ឹ] + [ង]

គ្នា < [គ្ន] + [□ា]

ដូចនេះ [ប្រ] [គ្ន] ជាសទ្ទដើមព្យាង្គ។

*សម្គាល់* : សូរព្យញ្ជនៈទាំងអស់អាចប្រើជាព្យញ្ជនៈដើមព្យាង្គ។ សូរព្យញ្ជនៈផ្សំទាំងអស់អាចប្រើជាព្យញ្ជនៈដើមព្យាង្គដែរ។

## ខ. សទ្ទកណ្ដាលព្យាង្គ

- សូរស្រៈក្នុងទម្រង់ "ពសព ឬពពសព"

*ឧទាហរណ៍ :* កូនប្រើស។

កូន < [ក] + [□ូ] + [ន]

ប្រើស < [ប្រ] + [□ើ] + [ស]

ដូច្នេះស្រៈ [□ើ] [□ូ] ជាសទ្ទកណ្ដាលព្យាង្គ។

## គ. សទ្ទចុងព្យាង្គ អាចជាសូរស្រៈ ឬសូរព្យញ្ជនៈ

- សូរស្រៈក្នុងទម្រង់ : "ពស ឬ ពពស"

*ឧទាហរណ៍ :* គោ ស៊ី ស្មៅ។

គោ < [គ] + [□ោ]

ស្មៅ < [ស្ម] + [□ៅ]

ដូច្នេះ ស្រៈ [□ោ] [□ៅ] ជាសទ្ទចុងព្យាង្គ។

- សូរព្យញ្ជនៈក្នុងទម្រង់ "ពសព ឬ ពពសព"

*ឧទាហរណ៍ :* ស្លៀក ពាក់ ខោ អាវ។

ស្លៀក < [ស្ល] + [□ៀ] + [ក]

អាវ < [អ] + [□ា] + [វ]

ដូច្នេះ ព្យញ្ជនៈ [ក] [វ] ជាសទ្ទចុងព្យាង្គ។

## លំហាត់

១. ដូចម្ដេចដែលហៅថាព្យាង្គ ? ចូររកឧទាហរណ៍បញ្ជាក់ ។

២. ចូរស្រង់ព្យាង្គពីក្នុងល្បះនេះ "កង្កែបច្រៀងលេងសប្បាយ ពេលភ្លៀងរលឹម" ។

៣. ចូររកពាក្យទាំងនេះ "គោ មេ មួយ នឹម ភ្នួរ ស្រែ ស្ទូង ស្រូវ" ដែលជា :

- សទ្ទដើមព្យាង្គ
- សទ្ទកណ្ដាលព្យាង្គ
- សទ្ទចុងព្យាង្គ

៤. ចូរជ្រើសរើសព្យាង្គទោលដែលមានសទ្ទដើមព្យាង្គ សទ្ទកណ្ដាលព្យាង្គ និងសទ្ទចុងព្យាង្គពីក្នុងល្បះខាងក្រោមឱ្យបានពីរ ក្នុងទម្រង់នីមួយៗ :

[...] នៅក្នុងវិមានលោកម្ចាស់លូ ឈ្នួញគ្រប់គ្នាបានត្រូវម្ចាស់ផ្ទះបង្គាប់ឱ្យរៀបចំពិធីជប់លៀងយ៉ាងអធិកអធម ។ បន្ទាប់មក គេបានបញ្ចេញទាសីល្អៗ ពីក្នុងបន្ទប់យកមកបង្ហាញទស្សនិកជនដែលជាត្រកូលអភិជនម្នាក់ម្ដងៗ ។ ពេលនោះ ឌុងជីត្រូវចៅហ្វាយរបស់គាត់បញ្ជាឱ្យទៅជញ្ជូនស្នែងសត្វប្រើសតំបន់ទឹកកកចេញពីសំពៅ ។ ទស្សនវិទូកំលោះក្នុងវ័យម្ភៃឆ្នាំ មានកម្លាំងមាំមួន ប្រកបដោយអវយវៈតាន់ដូចដែក ។ អ្នកនិពន្ធ លីវូធី បានពោល ៖ "ឌុងជី មានមាឌខ្ពស់ស្រឡះ ជើងដៃមាំដូចឪពុករបស់ខ្លួន តែមានសភាពស្លូតបូតដូចអ្នកបួស ។ ក្នុងមួយថ្ងៃគាត់អាចដើរបានមួយរយគីឡូម៉ែត្រដោយអត់មានហត់ ឬអស់កម្លាំងអ្វីឡើយ" ។ លោក ហ៊ុង យូឡាន់ បានពោល ៖ "ឌុងជី ជាគ្រូទស្សនវិជ្ជាផង ជាគ្រូពេទ្យព្យាបាលជំងឺផង ។ ក្បួនវេជ្ជសាស្ត្រជាទេពកោសល្យដែលម្ដាយរបស់គាត់បានបង្ហាត់បង្រៀន ព្រោះជីតាខាងម្ដាយរបស់គាត់ជាគ្រូពេទ្យជនបទយ៉ាងចំណានម្នាក់មានក្បួនតម្រាថ្នាំនិងក្បួនទស្សន៍ទាយ ទុកជាមរតកឱ្យកូនស្រីគាត់ ដែលជាម្ដាយរបស់ឌុងជីតាំងតែពីកូនរបស់គាត់រៀងដំណើរតាមប្ដីមកស្រុកចាន់តុង" ។ [...]

# កិត្តិយស ឬស្នេហា



## ក. សិក្សាពាក្យគន្លឹះ

- កិត្តិគុណ (ន) : គុណ គឺកេរ្តិ៍ឈ្មោះ សេចក្តីចម្រើនដោយកេរ្តិ៍ឈ្មោះពីរោះពិសា ។
- ចេតនា (ន) : គំនិតដែលនាំចិត្តឱ្យភ្ញាក ឱ្យផ្ដួចគិត ។
- ជិនណាយ (កិ) : ទ្រាន់ចិត្ត រសាយចិត្ត ទាល់ចិត្ត ថយចំណង់ ធុញទ្រាន់ ។
- ផ្តន្ទា (កិ) : ផ្ដាល ធ្វើទោសផ្ដាល បន់ឱ្យគេវិនាស ។
- វឱស្មាន (ន) : សេចក្តីហ្មងឆ្គង ឬមោះហ្មង មោះមៃដែលនាំឱ្យក្ដៅក្រហាយ ស្អុះស្អាប់ បែកចិត្តគំនិត ឬបែកឃ្លាតចាកទី ចាកលំនៅ ។
- ទោសឧក្រិដ្ឋ (ន) : ទោសធ្ងន់ កំហុសធ្ងន់ ។
- ភពត្រ័យ (ន) : ភពទាំងបី ទីសម្រាប់កើត ។
- កាមតណ្ហា (ន) : ចំណង់ចំពោះកាម សេចក្តីប្រាថ្នាក្នុងកាម ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរដែលទាក់ទងនឹងសង្គមបរិយាកាស វិភាគតួអង្គ សង្ខេបអត្ថបទ លក្ខណៈអក្សរសិល្ប៍ កាព្យវិធី ... ។

## គ. អត្ថបទ

ស្ថានភាពរឿង : សតវត្សទី ១១ នៅទីក្រុងសេវី ប្រទេសអេស្ប៉ាញ រ៉ូឌ្រិចនិងនាងស៊ីម៉ែនជាគូសង្សារនឹងគ្នា តែអាស្រ័យដោយទំនាស់រវាងឪពុកនិងឪពុក បានធ្វើឱ្យសេចក្ដីស្នេហារបស់អ្នកទាំងពីរជួបឧបសគ្គ ។ ឪពុកនាងស៊ីម៉ែនបានទះកំផ្លៀងឪពុករ៉ូឌ្រិច ។ រ៉ូឌ្រិចសងសឹកជួសឪពុកដោយសម្លាប់ឪពុកនាងស៊ីម៉ែន ។ នាងស៊ីម៉ែនទាមទារកាត់ក្បាលឃាតករ តែក្នុងបេះដូងនាងនៅតែស្រឡាញ់រ៉ូឌ្រិចដដែល ។ រ៉ូឌ្រិចអស់សង្ឃឹម យប់មួយបានបង្ហាញខ្លួននៅចំពោះមុខនាងស៊ីម៉ែន ... ។

### ឈុតទី៣

ដុងសង់ចូលសុំខ្លួនតាមសងសឹកជួសនាងស៊ីម៉ែន តែនាងមិនព្រម ។ នាងបានប្រាប់អិលវៀរថានាងនៅស្រលាញ់រ៉ូឌ្រិចនោះជានិច្ច ស្រាប់តែពេលនេះរ៉ូឌ្រិចចូលមកអង្វរឱ្យនាងផ្ដាច់ជីវិតខ្លួន ឯនាងក៏បានបង្ហើយពាក្យថានាងនៅស្រលាញ់ជារាល់ថ្ងៃ ។ ...

### ឆាកទី៤

| | | | |
|---|---|---|---|
| រ៉ូឌ្រិច | : | នែស៊ីម៉ែន ឈប់គិតវែង ពីរឿងក្ដី | បើនាងស្រី ចង់រក្សា ការថ្លៃថ្នូរ |
| | | ផ្ដាច់ជីវិត បងទៅចុះ កុំទុកយូរ | ជាគំរូ ដល់នារី នៅក្នុងលោក ។ |
| ស៊ីម៉ែន | : | ឱអិលវៀរ ! មើលនរណា ! ស្លាប់ខ្ញុំហើយ | ពុទ្ធោអើយ អ្នកណាហៅរ៉ូឌ្រិចមក |
| | | ខ្ញុំគ្មាននឹក គ្មានត្រូវការ គ្មាននឹកភ្នក ។ | |
| រ៉ូឌ្រិច | : | បងខំមក រកស៊ីម៉ែន នឹងសុំទោស | |
| | | កុំបន្ត នាំបង្ក ហេតុឱ្យធំ | អាណិតខ្ញុំ ខ្ញុំទទួលនូវកំហុស ។ |
| ស៊ីម៉ែន | : | បើខ្ញុំលាក់ការសងសឹកខ្ញុំនឹងខុស | នឹងខ្មាសអស់បណ្ដាជនគេគ្រប់គ្នា ។ |
| រ៉ូឌ្រិច | : | អូនព្រលឹង កុំអាលខឹង ច្រឡោតតូង | |
| ស៊ីម៉ែន | : | មិនបាច់បង មកនិយាយ កែដោះសា | ចេញទៅចុះ ទុកឱ្យខ្ញុំ យំសោកា |
| រ៉ូឌ្រិច | : | ឱ ! ស្នេហា បងសូមថ្លែង តែបួនម៉ាត់ ។ | |
| | | លុះបងឈប់ និយាយចប់ ក្នុងពេលណា | សូមជីវ៉ា កាន់ដាវកាប់ ក-បងម៉ាត់ |
| | | យកជីវិត បងទៅចុះ ឱ្យឆ្ងាយបាត់ | ទើបបានស្ងាត់ សមចិត្តអូន កំពុងខឹង ។ |

ស៊ីម៉ែន : ដាវដែលកាប់ ដកឱ្យឆាប់ ពីចក្ខុ　　ឈាមឪពុក បានជិតជាប់ លើដាវហ្នឹង
មិនចង់ឃើញ មិនចង់យល់ មិនចង់ដឹង

រ៉ូឌ្រិច : អូនសម្លឹង មើលឱ្យជាក់ សិននារី ។
ឱ្យកំហឹង អូនរឹតរឹង ខ្លាំងឥតប្រៀប　　ដុតឆុរឆៀប រីករោលរាល ដូចអគ្គី
ទុកឱ្យបង រឹតតែធ្ងន់ ដូចធរណី　　អូនជីវី កាប់បងមក កុំទុកនៅ ។
លាងឈាមនាង ក្នុងឈាមបង ទើបបានជ្រះ　　ឱ្យស្រឡះ ច្បាស់ប្រាកដ ណាអូនពៅ

ស៊ីម៉ែន : ឱ! ដកដាវ ចេញឱ្យ ឆាប់បាត់ភ្លាមទៅ　　កុំទុកនៅ នាំតែខ្ញុំ មួម៉ៅចិត្ត ។

រ៉ូឌ្រិច : បងស៊ូរង តាមបំណង អូនសោភី　　ដៃទាំងពីរ សូមឱ្យអូន ផ្តាច់ជីវិត
បំពេញកិច្ច សម្លាប់បង កុំអាណិត　　កុំនឹកគិត ដល់ស្នេហា យើងសោះឡើយ ។
ឪអូនខឹង ចិត្តអាក្រក់ គួរឱ្យស្អប់　　មកទះតប់ ឪពុកបង ចាស់ទៅហើយ
អូនដឹងទេ ឪពុកបង ខឹងពុំស្បើយ　　ហេតុនេះ ហើយបានជាបងចេញវ៉ាប់រង ។
តែម្តេចម្តា អូនស្នេហា ចាំឱ្យជាក់　　ថាក្តីស្ម័គ្រ ចិត្តមេត្រី របស់បង
នៅដូចដើម គ្មានវៀចវេរ ពីនួនល្អង　　ឬកន្លង ឆ្លងឱ្យផុត ពីអូនឡើយ ។
ទោះស្នេហា ធំប៉ុណ្ណា ក៏ចិត្តបង　　ត្រូវចេញស្នង ជំនួសឪ ឱ្យបានល្ហើយ
បំណាច់កើត ជាកូនប្រុសប៉ុណ្ណោះហើយ　　មិនព្រងើយ ឱ្យគ្រួសារ អាប់រស្មី ។
បងមិនចង់ ឱ្យអូនថា បងមនុស្សភ្លើ　　គេជាន់លើ គ្របសង្កត់ បាត់ក្នុងដី
គ្មានហ៊ានងើប ក្អកមួយម៉ាត់ ព្រោះតែស្រី　　ទុកតម្លៃ ឱ្យគ្រួសារ អន់ថោកថយ ។
ឪពុកអូន ជីវិតសូន្យ ព្រោះរូបបង　　ត្រូវអូនប៉ង សងសឹកជួស កុំឱ្យធ្លោយ
ទុកជាស្រី មានល្បីឈ្មោះ ដល់ជាន់ក្រោយ　　ហុចកឱ្យ ឱ្យតែអូន ចាក់បងមក ។
អូនស៊ីម៉ែន ត្រូវក្លាហាន លាងឈាមឪ　　ដែលស្លាប់ទៅ ត្រូវតែអូន ខំលៃលក
ខំឱ្យល្បី សមជាស្រី គ្រប់លក្ខណា　　ខំស្វែងរក កិត្តិគុណ សងគ្រួសារ ។

ស៊ីម៉ែន : ទោះជាខ្ញុំ សត្រូវធំ នឹងរ៉ូឌ្រិច　　តែគំនិត ខ្ញុំឥតគិត មានផ្គន្ធា
ខ្ញុំស៊ូយំ ទ្រាំកើតទុក្ខ តែឯកា　　ព្រោះដឹងថា នេះជាកិច្ច របស់បង ។
ករណីយកិច្ច បងរ៉ូឌ្រិក យ៉ាងក្លាហាន　　កិច្ចបងបាន ឈ្នះសងសឹក ដូចបំណង
កិច្ចបងបាន មកបង្រៀន ដល់ខ្ញុំផង　　ដោយរូបបង សមជាប្រុស ស្គាល់គ្រួសារ ។
ខាងខ្ញុំវិញ កិច្ចបំពេញ ក៏ដូចបង　　ត្រូវតែស្នង ល្បងជំនួស លោកបិតា
ឥឡូវនេះ អស់សង្ឃឹម ក្តីស្នេហា　　ចិត្តចេតនា ទាំងប៉ុន្មាន ក៏រលាយ ។
បើក្រៅរឿង ដែលកើតឡើង ស្លាប់ឪខ្ញុំ　　ប្រហែលសម ខ្ញុំនឹងបង នៅសប្បាយ

ចិត្តស្នេហា នៅចាំជាក់ ឥតជិនណាយ គ្មានប្រែក្លាយ ដូចបានដៃ ជូតភ្នែកខ្ញុំ ។
ការសងសឹក ត្រូវតែធ្វើ លើស្នេហា ខ្ញុំយល់ថា បើអស់អ្នក ខ្ញុំខាតធំ
ករណីយកិច្ច យ៉ាងអាក្រក់ មកបង្ខំ ធ្វើឱ្យខ្ញុំ ចង់រំលាយ ជីវិតអ្នក ។
បើដូច្នេះ ត្រូវលែងលះ ពីក្ដីស្នេហ៍ ខ្ញុំដឹងដែរ បេះដូងបង នៅជំពាក់
ឯរូបខ្ញុំ ចិត្តស្នេហា នៅចាំជាក់ លើរូបអ្នក ដែលខ្ញុំផ្សង ជាយូរហើយ ។
បងរ៉ូឌ្រិច បំពេញកិច្ច យ៉ាងពេញលេញ បានបញ្ចេញ សមចិត្តប្អូន ពុំកន្តើយ
ឯខ្ញុំវិញ ក៏ដូចគ្នា គ្មានខុសឡើយ តែបងអើយ ខ្ញុំធ្វើនេះ តម្រូវបង ។

រ៉ូឌ្រិច : ចាំឱ្យច្បាស់ កុំក្រឡះ ចង់ផ្លាស់ប្ដូរ ការថ្លៃថ្នូរ បានបង្ខំ ចិត្តនួនល្អង
ឱ្យសម្លាប់ កាប់ក្បាលខ្ញុំ កុំខ្លាចហ្មង ឯរូបបង ក៏សុខចិត្ត ឥតមានស្ដាយ ។
កុំទុកនៅ អូនធ្វើទៅ កុំខ្លាចចិត្ត ផ្ដាច់ជីវិត សមរូបបង ត្រេកសប្បាយ
កុំទុកយូរ រកខុសត្រូវនាំវែងឆ្ងាយ អាចរលាយ សងសឹកអូន លើទោសបង ។
បើជីវិត បងដាច់ប៉ិត ស្លាប់រហ័ស ត្រេកអរណាស់ ស្លាប់ដោយដៃអូននួនល្អង

ស៊ីម៉ែន : នែរ៉ូឌ្រិច បងទោចុះ ឈប់សាសង ខ្ញុំនេះហោង មិនមែនអ្នក ពិឃាតទេ ។
តើចិត្តខ្ញុំ ហ៊ានចូលស៊ុំ ជីវិតឬ ? ខ្ញុំធ្វើនេះ ត្រូវតែបង ខំរិះរេ
ការសងសឹក ត្រូវតែគិត រក្សាកេរ្តិ៍ ក៏ប៉ុន្តែ ចិត្តខ្ញុំគ្មាន ផ្ដន្ទាបង ។

រ៉ូឌ្រិច : ឯស្នេហា លើដីវ៉ា នៅជានិច្ច ដោយកលកិច្ច ចិត្តអូនឯង ក៏ព្រមផង
អូនស៊ីម៉ែន ចាំឱ្យជាក់ ពាក្យប្រុសបង ល្អកន្លង គួរត្រងត្រាប់ ចាប់យកទុក ។
នែអូនស្រី មិនត្រូវខ្ចី ដៃឯណា មកប្រហារ ជីវិតបង សងឪពុក
ត្រូវដៃអូន ចេញខ្លួនឯង ឱ្យសមមុខ ទើបជ្រះទុក្ខ ដូចកាលបង សងសឹកនោះ ។

ស៊ីម៉ែន: ខ្ញុំមិនអាច យកអំណាច នេះទៅល្បង អាងតែបង មានកម្លាំង ធ្វើទៅចុះ
បើខ្ញុំធ្វើ តាមគំរូ នេះនឹងខុស ឈ្នះប៉ុណ្ណោះ មិនស្មើទុក្ខ ខ្ញុំទេបង ។
ស្ដាប់ឱ្យច្បាស់ ពិតតែឈ្នះ ដូចប្រាថ្នា ត្រូវដឹងថា ឪខ្ញុំទៀត ក៏គ្មានប៉ង
ចង់ផ្ដន្ទា ក្ដីស្នេហា របស់បង

រ៉ូឌ្រិច : ឱ! នួនល្អង ត្រូវតែគិត ។

ស៊ីម៉ែន : លែងនឹកនា ពីស្នេហា យើងទៀតទៅ

រ៉ូឌ្រិច : កិច្ចនេះត្រូវ តែអូនស្ងួន នាងសម្លាប់ លឿនឡើងអូន ផ្ដាច់ជីវិត បងឱ្យឆាប់
បងនឹងប្រាប់ ឱ្យអូនដឹង យល់មិនខាន ។
សប្បាយចិត្ត ឥតបើគិត ដោយបានក្ស័យ ស្លាប់ដោយដៃ ទន់ត្រជាក់ អូនកល្យាណ
ជាជាងរស់ នៅលើដី នាំរំខាន រឱស្ឋាន ដល់រូបអូន ជាសត្រូវ ។

ស៊ីម៉ែន : ខ្ញុំឥតខ្ពើម ស្អប់រអើម បងសោះឡើយ    អើល្មមហើយ ខ្ញុំអង្វរ សូមចេញទៅ

រ៉ូមេ៉អូ : ម្ដេចមិនផ្ញើ ឬអូនខ្លាច ពាក្យអាស្រូវ    អូនផ្ញើទៅ ព្រោះទោសបង ដល់ឧក្រិដ្ឋ ។
លែងរវល់ ឈប់គិតខ្វល់ រឿងស្នេហា    ព្រែងគេថា បងមកនេះ បង្ខំចិត្ត
ឱ្យអូនស្ញៀម លែងប្ដឹងផ្ដល់ ឈប់នឹកគិត    ទោសឧក្រិដ្ឋ ត្រូវតែអូន សម្លាប់បង ។

ស៊ីម៉ែន : ឥតបានការ នឹងប្រហារ ជីវិតនោះ    ទុកឱ្យរស់ លើភពត្រ័យ នៅខ្វាប់ខ្លួន
សូមចេញទៅ នៅនាំក្ដៅ មួម៉ៅចិត្ត    តែអាណិត សូមបងដើរ ប្រយ័ត្នខ្លួន
ព្រែងគេឃើញ គេដៀលត្មះ មកដល់ប្អូន ។

រ៉ូមេ៉អូ : ស្លាប់ហើយស្ងួន !

ស៊ីម៉ែន : ចេញទៅបង !

រ៉ូមេ៉អូ : អូនគិតម្ដេច ?

ស៊ីម៉ែន : ទោះស្នេហា ធំយ៉ាងណា មកលាយឡំ    ត្រូវតែខំ តាមសងសឹក ឥតមានភ្លេច
តែម្ដេចម្ដា ការដែលខំ គិតមកស្រេច    បន់ជានិច្ច ឱ្យកិច្ចនោះ បាត់រលាយ ។

រ៉ូមេ៉អូ : កាមតណ្ហា !

ស៊ីម៉ែន: ទោះយ៉ាងណា ក៏ទុក្ខធ្ងន់

រ៉ូមេ៉អូ : ទុក្ខយើងស្ងួន ព្រោះតែឪ ទាំងពីរកាយ

ស៊ីម៉ែន : ជ័យមង្គល ជិតសម្រេច ប្រែបែកខ្ចាយ

រ៉ូមេ៉អូ : អន្តរាយ ដូចខ្យល់ព្យុះ វាយកំទេច

ស៊ីម៉ែន: ឈឺផ្សាពេក

រ៉ូមេ៉អូ : ស្ដាយអនេក អស់រំពឹង

ស៊ីម៉ែន : ចុះស៊ូប្រឹង និយាយអ្វី ក៏មិនស្រេច

រ៉ូមេ៉អូ : បងសូមលា ជាអវសាន បញ្ចប់កិច្ច    បងមិនភ្លេច ចាំទទួល សងសឹកអូន

ស៊ីម៉ែន : អញ្ជើញចុះ កុំអាឡោះ ណាប្រុសថ្លៃ    កុំអាល័យ ស្រមៃនឹក មកដល់ប្អូន
តែខ្ញុំផ្ដាំ សូមឱ្យបង រក្សាខ្លួន    សូមជឿអូន ថាចិត្តខ្ញុំ ត្រង់នឹងបង ។

អិលវៀរ : ហៃអ្នកនាង ទុក្ខតែងមាន ជាធម្មតា    រាល់រូបា ចៀសមិនផុត ពីទុក្ខហោង

ស៊ីម៉ែន : ទុក្ខខ្ញុំនេះ ទុក្ខធ្ងន់ក្រៃ ពេកកន្លង    ឈប់សាសង ទុកឱ្យខ្ញុំ យំឯកា ។...

*(ដកស្រង់ពីរឿង កិត្តិយស ឬស្នេហាដែលប្រែសំរួលជាភាសាខ្មែរដោយលោកអាន-យុន ឆ្នាំ ១៩៥៤)*

## សំណួរ

១. តើអត្ថបទនេះជាអត្ថបទប្រភេទណា ? ដកស្រង់ពីណា ? ស្ថិតនៅឈុតទីប៉ុន្មាន ? ឆាកទីប៉ុន្មាន ? មានតួអង្គណាខ្លះ ?

២. តើអត្ថបទដកស្រង់នេះស្ថិតក្នុងសង្គមបរិយាកាសបែបណា ?

៣. ចូរវិភាគតួអង្គ ដុងរ៉ូឌ្រិចនិងស៊ីម៉ែន ។

៤. តើចំណុចណាខ្លះដែលបញ្ជាក់ថា អត្ថបទនេះមានលក្ខណៈជាអក្សរសិល្ប៍សកល ?

៥. ចូរសង្ខេបវគ្គដកស្រង់ខាងក្រោមឱ្យទៅជាពាក្យរាយ ។

រ៉ូឌ្រិច : នែស៊ីម៉ែន ឈប់គិតវែង ពីរឿងក្ដី បើនាងស្រី ចង់រក្សា ការថ្លៃថ្នូរ
ផ្ដាច់ជីវិត បងទៅចុះ កុំទុកយូរ ជាគំរូ ដល់នារី នៅក្នុងលោក ។

ស៊ីម៉ែន : ឱអិលវៀរ ! មើលនរណា ! ស្លាប់ខ្ញុំហើយ ពុទ្ធោអើយ អ្នកណាហៅរ៉ូឌ្រិចមក
ខ្ញុំគ្មាននឹក គ្មានត្រូវការ គ្មាននឹកភ្នក ។

រ៉ូឌ្រិច : បងខំមក រកស៊ីម៉ែន នឹងសុំទោស
កុំបន្ត នាំបង្ក ហេតុឱ្យធំ អាណិតខ្ញុំ ខ្ញុំទទួលនូវកំហុស ។

ស៊ីម៉ែន : បើខ្ញុំលាក់ការសងសឹកខ្ញុំនឹងខុស នឹងខ្មាសអស់បណ្ដាជនគេគ្រប់គ្នា ។

រ៉ូឌ្រិច : អូនព្រលឹង កុំអាលខឹង ច្រឡោតតូង

ស៊ីម៉ែន : មិនបាច់បង មកនិយាយ កែដោះសា ចេញទៅចុះ ទុកឱ្យខ្ញុំ យំសោកា

រ៉ូឌ្រិច : ឱ ! ស្នេហា បងសូមថ្លែង តែបួនម៉ាត់ ។
លុះបងឈប់ និយាយចប់ ក្នុងពេលណា សូមជីវ៉ា កាន់ដាវកាប់ ក-បងម៉ាត់
យកជីវិត បងទៅចុះ ឱ្យឆ្វាយបាត់ ទើបបានស្ងាត់ សមចិត្តអូន កំពុងខឹង ។

ស៊ីម៉ែន : ដាវដែលកាប់ ដកឱ្យឆាប់ ពីចក្ខុ ឈាមឪពុក បានជិតជាប់ លើដាវហ្នឹង
មិនចង់ឃើញ មិនចង់យល់ មិនចង់ដឹង

រ៉ូឌ្រិច : អូនសម្លឹង មើលឱ្យជាក់ សិននារី ។
ឱ្យកំហឹង អូនរឹតរឹង ខ្លាំងឥតប្រៀប ដុតឆុរឆៀប រីករោលរាល ដូចអគ្គី
ទុកឱ្យបង រឹតតែធ្ងន់ ដូចធរណី អូនជីវី កាប់បងមក កុំទុកនៅ ។
លាងឈាមនាង ក្នុងឈាមបង ទើបបានជ្រះ ឱ្យស្រឡះ ច្បាស់ប្រាកដ ណាអូនពៅ

ស៊ីម៉ែន : ឱ ! ដកដាវ ចេញឱ្យ ឆាប់បាត់ភ្លាមទៅ កុំទុកនៅ នាំតែខ្ញុំ មួម៉ៅចិត្ត ។ [...]

# អាប៉ាកុងបាត់ហិបប្រាក់



ពេលស្ដាប់អត្ថបទដកស្រង់ "អាប៉ាកុងបាត់ហិបប្រាក់" ចូរអ្នកកត់ចំណាំចំណុចសំខាន់ៗដើម្បីឆ្លើយសំណួរខាងក្រោម ៖

១. តើអត្ថបទនេះស្រង់ចេញពីរឿងអ្វី ? ឈុតទីប៉ុន្មាន ?

២. តើអ្នកនិពន្ធរឿងនេះឈ្មោះអ្វី ?

៣. ចូររាប់ឈ្មោះតួអង្គនិងប្រាប់មុខងាររបស់តួអង្គនីមួយៗផង ។

៤. ចូរវិភាគតួអង្គ អាប៉ាកុងតាមរយៈអត្ថបទដកស្រង់នេះ ។

៥. តើមនុស្សកំណាញ់មានសកម្មភាពនិងចរិតលក្ខណៈដូចម្ដេចខ្លះ ? វិធីណាខ្លះដែលអាចជួយកាត់បន្ថយភាពកំណាញ់របស់មនុស្សកំណាញ់ ?



# ការនិយាយសម្របសម្រួលក្នុងពិធីសំខាន់ៗ

អ្នកបានសិក្សាអំពីការនិយាយបញ្ចេញមតិវាយតម្លៃតួអង្គ ការនិយាយបញ្ចេញមតិផ្ទាល់ខ្លួនចំពោះជំនឿផ្សេងៗ ការនិយាយប្រៀបធៀប ការនិយាយបញ្ចុះបញ្ចូលអូសទាញ ... ពីមេរៀនមុនរួចហើយ ។ ឥឡូវអ្នកនឹងសិក្សាអំពីការនិយាយសម្របសម្រួលបន្ថែមទៀត ។

ការនិយាយសម្របសម្រួល គឺជាការនិយាយឱ្យបានស្របស្រួលចិត្តគំនិតឱ្យអែបស្របគ្នាប្រកបដោយភាពរលូន ។ អ្នកសម្របសម្រួល គឺជាអ្នកនិយាយដោយធ្វើយ៉ាងណា ឱ្យពិធីប្រព្រឹត្តទៅប្រកបដោយភាពស្របស្រួលនិងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក ។

ការសម្របសម្រួលគេសង្កេតឃើញមានសកម្មភាពពីរ ៖

- ការចូលរួមស្តាប់នៃសមាជិកម្នាក់ៗ ក្នុងក្រុម
- ការចូលរួម ដោយមានសមាជិកប្តូរមតិ បទពិសោធ ចំណេះដឹងជាមួយសមាជិកក្នុងក្រុម ។

តាមរយៈការបង្ហាញខាងលើ យើងអាចនិយាយបានថា អ្នកសម្របសម្រួលក៏ជាអ្នកលើកទឹកចិត្តចំពោះសកម្មភាព ដែលអនុវត្តទៅតាមផែនការនៃកិច្ចពិភាក្សាក្រុម ។ អ្នកសម្របសម្រួលក៏ជាអ្នកគ្រប់គ្រងដឹកនាំ ចាត់តាំងសមាជិកក្នុងក្រុមដើម្បីឱ្យដឹងថា ការងារក្រុមឱ្យសម្រេចវត្ថុបំណងដោយរបៀបណា ។ ប៉ុន្តែអ្នកសម្របសម្រួល គឺធ្វើជាអ្នកអាជ្ញាកណ្តាល មិនប្រាប់អំពីខ្លឹមសារថា តើត្រូវធ្វើយ៉ាងណាជាក់ស្តែងទេ ។

អ្នកសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ជាអ្នកបង្កើតបរិយាកាសមួយ ដែលលើកទឹកចិត្តឱ្យសមាជិកក្នុងក្រុមពិភាក្សាបញ្ចេញយោបល់និងបង្ហាញបទពិសោធរបស់គេ ។

ការសម្របសម្រួលបានទទួលជោគជ័យ គឺអាស្រ័យលើគុណសម្បត្តិរបស់អ្នកសម្របសម្រួល ។

ដូច្នេះអ្នកសម្របសម្រួលត្រូវមានសមត្ថភាពដូចខាងក្រោម ៖

១. ផ្នែកចំណេះដឹង គឺចេះធ្វើផែនការ ចាត់ចែងកម្មវិធី ប៉ិនប្រសប់ខាងការទាក់ទង និងចេះធ្វើយ៉ាងណាឱ្យការងារក្រុមមានប្រសិទ្ធភាព ។

២. ផ្នែកឥរិយាបថ គឺមានអធ្យាស្រ័យនិងគោរពសិទ្ធិសមាជិក ដោយចាត់ទុកថាការខុសឆ្គង ជាបទពិសោធសម្រាប់កែលម្អ ។ មិនតក់ក្រហល់ ព្រមទាំងគោរពពេលវេលាដោយភាពហ្មត់ចត់ ។

៣. បំណិន គឺមានភាពប៉ិនប្រសប់ក្នុងការគ្រប់គ្រងក្រុមបង្កើតបរិយាកាសរីករាយ ស្និទ្ធស្នាល ព្រមទាំងមានសមត្ថភាពបញ្ចប់ការងារដោយជោគជ័យ ។

*ឧទាហរណ៍ :* បញ្ចៀសទំនាស់ ទប់ស្កាត់ការសើចចំអក និយាយអាក្រក់ពីគ្នាក្នុងពេលបំពេញការងារក្នុងពិធី ។

ខាងក្រោមនេះជាបំណិនសម្របសម្រួលមួយចំនួន :

## ក. ការប្រើពាក្យសំដី

- **សំនួនទូទៅ**
  - សូមអធ្យាស្រ័យ ខ្ញុំបាទ/នាងខ្ញុំសូមជួយបន្ថែមត្រង់ចំណុចនេះ ..................................
  - ក្នុងនាមអ្នកសម្របសម្រួល ខ្ញុំបាទ/នាងខ្ញុំសូមរំឭកថា ..........................................
  - ជាការសមស្របហើយ ! ប្រសិនបើយើង(អស់លោក ...) ធ្វើការពិចារណាតទៅទៀត ...
  - មិនថ្វីទេត្រង់ចំណុចនេះ ! ព្រោះបើតាមរបៀបវារៈអង្គប្រជុំថ្ងៃនេះ ..........................
  - ក្នុងនាមអ្នកសម្របសម្រួល ខ្ញុំបាទ/នាងខ្ញុំ សូមឱ្យអង្គពិធី (អង្គប្រជុំ ...) មេត្តាងាកមករកប្រធានបទខាងដើម ហើយសូមមេត្តាសមាជិកឡើងបញ្ចេញយោបល់ ......................
  - ..................................................................................................,,,,....
- **សំនួនយល់ព្រម**
  - គំនិតនេះពិតជាត្រឹមត្រូវ ...
  - ជាការពិតណាស់ បើសិនជា ...
  - មែនហើយ ការពិតនៅតែជាការពិត ព្រោះ ...
  - ខ្ញុំសូមគាំទ្រ ...
  - ត្រឹមត្រូវហើយ ...
- **សំនួនមិនយល់ព្រម**
  - ប្រសើរណាស់ប៉ុន្តែ ...
  - យើងគួរពិចារណាលើចំណុចផ្សេងវិញ ...
  - យើងគួរងាកមករកប្រធានបទយើងវិញ ...
  - តាមគំនិតអស់លោក លោកស្រី ខាងលើនេះក៏សមម្យ៉ាងដែរ តែ ...
  - តាមគំនិតអស់លោក លោកស្រី ខាងលើនេះក៏ត្រឹមត្រូវដែរ តែគំនិតលោក លោកស្រីខាងនេះច្បាស់លាស់ជាង ...
  - ........................................

## ខ. ការប្រើប្រាស់ពេលវេលា គឺមានការបែងចែកឱ្យបានសមស្របទៅតាម :

- ទំហំនៃខ្លឹមសារប្រធានបទ
- កាលវេលានៃការបកស្រាយ
- ការសាកសួរខ្លឹមសារ ឬបន្ថែមលើខ្លឹមសារប្រធានបទ ពីសំណាក់អ្នកចូលរួម
- ................................

## គ. សំយោគ គឺជាការប្រមូលខ្លឹមសារពិភាក្សាដោយ :

- បញ្ចូលគ្នានូវគំនិត ឬទស្សនវិជ្ជមានរបស់ប្រធានបទ
- បង្ហាញពីមូលហេតុនៃការទទួលយក ឬមិនទទួលយកគំនិតណាមួយ

## ឃ. សន្និដ្ឋាននិងសរុប

- ទាញយកអត្ថន័យសំខាន់ៗពីកិច្ចពិភាក្សាលើប្រធានបទនោះ (ក្នុងសង្គម សហគមន៍ គ្រួសារ)
- លើកទឹកចិត្តនិងថ្លែងអំណរគុណអ្នកចូលរួមនិងការផ្តល់យោបល់ (ទាំងគំនិតគាំទ្រនិងទាំងគំនិតមិនគាំទ្រ) ។

## លំហាត់

ចូរនិយាយសម្របសម្រួលក្នុងអង្គពិភាក្សាលើប្រធានបទស្តីពី ៖

១. " បញ្ហាទឹកស្អាតនៅប្រទេសកម្ពុជា "

២. " បញ្ហាគ្រោះថ្នាក់ចរាចរនៅទីក្រុងភ្នំពេញ "

៣. " បញ្ហាទទួលយកវប្បធម៌បរទេសមួយចំនួនរបស់យុវវ័យសម័យបច្ចុប្បន្ន" ។

# បំពេញលិខិតផ្សេងៗ

អ្នកធ្លាប់បានសិក្សារួចហើយពីការសរសេរបំពេញលិខិត ។ ពេលនេះ ចូរអ្នកបំពេញលិខិតតាមគំរូខាងក្រោមនេះ ៖

## ១ . លិខិតប្រគល់និងទទួល

| | |
|---|---|
| ........ ថ្ងៃទី ....... ខែ ......... ឆ្នាំ ........ | ........ ថ្ងៃទី ....... ខែ ......... ឆ្នាំ ........ |
| ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ ........... ភេទ ...... | ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ .......... នៅផ្ទះលេខ |
| អាយុ ........... មុខរបរ .................... | .................... ភូមិ/ ក្រុម ............... |
| បានប្រគល់ ...................... គ្រប់ចំនួន | ឃុំ/ សង្កាត់ .......... ស្រុក/ ខណ្ឌ ........... |
| ជូនលោក/ លោកស្រី ......... នៅផ្ទះលេខ | ខេត្ត/ ក្រុង .......... បានទទួលគ្រប់ចំនួនជា |
| ភូមិ/ ក្រុម ........... ឃុំ/ សង្កាត់ ............ | ស្ថាពរ ហើយពីលោក/ លោកស្រី ........ ។ |
| ស្រុក/ ខណ្ឌ ........... ខេត្ត/ ក្រុង .......... | |
| ហត្ថលេខានិងឈ្មោះអ្នកប្រគល់ | ហត្ថលេខានិងឈ្មោះអ្នកទទួល |
| ............................................... | ............................................... |
| ហត្ថលេខានិងឈ្មោះសាក្សី | ហត្ថលេខានិងឈ្មោះសាក្សី |
| ............................................... | ............................................... |

## ២ . លិខិតលក់ (ទំនិញ)

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ........................ ភេទ .......... អាយុ ......... ឆ្នាំ

មុខរបរបច្ចុប្បន្ន : ..............................................................................

ទីលំនៅបច្ចុប្បន្ន : ..............................................................................

ទូរស័ព្ទលេខ : ..............................................................................

បានលក់ .................. ចំនួន ........... ម៉ាក ............... តម្លៃ .................

ឱ្យទៅឈ្មោះ : ..............................................................................

មុខងារបច្ចុប្បន្ន : ..............................................................................

ទីលំនៅបច្ចុប្បន្ន : ..............................................................................

បើខុសពីការពិត យើងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ ។

បញ្ជាក់ : របស់ទិញហើយ មិនអាចដូរវិញបាន ។

ធ្វើនៅ .......... ថ្ងៃទី ....... ខែ ......... ឆ្នាំ ............

ស្នាមមេដៃអ្នកលក់ សាក្សីខាងអ្នកលក់ ស្នាមមេដៃអ្នកទិញ សាក្សីខាងអ្នកទិញ

## ៣ . ជីវប្រវត្តិសង្ខេប

### ជីវប្រវត្តិផ្ទាល់ខ្លួន

១. នាមត្រកូលនិងនាមខ្លួន .................... ជាអក្សរឡាតាំង ............ ភេទ ...........

២. សញ្ជាតិ ............ ជនជាតិ .................

៣. ថ្ងៃខែឆ្នាំកំណើត ........................ ទីកន្លែងកំណើត .......................................

៤. មុខរបរសព្វថ្ងៃ ......................... នៅផ្ទះលេខ ............... ផ្លូវលេខ ..............

ក្រុម .............. ភូមិ .................... ឃុំ/សង្កាត់ .......................................

ស្រុក/ខណ្ឌ .................................... ខេត្ត/ក្រុង ........................................

៥. កំរិតវប្បធម៌ ..................................................

៦. កំរិតជំនាញ ឬបទពិសោធ .........................

5

ស្ថានភាពគ្រួសារ

**អំពីឪពុកម្ដាយបង្កើត**

- ឪពុកឈ្មោះ ...................... អាយុ ......... សញ្ជាតិ ...... ជនជាតិ ...........
  រស់/ ស្លាប់ .................... មុខរបរនិងទីលំនៅបច្ចុប្បន្ន ..............................
- ម្ដាយឈ្មោះ ...................... អាយុ ......... សញ្ជាតិ ...... ជនជាតិ ...........
  រស់/ ស្លាប់ .................... មុខរបរនិងទីលំនៅបច្ចុប្បន្ន ..............................

**អំពីបងប្អូនបង្កើត (ឈ្មោះ ភេទ អាយុ មុខរបរ ទីលំនៅបច្ចុប្បន្ន)**

១. ...........................

២. ...........................

៣. ...........................

រៀបរាប់អំពីការសិក្សាផ្ទាល់ខ្លួន ពីតូចដល់បច្ចុប្បន្ន

| រៀននៅសាលា | ពីឆ្នាំណាដល់ឆ្នាំណា | ថ្នាក់ទីដល់ទី | នៅឯណា(ក្រុង-ខេត្ត) | ថ្ងៃ ខែ ឆ្នាំទទួលសញ្ញាប័ត្រ |
|---|---|---|---|---|
| បឋមសិក្សា | | | | |
| អនុវិទ្យាល័យ | | | | |
| វិទ្យាល័យ | | | | |
| ............... | | | | |

កិច្ចសន្យាទទួលខុសត្រូវរបស់សាមីខ្លួនលើប្រវត្តិរូបនេះ ........................

...............................

...............................

អាសយដ្ឋានសម្រាប់ទាក់ទង

- ឈ្មោះ .........
- ទីកន្លែងធ្វើការ
- ទូរស័ព្ទលេខ ........

ធ្វើនៅ ........ ថ្ងៃទី ....... ខែ ........ ឆ្នាំ ........

ហត្ថលេខានិងឈ្មោះសាមីខ្លួន

## ៤ . សេចក្តីប្រកាសអះអាងផ្ទាល់ខ្លួន

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ .......................... បច្ចុប្បន្នជា ................................
នៅ ............................ នៃ ...................................................

សូមធានាអះអាងថា រាល់ការបំពេញក្នុងសលាកប័ត្រព័ត៌មាននេះពិតជាត្រឹមត្រូវពិតប្រាកដមែន ។ បើថ្ងៃក្រោយមានបញ្ហាណាមួយ ដែលផ្ទុយពីការធានាក្នុងសលាកប័ត្រនេះ ខ្ញុំបាទ/ នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ ។

ធ្វើនៅ ........ ថ្ងៃទី ....... ខែ ........ ឆ្នាំ ........

សាក្សីដឹងឮ　　　　　　　　　　　　ហត្ថលេខានិងឈ្មោះ

ហត្ថលេខានិងឈ្មោះ

## ៥ . លិខិតរាយការណ៍របស់អ្នកដំណើរតាមយន្តហោះ

**អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា**
**CAMBODIAN CUSTOMS AND EXCISE DEPARTMENT**

**លិខិតរាយការណ៍របស់អ្នកដំណើរ Passenger's Declaration**

នាមត្រកូល Family Name
នាមខ្លួន Given Names
ភេទ Sex ☐ ប្រុស Male ☐ ស្រី Female
ថ្ងៃ ខែ ឆ្នាំកំណើត Date of Birth
លិខិតឆ្លងដែនលេខ Passport No.
សញ្ជាតិ Nationality
មុខរបរ Occupation
យន្តហោះលេខ Flight No.
មកពី / ទៅ From / To

សូមគូសបញ្ជាក់ Please Check
☐ មានទំនិញរាយការណ៍ Goods to declare ☐ គ្មានទំនិញរាយការណ៍ Nothing to declare
បើមានទំនិញសូមរាយការណ៍នៅផ្នែកខាងខ្នង
If you have goods to declare please list them on the reverse side.

អ្នកមានរូបិយប័ណ្ណបរទេស រូបិយវត្ថុ យកតាមខ្លួនលើសពី $10,000 U.S. ឬទេ?
You are carrying foreign currency or monetary instruments over $10,000 U.S. or its equivalent. ☐ មាន Yes ☐ គ្មាន No

ខ្ញុំសូមបញ្ជាក់ថា ការរាយការណ៍លើលិខិតនេះពិតជាត្រឹមត្រូវមែន ។
I certify that all statements on this declaration are true and correct.
ហត្ថលេខា Signature ..........................................
កាលបរិច្ឆេទ Date ថ្ងៃ Day .......... ខែ Month ................ ឆ្នាំ Year ..............

បើសិនអ្នកមានចម្ងល់ សូមសាកសួរមន្ត្រីគយ
If you have any questions, please ask a customs officer.

**កំណត់សំគាល់ :**
ទំនិញមិនបាច់រាយការណ៍ : មានតែទំនិញប្រើប្រាស់ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។

**Notice :**
**Goods not to declare** cover only your own personal effects.
ទំនិញត្រូវរាយការណ៍ : (1) ទំនិញជាប់ពន្ធ ឧទាហរណ៍ គ្រឿងអេឡិចត្រូនិច កុំព្យូទ័រ ទំនិញមានលក្ខណៈពាណិជ្ជកម្ម...។ល។ (2) ទំនិញហាមឃាត់ ឧទាហរណ៍ អាវុធ ជាតិផ្ទុះ វិទ្យុទាក់ទង ថ្នាំញៀន សារធាតុគីមី...។ល។
**Goods to declare** cover (1) dutiable goods e.g. electronic goods, computers, commercial goods...etc., (2) prohibited/restricted goods e.g. firearms, ammunition, explosives, wireless transmitters and receivers, drugs, nacotics, chemical substances...etc.

ចំណាំ : ការខ្វះខាតក្នុងការរាយការណ៍ មិនបានរាយការណ៍ ឬរាយការណ៍ខុស គឺជាការល្មើសច្បាប់ ហើយត្រូវទទួលការពិន័យ ឬផ្តន្ទាទោស ។
Warning : Failure to declare, misdeclaration or false declaration are offences under the law and can result in fines or other penalties.

**តារាងទំនិញត្រូវរាយការណ៍ List of declared goods**

| រាយឈ្មោះសំភារៈ Description of goods | បរិមាណ Quantity | តំលៃ Value | សំរាប់មន្ត្រីគយ Customs Use Only |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| សរុប Total | | | |

បង្កាន់ដៃលេខ : Receipt No.
កាលបរិច្ឆេទ : Date :

កាលបរិច្ឆេទ Date ........................
មន្ត្រីគយ-រដ្ឋាករ........................
Customs and Excise Officer

# ៦ . សលាកប័ត្រចូល-ចេញរបស់អ្នកដំណើរតាមយន្តហោះ

កំណត់សំគាល់
NOTICE

រក្សាសិទ្ធិ
Printed by Cambodian Immigration
Reproduction prohibited

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA



សលាកប័ត្រ ចូល-ចេញ
ARRIVAL/DEPARTURE CARD

សលាកប័ត្រចូល
ARRIVAL CARD
Nº 0988368

នាមត្រកូល
Family name
នាមខ្លួន
Given name
កន្លែងកំណើត
Place of birth
ភេទ ប្រុស /M
Sex ស្រី /F
ថ្ងៃខែឆ្នាំកំណើត
Date of birth
សញ្ជាតិ
Nationality
លិខិតឆ្លងដែន
Passport Nº
យន្តហោះលេខ Flight Nº | នាវា Ship | រថយន្ត Car | រថភ្លើង Train
មធ្យោបាយធ្វើដំណើរ
Type of transportation
មកពី
Arriving from
ប្រភេទ/លេខទិដ្ឋាការ
Type/Visa Nº
កន្លែងផ្តល់
Place of issue
បំណងនៃការធ្វើដំណើរ
Purpose of trip
រយៈពេលស្នាក់នៅ
Lenght of stay
អាសយដ្ឋាននៅកម្ពុជា
Address in Cambodia

ហត្ថលេខា/Signature

សំរាប់សមត្ថកិច្ច
For official use only

សលាកប័ត្រចេញ
DEPARTURE CARD
Nº 0988368

នាមត្រកូល
Family name
នាមខ្លួន
Given name
កន្លែងកំណើត
Place of birth
ភេទ ប្រុស /M
Sex ស្រី /F
ថ្ងៃខែឆ្នាំកំណើត
Date of birth
សញ្ជាតិ
Nationality
លិខិតឆ្លងដែន
Passport Nº
យន្តហោះលេខ Flight Nº | នាវា Ship | រថយន្ត Car | រថភ្លើង Train
មធ្យោបាយធ្វើដំណើរ
Type of transportation
ឆ្ពោះទៅកាន់
Destination
ប្រភេទ/លេខទិដ្ឋាការ
Type/Visa Nº
ថ្ងៃចេញដំណើរ
Departure on

សំរាប់ពលរដ្ឋខ្មែរប៉ុណ្ណោះ FOR CAMBODIAN ONLY

រយៈពេលស្នាក់នៅក្រៅប្រទេស

ប្រទេសស្នាក់នៅចុងក្រោយ

អន្តោប្រវេសន៍ | ទេសចរណ៍/សួរសុខទុក្ខបងប្អូន
រៀបការ | ជំនួញ
សិក្សា | ធ្វើការ

ហត្ថលេខា/Signature

សំរាប់សមត្ថកិច្ច
For official use only

មេរៀនទី ១០

# សុទិដ្ឋិនិយម



ការយល់ឃើញប្រសើរសុខស្រួល ការប្រកាន់យកតែអំពើល្អសុចរិត ដែលជាមាគ៌ានាំទៅរកសេចក្ដីសុខចម្រើន ឬជាសេចក្ដីសង្ឃឹមទៅលើកិច្ចការទាំងឡាយឆ្ពោះទៅរកតែអំពើល្អប្រសើរ គឺផុសចេញពីសុទិដ្ឋិនិយម ។ អ្នកដែលប្រកបទៅដោយសុទិដ្ឋិនិយម តែងមានសេចក្ដីសង្ឃឹមនិងទទួលជោគជ័យក្នុងឆាកជីវិតជានិច្ច ។ ដូច្នេះមនុស្សគ្រប់រូប គប្បីប្រកាន់ខ្ជាប់នូវសុទិដ្ឋិនិយម ដើម្បីធ្វើឱ្យសម្រេចបំណងប្រាថ្នាក្នុងជីវិត ។

មេរៀននេះ អ្នកនឹងបានសិក្សាស្វែងយល់អំពីគំនិតសុទិដ្ឋិនិយមមួយចំនួន អំពីការសំយោគគំនិត លក្ខណៈអក្សរសិល្ប៍ ប្រភេទអក្សរសិល្ប៍ ប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា តួអង្គ អ្នកនិពន្ធ កាលអាកាស កាលកំណត់តែង តម្លៃអប់រំ សង្គមបរិយាកាសនិងខ្លឹមសារអត្ថបទ សូរព្យាង្គ និងសំណេររបាយការណ៍ ។

## រឿង គ្រូបង្រៀនស្រុកស្រែ



### ក. សិក្សាពាក្យគន្លឹះ

- ដំប (ប.សំ.) : ពីរគូ(បួន)។ ពាក្យប្រើសម្រាប់រាប់ផ្លែឈើ កណ្ដាប់ស្រូវ កណ្ដាប់សំណាប ជាដើម។
- ថី (យ)(ន) : គ្រូ។ ពាក្យសម្រាប់ហៅលេខាធិការ ឬលេខានុការ គឺស្មៀនអ្នកចេះភាសាបារាំងចំពោះតែខាងប៉ែករាជការប្រូតិកតូរ៉ាតត៍ពីដើមថា ថី(តាមយួន)។
- រាជការ (ន) : ការរបស់ព្រះរាជា ការផែនដី ការរក្សាប្រទេស។
- នាម៉ឺន (ន) : មន្ត្រីមានបណ្ដាស័ក្តិ១០ហ្មឺពាន់ គឺស័ក្តិមួយម៉ឺន។ ពាក្យនេះជាប់មកពីសំដីសៀមថាន៉ាហ្មឺន "ស្រែមួយម៉ឺន" បណ្ដាស័ក្តិមន្ត្រីធំក្នុងសម័យពីព្រេងនាយយូរមកហើយ ដែលមានមុខងារត្រូវស្ដីត្រួតត្រា ឬត្រូវបានស្រែមួយម៉ឺន។
- ត្រាវ៉ូ (ន) : ផ្នែកសាធារណៈការខាងធ្វើផ្លូវថ្នល់ ស្ពានជាដើម។
- មេការ (ន) : អ្នកត្រួតត្រាក្រុមការងារ។
- ថីដោយ (ន) : បណ្ដាស័ក្តិមន្ត្រីមួយពួកដែលគេប្រើក្នុងសម័យមុន។ បណ្ដាស័ក្តិទាហានដែលខ្ពស់ជាងពលបាលឯកមួយថ្នាក់។

- ប្រជាធិបតេយ្យ (ន) : ភាពនៃប្រទេសដែលមានប្រជារាស្ត្រជាអធិបតី គឺប្រទេស ឬរដ្ឋបាលដែលមានប្រជាជនជាធំក្នុងការរើសតំណាងរបស់ខ្លួន ឱ្យជាអ្នកសម្រេចកិច្ចការក្នុងប្រទេស ។
- ភ្លឺ (ន) : ដីដែលគេលើកពូនជាព្រំចារឹក ឬជាទំនប់ស្រែជាដើម ។
- កាប៉ូរ៉ាល់ (ន) : អ្នកត្រួតការ អ្នកកាន់កាប់ការងារ ។
- ជីវពល (ន) : ពលក្លាហាន កងកម្លាំងដ៏អង់អាច គឺបុរសជាពលរដ្ឋធម្មតាដែលស្លៀកពាក់ជាទាហាន ក្នុងគ្រាស្រុកទេសភ័យអាសន្ន ជាជំនួយដល់ក្រុមទាហានក្នុងក្របខណ្ឌ ។
- ភាវនា (ន) : ការរីកចម្រើន ការនឹកចំពោះត្រង់អារម្មណ៍តែមួយដដែលៗឱ្យច្រើនៗ គឺនឹកហើយនឹកទៀតរឿយៗ ការរំពឹងស្មឹងស្មាធិ៍ ។
- ចក្រពត្តិ (ន) : បរមក្សត្រដែលមានបុណ្យអំណាចជាពន្លឹក ជាម្ចាស់លើទ្វីបក្នុងពិភពលោក ។

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទដកស្រង់នេះ ចូរអ្នកអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងតួអង្គ លក្ខណៈអក្សរសិល្ប៍ ប្រភេទអក្សរសិល្ប៍ ប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា កាលអាកាស សង្គមបរិយាកាស តម្លៃអប់រំ និងខ្លឹមសាររឿង ។

## គ. អត្ថបទ

### វគ្គទី១ : រកមិនជួប

... ថ្ងៃរសៀលម៉ោង៤ ម៉ាស៊ីនស្រូវតូចមួយ នៅខាងកើតផ្លូវទៅភូមិត កំពុងរត់ញាប់រន្ថាន់ ។ នៅខាងលិចផ្លូវចំមុខម៉ាស៊ីននេះ រំលងផ្ទះមួយខ្នងធំមានតៀមមួយ ។ ផ្ទះនេះ មានបណ្ដោយប្រវែង ១០ម៉ែត្រ ទទឹង ៥ម៉ែត្រ បែងចែកជាពីរល្វែង ។ នៅខាងក្រោមល្វែងខាងជើង មានផ្ទះបាយមួយ ហើយជាប់ផ្ទះបាយនេះគឺទ្រុងជ្រូក ។ ផ្ទះតូចនេះ ជាលំនៅរបស់អ្នកស្រែពីរគូ ពូព្រឿងនិងបងហម ។

ពូព្រឿងចំណាស់ ៥០ឆ្នាំ ។ គាត់នៅល្វែងខាងត្បូង ភ្នែកគាត់ឈឺមើលអ្វីមិនបានឆ្ងាយ ។ រោគស្លឹកបានរោមរឹតគាត់ ឃាត់គាត់មិនឱ្យដើររកស៊ីក្រៅផ្ទះ ។ គាត់នៅចាំផ្ទះមើលថែទាំកូនតូចៗបួននាក់ ។ គាត់មិនមែនជាអ្នកទម្រន់ដេកស្ងៀមឡើយ ។ នៅផ្ទះគាត់ឆ្លៀតត្រដរដាំអំពៅ ស្លឹកគ្រៃ ដំឡូងឈើ ចិញ្ចឹមជ្រូកពីរដំប និងមាន់បួនដប់សំបុក ... ។

បងហាម មានអាយុ ៤០ឆ្នាំ ។ គាត់មានមាឌធំបង គាត់ជាទាហានជើងក្របាមចាស់ ។ គាត់បានឈប់ធ្វើទាហានតាំងពីឆ្នាំ ១៩៤០ ។ មិត្តភក្តិដែលធ្វើទាហានជាមួយគាត់ច្រើននាក់ ក្រោយពីចេញពីទាហាន បានធ្វើជាភ្នាក់ងាររាជការ ។ ខ្លះបានធ្វើពេទ្យ ខ្លះបានធ្វើចៅមេព្រៃ ខ្លះទៀតបានធ្វើស្មៀន... ។ ឯចំណែកបង ហាម បានធ្វើកូននាម៉ឺន តូចក្នុងត្រារ៉ូដែរ ។ គាត់ធ្វើការប៉ុរ៉ាល់ត្រួតផ្លូវគរពាមក្បែរផ្ទះគាត់ជាប់ជិតប្រាំឆ្នាំហើយ ។ គាត់បានឈប់ធ្វើនាម៉ឺន ព្រោះគាត់បានប្រកែកនឹងមេការបារាំងដែលបានបន្ទោសគាត់មិនសមហេតុមិនសមផល ។ កាលនៅពេលទាមទារឯករាជ្យដេញបារាំងបង **ហាម** បានធ្វើជីវពល ។ ដោយធ្លាប់បានធ្វើទាហានជើងក្របាម គាត់បានឆាប់ចេះមួយពីរ ឆ្វេងស្តាំត្រឡប់មុខ បែរក្រោយ ដូច្នេះគាត់ត្រូវតាំងជាមេកងជីវពល ។ ក្នុងខណៈនោះដូចអ្នកភូមិគាត់ភាគច្រើន គាត់បានខ្ចីលុយគេកាត់ខោអាវកាគី ស្បែកជើងឃ្លុប និងទិញកាំភ្លើងឈើមួយ ។ ស្រុកបានសន្តិភាព គាត់ក៏បានច្បាប់ទទួលកាន់កាំភ្លើងមួយពីសាលាស្រុកដើម្បីការពារភូមិគាត់ ។

អ្នកសន ប្រពន្ធគាត់ ជានារីមួយរូបឆ្នើមក្នុងការរកស៊ី ។ ក្រៅពីធ្វើស្រែ គាត់បានឆ្លៀតលក់ទៀត ។ រាល់ព្រឹកគាត់បានក្រោកពីមាន់រងាវ ផ្ទុកអង្ករដាក់ឡានយកទៅលក់ឯចំការទាល់ពេលត្រង់ជាក់ បានមកផ្ទះវិញ ។ រាល់រសៀលម៉ោងពីរ គាត់បានទៅអុំស្ទៃអង្ករ នៅម៉ាស៊ីនស្រូវខាងកើតផ្លូវទល់ព្រលប់ មើលគ្នាមិនស្គាល់បានមកផ្ទះ ។

ថ្ងៃនេះនៅវេលាម៉ោង ៤ជាង ម៉ាស៊ីនស្រូវកំពុងតែដើរញាប់ ហើយអ្នកសនកំពុងតែញើសជោកអុំស្ទៃប្រមូលអង្ករ មីកូនពូព្រឿង បានរត់ទៅដល់ស្រែកហៅ :

- មីង សនៗ មានគេរកនៅផ្ទះ ។
- អ្នកណាឱ្យហៅ ហាង ! (អ្នកសនបានសួរ)
- ខ្ញុំមិនស្គាល់ទេ ឪខ្ញុំឱ្យហៅ ឆាប់មកទៅ !

អ្នកសន បានខំបោសជជុះកន្ទក់និងអង្កាមចេញពីខ្លួនរួចកាលណា ក៏ខំដើរយ៉ាងញាប់ទៅផ្ទះគាត់ ។ ដល់ផ្ទះគាត់ មនុស្សពីរនាក់ប្រដាប់ដោយសំលៀកបំពាក់ជាប៉ូលិសនិងពូព្រឿងឈរនៅជាមួយ ។ ឃើញអ្នកសន ទៅជិតដល់ប៉ូលិសម្នាក់គេះថីដោយជម្រាបថា ប្រពន្ធហាមមកហើយ ។

អ្នកសន ក៏បានសួរទៅភ្នាក់ងារប៉ូលិសដែលនិយាយនោះថា ៖

- លោកបងមុយ ឯងអញ្ជើញរកអី ?
- លោកចៅហ្វាយឱ្យហៅហាម
- ប្តីខ្ញុំគាត់មិននៅទេ មានការអីរកគាត់ ?

- ឃើញទេ មុយឯងគ្រាន់តែនាំខ្លួនវាពីព្រឹកមិញជាមួយកាំភ្លើងទៅមិនបានទេ ទាល់តែគេចបាត់បានមករក ។ ... លោកចៅហ្វាយកិនងាប់ហើយអញមិនដឹងទេ (ចីដោយបានកិន) ។
- លោកស្មៀន ហ៊ុន បានប្រើខ្ញុំឱ្យមកហូតកាំភ្លើង ។ ខ្ញុំហូតយកទៅដល់សាលាស្រុកបានលោកថាឱ្យនាំអាហាម ទៅមិនមែនខុសពីខ្ញុំទេ ។

ចីដោយបានចោលភ្នែកទៅ ... លើតុពេញដោយកាសែតប្រជាធិបតេយ្យ សាមគ្គី ... ក៏លាន់មាត់ថា ៖

- មើលកាសែតម្ទឹងៗ បានជាពូកែដោះស្រាយណាស់
- ខ្ញុំបានមកដាស់តឿនពន្យល់វាពីរបីលើកដែរ ប៉ូលិសមុយបានឆ្លើយ ។ វាត្រឡប់ជាកិនខ្ញុំវិញ ។ វាថាកុំឱ្យខ្ញុំល្មើពកថ្វាសកាន់ក្បួនប៉ូលិស ទាហានបារាំងដើរសម្លុតជីកស្រាមិនឱ្យលុយគេទៀត ។ វាថា វាដឹងខ្លួនហើយ ។ វាពន្យល់ខ្ញុំថា អាមេរិចកាំងមេបង្កើតម៉ាស៊ីនស្រូវធំស្រុកយើងនេះ ខូចណាស់ចង់អូសទាញខ្មែរឱ្យខ្ញុំវាទៀត ។
- បើដឹងដូច្នេះ ហេតុអ្វីក៏ប៉ូលិស មុយឯងមិនប្ដឹង (ចីដោយកិន) ។
- ប្ដឹងម៉េចបាន ។ បើលោកចៅហ្វាយជាប់ដៃជាមួយវា ។ ទៅគេរក៏ហៅវាទៅដែរ ហើយបែបផ្អែកលើវាជាងខ្ញុំ ។
- លោកចៅហ្វាយណា
- លោកមុន
- ឈប់ជជែក យើងត្រូវរកហាម ។ ចីដោយបានឃាត់ រួចបើកភ្នែកមើលមុខអ្នក សនសួរដោយពាក្យធំៗថាប្ដីទៅណាប្រាប់មកកុំលាក់
- ខ្ញុំមិនដឹងទេ ខ្ញុំមកពីលក់អង្ករវិញមិនឃើញគាត់ ។

គ្រែងនៅពួនក្រោមផ្ទះបាយទេ បើដូច្នេះខ្ញុំចូល ថាចប់ចីដោយដើរចូលកាត់ផ្ទះទៅក្រោយបើករាំងននឈ្ងោកមើលក្រោមគ្រែមិនឃើញ ហួសទៅផ្ទះបាយ រួចបកត្រឡប់កាត់ល្វែងពូព្រៀង ឈ្ងោកមើលកៀនៗទៀត ។

ប៉ូលិសមុយនិងចីដោយបានឈ្ងោកមើលគ្រប់មិនឃើញ ក៏បបួលគ្នាចេញទៅវិញ ។ អ្នកផ្ទះជិតខាងបានផ្អើលមើលឈូរឆរ ឯចំណែកឆ្កែ ក៏ព្រូសសន្ធាប់យ៉ាងខ្លាំងដេញពីក្រោយ ... ។

# វគ្គទី៤ ៖ កាត់វាលស្រែពេលយប់

ក្រោយពេលប្រជុំគ្នាបានមួយថ្ងៃ នៅពេលយប់ងងឹតមើលគ្នាមិនស្គាល់ លោកគ្រូម៉េងបានជូនបងហាម ទៅផ្ទះអាចារ្យសម នៅខាងលិចដើមពោធិ៍។ ផ្ដាំផ្ញើសព្វគ្រប់រួចកាលណាលោកគ្រូម៉េងត្រឡប់មកវិញ។ ឯចំណែកបងហាម អាចារ្យសមក៏បានបណ្ដើរគ្នាចេញទៅទៀត។ អ្នកថ្មើរជើងទាំងពីរនាក់ដើរយ៉ាងលឿនមិនបានផ្លាស់ប្ដូរសំដីរកគ្នាទេ។ គាត់ដើរឱ្យឆាប់ដល់ ដើម្បីឱ្យផុតពីមុខមាត់ប៉ូលិស ឱ្យឆាប់ឃ្លាតឆ្ងាយពីផ្លូវថ្នល់។ កន្លះម៉ោងក្រោយមក គាត់ទៅដល់ភូមិប្រាសាទ។ ចេញផុតផ្លាក្រោយភូមិជិតដើមចំបក់គាត់ឃើញស្រមោលមនុស្សមួយស្ទុងបានដើរចេញទៅ។ បងហាម ទុចអង្គុយក្រាបចុះ។ អាចារ្យសមបានដើរទៅទៀត។ ជិតដល់ស្រមោលនោះ គាត់ក្អកគ្រហែមស្រែកហៅ ៖

- អាដែងអើយមកទៅផ្ទះ យប់ងងឹតណាស់ កុំនៅយូរពេក។

ស្រមោលមនុស្សស្ទុងបានទុច ហើយស្រែកឆ្លើយថា យីលោកពូទេ! អញ្ជើញទៅណា ? អញស្មានតែខ្មោចលង ខំសូត្រយថាមួយចប់ពីរទៅហើយ មិនដឹងថាខ្មោចអន្ទិតឡឹងសោះ។

- ម៉េចទៅណាទាំងយប់ដូច្នេះ ?
- ទៅភូមិឫស្សី ទៅសួរបងខ្ញុំឆ្លងទន្លេ
- បងអន្ទិតឡឹងណាមួយ ?
- បងឡេងណា
- វាបានកូនស្រី ឬប្រុស ?
- ប្រុស
- អន្ទិតទៅតែម្នាក់ឯងទេឬ ?
- ចុះចាំបាច់នរណាជូន

ឮអន្ទិតឡឹងថាដូច្នេះ បងហាមក៏ដើរចូលមកបៀតហើយនិយាយថា ៖

- អញស្មានតែមិនមែនអ្នកឡឹងឯង
- យីលោកបងហាមទេតើ សុទ្ធតែគ្នាឯងតែម្ដង ...។ ឮគេរកចាប់ បងម៉េចទៅឥឡូវ។
- វាគ្មានការអ្វីជាធំដុំទេ។ កុំព្រួយធ្វើអ្វីអ្នកឡឹងឯងទៅណា ?
- ខ្ញុំទៅភូមិឫស្សី
- នៅឯណាទៅភូមិឫស្សី ?
- នៅតែធ្វើពើមិនស្គាល់ទៀត ភូមិដែលយើងទៅពីខែមុននោះ ...។

- ភូមិដក់គាំនោះឬ ?
- ហ្នឹងហើយ
- បើដូច្នេះយើងត្រូវផ្លូវគ្នាហើយ ។ តោះយើងដើរទៅផ្លូវជាមួយគ្នា ... ។ ដល់អូរចាំយើងបែកគ្នា ។

អ្នកដំណើរបានបន្តដំណើរទៅ ។ បងហមបានចាប់សួរ ៖

- ម៉េចអ្នកឡឹងមានផ្លូវទេ ភូមិឫស្សី បងប្អូនយើងសុខសប្បាយទេ ?
- សុខតែមិនសប្បាយទេ ដូចលោកបងឃើញស្រាប់ហើយគ្នាក្រណាស់ សព្វថ្ងៃនេះគ្មានបាយសុទ្ធស៊ីទេ គ្នាស៊ីបាយលាយពោត ។
- ភូមិឫស្សីបានបើកភ្នែកខ្ញុំឱ្យឃើញទុក្ខវេទនារាស្ត្រ ម៉ៅស្រលាញ់អ្នកភូមិនេះណាស់ ។
- អើម៉េចទៅលោកគ្រូម៉ៅ "ឡឹងបានសួរ" ខ្ញុំឮគេចាប់គាត់ ខ្ញុំញ័រខ្លួនអាណិតគាត់ជាពន់ពេកគេមានវាយដាក់ខ្នោះទេ ...?
- ខ្ញុំមិនសូវបានដឹងដែររឿងនេះ ព្រោះខ្ញុំបានឈប់ជួបគាត់ជិតមួយខែ តាំងពីពេលក្រោយពីត្រឡប់ពីភូមិនេះទៅ ... ។ បានដឹងថាសព្វថ្ងៃគាត់ជាប់គុកនៅកំពង់ ... ។
- នេះបានចំ ! ខ្ញុំចូលចិត្តគាត់ណាស់ អ្នកភូមិឫស្សីសរសើរគាត់គ្រប់មាត់ ។

អាចារ្យសមបានកាត់ ៖

- មើល៍ហមឯងបាននិយាយថាភូមិឫស្សីបានបើកភ្នែកខ្លួន តើមានអ្វីខ្លះ ។ ខ្ញុំនៅជិតភូមិនេះដែរតែដូចជាវាមិនឃើញមានអ្វីខុស ?
- លោកបង អាចារ្យមិនដែលទៅ បានជាអ៊ីចឹង ។ កាលពីមុនខ្ញុំនិងប្អូនម៉ៅព្រមទាំងគ្រូៗ ប្អូនប្រាំនាក់ទៀតបានជិះកង់លើភ្លឺទៅភូមិនោះ ។ អ្នកស្រុកហោមហាក្របានទទួលយើងដូចស្គាល់គ្នា ប៉ុន្មានឆ្នាំមកហើយអ៊ីចឹង ។ គេនិយាយប្រាប់យើងគ្រប់ ។ គេមិនដែលស្គាល់នាម៉ឺនមកភូមិគេទេ ។ រាល់ឆ្នាំ គេមានរឿងតែជាមួយមេសង្វៀនបឹង ។ បងអាចារ្យដឹងទេ មេសង្វៀនបឹងបានចាត់អ្នកលេងប៉ាវគេបឹងឱ្យមកលើក មកកាប់ទ្រូ លបអ្នកស្រុក ។ ថៅកែបឹងមានអ្នកលេងកាប់ចាក់សម្លុតអ្នកស្រុកដែលដាក់ទ្រូដាក់លបបន្តិចបន្តួចគ្រាន់នឹងចិញ្ចឹមឆ្នាំង ។ ថៅកែបឹងរំលោភអស្ចារ្យហើយ គេបានប្រកាន់ថា បឹងនេះមានព្រំត្រឹមទឹកឡើងរហូតមាត់ភូមិក្នុងស្រែ អ្នកស្រុក ... ។ រាល់ឆ្នាំ អ្នកភូមិត្រូវមេសង្វៀនធ្វើបាប ហើយអ្នកលេងបឹងនោះកាច

សាហាវ មានអំណាចអស្ចារ្យ គេអាចសម្លាប់អ្នកភូមិបានហើយគ្មានទោសទេ ។ គេបង្វែង ដានបានទាំងអស់ ។ ចៅកែគេបានស្គាល់អស់លោកនាម៉ឺននៅខេត្តស្រុកស្រេច ។

- ខ្ញុំគ្មានដឹងសោះ "អាចារ្យសមលាន់មាត់"
- លោកបងអាចារ្យដឹងម៉េចកើត បើរស់តែឋានទេវតាឯណាឯណោះ ត្រូវគិតការរស់នៅលើ ដីផង ... ។ កុំគិតតែភាវនាមូសខាំជិតងាប់មិនហ៊ានទះនោះ ផ្លូវនោះបងវ៉ែនខ្ញុំលែងដើរ ហើយ ។
- យើងគិតដូចម្តេចជួយដោះទុក្ខអ្នកភូមិនោះផង "ឡឹងបានចោទ" ។
- ការដោះទុក្ខកែប្រែការរស់នៅពិបាក ហើយយូរផង ។ យើងមិនអាចពិភាក្សាគ្នាដើរផងទេ ព្រោះយើងដល់ផ្លូវបែកគ្នាហើយ ... ។
- យើងឈប់និយាយគ្នាមួយស្របក់ទៅ យើងកំពុងតែជក់មាត់ "ឡឹងបានស្នើ"
- ឈប់ក៏ឈប់ "អាចារ្យសមយល់ព្រម" តស់យើងទៅឈប់ឯមាត់អូរ ... ។

អ្នកទាំងបីបានឈប់ ។ ឡឹងអង្គុយមុនគេ ។ អាចារ្យសមបានជក់បារី បងហាមបានបត់ជើងតូចរួច ក៏ត្រឡប់ទៅអង្គុយជាមួយគេ ។ បន្ទាប់មកគាត់ចាប់និយាយ ៖

... ការដោះទុក្ខកែប្រែការរស់នៅប្រជាជនយើងគ្រប់គ្នា ជាការពិបាក ជាការយូរមិនឆាប់ដូច មាត់ទេ ព្រោះមនុស្សធ្វើមិនមែនទេវតាឯណាធ្វើជួសយើងទេ ... ។ យើងត្រូវអប់រំខ្លួនយើងនិងអប់រំ អ្នកភូមិឱ្យយល់ ជឿលើកម្លាំងខ្លួន ហើយឱ្យដឹងថាទាល់តែយើងរួមកម្លាំងសាមគ្គីគ្នាបានយើងអាចទប់ ទល់នឹងអ្នកលេងដៃជើងចៅកែមេសង្វៀនបាន ។ នៅស្រុកស្រែជាមួយយើង វាអាងអ្នកលេង នៅ ទីក្រុងវាអាងទឹកប្រាក់ ។ បើដូច្នេះ បើយើងចង់រួចខ្លួន ចង់បានស្រួល ចង់បានយុត្តិធម៌ ទាល់តែអ្នកភូមិ នេះចេះបម្រះកែប្រែខ្លួនឡើង ។ ការរៀបចំភូមិឃុំ ជាការចាំបាច់មុនគេបង្អស់ចំពោះក្រុមយើង ។ ដោយហេតុនេះ បានជាខ្ញុំយល់ឃើញថា ដល់រួចរាល់ឆ្នាំក្រោយៗនេះ យើងត្រូវតែឱ្យមានសិទ្ធិប្រជា ជនរើសនាយកឃុំ ... ។ តែនាយកឃុំយើងមិនមែនតែមានភារៈដើរជិះជាន់សង្កត់សង្កិនរាស្ត្រ ដូច អាណានិគមបារាំងបង្កបង្កើតនោះទេ ។ នាយកឃុំយើងជាតំណាងប្រជាជនភូមិ ហើយមានភារៈកែប្រែ អ្នកភូមិពីក្តីវេទនាគ្មានអាវពាក់ ពីអំពើចោរកម្ម ពីការគំរាមកំហែង ។ យើងត្រូវមានគ្រោងការណ៍ដូច តទៅនេះ ៖

១. ខាងនយោបាយការពារនិងពង្រីកសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ ជាក់ស្តែងពិតៗ ឱ្យ ប្រជាជនអ្នកស្រែមានអំណាចបោះឆ្នោតជ្រើសរើសរបៀបគ្រប់គ្រងឃុំ ភូមិរបស់ខ្លួន ។

២. ខាងសេដ្ឋកិច្ច បង្កើតសមាគមកសិករ នៅភូមិ ឃុំ ការពារផលដំណាំ ពោត ស្រូវ ស្ករកុំឱ្យពួកថៅកែហាងឆេងមកវាយបន្ថោក យកចំណេញកប់ក្តោងដូចសព្វថ្ងៃ ។ ម្យ៉ាងទៀតខាងបឹងព្រៃវិញ ប្រមូលប្រជាជនធ្វើសមាគមការពារផលធម្មជាតិទាំងនោះ ទុកចែកសម្រាប់គ្រប់គ្នា មិនឱ្យមេសង្វៀនក្តាប់ចំណេញរាប់សែនយកទៅជួលអ្នកលេងឱ្យមកធ្វើបាបអ្នកភូមិដូចសព្វថ្ងៃនេះទេ ... ។

៣. ខាងសង្គមកិច្ច ចាត់តាំងឱ្យមានផ្នែកសមាគមនារី សមាគមយុវជន សមាគមអ្នកស្រែចំការ បង្កើតផ្ទះពេទ្យ ... ។

៤. ខាងវប្បធម៌ ពង្រីកនិងបង្កើតសាលារៀននៅគ្រប់ភូមិ គ្រប់វត្ត ឱ្យមានចំនួនគ្រប់គ្រាន់ ដើម្បីគ្រប់ក្មេងបានរៀនសូត្រ ។ បង្កើតសាលារៀនមនុស្សចាស់ ប្រុស ស្រីមិនចេះអក្សរ ... ឧបត្ថម្ភលោកគ្រូបង្រៀនឱ្យជួយរៀបចំដាក់កម្មវិធីសិក្សារបៀបប្រជាធិបតេយ្យពិតប្រាកដ ។ បង្កើតបណ្ណាល័យទិញសៀវភៅឱ្យប្រជាជនខ្ចីមើល ... ។

- គម្រោងការណ៍នេះខ្ញុំពេញចិត្តណាស់ តែតើយើងធ្វើបានឬទេ ? "ឡឹងបានកាត់"
- បានប្រាកដជាបាន គ្រាន់តែយូរនិងឆាប់ ។ កង់ប្រវត្តិសាស្ត្រសង្គមមនុស្សកំពុងតែវិលសំដៅទៅលទ្ធិប្រជាធិបតេយ្យប្រជាជន ហើយគង់តែចក្រពត្តិអាមេរិចមកបង្វែរគំរាមកំហែងខ្លាំងយើងគ្រប់គ្នាយ៉ាងណា ក៏ទប់មិនបានឡើយ ។ បើមិនឆ្នាំនេះ ឆ្នាំក្រោយ ។ បើយើងធ្វើមិនទាន់បាន កូនយើងធ្វើ ។ បើកូនយើងធ្វើមិនបានសម្រេច ចៅយើងមុខជាសម្រេច ។ បើភូមិ ឃុំយើងធ្វើមិនទាន់កើត ក៏ភូមិ ឃុំផ្សេងទៀតធ្វើបាន ។
- សប្បាយហើយក្មេងជាន់ក្រោយ "ឡឹងបានសាទរ" ខ្ញុំមុខតែទៅនិយាយប្រាប់អ្នកភូមិឫស្សីទាំងយប់នេះហើយ ។
- ខែវរះហើយ តស់យើងទៅ ! "អាចារ្យសមបានបញ្ឈប់" ។

រួចគាត់ក្រោកឈរ បងហមក្រោកតាមក្រោយ ទីបំផុតឡឹងក្រោកទៀត ។ អ្នកទាំងបីបានបែកគ្នាឡឹងឆ្លងអូរទៅភូមិឫស្សី អាចារ្យសម និងបងហមដើរតាមផ្លូវដងអូរទៅត្បូងសំដៅពាម ... ។

*(ដកស្រង់និងកែសម្រួលពីរឿងគ្រូបង្រៀនស្រុកស្រែរបស់លោក អ៊ឹម ថុក ឆ្នាំ១៩៥៧*

*ត្រង់វគ្គ១និងវគ្គ៤ ទំព័រទី ១ ដល់ ១៤)*

## សំណួរ

១. តើនៅក្នុងអត្ថបទអំណាននេះមានតួអង្គប៉ុន្មាននាក់ ? ឈ្មោះអ្វីខ្លះ ? តើតួអង្គនីមួយៗបានធ្វើសកម្មភាពអ្វីខ្លះ ?

២. តើអ្នកណាជាតួអង្គឯកនិងអ្នកណាជាតួអង្គរង ? ចូរផ្ដល់អំណះអំណាង ។

៣. តាមរយៈអក្សរសិល្ប៍នៅក្នុង "រឿងគ្រូបង្រៀនស្រុកស្រែ" ចូរអ្នកបង្ហាញពី :

ក. លក្ខណៈជាតិនៃអក្សរសិល្ប៍ ។

ខ. លក្ខណៈមនុស្សនៃអក្សរសិល្ប៍ ។

គ. លក្ខណៈសង្គមនៃអក្សរសិល្ប៍ ។

៤. តើរឿងនេះស្ថិតក្នុងប្រភេទអក្សរសិល្ប៍អ្វី ? ចូរផ្ដល់អំណះអំណាង ។

៥. ដោយផ្អែកទៅលើអត្ថបទ "រឿងគ្រូបង្រៀនស្រុកស្រែ" ចូរអ្នកសិក្សាអំពី :

- ប្រធានរឿង
- ចំណោទបញ្ហា
- មូលបញ្ហា
- តម្លៃអប់រំ
- កាលអាកាស

៦. ចូរបកស្រាយអំពីសង្គមបរិយាកាសក្នុងអត្ថបទដកស្រង់ "រឿងគ្រូបង្រៀនស្រុកស្រែ" ។

៧. តើរឿងនេះ បង្ហាញពីគំនិតសុទិដ្ឋិនិយមដូចម្ដេចខ្លះ ? ហើយគំនិតទាំងនោះបានបង្ហាញតាមរយៈតួអង្គណា ?



# ការសំយោគគំនិត

ការនិយាយសំយោគ គឺជាការប្រមូលផ្ដុំគំនិត ព័ត៌មាន ព្រឹត្តិការណ៍ច្រើន ឬការបូកសរុបមតិយោបល់ទស្សនៈច្រើនរួមបញ្ចូលគ្នា ។ ការធ្វើសំយោគ ពេលខ្លះ អ្នកត្រូវទាញយកគំនិតទាំងអស់ពីព្រោះគំនិតទាំងនោះសុទ្ធតែត្រឹមត្រូវនិងពេលខ្លះទៀត អ្នកត្រូវទាញយកតែគំនិតមួយចំនួនដោយចោលគំនិតខ្លះដែលពុំសមស្រប ។

ចូរអានខ្លឹមសារនៃការពិភាក្សាបញ្ចេញគំនិត មតិយោបល់ ឬទស្សនៈផ្សេងៗ និងការសំយោគគំនិតទាក់ទងនឹងប្រធានបទ "ការឈប់ជក់បារី" ខាងក្រោម ។

**រក្សា** : ខ្ញុំយល់ថា យើងពិតជាអាចជួយអ្នកជក់បារីបានដោយប្រើវិធីសាស្ត្រផ្សេងៗ ដូចជានៅពេលជួបអ្នកជក់បារី យើងអាចជួយពួកគាត់ឱ្យលះបង់ការជក់បារីដោយ ៖

១. សួរអ្នកជក់បារីគ្រប់ៗគ្នា បើសិនជាគាត់ចង់ឈប់ជក់ បើគាត់ពុំទាន់ចង់ឈប់ជក់ទេត្រូវពន្យល់គាត់ពីគ្រោះថ្នាក់និងការខាតបង់ទាំងឡាយដែលកើតឡើងពីការជក់បារីជាមុនសិន ។

២. ជួយផ្ដល់យោបល់ដល់អ្នកជក់ដែលចង់ឈប់ជក់ រួចលើកទឹកចិត្តគាត់ឱ្យកំណត់កាលបរិច្ឆេទឈប់ជក់ ។

៣. តាមដាននិងបន្តជួយពួកគាត់កុំឱ្យជក់បារីឡើងវិញ ។

**បុស្បា** : ខ្ញុំឯកភាពនឹងយោបល់នេះ ប៉ុន្តែខ្ញុំមានគំនិតខ្លះទៀតគឺ

១. ការតាំងចិត្ត : ជាដំបូងត្រូវលើកទឹកចិត្តឱ្យមានការតាំងចិត្តយ៉ាងពិតប្រាកដក្នុងការសម្រេចចិត្តឈប់ជក់បារី ។ ចំណុចនេះមានសារៈសំខាន់ណាស់ ព្រោះអ្នកជក់បារីមិនអាចឈប់ជក់បានដោយគ្មានការតាំងចិត្តនោះទេ ។ កាលណាមានការតាំងចិត្តកាន់តែខ្លាំងក្លានោះជោគជ័យនៃការផ្ដាច់បារីក៏កាន់តែជាក់លាក់ដែរ ។

២. កំណត់កាលបរិច្ឆេទច្បាស់លាស់ដើម្បីឈប់ជក់បារី : ត្រូវជួយគាត់ក្នុងការកំណត់កាលបរិច្ឆេទឈប់ជក់បារីឱ្យច្បាស់ ។ ត្រូវធ្វើភ្លាមៗតែម្ដង ព្រោះការពន្យារពេលអាចធ្វើឱ្យការតាំងចិត្តធ្លាក់ចុះ ។ បន្ទាប់មក ឱ្យគាត់ចុះកាលបរិច្ឆេទនោះក្នុងខិត្តប័ណ្ណដោយមានចុះហត្ថលេខាផង ។

៣. ការត្រៀមខ្លួនឈប់ជក់បារីដោយ ៖

- បោះចោលបារីនិងចានគោះបារី
- នៅឱ្យឆ្ងាយពីអ្នកជក់បារី ព្រោះការឃើញគេជក់ នាំឱ្យនឹកឃើញចង់ជក់ដែរ
- ចៀសវាងកុំទទួលទានគ្រឿងស្រវឹង ឬកាហ្វេក្នុងដំណាក់ដំបូងនៃការឈប់ជក់បារី
- គួរតែទទួលទានបន្លែនិងផ្លែឈើឱ្យបានច្រើន

- ទទួលទានដំណេកឱ្យបានគ្រប់គ្រាន់និងហាត់ប្រាណឱ្យបានទៀងទាត់ ដើម្បីឱ្យមានអារម្មណ៍ល្អ
- សុំការគាំទ្រពីក្រុមគ្រួសារនិងមិត្តភក្តិ ។

មុនី ៖ ខ្ញុំគិតថា យោបល់អ្នកទាំងពីរសុទ្ធតែល្អៗ សម្រាប់យកមកអនុវត្តក្នុងការជួយអ្នកជក់បារីឱ្យឈប់ជក់បារីបានដោយប្រើវិធី សួរអ្នកជក់បារីគ្រប់ៗគ្នា បើគាត់ពុំទាន់ចង់ឈប់ជក់ទេត្រូវពន្យល់គាត់ពីគ្រោះថ្នាក់និងការខាតបង់ទាំងឡាយដែលកើតឡើងពីការជក់បារីជាមុនសិន ។ ជួយផ្តល់យោបល់ដល់អ្នកដែលចង់ឈប់ជក់ រួចលើកទឹកចិត្តគាត់ឱ្យកំណត់កាលបរិច្ឆេទឈប់ជក់ ។ ត្រូវតាមដាននិងបន្តជួយពួកគាត់កុំឱ្យជក់បារីឡើងវិញ ។ ត្រូវលើកទឹកចិត្តឱ្យមានការតាំងចិត្តយ៉ាងពិតប្រាកដក្នុងការឈប់ជក់បារី ។ ត្រូវត្រៀមខ្លួនឈប់ជក់បារី ដោយបោះចោលបារីនិងចានគោះបារី នៅឱ្យឆ្ងាយពីអ្នកជក់បារី ចៀសវាងកុំទទួលទានគ្រឿងស្រវឹង ឬកាហ្វេក្នុងដំណាក់ដំបូងនៃការឈប់ជក់បារី គួរតែទទួលទានបន្លែនិងផ្លែឈើឱ្យបានច្រើន ទទួលទានដំណេកឱ្យបានគ្រប់គ្រាន់និងហាត់ប្រាណឱ្យបានទៀងទាត់ ដើម្បីឱ្យមានអារម្មណ៍ល្អ សុំការគាំទ្រពីក្រុមគ្រួសារនិងមិត្តភក្តិ។ យើងសង្ឃឹមថា គំនិតប្រកបដោយសុទិដ្ឋិនិយមទាំងនេះនឹងបានរួមចំណែកក្នុងការជួយឱ្យអ្នកជក់បារីឈប់ជក់បារីបាន ។

ដូច្នេះ មុនពេលធ្វើសំយោគ អ្នកត្រូវញែករវាងគំនិត មតិ យោបល់ ទស្សនៈដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នា និងគំនិតផ្សេងៗទៀត ។ ពេលធ្វើសំយោគ អ្នកត្រូវផ្តុំគំនិត មតិយោបល់ ទស្សនៈដែលដូច ឬប្រហាក់ប្រហែលគ្នាដាក់ជាក្រុម ។ បន្ទាប់មក អ្នកត្រូវធ្វើសេចក្តីសន្និដ្ឋានដោយទាញយកតែគំនិតត្រឹមត្រូវ ។ ចំណែកគំនិតផ្សេងៗទៀត អ្នកគ្រាន់តែអះអាងថា គឺជាការយល់ឃើញមួយ ។

## លំហាត់

ចូរអ្នកសំយោគគំនិតក្នុងអង្គពិភាក្សាទៅលើប្រធានបទ ៖

១. ការជ្រើសរើសអាជីពសម្រាប់អនាគត

២. ការបង្កើតក្លឹបសិក្សា

៣. ការបង្កើតកម្មវិធីឥណទានទ្រទ្រង់សាលារៀន

៤. ការបង្កើតក្រុមផ្សព្វផ្សាយអប់រំសុខភាព ... ។



# ឪពុកក្មេករើសកូនប្រសា



## ក. សិក្សាពាក្យគន្លឹះ

- កល (ន) : ឧបាយយ៉ាងល្អិត ល្បិច ។
- កំពប់ (ន) : ខ្ចាត់ខ្ចាយ រាយរាយ ខ្ចាត់ចេញ ។
- ឆាយ (ន) : ទាក់កកាយឱ្យរាយ ឱ្យរាប ឱ្យស្មើ ។
- ឆ្អែង (ន) : ដែលមិនកប ។
- ស្ទាក់ (ន) : ដែលចេះតែសមប្រកបនឹងការស្វែង ដែលចេះជួបប្រទះលាភ ។
  ឧទាហរណ៍ : ឆ្អែស្ទាក់ ។
- តម (កិ) : កាន់ត្រណម ជៀសវាងមិនប្រព្រឹត្ត មិនធ្វើ តមខ្លាញ់ តមបង្អែម ។
- ឧបាយ (ន) : ល្បិច ល្បិចល្បង កិច្ចកល កលមាយារ ។
- ការុង (ន) : ប្រដាប់ច្រកអ្វីៗ ពួកស្បោង បាវ ប៉ូវតេ ។
- អម្រែក (ន) : វត្ថុដែលត្រូវរែក ទឹកមួយអម្រែក សំណាបមួយអម្រែក
- ស្បូវ (ន) : ស្មៅមួយប្រភេទ វែងៗ រឹងគគ្រាត មានពីរប្រភេទ គឺស្បូវភ្លាំង ស្បូវស្លឹកធំៗ

## ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ ចូរអ្នកអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទង នឹងតួអង្គ ខ្លឹមសារអត្ថបទ ប្រភេទអក្សរសិល្ប៍ លក្ខណៈអក្សរសិល្ប៍ ប្រធានរឿង កាលអាកាស មូលបញ្ហា ចំណោទបញ្ហា សង្គមបរិយាកាស និងតម្លៃអប់រំរឿង ។

## គ. អត្ថបទ

កាលពីព្រេងនាយ មានតាចាស់ម្នាក់និងដូនចាស់ម្នាក់នៅស្រុកមួយ ។ គាត់មានកូនក្រមុំម្នាក់ រូបល្អណាស់ ។ អ្នកណាទៅដណ្ដឹងក៏គាត់មិនព្រមឱ្យ គាត់ថាអ្នកណាតមមិនជេរម្ដាយគេបាន ទើបគាត់ឱ្យកូនជាប្រពន្ធអ្នកនោះ ។ ជួនជាថ្ងៃមួយនោះ មានកំលោះម្នាក់រូបរាងស្អាតបាតចូលទៅដណ្ដឹងកូនគាត់ ។ គាត់និយាយថា ៖ អញឱ្យឯង ឯងកុំព្រួយចិត្ត ប៉ុន្តែឯងត្រូវតមជេរម្ដាយ ហើយទទួលបម្រើអញតាមពាក្យអញបានអញឱ្យឯង ។ បើតមមិនបានអញផ្ដាច់ អញប្រាប់ឯងមុនឱ្យដឹងក្រោយមុខឯងកុំថាអញកាចណា ! កំលោះនោះថា ៖ ខ្ញុំបាទតមជេរម្ដាយគេបាន ហើយធ្វើការអ្វីៗបានទាំងអស់ ខ្ញុំបាទទទួលសព្វគ្រប់ប្រការតាមប្រសាសន៍លោកឪពុក ។ តានោះថា ៖ អើ ! បើឯងតមជេរម្ដាយគេបានមែន ឯងទៅសិនចុះព្រឹកត្រូវឯងមកពីព្រលឹម ។

ព្រឹកឡើងកំលោះនោះ ចូលទៅបម្រើឪពុកម្ដាយក្មេក ។ តានោះប្រើកូនក្រមុំគាត់ ឱ្យរៀបបាយទឹកឱ្យកំលោះនោះ រួចហើយតាប្រាប់ថា ៖ កូនចាប់ក្របីភ្ជួរស្រែ កូនភ្ជួរដល់កាលណាថ្មនៅខាងស្រែនោះយំតេវៗ សឹមឯងដោះក្របីលែង ។ អ្នកកំលោះទៅចាប់ក្របីមកទឹម ហើយទៅភ្ជួរស្រែតាំងពីព្រលឹមដល់ថ្ងៃត្រង់ក៏ថ្មពុំយំ ក្របីដើរពុំរួច ក៏ថ្មចេះតែឈឹងពុំយំសោះ ។ អ្នកកំលោះឃ្លានបាយណាស់ទ្រាំពុំបានក៏ជេរថា ៖ ម្ដាយអាថ្មនេះ កាលណានឹងយំឡើង ។ កំលោះនោះជេរតែប៉ុណ្ណោះ តានោះក៏ស្ទុះចេញពីក្រោយថ្មមកថា ៖ ណ្ហើយ ! ឯងដោះក្របីលែងទៅផ្ទះចុះ អញផ្ដាច់កូនហើយ ត្បិតឯងតមជេរម្ដាយមិនបាន ។ កំលោះនោះក៏ដោះក្របីលែងហើយទៅផ្ទះវិញ ។

ថ្ងៃក្រោយមក មានកំលោះម្នាក់ចូលទៅដណ្ដឹងកូនតានោះទៀត ។ គាត់បង្គាប់ដូចកំលោះមុនតែអ្នកកំលោះក្រោយមានប្រាជ្ញា ពេលទៅភ្ជួរស្រែវេចបាយទៅស៊ីផង លុះភ្ជួរដល់ថ្ងៃខ្ពស់ឃ្លានបាយក៏បញ្ឈប់ក្របីស៊ីបាយ ភ្ជួរដល់ថ្ងៃជ្រេក៏ថ្មពុំយំ ក្របីអស់ជើងដើរពុំរួច ។ អ្នកកំលោះនោះកាលណាបើបរក្របីទៅជិតថ្មធ្វើស្ដីថា ៖ ឱ ! លោកថ្មអើយ យំឡើងក្របីដើរពុំរួចទេអាណិតក្របីផងទៅ ខ្លួនខ្ញុំឥតបើអីទេ ខ្ញុំមានបាយហើយ ភ្ជួរដល់យប់ក៏បានដែរ បើមិនអាណិតខ្ញុំ អាណិតតែក្របីទៅចុះត្បិតវាជា

សត្វ ។ កំលោះនោះអង្វរដូចម្ដេចក៏ថ្មពុំយំ អ្នកកំលោះក៏ពុំជេរត្បិតដឹងថា តានោះនៅពួនក្រោយថ្ម ។ លុះនិយាយយូរៗទៅតានោះមើលឃើញក្របីដើរពុំរួចមែន គាត់នឹកអាណិតក្របីក៏យំក្រោយថ្មនោះឮសូរតេវៗ ។ អ្នកកំលោះនោះក៏ដោះក្របីឱ្យស៊ីស្មៅ ហើយត្រឡប់មកផ្ទះឪពុកក្មេកវិញ ។ តានោះក៏ឱ្យកូនគាត់លើកបាយមកឱ្យអ្នកកំលោះនោះស៊ី ។ លុះល្ងាចតាប្រាប់ថា ៖ កូនអើយទៅផ្ទះឯងចុះ ! ព្រឹកសឹមឯងមកវិញ ។

កំលោះនោះក៏លាទៅផ្ទះ លុះពេលយប់មកលបចាំស្ដាប់នៅក្រោមដំណេកតានោះ ដើម្បីយកការណ៍ព្រោះគាត់និយាយគិតគូរនឹងប្រពន្ធគាត់ទាល់តែដេកលក់ ។ តាចូលដេកក៏ពិគ្រោះនឹងយាយថា ៖ យាយ! អានេះវាតមជេរម្ដាយបាន ប៉ុន្តែរូបរាងអាក្រក់មិនសមនឹងកូនយើង ដូច្នេះយើងរកឧបាយយ៉ាងណាឱ្យវានឹងជេរម្ដាយ យើងនឹងផ្ដាច់កូនពីវា ។ ដូនឆ្លើយ ៖ ងាយទេ បើដូច្នេះ តាឯងចូលទៅក្នុងការុងមួយ ការុងមួយទៀតដាក់អង្ករ ព្រឹកឡើងវាមក ចាំខ្ញុំប្រាប់វាថា តាទៅកាប់អុសលើភ្នំមុនហើយ ។ ខ្ញុំឱ្យវាវែកតាឯងនិងអង្ករទៅលើភ្នំពេលវាធ្ងន់វាខឹង វាជេរនោះតាឯងនៅក្នុងការុងឮហើយចេញមកវិញផ្ដាច់វាបានដោយងាយ ។ តាយាយគិតគ្នាហើយក៏ដេកទៅ ។ ឯចៅនោះលបស្ដាប់ដឹងការណ៍ហើយក៏វិលទៅដេកផ្ទះ ។

ព្រឹកឡើង អ្នកកំលោះនោះទៅបម្រើម្ដាយឪពុកក្មេក ក៏ស្រាប់តែឃើញយាយចាស់បង្ហាញអម្រែក ហើយប្រាប់ថា ៖ កូនអើយ ! ឪពុកឯងទៅកាប់អុសលើភ្នំហើយ គាត់ផ្ដាំថាឱ្យកូនឯងវែកអង្ករនោះឡើងទៅតាមគាត់ឱ្យឆាប់ត្បិតគាត់ទៅពីព្រឹកមិនទាន់ហូបបាយផង មានតែកូនឯងវែកទៅឆាប់ៗនឹងអាលដណ្ដាំបាយឱ្យឪឯងហូប ។ កំលោះនោះវែកអម្រែកទៅតាមជើងភ្នំ ដល់ឡើងបន្តិចទៅធ្ងន់ណាស់ក៏វែកចុះមកវិញហើយស្រដីថា ៖ ឱ !ឪអើយខ្ញុំឃ្លានបាយហើយ ខ្ញុំវែកឡើងទៅលើភ្នំមិនបានទេបើធ្ងន់ម្ល៉េះ ! នរណានឹងវែកឡើងរួច ។ បើឪមិនអាណិតជេរបន្ទោសដូចម្ដេចក៏ទទួល ។ និយាយហើយអ្នកកំលោះវែកចុះមកវាលវិញ ។ លុះវែកដល់កន្លែងមួយឃើញស្បូវស្ងួតល្អ ក៏វែកទៅដាក់កន្លែងស្បូវនោះ ហើយដើរទៅបាត់មួយស្របក់ ទើបត្រឡប់មកវិញយកភ្លើងដុតជុំវិញអម្រែក ។ ពេលភ្លើងឆេះស្បូវ តាចាស់ដែលនៅក្នុងការុងបំរះញ័ររង្គើទាំងអម្រែកភ័យក្រែងភ្លើងឆេះស្លាប់ ប៉ុន្តែចេញមិនរួច ។ អ្នកកំលោះធ្វើជារត់មកពីណាស្រែកថា ៖ ដើ ! នរណាដុតភ្លើងឆេះអម្រែកអញអស់ធ្វើដូចម្ដេចនឹងអញចូលទៅបានភ្លើងឆេះខ្លាំងយ៉ាងនេះចូលពុំរួចទេ ។ ថាហើយស្រែកឈរនៅក្រៅលុះភ្លើងឆេះដល់ការុងរលាកតាចាស់បម្រះញ័រទទ្រើក ។ អ្នកកំលោះស្រាយមាត់ការុងចេញ ឃើញឪពុកក្មេករលាកភ្លើងឆេះទាំងសក់ក្បាលផងក៏ជម្រាបថា ដើលោកឪ ! ម្ដេចក៏មិនប្រាប់កូន កុំអីភ្លើង

នេះស្លាប់ចោលម៉ែឱ្យនៅមេម៉ាយ តាខឹងណាស់តែមិនដឹងធ្វើដូចម្ដេច ។ តាឡើងដើរតយង៉យមកផ្ទះវិញទាំងទ្រមខ្លួន ។ ណាមួយដោយវាអូសចេញពីភ្លើង ណាមួយដោយសាររលាកភ្លើង ។ មកដល់ផ្ទះលែងស្ដីមួយម៉ាត់ ហើយប្រាប់កូនប្រសាថា ទៅផ្ទះចុះព្រឹកសឹមមក ។

កូនប្រសាទៅផ្ទះ ដល់យប់លបពួនក្រោមផ្ទះស្ដាប់ទៀត ។ លុះយប់ តាយាយចូលដេកនិយាយគិតគ្នាទៀត តាថា គិតដូចម្ដេចនឹងផ្ដាច់វាបាន បើអានេះវាមានប្រាជ្ញាណាស់ តែនឹងឱ្យកូនទៅវាដូចជាមិនសមនឹងកូនយើងសោះ ។ យាយថា អើ ! ឥឡូវយើងគិតថា តាឯងធ្វើម្ចាស់ ឱ្យវាធ្វើឆ្កែ ឱ្យវាវារដូចឆ្កែនាំទៅរកអណ្ដើក បើវារកអណ្ដើកមិនបាន ឬវាបោលមិនទាន់នោះយើងផ្ដាច់វាបាន ។ តាចាស់ថា អើ ! យាយគិតដូច្នេះត្រូវ ព្រឹកអញធ្វើដូចឯងថា ។ តាយាយគិតគ្នាហើយក៏ដេកទៅ ។ ឯអ្នកកំលោះនោះស្ដាប់ដឹងការណ៍អស់ហើយវិលទៅផ្ទះរកទិញអណ្ដើកមកទុក ។ ដល់មាន់រងាវ ទើបពុនអណ្ដើកយកទៅចងទុកក្នុងគម្ពោតស្មៅវាល ឯនេះ ឯនោះពាសពេញតែវាល ។ លុះព្រហាមឡើងចៅនោះទៅដល់ផ្ទះឪពុកម្ដាយក្មេក យាយបានឱ្យកូនក្រមុំរៀបបាយទឹកឱ្យចៅនោះបរិភោគរួចក៏ប្រាប់ថាកូន ! ឥឡូវនេះយើងទៅរកអណ្ដើកក្រែងបានមួយពីមកហូប ប៉ុន្ដែយើងគ្មានឆ្កែ កូនឯងធ្វើឆ្កែ ឪធ្វើម្ចាស់ ។

តាចាស់ពុនបាយសំណុំ ទឹកបំពង់ដើរចេញពីផ្ទះទៅ ។ ចៅនោះក៏បោលដើងបួនតាមក្រោយកិតៗ ។ ទៅដល់វាលកន្លែងចងអណ្ដើកនោះ ក៏បោលទៅមុនចូលគម្ពោតស្មៅមួយរួចកោះង៉ុសៗ ។ តាចាស់ទៅដល់ខាំបានអណ្ដើកមួយ ហើយបោលទៅទៀតរហូតរកបានអណ្ដើកប្រាំមួយប្រាំពីរ ។ ដល់ថ្ងៃត្រង់ តាចាស់ឃ្លានបាយពេកណាស់ ក៏អង្គុយគិតស្រាយបាយស៊ី ។ ឆ្កែមើលទៅខាង ឃើញក្របីមួយហ្វូងក៏បោលទៅខាំក្របីឱ្យបោលចូលស៊ីស្រូវស្រែអ្នកស្រុក ។ តាឃើញហើយក៏រត់ទៅដេញក្របីចេញពីស្រែ ឆ្កែបានឱកាសបោលមកស៊ីបាយអស់ ហើយក៏បោលទៅបាត់ ។ ឯឪពុកក្មេកម្ចាស់ឆ្កែវិលមកវិញរកបាយស៊ីគ្មានខឹងណាស់ដេញវាយពុំទាន់ ណាអស់កម្លាំងឃ្លានបាយ ណាផ្លូវឆ្ងាយខំដើរមកផ្ទះវិញមិនចង់រួច បន្ទោសឆ្កែមិនបានត្បិតឆ្កែចំណាំតែអឺចឹង ។ ដល់ផ្ទះទទួលទានបាយរួច តាប្រាប់កូនប្រសាថាទៅផ្ទះចុះព្រឹកសឹមមកវិញ ។

ពេលយប់កូនប្រសាមកលបស្ដាប់តាយាយទៀត ។ តាប្រាប់រឿងរ៉ាវទៅយាយចប់សព្វគ្រប់ហើយ ឱ្យយាយជួយគិតទៀត ។ យាយគិតថា ពីមុនវាធ្វើឆ្កែ តាឯងធ្វើម្ចាស់ វាធ្វើបាបតាឯងបាន ព្រឹកនេះតាឯងធ្វើឆ្កែ ឱ្យវាធ្វើម្ចាស់ម្ដង ។ តាយាយគិតគ្នាហើយក៏ដេកទៅ ។ ចៅនោះដឹងការណ៍ហើយក៏ទៅដេកធ្វើហី ។

ព្រឹកឡើងអ្នកកំលោះទៅបម្រើឪពុកម្តាយក្មេកទៀត ។ តាយាយឱ្យកូនក្រមុំលើកបាយមកហូប រួចតាប្រាប់ថា កូនអើយ ! ពីម្សិលមិញឯងធ្វើភ្នែក ថ្ងៃនេះឯងធ្វើម្ចាស់ អញធ្វើភ្នែកម្តងវិញ ។ ចៅនោះឆ្លើយបាទ ហើយពុនបាយទឹកទៅ ឯតាបោលធ្វើភ្នែកតាមក្រោយ ។ លុះហួសផ្ទះបន្តិចចៅនោះ ខំដើរយ៉ាងលឿនកុំឱ្យភ្នែកបោលទាន់ ។ តាបោលពុំទាន់ត្បិតខ្លួនចាស់ ដើរត្រុកៗតាមក្រោយ ចៅនោះបែរមកនិយាយថា ភ្នែកអីស៊ីតែបាយបង្អស់ ទៅមុខមិនទៅដើរតែក្រោយម្ចាស់រកអណ្តើកម្តេចបាន ។ និយាយផុតពីមាត់អ្នកកំលោះវាយភ្នែកឱ្យបោលទៅមុខ ។ តាបោលក្នុងស្មោមិនរួចចេះតែតាមក្រោយ អណ្តើកក៏រកមិនបាន កូនប្រសាវាយស្ទើរស្លាប់ ហត់ស្ទើរដាច់ខ្យល់តែពុំហ៊ានស្តី ព្រោះខ្មាសកូនប្រសា ។ លុះទៅឆ្ងាយដល់ថ្ងៃត្រង់ អ្នកកំលោះស្រាយបាយស៊ីនិយាយទៅកាន់ថា ភ្នែកអីរកអណ្តើកមិនបាន ដើរតែក្រោយមនុស្ស ស៊ីតែបាយបង្អស់ កុំស៊ីបាយអីថ្ងៃនេះ ! ចៅនោះបង្អត់បាយភ្នែកមិនឱ្យស៊ី ឱ្យតែអ៊ឹងភ្នែងអង្គៀមមិនបែកត្បិតគ្មានធ្មេញ តាឃ្លានណាស់អង្គុយមើលតែមុខចៅនោះ ។ កូនប្រសាស៊ីបាយហើយវាយភ្នែកមួយព្រនង់ហើយនិយាយថា ណ្ហើយ ! ទៅផ្ទះវិញមិនផេះទេ ភ្នែកអីភ្នែងយ៉ាងហ្នឹង ! តាចាស់ហត់ណាស់វារមិនរួចឡើងដើរតាមក្រោយ ។ កូនប្រសាទៅដល់ផ្ទះប្រាប់ម្តាយក្មេកថា ម៉ែ! រកអណ្តើកមិនបានទេ ព្រោះភ្នែកមិនស្វាក់ ។ តាចាស់ខឹងណាស់ប្រាប់កូនប្រសាថា ឯងទៅផ្ទះចុះព្រឹកសឹមមកវិញ ។

ចៅនោះក៏លាទៅ ដល់យប់មកលបស្តាប់ទៀត ។ យាយគិតថា ឥឡូវមានតែពេលមាន់រងាវឡើងតាឯងលុបមុខ ស៊ីស្លា ហូបបាយ ហើយចូលទៅក្នុងការុងមួយ ការុងមួយទៀតច្រកអង្ករ ។ ព្រឹកឡើងវាមក ខ្ញុំប្រាប់វាថា តាឯងទៅផ្សារទិញអីវ៉ាន់ ។ ខ្ញុំប្រាប់វាឱ្យរែកទៅឱ្យទាន់វេលាស៊ីបាយព្រឹកត្បិតផ្លូវទៅផ្សារក៏ឆ្ងាយដែរ ។ បើវារែកទៅមិនទាន់ មកវិញផ្តាច់វាបានដោយងាយ ។ មួយទៀតដល់ពាក់កណ្តាលផ្លូវវាធួន់ វាប្រហែលឃើញផ្លូវស្ងាត់ ហើយវាជេរមិនខាន ។

លុះព្រឹកឡើង ម្តាយក្មេកឱ្យកូនប្រសាធ្វើតាមអ្វីដែលគាត់គិតពីយប់ ។ ចៅនោះរែកដើរហើយគិតថា ម្តងនេះអញធ្វើឱ្យឪពុកក្មេកឱ្យកូនមកអញ ដោយមិនឱ្យគាត់រកឧបាយកលបញ្ឆោតអញទៀតទេ ។ ចៅកំលោះរែកដើរទៅដល់ពាក់កណ្តាលផ្លូវដាក់អម្រែកចុះ ហើយនិយាយម្នាក់ឯងថា ការុងនេះចងមាត់មិនជាប់ទាល់តែចងថែមទៀតទើបមិនកំពប់អង្ករ ។ រែកទៅដល់ផ្លូវមានស្ពានឆ្លងព្រែក វាក៏ដាក់អម្រែកលើស្ពានត្រង់ចុងក្តារនៅតែបន្តិចនឹងធ្លាក់ពីស្ពាន ហើយពោលថា អញអើយថ្ងៃណាស់ហើយ ម៉្លេះសមឪជេរមិនខាន អម្រែកធ្ងន់រែកម្តេចឱ្យទាន់ ។ ណ្ហើយ ! ឪជេរក៏ជេរចុះ អញដាក់នៅទីនេះ ទៅទីវាលសិន រួចសឹមទៅទៀត ។ និយាយបណ្តើរទៅបណ្តើរ ។ មួយសន្ទុះចៅនោះកាន់ឈើធំមួយ ដើរមកពីនាយបុកក្តារស្ពានឬគ្រាំៗ ធ្វើជាដីរីឆ្លងស្ពាន ។ ចៅនោះស្រែកខ្លាំងៗថា នរណាដាក់

អប្រែកលើស្ពាន ដរីអញជាន់ខូចអស់ឥឡូវហើយ យកចេញឱ្យឆាប់។ ស្រែកហើយបុកក្ដារគ្រាំៗចូលមក។ ឯតាចាស់បម្រះជៀសផ្លូវដរីហួសពីក្ដារធ្លាក់ទៅក្នុងទឹក ឈ្លក់ទឹកត្រដរញ៉ររទាំងការុងស្ទើរតែ-នឹងស្លាប់។ កូនប្រសាឃើញដូច្នោះទុកឱ្យផឹកទឹកបន្តិចឱ្យអស់ខូចទៀត។ ចៅកំលោះធ្វើជាដើរមកពីវាលស្រែកថា នរណាហ៊ានបរដរីឱ្យឆាយអប្រែកអញធ្លាក់ទឹកទទឹកអង្ករអញអស់។ ឱអញអើយ ! ឪជេរថែមទៀតហើយ ថ្ងៃក៏កាន់តែខ្ពស់ ហើយអង្ករក៏ទទឹកអស់ថែមទៀត។ កូនប្រសាឃើញឪពុកក្មេកបម្រះញ៉ររក្នុងការុងស្រែកថា ៖ ឪ ! មានត្រីមកបិចផង ណ្ហើយ ! អញចុះទៅស្រង់មើលមើល៍។ ពោលចប់អ្នកកំលោះលោតប្រូងទៅក្នុងទឹកស្រង់ការុងឡើងរួចនិយាយថា ទទឹកអង្ករអស់ទាល់តែស្រាយហាលថ្ងៃ វែកទៅឱ្យម៉ែធ្វើនំបញ្ចុកទុកឱ្យឪ។ ពេលស្រាយឃើញតានៅក្នុងការុងក៏ឧទានឡើងអុញ ! ឪសោះ ម្ដេចក៏មិនស្រែកប្រាប់ខ្ញុំ កុំអីស្លាប់ទៅហើយ គេបរដរីមកពីណាមិនដឹង គេឱ្យដរីឆាយធ្លាក់ទៅក្នុងទឹក។ តាព្ទហើយ ក្រោកឈរដើរវិលមកផ្ទះវិញមិនស្ដីមួយម៉ាត់។ ទៅដល់ផ្ទះ អស់ចំណោះក៏រៀបការកូនក្រមុំឱ្យទៅអ្នកកំលោះនោះទៅ។

*(ដកស្រង់ពីសៀវភៅកំរងអត្ថបទអក្សរសិល្ប៍ថ្នាក់ទី ៦ បោះពុម្ពឆ្នាំ ១៩៨២)*

## សំណួរ

១. តើរឿងនេះមានតួអង្គប៉ុន្មាននាក់ ? ឈ្មោះអ្វីខ្លះ ? តើតួអង្គនីមួយៗបានធ្វើសកម្មភាពអ្វីខ្លះ ?

២. តើរឿងឪពុកក្មេករើសកូនប្រសាមានខ្លឹមសារដូចម្ដេច ?

៣. ចូរបង្ហាញពីលក្ខណៈនិងប្រភេទអក្សរសិល្ប៍ក្នុងរឿង។ ចូរផ្ដល់អំណះអំណាង។

៤. ចូរសិក្សាអំពីប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា កាលអាកាស និងសង្គមបរិយាកាស ក្នុងរឿងឪពុកក្មេករើសកូនប្រសា។

៥. តើរឿងនេះមានតម្លៃអប់រំដូចម្ដេចខ្លះ ?

៦. តើរឿងនេះបង្ហាញពីគំនិតសុទិដ្ឋិនិយមដូចម្ដេចខ្លះ ? តើគំនិតទាំងនោះបង្ហាញតាមរយៈតួអង្គណា ?

# លក្ខណៈរបស់ព្យាង្គ

នៅក្នុងភាសាខ្មែរ ពាក្យនីមួយៗសុទ្ធតែមានព្យាង្គ ពាក្យខ្លះមានមួយព្យាង្គ ពាក្យខ្លះមានពីរព្យាង្គ ពាក្យខ្លះមានបីព្យាង្គ និងពាក្យខ្លះទៀតមានរហូតដល់បួនព្យាង្គ។ ព្យាង្គ គឺជាសូររួមនៃសទ្ទ ដែលបន្លឺឡើងតែមួយបន្សាយសំឡេង។ នៅក្នុងព្យាង្គនីមួយៗមាន សទ្ទដើមព្យាង្គ សទ្ទកណ្ដាលព្យាង្គ និងសទ្ទចុងព្យាង្គ។ ក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីលក្ខណៈរបស់ព្យាង្គ។

លក្ខណៈរបស់ព្យាង្គមានពីរបែប ៖

## ១ . តាមមូលភេទ [អ-អ៊]

តាមមូលភេទ [អ-អ៊] ព្យាង្គមានពីរយ៉ាង គឺព្យាង្គពួក [អ] និងព្យាង្គពួក [អ៊]។

### ក. ព្យាង្គពួក [អ]

*ឧទាហរណ៍ :* សំណាង កាយ ចាប់ ...។

"ស ក ច" ជាព្យញ្ជនៈពួក [អ] នាំឱ្យពាក្យ "សំណាង កាយ ចាប់" ជាព្យាង្គ [អ]។

ព្យាង្គពួក [អ] គឺជាព្យាង្គដែលមានសញ្ញាព្យញ្ជនៈដើមព្យាង្គពួក [អ]។

### ខ. ព្យាង្គពួក [អ៊]

*ឧទាហរណ៍ :* ជួប គង ញាតិ ...។

"ជ គ ញ" ជាព្យញ្ជនៈពួក [អ៊] នាំឱ្យពាក្យ "ជួប គង ញាតិ" ជាព្យាង្គ [អ៊]

ព្យាង្គពួក [អ៊] គឺជាព្យាង្គដែលមានសញ្ញាព្យញ្ជនៈដើមព្យាង្គពួក [អ៊]។

***ព្យាង្គពួក [អ] មានសញ្ញាដើមព្យាង្គពួក [អ]។ ព្យាង្គពួក [អ៊] មានសញ្ញាដើមព្យាង្គពួក [អ៊]។***

## ២ . តាមលក្ខណៈខ្យល់

តាមលក្ខណៈខ្យល់ព្យាង្គមានបួនយ៉ាង គឺព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង និងព្យាង្គខ្លី។

### ក. ព្យាង្គបើក

*ឧទាហរណ៍ :* ស្រែ បើ គ្នា ...។

"[អែ] [អើ] [អា]" នៅខាងចុងព្យាង្គ នាំឱ្យ "ស្រែ បើ គ្នា" ជាព្យាង្គបើក។

*ព្យាង្គបើក គឺជាព្យាង្គដែលមានស្រៈនៅខាងចុង។ វាមានទម្រង់ ពស ឬ ពពស។*

### ខ. ព្យាង្គបិទ

*ឧទាហរណ៍ :* ចាស់ ម្នាក់ ស្រោច ... ។

"[ស] [ក] [ច]" នៅខាងចុងព្យាង្គ នាំឱ្យ "ចាស់ ម្នាក់ ស្រោច" ជាព្យាង្គបិទ ។

> *ព្យាង្គបិទ គឺជាព្យាង្គដែលមានព្យញ្ជនៈនៅខាងចុង ។ វាមានទម្រង់ ពសព ឬ ពពសព ។*

### គ. ព្យាង្គវែង

*ឧទាហរណ៍ :* កូន ថា ស្មើ ... ។

"[អូ]" ជាស្រៈវែង នាំឱ្យ "កូន" ជាព្យាង្គបិទវែង ។ "[អា] [អើ]" ជាស្រៈវែង នាំឱ្យ "ថា ស្មើ" ជាព្យាង្គបើកវែង ។

> *ព្យាង្គវែង គឺជាព្យាង្គដែលមានស្រៈវែង ។*

### ឃ. ព្យាង្គខ្លី

*ឧទាហរណ៍ :* បុក តិច ទៅ ... ។

"[អុ] [អិ]" ជាស្រៈខ្លី នាំឱ្យ "បុក តិច ទៅ" ជាព្យាង្គបិទខ្លី ។ "[អៅ]" ជាស្រៈខ្លី នាំឱ្យ "ទៅ" ជាព្យាង្គបើកខ្លី ។

> *ព្យាង្គខ្លី គឺជាព្យាង្គដែលមានស្រៈខ្លី ។*

## លំហាត់

១. ចូរស្រង់ពាក្យដែលមានព្យាង្គពួក [អ] និងពាក្យដែលមានព្យាង្គពួក [អ៊] ពីល្បះខាងក្រោម ។

ក. យុវជនគ្រប់រូប ត្រូវហ៊ានលះបង់គ្រប់បែបយ៉ាង ដើម្បីបុព្វហេតុការពារបូរណភាពទឹកដីរបស់ខ្លួន ។

ខ. មនុស្សដែលមានសុទិដ្ឋិនិយមក្នុងការធ្វើកិច្ចការ តែងទទួលជោគជ័យក្នុងឆាកជីវិត ។

២. ចូររកពាក្យដែលមានព្យាង្គពួក [អ] ឱ្យបាន១០និងពាក្យដែលមានព្យាង្គពួក [អ៊] ឱ្យបាន១០ ។

៣. ចូរស្រង់ពាក្យដែលមានព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង និងព្យាង្គខ្លីពីក្នុងកថាខណ្ឌខាងក្រោម ។

ពោធិ៍កំបោរ ជាវីរជនដ៏អង់អាចក្លាហាន ។ លោកមានទឹកចិត្តស្នេហាជាតិយ៉ាងជ្រាលជ្រៅ ។ លោកបានដឹកនាំចលនាតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំងដែលត្រួតត្រាលើប្រទេសកម្ពុជា ។ លោកបានបូជាជីវិតដើម្បីបុព្វហេតុរំដោះប្រទេសជាតិ ។ ប្រជាជនខ្មែរគ្រប់រូប គោរព កោតសរសើរ និងនៅចងចាំគំរូវីរភាពនេះក្នុងចិត្តជាប់ជានិច្ច ។

៤. ចូររកពាក្យដែលមានព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង និងព្យាង្គខ្លីក្នុងមួយក្រុមឱ្យបាន១០ពាក្យ ។

# របាយការណ៍

របាយការណ៍ គឺជាការផ្ដល់ព័ត៌មានអំពីបញ្ហាអ្វីមួយឱ្យគេបានដឹង។ របាយការណ៍មានច្រើនប្រភេទដូចជា របាយការណ៍តាមជំនាញ របាយការណ៍អង្គប្រជុំ ឬរបាយការណ៍សិក្ខាសាលា របាយការណ៍កម្មវិធី ឬគំរោង របាយការណ៍បេសកកម្ម ឬទស្សនៈកិច្ច របាយការណ៍ផ្ទាល់ខ្លួន ។ល។ របាយការណ៍ខ្លះ ជាពិសេសរបាយការណ៍តាមជំនាញស្ថាប័នផ្សេងៗត្រូវធ្វើឡើងយ៉ាងទៀងទាត់ ប្រចាំសប្ដាហ៍ ប្រចាំខែ ឬប្រចាំឆ្នាំ។ របាយការណ៍ខ្លះទៀត ធ្វើទៅតាមពេលវេលាដែលគេអនុវត្តការងារអ្វីមួយដូចជា របាយការណ៍អង្គប្រជុំ បេសកកម្ម កម្មវិធី ជាដើម។ ក្នុងការសរសេររបាយការណ៍ ត្រូវរៀបរាប់ឱ្យបានច្បាស់លាស់និងត្រឹមត្រូវជាក់ស្ដែងអំពីព្រឹត្តិការណ៍ សភាពការណ៍ ហេតុការណ៍ និងលទ្ធផលការងារដែលបានអនុវត្ត។

ចូរពិនិត្យទម្រង់គំរូរបាយការណ៍ខាងក្រោម ៖

## ក. របាយការណ៍អង្គប្រជុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

មន្ទីរ អយក. ខេត្ត .......

ការិយាល័យ .............

លេខ ....................

**របាយការណ៍**

ស្ដីពីការប្រជុំ ...............................................

យោងតាមលិខិតបង្គាប់ការលេខ ........... របស់ ........ ចុះថ្ងៃទី ..... ខែ ..... ឆ្នាំ ........

កាលពីថ្ងៃទី ...... ខែ ....... ឆ្នាំ .......... នៅ .................. មានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាព .......................................................................................... ។

- កិច្ចប្រជុំនេះពិភាក្សាលើរបៀបវារៈ

១. ..........................................

២. ..........................................

៣. ..........................................

- សមាសសភាពចូលរួម

១. ..........................................

២. ..........................................

៣. ..........................................

- អវត្តមាន

១. ..........................................

២. ..........................................

៣. ..........................................

ជាកិច្ចចាប់ផ្ដើមប្រធានអង្គប្រជុំបានលើកឡើងនូវ ....................................................................................................................................................................................................................................................................................................................................................................................................................................................................................................................................... ។

អង្គប្រជុំសម្រេចបាន ............................................................................................................................................................................................................................................................................................................................................................................................................................................................................................................................................................... ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង .......... ថ្ងៃទី .......... ខែ ........ ឆ្នាំ ដដែល ។

ធ្វើនៅ ......... ថ្ងៃទី ......... ខែ ........ ឆ្នាំ .......

**អ្នកធ្វើរបាយការណ៍**

ហត្ថលេខានិងឈ្មោះ

បានឃើញនិងឯកភាព

**ប្រធានការិយាល័យ**

ហត្ថលេខានិងឈ្មោះ

## ខ. របាយការណ៍ប្រចាំខែ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

មន្ទីរ អយក. ខេត្ត .......

ការិយាល័យ .............

លេខ ....................

**របាយការណ៍ប្រចាំខែ**

**ប្រធានការិយាល័យ ..............................**

**សូមគោរពជូន**

**ប្រធានមន្ទីរ អយក.ខេត្ត ........................**

**កម្មវត្ថុ :** អំពីលទ្ធផលការងារ .................................................... ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើនេះ ខ្ញុំមានកិត្តិយសសូមជំរាប លោក-លោកស្រី ប្រធានមេត្តាជ្រាបថាចាប់តាំងពីថ្ងៃទី ..... ខែ ...... ឆ្នាំ ......... រហូតដល់ថ្ងៃទី ..... ខែ ......ឆ្នាំ ..... មន្ត្រីរាជការនៅការិយាល័យ .................. បានធ្វើកិច្ចការទទួលលទ្ធផលដូចតទៅ :

**ក. ផ្នែកបុគ្គលិក**

មានបុគ្គលិកចំនួន ...... នាក់ ស្រីចំនួន ........ នាក់ ដោយរៀបចំកិច្ចការអនុវត្តជាក្រុមគឺ :

១. ផ្នែក .................................... ចំនួន ............. ស្រីចំនួន ............ នាក់

២. ផ្នែក .................................... ចំនួន ............. ស្រីចំនួន ............ នាក់

៣. ផ្នែក .................................... ចំនួន ............. ស្រីចំនួន ............ នាក់

**ខ. លទ្ធផល**

១. បានរៀបចំចុះធ្វើយុទ្ធនាការធានាការប្រមូលកុមារចូលរៀន ............................ ។

២. បានធ្វើ ................................................................................... ។

៣. បានរៀបចំ ............................................................................... ។

គ. សំណូមពរ

...................................................................................................................

...........................................................................................................................

.................................................................................................................. ។

សេចក្ដីដូចបានថែងក្នុងកម្មវត្ថុខាងលើនេះ សូមលោកប្រធានជ្រាបជារបាយការណ៍ ។ សូមលោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅ ........ ថ្ងៃទី ......... ខែ ......... ឆ្នាំ ..........

**ប្រធានការិយាល័យ**

ហត្ថលេខានិងឈ្មោះ

ចម្លងជូន

១. ..............

២. ..............

៣. ..............

## លំហាត់

ចូររៀបគ្នាជាក្រុមតូចៗ រួចពិភាក្សាសរសេររបាយការណ៍តាមទម្រង់ខាងលើ ។

១. របាយការណ៍ប្រជុំស្ដីពីពង្រឹងរបស់ការិយាល័យអប់រំ យុវជន និងកីឡា ស្រុកណាមួយ ។

២. របាយការណ៍អង្គប្រជុំបូកសរុបការងារប្រចាំខែរបស់ការិយាល័យអប់រំ យុវជន និងកីឡា ស្រុកណាមួយ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ។

# អក្សរកាត់ក្នុងសៀវភៅនេះ

| | | |
|---|---|---|
| ព្យា. | : | ព្យាង្គ |
| ជំ. កិ. | : | ជំនួយកិរិយា |
| ព. | : | ពង្រីក |
| កំ. | : | កំណត់ |
| គុ. ចំ. | : | គុណនាមចំនួន |
| គុ. ច. | : | គុណនាមចង្អុល |
| គុ. កម្ម. | : | គុណនាមកម្មសិទ្ធិ |
| គុ. ពណ៌. | : | គុណនាមពណ៌ |
| គុ. ប្រ. | : | គុណនាមប្រក្រតី |
| ន. | : | នាម |
| ក. ន. | : | កន្សោមនាម |
| ធ. | : | ធ្នាក់ |
| ក. ធ. ម. | : | កន្សោមមានធ្នាក់ |
| សព្វ. | : | សព្វនាម |

# បទានុក្រមអក្សរសាស្ត្រខ្មែរថ្នាក់ទី១១

(ក)

- កណ្ឋ (ន) : វគ្គ ខ្សែ សង្កាត់ ។ ឧទាហរណ៍ : សាស្ត្រមួយកណ្ឋ ។
- កកកុញ (គុ) : តាន់តាប់ ជុំជិត ត្រៀបត្រា ។
- កន្សែង (កិ) : រ.សៈ យំ សោយសោក ។
- កនិដ្ឋា (ន) : ប្អូន ប្អូនពៅ ។
- កន្ទ្រឹស (ន) : កំណាញ់ស្វិត ។
- កាតព្វកិច្ច [កា.តាប់.ពៈកិច] ន.(បា.) : កិច្ចដែលគួរធ្វើ ការងារដែលត្រូវធ្វើ ។
- កាមតណ្ហា [កាម តន់ ណៈ ហា] ន.(បា.) : ចំណង់ចំពោះកាម សេចក្ដីប្រាថ្នាមិនចេះចប់ក្នុងកាម ។
- ការពារធា (ន)(បា) : អំពើបៀតបៀន អំពើសម្លាប់... ។
- ក្ដាត់ (គុ) : ក្រៃលែង ពេក ណាស់... ។
- កិត្តិគុណ [កិត.តិ.គុន](ន)(បា) : គុណគឺកេរ្តិ៍ឈ្មោះ សេចក្ដីចម្រើនដោយកេរ្តិ៍ឈ្មោះពីរោះពិសា។
- កុងសី ឬកុង្សី (ន)(បា.រ) : ក្រុម ឬពួកអ្នកទូន្មាន ក្រុមជំនុំរាជការផែនដី ។
- កុដុម្ពិក (ន) : អ្នកមានសម្បត្តិដោយផលប្រយោជន៍ កើតអំពីស្រែចំការ ច្បារដំណាំ សំដី និយាយ ក្លាយមកជាកុម្ពី ។
- កូវ (និ)(ព.បុ) : ទេឬ ? ពាក្យសម្រាប់និយាយដោយឆ្ងល់ ។
- កៀង (កិ) : ប្រមូលនាំទៅ ប្រមូលនាំមក ។
- កេណ្ឌ [កែន] (កិ) : ប្រមូលហៅរកដោយអាជ្ញា ។
- កៅទណ្ឌសជ័យ (ន)(សំ.បា) : ធ្នូ និងព្រួញសម្រាប់ព្រះរាជាគ្រងរាជ្យ ។
- កំរោល (ន) : អការៈងឹតមុខជ្រប់ ឬងឹតខ្លាំងដល់ដួលដេក ។
- កោលាហល (ន) : សេចក្ដីភ្ញាក់ផ្អើល ការជ្រួលជ្រើម ។
- ក្រមការ [ក្រំ.មៈកា](ន) : អ្នកធ្វើការងារក្នុងរាជការឃុំ ។
- ក្រសាវ (កិ) : ឈោងចាប់ប្រមូលដោយដៃទាំងពីរ ។
- ក្តីមោហា (ន)(សំ.បា) : សេចក្ដីវង្វេងមិនស្គាល់ខុសត្រូវ ។

- ក្ស័យ (កិ)(សំ) : ការអស់ទៅ បាត់បង់ វិនាស សេចក្ដីបាត់បង់អស់ ។
- ក្សិណ (ន)(សំ. ក្ល) : ពេល ស្របក់ មួយរំពេច ។
- ក្រេវក្រោធទ្រនង់(កិ) : ខឹងខ្លាំង ។

ក្រតីក្រតើន (គុ. ឬគុ. កិ) : ស្ទុះទៅដោយខឹង ។

(ខ)

- ខមាទោស [ខៈមា. ទោស] (ន) : ការសុំអត់ឱនទោស, ការលើកលែងទោស ។

ខ្វាល់ (កិ) : រ. សៈ ខឹង ។

(គ)

- គឃ្លើន (គុ) : ងងើលដែលមានអាការឥតញញើត កោតក្រែង ។
- គ្រោះទុរ្ភិក្ស (ន) : គ្រោះអត់ឃ្លាន ។
- គន្លងធម៌ (ន) : លំអាននៃច្បាប់ ។
- គជា (ន)(បា. សំ) : ដំរីទាំងឡាយ ។
- គង្គា (ន)(បា. សំ) : ឈ្មោះទន្លេធំមួយនៅប្រទេសឥណ្ឌា(ទន្លេ ទឹក) ។
- គុណូបការគុណ (ន)(សំ. បា) : សេចក្ដីទំនុកបម្រុង អនុគ្រោះដោយគុណ ។
- គូលី (ន) : មនុស្សដែលស៊ីឈ្នួលធ្វើការ ។
- គ្រលុក (កិឬគុ. កិ) : បង្ខំគេចូលលុក ។
- គ្រិស្តសករាជ [គ្រិស. ស័ក. រាច] (ន) : សករាជដែលនិយមប្រើក្នុងប្រទេសអឺរុបនិងប្រទេសអាស៊ី ដោយច្រើនក្នុងសម័យសព្វថ្ងៃនេះ ។ (យេស៊ូឬយេស៊ូគ្រិស្ត នាមសាស្ដាម្នាក់ជាអ្នកបង្កើតលទ្ធិឬសាសនាក្រៅដែនឬគ្រិស្ត, កើតនៅបេថ្លេអែម(Betléem)ប្រទេសប៉ាឡេស្ទីនក្នុងរវាងព. ស. ៥៤៥ ទទួលមរណភាពក្នុងកាល ព. ស. ៥៧៤ ក្នុងអាយុគម្រប់ ៣០ឆ្នាំ គឺរវាង គ. ស. ៣០ តាំងសករាជមួយគិតពីថ្ងៃដែលសាស្ដានេះកើត ហៅថាគ្រិស្តសករាជ សរសេរសង្ខេប គ. ស. ) ។ គ្រិស្តសករាជតាំងក្នុងខាងដើមសតវត្សរ៍ទី៦ នៃពុទ្ធសករាជគឺតាំងឆ្នាំទី១ ពីក្នុងកាល ពុទ្ធសករាជ ៥៤៣៩ (ក្រោយពុទ្ធសករាជ៥៤២ឆ្នាំ) ។

(ច)

- ចក្រពត្តិ (ន) : ស្ដេចជាធំមានបុណ្យអំណាចដ៏ពន្លឹក ។
- ចក្រី (ន)(សំ. បា) : ស្ដេច ព្រះមហាក្សត្រ ។
- ចតុបព្វតា (ន)(បា) : ឈ្មោះភ្នំ(ភ្នំបួន) ។

- ចង្អេរគ្រាង (ន) : ចង្អេរធំសម្រាប់ហាលរបស់អ្វីៗ ។
- ចតុរាបាយ [ចតុរ៉ា] (ន)(សំ.បា) : ទីសម្រាប់សត្វដែលមានបាប បណ្តាលឱ្យឃើញស្តែងក្នុងពេល ជិតស្លាប់ ទៅចាប់កំណើតរងទុក្ខមាន៤ យ៉ាងគឺ នរក ប្រេត អសុរកាយ តិរច្ឆាន ។
- ចិត្តចោរកាចកល (ន) : ចិត្តអាក្រក់ ប្រកបដោយល្បិច ។
- ចុតហ្មាយ (ន) : សំបុត្រដែលសរសេរទៅមករកគ្នា ។
- ចេតនា [ចេ តៈ ន៉ា] (ន)(សំ.បា) : គំនិតដែលនាំចិត្តឱ្យភ្ញាក, ឱ្យផ្តួចគំនិត ។
- ចៅក្រម [ចៅ ក្រំ] (ន) : មន្ត្រីតុលាការ, មន្ត្រីអ្នកជម្រះក្តី ។
- ច្រងេងច្រងាង (គុ) : ទទឹងទទែង ច្រឡើសបើស ... ។

(ឆ)

- ឆន្ទៈ [ឆ័ន ទៈ] (ន)(បា.សំ) : សេចក្តីប្រាថ្នា បំណង គំនិត ការយល់ព្រម ។
- ឆ្មក់ (កិ) : លួចល្បក់ ។

  (គុ) : ដែលលបលួចល្បក់ ដែលរកស៊ីដោយឆក់ ។

(ជ)

- ជង់១. (កិ) : ដោតតាមបណ្តោយខ្លួនចុះទល់ពីក្រោម ។

  *ឧទាហរណ៍ :* ជង់ត្រីឈើស្រួច ជង់ជើង ។
- ជង់២. (ន) : អន្ទាក់តឿតតងង មានជើងស្រួចសម្រាប់ដោតនឹងជើង ។

  *ឧទាហរណ៍ :* កុកជាប់ជង់ ។
- ជដាធរ [ ជៈ ដា ធរ ] (ន) (បា.សំ) : អ្នកមានផ្នួងសក់ អ្នកទុកផ្នួងសក់ ។
- ជលធី (ន) (បា.សំ) : ទន្លេ សមុទ្រ... ។
- ជាក់ស្បាន់ (គុឬគុ.កិ) : ប្រាកដ ជាក់ស្តែង ច្បាស់ ។
- ជិនណាយ (កិ) : ទ្រាន់ចិត្ត ណាយចិត្ត ទាល់ចិត្ត ថយចំណង់ ធុញទ្រាន់ ។
- ជីវិតបរិច្ចាគ (ន) : លះបង់អាយុជីវិតជាទាន ។
- ជុក (ន) : កំប៉ូតសក់ ឬផ្នួងសក់ ដែលគេកោរឱ្យនៅសល់ត្រឹមបង្ហើយ ទុកជុក កោរជុក ។
- ជ្រប់ស្រងល់ (និ ឬកិ) : ខិនងប់ដោយកើតទុក្ខខ្លាំងនៅថ្មើង ។
- ជំទាវ (ន) : បណ្តាស័ក្តិសម្រាប់ស្ត្រីជាភរិយាសេនាបតីដោយព្រះករុណាជាម្ចាស់ជីវិត ទ្រង់ព្រះទានតាំង : លោកជំទាវ(លោកស្រី) ។

(ត)

- តបៈ (ន) (សំ) : ការប្រព្រឹត្តរក្សាឧបោសថសីលតាមកាលកំណត់ដែលត្រូវរក្សា ព្រមទាំងការរក្សាប្រជាជនឱ្យបានសុខស្រួល ។ ការប្រព្រឹត្តកាន់វត្តយ៉ាងតឹងរ៉ឹង ដើម្បីធ្វើកាយចិត្តឱ្យស្ងប់ ។
- តក្កមា (កិ) : ភ័យស្លន់ស្លោ ញ័រ ទទ្រាក់ទទ្រើក ។
- តម្រា [ តំ រ៉ា ] (ន) : សេចក្ដីត្រាទុក រឿងដែលកត់ទុកដោយសង្ខេប ក្បួនតូច ។
- តម្លោះ [ តំ ល៉ោះ ] (កិ) : ធ្វើឱ្យធ្លោះ ធ្វើឱ្យភ្លាត់ ឬឱ្យរបូត បន្ធូររបស់ដែលបានដំឡើងហើយឱ្យធូរ ។
- តេជះ (ន) (បា. សំ) : អំណាច អានុភាព កម្ដៅភ្លើង ។
- តាន់ (គុ) : ដែលជិតឥតមានប្រហោង ឧទាហរណ៍ : ថ្មតាន់ ឈើតាន់ ។ របស់ដែលធ្លាប់មានប្រហោង ហើយប្រែជាឥតប្រហោងវិញ : ខ្នាយតាន់ ។
- តិរច្ឆាន [ តិរ៉ាច់ឆាន ឬដិរ៉ាច់ឆាន ] (ន) (បា. សំ) : សត្វដែលមានរាងកាយចម្រើនដោយទទឹង ទីទៃពីសត្វដែលមានរាងកាយចម្រើនដោយត្រង់ ដោយបញ្ឈរ បានខាងចំពួកសត្វនានា ដែលកើតក្នុងមនុស្សលោកមានរាងកាយជាក់ស្ដែងទៅមកដោយទ្រេត ដោយផ្ដេកដូចយ៉ាង គោ ក្របី ដំរី សេះ ។ល ។ ជាសត្វផ្សេងទីទៃពីមនុស្សដែលហៅដោយរួបរួមថា សត្វដែរ ព្រោះមានចិត្តជំពាក់ក្នុងអារម្មណ៍ផ្សេងៗ ប៉ុន្តែមានរាងកាយទៅមកដោយត្រង់ ដោយបញ្ឈរ ។
- តេស្តឈាម (ន) : ការធ្វើវិភាគឈាម ។
- តោក (ន) : ភាជនៈឈើ ឬស្មាច់មានជើងស្រដៀងនឹងតុស្ពាន់ រាងកាច់ជ្រុងក្រឡូមជ្រៅជាងតុច្រើនដាំខ្សង ឬដាំកញ្ចក់ បិទមាសសម្រាប់ដាក់ទ្រអ្វីៗដែលជាវត្ថុចេញមុខ ។
- ត្រាស់ (កិ) : បានដឹង ញែយ្យធម៌សព្វគ្រប់ ។

(ថ)

- ថ្នឹក (គុឬកិរិ) : ដែលអាចអូសដឹកនាំអ្វីៗបានដោយស្រួល ប្រសប់ស្ទាត់ដោយធ្លាប់ ។
- ថ្វាយ (កិ) : ឱ្យ ប្រគល់ បូជា (រ. ស) ឧទាហរណ៍ : ថ្វាយខ្លួន ប្រគល់ខ្លួន ។

7

(ទ)

- ទស្សនវិទូ [ ទ័ស សៈ ន៉ៈ វិ ទូ] (ន) (បា) : អ្នកប្រាជ្ញខាងទស្សនវិជ្ជា ។
- ទស្សនីយភាព [ ទ័ស សៈ នីយ៉ៈ] (ន) (បា) : ភាពដែលគួរមើល គួរឃើញ អ្វីៗដែលគួរឱ្យចង់មើល ចង់ឃើញ ។
- ទស្សន៍ទាយ (ន) : ដំណើរយល់ឃើញ ការយល់ឃើញរបស់នរណាម្នាក់ ។ ឧទាហរណ៍ : ហោរាទស្សន៍ទាយ ។
- ទាសី (ន) (បា. សំ) : ខ្ញុំបម្រើស្រី ។
- ទានបារមី (ន) (បា) : ជាឈ្មោះបារមីទី១ (ការដាក់ទាន) ក្នុងចំណោមបារមីទាំង ១០យ៉ាង ។
- ទិដ្ឋិទ្រុស្ត (ន) : ការយល់ឃើញខុស ការយល់ឃើញមិនត្រឹមត្រូវ ។
- ទិព្វបព៌ត (ន) (បា. សំ) : ឈ្មោះភ្នំ ទិព្វបព៌ត ។
- ទិន្នន័យ [ ទិន-នៈនៃ] (ន) (បា) : ព័ត៌មានពិតជាក់ស្តែងជាលេខ ហើយជាពិសេសត្រូវគេរៀបចំឡើងសម្រាប់វិភាគ ឬប្រើប្រាស់សម្រាប់ធ្វើសេចក្តីសម្រេចចិត្តនានា ។
- ទិដ្ឋភាព [ ទិត-ថៈ] (ន) (បា) : ភាពនៃអ្វីៗដែលគេបានឃើញ បានជួបប្រទះមកហើយ បែបភាព ឬដំណើរទំនងនៃវត្ថុដែលហុចហេតុផលមកឱ្យឃើញ ។
- ទុគ៌ម [ ទុ រៈ គំ] (គុ) (សំ) : ដែលទៅបានដោយកម្រ ដែលកម្រអ្នកអាចទៅដល់ ។
- ទុច្ចរិតវាចា (ន) : សំដីអាក្រក់ អកុសល ។
- ទូរឋាន (ន)(បា) : ទីឆ្ងាយ ។
- ទោសឧក្រិដ្ឋ [-អុក ក្រិត] (ន) : ទោសធ្ងន់ កំហុសធ្ងន់ ។
- ទំនៀម (ន) : បវេណី ធម្មតា សណ្តាប់ សណ្តាប់ធ្នាប់ ទម្លាប់ បែបបទ ... ។
- ទេពកោសល្យ [ ទេប កោ សល់] (ន) : ការប៉ិនប្រសប់ឈ្លាសវៃដូចទេវតា ។
- ទេព្រក្ស (ន)(សំ) : ទេពតាអ្នករក្សាមនុស្ស ឬរក្សាអ្វីៗ ។
- ទៀងសត្យា (គុ)(បា. សំ) : ដែលពិតមិនប្រែប្រួល ។
- ទែនមណី (ន) : ទីកន្លែងសម្រាប់ស្តេចគង់ប្រថាប់ (គ្រែដាំត្បូង) ។
- ទ្រុស្តមិត្ត (កិ) : ធ្វើអាក្រក់ ។
- ទ្រូ (ន) : ប្រដាប់នេសាទធ្វើដោយបន្ទោះឬស្សីក្រងរាងប៉ោងទ្រវែង មានប្រឹសនៅខាងចំហៀង ។

- ទ្រើសឃ្នង (គុ) : ដែលឃ្នើសឃ្នង ។ ឧទាហរណ៍ : មនុស្សច្រឡើសបើស ព្រហើនឈ្លានពាន ។
- ទ្រើសទ្រង់អំណាច(គុ) : ដែលមានអំណាចខ្លាំងក្លាលើសលប់ ។

(ធ)

- ធនបរិច្ចាគ (ន)(បា.សំ) : ការលះបង់ទ្រព្យ ការចំណាយទ្រព្យធ្វើទាន ។
- ធុរៈ (ន) : កិច្ចរវល់ ការរវល់ ។ ឧទាហរណ៍ : ខ្ញុំមានធុរៈប្រចាំខ្លួន ។

(ន)

- នរបតី [ នៈ រៈ ប៉ះ ដី ] (ន) (បា.សំ) : ម្ចាស់នៃអ្នកទាំងឡាយ ។
- នរនាថ (ន)(បា) : មនុស្សដែលជាទីពំនាក់ ។
- នរេន្ទ្រពុទ្ធពង្ស (ន)(បា.សំ) : ពង្សព្រះពុទ្ធជាធំលើសអស់ជនទាំងឡាយ ។
- នទីទេពកញ្ញា (ន) : ស្រីទេពអប្សរប្រចាំស្ទឹង ។
- នាឡិ [ នាល ] (ន) (បា.សំ) : ទម្ងន់ ១៦តម្លឹង ។ រង្វាស់តូចមួយប្រភេទសម្រាប់វាល់អង្ករ ឬវាល់គ្រប់អ្វីៗ មានគ្រាប់សណ្តែកបាយជាដើម ។
- និមន្ត (កិ)(រ.ស) : អញ្ជើញ សូមឱ្យទៅ ឬមក ។
- និន្នាការ (ន) : អាការដែលទ្រេតទេរទៅ ឬដែលលម្អៀងទៅម្ខាងៗ ។
- និទាឃរដូវ (ន) : រដូវក្តៅ ។
- និរភ័យ (គុ)(បា.សំ) : ដែលឥតភិតភ័យ ឥតខ្លាច ។
- និម្មល (គុ)(បា.សំ) : ដែលឥតមន្ទិល ឥតសៅហ្មង ។
- និន្ទា [ និន ទា ] (ន)(បា.សំ) : ដំណើរតិះដៀល ការរិះគន់ ដំណៀល
- នុយ (ន) : អ្វីមួយជាគ្រឿងប្រលោម គ្រឿងទាក់ចិត្ត ចំណីបញ្ឆោត ។
- នួនស្រី (ន) : ឈ្មោះឈើតូចមានផ្កាស ក្លិនក្រអូប ។

(ប)

- បដិបត្តិ ឬប្រតិបត្តិ [ បៈដិប័ត ឬប្រៈតិប័ត ] (ន) : ការប្រព្រឹត្ត កាន់ ធ្វើតាម ច្រើន និយាយថា សេចក្តីបដិបត្តិ ការប្រតិបត្តិ ។
- បច្ចាមិត្ត ឬប្រត្យាមិត្រ [ ប៉ុច ចាមិត ឬប្រ័ត ត្យាមិត ] (ន): អមិត្ត សត្រូវ ។
- បរិយាកាស (ន)(បា.សំ) : អាកាសធាតុដែលនៅជុំវិញផែនដី ហើយដែលតែងតែប្រែប្រួលជាប្រក្រតី ។

- បដិសេធ (កិ) : ទំនាស់មិនយល់ស្រប ... ។
- បរិស្ថាន (ន)(សំ) : ទីកន្លែងដែលនៅជុំវិញ ។
- បរិវិតក្កគាថា (ន)(បា.សំ) : កំរងវាចាប្រកបដោយសេចក្ដីត្រិះរិះ ។
- បញ្ចុះបញ្ចូល (កិ) : និយាយណែនាំពន្យល់ឱ្យចុះចូល ។
- បន្ទាយ [ បន់ ទាយ ] (ន) : ដីលើកខ្ពស់ ឬកំពែងមាំមួនព័ទ្ធជុំវិញជារនាំងការពារសឹកសត្រូវ ដែលជាទ័ពខ្មាំង ។
- បរម (គុ)(បា.សំ) : ឧត្តមខ្ពង់ខ្ពស់ ប្រសើរក្រៃលែង ។
- បន្ទូល (ន)(រ.ស) : សំដី ការនិយាយ ។
- បា (ន) : អ្នករក្សា អ្នកគ្រប់គ្រង ... ឬជាពាក្យសម្រាប់ហៅកូនប្រុស ឬហៅអ្នក ដែលមានអនុភាពតិចជាងខ្លួន ហើយទុកស្មើកូនប្រុសបង្កើត ។
- បាល័ដ្ឋ (ន) : អ្នកមាននាទីជាអ្នកថែរក្សាស្រុក ឬថែរក្សាខេត្ត ។
- បារមី (ន)(បា.សំ) : គុណជាតិដ៏ល្អដែលបុគ្គលគួរបំពេញ ។
- បាវ (ន) : ទាសៈ ឬទាសី គឺខ្ញុំប្រុស ឬខ្ញុំស្រី ។
- បាតុភូត (ន)(បា.សំ) : អ្វីៗដែលកើតមានឡើង ។
- បុណ្យសក្តិ (ន) : អំណាចតេជៈដែលបានដោយសារ (យសសក្តិ ឬការងារ) ។
  *ឧទាហរណ៍ :* ឡើងបុណ្យសក្តិ ។
- បុគ្គលការណ៍ (ន) : ហេតុការណ៍ដែលតំណាងឱ្យបុគ្គលម្នាក់ ។
- បូជនីយដ្ឋាន [ បូជៈ នីយថាន ] (ន) : ទីកន្លែងសម្រាប់បូជា ។
- បេតិកភណ្ឌ (ន)(បា) : ទ្រព្យ ឬមត៌កមានជាប់ពីខាងឪពុក ។
- បោក្ខរព័ស៌ [ បោក ខៈ រ៉ៈ ព័រ ](ន) (បា.សំ) : ភ្លៀងមានអាការដូចជាទឹកធ្លាក់លើស្លឹកឈូក ។
- ប្រសិទ្ធិ [ ប្រសិត ធិ ] (ន) : ការតាក់តែង ការប្រដាប់ ដំណើរធ្វើឱ្យសម្រេច ។
- ប្រទក្សិណ (កិ) : ការសម្ដែងសេចក្ដីគោរពស្រលាញ់ដោយដើរព័ទ្ធជុំវិញវត្ថុ ឬបុគ្គល ដោយឱ្យវត្ថុ ឬបុគ្គលនោះនៅខាងស្ដាំដៃ ។
- ប្រមាថ [ -ម៉ាត ](ន)(សំ) : ការបៀតបៀនគេ ការញាំញីគេ ការធ្វើទុក្ខបុកម្នេញឱ្យគេលំបាក ការមើលងាយគេ ។
- ប្រតិស្ឋនាម [ ប្រ ដឹស នាម ] (ន) : ការកំណត់នាម ការផ្ដល់នាម ។
- ប្រាជ្ញាសារពេជ្ជតាញ្ញាណ (ន) (បា.សំ) : ការយល់ច្បាស់លាស់ ។

- បុត្តបរិច្ចាគ (ន) (បា. សំ) : ការលះបង់កូនជាទាន ។
- ប្រឹស (ន) : មុខទ្រូ ឬលបមានបន្ទោះរួមក្រួចខាងចុង ទុកផ្លូវច្រហាខាងមាត់ ឱ្យល្មមតែត្រីចូលបណ្តោយទៅខាងក្នុងបាន តែចេញច្រាសមកវិញពុំរួចឡើយ ។ ឧទាហរណ៍ : ប្រឹសទ្រូ ប្រឹសលប ។
- ប្រស្រី (គុ) : ភ្លឺថ្លា យល់ហេតុការណ៍ច្បាស់លាស់ ។
- ប្រផូរប្រផាន់ (គុ) : ដែលល្អិតផូរផង់ ដែលផូរផង់ប្រពៃ ។
- ប្រញត្តិ=បញ្ញត្តិ (ន)(បា. សំ) : សេចក្តីដែលគេតែងតាំង បម្រាម ។
- ប្រណិប័តន៍ (ន)(បា. សំ) : ការសម្តែងសេចក្តីគោរព ការគំនាប់ ការឱនសំពះ ។
- ប៉ុនកេសី (គុ) : ប៉ុនសក់ ។
- ប្រយង្គ ឬប្រយង្គុ [ ប្រយ៉ង់ ] (ន) ឈ្មោះឈើតូចមួយពួកមានផ្កាជាចង្កោមកំរងល្អិតៗសម្បុរលឿងក្លិនក្រអូបឆ្ងាញ់ ប៉ុន្តែក្រអូបស្មើយ ។
- ប្រតិភូ (ន)(បា. សំ) : អ្នកធានា អ្នកជាជំនួស អ្នកទទួលអំណាចធ្វើការជំនួស ។
- ប្រថមាភិសេក (ន)(សំ) : ការអភិសេកមុនគេ ។

(ផ)

- ផាសុកភាព (ន)(បា) : ភាពដែលនាំឱ្យមានសេចក្តីសុខ ។
- ផ្នត់គំនិត (ន) : គំនិតដែលប្រកាន់តាំងពីដើមរៀងរហូតមក ។
- ផ្នួស (ន) : ការបួស អំពើបួស ... ។
- ផ្កុលផ្កា (កិ) : ចេញផ្កា ។

(ព)

- ពលី (កិ) : បូជា លះបង់ ថ្វាយ ។
- ពលិការ (ន) : ការបូជា ការបួងសួង ។
- ពនេចរ (ន)(បា. សំ) : អ្នកត្រាច់ទៅក្នុងព្រៃ (ព្រានព្រៃ) ។
- ពលតេជះ (ន)(បា. សំ) : កម្លាំងអំណាច ឬអំណាចដោយប្រើកម្លាំង ។
- ពពារ (ន) : អាការសម្បើមរបស់ពស់ដែលប្រឹងដំឡើងកឱ្យរីកធំជាងប្រក្រតី ។
- ពាក្យសត្យ (ន)(សំ) : ពាក្យពិត ។
- ពិដោរ (គុ) : ដែលមានក្លិនក្រអូបល្អ ។
- ពិស្សុត (គុ) : ល្បីល្បាញ ។

- ពិស្សុតសោភា (គុ)(បា) : ដែលល្បីល្បាញល្អ ។
- ពិស្ណុ ឬវិស្ណុ [ពិស-ស្ណុ ឬ វិស-ស្ណុ] (ន) ព្រះនារាយណ៍ (នារាយណ៍ (ន) នាមម្យ៉ាងរបស់វិស្ណុ នាមនេះហៅដោយអានុភាព ដែលវិស្ណុចេះបែងភាគឱ្យកើតជារូបផ្សេងៗមានរូបមនុស្ស ជាដើម) ។
- ពិរោធ [-រោត] (ន)(សំ) : កំហឹង កំហុស សេចក្ដីស្អប់ ដំណើរឈ្លោះទាស់ទែង សត្រូវ ។
- ពិពិធពិពណ៌ (ន) : ការពិពណ៌នាមានលក្ខណៈផ្សេងៗ ការរៀបរាប់ដោយប្រការផ្សេងៗ ។
- ពុទ្ធដីកា [ ពុត ដី កា] (ន) : ព្រះបន្ទូលព្រះពុទ្ធ ។ ខ្មែរប្រើក្លាយមក ហៅដោយគោរពថា បព្វជិតនិយាយស្ដីតែពាក្យពិតតាមលំអានពុទ្ធវចនៈប្រយ័ត្នមិនហ៊ានឱ្យល្មៀង ។
- ពុរពង (គុ) : ដែលពងដោរឡើង សាច់ជោរជ្រាក ។
- ពៀរ (ន) : ចំណងចិត្តក្រោធ ដែលចងដោយព្យាបាទ បម្រុងនឹងសងសឹកវិញ ចំណងចិត្តជាសត្រូវ ចងពៀរ ស្រាយពៀរ មនុស្សមានពៀរ ។
- ពេជ្ឈឃាដ ឬពេជ្ឈឃាត [ ពេច ឈៈ÷ ] (ន) : អ្នកពិឃាតមនុស្សទោស គឺអ្នកដែលរាជការ តាំងឱ្យសម្លាប់មនុស្សដែលមានទោសគួរដល់ប្រហារជីវិត ។
- ពោធិសត្វ (ន)(បា. សំ) : អ្នកដែលកំពុងខំប្រឹងប្រែងបំពេញបារមី ។
- ព្រេងព្រឹទ្ធ (គុ) : ចាស់ពីព្រេងនាយ ។
- ព្រមាន (កិ) : ប្រាប់រំលឹកឱ្យដំណឹងជាមុន ។
- ព្រាហ្មណ៍ [ ព្រាម ] (ន) : មនុស្សដែលកំណត់តាមលទ្ធិបុរាណពីព្រេងនាយថា មានពូជដើម កើតអំពីព្រះឱស្ឋព្រហ្ម ពួកព្រាហ្មណ៍ ជាតិព្រាហ្មណ៍ ពូជព្រាហ្មណ៍ បើស្ត្រីជាព្រាហ្មណី ។ ក្នុង កម្ពុជាប្រទេសកំណត់យកពួកបារគូ បុរោហិតហៅថា ព្រាហ្មណ៍ ។ ខាងលទ្ធិពុទ្ធសាសនាហៅថា ព្រះអរហន្ត ថាព្រាហ្មណ៍សំដៅសេចក្ដីថា អ្នកបន្សាត់បាប ឬកម្ចាត់កិលេសអស់ហើយ ព្រោះ ព្រះអរហន្តលោកកម្ចាត់កិលេសជ្រះស្រឡះអស់ដោយអរហត្តមគ្គហើយ ។
- ព្រះរាជឱង្ការ (ន)(រ. ស) : ព្រះរាជតម្រាស់នៃព្រះមហាក្សត្រ ។ ពាក្យត្រាស់បង្គាប់នៃព្រះ មហាក្សត្រ ។
- ព្រះសវនីយ៍ (ន)(បា. សំ) : ព្រះបន្ទូលព្រះវររាជជនី ឬសម្ដេចព្រះអគ្គមហេសី ។
- ព្រះឧសុភរាជ (ន) : ស្ដេចគោ ។ ឧ : ពេលច្រត់ព្រះនង្គ័ល គេតែងប្រើគោឧសុភរាជ ។
- ព្យាបាទ [ ព្យា បាត ] (ន) (បា) : ដំណើរចងចិត្តនឹងធ្វើអ្នកដទៃឱ្យវិនាស សេចក្ដីគុំគួនគំនុំ ។

- ព្យួរក (កិ) : សម្លាប់មនុស្សដោយយកខ្សែទាក់ត្រង់ក ហើយចងបន្តោក បន្តោងទៅលើ ។
- ព្រហ្មវិហារ [ ព្រះ ហ្មះ ឬព្រំមះ ] (ន) (បា) : ធម៌ជាទីនៅនៃព្រហ្ម ។ ធម៌ជាលំនៅនៃចិត្តដ៏ប្រសើរមានមេត្តា ករុណា មុទិតា និងឧបេក្ខា ។
- ព្រានព្រៃ (ន) : អ្នកត្រាច់ទៅក្នុងព្រៃ (ពនេចរ) ។
- ព្រេច ១ (ន) : ឈ្មោះឫស្សីមួយពួក ដើមតូចៗ ស្លឹកល្អិតៗ ច្រើនដុះតាមដងព្រៃ ។
- ព្រេច ២ (កិ) : ពារនឹងក្បាល ជាន់នឹងជើង ចាក់នឹងភ្លុក ដោយពេញកម្លាំង (ប្រើចំពោះតែដំរី ) ។
- ព្រៃស្បាត (ន) : ព្រៃដែលមានប៉ែកខាងក្រោមញឹកជិតទ្រុបទ្រុល ។
- ព្រះសព្វញ្ញូ [ -សប់ ព័ញ ញូ ] (ន) : លោកអ្នកត្រាស់ដឹងសព្វ (ព្រះពុទ្ធ) ។
- ព្រះរាជសុណិសា(ន)(រ.ស) : ព្រះរាជបុត្រីប្រសា ។
- ព្រះសសុរៈ (ន)(រ.ស) : ព្រះបិតាក្មេក ។
- ពិលាប (ន)(រ.ស) : សេចក្ដីខ្សឹកខ្សួលរៀបរាប់ ។
- ព្រះហស្ដករ (ន)(បា.សំ) : ដៃ ។
- ព្រះភូវនាថ (ន)(បា.សំ) : ម្ចាស់ផែនដី ។
- ព្រះឥស្វរ (ន)(សំ.ក្ល) : ម្ចាស់ផែនដី ។
- ព្រះចេស្ដា (ន)(សំ.ក្ល) : ព្រះជាចម្បង ព្រះអង្គ ។
- ព្រះភូធរ (ន) : អ្នកទ្រទ្រង់ផែនដី (ព្រះរាជា) ។
- ព្រះអនុជក្សត្រី (ន) : ប្អូនស្រី ។
- ព្រះភូបាល (ន)(បា.សំ) : ព្រះម្ចាស់ផែនដី ។
- ព្រៀង (ន) : ព្រៀងលាន មានន័យថា អ្នកដទៃ អ្នកកន្ទៀត ដែលនៅភូមិជាមួយគ្នារាប់អានគ្នាទុកស្មើញាតិសន្ដាន ។
- ព្រះកន្សែងពិលាប(កិ)(រ.ស) : យំបួរបាច់ យំខ្សឹកខ្សួល ។
- ព្រះភូមី (ន) : ព្រះរាជា ។
- ព្រះឱស្ឋ (ន)(សំ) : មាត់ ។
- ព្រឹក្សាករ (គុ) : ពពួកដើមឈើ (ដើមឈើ) ។

(ភ)

- ភពត្រ័យ (ត្រៃ) [ ភប់- ] (ន) : ទីសម្រាប់សព្វសត្វកើតស្លាប់ទាំងបី គឺកាមភព រូបភាព អរូបភព (តាមទស្សនៈព្រះពុទ្ធសាសនា)។
- ភគវា (ន) : អ្នកមានជោគ អ្នកមានវាសនា។
- ភរិយាបរិច្ចាគ (ន) : ការលះបង់ប្រពន្ធជាទាន។
- ភក្តីភាព (ន) : សេចក្តីស្រលាញ់ស្មោះ សេចក្តីស្លូតត្រង់ សេចក្តីគោរព សេចក្តីរាប់អាន។
- ភាជន៍មាស (ន) : ប្រដាប់សម្រាប់ដាក់ភោជនាហារធ្វើអំពីមាស។
- ភាវនា (ន ឬ កិ) : ការរឹកចម្រើន ស៊ឹងស្មាធិ៍ ឬរំពឹង ស៊ឹងស្មាធិ៍ ស្មារតីសូត្រធម៌។
- ភុជង្គនាគរាជ (ន)(បា. សំ) : ស្តេចភុជង្គនាគ។
- ភុជង្គនាគ (ន)(បា. សំ) : ពស់ នាគ។
- ភូធរ (ន) : អ្នកទ្រទ្រង់នូវផែនដី ម្ចាស់ផែនដី (រាជា)។
- ភើចគះ (កិ) : ទាត់ផាត់ចេញ ឬចាប់ទាញចេញឱ្យមកដោយឡែកពីគ្នា។
- ភោជនាហារ (ន) : អាហារសម្រាប់បរិភោគ។
- ភោជនា (ន) : ចំណីអាហារ។
- ភ័យវេរា (ន) : ភ័យដែលកើតពីចំណងចិត្តព្យាបាទភ័យដែលកើតពីការចងពៀរ។
- ភ័ស្តុផល (ន) : ផលជាសំអាង។

(ម)

- មហិទ្ធិឫទ្ធិ (គុ) : មានឫទ្ធិអំណាចច្រើន។
- មហាធិបតិន្ទ [ មហា ធិប ដិន] (គុ) : ជាធំលើមហាធិបតី។
- មនោរម្យ (គុ) : ដែលជាទីរីករាយចិត្ត សប្បាយចិត្ត។
- មហាសាគរ (ន) : សមុទ្រធំល្វឹងល្វើយ។
- មនសិការ (ន) : ដំណើរយកចិត្តទុកដាក់។
- មហេសី (ន) : ឋានន្តរថ្នាក់ខ្ពស់សម្រាប់ព្រះរាជទេពីដែលក្សត្រទ្រង់រាជ្យបានប្រោសព្រះរាជទានអភិសេក ឬដែលបានអភិសេកជាមួយនឹងព្រះរាជា។
- មកុដអប្សរា (ន) : ក្រដាស ឬសំពត់រចនាវិចិត្របិទមាសដាំកញ្ចក់សម្រាប់ប្រើក្នុងការសម្តែងល្ខោន ឬរបាំ។

- មគ្គុទ្ទេសក៍នគរ (ន) : ឈ្មោះសៀវភៅ ឬទស្សនាវដ្ដីមួយដែលចង្អុលពីទីតាំងសំខាន់ៗនៃសំណង់បុរាណ ដើម្បីជួយបង្ហាញផ្លូវនៃពួកទេសចរ ។
- មហាហិង្គុ [ មៈហាហឹង ] (ន) : ឈ្មោះជ័រស្លមួយប្រភេទ មាន ក្លិនស្អុយ ឆួលហឹរក្ដៅភាយ សម្រាប់ប្រើផ្សំជាគ្រឿងឱសថ ។
- មន្តអាគម (ន) : របៀន ឬមន្តគាថាសម្រាប់សូត្រសែក ឬស្ដោះផ្លុំ ។
- មច្ចុរាជ (ន) : ស្ដេចនៃសេចក្ដីស្លាប់ ។
- មនុស្សសាស្ត្រវិទ្យា(ន) : ក្បួនវិជ្ជាដែលសិក្សាអំពីមនុស្ស ។
- មាល្បាយ (គុកិ) : ក្រៃ ក្រៃពេក ណាស់ អម្បាយ ។
- មាតុច្ឆា (ន) : ម្ដាយមីង ។
- មាគ៌ា (ន) : ផ្លូវ មធ្យោបាយ ។
- មឹង (បុ.ស) (ល.ស) : ចៅ ឯង ។
- មុសា (គុ ឬ គុ.កិ) : ដែលកុហកមិនពិត ខុសទទេ ។
- មូលមាត់គ្នា (កិ) : និយាយត្រូវគ្នា និយាយដូចៗគ្នា ។
- មេកន្ទ្រាញ [ -កន់-ទ្រាញ ] (ន) : មេត្រួតក្នុងស្រុកពួង ។
- មោហ៍បាំង (ន) : ងងឹតវឹងស៊ុង ភ្លេចស្មារតីពុំយល់ការខុសត្រូវបណ្ដាលឱ្យធ្វើអំពើអាក្រក់ឥតញញើត ។
- ម្រឹគ (ន) : សត្វចតុបាទព្រៃ ។

## (យ)

- យញ្ញ [ យ៉ាញ់ ] (ន) : ការបូជា (ពិធីក្នុងសាសនាព្រាហ្មណ៍) ។
- យមរាជ (ន)(បា.សំ) : ស្ដេចត្រួតត្រាឋាននរក ។
- យក្ខិនី ឬយក្សិណី [ យ័ក-ខនី ឬយ័ក-ក្សិណី ] (ន) : ស្រីយក្ស យក្សស្រី ។
- យាបនមត្ត (ន) : ស្បៀងសម្រាប់ចិញ្ចឹមជីវិត ។
- យុទ្ធភណ្ឌ [ យុត-ធ-ភ័ន ] (ន) : ប្រដាប់សម្រាប់សង្គ្រាម គ្រឿងចម្បាំង ។
- យោជន៍ (ន) : ឈ្មោះរង្វាស់បុរាណ (៧ហត្ថ) ។
- យោនយកកំណើត (កិ) : ចាប់ជាតិ ។
- យោបំ (ន) : សូររំពងសំឡេង យំខ្លាំង ។
- យ៉ាប់យ៉ឺន (គុ) : ដែលទ្រុឌទ្រោម ដែលដុនដាបត្រដាបត្រដួស ដែលលំបាកខ្លាំង ។

## (រ)

- រងោករងួយ (គុ) : ដែលមើលទៅឃើញច្រើនមីរត្រៀប ។
- រឱស្ឋាន [ រះ-អោស-ស្ថាន ] (ន) : សេចក្ដីហ្មងឆ្គង ឬមោះហ្មង មោះមៃដែលនាំឱ្យក្ដៅក្រហាយ ស្អុះស្អាប់ បែកចិត្តគំនិតគ្នា ឬបែកឃ្លាតចាកទី ចាកលំនៅ ។
- រតន៍កុញ្ជរ (ន) : ឈ្មោះដំរីរតន៍កញ្ជរ ។
- របាក្សត្រ (ន) : ពង្សាវតារក្សត្រក្នុងប្រទេសនីមួយៗតៗមក ។
- រជយ (កិ.វិ) : ដែលដើរតៗគ្នាតាមលំដាប់លំដោយ ។ ឧ. ដើររជយ ។
- រមណីយដ្ឋាន (បា.សំ) (ន) : កន្លែងដែលគួរឱ្យរីករាយត្រេកអរសប្បាយចាប់ចិត្ត ។
- រាជបពិត (ន)(បា.សំ) : ឈ្មោះភ្នំរាជបពិត ។
- រីស្សា ឬ ឫស្សា (កិ) : ច្រណែន ឈ្នានីស ។
- រិទ្ធិសាយ (គុ)(បា.សំ) : រិទ្ធិដ៏ល្បីរន្ទឺ ។
- រិទ្ធិ (សំ)(ន) : អំណាច ។
- រិទ្ធាសោតសល់ (ន) : រិទ្ធិអំណាចខ្លាំងក្លា ។
- ឫសីសិទ្ធិ (ន) : ការសម្រេចរបស់ឫសី ។
- រូ រូហាន (ធ្ន) : ដូច ដូចជា បីដូច ស្មើនឹង ។
- រោទិ៍រត់គង្គាន (កិ) : ស្រែករត់ចូលឥតញញើត ។
- រ័តន៍ (ន) : កែវ ឬរបស់មានតម្លៃ ។
- រ៉េស៊ីដង់ (ន)(បារ) : អ្នកតំណាង ។

## (ល)

- លន្តែ (ន) : ឈ្មោះឈើតូចមួយប្រភេទមានផ្កាក្រអូប ។
- លទ្ធភាព (ន) : ភាពដែលនឹងត្រូវមានផ្លូវ ឬដំណើរទំនងដែលនឹងអាចធ្វើឱ្យកើតការ ។ ភាពអាចធ្វើបាន ។
- លាមក (គុ)(បា) : អាក្រក់ ពុំប្រសើរ ។
- លេណដ្ឋាន (ន)(បា) : រូងភ្នំ ទីសម្រាប់ពួន ។
- លែបខាយ (គុ ឬ កិ.វិ) : ដែលចេញម៉េតប្រាយ ។
- លំហាកាស (ន) : ទីកន្លែងល្ហល្ហេវ វាលល្វឹងល្វើយ ។

## (វ)

- វណ្ណៈ (ន)(បា) : ថ្នាក់វង្ស ពូជពង្សរបស់មនុស្ស ។
- វដ្តសង្សារ (ន)(បា. សំ) : ដំណើរអន្ទោលវិលកើតវិលស្លាប់ ។
- វន្ទា (កិ) : ថ្វាយបង្គំ សំពះ គំនាប់ ។
- វាសនា (ន) : សំណាង ព្រេងសំណាង ភ័ព្វព្រេងបុណ្យភ័ព្វ ។
- វិមាន (ន) : ប្រាសាទ ដំណាក់ លំនៅល្អវិសេស ។
- វិញ្ញាណក្ខន្ធ [ វិញ-ញា-ណ័ក-ខ័ន ] (ន) : កងវិញ្ញាណ (ពួកចិត្ត) ដែលរាប់បញ្ចូលក្នុងខន្ធប្រាំ ។
- វិចារណញ្ញាណ (ន) : ញាណ ឬប្រាជ្ញាគ្រឿងត្រិះរិះរាវរកហេតុផលឱ្យឃើញច្បាស់ ឬឱ្យស្គាល់ខុសត្រូវ ។
- វិតក្ក (ន)(បា. សំ) : សេចក្តីត្រិះរិះ រំពឹងគិត ។
- វិទ្យុសកម្ម (ន) : ចំហាយដែលភាយចេញ ពីស្នូលអាតូម ហើយនៅក្នុងចំហាយនោះមានកាំរស្មីអគ្គិសនី ដែលអាចឱ្យមានជំងឺមហារីក ។
- វេទ [ វេ-ទៈ ឬ វេត ] (ន) : សេចក្តីដឹង វិជ្ជា ចំណេះ ។ គម្ពីរសម្តែងបែបរបៀបផ្សេងៗខាងសាសនាព្រាហ្មណ៍ ក្នុងសម័យដើមមានត្រឹមតែបីយ៉ាងគឺ ១-ឫគ្វេទ ឬ ឥរុវេទ មានដំណើរសេចក្តីជាពាក្យឆន្ទសម្រាប់សូត្រសរសើរពួកទេវតា, ២-យជុវេទ ឬ យជ្ជុវេទ មានដំណើរសេចក្តីជាពាក្យរាយរណ្តំ សម្រាប់សូត្របូជា ឬ បួងសួង, ៣-សាមវេទ មានដំណើរសេចក្តីជាពាក្យឆន្ទសម្រាប់សូត្រក្នុងពិធីថ្វាយទឹកសោម ។ វេទទាំងបីនេះសុទ្ធតែប្រើភាសាសំស្ក្រឹតហៅដោយរួបរួមថា វេទត្រ័យ ឬត្រ័យវិទ្យា ឬក៏ត្រៃវេទ ។
- វោហារ (ន) : ពាក្យ ពាក្យពេចន៍ សំនួនសម្តី ។

## (ស)

- សម្ពហភាព [ សៈ-ម្ពហៈ- ] (ន) (បា. សំ) : ភាពរួបរួម ។
- សម្ផស្ស [ ស័ម-ផ័ស សៈ ឬសំផស់ ] (ន) (បា) : ការប៉ះប្រសព្វជួបគ្នានៃអាយតនៈខាងក្នុងនិងអាយតនៈខាងក្រៅក៏កើតសេចក្តីដឹងឡើង ដូចយ៉ាងភ្នែក ឃើញជារូបជាដើម ។
- សរណគមន៍ (ន) : ការដល់នូវទីពឹង (ការយកអ្វីមួយជាទីពឹង) ។
- សតវត្ស ឬសតវត្សរ៍ [ សៈត-វ័ត ] (ន) : ឆ្នាំមួយរយ កាលកំណត់មួយជុំរយឆ្នាំ ឬមួយខួបរយឆ្នាំ ។

- សព្វាវុធ (ន)(បា) : អាវុធគ្រប់បែប គ្រឿងចម្បាំងគ្រប់បែបយ៉ាង ។
- សាក (កិ) : ល្បងមើលឱ្យដឹង ពិសោធមើល ។
- សាមណេរ [ -ម៉ះណេរ ឬ-ណែ ] (ន) (បា) : បព្វជិតពុទ្ធសាសនិក អ្នកកាន់សីលដប់ ... (លោកនេន) ។
- សាស្ត្រា [ សាល-ស្ត្រា ] (ន) : សាស្ត្រាទេសន៍ សាស្ត្រាល្បែង ។
- សាស្ត្រ [ សាល ](ន) : គម្ពីរ គម្ពីរប្រាប់វិទ្យា គម្ពីរសាសនា ច្បាប់ ច្បាប់ប្រដៅក្បួនតម្រា ។
- សិលាចារឹក ឬសិលាលេខ (ន) : អក្សរថ្ម (អក្សរដែលចារនៅលើផ្ទាំងថ្ម) ។
- សីតុណ្ហភាព (ន) : ភាពនៃបរិយាកាសត្រជាក់និងក្តៅ ។
- សំឡេងគង (ន) : សំឡេងគ្រលររបស់យុវជន ពេញវ័យ ។
- ស្មមយាចក (ន) : អ្នកសូមទាន ។
- សប្បុរស (គុ) : ល្អ ប្រសើរ ត្រឹមត្រូវ ។
- សព៌ាង្គកាយ (ន) : រូបកាយទាំងមូល ។
- សត្តសតកមហាទាន (ន) : ទានដ៏ធំអស្ចារ្យមានក្នុងមួយមុខៗ ៧០០ ។
- សម្មតិកម្ម (ន) : គំនិត ឬមតិដែលគេលើកឡើងទុកជាគោលជាការអះអាងសម្រាប់ពន្យល់ហេតុការណ៍ផ្សេងៗ ។
- សរសត្តី (ន)(បា. សំ) : ព្រួញខ្លាំងពូកែ ។
- សព្ទ (ន)(សំ) : សូរសំឡេង ។
- សព្ទសូម៉ែ (ន) : សំដីមិនគួរគប្បី ពាក្យទ្រគោះ ឬមើលងាយ ។
- សដា (ន)(បា. សំ) : ព្រៃព្រឹក្សា ព្រៃស្មាច់ ។
- សហារ ឬសាហារ (គុ) (បា. សំ) : ដែលកាច ដែលច្រណែន ដែលឆាប់ខឹង ។
- សម្តេចភូមី (ន) : សម្តេចផែនដីព្រះរាជា ។
- សយនា (ន)(បា. សំ) : ទីកន្លែងសម្រាប់ដេក ។
- សម័យបុរេប្រវត្តិសាស្ត្រ (ន) : សម័យកាលមុន ប្រវត្តិសាស្ត្រអាចកត់ត្រាបាន ។
- សហាគមន៍ (ន) : ប្រជុំភូមិ ឬតំបន់អ្នកស្រុក ប្រកបមុខរបរចូលគ្នា ។
- សក្តានុភាពអគ្គិសនី (បា) : អំណាចដ៏ខ្ពស់នៃអគ្គិសនី ។
- សន្ទិះ (ន)(បា. សំ) : សេចក្តីសង្ស័យ ។
- សង្កា (ន)(បា. សំ) : សេចក្តីសង្ស័យ សេចក្តីខ្លាចក្រែង ការប្រុងប្រយ័ត្ន ។

- សមាទាន (ន) : ការកាន់ដោយប្រពៃ ការទទួលកាន់តាម ។
- សាត់ព្រាត់ (កិ) : ចេញចោលស្រុកទេស ខ្ចាត់ខ្ចាយព្រាត់បងប្អូនញាតិមិត្ត ។
- សព្វញ្ញុតាញាណ (បា.សំ) : ញាណ ឬប្រាជ្ញា ដែលដឹងសព្វ ។
- សារថី (ន)(បា.សំ) : អ្នកបររថ អ្នកបង្ហាត់សេះ ។
- សិល្បសាស្ត្រ (ន) : ក្បួនរៀនសិល្បៈ ចំណេះជាង ។
- សិរិកា (ន)(បា.សំ) : ត្រែស្នែង ។
- សុពណ៌បាទ (ន)(រ.ស) : ទ្រនាប់ជើងមាស ។
- សុភមង្គល (ន) : មង្គលល្អ គ្រោះល្អ ។
- សុន្ទរកថា (ន) : ពាក្យសំដីសូត្រថ្លែងសេចក្ដី ។
- សុក្រឹតភាព (ន) : ភាពល្អឥតខ្ចោះ ។
- សុរភី (ន) : ឈ្មោះឈើមួយប្រភេទផ្កាល្អិតៗចេញពីមែកក្លិនក្រអូបឆ្ងាញ់ ។
- សូរេច (កិ) : ស្រេច ចង់ស្រេច ចប់បរិបូរ ។
- សូរសៀង (គុ) : សំឡេងក្លៀវក្លា ។
- សូក្ត (ន) : ឈ្មោះកាព្យនៅក្នុងគម្ពីរវេទ ។ ឧទាហរណ៍ : ១សូក្ត ស្មើ ៥៨គាថា ។
- សើ (ន) : ស្រទាប់ ។
- សំឡេះ (កិ) : សម្លាប់ ។
- សម្ពាធឈាម (ន)(បា.សំ) : បារ៉ាម៉ែតនៃប្រព័ន្ធឈាមរត់ ។ ការផ្លាស់ប្ដូរសម្ពាធអាចបញ្ជាក់ពីរោគសញ្ញាជំងឺផ្សេងៗ ។
- សេនាជន [ សេ-ន៉ា-ជន ] (ន) : អ្នកដែលមានតួនាទីការពារមូលដ្ឋាន ។
- សេនាបតី [ -ប៉ះដី ] (ន) (សំ) : ចៅហ្វាយសេនាគឺ មហាមាត្យ មន្ត្រីស័ក្តិធំទីចតុស្តម្ភ ។
- ស្តម្ភទ្វារ (ន) : ទ្វារនៃសសរ ទ្វារក្បែរសសរ ។
- ស្ថានភាព (ន) : បែបបទ ហេតុភេទដែលប្រព្រឹត្តទៅ ។
- ស្ទឹងស្ទាធី (កិ) : ភាវនារំពឹងក្នុងចិត្តឥតកម្រើក ។
- ស្រែកសំនៀរ (កិ) : ស្រែកបន្លឺសំឡេងខ្លាំង ។
- ស័ង្ខ (ន) : ឈ្មោះខ្យងសមុទ្រមួយបែប ។
- សោយ (កិ) : ទទួលរងអារម្មណ៍ជាសុខ ឬជាទុក្ខ ។
- សោយរាជ្យ [ -រាច ] (ន) : បានឡើងជាក្សត្រិយ៍ទ្រង់រាជ្យ ។
- ស្រីស្រិង្គារ (ន) : ស្រីដែលមានលំអគួរឱ្យកើតសេចក្ដីស្រលាញ់ ស្រីស្អំ ។

- ស្ថិតិ (សំ) : ចំនួនដែលគេកត់ត្រាក្នុងបញ្ជី ។
- ស្មៀនស្មេរ (ន) : អ្នកសរសេរ អ្នកជំនួយការ ។
- ស្វេតច្ឆត្រ (ន) : មានន័យថា ឆត្រស ក្នុងទីនេះ សំដៅទៅលើរាជសម្បត្តិ ។
- ស្រឹង្គារ (ន)(បា.សំ) : សេចក្ដីស្រលាញ់ គ្រឿងប្រលោមចិត្ត ។
- ស្រពេចស្រពិល (គុ ឬ កិ) : ដែលមិនជាក់លាក់ មិនប្រាកដ ។
- សោកា (ន)(បា.សំ) : សេចក្ដីឈឺផ្សាចិត្ត ។
- សម្រន់ (កិ) : ធ្វើឱ្យស្រន់ គឺគ្រាន់តែទប់ទល់ឱ្យអន់សិន ។
- ស្មុង (កិ.វិ) : ដែលឃើញទទុង ព្រិលៗមិនច្បាស់ ។
- ស្នា (ន) : អាវុធមួយប្រភេទ ធ្វើដោយឈើ មានត្រពង មានដៃ មានខ្សែបន្លោះ មានកែតម្លោះបាន មានព្រួញស្លាបសម្រាប់ដាក់ផ្ដាប់យឹតបាញ់ ។
- ស្រូវភោជ្ជសាលី (ន)(បា.សំ) : ឈ្មោះស្រូវវិសេសមួយពួក ស្រូវខ្សាយ ។

(ហ)

- ហាយនភាព [ -យនៈ- ] (ន)(សំ) : ភាវៈ ឬដំណើរនៃសេចក្ដីវិនាស ។
- ហៀវហោះលីលា(ន) : ដំណើរហោះលឿន ផ្លេកផ្លោះច្រៀវច្រៃ ។
- ហៅហាន (គុ) : មោះមុត ក្លាហានខ្លាំង ។
- ហោះផ្លេកផ្លោះ (កិ) : ហោះរំលង ។
- ហេតុការណ៍ (ន)(បា.សំ) : រឿងរ៉ាវ រឿងហេតុ ព្រឹត្តិការណ៍ ។

(ឡ)

- ឡ (ន) : គុក ឬជើងក្រានធំល្មមសម្រាប់ដុតឥដ្ឋជាដើម ។

(អ)

- អង្គការ [ អង់-កា ] (ន) (បា.សំ) : បែបផែនរបៀបរៀបចំកិច្ចការ ដែលរដ្ឋ ឬក្រុមរាជការណាមួយបង្កើតឡើង ដើម្បីប្រព្រឹត្តទៅកាន់សេចក្ដីចម្រើន ទីកន្លែងចាត់ការធំៗ ។
- អង្គរក្ស [ អង់-គៈរ៉ក ] (ន)(បា) : ទាហានរក្សាអង្គព្រះរាជាឬទាហានការពារ ទាហានរក្សា ។
- អន្ធការ [ អន់ធៈ- ] (គុ)(បា.សំ) : ងងឹត ។
- អភិជន [ អៈភិ-ជន ] (ន)(បា.សំ) : មនុស្សខ្ពង់ខ្ពស់ ។
- អវិចី ឬ អវីចី [ អៈវិ-ចី ] (ន)(សំ) : ឈ្មោះរណ្ដៅនរកធំមួយ ក្នុងពួកនរកធំទាំង៨រណ្ដៅ ។ នរកមានអណ្ដាតភ្លើងឥតស្រាក ។

- អត្ថានុរូប [ អាត់-ថា-នុ-រូប ] (ន) : ន័យស្រប ន័យចំ ន័យត្រង់ ។
- អត្ថប្បដិរូប [ អាត់-ថាប់-ប៉ាក់ដិរូប ] (ន) : ន័យធៀប ន័យប្រដូច ។
- អត្តសញ្ញាណជាតិ [ អ័ត-តៈស័ញ-ញ៉ាន ] (ន) : គ្រឿងសម្គាល់ជាតិខ្លួន សញ្ញាដែលអាចសម្គាល់បានថាព័ត៌មាននោះពិត ដែលសម្គាល់របស់ជាតិណាមួយ ។
- អសង្ខេយ្យ (គុ)(បា) : ដែលច្រើនរាប់ពុំអស់ ដែលរាប់ពុំបានប្រមាណពុំអស់ ។
- អត្ថិភាព (ន)(បា. សំ) : ភាពនៃអ្វីដែលមាន ។
- អនុស្សាវរីយ ឬរីយ៍ (ន)(បា. សំ) : ការដែលគួរ រលឹកនឹកឃើញ ។
- អតុល្យភាព (ន)(បា) : ភាពមិនស្មើគ្នា ។
- អយ្យកោ (ន)(បា) : ជីតា ។
- អយ្យកា (ន)(បា) : ជីដូន ។
- អធិដ្ឋាន (ន)(បា) : ការតាំងចិត្ត ការសំបូងសង្រួង ឬការសំបូងសង្រួងដោយចិត្តនឹក ។
- អលង្ការ (ន)(បា) : គ្រឿងប្រដាប់សំរាប់តាក់តែងខ្លួន ។
- អមរ (ន)(បា. សំ) : ទេវតា ។
- អកុសល (ន)(បា. សំ) : សេចក្តីអាក្រក់ បាប អពមង្គល ។
- អប្រិយ (គុ) : ដែលមិនជាទីស្រលាញ់ ពុំគួរស្រលាញ់ ។
- អន្ធពាល (គុ) : ល្ងង់ងងឹតសូន្យឈឹង ។
- អបលក្ខណ៍ (គុ) : ដែលប្រាសចាកលក្ខណៈល្អ ថោកទាប ។
- អង្គបរិច្ចាគ (ន) : ការលះបង់ភាគណាមួយនៃរាងកាយជាទាន ។
- អាគម [ អា-គម ] (ន) (បា. សំ) : ការរៀនសូត្រ សេចក្តីដឹង គម្ពីរ សាស្ត្រ ឬសាស្ត្រាពុទ្ធមន្តគាថាដែលរៀនចេះចាំតៗគ្នាមក របៀន ។
- អាចក្តី (បុ. ស) : ពាក្យជាបុរិសសព្វនាមសម្រាប់បព្វជិត ប្រើជាជំនួសឈ្មោះខ្លួននិយាយទៅកាន់គ្រហស្ថជាសាធារណជន ជាជំនួសពាក្យថា "អាត្មា" ។ មានន័យថា "ជាអ្នកដឹងសេចក្តីខុសត្រូវរាក់ជ្រៅបាន" ឬ "ជាអ្នកអាចដឹងកិច្ចការក្នុងក្តី គឺក្នុងវត្តអារាមបាន" ។
- អាណាព្យាបាល (ន) : អ្នកគ្រប់គ្រងរក្សាអាណាខេត្ត ឬការគ្រប់គ្រងរក្សាអាណាខេត្ត ។
- អាទិទេព (ន)(សំ) : ទេព្តាខាងដើម ទេព្តាមុនបង្អស់ ។

- អាស្រូវភាស (គុ)(សំ) : ដែលគេចេះតែនិយាយតៗគ្នា ឮសុសសព្ទអំពីកេរ្តិ៍ឈ្មោះសៅហ្មង ។
- អាសនៈ (ន)(បា) : ទីអង្គុយ កន្លែងអង្គុយ កន្លែង ឬប្រដាប់សម្រាប់អង្គុយ ។
- អាស្រូវស្ថាន (ន) : កន្លែងដែលសេចក្ដីឮសុសសាយថាមិនល្អ កន្លែងដែលមានកេរ្តិ៍ឈ្មោះសៅហ្មង ។
- ឥស្សរជន (ន) : ជនជាចម្បង ជាធំ ជាកំពូលលើសគេ ។
- ឧទ្ទិស [ អ៊ុត-ទិស ] (កិ)(បា) : សំដៅទៅរក សំដៅចំពោះ ឆ្ពោះត្រង់ តម្រង់ទៅរកបម្រុងត្រង់ បម្រុងចំពោះ ធ្វើបម្រុង ឬដើម្បី ឧទ្ទិសសង្ឃចំពោះសង្ឃ ។
- ឧកញ៉ា (ន) : ពាក្យប្រើជាឋានន្តរសក្តិនៃមន្ត្រីថ្នាក់ខ្ពស់ជាងទីព្រះ សំដៅសេចក្ដីថា "អ្នកចេះត្រួតត្រាមុខការក្នុងក្រសួង ឬនាទីរបស់ខ្លួន" ។
- ឧបជ្ឈា ឬឧបជ្ឈាយ៍ (ន)(បា.សំ) : គ្រូបង្រៀនធម៌ ឬគ្រូបង្រៀនច្បាប់ គ្រូបាធ្យាយ ។
- ឧបសគ្គ (ន)(បា) : ឧបទ្រពចង្រៃ គ្រឿងទើសទាត់ គ្រឿងរាំងរាដំណើរ ។
- ឧបាយកល [ អ៊ុ- ] (ន)(បា.សំ) : ល្បិចល្បួងយ៉ាងល្អិត ឧបាយបញ្ឆោត ក្រឡិចក្រលៀត ។
- ឧត្តមភាព (ន)(បា.សំ) : ភាពខ្ពង់ខ្ពស់ ភាពប្រសើរថ្លៃថ្លា ។
- ឧគ្ឃោសនសព្ទ (ន) : គ្រឿងបំពងសំឡេង មេក្រូ ។
- អេកូឡូស៊ី (ន)(បា.រ) : វិទ្យាសាស្ត្រដែលសិក្សាអំពីទំនាក់ទំនងរវាងមនុស្សនិង-បរិស្ថាន ។
- ឱវាទ [ អោ-វ៉ាត ] (ន) : ដំបូន្មាន អនុសាសន៍ ។
- ឱឡារិក (គុ) : ធំដុំ យ៉ាងធំ ហ៊ឹកហ៊ាក់ ។
- អ្នកម្នាង (ន) : ឋានន្តរសម្រាប់ស្រីព្រះស្នំ ព្រះម្នាង ... ។

**យើងបម្រើសេវាកម្ម :**

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

**WE SERVE :**

- book and teaching-aid development
- printing
- distribution to schools


គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ( គ.ប.ច )

PUBLISHING AND DISTRIBUTION HOUSE ( PDH )

# បណ្ណាគារ គ.ប.ច

# PDH BOOKSHOP

១៤៨ មហាវិថីព្រះនរោត្តម ភ្នំពេញ ទូរស័ព្ទ: ០២៣ ៦៣ ៦៣ ០៣៣ 148, Norodom Boulevard, Phnom Penh, Tel: 023 63 63 033


**មានលក់ :**

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

**SELLING :**

textbooks , teacher's manuals , workbooks , supplementary readers , teaching-aids and stationary !


IBC INTERNATIONAL BOOK CENTER
$ 3.20



9 789995 000998